# ការធ្វើការងារជាមួយ
# កម្មវិធី
# សិទ្ធិមនុស្ស
# អង្គការសហប្រជាជាតិ

## សៀវភៅសម្រាប់សង្គមស៊ីវិល

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
*កម្ពុជា*

ចែកជូនដោយឥតគិតថ្លៃ

# ការធ្វើការខារជាមួយ
# កម្មវិធី
# សិទ្ធិមនុស្ស
# អង្គការសហប្រជាជាតិ

## សៀវភៅ
## សម្រាប់សង្គមស៊ីវិល

ទីក្រុងញូវយក និងទីក្រុងហ្សឺណែវ ឆ្នាំ២០០៨

## សិទ្ធិមនុស្ស
## អង្គការសហប្រជាជាតិ

**ការិយាល័យឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្ស**

*នាមកត្តាដែលត្រូវបានប្រើប្រាស់ និងការបង្ហាញសម្ភារៈឯកសារនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនថ្លែងបង្កប់អំពីការសម្តែងទោះជាមតិណាមួយក៏ដោយ ដែលត្រូវបានធ្វើឡើងដោយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់របស់ប្រទេស ទឹកដី ទីក្រុង ឬ តំបន់ណាមួយ ឬ របស់អាជ្ញាធរនៃប្រទេស ទឹកដី ទីក្រុង ឬ តំបន់នោះ ឬ ពាក់ព័ន្ធនឹងការកំណត់កម្រិតព្រំដែន ឬ ព្រំដែនរបស់ប្រទេស ទឹកដី ទីក្រុង ឬ តំបន់នោះទេ ។*

HR/PUB/06/10/Rev. 1

**សៀវភៅនេះ ត្រូវបានផលិតឡើង ដោយមានជំនួយហិរញ្ញវត្ថុពីផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ។**

# បុព្វកថា

ការសរសេរបុព្វកថាសម្រាប់*សៀវភៅ*នេះ គឺជាសកម្មភាពដំបូងមួយក្នុងចំណោមសកម្មភាពដំបូងជាច្រើនទៀតរបស់ខ្ញុំជាឧត្តមស្នងការថ្មីទទួលបន្ទុកសិទ្ធិមនុស្ស ។ ខ្ញុំគិតថានេះជាការងារសមស្រប ។ វាផ្តល់ឲ្យខ្ញុំនូវឱកាសដំបូង ដើម្បីគូសបញ្ជាក់នៅក្នុងឋានៈថ្មីរបស់ខ្ញុំ នូវអ្វីជាជំនឿដែលត្រូវបានកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នៅក្នុងអាជីពរបស់ខ្ញុំ ដែលនោះគឺជាទំនុកចិត្តរបស់ខ្ញុំលើសមត្ថភាពផ្លាស់ប្តូររបស់សង្គមស៊ីវិល ។ តាមការពិតគេមិនអាចមិនឲ្យតម្លៃខ្ពស់ទៅលើការរួមចំណែក ដែលសង្គមស៊ីវិលមាន នៅក្នុងការរៀបចំបង្កើតឲ្យមានស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ ការតស៊ូមតិរបស់សង្គមស៊ីវិល និងដំណើរការនៃយន្តការសិទ្ធិមនុស្ស ដែលត្រូវបានពិភាក្សានៅក្នុង*សៀវភៅ*នេះ ។ នៅពេលបច្ចុប្បន្ននេះ ទស្សនៈ ចំណេះដឹងជាក់ស្តែង និងចំណេះវិជ្ជារបស់សង្គមស៊ីវិល នៅតែមានសារៈសំខាន់ចំពោះចលនាសិទ្ធិមនុស្សជាដដែល នៅក្នុងការស្វែងរកយុត្តិធម៌ និងសមភាពសម្រាប់មនុស្សទាំងអស់គ្នា ។

តាមការពិត ការសហការរបស់ការិយាល័យខ្ញុំ ជាមួយសង្គមស៊ីវិល នៅតែជាអាទិភាពជាយុទ្ធសាស្ត្រមួយ ពីព្រោះវាគាំទ្រដល់ទិសដៅរួមរបស់យើង ជួយដោះស្រាយកង្វល់របស់យើងទៅវិញទៅមក និងគាំទ្របេសកកម្ម និងគំនិតផ្តួចផ្តើមរបស់ការិយាល័យខ្ញុំ ទាំងនៅទីស្នាក់ការកណ្តាល ទាំងនៅការិយាល័យប្រចាំប្រទេសនានា ។

ការរួមចំណែករបស់តួអង្គសង្គមស៊ីវិល ក៏បានធ្វើឲ្យមានខ្លឹមសារថែមទៀត ដល់ការងាររបស់អ្នកជំនាញឯករាជ្យដែលជារបស់យន្តការសិទ្ធិមនុស្សផ្សេងទៀតដែលមានប្រវត្តិដ៏យូរលង់ ដូចជា ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងនីតិវិធីពិសេស ។ ម្យ៉ាងវិញទៀត ទម្ងន់ និងចំណេះដឹងរបស់ពួកគេ ក៏ត្រូវបាននាំយកទៅអនុវត្តនៅក្នុងប្រតិបត្តិការ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័នអន្តររដ្ឋាភិបាលថ្មី ដែលនៅក្នុងខែមិថុនា ឆ្នាំ២០០៦ បានជំនួសគណៈកម្មការសិទ្ធិមនុស្ស ។

អ្នកការពារសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសង្គមស៊ីវិលផ្សេងទៀតទាំងអស់បំពេញការងារសិទ្ធិមនុស្សរបស់ខ្លួនតាមរបៀបមួយចំនួនខុសៗគ្នា ៖ ពួកគេចែករំលែកព័ត៌មាន តស៊ូមតិ និងពិនិត្យពិច័យលើការអនុវត្តសិទ្ធិមនុស្ស រាយការណ៍អំពីការរំលោភបំពាន ជួយជនរងគ្រោះដោយអំពើបំពារបំពាន និងធ្វើយុទ្ធនាការរៀបចំបង្កើតស្តង់ដាសិទ្ធិមនុស្សថ្មី ។ ពួកគេធ្វើដូច្នេះ តាមរយៈការពិនិត្យអារម្មណ៍របស់សហគមន៍ និងប្រជាជន ។ ពួកគេផ្តល់សម្លេងដល់អ្នកគ្មានអំណាចនៅគ្រប់ទិសទី ដែលបើពុំនោះទេអាចស្ថិតនៅឆ្ងាយផុតពីការទៅដល់របស់ជនរងគ្រោះ ក្នុងនោះរួមមាន វេទិកា និងយន្តការសិទ្ធិមនុស្សអន្តរជាតិ ។ ដោយច្បាស់ មានសេចក្តីត្រូវការក្នុងចំណែកផ្ទាល់ខ្លួនរបស់តួអង្គសង្គមស៊ីវិល ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅ និងម្ចាស់ការលើវិធីសាស្ត្រធ្វើការងាររបស់ស្ថាប័នសិទ្ធិមនុស្សជាតិ តំបន់ និងអន្តរជាតិ ។ *សៀវភៅ*នេះ មានគោលបំណងសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាមួយបែបនេះ ។

នៅទីបញ្ចប់ អនុញ្ញាតឲ្យខ្ញុំគូសបញ្ជាក់ថា ការចេញផ្សាយ*សៀវភៅ*នេះ គឺគាប់ជួននឹងទិវាខួប លើកទី៦០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។ ការសន្យាផ្នែកយុត្តិធម៌ សេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សសម្រាប់មនុស្សទាំងអស់ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ នៅមិនទាន់បំពេញបានពេញលេញនៅឡើយទេ ។

យើងត្រូវតែខិតខំព្យាយាម ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការធ្វើឲ្យគោលការណ៍នៃសេចក្តីប្រកាសជាសកល សម្រេចបំណងប្រាថ្នារបស់សហគមន៍ខុសៗគ្នាដែលយើងបានបម្រើ ។ វាជាក្តីសង្ឃឹមរបស់ខ្ញុំថា *សៀវភៅ*នេះ នឹងត្រូវបានប្រើប្រាស់ដើម្បីសម្របសម្រួលការស្វែងយល់ និងលទ្ធភាពរបស់តួអង្គសង្គមស៊ីវិល ក្នុងការប្រើប្រាស់ប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។ វាជាធនធានមិនសូវច្រើនទេ ប៉ុន្តែមានសារៈសំខាន់ក្នុងការខំប្រឹងប្រែងរួមរបស់យើង ដើម្បីប្រែក្លាយសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងសមភាពទៅតថភាពពិតជាសកល ។

ហត្ថលេខា

**ណាវ៉ាណិថិម ភីឡៃ**
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# មាតិកា


ទំព័រ

បុព្វកថា ………………………………………………………………………… iii

ពាក្យសរសេរកាត់ និងពាក្យបំព្រួញ ……………………………………………… vi

សេចក្តីផ្តើម…………………………………………………………………… viii

I សេចក្តីផ្តើមអំពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOHCHR)……………………………………………… 11

II កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)…………………………………… 29

III អត្ថបទបោះពុម្ពផ្សាយ និងធនធានសម្ភារៈរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ………………………………… 42

IV ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ………………………………………… 50

V ក្រុមប្រឹក្សាសិទ្ធិមនុស្ស ………………………………………………… 103

VI យន្តការពិសេស ……………………………………………………………… 145

VII យន្តការត្រួតពិនិត្យមើលរបាយការណ៍ឡើងវិញតាមពេលកំណត់ជាសកល ………………… 185

VIII ការដាក់ពាក្យបណ្តឹងស្តីពីការរំលោភសិទ្ធិមនុស្ស……………………………… 210

IX មូលនិធិ និងជំនួយ…………………………………………………………… 237

# ពាក្យសរសេរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACT | គម្រោង "ទាំងអស់គ្នា រួមគ្នាជួយសហគមន៍" |
| CAT | អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប |
| CEDAW | អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ECOSOC | ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICERD | អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| ICESCR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ |
| ICRMW | អនុសញ្ញអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ |
| LDC | ប្រទេសអភិវឌ្ឍតិចបំផុត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NHRI | ស្ថាប័នជាតិសិទ្ធិមនុស្ស |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| OPCAT | ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប |
| UNDEF | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាធិបតេយ្យ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNITAR | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវរបស់អង្គការសហប្រជាជាតិ |
| UPR | យន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ |

# សេចក្តីផ្តើម

## អំពី *សៀវភៅ*នេះ

*ការធ្វើការងារជាមួយកម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ៖ សៀវភៅសម្រាប់សង្គមស៊ីវិល* ត្រូវបានផ្តោតលើតួអង្គសង្គមស៊ីវិលដែលរួមចំណែកដល់ការលើកកម្ពស់ កិច្ចការពារ និងការធ្វើឲ្យចម្រើនជឿនលឿនទៅមុខនូវ សិទ្ធិមនុស្ស រៀងរាល់ថ្ងៃ នៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក ។

ដែលត្រូវបានរៀបចំបង្កើតឡើង បន្ទាប់ពីមានការស្ទង់មតិ ក្នុងចំណោមអ្នកប្រើប្រាស់*សៀវភៅ*បោះពុម្ពផ្សាយលើកទីមួយ - *ការធ្វើការងារជាមួយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ៖ សៀវភៅសម្រាប់អង្គការមិនមែនរដ្ឋាភិបាល*(២០០៦) - សៀវភៅនៃការ បោះពុម្ពផ្សាយលើកទីពីរនេះ ត្រូវបានធ្វើបច្ចុប្បន្នភាព និងពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយ ដោយបានដាក់ស្ថាប័ន និងយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិឲ្យស្ថិតនៅជាចំណុចផ្តោតការយកចិត្តទុកដាក់ ។ និយាយចំពោះតួអង្គសង្គមស៊ីវិលទាំងអស់ ក្នុងនោះមានបញ្ចូល មិនចំពោះតែអង្គការមិនមែនរដ្ឋាភិបាល (NGO) ប៉ុណ្ណោះទេ *សៀវភៅនេះ* ពន្យល់អំពីរបៀបដែលសង្គមស៊ីវិលអាចចូលរួមធ្វើការជាមួយស្ថាប័ន និងយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។ វាជាក្តីសង្ឃឹមរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ថា *សៀវភៅ*នេះ នឹងជួយដល់មនុស្សកាន់តែច្រើនឡើងថែមទៀតឲ្យទទួលបានសិទ្ធិ និងធ្វើការទាមទារសិទ្ធិមនុស្សរបស់ខ្លួន តាមរយៈស្ថាប័ន និងយន្តការទាំងនេះ ។

## តើនរណាខ្លះ ជាតួអង្គសង្គមស៊ីវិល ?

សម្រាប់គោលបំណងនៃ*សៀវភៅ*នេះ តួអង្គសង្គមស៊ីវិល គឺជាបុគ្គលទាំងឡាយដែលចូលរួមធ្វើការដោយស្ម័គ្រចិត្ត ក្នុងរូបភាពជាសកម្មភាព និងការចូលរួមជាសាធារណៈ ជុំវិញផលប្រយោជន៍ គោលបំណង ឬតម្លៃរួម ស្របតាមគោលដៅរបស់អង្គការសហប្រជាជាតិ ។ *សៀវភៅ*នេះ ដោះស្រាយកង្វល់របស់តួអង្គសង្គមស៊ីវិលពាក់ព័ន្ធនឹងការលើកកម្ពស់ និង កិច្ចការពារសិទ្ធិមនុស្សជាសកល ឧទាហរណ៍:

- អ្នកការពារសិទ្ធិមនុស្ស ។
- អង្គការសិទ្ធិមនុស្ស (អង្គការមិនមែនរដ្ឋាភិបាល សមាគម ក្រុមជនរងគ្រោះ) ។
- អង្គការដែលធ្វើការលើបញ្ហាពាក់ព័ន្ធ ។
- សម្ព័ន្ធភាព និងបណ្តាញ (សិទ្ធិនារី សិទ្ធិកុមារ សិទ្ធិបរិស្ថាន) ។
- ជនពិការ និងអង្គការតំណាងរបស់ពួកគេ ។
- ក្រុមដែលមានមូលដ្ឋាននៅសហគមន៍ (ជនជាតិដើមភាគតិច ក្រុមជនភាគតិច) ។
- ក្រុមដែលមានមូលដ្ឋានលើជំនឿសាសនា (វិហារសាសនាគ្រឹះ ក្រុមសាសនា) ។
- សហជីព (សហជីពកម្មករ ព្រមទាំង សមាគមអ្នកវិជ្ជាជីវៈ ដូចជា សមាគមអ្នកសារព័ត៌មាន គណៈមេធាវី សមាគមអង្គចៅក្រម សហជីពនិស្សិត) ។
- ចលនាសង្គម (ចលនាសន្តិភាព ចលនានិស្សិត ចលនាគាំទ្រប្រជាធិបតេយ្យ) ។

- អ្នកវិជ្ជាជីវៈ ដែលរួមចំណែកដោយផ្ទាល់ក្នុងការទទួលបានសិទ្ធិមនុស្ស (បុគ្គលិកមនុស្សធម៌ អ្នកច្បាប់ វេជ្ជបណ្ឌិត និងបុគ្គលិកសុខាភិបាល) ។
- សាច់ញាតិរបស់ជនរងគ្រោះ និង
- ស្ថាប័នសាធារណៈដែលអនុវត្តសកម្មភាពទាំងឡាយ ដែលមានគោលបំណងលើកកម្ពស់សិទ្ធិមនុស្ស (សាលារៀន សកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវនានា) ។

សង្គមស៊ីវិលមួយដែលខ្លាំងនិងស្វយ័ត ដែលអាចដំណើរការបានដោយសេរី និងដែលមានចំណេះដឹង និងជំនាញសិទ្ធិមនុស្ស គឺជាកត្តាគន្លឹះក្នុងការធានាឲ្យមានកិច្ចការពារសិទ្ធិមនុស្សប្រកបដោយនិរន្តរភាពនៅថ្នាក់ជាតិ ។ ហេតុដូច្នេះ តួអង្គសង្គមស៊ីវិល គឺជាដៃគូដ៏សំខាន់ជាសារវន្តនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។

ទោះជាអ្នករួមចំណែកសំខាន់ៗ ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRI) មិនត្រូវបានលើកនិយាយក្នុង*សៀវភៅ*នេះក្តី ។ ក៏ព័ត៌មាន និងធនធានស្តីពីស្ថាប័នជាតិសិទ្ធិមនុស្ស (NHRI) ត្រូវបានដាក់នៅក្នុងវិបសាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ មិត្តអ្នកអាន ក៏ត្រូវបានអញ្ជើញឲ្យទាក់ទងមកអង្គភាពស្ថាប័នជាតិរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) តាមរយៈ **niu@ohchr.org** ។

## មាតិកានៃ*សៀវភៅ*

*សៀវភៅនេះ* ផ្តើមដោយសេចក្តីផ្តើមអំពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ជំពូកទី I) កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ជំពូកទី II) និងអត្ថបទបោះពុម្ពផ្សាយ និងសម្ភារៈធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ជំពូកទី III) ។ បន្ទាប់មក វាផ្តោតលើស្ថាប័ន និងយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងរបៀបដែលគេអាចត្រូវបានប្រើប្រាស់ ។ ទាំងនេះមាន:

- ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស (ជំពូកទី IV) ។
- ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការទាំងឡាយរបស់ក្រុមប្រឹក្សានេះ ក្នុងនោះរួមមាន គណៈកម្មាធិការប្រឹក្សាយោបល់ វេទិកាសង្គម វេទិកាស្តីពីបញ្ហាក្រុមជនភាគតិច យន្តការមន្ត្រីជំនាញសិទ្ធិជនជាតិដើមភាគតិច ក្រុមការងារមិនកំណត់ស្តីពីសិទ្ធិអភិវឌ្ឍ និងយន្តការមួយចំនួនទាក់ទងនឹងសេចក្តីប្រកាសទីក្រុងឌឺបែន និងកម្មវិធីសកម្មភាព (ជំពូកទី V) ។
- នីតិវិធីពិសេស (ជំពូកទី VI) ។
- យន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (ជំពូកទី VII) និង
- ការបញ្ជូនបណ្តឹងចោទប្រកាន់ពីការរំលោភបំពានសិទ្ធិមនុស្ស (ជំពូកទី VIII) ។

ជំពូកចុងក្រោយ ផ្ដល់នូវព័ត៌មានស្ដីពីមូលនិធិ និងជំនួយ (ជំពូកទី IX) ដែលមូលនិធិ និងជំនួយខ្លះត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)។

ដើម្បីឲ្យមិត្តអ្នកអានកាន់តែងាយស្រួលថែមទៀត ក្នុងការទទួលបានព័ត៌មាន ជំពូកនីមួយៗត្រូវបានសរសេរតាមរបៀបមួយ ដែលដាក់វាឲ្យនៅដាច់ចេញពីជំពូកដទៃទៀតនៃសៀវភៅនេះ ។ ជំពូកនីមួយៗអាចត្រូវ បានផ្ទេរចេញពីវិបសាយរបស់ការិយាល័យ ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាមួយនឹងអត្ថបទទាំងស្រុងនៃសៀវភៅនេះ ។

សំខាន់ត្រូវកត់សំគាល់ថា *សៀវភៅ*នេះ មិនមែនជាការណែនាំមួយដាច់ដោយឡែកតែឯង ឬបិតិវន្តនោះទេ ។ ក្នុងករណីចាំបាច់ សេចក្ដីយោងទៅវិបសាយ របស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ (OHCHR) និងធនធានផ្សេងទៀត ត្រូវបានផ្ដល់ជូន ដើម្បីធានាថាមិត្តអ្នកអានទាំងឡាយមានលទ្ធភាពទទួលបានព័ត៌មានថ្មីៗ ។ មិត្តអ្នកអាន ត្រូវបានជំរុញលើកទឹកចិត្តឲ្យប្រើប្រាស់ ធនធានបំពេញបន្ថែមទាំងនេះ ។

## រចនាសម្ព័ន្ធ

ជំពូកទាំងនេះ ជាទូទៅត្រូវបានចែកចេញជាបីផ្នែក ៖

- អ្វីទៅជាស្ថាប័ន ឬយន្តការ ។
- របៀបដែលស្ថាប័ន ឬយន្តការនេះធ្វើការ និង
- របៀបដែលតួអង្គសង្គមស៊ីវិល អាចប្រើប្រាស់និងសហការជាមួយស្ថាប័ន ឬយន្តការនេះ ។

ជំពូកនីមួយៗ ក៏រៀបរាប់អំពីអាស័យដ្ឋានទំនាក់ទំនងសំខាន់ៗ នៅឯការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) និងមានបញ្ចូលគេហទំព័រភ្ជាប់លិញទៅគេហទំព័រធនធានព័ត៌មានផ្សេងទៀត ។

## ព័ត៌មានត្រឡប់របស់អ្នក

*សៀវភៅ*នេះ គឺជាឧបករណ៍មួយមានប្រសិទ្ធភាព ។ អង្គភាពសង្គមស៊ីវិលនៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ស្វាគមន៍ព័ត៌មានត្រឡប់របស់មិត្តអ្នកអាន ។ សូមផ្ញើសេចក្ដីសង្កេត និងគំនិតយោបល់របស់អ្នកទៅកាន់:

# អង្គភាពសង្គមស៊ីវិល

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
វិមានជាតិ(Palais des Nations)
CH-1211 Geneva 10 ប្រទេសស្វីស
តាមរយៈអ៊ីម៉ែល ៖ CivilSocietyUnit@ohchr.org

# I. សេចក្តីផ្តើមអំពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ( UNOHCHR )

## ក. កម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

កម្មវិធីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង ។ កម្មវិធីនេះ ត្រូវបានអនុវត្តតាមរយៈស្ថាប័ន និងទីភ្នាក់ងារសិទ្ធិមនុស្សអង្គការសហប្រជាជាតិខុសៗគ្នា និងរួមបញ្ចូលទាំងស្ថាប័ន និងយន្តការសិទ្ធិមនុស្សផ្សេងៗ ដែលបានបរិយាយនៅក្នុង*សៀវភៅ*នេះ ដែលស្ថាប័ន និងយន្តការទាំងអស់នេះ មានគោលបំណងរួមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ពោលគឺ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ដែលត្រូវបានប្រកាសនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អស់រយៈពេលជាង ៦០ ឆ្នាំកន្លងមកនេះ ។

ក្នុងនាមជាអាជ្ញាធរពិភពលោកផ្នែកសិទ្ធិមនុស្ស **ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ទទួលខុសត្រូវចំពោះការដឹកនាំកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សទាំងអស់ ដែលត្រូវបានកំណត់នៅក្នុង**ធម្មនុញ្ញអង្គការសហប្រជាជាតិ** និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

ចក្ខុវិស័យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ គឺពិភពលោកមួយដែលក្នុងនោះសិទ្ធិមនុស្សរបស់មនុស្សទាំងអស់ ត្រូវបានគោរព និងទទួលបានដោយពេញលេញ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ធ្វើការខិតខំប្រឹងប្រែងខ្លាំងដើម្បីសម្រេចឲ្យបាននូវកិច្ចការពារសិទ្ធិមនុស្ស*ទាំងអស់* សម្រាប់មនុស្ស*គ្រប់រូប* ដើម្បីផ្តល់សិទ្ធិអំណាចដល់មនុស្សឲ្យសម្រេចបានសិទ្ធិរបស់ខ្លួន និងដើម្បីជួយអ្នកដែលទទួលខុសត្រូវចំពោះការគោរពសិទ្ធិបែបនេះ ក្នុងការធានាថាសិទ្ធិទាំងនេះត្រូវបានអនុវត្ត ។

## ខ. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គឺជាផ្នែកមួយនៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងត្រូវបានដឹកនាំដោយ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ពោលគឺ ជាមុខតំណែងមួយដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ ។[1] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សហការជាមួយនឹងតួអង្គកាន់តែច្រើន ក្នុងនោះរួមមាន

[1] សូមមើលសេចក្តីសម្រេចចិត្តលេខ 48/141 ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ។ ការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ក៏ត្រូវបានណែនាំផងដែរ តាមរយៈធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សជាបន្ត ក្នុងនោះរួមមាន សេចក្តីប្រកាសក្រុងវីយែនឆ្នាំ១៩៩៣ និងកម្មវិធីសកម្មភាព និងឯកសារលទ្ធផលនៃកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០០៥ (សេចក្តីសម្រេចចិត្តលេខ 60/1 ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥) ។

រដ្ឋាភិបាល ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRI) អង្គការមិនមែនរដ្ឋាភិបាល (NGO) និងតួអង្គសង្គមស៊ីវិលផ្សេងទៀតផងដែរ ដើម្បីបណ្តុះការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្សឲ្យបានទូលំទូលាយតាមដែលអាចធ្វើបាន ។

ក្នុងនាមជាមន្ត្រីសិទ្ធិមនុស្សដ៏សំខាន់បំផុតមួយរូបនៃអង្គការសហប្រជាជាតិ ឧត្តមស្នងការបំពេញតួនាទីជាអាជ្ញាធរផ្នែកសីលធម៌ និងជាសម្លេងមួយសម្រាប់ជនរងគ្រោះ ។ ឧត្តមស្នងការណែនាំអំពីបេសកកម្ម និងតម្លៃរបស់ការិយាល័យ កំណត់អំពីអាទិភាពរបស់ការិយាល័យ និងជំរុញសកម្មភាពរបស់ការិយាល័យ ។ ឧត្តមស្នងការចេញសេចក្តីថ្លែងការណ៍ និងសេចក្តីអំពាវនាវជាសាធារណៈស្តីពីស្ថានភាព និងវិបត្តិសិទ្ធិមនុស្ស ចូលរួមក្នុងកិច្ចសន្ទនាជាមួយដ្ឋាភិបាលនានា ដើម្បីពង្រឹងការការពារសិទ្ធិមនុស្សថ្នាក់ជាតិ និងបំពេញទស្សនកិច្ចយ៉ាងទូលំទូលាយ ដើម្បីធានាថា សារស្តីពីសិទ្ធិមនុស្ស ត្រូវបានគេស្តាប់ឮនៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក ដើម្បីស្តាប់អ្នកដែលសិទ្ធិរបស់គេត្រូវបានបដិសេធ និងចូលរួមពាក់ព័ន្ធជាមួយអ្នកកាន់ភារកិច្ច ។

ឧត្តមស្នងការ ខិតខំពុះពារបញ្ជ្រាបស្តង់ដាសិទ្ធិមនុស្សទៅក្នុងគ្រប់កម្មវិធីទាំងអស់របស់អង្គការសហប្រជាជាតិ ដើម្បីធានាថា សន្តិភាព និងសន្តិសុខ ការអភិវឌ្ឍ និងសិទ្ធិមនុស្ស ពោលគឺ សរសេរស្តម្ភទាំងបីរបស់ប្រព័ន្ធសហប្រជាជាតិ ត្រូវបានផ្សាភ្ជាប់គ្នា និង ពង្រឹងគ្នាទៅវិញទៅមក ហើយថា សិទ្ធិមនុស្សបង្កើតជាមូលដ្ឋានគ្រឹះ នៃសកម្មភាពទាំងអស់របស់អង្គការសហប្រជាជាតិ ។

ដោយហេតុថាឧត្តមស្នងការ មានប្រសាសន៍ជាចំហ និងជាសាធារណៈ អំពីស្ថានភាពសិទ្ធិមនុស្សពិភពលោក និងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព តាមរយៈការតម្រូវឲ្យរដ្ឋទាំងឡាយទទួលខុសត្រូវចំពោះសកម្មភាព និងភាពអសកម្មភាពរបស់ខ្លួន ដែលគេរំពឹងថា ឧត្តមស្នងការ និងការិយាល័យឧត្តមស្នងការជារឿយៗ តែងតែទទួលរងការរិះគន់ពីមជ្ឈដ្ឋានផ្សេងៗ ។ រិតតែសំខាន់ជាងនេះទៀតនោះគឺ នៅពេលបញ្ចូលទស្សនទាន និងវិធីសាស្ត្រសិទ្ធិមនុស្សទៅក្នុងការជជែកដេញដោល ដែលជាញឹកញាប់ត្រូវបានគេភ្ជាប់វាទៅរឿងនយោបាយនោះ នោះភាពមិនលំអៀង ភាពត្រឹមត្រូវ និងសកលភាពនៃសិទ្ធិមនុស្សគឺជាគោលការណ៍គ្រឹះ ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ត្រូវតែប្រកាន់ខ្ជាន់សម្រាប់ការងាររបស់ខ្លួន ។

ឧត្តមស្នងការបច្ចុប្បន្ន អ្នកស្រី ណាវ៉ាណិថិម ភីឡៃ ចូលកាន់តំណែងក្នុងខែកញ្ញា ឆ្នាំ២០០៨ ។ អ្នកស្រី ភីឡៃ កាន់តំណែងបន្តពីបុព្វាធិការី និងបុព្វាធិការិនី របស់អ្នកស្រីគឺ អ្នកស្រី លូអ៊ីសអាប៊ឺរ (២០០៤-២០០៨) លោក សឺជីអូវីអេរ៉ាដឺម៉េឡូ (២០០២-២០០៣)[2] អ្នកស្រី ម៉ារីរ៉ូប៊ីនសុន (១៩៩៧-២០០២) និងលោក ចូសេអាយ៉ាឡាឡាសូ (១៩៩៤-១៩៩៧) លោក ប៊ីទ្រែនជី.រ៉ាមចារ៉ែន គឺជាឧត្តមស្នងការរងពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៤ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) មានទីស្នាក់ការកណ្តាលនៅឯវិមានរដ្ឋវីលសុន ក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស និងមានការិយាល័យនៅឯទីស្នាក់ការធំក្នុងទីក្រុងញូវយ៉ក ។ ដោយមានបុគ្គលិកជាង ៩០០នាក់ ដែលជាងពាក់កណ្តាលនៃបុគ្គលិកទាំងនោះ

---

[2] នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣ លោក សឺជីអូវីអេរ៉ាដឺម៉េឡូ ត្រូវស្លាប់បាត់បង់ជីវិត រួមជាមួយនឹងបុគ្គលិកអង្គការសហប្រជាជាតិចំនួន ២១ រូបផ្សេងទៀត នៅក្នុងទីក្រុងបាក់ដាត ជាទីកន្លែងដែលគាត់បម្រើអង្គការសហប្រជាជាតិ ក្នុងនាមជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំប្រទេសអ៊ីរ៉ាក់ ។

ធ្វើការងារនៅមូលដ្ឋាន បុគ្គលិកបច្ចុប្បន្នរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រួមមានក្រុម និងមន្ត្រីការិយាល័យប្រចាំប្រទេស មន្ត្រីការិយាល័យប្រចាំតំបន់ ទីប្រឹក្សាសិទ្ធិមនុស្ស និងបុគ្គលិកផ្នែកសិទ្ធិមនុស្សនៃបេសកកម្មសន្តិភាពអង្គការសហប្រជាជាតិ ។

## *i* អាណត្តិរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

ឧត្តមស្នងការ ត្រូវបានប្រគល់អាណត្តិដោយសេចក្តីសម្រេចចិត្តលេខ ៤៨/១៤១ នៃមហាសន្និបាតអង្គការសហប្រជាជាតិដើម៖

- លើកកម្ពស់ និងការពារសិទ្ធិមនុស្សទាំងអស់ សម្រាប់មនុស្សគ្រប់រូប ។
- ផ្តល់អនុសាសន៍ដល់ស្ថាប័នមានសមត្ថភាពរបស់ប្រព័ន្ធសហប្រជាជាតិ ដើម្បីពង្រឹងការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្សទាំងអស់ ។
- លើកកម្ពស់ និងការពារសិទ្ធិទទួលបានការអភិវឌ្ឍ ។
- ផ្តល់ជំនួយបច្ចេកទេសសម្រាប់សកម្មភាពសិទ្ធិមនុស្ស ។
- សម្របសម្រួលកម្មវិធីអប់រំសិទ្ធិមនុស្ស និងព័ត៌មានសាធារណៈរបស់អង្គការសហប្រជាជាតិ ។
- បំពេញតួនាទីដោយសកម្មក្នុងការពុះពារឧបសគ្គដែលរារាំងដល់ការសម្រេចបានសិទ្ធិមនុស្ស ។
- បំពេញតួនាទីដោយសកម្មក្នុងការទប់ស្កាត់ការបន្តការរំលោភបំពានលើសិទ្ធិមនុស្ស ។
- ចូលរួមពាក់ព័ន្ធនៅក្នុងកិច្ចពិភាក្សាជាមួយនឹងរដ្ឋាភិបាល ដោយមានគោលបំណងធានាឲ្យមានការគោរពសិទ្ធិមនុស្សទាំងអស់ ។
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- សម្របសម្រួលសកម្មភាពលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅទូទាំងប្រព័ន្ធសហប្រជាជាតិ និង
- ធ្វើសនិទានកម្ម កែសម្រួលតាមពង្រឹង និងបង្កើនប្រសិទ្ធភាពក្បាលម៉ាស៊ីនដឹកនាំផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ។

## គ. ការងារ និងសកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្វែងរកការអនុវត្តស្តង់ដាសិទ្ធិមនុស្សនៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទាំងអស់នៅសព្វទីកន្លែង ។ ដោយធ្វើការងារឆ្ពោះទៅរកគោលដៅនេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សហការជាមួយនឹងរដ្ឋាភិបាល សភា អាជ្ញាធរតុលាការ នគរបាល និងមន្ត្រីពន្ធនាគារ ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRI) អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀតដ៏ច្រើនសន្ធឹកសន្ធាប់ ជាបន្ថែមទៅលើដៃគូអង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់ការយល់ដឹង និងការគោរពសិទ្ធិមនុស្ស ។ ការិយាល័យឧត្តមស្នង

ការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់សិទ្ធិអំណាចដល់បុគ្គល ដើម្បីទាមទារសិទ្ធិរបស់ខ្លួន និងជួយដល់រដ្ឋទាំងឡាយ ក្នុងការគោរពតាមកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សរបស់ខ្លួន ។

អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានជាតិ និងអន្តរជាតិទទួលបន្ទុកសិទ្ធិមនុស្ស គឺជាផ្នែកសំខាន់ជាសារវន្តមួយនៃចលនាសិទ្ធិមនុស្សអន្តរជាតិ និងជាដៃគូសំខាន់ជាសារវន្តរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ គេប្រាប់ដល់ពិភពលោកឲ្យបានដឹងអំពីការរំលោភបំពានលើសិទ្ធិមនុស្ស ។ គេការពារជនរងគ្រោះ លើកកម្ពស់សិទ្ធិមនុស្សតាមរយៈការអប់រំ និងធ្វើយុទ្ធនាការដើម្បីការកែលម្អ និងធ្វើឲ្យចម្រើនជឿនលឿនទៅមុខ ។ ទំនាក់ទំនងមិត្តភាព រវាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងសង្គមស៊ីវិល គឺជាទំនាក់ទំនងមិត្តភាពប្រកបដោយថាមវន្ត និងមានលក្ខណៈសហការ ដែលបញ្ចូលគ្រប់ផ្នែកទាំងអស់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

វិស័យការងារ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ពង្រីកវិសាលភាពពេញលេញផ្នែកសិទ្ធិមនុស្ស ។ សកម្មភាពនីមួយៗ មានទំនាក់ទំនងគ្នាទៅវិញទៅមក និងបំពេញគ្នាទៅវិញទៅមក និងបង្កើតជាផ្នែកសំខាន់ជាសារវន្តមួយនៃបេសកកម្មរបស់ខ្លួន ។

**ការងារប្រធានបទ** របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស កំណត់អត្តសញ្ញាណ និងកំណត់ជាគោលដៅនូវគំលាតនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សដែលមានស្រាប់ ដោយដឹកនាំកិច្ចការពារ និងការស្រាវជ្រាវ និងដោយដោះស្រាយបញ្ហាសហកាល ដូចជា ការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាដែលមានមូលដ្ឋាននៅលើយេនឌ័រ ផ្តើមចេញពីក្នុងក្របខ័ណ្ឌសិទ្ធិមនុស្ស ។

នៅក្នុង**ការងារកំណត់ស្តង់ដារ**របស់ខ្លួន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រួមចំណែកដល់ការបង្កើតឡើងនូវបទដ្ឋានអន្តរជាតិថ្មី ដើម្បីបង្កើនការការពារសិទ្ធិមនុស្ស និងសិទ្ធិទទួលបានសិទ្ធិមនុស្ស ។

**ការងារពិនិត្យតាមដាន**របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានគោលបំណងធានាថា ស្តង់ដាទាំងនេះ ត្រូវបានអនុវត្តជាក់ស្តែង និងដូច្នេះរួមចំណែកដល់ការប្រែក្លាយសិទ្ធិមនុស្សទៅជាតថភាពពិត ។

តាមរយៈការងាររបស់ខ្លួនលើការ**អនុវត្តន៍**នៅមូលដ្ឋាន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្វែងរកសញ្ញាព្រមានដំបូងនៃវិបត្តិសិទ្ធិមនុស្ស និងស្ថានភាពកាន់តែធ្ងន់ធ្ងរ ដោយផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល និងត្រៀមខ្លួនជាស្រេចដើម្បីដាក់ពង្រាយបុគ្គលិក និងផ្តល់ធនធាន នៅពេលណាដែលវិបត្តិកើតមាន ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ខិតខំពុះពារបង្កើន**ការអប់រំ** និងការយល់ដឹងអំពី**សិទ្ធិមនុស្ស** ។ ការិយាល័យនេះ ផ្តល់សិទ្ធិអំណាចដល់មនុស្សដើម្បី

ទទួលបានសិទ្ធិរបស់ខ្លួន ដោយប្រើប្រាស់ស្ថាប័ន និងយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រកប ដោយប្រសិទ្ធភាព ដើម្បីក្លាយជាភ្នាក់ងារផ្លាស់ប្តូរ ដែលមានគោលបំណងញ៉ាំងឲ្យមានការបង្កើតឡើងនូវ *សៀវភៅ*នេះ ។

សកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) បានទទួលមូលនិធិពីថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិ និងពីវិភាគទានស្ម័គ្រចិត្តពីរដ្ឋជាសមាជិក អង្គការអន្តររដ្ឋាភិបាល មូលនិធិ និងបុគ្គលផ្សេងៗ។

## ការងារតាមវិស័យនីមួយៗ

*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្រាវជ្រាវរក វិស័យថ្មីៗនៃកិច្ចការពារ និងការកំណត់ស្តង់ដាសិទ្ធិមនុស្សនៅទូទាំងប្រធានបទ និងបញ្ហាមួយចំនួនធំ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ផ្តល់ការណែនាំផ្នែកច្បាប់ និង គោលនយោបាយ ទទួលរ៉ាប់រងអនុវត្តការស្រាវជ្រាវដ៏សំខាន់ សម្របសម្រួលកិច្ចពិភាក្សា និងកិច្ចពិគ្រោះ យោបល់លើបញ្ហា និងនិន្នាការដែលកំពុងលេចចេញឡើង និងរកឲ្យឃើញភាពជាដៃគូដែលមានមូលដ្ឋាន នៅលើបញ្ហាជាមួយនឹងអ្នកពាក់ព័ន្ធផ្នែកសិទ្ធិមនុស្សជាច្រើន ដោយលើកកម្ពស់វិធីអនុវត្តដែលប្រសើរបំផុត។*

*ការងារតាមវិស័យនីមួយៗ របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ មនុស្ស រួមមាន៖*

- ការប្រឆាំងនឹងការរើសអើង
- កុមារ
- ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន
- សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងនោះរួមមាន សិទ្ធិសុខភាព សិទ្ធិមានលំនៅឋាន សិទ្ធិមាន ស្បៀងអាហារ និងសិទ្ធិទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ ។
- មេរោគអេដស៍/ជំងឺអេដស៍ ។
- ការធ្វើផែនការ និងការវាយតម្លៃអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ។
- ធុរកិច្ច និងសិទ្ធិមនុស្ស ។
- សិទ្ធិមនុស្ស និងការប្រឆាំងនឹងភេរវកម្ម ។
- សិទ្ធិមនុស្ស និងពិការភាព ។
- ការអប់រំ និងបណ្តុះបណ្តាលសិទ្ធិមនុស្ស ។
- ការបញ្ជ្រាបសិទ្ធិមនុស្ស ។
- ការពិនិត្យតាមដាន និងការស៊ើបអង្កេតបញ្ហាសិទ្ធិមនុស្ស ។
- សិទ្ធិមនុស្សក្នុងប្រតិបត្តិការសន្តិភាព ។
- ជនជាតិដើមភាគតិច និងក្រុមជនភាគតិច ។

- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងសិទ្ធិអភិវឌ្ឍ រាប់ទាំង ការកាត់ បន្ថយភាពក្រីក្រផងដែរ ។
- ការរើសអើងពូជសាសន៍ ។
- នីតិរដ្ឋ និងលិទ្ធិប្រជាធិបតេយ្យ រាប់ទាំងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ អភិបាលកិច្ចល្អ គណនេយ្យភាព និទណ្ឌភាព និងគំនិតផ្តួចផ្តើមប្រឆាំងនឹងអំពើពុករលួយ ។
- គោលនយោបាយសន្តិសុខ ។
- ពាណិជ្ជកម្ម និងសកលភាវូបនីយកម្ម ។
- ការជួញដូរមនុស្ស ។
- យុត្តិធម៌អន្តរកាល ។
- សិទ្ធិមនុស្សរបស់ស្ត្រី និងយែនឌ័រ ។

កម្មវិធីទាំងនេះ ព្យាយាមបញ្ចូលជំនាញ និងគំនិតថ្មីៗ ទៅក្នុងប្រធានបទដែលប្រទាក់ក្រឡាគ្នា ដែលបានជ្រើសសម្រាំងថា មានសារៈសំខាន់ជាពិសេសចំពោះកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ មានជាអាទិ៍ សមភាព និងភាពមិនរើសអើង ។ វាដោះស្រាយបញ្ហាក្រុម និងបញ្ហា ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ពិសេស ដូចជា ជនរងគ្រោះដោយការរើសអើងពូជសាសន៍ ក្រុមជនភាគតិច និងជនជាតិដើមភាគតិច សិទ្ធិនារី និងយែនឌ័រ ពិការភាព ការជួញដូរមនុស្ស និងអ្នកដែលទទួលរងផលប៉ះពាល់ដោយមេរោគអេដស៍/ជំងឺអេដស៍ ។

# ការធ្វើការរួមគ្នាលើផ្នែកនិទណ្ឌភាព និងនីតិរដ្ឋ

**សំណុំគោលការណ៍មួយដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បី ប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និង គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋាន ស្តីពីសិទ្ធិទទួលបានការដោះស្រាយ និង សំណងត្រឹមត្រូវ** ត្រូវបានសរសេរ បញ្ចប់ក្នុងឆ្នាំ ២០០៥ ។

នៅពេលដែលសេចក្តីព្រាងដំបូង ត្រូវបានរៀបចំរួចជាស្រេច ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីការពិភាក្សា និងព័ត៌មានត្រឡប់ ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួនបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងនេះ ក្នុងនោះរួមមាន **គណៈកម្មការអ្នកច្បាប់អន្តរជាតិ អង្គការលើកលែងទោសអន្តរជាតិ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស** និង**មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល** ។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ទស្សនវិស័យរបស់ទីភ្នាក់ងារដៃគូអន្តរជាតិ និងជាតិ ដោយតម្រូវឲ្យមានការបញ្ចូលសេចក្តីត្រូវការ និងបទពិសោធន៍ពីមូលដ្ឋានទៅក្នុងសេចក្តីព្រាង ។

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍ និងគោលការណែនាំជាមូលដ្ឋានស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងនៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ ២០០៥ នេះផងដែរ អតីតគណៈកម្មការសិទ្ធិមនុស្ស បានកត់សម្គាល់លើគោលការណ៍មួយសំណុំ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីប្រយុទ្ធនឹងនិទណ្ឌភាព ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ មនុស្ស (OHCHR) បានរៀបចំសិក្ខាសាលាជាបន្តបន្ទាប់គ្នាដើម្បីផ្សព្វផ្សាយ ព័ត៌មាន ស្តីពីគោលការណ៍ទាំងពីរសំណុំ ក៏ដូចជាដើម្បីពិភាក្សាលើយុទ្ធសាស្ត្រសម្រាប់អនុវត្តន៍វានៅថ្នាក់ជាតិ ។ ដោយរួមទាំងបុគ្គលិកមកពីការិយាល័យនៅមូលដ្ឋាននៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងបេសកកម្មសន្តិភាពរបស់អង្គការសហប្រជាជាតិផង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមកពីប្រទេសដែលទើបតែចប់ជម្លោះ បានចូលរួមយ៉ាងសកម្មនៅក្នុងសិក្ខាសាលាទាំងនេះ ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានទាំងនេះ មានលក្ខណៈសំខាន់ក្នុងការជួយផ្សព្វផ្សាយគោលការណ៍ និងធានាថា វា មានដំណើរការនៅនឹងកន្លែង ។ ការធ្វើការងារជាមួយនឹងរដ្ឋាភិបាល ដើម្បីធានាឲ្យមានការអនុវត្ត និងការជំរុញឲ្យអនុវត្តស្តង់ដាទាំងនេះ គឺជាតួនាទីសំខាន់ដែលអង្គការមិនមែនរដ្ឋាភិបាល បន្តបំពេញ ដើម្បីធានាថា សិទ្ធិដែលត្រូវបានចែងនៅក្នុងឯកសារទាំងនេះ ត្រូវបានសម្រេចបាន ។

សម្រាប់ព័ត៌មានបន្ថែម ចូរមើលៈ

- គោលការណ៍មួយសំណុំ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព សម្រាប់កិច្ចការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស តាមរយៈសកម្មភាពប្រយុទ្ធនឹងនិទណ្ឌភាព (E/CN.4/2005/102/ Add.1) និង
- គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋាន ស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណង សម្រាប់ ជនរងគ្រោះដោយការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (សេចក្តីសម្រេច ចិត្តលេខ 60/147 របស់មហាសន្និបាតអង្គការសហប្រជាជាតិ) ។

# ការកំណត់ស្តង់ដា និងការពិនិត្យតាមដាន

*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ព្យាយាមផ្តល់ការស្រាវជ្រាវដែលមានគុណភាពខ្ពស់បំផុត ជំនាញ ការណែនាំ និងសេវារដ្ឋបាល ដល់ស្ថាប័ន និងយន្តការសិទ្ធិមនុស្សដ៏សំខាន់របស់អង្គការសហប្រជាជាតិ ដោយហេតុថា ស្ថាប័នទាំងនេះ អនុវត្តករណីយកិច្ចក្នុងការកំណត់ស្តង់ដា និងពិនិត្យតាមដានរបស់ខ្លួន ដោយរួមចំណែកក្នុងការបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងយុត្តិសាស្ត្រ និងដោយខិតខំពុះពារធានាឲ្យមានការអនុវត្តស្តង់ដាសិទ្ធិមនុស្សដែលត្រូវបានព្រមព្រៀង ។ ស្ថាប័ន និងយន្តការទាំងនេះ រួមមាន៖*

- **ក្រុមប្រឹក្សាសិទ្ធិមនុស្ស** និងយន្តការរបស់វា ដូចជាឧទាហរណ៍ៈ យន្តការពិសេស យន្តការត្រួតពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ យន្តការបណ្តឹង គណៈកម្មាធិការប្រឹក្សាយោបល់ វេទិកាសង្គម វេទិកាស្តីពីបញ្ហាក្រុមជនភាគតិច និងយន្តការអ្នកជំនាញខាងសិទ្ធិជនជាតិដើមភាគតិច និង
- ស្ថាប័ន**សន្ធិសញ្ញាសិទ្ធិមនុស្ស** ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្តេជ្ញាចិត្តពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការប្រើប្រាស់កម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ប្រកបដោយប្រសិទ្ធភាព ។ ជំពូកដែលមកបន្ទាប់នេះ ស្រាវជ្រាវករបៀបផ្សេងៗដែលសង្គមស៊ីវិលអាចចូលរួមពាក់ព័ន្ធនិងរួមចំណែកនៅក្នុងស្ថាប័ន និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ តាមរយៈការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)៖

- **ជំពូក IV** ផ្តោតការយកចិត្តទុកដាក់ទៅលើស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។
- **ជំពូក V** ផ្តោតការយកចិត្តទុកដាក់ទៅលើក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការរបស់វា ក្នុងនោះរួមមាន គណៈកម្មាធិការទីប្រឹក្សា វេទិកាសង្គម វេទិកាបញ្ហាក្រុមជនភាគតិច យន្តការមន្ត្រីជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍដ៏ទូលំទូលាយ និងយន្តការមួយចំនួនដែលទាក់ទងនឹងសេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព ។
- **ជំពូក VI** ផ្តោតការយកចិត្តទុកដាក់ទៅលើយន្តការពិសេស ។
- **ជំពូក VII** ផ្តោតការយកចិត្តទុកដាក់ទៅលើយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាល ជាសកល ។
- **ជំពូក VIII** ពន្យល់អំពីរបៀបដាក់ជូនពិនិត្យពាក្យបណ្តឹង ស្តីពីការរំលោភបំពានលើសិទ្ធិមនុស្ស ដែលមានទទ្បីករណ៍ ។

*i*

សម្រាប់ព័ត៌មានបន្ថែមស្តីពី**ការងារកំណត់ស្តង់ដា និងពិនិត្យតាមដានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** សូមចូលមើល**វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** ។

# ការអនុវត្តសិទ្ធិមនុស្ស

*ស្តង់ដាសិទ្ធិមនុស្ស មានគុណតម្លៃតិចតួច ប្រសិនប្រើវា មិនត្រូវបានអនុវត្តទេនោះ ។ រដ្ឋទាំងឡាយដែលកំពុងតែងើបឡើងវិញពីជម្លោះ ឬ ខ្វះខាតធនធាន ឬ ជំនាញ ត្រូវការជំនួយដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ។ ហេតុដូច្នេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) លះបង់ធនធានដ៏ច្រើនសម្រាប់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិក្នុងកិច្ចការពារសិទ្ធិមនុស្ស។ ដោយចូលរួមពាក់ព័ន្ធជាមួយនឹងប្រទេសនានា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ធ្វើការខិតខំប្រឹងប្រែងខ្លាំង ដើម្បីបំពេញគម្លាតអនុវត្តន៍ដ៏ធំ ក្នុងនោះរួមមាន គម្លាតដែលទាក់ទងនឹងចំណេះដឹង សមត្ថភាព ការប្តេជ្ញាចិត្ត និងសន្តិសុខ ។*

*តាមរយៈការងារអនុវត្តន៍របស់ខ្លួននៅមូលដ្ឋាន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានគោលបំណងធានាថា:*

- អាជ្ញាធរជាតិ ត្រូវបានផ្តល់ព័ត៌មានអំពីស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ និងរបៀបប្រែក្លាយស្តង់ដាទាំងនេះទៅជាច្បាប់ និយ័តកម្ម និងគោលនយោបាយ ។
- មន្ត្រីរដ្ឋាភិបាល និងសង្គមស៊ីវិល មានឋានៈកាន់តែធំធេងក្នុងការដោះស្រាយបញ្ហាកង្វល់ផ្នែកសិទ្ធិមនុស្ស ។
- អាជ្ញាធររដ្ឋាភិបាល មានការយល់ដឹងអំពីកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សរបស់ខ្លួន និងអនុវត្តឧបាស្រ័យប្រកបដោយប្រសិទ្ធភាព ដើម្បីពុះពារជំនះឧបសគ្គរារាំងដល់ការសម្រេចបានសិទ្ធិមនុស្ស ។
- អ្នកកាន់សិទ្ធិ ត្រូវបានការពារយ៉ាងល្អប្រសើរ ពីគោលនយោបាយដែលគំរាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ ។
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានលទ្ធភាពកាន់តែល្អប្រសើរក្នុងការឆ្លើយតបទៅនឹងតម្រូវការនៅនឹងកន្លែង ។

ការិយាល័យនៅតាមប្រទេសផ្សេងៗ និងវត្តមានរបស់ OHCHR បង្កើតការឆ្លើយតបសមស្រប និងមានប្រសិទ្ធភាពទៅនឹងបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្ស ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាល ប្រព័ន្ធសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសមាជិកដទៃទៀតរបស់សង្គមស៊ីវិល។ ឧទាហរណ៍ ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជួយដល់កិច្ចខិតខំប្រឹងប្រែងក្នុងការដាក់បញ្ចូលស្តង់ដាសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ និងណែនាំលើការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នជាតិ ទទួលបន្ទុកសិទ្ធិមនុស្សឯករាជ្យ (NHRI) ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក៏ធ្វើការងារ និងផ្តល់ការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្សផងដែរដល់តុលាការ មន្ត្រីកងរាជអាវុធហត្ថ និងសភា លើស្តង់ដាអន្តរជាតិដែលទាក់ទងទៅនឹងការងាររបស់គេ ផ្តល់ការណែនាំអំពីការរៀបចំរបាយការណ៍ដល់ស្ថាប័នសន្ធិសញ្ញា និងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងបង្កើតកម្មវិធីសម្រាប់ការអប់រំសិទ្ធិមនុស្ស ។

សង្គមស៊ីវិល គឺជាដៃគូសំខាន់ជាសារវន្តនៅក្នុងគ្រប់សកម្មភាពទាំងអស់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅមូលដ្ឋាន ។ នេះគឺជាឧទាហរណ៍ខ្លះ ស្តីពីការចូលរួមពាក់ព័ន្ធ និងកិច្ចសហការរបស់សង្គមស៊ីវិលជាមួយនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅមូលដ្ឋានៈ

- ការជម្រាបជូនការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) អំពីស្ថានភាពសិទ្ធិមនុស្សដែលកាន់តែធ្ងន់ធ្ងរ និងនិន្នាការដែលលេចឡើង ។
- ការផ្តល់ព័ត៌មានដល់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) អំពីស្ថានភាពសិទ្ធិមនុស្ស ហេតុការណ៍វិវត្តន៍ថ្មីៗ និងការបំពានដែលមានទទ្បីករណ៍នៅថ្នាក់មូលដ្ឋាន និងជាតិ ។
- ការធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) អំពីសិក្ខាសាលា និងសិក្ខាសាលាពិភាក្សាផ្នែកសិទ្ធិមនុស្ស កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្ស និងអំពីគម្រោងថ្នាក់ជាតិ និងតំបន់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និង
- ការធ្វើការងារជាមួយនឹងការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ដើម្បីលើកកម្ពស់ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស និងការអនុវត្តវា ។

ការិយាល័យបច្ចុប្បន្ននៅមូលដ្ឋានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រួមមាន ការិយាល័យប្រចាំប្រទេស ការិយាល័យតំបន់ ផ្នែកសិទ្ធិមនុស្សនៃបេសកកម្មសន្តិភាពអង្គការសហប្រជាជាតិ ផ្នែកទីប្រឹក្សាសិទ្ធិមនុស្សនៅក្នុងក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ និងផ្នែកឆ្លើយតបរហ័សទៅនឹងវិបត្តិសិទ្ធិមនុស្សដែលកំពុងលេចឡើង ។

## ១. ការិយាល័យប្រចាំប្រទេស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានបង្កើតការិយាល័យប្រចាំប្រទេសដែលមានចំនួនកាន់តែកើនច្រើនឡើង ។ សកម្មភាពរបស់ការិយាល័យប្រចាំប្រទេសរួមមាន ការពិនិត្យតាមដានសិទ្ធិមនុស្ស ការរៀបចំរបាយការណ៍សាធារណៈ ការផ្តល់ជំនួយបច្ចេកទេស និងការជួយដល់រដ្ឋាភិបាលក្នុងការរៀបចំបង្កើតគោលនយោបាយ និងចំណុចដៅផ្នែកសិទ្ធិមនុស្សរយៈពេលវែង និងប្រកបដោយនិរន្តរភាព ។

## ការធ្វើការងារជាមួយនឹងការិយាល័យប្រចាំប្រទេសរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅប្រទេសអ៊ូហ្គាន់ដា ដើម្បីការពារ និងលើកកម្ពស់ដោយកាន់តែល្អប្រសើរនូវសិទ្ធិរបស់ជនពិការ

ការិយាល័យប្រចាំប្រទេសរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅប្រទេសអ៊ូហ្គាន់ដា ធ្វើការងារជាមួយនឹងសមាគមជនពិការដើម្បីលើកកម្ពស់ការស្វែងយល់អំពីពិការភាពជាបញ្ហាសិទ្ធិមនុស្សមួយ បង្កើនការយល់ដឹងអំពីស្តង់ដាសិទ្ធិមនុស្សពាក់ព័ន្ធ និងលើកកម្ពស់ការប្រតិបត្តិតាមស្តង់ដាទាំងនេះនៅក្នុងច្បាប់ក្នុងស្រុក គោលនយោបាយ និងផែនការនានា ។ ការិយាល័យនៅប្រទេសអ៊ូហ្គាន់ដាបានចូលរួមពាក់ព័ន្ធជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល តាមរបៀបដូចតទៅៈ

- ការិយាល័យប្រចាំប្រទេស បានបើកកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីផ្តល់ការណែនាំផ្នែកបច្ចេកទេសស្តីពីការប្រតិបត្តិតាមច្បាប់ក្នុងស្រុក និងគោលនយោបាយស្តីពីពិការភាពជាមួយនឹងស្តង់សិទ្ធិមនុស្ស ។
- ការិយាល័យប្រចាំប្រទេសបានអនុវត្តសកម្មភាពពិនិត្យតាមដាន និងផ្តោតការពិភាក្សាក្រុមទៅលើស្ថានភាពរបស់ជនពិការដោយជំរុញយ៉ាងសកម្មនៅតាមស្រុក ផ្សេងៗ ឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលរបស់ជនពិការនៅក្នុងយន្តការសម្របសម្រួលសិទ្ធិមនុស្ស ។
- ការិយាល័យប្រចាំប្រទេស បានគាំទ្រដល់សហភាពជាតិជនពិការក្នុងការប្រមូលហត្ថលេខាសម្រាប់បដ្ឋនាលិខិតដែលជំរុញរដ្ឋាភិបាលឲ្យផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ។ ហត្ថលេខាចំនួនជាង ១.០០០ ត្រូវបានប្រមូលនៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០០៧។
- ការិយាល័យប្រចាំប្រទេសបានជួយឧបត្ថម្ភដល់ការសាងសង់ច្រកចូលទៅកាន់ផ្នែករដ្ឋបាលសំខាន់នៃទីក្រុងនៅក្នុងស្រុកសូរ៉ូធី ដើម្បីធានាឲ្យមានការចេញចូលផ្នែករូបវន្តនៃអគារសាធារណៈ ។ ការតស៊ូ មតិដែលត្រូវបានបន្តដោយអង្គការមិនមែនរដ្ឋាភិបាលបាននាំទៅដល់ការសាងសង់ច្រកចូលបន្ថែមនៅក្នុងទីក្រុងនិង
- ការិយាល័យប្រចាំប្រទេសបានផ្តល់ការបណ្តុះបណ្តាលដល់ជនពិការស្តីពីស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ក្នុងស្រុក និងគោលនយោបាយពាក់ព័ន្ធ ដោយរៀបចំឲ្យមានសម្ភារៈឯកសារពាក់ព័ន្ធនឹងអក្សរសម្រាប់មនុស្សពិការភ្នែក ឬអក្សរស្ទាប (Braille) ។

## ២. ការិយាល័យតំបន់

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ព្យាយាមកំណត់អំពីបញ្ហាកង្វល់ផ្នែកសិទ្ធិមនុស្ស ដែលមានសារៈសំខាន់ចំពោះប្រទេសនៅក្នុងតំបន់ ។ បន្ទាប់មក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស អាចផ្តល់ជំនួយទាំងចំពោះតំបន់ និងប្រទេស តាមរយៈការលើកកម្ពស់ការចែករំលែក និងការផ្សព្វផ្សាយបទពិសោធន៍ និងវិធីអនុវត្តន៍ត្រឹមត្រូវ ។ ការិយាល័យតំបន់របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ក៏ជាប្រភពនៃជំនាញប្រធានបទ និងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នតំបន់ និងរដ្ឋាភិបាល ក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងតំបន់ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងសង្គមស៊ីវិល ។

## ៣. ផ្នែកសិទ្ធិមនុស្សនៃបេសកកម្មសន្តិភាពអង្គការសហប្រជាជាតិ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ចូលរួមពាក់ព័ន្ធក្នុងការរក្សាសន្តិភាព និងការកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ និងបំពេញតួនាទីដ៏សំខាន់នៅក្នុងផ្នែកសិទ្ធិមនុស្សនៃប្រតិបត្តិការដ៏ស្មុគស្មាញនៅមូលដ្ឋាន ដែលត្រូវបានគ្រប់គ្រងដោយផ្នែកប្រតិបត្តិការរក្សាសន្តិភាព និងកិច្ចការនយោបាយនៃអង្គការសហប្រជាជាតិ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏រួមចំណែកក្នុងការងាររបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលទទួលខុសត្រូវចំពោះសន្តិភាព និងសន្តិសុខអន្តរជាតិ ។ តួនាទីទាំងនេះ បង្ហាញអំពីទីតាំងកណ្តាល ដែលសិទ្ធិមនុស្សមាននៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការងាររបស់អង្គការសហប្រជាជាតិ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានកំណត់អាទិភាពចំនួនបួន ដែលខ្លួនព្យាយាមធ្វើសមាហរណកម្មចូលទៅក្នុងបេសកកម្មសន្តិភាពៈ

- ការធានាឲ្យមានយុត្តិធម៌ និងគណនេយ្យភាពនៅក្នុងដំណើរការសន្តិភាព ។
- ការទប់ស្កាត់ និងការជួសជុលសងការរំលោភបំពានលើសិទ្ធិមនុស្ស ។
- ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័នជាតិ និង
- ការបញ្ជ្រាបបញ្ហាសិទ្ធិមនុស្សទៅក្នុងកម្មវិធីទាំងអស់របស់អង្គការសហប្រជាជាតិ ។

## ការធ្វើការងារជាមួយនឹងបេសកកម្មអង្គការសហប្រជាជាតិនៅស៊ូដង់លើផ្នែកសិទ្ធិស្ត្រី

ចាប់តាំងពីខែ មីនា ឆ្នាំ ២០០៨ មក ការិយាល័យសិទ្ធិមនុស្ស នៃបេសកកម្មអង្គការសហប្រជាជាតិ ប្រចាំប្រទេសស៊ូដង់ (UNMI- S) បានផលិតកម្មវិធីវិទ្យុ ដោយធ្វើសហប្រតិបត្តិការជាមួយនឹងក្រុមតស៊ូមតិដើម្បីស្ត្រីក្រុងម៉ាឡាកាល់ និងវ៉េឌីអូម៉ាឡាកាល់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី ជាពិសេស សិទ្ធិរបស់ពួកគេក្នុងការរស់រានមានជីវិតរួចផុតពីអំពើហិង្សាដែលមានមូលដ្ឋាននៅលើយេនឌ័រ ។ សមាជិកសភានីតិកម្មនៃរដ្ឋអាប់ភើនីល និងសកម្មជនសង្គមស៊ីវិល ផ្តោតទៅលើកម្មវិធីនេះ ។ កិច្ចផ្តួចផ្តើម ត្រូវបានបញ្ចូលទៅក្នុងសិក្ខាសាលារបស់សហគមន៍មូលដ្ឋាន ។

## ៤. ផ្នែកទីប្រឹក្សាសិទ្ធិមនុស្សនៅក្នុងក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ

ទីប្រឹក្សាសិទ្ធិមនុស្ស ជាមន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីគាំទ្រក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ តាមការស្នើសុំរបស់មន្ត្រីសម្របសម្រួលប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ ។ ពួកគេណែនាំអំពីយុទ្ធសាស្ត្រដើម្បីកសាង ឬពង្រឹងសមត្ថភាពរបស់ប្រទេស និងស្ថាប័ន ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ។ ទីប្រឹក្សាសិទ្ធិមនុស្ស ក៏ចូលរួមពាក់ព័ន្ធផងដែរជាមួយនឹងតួអង្គជាតិ (រដ្ឋាភិបាល និងសង្គមស៊ីវិល) លើវិធីលើកកម្ពស់ និងអនុវត្តស្តង់ដាសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព ។

## ៥. ផ្នែកឆ្លើយតបរហ័សទៅនឹងវិបត្តិសិទ្ធិមនុស្សដែលលេចឡើង

ដោយរួមទាំងការចូលរួមពាក់ព័ន្ធជាមួយនឹងប្រទេសនានា តាមរយៈ ការិយាល័យបច្ចុប្បន្ននៅមូលដ្ឋាន អង្គភាពឆ្លើយតបរហ័សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដាក់ពង្រាយបុគ្គលិកដែលត្រូវបានបណ្តុះបណ្តាល ដើម្បីជួយក្នុងការទប់ស្កាត់ ឬ ឆ្លើយតបទៅនឹងស្ថានភាពសិទ្ធិមនុស្សដែលកាន់តែធ្ងន់ធ្ងរនៅទូទាំងសកលលោក ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) អាចរៀបចំ ឬ គាំទ្របេសកកម្មស្វែងរកការពិត និងគណៈកម្មការស៊ើបសួរ ដើម្បីស៊ើបអង្កេតទឡ្ហីករណ៍ធ្ងន់ធ្ងរនៃការរំលោភបំពានលើសិទ្ធិមនុស្ស ។

អង្គភាព ក៏បំពេញមុខងារជាអ្នកដែលបម្រើជាមណ្ឌលសកម្មភាពផងដែរ សម្រាប់ការចូលរួមពាក់ព័ន្ធរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាមួយនឹងផ្នែកសិទ្ធិមនុស្សនៃបេសកកម្មសន្តិភាព ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ

មនុស្ស (OHCHR) បានគាំទ្រ តាមរយៈការផ្តល់ជំនួយទាក់ទងនឹងការជ្រើសរើសបុគ្គលិក ការប្រគល់តំណែង និងការបណ្តុះបណ្តាល ក៏ដូចជា ការណែនាំលើគោលនយោបាយ និងកម្មវិធីសំខាន់ៗ ។

## កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានរៀបចំបង្កើតឡើងនូវកម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាល ដើម្បីជួយបង្កើនតួនាទី និងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងយន្តការសិទ្ធិមនុស្ស ។ កម្មវិធីទាំងនេះ គឺៈ

- **កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**
- **កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច**
- **កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សសម្រាប់ប្រទេសក្រីក្រ និងទន់ខ្សោយបំផុត** និង
- **កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

i

សម្រាប់ព័ត៌មានបន្ថែមស្តីពី**កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលរបស់ការិយាល័យឧត្តម-ស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** សូមមើលជំពូក II នៃ *សៀវភៅ*នេះ ។

## អត្ថបទបោះពុម្ពផ្សាយ និងធនធានសម្ភារៈរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានបោះពុម្ពផ្សាយអត្ថបទដ៏ច្រើនសន្ធឹកសន្ធាប់ទាក់ទងនឹងសិទ្ធិមនុស្ស ដែលផ្តល់ព័ត៌មានដែលមានផលប្រយោជន៍ដល់រដ្ឋាភិបាល ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) សង្គមស៊ីវិល សាធារណជនទូទៅ និងប្រព័ន្ធផ្សព្វផ្សាយ ។ អត្ថបទបោះពុម្ពផ្សាយ និងធនធានជាច្រើន ត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ពីវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ឬ អាចត្រូវបានស្នើសុំពី**ការិយាល័យផ្នែកអត្ថបទបោះពុម្ពផ្សាយ និងព័ត៌មាន**នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

i

សម្រាប់ព័ត៌មានបន្ថែមស្តីពី***អត្ថបទបោះពុម្ពផ្សាយ និងធនធានសម្ភារៈរបស់ការិយាល័យឧត្តម-ស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)*** *សូមមើលជំពូក III នៃ សៀវភៅនេះ* និងទាក់ទងតាមរយៈ **publications@ohchr.org** ឬ **library@ohchr.org**

## មូលនិធិ និងជំនួយ

មូលនិធិ និងជំនួយរបស់អង្គការសហប្រជាជាតិ ដែលខ្លះត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នោះ ផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់អង្គការមិនមែនរដ្ឋាភិបាល អង្គការមហាជន សមាគមអ្នកវិជ្ជាជីវៈ និងតួអង្គសង្គមស៊ីវិលដទៃទៀត ។

មូលនិធិ និងជំនួយ ដែលត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គឺៈ

- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម**
- **មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច**
- **មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់ទំនើបនៃទាសភាព**
- **គម្រោង "ជួយសហគមន៍រួម" (ACT)**

> i សម្រាប់ព័ត៌មានបន្ថែមស្តីពី**មូលនិធិ និងជំនួយ** សូមមើល**ជំពូក IX** នៃ*សៀវភៅ*នេះ ។

# ឃ. រចនាសម្ព័ន្ធរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវបានដឹកនាំដោយឧត្តមស្នងការ និងឧត្តមស្នងការរង ។ ទាំងពីរ ត្រូវបានគាំទ្រ តាមរយៈការងាររបស់ពួកគាត់ ដោយ**ការិយាល័យប្រតិបត្តិ** ដែលជាផ្នែកមួយនៃ**សាខាដឹកនាំប្រតិបត្តិ និងគ្រប់គ្រង**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

សាខាដឹកនាំប្រតិបត្តិ និងគ្រប់គ្រង ក៏រួមបញ្ចូលផងដែរនូវៈ

- **ការិយាល័យក្រុងញូវយ៉ក** ដែលខិតខំពុះពារ ដើម្បី ធានាថា សិទ្ធិមនុស្ស ត្រូវបានធ្វើសមាហរណកម្មដោយពេញលេញទៅក្នុងរបៀបវារៈរបស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ និងសន្តិសុខ និងផ្តល់ជំនួយគាំទ្រដ៏សំខាន់ផ្នែកបញ្ហាសិទ្ធិមនុស្សដល់មហាសន្និបាតអង្គការសហប្រជាជាតិ **ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ក្រុមប្រឹក្សាសន្តិសុខ** និងស្ថាប័ន អន្តររដ្ឋាភិបាលដទៃទៀត ។
- **ផ្នែកគោលនយោបាយ ផែនការ ពិនិត្យតាមដាន និងវាយតម្លៃ** ដែលធ្វើការងារជាមួយនឹងបុគ្គលិករបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីធានាថា ចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ការិយាល័យ ត្រូវបានប្រែក្លាយទៅជាអាទិភាពពិតជាក់ស្តែង

និងផែនការប្រតិបត្តិ និងថាផលប៉ះពាល់ត្រូវបានពិនិត្យតាមដាន និងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាព ។

- **ផ្នែកទំនាក់ទំនង** ដែលបង្កើត និងអនុវត្តយុទ្ធសាស្ត្រ ដើម្បីធ្វើឲ្យប្រសើរឡើងនូវចំណេះដឹងទូទៅផ្នែកសិទ្ធិមនុស្ស និងជម្រាបដល់សហគមន៍អន្តរជាតិអំពីហេតុការណ៍វិវត្តន៍ថ្មីៗផ្នែកសិទ្ធិមនុស្ស និងការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។
- **ផ្នែកជំនួយ និងទំនាក់ទំនងការបរទេស** ដែលខិតខំពុះពារ ដើម្បីធានាថា រដ្ឋសមាជិក ត្រូវបានបន្តផ្តល់ព័ត៌មានដោយពេញលេញអំពីផែនការ អាទិភាព និងតម្រូវការមូលនិធិជំនួយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងកៀងគរធនធាន ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។
- **ផ្នែកសុវត្ថិភាព និងសន្តិសុខនៅមូលដ្ឋាន** ដែលទទួលខុសត្រូវចំពោះការធានាឲ្យមានសន្តិសុខសម្រាប់បុគ្គលិក និងការិយាល័យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

**អង្គភាពសង្គមស៊ីវិល**ដែលត្រូវបានបង្កើតឡើងថ្មីៗនេះ ក៏ជាផ្នែកមួយផងដែរនៃសាខាដឹកនាំប្រតិបត្តិ និងគ្រប់គ្រង ។ វា គឺជាចំណុចច្រកចូលដ៏សំខាន់សម្រាប់តួអង្គសង្គមស៊ីវិល ដែលមានបំណងប្រាថ្នាចង់ទាក់ទងនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ អង្គភាពសង្គមស៊ីវិល ផ្តល់ព័ត៌មាន និងការណែនាំអំពីបញ្ហាដ៏ច្រើនសន្ធឹកសន្ធាប់ ណែនាំអំពីគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងបង្កើតមធ្យោបាយ ដើម្បីជួយសង្គមស៊ីវិលក្នុងការចូលរួមពាក់ព័ន្ធជាមួយនឹងស្ថាប័ន និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែល*សៀវភៅ*នេះ គឺជាឧទាហរណ៍បឋម ។

**សេវាគាំទ្រ និងគ្រប់គ្រងកម្មវិធី**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់ការគាំទ្រក្នុងការធ្វើផែនការថវិកា និងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ការជ្រើសរើសបុគ្គលិក និងធនធានមនុស្ស លទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការគាំទ្រផ្នែកភស្តុភារទូទៅសម្រាប់សកម្មភាពនៅមូលដ្ឋាន បច្ចេកវិជ្ជាព័ត៌មាន និង ការអភិវឌ្ឍ និងការបណ្តុះបណ្តាលបុគ្គលិក ។

ដោយរួមទាំងសាខាដឹកនាំប្រតិបត្តិ និងគ្រប់គ្រង និងសេវាគាំទ្រ និងគ្រប់គ្រងកម្មវិធី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានផ្នែកសំខាន់ៗបួនៈ

- **ផ្នែកក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសន្ធិសញ្ញា** ដែលធានាឲ្យមានការប្រព្រឹត្តទៅដោយរលូននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការមួយចំនួនរបស់វា និងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ វាក៏គាំទ្រសកម្មភាពដែលត្រូវបានអនុវត្ត តាមរយៈមូលនិធិស្ម័គ្រចិត្តសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម និងសម្របសម្រួលឲ្យមានកម្រងឯកសារផ្លូវការទាំងអស់ ដែលត្រូវបានរៀបចំសម្រាប់ស្ថាប័នអន្តររដ្ឋាភិបាលប្រើប្រាស់ ។
- **ផ្នែកយន្តការពិសេស** ដែលគាំទ្រដល់ការងាររបស់យន្តការពិសេស តាមរយៈ ការផ្តល់ជំនាញ ការស្រាវជ្រាវ និងការវិភាគប្រធានបទ ការស្វែងរកការពិត និងច្បាប់ និងជំនួយផ្នែករដ្ឋបាល និង

ភស្តុភារ ។ ផ្នែកនេះ ក៏សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងកិច្ចប្រជុំ រវាងអ្នកកាន់អាណត្តិ និងអ្នកពាក់ព័ន្ធ ក្នុងនោះរួមមាន សង្គមស៊ីវិលផងដែរ ។

- **ផ្នែកប្រតិបត្តិការ និងសហប្រតិបត្តិការបច្ចេកទេសនៅមូលដ្ឋាន** ដែលសម្របសម្រួលដល់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រចូលរួមរបស់ប្រទេសរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គ្រប់គ្រងកម្មវិធីសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួន និង បំពេញមុខងារជាចំណុចច្រកចូល សម្រាប់ការិយាល័យនៅមូលដ្ឋាន របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និង
- **ផ្នែកស្រាវជ្រាវ និងសិទ្ធិទទួលបានការអភិវឌ្ឍ** ដែលអនុវត្តការស្រាវជ្រាវប្រធានបទស្តីពីសិទ្ធិមនុស្សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងនោះរួមមានតាមរយៈការផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេសដល់មូលដ្ឋានផងដែរ ។ ផ្នែកនេះ ក៏គ្រប់គ្រងផងដែរនូវកម្មវិធីមជ្ឈមណ្ឌលឯកសារ និងអត្ថបទបោះពុម្ពផ្សាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដោយផលិតឧបករណ៍វិធីសាស្ត្រ និង កញ្ចប់សិក្សាជាច្រើនសម្រាប់ប្រើប្រាស់នៅតាមបណ្តាប្រទេស និងទីស្នាក់ការធំ ដើម្បីកសាងសមត្ថភាពរបស់ស្ថាប័នជាតិ សង្គមស៊ីវិល និងដៃគូដទៃទៀត ។

## ខ. ធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ( OHCHR )

### វិបសាយរបស់ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ( OHCHR )

តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្ត ឲ្យចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីរកព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីការងារ និងសកម្មភាពរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ក្នុងនោះរួមមាន ព័ត៌មានស្តីពីយន្តការសិទ្ធិមនុស្សផ្សេងៗ ។ **របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព និង លទ្ធផល**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និង **ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្ររបស់ឧត្តមស្នងការ** ក៏មាននៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផងដែរ ។

*i* ចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org** ។

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

## ច. វិធីទាក់ទងនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

### អាសយដ្ឋានសម្រាប់ចូលជួប

**វិមានវេដ្ឋវីលសុន**
52 rue des Pâquis
CH- 1201 ទីក្រុងហ្សឺណែវ ប្រទេសស្វីស

**អគារម៉ូតា**
48 avenue Giuseppe Motta
CH- 1202 ទីក្រុងហ្សឺណែវ ប្រទេសស្វីស

**អាសយដ្ឋានទំនាក់ទំនងតាមប្រៃសណីយ៍**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10
ទូរស័ព្ទលេខ: +៤១ (0)២២ ៩១៧ ៩0 00
អ៊ីម៉ែល: InforDesk@ohchr.org (ការសាកសួរទូទៅ)
វ៉ិបសាយ: **http://www.ohchr.org**

# II. កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ( OHCHR )

កម្មវិធីអាហារូបករណ៍ និងបណ្តុះបណ្តាលដែលត្រូវបានពិភាក្សានៅក្នុងជំពូកនេះ ត្រូវបានបង្កើតឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីបង្កើនតួនាទី និងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងយន្តការសិទ្ធិមនុស្ស ។ ការរួមចំណែក និងការចូលរួមពាក់ព័ន្ធដ៏សកម្មរបស់សង្គមស៊ីវិល រួមចំណែកក្នុងការសម្រេចបានកាន់តែខ្លាំងក្លានូវសិទ្ធិមនុស្ស ។ ជំពូកនេះ មានបញ្ចូលព័ត៌មានសំខាន់ ដែលតួអង្គសង្គមស៊ីវិល ត្រូវការចាំបាច់ ដើម្បីចូលរួមក្នុងកម្មវិធីអាហារូបករណ៍ និងសិក្ខាសាលាពិភាក្សា សម្រាប់ការបណ្តុះបណ្តាលរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

**ឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ (ECOSOC) មិនមែនជាតម្រូវការសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលដទៃទៀតដើម្បីចូលរួម ឬ ប្រើប្រាស់កម្មវិធី និងសិក្ខាសាលា ដែលត្រូវបានពិភាក្សានៅក្នុងជំពូកនេះទេ ។**

## ក. កម្មវិធីអាហារូបករណ៍

**កម្មវិធីអាហារូបករណ៍** ផ្តល់ដល់បុគ្គលទាំងឡាយដែលត្រូវបានជ្រើសរើសនូវឱកាសសិក្សាដោយបង្ខំរយៈពេលខ្លីអំពីយន្តការសិទ្ធិមនុស្ស និងស្ថាប័នអន្តរជាតិ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គ្រប់គ្រងកម្មវិធីអាហារូបករណ៍ចំនួនបួន ។ កម្មវិធីទាំងនេះ មានគោលបំណងពង្រឹងសមត្ថភាពរបស់ក្រុម ឬ បុគ្គលពិសេសលើផ្នែកការងារសិទ្ធិមនុស្សៈ

- **កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច** គាំទ្រសមាជិកក្រុមជនជាតិដើមភាគតិចឲ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្ស ។
- **កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច** គាំទ្រដល់បុគ្គលដែលជារបស់ក្រុមជនភាគតិចជាតិជនជាតិ សាសនា ឬ ភាសា ដើម្បីចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្ស ។
- **កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សសម្រាប់ប្រទេសក្រីក្រ និងទន់ខ្សោយបំផុត** គាំទ្រដល់និស្សិតផ្នែកជាន់ខ្ពស់នៃមហាវិទ្យាល័យមកពីប្រទេសក្រីក្រ និងទន់ខ្សោយបំផុត (LDC) ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីអង្គការសហប្រជាជាតិ និងសិទ្ធិមនុស្ស និង

- **កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស** គាំទ្រដល់បុគ្គលិកមកពីស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) នៅក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ។

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

## i ព័ត៌មានទំនាក់ទំនងផ្នែកអាហារូបករណ៍

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**
**អង្គភាពជនជាតិដើមភាគតិច និងក្រុមជនភាគតិច**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩០ ០៨ ឬ +៤១ (0)២២ ៩២៨ ៩០ ៦៦
អ៊ីម៉ែល: **fellowship@ohchr.org**

**កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច**
**អង្គភាពជនជាតិដើមភាគតិច និងក្រុមជនភាគតិច**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩២៨ ៩៨ ៤៥
ទូរសារលេខ: +៤១ (0)២២ ៩២៨ ៩០ ១០
អ៊ីម៉ែល: **minorities@ohchr.org**

**កម្មវិធីអាហារូបករណ៍សម្រាប់និស្សិតប្រទេសក្រីក្រ និងតំបន់ខ្សោយបំផុត**
**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវនៃអង្គការសហប្រជាជាតិ (UNITAR)**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩១៧ ៨៦ ៤០
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៨០ ៤៧
វិបសាយ: **http://www.ohchr.org** ឬ **http://www.unitar.org/diplomacy**

**កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI)**
**អង្គភាពស្ថាប័នជាតិ**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10- ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩២៨ ៩២ ៨៣ ឬ +៤១ (0)២២ ៩២៨ ៩៦ ៦៣
ទូរសារលេខ: +៤១ (0)២២ ៩២៨ ៩០ ១៨
អ៊ីម៉ែល: **niu@ohchr.org**

## ១. កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច** បានចាប់ផ្ដើមនៅក្នុងឆ្នាំ ១៩៩៧ ជាកិច្ចផ្តួចផ្តើមរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីអនុវត្តគោលដៅនៃទសវត្សរ៍អន្តរជាតិរបស់ជនជាតិដើមភាគតិចពិភពលោក (ពីឆ្នាំ១៩៩៥-២០០៤) រួមជាមួយនឹងទិសដៅដំបូងនៃការផ្តល់សិទ្ធិអំណាចដល់តំណាងជនជាតិដើមភាគតិច និងសហគមន៍របស់ពួកគេ តាមរយៈ ការពង្រឹងចំណេះដឹង និងសមត្ថភាពរបស់ពួកគេ ក្នុងការប្រើប្រាស់ប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ។

កម្មវិធីនេះ មានគោលបំណងផ្តល់ដល់ស្ត្រី និងបុរសជនជាតិដើមភាគតិចនូវឱកាសទទួលបានចំណេះដឹងអំពីសិទ្ធិមនុស្សអន្តរជាតិជារួម និងសិទ្ធិរបស់ជនជាតិដើមភាគតិច ដោយឡែក ដើម្បីជួយអង្គការ និងសហគមន៍របស់ពួកគេ ឲ្យការពារ និងលើកកម្ពស់កាន់តែល្អប្រសើរនូវសិទ្ធិរបស់ពួកគេ ។ នៅចុងបញ្ចប់នៃកម្មវិធីនេះ និស្សិត គួរតែអាចផ្តល់បាននូវការបណ្តុះបណ្តាលនៅក្នុងសហគមន៍ និងអង្គការរបស់ពួកគេអំពីសិទ្ធិមនុស្សអន្តរជាតិជារួម និងសិទ្ធិរបស់ជនជាតិដើមភាគតិច ដោយឡែក និងអាចផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹងដែលត្រូវបានទទួលនៅក្នុងអំឡុងកម្មវិធីអាហារូបករណ៍របស់ពួកគេ ។ កម្មវិធីនេះ មានគោលបំណងផ្តល់ប្រយោជន៍ដល់បុគ្គលខ្លួនឯង អង្គការរបស់ពួកគេ ប៉ុន្តែសំខាន់បំផុតនោះគឺ សហគមន៍របស់ពួកគេ។

កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច អនុវត្តជាបួនភាសាៈ **ភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ** ។ ក្នុងឆ្នាំនីមួយៗ និស្សិតប្រហែលប្រាំនាក់ ត្រូវបានជ្រើសរើសសម្រាប់ទម្រង់ភាសានីមួយៗនៃកម្មវិធីនេះ ។

- កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ (ជា**ភាសាអង់គ្លេស**) ។
- កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងដឺស្តូ (ជា**ភាសាអេស្ប៉ាញ**) ។
- កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងឪចុង (ជា**ភាសាបារាំង**) ។
- កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងម៉ូស្គូ (ជា**ភាសារុស្ស៊ី**) ។

***កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ*** ត្រូវបានអនុវត្តដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅទីក្រុងហ្សឺណែវ ។ ដោយចាប់ផ្តើមនៅក្នុងខែឧសភា ក្នុងមួយឆ្នាំៗ និងជាទូទៅ មានរយៈពេលបួនខែ វាជាវគ្គសិក្សាដោយបង្ហំរយៈពេលខ្លីលើផ្នែកយន្តការ និងស្ថាប័នសិទ្ធិមនុស្ស ។ កម្មវិធីនេះ តម្រូវឲ្យមានសកម្មភាពទំនាក់ទំនងគ្នាទៅវិញទៅមក និងមានការពន្យល់ប្រាប់ដោយសង្ខេបអំពីប្រធានបទផ្សេងៗ និងកិច្ចការជាបុគ្គល និងក្រុម ។

***កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងដឺស្តូ*** គឺជាកិច្ចផ្តួចផ្តើមរួមរបស់សកលវិទ្យាល័យដឺស្តូ នៅក្នុងទីក្រុងបាល់បាវ ប្រទេសអេស្ប៉ាញ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ ជាទូទៅ វា មានរយៈពេលបួនខែ និងមានពីរវគ្គៈ វគ្គទីមួយ ត្រូវបានអនុវត្តនៅឯសកល

វិទ្យាល័យដឹស្តូ និងវគ្គទីពីរ នៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ ។ វាមានរចនាសម្ព័ន្ធស្រដៀងគ្នានឹងកម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវដែរ ទន្ទឹមនឹងនេះ ក៏ព្យាយាមផងដែរក្នុងការជំរុញលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរគ្នាទៅវិញទៅមក រវាងនិស្សិត និងអង្គការពាក់ព័ន្ធផ្សេងទៀត ដូចជា អង្គការមិនមែនរដ្ឋាភិបាលបាស្គ និងរដ្ឋាភិបាលបាស្គ ។

**កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងឌឺចុង** គឺជាកិច្ចផ្តួចផ្តើមរួមរបស់សកលវិទ្យាល័យបឺហ្គូញ នៅក្នុងទីក្រុងឌឺចុង ប្រទេសបារាំង និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ហើយត្រូវបានរៀបចំឡើងសម្រាប់ជនជាតិដើមភាគតិច ដែលមានភាសាបារាំង ជាភាសាទីមួយ ឬទីពីររបស់ពួកគេ ។ កម្មវិធីនេះ មានរយៈពេល ១០ សប្តាហ៍ (៤ សប្តាហ៍នៅឯសកលវិទ្យាល័យឌឺចុង ៤ សប្តាហ៍នៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ និង ២សប្តាហ៍នៅឯអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ (UNESCO) ក្នុងទីក្រុងប៉ារីស) ។

**កម្មវិធីដែលមានមូលដ្ឋាននៅក្នុងទីក្រុងម៉ូស្គូ** គឺជាកិច្ចផ្តួចផ្តើមរបស់សមាគមរុស្ស៊ីនៃជនជាតិដើមភាគតិចភាគខាងជើង (RAIPON) នៅក្នុងទីក្រុងម៉ូស្គូ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ វគ្គសិក្សានៅក្នុងទីក្រុងម៉ូស្គូ មានការបណ្តុះបណ្តាលរយៈពេលបួនសប្តាហ៍ជាមួយនឹងសមាគមរុស្ស៊ីនៃជនជាតិដើមភាគតិចភាគខាងជើង (RAIPON) ការិយាល័យក្រុងម៉ូស្គូនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងការិយាល័យផ្សេងទៀតរបស់អង្គការសហប្រជាជាតិប្រចាំនៅទីក្រុងម៉ូស្គូ បន្ទាប់មកមានបួនសប្តាហ៍ទៀតនៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ ។

**កម្មវិធីអាហារូបករណ៍ទាំងអស់ ផ្តល់ជំនួយទ្រទ្រង់ជីវភាពប្រចាំខែសម្រាប់ការស្នាក់នៅសមរម្យ ការធ្វើដំណើរ ការធានារ៉ាប់រងសុខភាព និងចំណាយទ្រទ្រង់ជីវភាពផ្សេងទៀត ។**

## លក្ខណាវិនិច្ឆ័យនៃការជ្រើសរើស

- បេក្ខជន ត្រូវតែជាសមាជិកនៃក្រុមជនជាតិដើមភាគតិច និងគួរតែត្រូវបានគាំទ្រដោយសហគមន៍ ឬអង្គការជនជាតិដើមភាគតិចរបស់ពួកគេ ។
- ទោះបីជាអាយុ មិនមែនជាការកម្រិតលក្ខខណ្ឌក៏ដោយ ក៏អាទិភាព ត្រូវបានផ្តល់ជូនទៅបេក្ខជនដែលមានអាយុចន្លោះ ២៥ ឆ្នាំ និង ៣៥ ឆ្នាំ ។
- កង្វះការអប់រំក្នុងប្រព័ន្ធ មិនមែនជាការកម្រិតលក្ខខណ្ឌ សម្រាប់ការចូលរួមនៅក្នុងកម្មវិធីអាហារូបករណ៍ទេ ដោយពិចារណាទៅលើឧបសគ្គផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ចំពោះការអប់រំបែបនេះ ដែលជនជាតិដើមភាគតិចជាច្រើនប្រឈមមុខ ។

- បេក្ខជន គួរតែមានសមត្ថភាព និងការស្ម័គ្រចិត្តបណ្តុះបណ្តាលជនជាតិដើមភាគតិចផ្សេងទៀត នៅពេលដែលពួកគេ ត្រឡប់មកករកសហាគមន៍/អង្គការរបស់ពួកគេវិញ ។
- វាជាបំណងប្រាថ្នាថា អង្គការដែលជួយឧបត្ថម្ភ មានក្រុមគាំទ្រផ្នែកនយោបាយដ៏រឹងមាំ ឬ សមាជិកភាព ។
- ការជ្រើសរើសនិស្សិត គួរតែឆ្លុះបញ្ចាំងអំពីតុល្យភាពយេនឌ័រ និងតំបន់ និង
- បេក្ខជន ត្រូវតែមានការយល់ដឹងច្បាស់លាស់លើផ្នែកភាសា ដែលត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីអាហារូបករណ៍ ។

**ទម្រង់ភាសាបួននៃកម្មវិធី ត្រូវបានប្រើប្រាស់រៀងរាល់ឆ្នាំ និងពេលកំណត់ឈប់ទទួលសំណុំឯកសារសុំអាហារូបករណ៍ មានការផ្លាស់ប្តូរ ។ មានតែសំណុំឯកសារសុំអាហារូបករណ៍ដែលត្រូវបានបំពេញដោយពេញលេញប៉ុណ្ណោះ ដែលនឹងត្រូវបានពិចារណា ។ សំណុំឯកសារសុំអាហារូបករណ៍ ត្រូវតែត្រូវបានបញ្ជូនតាមទូរសារ ឬ ប៉ុស្តិ៍ប្រៃសណីយ៍ធម្មតា ។ សំណុំឯកសារសុំអាហារូបករណ៍ ដែលត្រូវបានបញ្ជូនតាមអ៊ីម៉ែល នឹងមិនត្រូវបានពិចារណាឡើយ លុះត្រាតែភាគ I និង II នៃសំណុំឯកសារសុំអាហារូបករណ៍ ត្រូវបានចុះហត្ថលេខា និងត្រូវបានស្កែន ។**

### *i* ទីកន្លែងដែលត្រូវដាក់ជូនពិនិត្យសំណុំឯកសារសុំអាហារូបករណ៍

**កម្មវិធីអាហារូបករណ៍សម្រាប់ជនជាតិដើមភាគតិច**

**អង្គភាពជនជាតិដើមភាគតិច និងក្រុមជនភាគតិច**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩0 0៨ ឬ +៤១ (0)២២ ៩២៨ ៩0 ៦៦
អ៊ីម៉ែល: **fellowship@ohchr.org**

ប្រសិនបើចង់ដឹងព័ត៌មានបន្ថែមស្តីពី**កម្មវិធីអាហារូបករណ៍** និងចង់បានទម្រង់ឯកសារសុំអាហារូបករណ៍ទាំងអស់បួនភាសា ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ២. កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច

តាមរយៈ**កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច** ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានគោលបំណងផ្តល់ដល់បុគ្គលទាំងឡាយដែលជារបស់ក្រុមជនភាគតិចជាតិ ឬ ជាតិពន្ធុ សាសនា និងភាសា ជាពិសេស ស្ត្រីវ័យក្មេង និងបុរស នូវឱកាសទទួលបានចំណេះដឹងអំពីសិទ្ធិមនុស្សអន្តរជាតិជារួម និងសិទ្ធិរបស់ជនភាគតិចដោយឡែក ។ វាត្រូវបានគេរំពឹងថា នៅពេលចប់កម្មវិធីនេះ និស្សិតជនភាគតិច នឹងទទួលបានចំណេះដឹងទូទៅអំពីយន្តការសិទ្ធិមនុស្សនៃអង្គការ

សហប្រជាជាតិ ពីព្រោះវាទាក់ទងទៅនឹងបញ្ហាពាក់ព័ន្ធនឹងក្រុមជនភាគតិច និងមានសមត្ថភាពផ្តល់ការបណ្តុះបណ្តាលនៅក្នុងសហគមន៍ និងអង្គការរបស់ពួកគេលើព័ត៌មាន និងចំណេះដឹងដែលត្រូវបានទទួលបានក្នុងអំឡុងពេលវគ្គសិក្សាអាហារូបករណ៍របស់ពួកគេ ។

## ការបណ្តុះបណ្តាលដែលត្រូវបានដឹកនាំដោយសហគមន៍នៅក្នុងប្រទេសប៊ុលហ្គារី ដោយអតីតនិស្សិតជនភាគតិច

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានគាំទ្រគម្រោង ដែលត្រូវបានដាក់ជូនពិនិត្យដោយអតីតនិស្សិតជនភាគតិចមកពីសហគមន៍រ៉ូម៉ា នៅក្នុងប្រទេស**ប៊ុលហ្គារី** ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលនៅក្នុងក្រុងប៉ុលស្តីត្រាំបិស្ស នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៦ ។ គម្រោងនេះ បានជួយ អង្គការរបស់គេដែលជាអង្គការ រួមរ៉ូម៉ាឲ្យអាចរៀបចំបាននូវសិក្ខាសាលាបណ្តុះបណ្តាលដើម្បីជំរុញឲ្យមានការចូលរួមនិងផ្តត់ផ្គង់ សហគមន៍រ៉ូម៉ានៅក្នុងមូលដ្ឋានក្នុងការដាក់ឲ្យអនុវត្តនូវ "ទសវត្សរ៍បរិយាប័ន្នរ៉ូម៉ាពីឆ្នាំ ២០០៥-២០១៥" ដូចដែលត្រូវបានកំណត់ដោយប្រទេសចំនួនប្រាំបួន នៅអឺរ៉ុបកណ្តាល និងអាគ្នេយ៍ ។ អ្នកចូលរួម បានរៀបចំយុទ្ធសាស្ត្រដើម្បីបង្កើនការចូលរួមរបស់រ៉ូម៉ានៅក្នុងការធ្វើសេចក្តីសម្រេចចិត្តជាផ្លូវការ ជាពិសេស នៅក្នុងតំបន់ដែលសិទ្ធិ និងជីវភាពប្រចាំថ្ងៃរបស់គេ ត្រូវបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ។ ពួកគេ បានស្នើឡើងថា ក្រុមប្រឹក្សាក្រុង គួរតែបង្កើតស្ថាប័នអចិន្ត្រៃយ៍នៃតំណាងជនភាគតិចនៅក្នុងមូលដ្ឋាន ដើម្បីផ្តល់ទិន្នន័យបញ្ចូលសម្រាប់ គោលនយោបាយពាក់ព័ន្ធនឹងបញ្ហារបស់ក្រុមជនភាគតិច និងនេះ ត្រូវបានទទួលយកដោយចៅហ្វាយក្រុង និងប្រធានក្រុមប្រឹក្សាក្រុង ។

បច្ចុប្បន្ននេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គ្រប់គ្រងកម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិចចំនួនពីរ ដែលមួយជាភាសាអង់គ្លេស និងមួយទៀតជាភាសាអារ៉ាប់ ។ កម្មវិធីជាភាសាអង់គ្លេស ត្រូវបានអនុវត្តរៀងរាល់ខែ មេសា សម្រាប់រយៈពេលបីខែ ដោយមាននិស្សិតចូលរួមប្រហែលប្រាំរូប ។ កម្មវិធីសាកល្បងជាភាសាអារ៉ាប់ ត្រូវបានអនុវត្តជាលើកដំបូងក្នុងឆ្នាំ ២០០៧ ដោយមាននិស្សិតចូលរួមចំនួនបួនរូប ដែលចូលរួមក្នុងការបណ្តុះបណ្តាលនៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ សម្រាប់រយៈពេលមួយខែ ។ កម្មវិធីអាហារូបករណ៍នេះ ផ្តល់ជំនួយទ្រទ្រង់ជីវភាពប្រចាំខែ ដើម្បីឲ្យមានគ្រប់គ្រាន់ល្មមសម្រាប់ការស្នាក់នៅសមរម្យ និងចំណាយទ្រទ្រង់ជីវភាពផ្សេងទៀត ការធ្វើដំណើរទៅ និងមកពីទីក្រុងហ្សឺណែវ និងការធានារ៉ាប់រងសុខភាព ។

### លក្ខណវិនិច្ឆ័យនៃការជ្រើសរើស

- បេក្ខជន ត្រូវតែជារបស់ក្រុមជនភាគតិចជាតិ ជាតិពន្ធុ សាសនា ឬ ភាសា ។
- ទោះបីជាអាយុ មិនមែនជាការកម្រិតលក្ខខណ្ឌក៏ដោយ ក៏អាទិភាព ត្រូវបានផ្តល់ជូនទៅបេក្ខជនដែលមានអាយុចន្លោះ ២៥ ឆ្នាំ និង ៣៥ ឆ្នាំ ។

- កង្វះការអប់រំក្នុងប្រព័ន្ធ មិនមែនជាការកម្រិតលក្ខខណ្ឌសម្រាប់ការចូលរួមក្នុងកម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិចទេ ប្រសិនបើបទពិសោធន៍ពាក់ព័ន្ធ អាចត្រូវបានបង្ហាញនោះ ។
- វាជាបំណងប្រាថ្នាថា អង្គការដែលជួយឧបត្ថម្ភ ឬ សមាគម ទទួលរ៉ាប់រងធ្វើការងារផ្នែកបញ្ហាក្រុមជនភាគតិច និងមានបុគ្គលដែលជារបស់ក្រុមជនភាគតិច ។
- បេក្ខជន គួរតែមានសមត្ថភាព និងការស្ម័គ្រចិត្តបណ្តុះបណ្តាលបុគ្គលផ្សេងទៀតដែលជារបស់ក្រុមជនភាគតិច នៅពេលដែលពួកគេ ត្រឡប់មករកសហគមន៍/អង្គការរបស់ពួកគេវិញ ។
- បេក្ខជន គួរតែមានសំបុត្រអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសហគមន៍ ឬ អង្គការរបស់ពួកគេ ។
- បេក្ខជន ត្រូវតែមានការយល់ដឹងច្បាស់លាស់លើផ្នែកភាសា ដែលត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីនេះ (ជាភាសាអារ៉ាប់ ឬ អង់គ្លេស) ។

**មានតែសំណុំឯកសារសុំអាហារូបករណ៍ដែលត្រូវបានបំពេញដោយពេញលេញប៉ុណ្ណោះ ដែលនឹងត្រូវបានពិចារណា ។ សំណុំឯកសារសុំអាហារូបករណ៍ ត្រូវតែត្រូវបានបញ្ជូនតាមទូរសារ ឬ ប៉ុស្តិ៍ប្រៃសណីយ៍ធម្មតា ។ សំណុំឯកសារសុំអាហារូបករណ៍ ដែលត្រូវបានបញ្ជូនតាមអ៊ីម៉ែល នឹងមិនត្រូវបាពិចារណាឡើយ លុះត្រាតែសំណុំឯកសារសុំអាហារូបករណ៍ទាំងនោះ ត្រូវបានចុះហត្ថលេខា និងត្រូវបានស្កែន ។**

## i ទីកន្លែងដែលត្រូវដាក់ជូនពិនិត្យសំណុំឯកសារសុំអាហារូបករណ៍

**កម្មវិធីអាហារូបករណ៍សម្រាប់ក្រុមជនភាគតិច**
**អង្គភាពជនជាតិដើមភាគតិច និងក្រុមជនភាគតិច**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩២៨ ៩៨ ៤៥
ទូរសារលេខ: +៤១ (0)២២ ៩២៨ ៩0 ១0
អ៊ីម៉ែល: **minorities@ohchr.org**

ដើម្បីដឹងព័ត៌មានបន្ថែមស្តីពី**កម្មវិធីអាហារូបករណ៍** និងចង់បានទម្រង់ឯកសារសុំអាហារូបករណ៍ ចូរចូលមើលវ៉ិបសាយ របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ។

## ៣. កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សសម្រាប់ប្រទេសក្រីក្រ និងទន់ខ្សោយបំផុត

**កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សសម្រាប់និស្សិតមកពីប្រទេសក្រីក្រ និងទន់ខ្សោយបំផុត** (LDC) ដែលត្រូវបានអនុវត្តជាលើកដំបូង នៅក្នុងឆ្នាំ២០០៧ ត្រូវបានគ្រប់គ្រងរួមដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវនៃអង្គការសហប្រជាជាតិ (UNITAR) ។ គោលបំណង គឺដើម្បីបង្កើនការស្វែងយល់របស់និស្សិតនៃប្រទេសក្រីក្រ និងទន់ខ្សោយបំផុត (LDC) លើបញ្ហាសិទ្ធិមនុស្សបច្ចុប្បន្ននៅថ្នាក់អន្តរជាតិ និងផ្ដល់ដល់ពួកគេនូវការយល់ដឹងជ្រៅជ្រះអំពីការងាររបស់អង្គការសហប្រជាជាតិ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ដូចជា ដើម្បីផ្ដល់ដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនូវជំនួយ និងការរួមចំណែករបស់និស្សិត ឬ និស្សិតផ្នែកជាន់ខ្ពស់ដ៏ឆ្នើមនៃមហាវិទ្យាល័យមកពីប្រទេសក្រីក្រ និងទន់ខ្សោយបំផុត (LDC) ។

កម្មវិធីនេះ ដំណើរការទៅនៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ និងត្រូវបានអនុវត្តជាភាសាអង់គ្លេស ។ វា មានទាំងការបណ្ដុះបណ្ដាល និងផ្នែកអនុវត្តន៍លើការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាទម្រង់សិក្ខាសាលា និងការប្រើប្រាស់ជំនាញជាក់ស្ដែង បន្ទាប់មកគឺ កិច្ចការជាមួយនឹងសាខារបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ ការបន្តកម្មវិធីអាហារូបករណ៍នេះនៅឆ្នាំខាងមុខ នឹងអាស្រ័យទៅលើមូលនិធិជំនួយដែលត្រូវបានរៀបចំឲ្យមាន ។

កម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្ស បើកចំហជូនបេក្ខជនមកពីប្រទេសក្រីក្រ និងទន់ខ្សោយបំផុត (LDC) ។[3] បេក្ខជន ត្រូវតែជានិស្សិតផ្នែកជាន់ខ្ពស់នៃមហាវិទ្យាល័យ ឬ អ្នកមានសញ្ញាជាន់ខ្ពស់នៃមហាវិទ្យាល័យលើវិស័យទាក់ទងនឹងការងាររបស់អង្គការសហប្រជាជាតិ (ដូចជាឧទាហរណ៍ៈ ច្បាប់អន្តរជាតិ វិទ្យាសាស្ត្រនយោបាយ វិទ្យាសាស្ត្រសង្គម ឬ ប្រវត្តិសាស្ត្រ) ។ បេក្ខជន ត្រូវតែមានអាយុក្រោម ៣០ ឆ្នាំ នៅពេលដែលពួកគេ ដាក់ជូនពិនិត្យសំណុំឯកសារសុំអាហារូបករណ៍ ។

ថ្លៃធ្វើដំណើរ ត្រូវបានទូទាត់ជូនដោយកម្មវិធីនេះ និងនិស្សិតទទួលបានអាហារូបករណ៍ ដើម្បីទូទាត់ចំណាយទ្រទ្រង់ជីវភាពរបស់ពួកគេនៅក្នុងទីក្រុងហ្សឺណែវ ។ ការរៀបចំទិដ្ឋាការ ការស្នាក់នៅ សុខភាព និងការធានារ៉ាប់រងនៅពេលមានគ្រោះថ្នាក់ ក៏ត្រូវបានផ្ដល់ជូនផងដែរ ។

ពីព្រោះការបន្តកម្មវិធីនេះ អាស្រ័យទៅលើការទទួលបានមូលនិធិជំនួយគ្រប់គ្រាន់នោះ បុគ្គលដែលមានការចាប់អារម្មណ៍ ត្រូវបានជំរុញលើកទឹកចិត្តឲ្យចូលពិនិត្យមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការ

[3] ប្រសិនបើចង់ដឹងព័ត៌មានបន្ថែមស្ដីពីលក្ខណវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់ដោយអង្គការសហប្រជាជាតិ ដើម្បីជ្រើសរើសប្រទេសក្រីក្រ និងទន់ខ្សោយបំផុត ចូរចូលមើល **http://www.unohrlls.org/** ។

អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវនៃអង្គការសហប្រជាជាតិ (UNITAR) ជាទៀងទាត់ ដើម្បីរកមើលព័ត៌មាន ។

i **វិធីទាក់ទងនឹងកម្មវិធីអាហារូបករណ៍ផ្នែកសិទ្ធិមនុស្សសម្រាប់ប្រទេសក្រីក្រ និងទន់ខ្សោយបំផុត**

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវនៃអង្គការសហប្រជាជាតិ ( UNITAR )**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៨៦ ៥0
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៨0 ៤៧

## ៤. កម្មវិធីអាហារូបករណ៍ សម្រាប់បុគ្គលិកស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស

**កម្មវិធីអាហារូបករណ៍សម្រាប់បុគ្គលិកស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស** ដែលត្រូវបានអនុវត្តជាលើកដំបូងនៅក្នុងឆ្នាំ ២00៨ ត្រូវបានគ្រប់គ្រងដោយ**អង្គភាពស្ថាប័នជាតិ**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ កម្មវិធី មានគោលបំណងផ្តល់ដល់និស្សិតចូលរួមនូវឱកាសទទួលបានចំណេះដឹង និងបទពិសោធន៍អនុវត្តន៍ជាក់ស្តែងលើប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ការងាររបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ជាមួយនិងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និង បញ្ហាបច្ចេកទេស និងសំខាន់ទាក់ទងនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ។ វាត្រូវបានគេរំពឹងថា និស្សិត នឹងត្រឡប់ទៅកាន់ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) របស់ពួកគេវិញ និងដោយហេតុនោះ ពង្រឹងសមត្ថភាពនៃអង្គការរបស់ពួកគេលើផ្នែកសិទ្ធិមនុស្សអន្តរជាតិ ។

កម្មវិធីនេះ ដំណើរការទៅនៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ ។ និស្សិតពីររូប ត្រូវបានជ្រើសរើសក្នុងមួយឆ្នាំ សម្រាប់រយៈពេលប្រាំមួយខែ ដោយនិស្សិតម្នាក់ចាប់ផ្តើមនៅក្នុងខែ មករា និងម្នាក់ទៀត នៅក្នុងខែ កក្កដា ។ និស្សិតទទួលបានការពន្យល់ប្រាប់ដោយសង្ខេបទៅតាមដំណាក់កាលលើប្រព័ន្ធសិទ្ធិមនុស្ស និងបញ្ហាប្រធានបទពាក់ព័ន្ធ និងទទួលរ៉ាប់រងអនុវត្តកិច្ចការ និងត្រូវបានជំរុញឲ្យចូលរួមពាក់ព័ន្ធក្នុងគម្រោង ។

បេក្ខជន ត្រូវតែមានបទពិសោធន៍ផ្ទាល់យ៉ាងតិចណាស់បីឆ្នាំក្នុងការធ្វើការងារជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ដែលបំពេញស្តង់ដាដែលត្រូវបានអនុម័តជាអន្តរជាតិ ពោលគឺ គោលការណ៍

ក្រុងប៉ារីស[4] និងបទពិសោធន៍ដ៏ទូលំទូលាយក្នុងការធ្វើការងារលើបញ្ហាពាក់ព័ន្ធនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ជាលក្ខណៈជាតិ តំបន់ និងជាគោលការណ៍អន្តរជាតិ ។

បេក្ខជន គួរតែមានលិខិតបន្ថែមពីស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) របស់ខ្លួន និងប្តេជ្ញាចិត្តផ្តល់ចំណេះដឹង និងបទពិសោធន៍ដែលទទួលបានក្នុងអំឡុងពេលកម្មវិធីអាហារូបករណ៍របស់ពួកគេ ដល់សហសេវិកនៅក្នុងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) របស់ពួកគេ នៅពេលដែលពួកគេត្រឡប់មកវិញ ។ ជាងនេះទៀត ពួកគេ គួរតែមានភាពស្ទាត់ជំនាញខាងភាសាអង់គ្លេស និង/ឬ បារាំង ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុជាទម្រង់អាហារូបករណ៍ប្រចាំខែ ក្នុងអំឡុងពេលកម្មវិធីអាហារូបករណ៍ ។

បេក្ខជន គួរតែដាក់ជូនពិនិត្យសំណុំឯកសារសុំអាហារូបករណ៍របស់ពួកគេ (លិខិតអមប្រវត្តិរូប លិខិតបន្ថែមពីស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI)) ដោយផ្ទាល់ទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ អង្គភាពស្ថាប័នជាតិ ជ្រើសរើសបេក្ខជនដោយពិគ្រោះយោបល់ជាមួយនឹងការិយាល័យគណៈកម្មាធិការសម្របសម្រួលអន្តរជាតិ នៃស្ថាប័នជាតិទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (ICC) ។

**i ទីកន្លែងដែលត្រូវដាក់ជូនពិនិត្យសំណុំឯកសារសុំអាហារូបករណ៍ អង្គភាពស្ថាប័នជាតិ**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10- ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩២ ៨៣ ឬ +៤១ (0)២២ ៩២៨ ៩៦ ៦៣
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០ ១៨
អ៊ីម៉ែលៈ **niu@ohchr.org**

សម្រាប់ព័ត៌មានបន្ថែមស្តីពី**កម្មវិធីអាហារូបករណ៍សម្រាប់ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

# ខ. សិក្ខាសាលាបណ្តុះបណ្តាល

**សិក្ខាសាលាបណ្តុះបណ្តាល** ផ្តល់ដល់តួអង្គសង្គមស៊ីវិលនូវឱកាសសិក្សាអំពីយន្តការសិទ្ធិមនុស្សជាក់លាក់ និងវិធីពង្រឹងការចូលរួមពាក់ព័ន្ធរបស់គេជាមួយនឹងយន្តការទាំងនោះ ។

[4] ចូរមើលឧបសម្ព័ន្ធនៃសេចក្តីសម្រេចចិត្តលេខ 48/134 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

**សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តបន្តនូវអនុសាសន៍របស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិ មនុស្ស**

**សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តបន្តនូវអនុសាសន៍របស់ស្ថាប័ន សន្ធិសញ្ញា** គឺសម្រាប់តួអង្គជាតិ និងសង្គមស៊ីវិល និងមានគោលបំណងកសាងសមត្ថភាពរបស់គេ ដើម្បីចូលរួមពាក់ព័ន្ធជាមួយនឹងស្ថាប័នសន្ធិសញ្ញា ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រៀបចំសិក្ខាសាលាពិភាក្សា និងសិក្ខាសាលាធម្មតាសម្រាប់តួអង្គជាតិនៅក្នុងប្រទេសរបស់គេផ្ទាល់ ដើម្បីពង្រឹងសមត្ថភាពរបស់គេក្នុងការរួមចំណែកនៅក្នុងដំណើរការធ្វើរបាយការណ៍សន្ធិសញ្ញា និងអនុវត្តបន្តអនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញា ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ចូលរួមពាក់ព័ន្ធជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) អង្គការមិនមែនរដ្ឋាភិបាល និងតំណាងរបស់ប្រព័ន្ធផ្សព្វផ្សាយនៅថ្នាក់ជាតិ នៅក្នុងសិក្ខាសាលាពិភាក្សាទាំងនេះ ដើម្បីកសាងសមត្ថភាព និងជំរុញលើកទឹកចិត្តឲ្យមានការបង្កើតបណ្តាញតួអង្គជាតិ ដើម្បីគាំទ្រដល់ការអនុវត្តអនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ ។

ចាប់តាំងតែពីឆ្នាំ ២០០៣ មក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តបន្តនៅគ្រប់តំបន់ទាំងអស់នៅក្នុងពិភពលោក ។ កម្មវិធីបណ្តុះបណ្តាល មានមុខងារជាក្របខ័ណ្ឌសម្រាប់ការបង្កើតឡើងនូវក្រុមបណ្តាញសង្គមស៊ីវិលថ្នាក់ជាតិ ដើម្បីអនុវត្តបន្តដំណើរការធ្វើរបាយការណ៍សន្ធិសញ្ញាសិទ្ធិមនុស្ស និងទ្រទ្រង់កិច្ចពិភាក្សាក្នុងន័យស្ថាបនាថ្នាក់ជាតិស្តីពីបញ្ហាទាក់ទងនឹងការងាររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ដល់រដ្ឋាភិបាលទាំងឡាយដែលមានការចាប់អារម្មណ៍ តាមរយៈសិក្ខាសាលាពិភាក្សា និងសិក្ខាសាលាធម្មតា និងជំរុញលើកទឹកចិត្តសង្គមស៊ីវិលឲ្យចូលរួមក្នុងសកម្មភាពទាំងនេះ ។

**i**

**សម្រាប់ព័ត៌មានបន្ថែមស្តីពីសិក្ខាសាលាបណ្តុះបណ្តាលបន្ត ចូរទាក់ទង:**
**សាខាសន្ធិសញ្ញាសិទ្ធិមនុស្សអង្គភាពសន្ធិសញ្ញា និងអនុវត្តបន្ត**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10- ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩០ ២២

ដោយរួមទាំងកម្មវិធីបណ្តុះបណ្តាល ដែលត្រូវបានលើកឡើងខាងលើ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) តាមរយៈ ការិយាល័យបច្ចុប្បន្នជាច្រើននៅមូល

ដ្ឋានរបស់ខ្លួន រៀបចំជាទៀងទាត់នូវការបណ្តុះបណ្តាលថ្នាក់ជាតិ និងសិក្ខាសាលាពិភាក្សា និងសិក្ខាសាលាធម្មតាសម្រាប់ការកសាងសមត្ថភាព សម្រាប់សង្គមស៊ីវិលលើបញ្ហា និងយន្តការសិទ្ធិមនុស្សអន្តរជាតិ ។

*i*

សម្រាប់ព័ត៌មានពិស្តារស្តីពី**ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស** សូមមើល**ជំពូក IV (ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស)** នៃសៀវភៅនេះ ។

# III. អត្ថបទបោះពុម្ពផ្សាយ និងធនធានសម្ភារៈរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

## ក. អត្ថបទបោះពុម្ពផ្សាយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

កម្មវិធីបោះពុម្ពផ្សាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (**OHCHR**) មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងផ្សព្វផ្សាយលើវបៀបលើកកម្ពស់ និងការពារវានៅទូទាំងពិភពលោក ។ កម្មវិធីនេះ ក៏ជំរុញលើកទឹកចិត្តឲ្យមានការពិភាក្សាវែកញែកអំពីបញ្ហាសិទ្ធិមនុស្ស ដែលត្រូវបានត្រួតពិនិត្យឡើងវិញ នៅក្នុងស្ថាប័នរបស់អង្គការសហប្រជាជាតិ ។ មានអត្ថបទបោះពុម្ពផ្សាយប្រាំប្រភេទសំខាន់ៗ:

១. **ឯកសារសង្ខេបព័ត៌មាន** ផ្តល់ព័ត៌មានស្តីពីប្រធានបទសិទ្ធិមនុស្សច្រើនសន្ធឹកសន្ធាប់ ។
២. **ឯកសារបញ្ហាពិសេស** ស្រាវជ្រាវរកបញ្ហាដែលត្រូវបានជ្រើសរើសកាន់តែស៊ីជម្រៅ ។
៣. **ឯកសារបណ្តុះបណ្តាល និងអប់រំរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** មានការណែនាំ ឯកសារណែនាំ និងសៀវភៅសម្រាប់ជនជាតិដើមភាគតិច ក្រុមជនភាគតិច ក្រុមអ្នកវិជ្ជាជីវៈ និងគ្រឹះស្ថានអប់រំ ។
៤. **ឯកសារយោង** ផ្តល់ដល់មន្ត្រីផ្នែកសិទ្ធិមនុស្សនូវលិខិតុបករណ៍ និងយុត្តិសាស្ត្រសិទ្ធិមនុស្សសំខាន់ៗ និង
៥. **សម្ភារៈឯកសារសិទ្ធិមនុស្សជាមូលដ្ឋាន** ផ្តល់ដល់សាធារណជនទូទៅនូវព័ត៌មានស្តីពីការងារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

### ១. ឯកសារសង្ខេបព័ត៌មាន

**ឯកសារសង្ខេបព័ត៌មាន** របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់ព័ត៌មានស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន ។ ឯកសារសង្ខេបព័ត៌មានខ្លះ ដោះស្រាយបញ្ហា ឬ ក្រុមជាក់លាក់ខ្លះទៀត ពន្យល់អំពីស្ថាប័នសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងនីតិវិធីរបស់វា ។ ឯកសារសង្ខេបព័ត៌មាន ក៏ផ្តល់ផងដែរនូវការណែនាំជាក់ស្តែងអំពីវិធីធ្វើការងារជាមួយនឹងកម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

### ២. ឯកសារបញ្ហាពិសេស

**ឯកសារបញ្ហាពិសេស** ស្រាវជ្រាវរកបញ្ហាដែលត្រូវបានជ្រើសរើសកាន់តែស៊ីជម្រៅ ។ ប្រធានបទ ត្រូវបានជ្រើសរើស ដោយពិចារណាទៅលើប្រធានបទភាព ភាពបន្ទាន់ និងហេតុការណ៍វិវត្តន៍ថ្មីៗរបស់វា ។

ឯកសារបញ្ហាពិសេសថ្មីៗខ្លះ គឺ: *ការអនុវត្តអភិបាលកិច្ចសម្រាប់កិច្ចការពារសិទ្ធិមនុស្ស ការអះអាងអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ យុទ្ធវិធីសិទ្ធិមនុស្ស ឧបករណ៍នីតិរដ្ឋសម្រាប់រដ្ឋដែលងើបពីជម្លោះ ការវាយតម្លៃប្រសិទ្ធភាពរបស់ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស* (ដែលត្រូវបានបោះពុម្ពផ្សាយរួមជាមួយនឹងតុលាការសិទ្ធិមនុស្សអន្តរជាតិ) និង *សិទ្ធិរបស់ជនមិនមែនប្រជាពលរដ្ឋក្នុងប្រទេសមួយ* ។

## ៣. ឯកសារបណ្តុះបណ្តាល និងអប់រំ

**ឯកសារបណ្តុះបណ្តាល និងអប់រំ**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់នូវទិដ្ឋភាពទូទៅដ៏ទូលំទូលាយអំពីប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក៏ដូចជាឧបករណ៍អនុវត្តន៍ជាក់ស្តែងសម្រាប់កម្មវិធីបណ្តុះបណ្តាល និងអប់រំសម្រាប់អ្នកទទួលផល ដូចជានគរបាល មន្ត្រីពន្ធនាគារ ចៅក្រម សមាជិកសភា អ្នកពិនិត្យតាមដានផ្នែកសិទ្ធិមនុស្ស អ្នកពិនិត្យតាមដានដំណើរការបោះឆ្នោត និងបុគ្គលិកសង្គមកិច្ច ឬ ក្រុម ឬ បុគ្គលជាក់លាក់ ។

**ឯកសារស៊េរីសម្រាប់បណ្តុះបណ្តាលអ្នកវិជ្ជាជីវៈ** មានសៀវភៅ និងឯកសារណែនាំ ដើម្បីបង្កើនការយល់ដឹងអំពីស្តង់ដាអន្តរជាតិ និងត្រូវបានផ្តោតទៅលើអ្នកទទួលផល ដែលអាចមានឥទ្ធិពលលើស្ថានភាពសិទ្ធិមនុស្សថ្នាក់ជាតិ ។ ទោះបីត្រូវបានរៀបចំជាលើកដំបូង ដើម្បីគាំទ្រសកម្មភាពបណ្តុះបណ្តាលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ដោយ ក៏អត្ថបទបោះពុម្ពផ្សាយទាំងនេះ មានមុខងារជាឧបករណ៍អនុវត្តន៍ជាក់ស្តែងផងដែរសម្រាប់អង្គការ ដោយផ្តល់ការអប់រំសិទ្ធិមនុស្សដល់ក្រុមអ្នកវិជ្ជាជីវៈ ។ ឯកសារណែនាំ អាចកែសម្រួលបានតាមតម្រូវការ និងបទពិសោធន៍ ទាក់ទងនឹងវប្បធម៌ ការអប់រំ និងប្រវត្តិសាស្ត្ររបស់អ្នកទទួលផលជាច្រើននៅក្នុងក្រុមគោលដៅ ។ ក្នុងករណីចាំបាច់ព័ត៌មានស្តីពីបច្ចេកទេសគរុកោសល្យ ត្រូវបានបញ្ចូល ដើម្បីជួយដល់អ្នកបណ្តុះបណ្តាលក្នុងការប្រើប្រាស់ឯកសារណែនាំ ។

**ឯកសារស៊េរីអប់រំសិទ្ធិមនុស្ស** មានឯកសារសម្រាប់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអប់រំសិទ្ធិមនុស្សទូទៅរបស់ដៃគូទាំងអស់ ។ វា រួមបញ្ចូលព័ត៌មានស្តីពីកម្មវិធីពិភពលោកសម្រាប់ការអប់រំសិទ្ធិមនុស្ស ការសិក្សាអំពីការអប់រំសិទ្ធិមនុស្ស និងសន្និសញ្ញាសិទ្ធិមនុស្ស កម្រងឯកសារបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិ និងតំបន់ដែលពិភាក្សាលើការអប់រំសិទ្ធិមនុស្ស និងសៀវភៅដែលផ្តល់ការណែនាំជាក់ស្តែងដល់អ្នកអប់រំ និងគ្រូបង្រៀន ។

នៅទីបំផុត **ឯកសារស៊េរីណែនាំ** មានសំណុំព័ត៌មានសម្រាប់ក្រុម ឬ បុគ្គលជាក់លាក់ ដែលស្តីពីវិធីស្វែងរកកិច្ចការពារសិទ្ធិមនុស្ស តាមរយៈនីតិវិធីអន្តរជាតិ និងតំបន់ខុសៗគ្នា ។ ឯកសារស៊េរីទាំងនេះ រួមមាន *ការណែនាំនៃអង្គការសហប្រជាជាតិសម្រាប់ជនជាតិដើមភាគតិច* និង *ការណែនាំនៃអង្គការសហប្រជាជាតិសម្រាប់ក្រុមជនភាគតិច* ដែលមានកូនសៀវភៅផ្សព្វផ្សាយចំនួន ១៤ ស្តីអំពីរបៀបដែលក្រុមជនភាគតិចអាចប្រើប្រាស់នីតិវិធី និងយន្តការតំបន់ផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ។

## ៤. ឯកសារយោង

**ឯកសារយោង** ផ្តល់ដល់អ្នកស្រាវជ្រាវ និងអ្នកច្បាប់ផ្នែកសិទ្ធិមនុស្សនូវលទ្ធភាពទទួលបានលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗ និងព័ត៌មានសំខាន់ជាសារវន្តផ្សេងទៀត ។ ឧទាហរណ៍ រួមបញ្ចូលកម្រងឯកសារ លិខិតុបករណ៍សិទ្ធិមនុស្ស ដូចជា *សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិថ្មីដ៏សំខាន់* និងយុត្តិសាស្ត្រដែលបានមកពីស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ដូចជា *សេចក្តីសម្រេចចិត្តដែលត្រូវបានជ្រើសរើសរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងពិធីសារបន្ថែម ឬ សេចក្តីសម្រេចចិត្តដែលត្រូវបានជ្រើសរើសរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។*

## ៥. សម្ភារៈឯកសារសិទ្ធិមនុស្សជាមូលដ្ឋាន

គោលបំណងនៃសម្ភារៈឯកសារនេះ ក្នុងនោះរួមមាន ផ្ទាំងអប់រំលើប្រធានបទសិទ្ធិមនុស្សផងដែរ គឺដើម្បីផ្តល់ដល់សាធារណជនទូទៅនូវព័ត៌មានស្តីពីការងារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងផ្តល់ចម្លើយសម្រាប់សំណួរដែលត្រូវបានសួរជាទូទៅបំផុតអំពីកម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

### *វិធីស្នើសុំអត្ថបទបោះពុម្ពផ្សាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)*

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវ**បញ្ជីអត្ថបទបោះពុម្ពផ្សាយ**របស់ខ្លួន ។ អត្ថបទបោះពុម្ពផ្សាយភាគច្រើនរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវបានបោះពុម្ពផ្សាយជាភាសាផ្លូវការទាំងអស់ចំនួនប្រាំមួយរបស់អង្គការសហប្រជាជាតិៈ ភាសាអារ៉ាប់ (A) ចិន (C) អង់គ្លេស (E) បារាំង (F) រុស្ស៊ី (R) និងអេស្ប៉ាញ (S) ។

អត្ថបទបោះពុម្ពផ្សាយ ដែលត្រូវបានដាក់សម្គាល់ (w) ត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ដោយឥតគិតថ្លៃពី**វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** ។ អត្ថបទបោះពុម្ពផ្សាយ ដែលត្រូវបានដាក់សម្គាល់សញ្ញាផ្កាយ (*) គឺជា**អត្ថបទបោះពុម្ពផ្សាយសម្រាប់លក់របស់អង្គការសហប្រជាជាតិ** និងអាចត្រូវរកទិញបានពីកន្លែងលក់សៀវភៅ និងអ្នកចែកចាយនៅទូទាំងពិភពលោក ។

សម្រាប់ព័ត៌មានបន្ថែម ចូរចូលមើលវិបសាយបណ្ណាគាររបស់អង្គការសហប្រជាជាតិនៅក្នុងទីក្រុងញូវយ៉ក (ក្រុមគោលដៅនៅអាស៊ី និងប៉ាស៊ីភិច អាមេរិកឡាទីន និងអាមេរិកខាងជើង) ឬ នៅក្នុងទីក្រុងហ្សឺណែវ (ក្រុមគោលដៅនៅអាព្រិច អឺរ៉ុប និងមជ្ឈិមបូព៌ា) ។

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

**i** សម្រាប់ព័ត៌មានបន្ថែមស្ដីពីអត្ថបទបោះពុម្ពផ្សាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សូមចូលមើល **OHCHR publication web page** ។

តួអង្គសង្គមស៊ីវិល ដែលមានបំណងប្រាថ្នាចង់ទទួលបានអ៊ីម៉ែល នៅពេលដែលអត្ថបទបោះពុម្ព ផ្សាយថ្មីត្រូវបានរៀបចំឲ្យមាន គួរតែផ្ញើតាម **publications@ohchr.org** ។

i

**អត្ថបទបោះពុម្ពផ្សាយភាគច្រើនរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវបានរៀបចំឲ្យមានតាមបណ្តាញអេឡិចត្រូនិច ។ លើសពីនេះទៀត បរិមាណតិចតួចនៃឯកសារច្បាប់រឹងសម្រាប់ព័ត៌មាន និងសកម្មភាពបណ្តុះបណ្តាលជាក់លាក់ អាចត្រូវបានបញ្ជាទិញពី:**

ការិយាល័យផ្នែកអត្ថបទបោះពុម្ពផ្សាយ និងព័ត៌មាន
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10- ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩២ ២៤
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០ ១០
អ៊ីម៉ែលៈ **publications@ohchr.org**

**នៅពេលបញ្ជាទិញអត្ថបទបោះពុម្ពផ្សាយរបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) អ្នកគួរតែបង្ហាញឲ្យបានច្បាស់លាស់នូវៈ**

- គោលបំណងចំពោះអត្ថបទបោះពុម្ពផ្សាយដែលត្រូវប្រើប្រាស់ ។ សូមផ្តល់ព័ត៌មានស្តីពីវគ្គបណ្តុះបណ្តាល គោលបំណង កាលបរិច្ឆេទ ចំនួនអ្នកចូលរួម ជាដើម ។ អ្នកក៏ត្រូវបានសុំឲ្យផ្តល់ព័ត៌មានត្រឡប់ បន្ទាប់ពីចប់ការបណ្តុះបណ្តាល ឬ ព្រឹត្តិការណ៍ព័ត៌មាន តាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ អ៊ីម៉ែល ។
- ចំនួនឯកសារដែលត្រូវបានស្នើសុំ ចំពោះអត្ថបទបោះពុម្ពផ្សាយនីមួយៗ ។
- ឈ្មោះរបស់អ្នកទំនាក់ទំនង
- ឈ្មោះរបស់អង្គការ (ក្នុងករណីដែលអាចធ្វើបាន)
- អាសយដ្ឋានទំនាក់ទំនងតាមប្រៃសណីយ៍
- លេខទូរស័ព្ទ
- លេខទូរសារ
- អ៊ីម៉ែល

**ដើម្បីផ្ទេរចេញនូវទម្រង់បញ្ជាទិញអត្ថបទបោះពុម្ពផ្សាយយកមកប្រើប្រាស់ សូម ចូលមើល OHCHR publications web page ។ ប្រសិនបើ មានអត្ថបទបោះពុម្ពផ្សាយនៅក្នុងឃ្លាំង អត្ថបទបោះពុម្ពផ្សាយ នឹងត្រូវបានរៀបចំឲ្យមានសម្រាប់បញ្ជាទិញ នៅការិយាល័យរបស់អង្គការសហប្រជាជាតិដែលនៅជិត ក្នុងករណីណាក៏ដោយដែលអាចធ្វើបាន ។ សូមកត់សម្គាល់ថា បរិមាណត្រូវបានកម្រិត និងចន្លោះដែលមានគំនូសពណ៌ខ្មៅនៅក្នុងបញ្ជី មានន័យថា អត្ថបទបោះពុម្ពផ្សាយមិនមាននៅក្នុងឃ្លាំងទេ ។**

អ្នកបោះពុម្ពផ្សាយដើម្បីពាណិជ្ជកម្ម ដែលមានបំណងប្រាថ្នាចង់បោះពុម្ពបន្ថែម ឬ ផលិតឡើងវិញនូវឯកសាររបស់ការិយាល័យផ្នែកអត្ថបទបោះពុម្ពផ្សាយ គួរតែបញ្ជូនសំណើសុំរបស់ខ្លួនទៅផ្នែកលក់នៃ ការិយាល័យអង្គការសហប្រជាជាតិនៅវិមានជាតិ8-14, avenue de la Paix, CH- 1211 Geneva 10- ប្រទេសស្វីស អ៊ីម៉ែលៈ **unpubli@unog.ch**។

## ២. បណ្ណាល័យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

បណ្ណាល័យរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្ស៊ឺណែវ ផ្តល់ព័ត៌មាន និងសេវាយោងគ្រប់ជ្រុងជ្រោយដល់ដៃគូរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) យន្តការ និងមន្ត្រីជំនាញផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងបុគ្គលិករបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCH-R) ។ វាមានឯកសារស្តីពីសិទ្ធិមនុស្ស អត្ថបទបោះពុម្ពផ្សាយ និងសម្ភារៈឯកសារផ្សេងទៀតមួយចំនួនធំជាទម្រង់រឹង និងអេឡិចត្រូនិក ។ បណ្ណាល័យដែលក៏ធ្វើសមាហរណកម្មក្រុមធនធានឯកសារស្តីពីការអប់រំ និងបណ្តុះបណ្តាលសិទ្ធិមនុស្សផងដែរនោះ បន្តរក្សាទំនាក់ទំនងជាមួយនឹងអង្គការសហប្រជាជាតិ និងបណ្ណាល័យ និងវិទ្យាស្ថានស្រាវជ្រាវសំខាន់ៗផ្សេងទៀត នៅជុំវិញពិភពលោក ដោយផ្តល់ដល់ក្រុមគោលដៅនូវការស្រាវជ្រាវ និងសេវាយោងតាមបណ្តាញអេឡិចត្រូនិក ។

បណ្ណាល័យរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) មិនត្រឹមតែបម្រើសហគមន៍អន្តរជាតិប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងបើកបម្រើជូនអ្នកវិជ្ជាជីវៈនៅក្រៅអង្គការផងដែរ ។ អង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្ស៊ឺណែវនិងត្រូវបានទទួលស្គាល់ជាផ្លូវការរួចហើយពីការិយាល័យអង្គការសហប្រជាជាតិ នៅក្នុងទីក្រុងហ្ស៊ឺណែវនោះ ហើយត្រូវបានផ្តល់ឲ្យនូវលទ្ធភាពងាយស្រួលក្នុងការប្រើប្រាស់បណ្ណាល័យនេះ ។ សមាជិកអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលដទៃទៀត អាចទទួលបានស្លាកសម្គាល់ប្រើប្រាស់បណ្ណាល័យបណ្តោះអាសន្ន ។

បណ្ណាល័យនេះ បើកបម្រើជូនចាប់ពីថ្ងៃ ច័ន្ទ រហូតដល់ថ្ងៃ សុក្រ នៅពេលព្រឹកចាប់ពីម៉ោង ៩ និង ៣០ នាទី ដល់ម៉ោង ១២ និង ៣០ នាទី និងពេលល្ងាចចាប់ពីម៉ោង ២ ដល់ម៉ោង ៥ ។ ក្រុមគោលដៅ ត្រូវតែមានអត្តសញ្ញាណប័ណ្ណដែលមានបិទរូបថត និងនៅមានសុពលភាព (ស្លាកសម្គាល់របស់អង្គការសហប្រជាជាតិ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណបើកបរ) ។ សៀវភៅយោង មិនត្រូវបានរៀបចំឲ្យមានសម្រាប់ក្រុមគោលដៅខ្ចីនោះទេ និងត្រូវតែត្រូវបានប្រើប្រាស់នៅក្នុងបណ្ណាល័យតែប៉ុណ្ណោះ ។ ការប្រើប្រាស់បណ្ណាល័យ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោម**វិធាន និងបទបញ្ជានៃបណ្ណាល័យ**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានការសោកស្តាយដោយថា បណ្ណាល័យនេះ មិនអនុញ្ញាតឲ្យអនីតិជនដែលមិនត្រូវបានអមដំណើរចូលនោះទេ ។

### *វិធីទាក់ទងនឹងបណ្ណាល័យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR )*

i

**បណ្ណាល័យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្ថិតនៅជាន់ផ្ទាល់ដីនៃអគារហ្គាយសិពី ម៉ូតា**

(48, Avenue Guiseppe Motta, Geneva)

បណ្ណាល័យនេះ បើកបម្រើជូនចាប់ពីថ្ងៃ ច័ន្ទ រហូតដល់ថ្ងៃ សុក្រ នៅពេលព្រឹកចាប់ពីម៉ោង ៩ និង ៣០ នាទី ដល់ម៉ោង ១២ និង ៣០ នាទី និងពេលល្ងាចចាប់ពីម៉ោង ២ ដល់ម៉ោង ៥ ។ ក្រុមគោលដៅ ត្រូវតែមានអត្តសញ្ញាណប័ណ្ណដែលមានបិទរូបថត និងនៅមានសុពលភាព (ស្លាកសម្គាល់របស់អង្គការសហប្រជា ជាតិ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណបើកបរ) ។

ទូរស័ព្ទលេខ: +៤១ (០)២២ ៩២៨ ៩៧ ៩០
ទូរសារលេខ: +៤១ (០)២២ ៩២៨ ៩០ ៦៥
អ៊ីម៉ែល: **library@ohchr.org**

## គ. ធនធានសម្ភារៈផ្សេងទៀតរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

**វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** គឺជាប្រភពដ៏មានសារៈសំខាន់សម្រាប់រកអត្ថបទបោះពុម្ពផ្សាយ ឯកសារយោង និងកម្រងឯកសារផ្សេងទៀត ទាក់ទងនឹងយន្តការសិទ្ធិមនុស្សអន្តរជាតិ និងសកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ ទំព័រដ៏សំខាន់នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានប្រអប់សម្រាប់ស្វែងរកដែលនាំផ្លូវទៅរកព័ត៌មានសិទ្ធិមនុស្ស ក្នុងនោះរួមមាន ឯកសារផ្លូវការ តាមប្រទេស តាមបញ្ហា ឬ តាមផលប្រយោជន៍របស់អ្នកវិជ្ជាជីវៈផងដែរ ។

កម្រងឯកសារផ្លូវការទាំងអស់របស់អង្គការសហប្រជាជាតិ ក៏អាចត្រូវបានប្រើប្រាស់ផងដែរតាមបណ្ដាញអេឡិចត្រូនិក តាមរយៈ**ប្រព័ន្ធឯកសារផ្លូវការ**របស់អង្គការសហប្រជាជាតិ ។

### មជ្ឈមណ្ឌលព័ត៌មាន

*សេចក្ដីថ្លែងការណ៍ និងសេចក្ដីប្រកាសព័ត៌មាន ទាក់ទងនឹងសកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ អាចត្រូវបានប្រើប្រាស់តាមបណ្ដាញអេឡិចត្រូនិក តាមរយៈមជ្ឈមណ្ឌលព័ត៌មាន ។ ព័ត៌មានថ្មីៗ ប្រតិទិននៃកិច្ចប្រជុំ និងព្រឹត្តិការណ៍នានា សេចក្ដីថ្លែងការណ៍របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និង*

*សេចក្តីប្រកាសព័ត៌មានដែលត្រូវបានរៀបចំរក្សាទុក ត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។*

*សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយដែលស្វែងរកព័ត៌មាន បទសម្ភាសន៍ ឬ សេចក្តីសង្កេត គួរតែទាក់ទងនឹងផ្នែកទំនាក់ទំនងព័ត៌មាន តាមរយៈ*


អ៊ីម៉ែល: **press-info@ohchr.org**

ទូរស័ព្ទលេខៈ +៤១ (០)២២ ៩១៧ ៩៧ ៦៧

+៤១ (០)២២ ៩១៧ ៩៣ ៨៣


*i* ដើម្បីទទួលបាន**ព័ត៌មានប្រាប់ពីហេតុការណ៍ជាមុន** តាមរយៈអ៊ីម៉ែល ចូរបញ្ជូនសំណើសុំទៅកាន់ **press-info@ohchr.org**

សម្រាប់ព័ត៌មានស្តីពីធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលមានលក្ខណៈជាក់លាក់ចំពោះស្ថាប័ន និងយន្តការសិទ្ធិមនុស្សដ៏ពិសេស របស់អង្គការសហប្រជាជាតិ សូមមើលជំពូកមួយ (ច្រើន) ដែលពាក់ព័ន្ធរបស់*សៀវភៅ*នេះ ។

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

# IV. ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

## ទិដ្ឋភាពរួមនៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

**ដូចដែលហៅថាស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ?**

**ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស** គឺជាគណៈកម្មាធិការនៃមន្ត្រីជំនាញឯករាជ្យ ដែលពិនិត្យតាមដានការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិរបស់ភាគីរដ្ឋ ។ គេ ធ្វើកិច្ចការនេះដោយត្រួតពិនិត្យឡើងវិញលើរបាយការណ៍ ដែលត្រូវបានដាក់ជូនពិនិត្យតាមដំណាក់កាលដោយភាគីរដ្ឋស្តីពីវិធានការ ដែលត្រូវបានប្រកាន់យក ដើម្បីអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា ។ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សភាគច្រើនមានសមត្ថភាពក្នុងការទទួល និងពិចារណាលើពាក្យបណ្តឹងនីមួយៗ ចំណែកឯ មួយចំនួនតូចអាចអនុវត្តការស៊ើប សួរ ។ ស្ថាប័នមួយ **គឺអនុគណៈ កម្មការទប់ស្កាត់ការធ្វើទារុណកម្ម** ត្រូវបានប្រគល់អាណត្តិ ដើម្បីអនុវត្តដំណើរទស្សនកិច្ចទៅកាន់ទីកន្លែងដែលមនុស្ស អាចត្រូវបាន ដកហូតសេរីភាពជាមូលដ្ឋាន ដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម ។

***តើគេធ្វើការងារតាមវិធីណា ?***

ដោយរួមទាំងកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តបទប្បញ្ញត្តិសំខាន់ៗនៃសន្ធិសញ្ញា ដែលខ្លួនជាភាគីនៃសញ្ញានេះដែរនោះ ភាគីរដ្ឋនីមួយៗ ត្រូវបានតម្រូវឲ្យដាក់ជូនពិនិត្យរបាយការណ៍ទៀងទាត់ស្តីពីរបៀបដែលរដ្ឋនេះ បានអនុវត្តបទប្បញ្ញត្តិសន្ធិសញ្ញា ។ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធពិចារណាលើរបាយការណ៍ទាំង នេះ នៅចំពោះមុខគណៈប្រតិភូនៃ រដ្ឋភាគី និងដោយពិចារណាលើព័ត៌មានទាំងអស់ ក្នុងនោះរួមមានព័ត៌មានជាលាយលក្ខណ៍អក្សរបន្ថែមដែលត្រូវបានផ្តល់ជូនដោយភាគីរដ្ឋ ក៏ដូចជា ព័ត៌មាន ដែលត្រូវបានផ្តល់ដោយផ្ទាល់មាត់ នៅក្នុងអំឡុងពេលពិចារណាលើរបាយការណ៍ ។ គណៈកម្មាធិការ ក៏ត្រូវទទួលផងដែរនូវព័ត៌មានពីទីភ្នាក់ងារអង្គការសហប្រជាជាតិ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងតួអង្គសង្គម ស៊ីវិលជាពិសេស អង្គការមិនមែនរដ្ឋាភិបាល (NGO) សមាគមអ្នកវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សាអប់រំ ។

ដោយផ្អែកលើដំណើរការនេះ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអនុម័តលើអ្វីដែលត្រូវ បានគេដឹងជាទូទៅថាជា "សេចក្តីសង្កេតសន្និដ្ឋាន" ដែលយោងទៅតាមទិដ្ឋភាពវិជ្ជមាននៃការអនុវត្តសន្ធិសញ្ញារបស់រដ្ឋ និងតំបន់ដែលស្ថាប័ន សន្ធិសញ្ញា ផ្តល់អនុសាសន៍ដល់រដ្ឋឲ្យអនុវត្តវិធានការបន្ត ។

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

ដោយរួមទាំងការពិចារណាទៅលើរបាយការណ៍របស់ភាគីរដ្ឋ ស្ថាប័នសន្ធិសញ្ញា ប្រើប្រាស់មុខងារផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តសន្ធិសញ្ញាៈ

- **គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គណៈកម្មាធិការប្រឆាំងទារុណកម្ម គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់នៃគ្រួសារពួកគេ គណៈកម្មាធិការការពារសិទ្ធិរបស់ជនពិការ** និង គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ (នៅត្រឹម ខែកញ្ញា ឆ្នាំ ២០០៨ មិនទាន់ត្រូវបានបង្កើតឡើងទេ) អាចពិចារណាទៅលើពាក្យបណ្តឹង ឬឯកសារបណ្តឹងពីបុគ្គល (ឬ ក្រុមរបស់បុគ្គល ក្នុងករណីគណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ និងគណៈកម្មាធិការការពារសិទ្ធិជនពិការ) ដែលទាមទារសុំសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពានដោយភាគីរដ្ឋ ។ នៅពេលដែលវាចូលជាធរមាន ពិធីសារបន្ថែមនៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ក៏នឹងអនុញ្ញាតឲ្យមានផងដែរនូវបណ្តឹងជាលក្ខណៈបុគ្គល ។ នៅក្នុងយន្តការទទួលពាក្យបណ្តឹងទាំងនេះ ស្ថាប័ន សន្ធិសញ្ញាអាចអនុម័តវិធានការបណ្តោះអាសន្ន ក្នុងករណីបន្ទាន់ ដើម្បីរក្សាស្ថានភាពរហូតដល់គេអាចធ្វើសេចក្តីសម្រេចចិត្តជាស្ថាពរលើបញ្ហា ។
- គណៈកម្មាធិការប្រឆាំងទារុណកម្ម គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង ស្ត្រីភេទ គណៈកម្មាធិការការពារសិទ្ធិជនពិការ និង គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ អាចផ្តួចផ្តើមការសាកសួរ ប្រសិនបើគេបានទទួលបានព័ត៌មាន ដែលអាចជឿទុកចិត្តបានដែលមានសន្ទស្សន៍សមហេតុសមផលនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរធ្ងន់ធ្ងរខ្លាំង ឬ ជាប្រព័ន្ធលើសន្ធិសញ្ញារបស់ភាគីរដ្ឋ ។
- គណៈកម្មាធិការបំបាត់រាល់ទម្រង់ការរើសអើងពូជសាសន៍ គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងទារុណកម្ម គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍មាននីតិវិធី ដើម្បីដោះស្រាយបណ្តឹងអន្តររដ្ឋ ឬ ទំនាស់ និង
- គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍បានបង្កើតនីតិវិធីទាក់ទងនឹងវិធានការព្រមានជាមុន និងវិធានការបន្ទាន់ ។

ស្ថាប័ន សន្ធិសញ្ញាសិទ្ធិក៏អនុម័តផងដែរនូវសេចក្តីសង្កេតទូទៅ និងរៀបចំកិច្ចពិភាក្សាប្រធានបទទូទៅស្តីពីកម្មវត្ថុពិសេស ដើម្បីផ្តល់ការណែនាំសំខាន់លើការអនុវត្ត ។

### *វិធីទាក់ទង និងធ្វើការជាមួយនឹងស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស*

ការធ្វើការងារជាមួយនឹងស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សបញ្ជាក់ថាជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់សង្គមស៊ីវិល រួមចំណែកក្នុងការអនុវត្តសិទ្ធិមនុស្ស និងការបង្កើតវិធានការសិទ្ធិមនុស្ស ។

មានមធ្យោបាយមួយ ចំនួនដែលតាមរយៈនេះសង្គមស៊ីវិលអាចចូលរួមពាក់ព័ន្ធជាមួយនឹងប្រព័ន្ធស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ទន្ទឹមនឹងនេះពិចារណាទៅលើការរៀបចំដាក់

លាក់របស់ស្ថាប័នសន្ធិសញ្ញា

| | | |
|---|---|---|
| នីមួយៗ ឧទាហរណ៍:<br>• ការលើកកម្ពស់ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ។<br>• ការពិនិត្យតាមដានលើការអនុវត្តតាមរបស់ភាគីរដ្ឋទៅនឹងកាតព្វកិច្ចធ្វើរបាយការណ៍របស់ខ្លួន ។<br>• ការដាក់ជូនពិនិត្យព័ត៌មានជាលាយលក្ខណ៍អក្សរ និងឯកសារទៅស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សក្នុងនោះរួមមាន តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ ។<br>• ការពឹងពាក់ទៅនឹងច្បាប់របស់អង្គ/គណៈសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ ដោយចូលរួមក្នុងវគ្គសិក្សារបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងនាមជាអ្នកសង្កេតការណ៍ ឬ តាមរយៈឯកសារស្នើសុំពិនិត្យ ដែលត្រូវបានបង្ហាញ | ជូនដោយផ្ទាល់មាត់ ។<br>• ការអនុវត្តបន្តសេចក្តីសង្កេតសន្និដ្ឋានរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។<br>• ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងនីមួយៗទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស (គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងគណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍) ។<br>• ការផ្តល់ព័តមាន ដើម្បីជំរុញឲ្យមានការសាកសួរជាការសម្ងាត់ (គណៈកម្មាធិការប្រឆាំងទារុណកម្ម និងគណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសការផ្តល់ព័ត៌មានសម្រាប់នីតិវិធី | អើងប្រឆាំងស្ត្រីភេទ) ។<br>• ការផ្តល់ព័ត៌មានសម្រាប់នីតិវិធីព្រមានជាមុន និងបន្ទាន់ (គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍) និង<br>• ការដាក់ឯកសារស្នើសុំពិនិត្យជូនទៅអន្តរគណៈកម្មាធិការប្រចាំឆ្នាំរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ |

*i*

## ការទាក់ទងនឹងស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស

គណៈកម្មាធិការទាំងអស់ អាចត្រូវបានទាក់ទង តាមរយៈការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវ តាមរយៈ:

[**ឈ្មោះរបស់គណៈកម្មាធិការ**]
ស្ថិតនៅជាមួយនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10- ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩0 ២៩

# ក. ដូចម្ដេចដែលហៅថា ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ?

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនប្រាំបួន ដែលត្រូវបានពិនិត្យតាមដានដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស បង្កើតឲ្យមានកាតព្វកិច្ចសម្រាប់រដ្ឋក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ។ នៅពេលដែលរដ្ឋសុខចិត្តលំឱនតាមសន្ធិសញ្ញាសិទ្ធិមនុស្ស តាមរយៈការផ្ដល់សច្ចាប័ន[5] ឬការចូលជាភាគី[6] រដ្ឋនោះក្លាយជាភាគីរដ្ឋនៃសន្ធិសញ្ញានោះ និងទទួលយកកាតព្វកិច្ចផ្លូវច្បាប់ ដើម្បីអនុវត្តសិទ្ធិដែលត្រូវបានចែងនៅក្នុងវា ។[7] សន្ធិសញ្ញាអនុញ្ញាតឲ្យមានការបង្កើត**គណៈកម្មាធិការមន្ត្រីជំនាញឯករាជ្យអន្តរជាតិ** (គណៈសន្ធិសញ្ញាសិទ្ធិមនុស្ស) ដើម្បីពិនិត្យតាមដានការអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញានៅក្នុងបណ្ដាប្រទេសទាំងនេះ ដែលបានផ្ដល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញាទាំងនេះ ។[8]

ប្រព័ន្ធស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ មានតួនាទីសំខាន់ក្រៃលែងក្នុងការពង្រឹងកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ ។ អាណត្តបឋម ដែលមានលក្ខណៈទូទៅចំពោះស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ គឺត្រូវពិនិត្យតាមដានការអនុវត្តសន្ធិសញ្ញាពាក់ព័ន្ធ ដោយត្រួតពិនិត្យឡើងវិញលើរបាយការណ៍ ដែលត្រូវបានដាក់ជូនពិនិត្យទៅតាមដំណាក់កាលដោយភាគីរដ្ឋ ។

នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ មានស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនប្រាំបួនៈ

---

[5] ការផ្ដល់សច្ចាប័ន ការសុខចិត្តលំឱនតាម និងការអនុម័តតាម ដែលទាំងអស់ សំដៅទៅលើអំពើដែលតាមរយៈនេះ រដ្ឋ កំណត់អំពីការយល់ព្រមរបស់ខ្លួន ដើម្បីឲ្យភ្ជាប់កាតព្វកិច្ចដោយសន្ធិសញ្ញា ។ ជាដំណាក់កាលមុនការផ្ដល់សច្ចាប័ន ការចុះហត្ថលេខាលើសន្ធិសញ្ញា ក៏បង្កើតឲ្យមានកាតព្វកិច្ចសម្រាប់រដ្ឋ នៅក្នុងចន្លោះពេលរវាងការចុះហត្ថលេខា និងការផ្ដល់សច្ចាប័ន ការសុខចិត្តលំឱនតាម ឬ ការអនុម័តតាម ដើម្បីបញ្ឈប់ ដោយចិត្តទៀងត្រង់ នូវអំពើដែលធ្វើឲ្យខូចខាតដល់ទិសដៅ និងគោលបំណងរបស់សន្ធិសញ្ញាណាមួយ (ចូរមើលមាត្រា ១៨ នៃ**អនុសញ្ញាក្រុងវីយែននៃច្បាប់សន្ធិសញ្ញា**) ។

[6] ការចូលជាភាគី គឺជាអំពើដែលតាមរយៈនេះ រដ្ឋដែលមិនទាន់បានចុះហត្ថលេខាលើសន្ធិសញ្ញា សម្ដែងចេញនូវការយល់ព្រមរបស់ខ្លួន ដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញានោះ ដោយបន្ដរក្សា "មធ្យោបាយចូលជាភាគី" ជាមួយនឹងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការចូលជាភាគី មានអានុភាពដូចគ្នានឹងការផ្ដល់សច្ចាប័ន ការសុខចិត្តលំឱនតាម ឬ ការអនុម័តតាម ។

[7] លើកលែងតែបទប្បញ្ញត្តិនៃសន្ធិសញ្ញាដែលផ្ទុយនឹងសេចក្ដីថ្លែងការណ៍ដែលរដ្ឋបានចូលជាភាគី ។ វាជាសេចក្ដីថ្លែងការណ៍ដែលត្រូវបានធ្វើឡើងដោយរដ្ឋ ដែលតាមរយៈនេះ វា អះអាងដកចេញ ឬ ប្ដូរអានុភាពតាមផ្លូវច្បាប់នៃបទប្បញ្ញត្តិខ្លះនៃសន្ធិសញ្ញា នៅក្នុងការប្រើប្រាស់វាចំពោះរដ្ឋនោះ ។ សេចក្ដីថ្លែងការណ៍ អាចជួយរដ្ឋឲ្យអាចចូលរួមបាននៅក្នុងសន្ធិសញ្ញាពហុភាគី ដែលរដ្ឋ បើមិនដូច្នោះទេ នឹងមិនអាច ឬ មិនសុខចិត្តចូលរួមទេ ។ រដ្ឋទាំងឡាយ អាចធ្វើសេចក្ដីថ្លែងការណ៍ចំពោះសន្ធិសញ្ញា នៅពេលដែលរដ្ឋទាំងនោះ ចុះហត្ថលេខា ផ្ដល់សច្ចាប័ន សុខចិត្តលំឱនតាម អនុម័តតាម ឬ ចូលជាភាគីនៃសន្ធិសញ្ញានោះ ។ សេចក្ដីថ្លែងការណ៍ មិនអាចផ្ទុយទៅនឹងទិសដៅ និងគោលបំណងនៃសន្ធិសញ្ញាទេ ។

[8] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ មិនអនុញ្ញាតជាក់លាក់ឲ្យមានការបង្កើតស្ថាប័ន សន្ធិសញ្ញាទេ ប៉ុន្តែផ្ដល់ដល់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាណត្តិទូទៅ ដើម្បីពិនិត្យតាមដានការអនុវត្តកតិកាសញ្ញានេះ ។ នៅក្នុងឆ្នាំ ១៩៨៥ ក្រុមការងារសម័យប្រជុំ ដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ដើម្បីជួយក្នុងការពិចារណាទៅលើរបាយការណ៍របស់ភាគីរដ្ឋ ត្រូវបានប្ដូរសមាសភាព តាមគំរូនៃស្ថាប័ន សន្ធិសញ្ញា និងប្ដូរឈ្មោះ "គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្ប-ធម៌ (សេចក្ដីសម្រេចចិត្តលេខ 1985/17 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)) ។ គណៈកម្មាធិការ ដែលបានជួបប្រជុំជាលើកទីមួយនៅក្នុងឆ្នាំ ១៩៨៧ ត្រូវបានចាត់ទុកជាគណៈសន្ធិសញ្ញា ។

- **គណៈកម្មាធិការសិទ្ធិមនុស្ស** ដែលពិនិត្យតាមដានការអនុវត្ត**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** (ឆ្នាំ ១៩៦៦) និងពិធីសារបន្ថែមរបស់វា ។
- **គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ដែលពិនិត្យតាមដានការអនុវត្ត **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌** (ឆ្នាំ ១៩៦៦) ។
- **គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** ដែលពិនិត្យតាមដានការអនុវត្ត **អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** (១៩៦៥) ។
- **គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ** ដែលពិនិត្យតាមដានការអនុវត្ត**អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ** (១៩៧៩) ។
- **គណៈកម្មាធិការប្រឆាំងទារុណកម្ម** ដែលពិនិត្យតាមដានការអនុវត្ត **អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប** (១៩៨៤) ។
- **អនុគណៈកម្មការបង្ការទារុណកម្ម** ដែលត្រូវបានបង្កើតឡើង តាមរយៈ **ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** (២០០២) ។
- **គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ** ដែលពិនិត្យតាមដានការអនុវត្ត**អនុសញ្ញាស្តីពីសិទ្ធិកុមារ** (១៩៨៩) និងពិធីសារបន្ថែមរបស់វា ។
- **គណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍** ដែលពិនិត្យតាមដានការអនុវត្ត**អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់នៃ គ្រួសារពួកគេ** (១៩៩០) និង
- **គណៈកម្មាធិការការពារសិទ្ធិជនពិការ** ដែលពិនិត្យតាមដានការអនុវត្ត**អនុសញ្ញាស្តីពីសិទ្ធិ ជនពិការ** (២០០៦) ។[9]

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សទីដប់ **គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ** នឹងត្រូវបានបង្កើតឡើង កាលណា**អនុសញ្ញាអន្តរជាតិការពារបុគ្គលទាំងឡាយ ពីការបាត់ខ្លួនដោយបង្ខំ** (២០០៦) ចូលជាធរមានភ្លាម ។[10]

---

[9] ការផ្តល់សច្ចាប័ន និងការចូលជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សរបស់បណ្តារដ្ឋនានា បានកើនឡើងយ៉ាងច្រើន ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅថ្មីៗនេះ ។ នៅត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៨ មានៈ ភាគីរដ្ឋចំនួន ១៦២ ជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៥៩ ជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ១៧៣ ជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ១៨៥ ជាភាគីនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ ១៤៥ ជាភាគីនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ១៩៣ ជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ៣៩ ជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ និង ៤០ ជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ ។

[10] នៅត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៨ មានភាគីរដ្ឋចំនួនប្រាំ ជាភាគីនៃអនុសញ្ញាអន្តរជាតិដើម្បីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ ។ សន្ធិសញ្ញា នឹងចូលជាធរមាន កាលណាវា ត្រូវបានផ្តល់សច្ចាប័ន ឬ ចូលជាភាគី ដោយរដ្ឋចំនួន ២០ ។

ដូចដែលបានបង្ហាញជូនខាងលើ សន្ធិសញ្ញាខ្លះ ត្រូវបានបំពេញដោយ**ពិធីសារបន្ថែម** ដែលភាគីរដ្ឋនៃសន្ធិសញ្ញា អាចផ្តល់សច្ចាប័ន ។[11] ពិធីសារបន្ថែម មានចែងពីសិទ្ធិសំខាន់ៗបន្ថែមទៀត ឬ ចែងពីនីតិវិធីពិនិត្យតាមដានបន្ថែមទៀត ។ មានពិធីសារបន្ថែមចំនួនប្រាំពីរនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ:

- **ពិធីសារបន្ថែម នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។**
- **ពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណងលុបចោលទោសប្រហារជីវិត ។**
- **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។**
- **ពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងកុមារនៅក្នុងជម្លោះប្រដាប់អាវុធ ។**
- **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាចារកុមារ និងកាមសាស្ត្រកុមារ ។**
- **ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។**
- **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ។**[12]

ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានអនុម័តពិធីសារបន្ថែម នៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ។[13]

គណៈកម្មាធិការ មានសមាសភាពមន្ត្រីជំនាញឯករាជ្យពី ១០ ទៅ ២៣ រូប ដែលមានសមត្ថភាពក្នុងវិស័យសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ ។ ពួកគេត្រូវបានជ្រើសតាំង និងបោះឆ្នោតជ្រើសរើសដោយភាគីរដ្ឋ សម្រាប់អាណត្តិថេររយៈពេលបួនឆ្នាំ ដែលអាចបន្តទៀតបាន ។ សន្ធិសញ្ញាថ្មីៗនេះ កម្រិតចំនួនអាណត្តិដែលសមាជិកនៃស្ថាប័នសន្ធិសញ្ញាអាចទទួលបានទៅពីរឆ្នាំវិញ ។

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ ត្រូវបានបម្រើដោយអង្គភាពសន្ធិសញ្ញា និងតាមដានបន្ត**នៃសាខាសន្ធិសញ្ញាសិទ្ធិមនុស្សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ដែលទទួលឯកសារស្នើសុំពិនិត្យរបាយការណ៍ និងឯកសារទាក់ទងគ្នាសម្រាប់ស្ថាប័នសន្ធិសញ្ញា រៀបចំរបាយការណ៍ អនុវត្តការស្រាវជ្រាវ ផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ការណែនាំ និងសេចក្តី

---

[11] រដ្ឋ អាចផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ប្រសិនបើរដ្ឋនោះ ជាហត្ថលេខីនៃអនុសញ្ញា ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃអនុសញ្ញានោះទេ ។

[12] នៅត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៨ មាន: ភាគីរដ្ឋចំនួន ១១១ ជាភាគីនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ៦៨ ជាភាគីនៃពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណងលុបបំបាត់ចោលទោសប្រហារជីវិត ៩២ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ១២៣ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងកុមារនៅក្នុងជម្លោះប្រដាប់អាវុធ ១២៩ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ដូរកុមារពេស្យាចារកុមារ និងកាមសាស្ត្រកុមារ ៣៥ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និង ២៤ ជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ។

[13] មហាសន្និបាតអង្គការសហប្រជាជាតិ ក៏ត្រូវបានគេរំពឹងថា នឹងអនុម័តពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងឆ្នាំ ២០០៨ ។

ណែនាំដល់ភាគីរដ្ឋទាំងឡាយ រៀបចំចាត់ចែងកិច្ចប្រជុំ និងទទួលរ៉ាប់រងធ្វើការងារភស្តុភារផ្សេងទៀត ដែលត្រូវបានតម្រូវដោយស្ថាប័នសន្ធិសញ្ញា ។

វគ្គប្រជុំពេញអង្គរបស់ស្ថាប័នសន្ធិសញ្ញាទាំងអស់ ត្រូវបានរៀបចំឡើងនៅក្នុងទីក្រុង ហ្សឺណែវ ឬទីក្រុងញូវយ៉ក[14] (នៅក្នុងទីក្រុងហ្សឺណែវ តាមធម្មតា នៅអគារធំរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)) វិមានរដ្ឋវីលសុន ប៉ុន្តែយូរៗម្តងនៅវិមានជាតិផងដែរ) ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) កំពុងតែខិតខំពុះពារធានាឲ្យមានការប្រើប្រាស់បន្ទប់ប្រជុំ ឯកសារ និងបច្ចេកវិជ្ជារបស់ខ្លួន ដើម្បីឲ្យមន្ត្រីជំនាញ ប្រតិភូ និងតំណាងជនពិការនៃសង្គមស៊ីវិល អាចចូលរួមក្នុងការងាររបស់ស្ថាប័នសន្ធិសញ្ញាបាន ។

[14] វគ្គប្រជុំពេញអង្គខែ មីនា ("និទាឃរដូវ") របស់គណៈកម្មាធិការសិទ្ធិមនុស្ស ប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក ។ វគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក និងហ្សឺណែវ ។

| ប្រព័ន្ធនៃស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស | | |
|---|---|---|
| ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស | សន្ធិសញ្ញា ដែលត្រូវបានរៀបចំបង្កើតឡើង | ពិធីសារនៃសន្ធិសញ្ញា ដែលត្រូវបាន រៀបចំបង្កើតឡើង |
| **គណៈកម្មាធិការសិទ្ធិមនុស្ស** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៧ ។ | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៦៦ ។ | **ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** (ដែលអនុញ្ញាតឲ្យមានការប្តឹងជាលក្ខណៈបុគ្គល) ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៦៦ ។<br><br>**ពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណងលុបបំបាត់ចោលទោសប្រហារជីវិត** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៨៩ ។ |
| **គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៥ ។ | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ (ICESCR)** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៦៦ ។ | **ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌** ត្រូវបានអនុម័តដោយក្រុមប្រឹក្សា នៅក្នុងខែមិថុនា ឆ្នាំ ២០០៨។ ដោយត្រូវបានរំពឹងថា នឹងត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ២០០៨ ពិធីសារបន្ថែមនឹងអនុញ្ញាតឲ្យមានការប្តឹងជាលក្ខណៈបុគ្គល កាលណាវា បានចូលជាធរមានភ្លាម ។ |
| **គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧០ ។ | **អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងជាតិសាសន៍ (ICERD)** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៦៥ ។ | មិនមានពិធីសារទេ ។ |
| **គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨២ ។ | **អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៧៩។ | **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ** (ដែលអនុញ្ញាតឲ្យមានការប្តឹងជាលក្ខណៈបុគ្គល) ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៩៩ ។ |
| **គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៧ ។ | **អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT)** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៨៤ ។ | សូមមើលប្រអប់បន្ទាប់ ។ |

| ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស | សន្ធិសញ្ញា<br>ដែលត្រូវបានរៀបចំបង្កើតឡើង | ពិធីសារនៃសន្ធិសញ្ញា ដែលត្រូវបាន<br>រៀបចំបង្កើតឡើង |
|---|---|---|
| **អនុគណៈកម្មការបង្ការទប់ស្កាត់ការធ្វើទារុណកម្ម** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦ ។ | **ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** (**OPCAT**) (ដែល បង្កើតយន្តការពិនិត្យតាមដានថ្នាក់ជាតិ និងអន្តរជាតិ) ដែលត្រូវបានអនុម័តនៅ ក្នុងឆ្នាំ ២០០២ ។ | |
| **គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩១ ។ | **អនុសញ្ញាស្តីពីសិទ្ធិកុមារ** (**CRC**) ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៨៩ ។ | **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងកុមារនៅក្នុងជម្លោះប្រដាប់អាវុធ** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០០ ។<br><br>**ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបអាសអាភាសកុមារ** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០០ ។ |
| **គណៈកម្មាធិការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៤ ។ | **អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និង សមាជិកទាំងអស់របស់គ្រួសារពួកគេ** (**ICRMW**) ដែលត្រូវបានអនុម័តនៅក្នុង ឆ្នាំ ១៩៩០ ។ | មិនមានពិធីសារបន្ថែមទេ ។ |
| **គណៈកម្មាធិការការពារសិទ្ធិរបស់ជនពិការ** ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៨ ។ | **អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៦ ។ | **ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** (ដែលអនុញ្ញាតឲ្យមានការប្តឹងជាលក្ខណៈបុគ្គល) ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៦ ។ |
| **គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ** (នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ មិនទាន់ត្រូវបានបង្កើតឡើងទេ) ។ | **អនុសញ្ញាអន្តរជាតិដើម្បីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ** ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៦ (នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ មិនទាន់ចូលជាធរមាននៅឡើយ) ។ | មិនមានពិធីសារទេ ។ |

**i**

## ព័ត៌មានស្តីពីស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

ព័ត៌មានបន្ថែមអំពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានរៀបចំឲ្យមាននៅក្នុង**វិបសាយ** របស់**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR)** និងនៅក្នុង**ឯកសារសង្ខេបព័ត៌មាន**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដូចតទៅនេះ:

- **No. 10 (Rev.1): សិទ្ធិកុមារ**
- **No. 12: គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍**
- **No. 15 (Rev.1): សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយៈ គណៈកម្មាធិការសិទ្ធិមនុស្ស**
- **No. 16 (Rev.1): គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**
- **No. 17: គណៈកម្មាធិការប្រឆាំងទារុណកម្ម**
- **No. 22: ការរើសអើងប្រឆាំងនឹងស្ត្រីភេទៈ អនុសញ្ញា និងគណៈកម្មាធិការ**
- **No. 24 (Rev.1): អនុសញ្ញាអន្តរជាតិស្តីពីពលករទេសន្តរប្រវេសន៍ និងគណៈកម្មាធិការរបស់វា**
- **No. 30: ប្រព័ន្ធសន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិៈ សេចក្តីផ្តើមនៃសន្ធិសញ្ញាសិទ្ធិមនុស្សដ៏សំខាន់ និងស្ថាប័ន សន្ធិសញ្ញាផ្សេងៗ** និង
- **No. 7 (Rev.1): នីតិវិធីបណ្តឹង**

សូមចូលមើលវិបសាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីរកមើលបញ្ជីថ្មីនៃឯកសារសង្ខេបព័ត៌មានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើរបាយការណ៍របស់ភាគីរដ្ឋ ចូរមើល*របាយការណ៍ស្តីពីវិធីសាស្ត្រធ្វើការងាររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សទាក់ទងនឹងដំណើរការធ្វើរបាយការណ៍របស់ភាគីរដ្ឋ* (HRI/MC/2008/4) ។

# ខ. តើស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ធ្វើការងារដោយវិធីណា?

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អនុវត្តមុខងារមួយចំនួន ក្នុងការពិនិត្យតាមដានរបៀបដែលភាគីរដ្ឋអនុវត្តសន្ធិសញ្ញា ។ ទោះណាជាគេ សម្របសម្រួលសកម្មភាពរបស់រដ្ឋទាំងនោះក៏ដោយ ក៏នីតិវិធី និងការអនុវត្តរបស់រដ្ឋទាំងនោះខុសៗគ្នាដែរ ។ ចំណុចខុសគ្នាសំខាន់ៗខ្លះ ពាក់ព័ន្ធនឹងការងាររបស់សង្គមស៊ីវិលត្រូវបានចែងនៅក្នុងឧបសម្ព័ន្ធដែលស្ថិតនៅខាងចុងនៃជំពូកនេះ ។

## ១. ភាតព្វកិច្ចធ្វើរបាយការណ៍របស់ភាគីរដ្ឋ

កាលណារដ្ឋបានផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញាភ្លាម ដោយរួមទាំងកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តបទប្បញ្ញត្តិសំខាន់ៗនៃសន្ធិសញ្ញា រដ្ឋនោះត្រូវទទួលយកកាតព្វកិច្ចក្នុងការដាក់ជូនពិនិត្យ**របាយការណ៍តាមដំណាក់កាល** ទៅគណៈកម្មាធិការពាក់ព័ន្ធដែលស្តីពីវិធានការ ដែលត្រូវបានប្រកាន់យកលើការអនុវត្ត ។ របាយការណ៍ត្រូវតែបង្ហាញអំពីវិធានការច្បាប់ រដ្ឋបាល តាមផ្លូវតុលាការ និងផ្សេងទៀត ដែលរដ្ឋបានអនុម័ត ដើម្បីអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងផ្តល់ព័ត៌មានស្តីពីការលំបាកដែលរដ្ឋនោះជួបប្រទះ ។ របាយការណ៍ទាំងនេះ ត្រូវបានត្រួតពិនិត្យចុងក្រោយដោយគណៈកម្មាធិការពាក់ព័ន្ធ នៅចំពោះមុខគណៈប្រតិភូដែលធ្វើជាតំណាងឲ្យរដ្ឋនោះ ។

តាមធម្មតា **របាយការណ៍ដំបូង** ត្រូវបានតម្រូវឲ្យមានក្នុងរយៈពេលពីមួយទៅពីរឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានៅក្នុងរដ្ឋពាក់ព័ន្ធ ។ ដំណាក់កាលនៃរបាយការណ៍ជាបន្តបន្ទាប់ ផ្លាស់ប្តូរពីពីរទៅប្រាំឆ្នាំ ដោយអាស្រ័យទៅលើបទប្បញ្ញត្តិរបស់សន្ធិសញ្ញា និងសេចក្តីសម្រេចចិត្តដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការ ។ គណៈកម្មាធិការមួយចំនួនតូច ទទួលយករបាយការណ៍ផ្ទួប ដោយមានន័យថា ភាគីរដ្ឋអាចដាក់ជូនពិនិត្យរបាយការណ៍តាមដំណាក់កាលរបស់វាពីរ ឬ ច្រើន ដោយសារតែគណៈកម្មាធិការកំណត់មួយនៅក្នុងរបាយការណ៍ផ្ទួបមួយ ។ ស្ថាប័នសន្ធិសញ្ញាភាគច្រើន កំណត់ថានៅពេលណារបាយការណ៍បន្ទាប់ ដល់ពេលកំណត់ដាក់ជូនពិនិត្យនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន ។

ភាគីរដ្ឋ ត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលការរៀបចំរបាយការណ៍របស់ខ្លួន សម្រាប់ស្ថាប័នសន្ធិសញ្ញា ដោយមិនត្រឹមតែជាការបំពេញកាតព្វកិច្ចអន្តរជាតិប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងជាឱកាស ដើម្បីវាយតម្លៃលើស្ថានភាពនៃកិច្ចការពារសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន ដើម្បីគោលបំណងនៃការធ្វើផែនការគោលនយោបាយផងដែរ ។

## ២. ការពិចារណាលើរបាយការណ៍របស់ភាគីរដ្ឋ ដោយស្ថាប័នសន្ធិសញ្ញា

### បញ្ជីបញ្ហា

មុនវគ្គប្រជុំពេញអង្គដែលក្នុងនោះ គណៈកម្មាធិការ នឹងពិចារណាលើរបាយការណ៍របស់ភាគីរដ្ឋ គណៈកម្មាធិការ រៀបចំ**បញ្ជីបញ្ហា** និងសំណួរ ដែលត្រូវបានបញ្ជូនទៅភាគីរដ្ឋ ។ តាមធម្មតា ភាគីរដ្ឋ នឹងដាក់ជូនពិនិត្យរបាយការណ៍ឆ្លើយតបរបស់ខ្លួនទៅនឹងបញ្ជីនេះជាលាយលក្ខណ៍អក្សរ ។ ចម្លើយទាំងនេះ ត្រូវបានដាក់ផ្សាយនៅក្នុងវិបសាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

របាយការណ៍ឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងបញ្ជីបញ្ហា បំពេញបន្ថែមរបាយការណ៍របស់ភាគីរដ្ឋ និងមានសារៈសំខាន់យ៉ាងពិសេស នៅពេលដែលមានការពន្យារពេលយូរ នៅចន្លោះរវាងការដាក់ជូនពិនិត្យរបាយការណ៍តាមដំណាក់កាល និងការត្រួតពិនិត្យវា ។

គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ និងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ដែលនីមួយៗ រៀបចំកិច្ចប្រជុំក្រុមការងារមុនវគ្គប្រជុំពេញអង្គដែលមានរយៈពេលមួយសប្តាហ៍ ដើម្បីរៀបចំបញ្ជីបញ្ហា និងសំណួរទាក់ទងនឹងរបាយការណ៍របស់ភាគីរដ្ឋ ដែលគេនឹងពិចារណា នៅពេលអនាគតដ៏ខ្លីខាងមុខ ។ គណៈកម្មាធិការសិទ្ធិមនុស្សប្រគល់កិច្ចការនេះ ឲ្យទៅ**ក្រុមការងារពិសេសទទួលបន្ទុករបាយការណ៍ប្រចាំប្រទេស**របស់ខ្លួន[15] ដែលជួបប្រជុំគ្នាក្នុងអំឡុងពេលវគ្គប្រជុំពេញអង្គ មុនវគ្គប្រជុំពេញអង្គដែលរបាយការណ៍របស់រដ្ឋណាមួយនឹងត្រូវបានត្រួតពិនិត្យ ។

គណៈកម្មាធិការភាគច្រើន តែងតាំងសមាជិករបស់គេម្នាក់ជា**អ្នករាយការណ៍ប្រចាំប្រទេស** ដើម្បីដឹកនាំក្នុងការរៀបចំបញ្ជីបញ្ហាសម្រាប់ប្រទេសជាក់លាក់ ។

## ប្រភពផ្សេងទៀតនៃព័ត៌មាន

ដោយរួមទាំងរបាយការណ៍របស់ភាគីរដ្ឋ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អាចទទួលព័ត៌មានស្តីពីការអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញាពីទីភ្នាក់ងារ មូលនិធិ និងកម្មវិធីរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាលផ្សេងទៀត ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចជា ពីសង្គមស៊ីវិល ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល (ទាំងជាតិ និងអន្តរជាតិ) សមាគមអ្នកវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សាអប់រំ ។

## ការពិចារណាទៅលើរបាយការណ៍របស់ភាគីរដ្ឋ

ភាគីរដ្ឋ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ដើម្បីបង្ហាញរបាយការណ៍របស់ខ្លួន ឆ្លើយតបទៅនឹងសំណួររបស់សមាជិកគណៈកម្មាធិការ និងផ្តល់ដល់គណៈកម្មាធិការនូវព័ត៌មានបន្ថែម ។ ដោយពិចារណាលើព័ត៌មានទាំងអស់ ដែលត្រូវបានរៀបចំឲ្យមានគណៈកម្មាធិការត្រួតពិនិត្យរបាយការណ៍រួមគ្នាជាមួយនឹងតំណាងរដ្ឋាភិបាល ។ គោលបំណង គឺដើម្បីចូលរួមពាក់ព័ន្ធក្នុងកិច្ចពិភាក្សាក្នុងន័យស្ថាបនា ដើម្បីជួយដល់រដ្ឋក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋនោះ ក្នុងការអនុវត្តសន្ធិសញ្ញាឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើបាន។ ស្ថាប័នសន្ធិសញ្ញាមិនមែនជាតុលាការទេ ហើយគេពិនិត្យតាមដានការអនុវត្តសន្ធិសញ្ញា និងផ្តល់ជំរុញលើកទឹកចិត្ត និងការណែនាំដល់រដ្ឋទាំងឡាយ ។

[15] ក្រុមការងារពិសេសទទួលបន្ទុករបាយការណ៍ប្រចាំប្រទេស មានអ្នករាយការណ៍ប្រចាំប្រទេស និងសមាជិកដទៃទៀតចំនួនពីបួនទៅប្រាំមួយរូបរបស់គណៈកម្មាធិការដែលត្រូវបានជ្រើសតាំងឡើងដោយប្រធានគណៈកម្មាធិការ ។

i

ព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ស្តីពី**វគ្គប្រជុំពេញអង្គរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនៅពេលខាងមុខ** និងរដ្ឋទាំងឡាយដែលត្រូវបានរៀបចំគម្រោងពេលវេលា ដើម្បីបង្ហាញខ្លួននៅក្នុងវគ្គប្រជុំពេញអង្គទាំងនោះ ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកស្តីពីអង្គ/គណៈសន្ធិសញ្ញាសិទ្ធិមនុស្សនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## សេចក្តីសង្កេតសន្និដ្ឋាន និងអនុសាសន៍

ដោយមានមូលដ្ឋាននៅលើកិច្ចពិភាក្សារបស់ខ្លួនជាមួយនឹងរដ្ឋ និងព័ត៌មានផ្សេងទៀតក៏ដោយដែលគេបានទទួលបាន ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អនុម័តលើអ្វីដែលត្រូវបានគេដឹងជាទូទៅថាជា**សេចក្តីសង្កេតសន្និដ្ឋាន**[16] ដែលសំដៅទៅលើទាំងទិដ្ឋភាពវិជ្ជមាននៃការអនុវត្តសន្ធិសញ្ញារបស់រដ្ឋ និងផ្នែកដែលអង្គ/គណៈសន្ធិសញ្ញា ផ្តល់អនុសាសន៍ដល់រដ្ឋឲ្យអនុវត្តវិធានការបន្តទៀត ។ វាមានសារៈសំខាន់ចំពោះភាគីរដ្ឋក្នុងការធ្វើការរាយការណ៍ត្រឡប់ទៅគណៈកម្មាធិការវិញ នៅក្នុងរបាយការណ៍តាមដំណាក់កាលជាបន្តបន្ទាប់ស្តីពីវិធានការដែលត្រូវប្រកាន់យក ដើម្បីអនុវត្តអនុសាសន៍ទាំងនេះ ក៏ដូចជា បទប្បញ្ញត្តិនៃសន្ធិសញ្ញា ។

## ការអនុវត្តបន្តនូវអនុសាសន៍

ដើម្បីជួយដល់រដ្ឋទាំងឡាយក្នុងការអនុវត្តអនុសាសន៍របស់ខ្លួន ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស បានចាប់ផ្តើមណែនាំឲ្យប្រើប្រាស់នូវនីតិវិធី ដើម្បីធានាឲ្យមានការអនុវត្តបន្តប្រកបដោយប្រសិទ្ធភាពនូវសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន ។ គណៈកម្មាធិការខ្លះ ស្នើសុំនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួនថា រដ្ឋទាំងឡាយត្រូវធ្វើការរាយការណ៍ត្រឡប់ទៅអ្នករាយការណ៍ប្រចាំប្រទេសវិញ ឬ តាមដានបន្តនៅក្នុងរយៈពេលកំណត់ដែលត្រូវបានព្រមព្រៀង ស្តីពីវិធានការដែលត្រូវបានអនុវត្តក្នុងការឆ្លើយតបទៅនឹងអនុសាសន៍ជាក់លាក់ ឬ "កង្វល់ជាអាទិភាព" ។ បន្ទាប់មក អ្នករាយការណ៍ រាយការណ៍ត្រឡប់ទៅគណៈកម្មាធិការវិញ ។

សមាជិកខ្លះនៃស្ថាប័នសន្ធិសញ្ញា បានទទួលរ៉ាប់រងបំពេញបេសកកម្មទៅកាន់ប្រទេសនានា តាមការអញ្ជើញរបស់ភាគីរដ្ឋ ដើម្បីតាមដានបន្តនូវរបាយការណ៍ និងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន ។

# ៣. ការពិចារណាទៅលើពាក្យបណ្តឹងពីបុគ្គល ដែលទាមទារថា សិទ្ធិរបស់ពួកគេ ត្រូវបានរំលោភបំពានដោយភាគីរដ្ឋ

[16] ក៏ត្រូវបានហៅថាជា "សេចក្តីសង្កេតសន្និដ្ឋាន" របស់គណៈកម្មាធិការខ្លះ ដោយអនុលោមទៅតាមពាក្យពេចន៍របស់សន្ធិសញ្ញារបស់ខ្លួន ។

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនប្រាំពីរ អាចប្រសិនបើល័ក្ខខ័ណ្ឌខ្លះត្រូវបានបំពេញ ពិចារណាលើពាក្យបណ្តឹង ឬ **ឯកសារបណ្តឹងពីបុគ្គល** ដែលទាមទារថា សិទ្ធិរបស់ពួកគេ ត្រូវបានរំលោភបំពានដោយភាគីរដ្ឋ ។ គណៈកម្មាធិការទាំងនេះ គឺ គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍ គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ គណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ គណៈកម្មាធិការការពារសិទ្ធិរបស់ជនពិការ និង គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ ។ **នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ យន្តការទទួលពាក្យបណ្តឹងរបស់គណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ មិនទាន់ចូលជាធរមាននៅឡើយទេ និង យន្តការទទួលពាក្យបណ្តឹងរបស់គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ មិនទាន់ត្រូវបានបង្កើតឡើងទេ ។** នៅពេលដែលវាចូលជាធរមាន ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ក៏នឹងអនុញ្ញាតឲ្យមានការប្តឹងជាលក្ខណៈបុគ្គល ។

ស្ថាប័នសន្ធិសញ្ញា មិនអាចពិចារណាលើពាក្យបណ្តឹងទាក់ទងនឹងភាគីរដ្ឋទេ លុះត្រាតែភាគីរដ្ឋនោះបានទទួលស្គាល់ដោយជាក់លាក់នូវសមត្ថភាពរបស់ស្ថាប័ន សន្ធិសញ្ញានោះក្នុងការធ្វើដូច្នេះ ដោយធ្វើ**សេចក្តីប្រកាស**ដូចមានចែងនៅក្នុងមាត្រានៃសន្ធិសញ្ញាពាក់ព័ន្ធ ឬ ដោយទទួលយកពិធីសារបន្ថែមដែលពាក់ព័ន្ធ ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្តីពីការប្តឹងជា**លក្ខណៈបុគ្គល** សូមមើល**ជំពូក VIII (ការដាក់ជូនពិនិត្យពាក្យបណ្តឹងស្តីពីការរំលោភបំពានសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍)** នៃសៀវភៅនេះ ។
>
> ព័ត៌មានពិស្តារអំពីការប្តឹងជាលក្ខណៈបុគ្គលទៅស្ថាប័ន សន្ធិសញ្ញា (ក៏ត្រូវបានហៅផងដែរថា បដ្ឋនាលិខិត) ក្នុងនោះរួមមាន ការណែនាំ និងអនុទ្ទេសស្តីពីវិធីដាក់ជូនពិនិត្យពាក្យបណ្តឹងផងដែរ ក៏ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ៤. បណ្តឹង និងទំនាស់អន្តររដ្ឋ

សន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួនតូច មានបទប្បញ្ញត្តិអនុញ្ញាតឲ្យភាគីរដ្ឋ ប្តឹងទៅស្ថាប័នសន្ធិសញ្ញាពាក់ព័ន្ធ អំពីការរំលោភបំពានលើសន្ធិសញ្ញារបស់ភាគីរដ្ឋមួយទៀត ។ **នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ នីតិវិធីទាំងនេះ មិនដែលត្រូវបានប្រើប្រាស់ទេ ។**

## ៥. ការស៊ើបសួរ

ស្ថាប័នសន្ធិសញ្ញាចំនួនបួន ពោលគឺ គណៈកម្មាធិការប្រឆាំងទារុណកម្ម គណៈកម្មាធិការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការការពារសិទ្ធិជនពិការ និងគណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ (កាលណាត្រូវបានបង្កើតឡើងភ្លាម) អាចផ្តួចផ្តើមការស៊ើបសួរជាលក្ខណៈសម្ងាត់ ប្រសិនបើគេទទួលបានព័ត៌មានដែលអាចជឿទុកចិត្តបាន និងមានសន្ទស្សន៍សមហេតុសមផល ស្តីពីការ

រំលោភបំពានដ៏ធ្ងន់ធ្ងរ ធ្ងន់ធ្ងរខ្លាំង ឬ ជាលក្ខណៈប្រព័ន្ធលើអនុសញ្ញារៀងៗខ្លួនរបស់គេនៅក្នុងភាគីរដ្ឋ ។ ការស៊ើបសួរ មិនអាចត្រូវបានរ៉ាប់រងអនុវត្តចំពោះភាគីរដ្ឋ ដែលបានសម្រេចចិត្តមិនចូលរួមក្នុងយន្តការនេះ និងដោយហេតុនេះ បដិសេធដោយច្បាស់លាស់នូវសមត្ថភាពរបស់គណៈកម្មាធិការពាក់ព័ន្ធ ក្នុងការអនុវត្តការស៊ើបសួរ ។[17]

ក្នុងករណីដែលត្រូវបានធានា និងដោយមានការយល់ព្រមពីភាគីរដ្ឋ ការស៊ើបសួរ ក៏អាចរួមបញ្ចូលដំណើរទស្សនកិច្ចទៅកាន់រដ្ឋ ។ បន្ទាប់ពីត្រួតពិនិត្យលើលទ្ធផលរកឃើញនៃការស៊ើបសួរបែបនេះ គណៈកម្មារធិការ បញ្ជូនវាទៅភាគីរដ្ឋពាក់ព័ន្ធ រួមជាមួយនឹងសេចក្ដីសង្កេត និងអនុសាសន៍ ។

នីតិវិធីការស៊ើបសួរ មានលក្ខការណ៍សម្ងាត់ និងកិច្ចសហប្រតិបត្តិការរបស់ភាគីរដ្ឋ ត្រូវតែបានស្វែងរកនៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីទាំងមូល ។

> *i* ព័ត៌មានថ្មីស្ដីពី**ការស៊ើបសួរ** អាចត្រូវបានរកឃើញនៅក្នុងឯកសារ**ឯកសារសង្ខេបព័ត៌មានលេខ** ៣០ *ស្ដីពីប្រព័ន្ធសន្ធិសញ្ញាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ។*

## ៦. នីតិវិធីព្រមានជាមុន និងវិធានការបន្ទាន់

ចាប់តាំងពីឆ្នាំ ១៩៩៣ មក គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍ បានបង្កើតនីតិវិធីដែលទាក់ទងនឹង**ការព្រមានជាមុន និងវិធានការបន្ទាន់** ។[18] នីតិវិធីព្រមានជាមុន មានគោលបំណងទប់ស្កាត់បញ្ហាដែលមានស្រាប់របស់ភាគីរដ្ឋមិនឲ្យក្លាយទៅជម្លោះថ្មី ឬ ទប់ស្កាត់ការបន្តជម្លោះ ។ នីតិវិធីវិធានការបន្ទាន់ មានគោលបំណងឆ្លើយតបទៅនឹងបញ្ហាដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ភ្លាមៗក្នុងការទប់ស្កាត់ ឬ កម្រិតលក្ខខណ្ឌលើកម្រិត ឬ ចំនួននៃការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ។ តាមការអនុវត្តជាក់ស្ដែង នីតិវិធីទាំងនេះត្រូវបានប្រើប្រាស់ដោយព្រមៗគ្នា ។ វាអាចត្រូវបានប្រើប្រាស់ ដោយគណៈកម្មាធិការខ្លួនឯង ឬ ដោយភាគីដែលចាប់អារម្មណ៍ ក្នុងនោះរួមមាន តួអង្គសង្គមស៊ីវិល ដូចជា ក្រុមរបស់ជនជាតិដើមភាគតិច ។

## ៧. សេចក្ដីសង្កេតទូទៅ

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ផ្សព្វផ្សាយអំពីការបកស្រាយរបស់ខ្លួនលើបទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សដែលស្ថាប័នសន្ធិសញ្ញានេះ ពិនិត្យតាមដាន ក្នុងទម្រង់ជា**សេចក្ដីសង្កេតទូទៅ** (គណៈកម្មាធិការ

---

[17] នៅពេលផ្ដល់សច្ចាប័ន ឬ ចូលជាភាគី រដ្ឋភាគីនៃអនុសញ្ញាប្រឆាំងទារុណកម្ម អាចសម្រេចចិត្តមិនចូលរួម ដោយធ្វើសេចក្ដីប្រកាសដូចមានចែងនៅក្នុងមាត្រា ២៨ ។ ស្រដៀងគ្នានេះ ភាគីរដ្ឋជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីបំបាត់រាល់ទម្រង់នៃរើសអើងប្រឆាំងនឹងស្ត្រីភេទ អាចបដិសេធសមត្ថភាពរបស់គណៈកម្មាធិការ ដោយធ្វើសេចក្ដីប្រកាសដូចមានចែងក្នុងមាត្រា ១០ ។ រដ្ឋណាមួយដែលសម្រេចចិត្តមិនចូលរួម ក្នុងយន្តការអាចសម្រេចចិត្តទទួលយកវានៅដំណាក់កាលបន្ទាប់ ។

[18] ចូរមើលឧបសម្ព័ន្ធ III នៃ A/48/18 ។

លុបបំបាត់ការរើសអើងជាតិសាសន៍ និងគណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ ប្រើប្រាស់វាក្យសព្ទ "អនុសាសន៍ទូទៅ") ។

សេចក្តីសង្កេត ផ្តល់នូវការណែនាំស្តីពីការអនុវត្តអនុសញ្ញា ។ វារួមបញ្ចូលកម្មវត្ថុច្រើនប្រភេទ ចាប់ពីការបកស្រាយគ្រប់ជ្រុងជ្រោយនូវបទប្បញ្ញត្តិសម្រាប់ការណែនាំទូទៅ លើព័ត៌មានស្តីពីមាត្រាជាក់លាក់នៃសន្ធិសញ្ញាដែលរដ្ឋទាំងឡាយ ដាក់ជូនពិនិត្យតាមរយៈរបាយការណ៍របស់ខ្លួន ។

> *i*
>
> **សេចក្តីសង្កេតទូទៅ និងអនុសាសន៍ទូទៅ** ដែលត្រូវបានអនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានចងក្រងជារៀងរាល់ឆ្នាំ ។ ដើម្បីប្រើប្រាស់វា និងព័ត៌មានស្តីពី**កិច្ចពិភាក្សានៅថ្ងៃ**ខាងមុខ ចូរចូលមើល**ផ្នែក**ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស**នៃវិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** ។

## ៨. កិច្ចពិភាក្សាទូទៅ/កិច្ចពិភាក្សាវែកញែកប្រធានបទទូទៅជាច្រើនថ្ងៃ

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួន រៀបចំកិច្ចពិភាក្សាទូទៅលើប្រធានបទពិសេសណាមួយ ឬបញ្ហាកង្វល់ ។ តាមធម្មតា កិច្ចពិភាក្សាប្រធានបទទាំងនេះ បើកចំហឲ្យមានការចូលរួមពីអ្នកចូលរួមខាងក្រៅ ដូចជា ដៃគូរបស់អង្គការសហប្រជាជាតិ គណៈប្រតិភូមកពីភាគីរដ្ឋ និងតួអង្គសង្គមស៊ីវិល ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាអប់រំ សមាគមអ្នកវិជ្ជាជីវៈ និងមន្ត្រីជំនាញម្នាក់ៗ ។ លទ្ធផលរបស់វាអាចជួយដល់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងការធ្វើពង្រាងសេចក្តីសង្កេតទូទៅថ្មី ។ វាក៏ជួយផងដែរដល់រដ្ឋ និងអ្នកពាក់ព័ន្ធដទៃទៀត ឲ្យស្វែងយល់ពីលក្ខខណ្ឌនៃសន្ធិសញ្ញា ។

## ៩. កិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធានស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងកិច្ចប្រជុំអន្តរគណៈកម្មាធិការ

**កិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធានស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស** ប្រព្រឹត្តទៅនៅក្នុងទីក្រុងហ្សឺណែវ និងផ្តល់នូវវេទិកាដល់សមាជិកនៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ដើម្បីពិភាក្សាលើការងាររបស់គេ និងពិចារណាលើរបៀបធ្វើឲ្យប្រព័ន្ធស្ថាប័នសន្ធិសញ្ញាកាន់តែមានប្រសិទ្ធភាពទាំងមូល ។ បញ្ហាដែលត្រូវបានដោះស្រាយនៅក្នុងកិច្ចប្រជុំទាំងនេះ បានរួមបញ្ចូលការបង្កើនប្រសិទ្ធភាព និងការកែលម្អទូទៅលើនីតិវិធីធ្វើសេចក្តីរាយការណ៍អំពីសិទ្ធិមនុស្ស ការធ្វើសុខដុមនីយកម្មលើវិធីសាស្ត្រការងាររបស់គណៈកម្មាធិការ ការអនុវត្តបន្តទៅនឹងសន្និសីទពិភពលោក និងបញ្ហាហិរញ្ញវត្ថុ ។ ការពិគ្រោះយោបល់មិនផ្លូវការជាមួយនឹងភាគីរដ្ឋ ក៏ដូចជាដៃគូរបស់អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក៏បានជាទិដ្ឋភាពមួយនៃកិច្ចប្រជុំរបស់ប្រធានផងដែរ ។

**កិច្ចប្រជុំអន្តរគណៈកម្មាធិការ** រួមបញ្ចូលប្រធាននៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ និងសមាជិកបន្ថែមពីររូបទៀតមកពីគណៈកម្មាធិការនីមួយៗ ។ ការធ្វើជាតំណាងដ៏ធំនៃគណៈកម្មាធិការនៅក្នុងកិច្ចប្រជុំអន្តរគណៈកម្មាធិការ អនុញ្ញាតឲ្យមានការពិភាក្សាកាន់តែលម្អិតលើអនុសាសន៍ស្តីពីបញ្ហាដែលទាក់

ទងនឹងវិធីសាស្ត្រការងារ និងបញ្ហាផ្សេងទៀត ជាងការពិភាក្សាដែលអាចធ្វើបាននៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធាន ។

> **i** សម្រាប់ព័ត៌មានបន្ថែម ស្តីពី **កិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធានស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និង កិច្ចប្រជុំអន្តរគណៈកម្មាធិការ** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ១០. កំណែទម្រង់ស្ថាប័នសន្ធិសញ្ញា

នីតិវិធី និងវិធីសាស្ត្រការងាររបស់ស្ថាប័នសន្ធិសញ្ញា បាននិងកំពុងតែត្រូវបានពិភាក្សាជាផ្នែកមួយនៃកំណែទម្រង់ទូទាំងប្រព័ន្ធដែលអង្គការសហប្រជាជាតិ បានទទួលរ៉ាប់រងអនុវត្តក្នុងឆ្នាំកន្លងមកថ្មីៗនេះ ។[19] កំណែទម្រង់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស រហូតមកដល់ពេលនេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើការសម្របសម្រួល និងការធ្វើសុខដុមនីយកម្មលើវិធីសាស្ត្រការងារ ក្នុងនោះរួមមាន ការអនុម័ត "វិធីអនុវត្តត្រឹមត្រូវ" និងការបង្កើនប្រសិទ្ធភាពតម្រូវការធ្វើសេចក្តីរាយការណ៍របស់ភាគីរដ្ឋ តាមរយៈការប្រើប្រាស់**ឯកសារសំខាន់ទូទៅ** និងរបាយការណ៍ពាក់ព័ន្ធតែនឹងសន្ធិសញ្ញាដែលត្រូវបានកំណត់គោលដៅ ។[20]

ជាបន្ថែម ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស កំពុងតែខិតខំពុះពារដើម្បីបង្កើតកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព រវាងខ្លួនឯង និង**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ជាពិសេសទាក់ទងនឹង**យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល**ថ្មី និងបង្កើតទម្រង់បែបបទសម្រាប់ទំនាក់ទំនងទៅវិញទៅមកដែលបានលើកកម្ពស់ជាមួយនឹងអ្នកមានអាណត្តិនៃ**យន្តការពិសេស** ។[21] ដោយពិចារណាទៅលើការកើនឡើងយ៉ាងរហ័សនៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងនីតិវិធីកំណែទម្រង់ដែលមានរចនាសម្ព័ន្ធកាន់តែច្រើនឡើង ក៏ត្រូវបានពិភាក្សាផងដែរ ក្នុងនោះរួមមាន ដូចដែលបានស្នើឡើងនៅក្នុងឆ្នាំ ២០០៥ ដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅពេលនោះ គឺ អ្នកស្រី លូអ៊ីស៍អាបើ នូវការបង្កើតឲ្យមានឡើងនូវស្ថាប័នសន្ធិសញ្ញាអចិន្ត្រៃយ៍ ដែលត្រូវបានធ្វើឯកភាវូបនីយកម្ម ។

[19] នៅក្នុងរបាយការណ៍ឆ្នាំ ២០០២ ស្តីពី "ការពង្រឹងអង្គការសហប្រជាជាតិៈ របៀបវារៈសម្រាប់ការផ្លាស់ប្តូរបន្ថែមទៀត" របស់លោក (A/57/387 និង Corr.1) លោក កូហ្វីអាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិនៅពេលនោះ បានអំពាវនាវដល់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ឲ្យរៀបចំបង្កើតឲ្យមានយុទ្ធវិធីដែលមានការសម្របសម្រួលកាន់តែច្រើនឡើងចំពោះសកម្មភាពរបស់ខ្លួន ។ នៅក្នុងខែ មីនា ឆ្នាំ ២០០៥ នៅក្នុងរបាយការណ៍ស្តីពី "ដោយមានសេរីភាពកាន់តែច្រើនឡើងៈ ឆ្ពោះទៅរកការអភិវឌ្ឍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា" របស់លោក លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានស្នើឡើងថា "គោលការណ៍ណែនាំដែលមានសុខដុមនីយកម្មស្តីពីការធ្វើសេចក្តីរាយការណ៍ជូនស្ថាប័ន សន្ធិសញ្ញាទាំងអស់ គួរតែត្រូវបានបង្ហើយ និងអនុត្ត ដើម្បីស្ថាប័ន ទាំងនេះអាចដំណើរការទៅបាន ជាប្រព័ន្ធដែលត្រូវបានធ្វើឯកភាវូបនីយកម្ម" (A/59/2005 កថាខ័ណ្ឌទី ១៤៧) ។

[20] ចូរមើល "គោលការណ៍ណែនាំដែលត្រូវបានធ្វើសុខដុមនីយកម្មស្តីពីការធ្វើសេចក្តីរាយការណ៍ ដូចមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ក្នុងនោះរួមមាន គោលការណ៍ណែនាំស្តីពីឯកសារសំខាន់ទូទៅ និងឯកសារពាក់ព័ន្ធតែនឹងសន្ធិសញ្ញាដែលត្រូវបានកំណត់គោលដៅ" (HRI/MC/2005/3) ។

[21] ចូរមើល "ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស ក្នុងនោះរួមមានកាតព្វកិច្ចធ្វើសេចក្តីរាយការណ៍ដូចមានចែងក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស" (A/62/224) ។

## គ. វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹង ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

ការធ្វើការងារជាមួយនឹងស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស បានបញ្ជាក់ថាជារបៀបមួយដែលមានប្រសិទ្ធភាពណាស់ សម្រាប់សង្គមស៊ីវិល ដើម្បីរួមចំណែកក្នុងការអនុវត្តសិទ្ធិមនុស្ស និងការរៀបចំបង្កើតគោលការណ៍សិទ្ធិមនុស្សដ៏ច្បាស់លាស់ ។ នៅថ្នាក់ជាតិ សង្គមស៊ីវិល មានតួនាទីសំខាន់ណាស់ តាមរយៈសកម្មភាពពិនិត្យតាមដាន លើកកម្ពស់ និងអនុវត្តបន្តដែលពាក់ព័ន្ធទៅនឹងការងាររបស់ស្ថាប័ន សន្ធិសញ្ញា។ ការងាររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ទទួលបានផលប្រយោជន៍ពីការចូលរួមដ៏សកម្មរបស់តួអង្គសង្គមស៊ីវិលនៅក្នុងដំណាក់កាលផ្សេងៗ នៃខួបធ្វើសេចក្តីរាយការណ៍ និងនៅក្នុងដំណើរការ ដូចជា បដ្ឋនាលិខិតការស៊ើបសួរ និងការព្រមានជាមុន ។

អង្គការមិនមែនរដ្ឋាភិបាល ជាប្រពៃណី បានជាតួអង្គសង្គមស៊ីវិលដ៏សំខាន់ ដោយចូលរួមជាមួយនឹងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ជាពិសេស នៅក្នុងវគ្គប្រជុំពេញអង្គរបស់ស្ថាប័នសន្ធិសញ្ញា ។ តួអង្គសង្គមស៊ីវិលដទៃទៀត ដូចជា មន្ត្រីជំនាញម្នាក់ៗ និងអ្នកការពារសិទ្ធិមនុស្ស តំណាងគ្រឹះស្ថានសិក្សាអប់រំ និងស្រាវជ្រាវ និងសមាជិកក្រុមអ្នកវិជ្ជាជីវៈ ក៏ជាញឹកញាប់ រួមចំណែកផងដែរដល់ដំណើរការធ្វើសេចក្តីរាយការណ៍ស្តីពីសន្ធិសញ្ញា ។ ការចូលរួមពាក់ព័ន្ធរបស់គេ ជាពិសេស ទាក់ទងនឹងការដាក់ជូនពិនិត្យព័ត៌មានទៅគណៈកម្មាធិការ ឬ ការចូលរួមក្នុងវគ្គប្រជុំពេញអង្គ ជារឿយៗ ត្រូវបានសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាលដែលដឹង និងសកម្មនៅក្នុងប្រព័ន្ធធ្វើសេចក្តីរាយការណ៍របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។

អនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ និងអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ មានការប្រមើលមើលលើតួនាទីសម្រាប់ "ស្ថាប័នដែលមានសមត្ថភាពដទៃទៀត" នៅក្នុងការងាររបស់ស្ថាប័នសន្ធិសញ្ញានីមួយៗរបស់វាដែលនៅក្នុងករណីនៃពីរដំបូង ត្រូវបានបកស្រាយដើម្បីឲ្យមានអង្គការមិនមែនរដ្ឋាភិបាល ។ ជាងនេះទៀត គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ និងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ បានអនុម័តគោលការណ៍ណែនាំអំពីការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងការងាររបស់គេ (នៅក្នុងករណីទាំងនេះ បានផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើអង្គការមិនមែនរដ្ឋាភិបាល) ។[22]

ទម្រង់បែបបទសម្រាប់ទំនាក់ទំនងទៅវិញទៅមករបស់តួអង្គសង្គមស៊ីវិល ប្រែប្រួលពីស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សមួយ ទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សមួយផ្សេងទៀត ។ **វាត្រូវបានចែងនៅក្នុងឧបសម្ព័ន្ធនៃជំពូកនេះ ។**

---

[22] ចូរមើល "ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងសកម្មភាពរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌" (E/C.12/2000/6) និងគោលការណ៍ណែនាំសម្រាប់ការចូលរួមរបស់ដៃគូ (អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីជំនាញម្នាក់ៗ) នៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ (ឧបសម្ព័ន្ធ VIII នៃ CRC/C/90) ។

## ១. ការជំរុញឲ្យមានការអនុម័តលើលិខិតុបករណ៍អន្តរជាតិថ្មី និងការផ្តល់សច្ចាប័ន ឬ ការចូលជាភាគីនៃសន្ធិសញ្ញាដែលកំពុងតែនៅជាធរមាន

សង្គមស៊ីវិល អាចដើរតួរយ៉ាងសកម្មនៅក្នុងការរៀបចំបង្កើត និងការអនុម័តលើលិខិតុបករណ៍អន្តរជាតិថ្មី ។ ដោយការតស៊ូមតិដើម្បីការរៀបចំបង្កើតសន្ធិសញ្ញាថ្មី និងការជំរុញឲ្យមានការអនុម័តវាដោយរដ្ឋទាំងឡាយ តួអង្គសង្គមស៊ីវិល អាចជួយគាំទ្របទដ្ឋានអន្តរជាតិ និងកិច្ចការពារសិទ្ធិមនុស្ស ។

### តួនាទីរបស់សង្គមស៊ីវិលក្នុងការរៀបចំបង្កើតស្តង់ដារសិទ្ធិមនុស្សអន្តរជាតិថ្មី

**អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ និងពិធីសារបន្ថែមរបស់វា**

នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញាស្តីពី សិទ្ធិរបស់ជនពិការ និងពិធីសារបន្ថែមរបស់វា ។ សង្គមស៊ីវិល ជាពិសេស ជនពិការ និងអង្គការ តំណាងរបស់ពួកគេ មានតួនាទី សំខាន់ជាសារវន្តនៅរាល់ដំណាក់កាលនៅក្នុងដំណើរការត្រៀមពាក់ព័ន្ធឆ្ពោះទៅរកការអនុម័តលិខិតុបករណ៍ទាំងនេះ ។ តំណាងរបស់សង្គមស៊ីវិលដែលបានចូលរួមនៅក្នុងការចរចាលើខ្លឹមសារ និងឥឡូវនេះ កំពុងតែសកម្មក្នុងការជំរុញឲ្យមានការផ្តល់សច្ចាប័នលើវាដោយរដ្ឋទាំងឡាយ ។

អនុសញ្ញាស្តីពីសិទ្ធិរបស់ ជនពិការ ត្រូវបានចរចាពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៦ ដោយធ្វើឲ្យវាក្លាយជាសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលបានចរចលឿនបំផុត ។ នៅក្នុងឱកាសអនុម័តវា ឧត្តមស្នងការ អ្នកស្រី លូអ៊ីស៍អាបើ បានកត់សម្គាល់លើការសហការ ដែលមិនធ្លាប់មានពីមុនមករវាងរដ្ឋ អង្គការសហប្រជាជាតិ សង្គមស៊ីវិល និងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) នៅក្នុងការធ្វើសេចក្តីព្រាងសន្ធិសញ្ញាថ្មី ដោយថ្លែងថាៈ

*ខ្ញុំចង់... សម្តែងការគោរពចំពោះសហគមន៍ពិការភាពដែលបានផ្តល់សំទុះដ៏ខ្លាំងសម្រាប់ឱកាសដ៏សំខាន់ជាខ្លាំងនេះ ។ តួនាទីរបស់គេជាតួនាទីផ្លាស់ប្តូរ ។ ដោយមានទំហំកាន់តែធំធេងជាងតាមរយៈសេចក្តីប្រកាស ឬ សេចក្តីថ្លែងការណ៍ណាមួយ ចលនាពិការភាព បញ្ជាក់ថាអាចចំពោះរាល់វិធីដែលអាចធ្វើបានប្រយុទ្ធនឹងនិចលភាព អនាទរភាព និងជារឿយៗការទប់ទល់ជាចំហ ដើម្បីសម្រេចឲ្យបានតាមរយៈអានុភាពនៃច្បាប់ នូវបំណងប្រាថ្នាដោយស្របច្បាប់ឲ្យមានសមភាព និងយុត្តិធម៌ ។*

## អនុសញ្ញាអន្តរជាតិ សម្រាប់កិច្ចការពារមនុស្សទាំងអស់ ពីការបាត់ខ្លួនដោយបង្ខំ

តួអង្គសង្គមស៊ីវិលជាពិសេស សមាគមគ្រួសារជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ គឺជាអ្នកចូលរួមដ៏សកម្មនៅក្នុងវគ្គ ប្រជុំពេញអង្គរបស់ក្រុមការងារនៃ អតីតគណៈកម្មការសិទ្ធិមនុស្ស ដែលបានធ្វើសេចក្តីព្រាងអនុសញ្ញា ។ អ្នកស្រី ម៉ាតាអូយែម ប៉ូដីវ៉ាសខ្វេ ដែលកូនស្រីរបស់គាត់ជាជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ នៅប្រទេសអាសង់ទីន បាននិងកំពុងតែតស៊ូមតិគាំទ្រការបញ្ចប់ការអនុវត្តការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងដើម្បីការអនុម័ត លិខិតុបករណ៍អន្តរជាតិដែលដោះ ស្រាយបញ្ហានេះអស់រយៈពេល ៣០ ឆ្នាំមកហើយ ដោយធ្វើជាតំណាងឲ្យសហព័ន្ធអាមេរិកនៃសមាគមសាច់ញាតិរបស់គណបក្សប្រឆាំងដែលត្រូវឃុំខ្លួនតាមការចាប់ពង្រត់ (FEDEFAM) នៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ។ នៅក្នុងវគ្គប្រជុំពេញអង្គជាលក្ខណៈសម្ពោធន៍នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៦ មុននឹងអនុម័តអនុសញ្ញា អ្នកស្រី ដីវ៉ាសខ្វេ បានមានប្រសាសន៍ថា:

*នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៧ ខ្ញុំបានចូលរួមក្នុងចលនាពេញលេញរបស់សមាគមម្តាយអាសង់ទីនដែលមានកូន ត្រូវបានបាត់ខ្លួនដោយបង្ខំ... ។ រួមជាមួយនឹងស្ត្រីវ័យក្មេងទាំងនោះ ខ្ញុំបានចាប់ផ្តើមដំណើរការរៀនសូត្រ ។ ខ្ញុំបានចាប់ផ្តើមយល់ថា ខ្ញុំមិនគ្រាន់តែស្រាវជ្រាវរកកូនស្រី និង កូនប្រសាររបស់ខ្ញុំប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងរកកូនប្រុស និងកូនស្រីដែលត្រូវបានបាត់ខ្លួនរបស់ អាសង់ទីន និងអាមេរិកឡាទីន និងបច្ចុប្បន្ននេះ រក "អ្នកដែលត្រូវបានបាត់ខ្លួនដោយបង្ខំ" នៅជុំវិញពិភពលោកផងដែរ ។*

*ខ្ញុំចង់ឲ្យអ្នកដឹងថា បន្ទាប់ពីការកើតមានឡើងនូវការឃុំឃាំង និងការបាត់ខ្លួនរបស់អ្នកជាទីស្រឡាញ់ យើងបានឈានដល់ ការសន្និដ្ឋានដ៏ឈឺចាប់ថា មិនមានចម្លើយទេ ។ មិនមានដំណើរការទេ និងមិនមានដីកាកោះដើម្បីពិនិត្យនីត្យានុកូលភាពនៃការឃុំខ្លួនដែរ ឬ សេចក្តីបង្គាប់គាំពារផ្នែកតុលាការ ដែលមានសុពលភាពផងដែរ ។ បន្ទាប់មក វាស្ថិតនៅក្នុងក្តីអស់សង្ឃឹមរបស់យើង ដែលយើង ត្រូវតែជួយសហគមន៍អន្តរជាតិ ប៉ុន្តែគ្រាន់តែ រកឃើញថា មិនមានលិខិតុបករណ៍សមស្រប នៅទីនោះទេ ។ នោះ គឺជាមូលហេតុដែលនាំយើងមកទីនេះជាថ្មីម្តងទៀត លោកប្រធានដោយស្នើសុំអ្នក និងប្រតិភូកិត្តិយសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីអនុម័តជាស្ថាពរនូវអនុសញ្ញានេះ ។ យើងបានធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ ដោយទទួលបានទាំងស្នាដៃ និងសេចក្តីស្រងាកចិត្តយ៉ាងខ្លាំង ប៉ុន្តែបច្ចុប្បន្ននេះ យើងបែរទៅរកអ្នកទាំងអស់គ្នា ដើម្បីឲ្យពិភពលោករបស់យើងគ្មាន ជនរងគ្រោះដោយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការបាត់ខ្លួនដោយបង្ខំ ។*

ប្រសិនបើរដ្ឋ មិនទាន់បានផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញា ឬ ពិធីសារបន្ថែម តួអង្គសង្គមស៊ីវិលជាតិ អាចជំរុញលើកទឹកចិត្តដល់រដ្ឋាភិបាលឲ្យធ្វើដូច្នេះ ដោយសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងប្រព័ន្ធផ្សព្វផ្សាយជាតិ និង/ឬ ដោយលើកកម្ពស់ការយល់ដឹងជាសាធារណៈលើបញ្ហានេះ ។

i

ដើម្បីមើល**ស្ថានភាពនៃការផ្តល់សច្ចាប័ន**លើសន្ធិសញ្ញាសិទ្ធិមនុស្ស និងពិធីសារបន្ថែម ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ២. ការពិនិត្យតាមដានកាតព្វកិច្ចធ្វើសេចក្ដីរាយការណ៍របស់ភាគីរដ្ឋ

ភាគីរដ្ឋ ជានិច្ចកាល មិនអាច ដោយមានមូលហេតុខុសៗគ្នា ដើម្បីបំពេញកាតព្វកិច្ចធ្វើសេចក្ដីរាយការណ៍របស់ខ្លួន ។ សង្គមស៊ីវិល អាចខិតខំពុះពារជំរុញលើកទឹកចិត្តរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងកាលបរិច្ឆេទផុតកំណត់ធ្វើសេចក្ដីរាយការណ៍ និងអាចលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកាតព្វកិច្ចរបស់រដ្ឋ ក្នុងការដាក់ជូនពិនិត្យរបាយការណ៍ទៅតាមពេលកំណត់ ។ តួអង្គសង្គមស៊ីវិល ក៏អាចផ្ដល់ផងដែរដល់រដ្ឋនូវព័ត៌មានបំពេញបន្ថែម ស្ដីពីការអនុវត្តសន្ធិសញ្ញា ដែលត្រូវបានប្រមូលផ្ដុំនៅក្នុងអំឡុងពេលអនុវត្តសកម្មភាពរបស់គេ និងធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងរដ្ឋទាំងឡាយឆ្ពោះទៅរកការអនុវត្តសន្ធិសញ្ញា ។

ប្រសិនបើភាគីរដ្ឋ មិនបានដាក់ជូនពិនិត្យរបាយការណ៍អស់រយៈពេលដ៏យូរ និងមិនបានឆ្លើយតបទៅនឹងសំណើសុំរបាយការណ៍របស់គណៈកម្មាធិការស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អាចពិចារណាលើស្ថានភាពនៅក្នុងប្រទេសនោះ នៅក្នុងវគ្គប្រជុំពេញអង្គមួយក្នុងចំណោមវគ្គប្រជុំពេញជាច្រើនរបស់ខ្លួន ដោយគ្មានរបាយការណ៍ពីភាគីរដ្ឋនោះ ។ នីតិវិធីនេះ ត្រូវបានគេដឹងថាជា**នីតិវិធីត្រួតពិនិត្យឡើងវិញ** ។

**តួអង្គសង្គមស៊ីវិល រួមជាមួយនឹងអង្គការដៃគូរបស់អង្គការសហប្រជាជាតិ អាចរួមចំណែកជាព័ត៌មានដល់ដំណើរការនីតិវិធីនេះ ។ ដោយមានមូលដ្ឋាននៅលើព័ត៌មាននេះ និងកិច្ចពិភាក្សាជាមួយនឹងភាគីរដ្ឋ គណៈកម្មាធិការ នឹងចេញសេចក្ដីសង្កេតសន្និដ្ឋានរបស់ខ្លួន ក្នុងនោះរួមមានអនុសាសន៍ផងដែរ ។**

## ៣. ការដាក់ជូនពិនិត្យព័ត៌មានជាលាយលក្ខណ៍អក្សរ

នៅទូទាំងខួបនៃការធ្វើសេចក្ដីរាយការណ៍ គណៈកម្មាធិការ សូមស្វាគមន៍ព័ត៌មានបន្ថែមស្ដីពីផ្នែកទាំងអស់ដែលត្រូវបានចែងដោយសន្ធិសញ្ញារៀងៗខ្លួនរបស់គេ ដើម្បីពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពនូវការអនុវត្តនៅក្នុងរដ្ឋទាំងឡាយ ។ របៀបដ៏មានប្រសិទ្ធភាពបំផុតមួយសម្រាប់តួអង្គសង្គមស៊ីវិលដាក់ជូនពិនិត្យព័ត៌មានបន្ថែម គឺតាមរយៈ**របាយការណ៍ជាលាយលក្ខណ៍អក្សរ** ។ របាយការណ៍ដ៏មានប្រយោជន៍បំផុតជារឿយៗ គឺរបាយការណ៍ដែលត្រូវបានផលិតឡើង តាមរយៈកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរបស់តួអង្គសង្គមស៊ីវិលជាច្រើន ។ ហេតុដូច្នេះ តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្តឲ្យដាក់ជូនពិនិត្យជារួមនូវព័ត៌មានជាលាយលក្ខណ៍អក្សរស្ដីពីប្រទេសណាមួយ ។

ស្ថានបែបបទសម្រាប់ការដាក់ជូនពិនិត្យព័ត៌មាន ប្រែប្រួលពីស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សមួយទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សមួយទៀត ។ ជាទូទៅ តួអង្គសង្គមស៊ីវិល គួរតែដាក់ជូនពិនិត្យនូវព័ត៌មាន និងឯកសារ បន្ទាប់ពីការដាក់ជូនពិនិត្យនូវរបាយការណ៍របស់ភាគីរដ្ឋទៅស្ថាប័នសន្ធិសញ្ញា និងមុនពេលមានការពិចារណាលើវា ។

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ និងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ សូមស្វាគមន៍ព័ត៌មានជាលាយលក្ខណ៍អក្សរពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក៏ដូចជា ពីតួអង្គសង្គមស៊ីវិលផ្សេងទៀត (ជាពិសេសមន្ត្រីជំនាញម្នាក់ៗ គ្រឹះស្ថានសិក្សាអប់រំ សមាគមអ្នកវិជ្ជាជីវៈ និងសមាជិកសភា) នៅក្នុងកិច្ចប្រជុំក្រុមការងារមុនវគ្គប្រជុំពេញអង្គរបស់ខ្លួន ដើម្បីរៀបចំបញ្ជីបញ្ហា ។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ត្រូវការព័ត៌មានជាលាយលក្ខណ៍អក្សរដែលត្រូវបានដាក់ជូនពិនិត្យ ក្នុងរយៈពេលពីរខែ មុនកិច្ចប្រជុំក្រុមការងារមុនវគ្គប្រជុំពេញអង្គរបស់ខ្លួន ។ តួអង្គសង្គមស៊ីវិល ក្នុងនោះរួមមាន គ្រឹះស្ថានសិក្សាអប់រំ និងសមាគមអ្នកវិជ្ជាជីវៈជាដើម ក៏អាចដាក់ជូនពិនិត្យផងដែរនូវព័ត៌មានជាលាយលក្ខណ៍អក្សរ ជូនទៅក្រុមការងារពិសេសផ្នែករបាយការណ៍ប្រចាំប្រទេសរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម និងគណៈកម្មាធិការសិទ្ធិមនុស្ស ។

ជាទូទៅ ព័ត៌មានជាលាយលក្ខណ៍អក្សរដែលត្រូវបានដាក់ជូនពិនិត្យទៅស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានចាត់ទុកជាព័ត៌មានជាសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការ នឹងរក្សាទុកព័ត៌មានជាការសម្ងាត់ ប្រសិនបើត្រូវបានស្នើសុំដោយជាក់លាក់ឲ្យធ្វើដូច្នេះ ។

របាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលត្រូវបានដាក់ជូនពិនិត្យដោយតួអង្គសង្គមស៊ីវិល មិនក្លាយជាកម្រងឯកសារផ្លូវការរបស់អង្គការសហប្រជាជាតិទេ និងវា ក៏មិនត្រូវបានពិនិត្យផ្ទៀងផ្ទាត់កែសម្រួល ឬបកប្រែភាសាផងដែរ ។ ហេតុដូច្នេះ វាមានលក្ខណៈសំខាន់សម្រាប់តួអង្គសង្គមស៊ីវិលពិចារណាថាតើភាសាណា (ឬ ណាខ្លះ) ដែលត្រូវដាក់ជូនពិនិត្យព័ត៌មានរបស់ខ្លួន និងធានាថា ឯកសារស្នើសុំពិនិត្យ ត្រូវបានប្រើប្រាស់ភាសាមួយក្នុងចំណោមភាសាការងារជាច្រើនរបស់គណៈកម្មាធិការពាក់ព័ន្ធមួយ (ឬ ច្រើន) ។

**មុននឹងដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ វាមានលក្ខណៈសំខាន់ត្រូវពិនិត្យមើលៈ**

- ថាតើរដ្ឋ បាន**ផ្តល់សច្ចាប័ន ឬ ចូលជាភាគី**នៃលិខិតុបករណ៍ពាក់ព័ន្ធឬអត់ និងប្រសិនបើដូច្នេះមែន ទំហំនៃសេចក្តីថ្លែងការណ៍ណាមួយដែលរដ្ឋនោះបានរៀបចំឡើងចំពោះបទបញ្ញត្តិរបស់វា ។ (ជាទូទៅ សេចក្តីថ្លែងការណ៍ មិនរារាំងតួអង្គសង្គមស៊ីវិលពីការដោះស្រាយបញ្ហាជាក់លាក់ និងពីការជម្រាបជូនឲ្យបានជ្រាបអំពីវាដល់គណៈកម្មាធិការនោះឡើយ) ។
- **នៅពេលដែលរបាយការណ៍បន្ទាប់របស់រដ្ឋ បានមកដល់ពេលកំណត់ដាក់ជូនពិនិត្យ** និងនៅពេលដែលវគ្គប្រជុំពេញអង្គបន្ទាប់របស់គណៈកម្មាធិការពាក់ព័ន្ធ ត្រូវបានកំណត់ពេលវេលា ។ កាលបរិច្ឆេទទាំងនេះ ស្ថិតនៅក្រោមការផ្លាស់ប្តូរ ដោយផ្តល់ដំណឹងជាមុនក្នុងរយៈពេលខ្លី ដូច្នេះ វាមានលក្ខណៈសំខាន់ត្រូវមានទំនាក់ទំនងជាទៀងទាត់ ជាមួយនឹងលេខាធិការដ្ឋានរបស់គណៈកម្មាធិការពាក់ព័ន្ធនៅក្នុងដំណើរការត្រៀមពាក់ព័ន្ធឆ្ពោះទៅវគ្គប្រជុំពេញអង្គនីមួយៗ ។
- បញ្ហាចម្បងដែលកំពុង ឬ បាននិងកំពុងពិចារណា ។ វាមានលក្ខណៈសំខាន់សម្រាប់តួអង្គសង្គមស៊ីវិល ធ្វើឲ្យខ្លួនឯងយល់អំពី**ខ្លឹមសារនៃរបាយការណ៍របស់ភាគីរដ្ឋមុនៗ ក៏ដូចជា សេចក្តីសង្កេតសន្និដ្ឋានមុនៗ និងបញ្ជីបញ្ហាមុនៗផងដែរ** ។ និង

- **គោលការណ៍ណែនាំរធ្វើសេចក្ដីរាយការណ៍**របស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ (ដើម្បីតួអង្គសង្គមស៊ីវិល អាចជួយពិនិត្យតាមដានលើកម្រិតដែលរបាយការណ៍របស់ភាគីរដ្ឋ អនុលោមទៅគោលការណ៍ណែនាំ) ។

## *i* ការដាក់ជូនពិនិត្យរបាយការណ៍ជាលាយលក្ខណ៍អក្សរ

របៀបដ៏មានប្រយោជន៍បំផុតសម្រាប់តួអង្គសង្គមស៊ីវិលដាក់ជូនពិនិត្យនូវព័ត៌មានទៅស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស គឺដោយផលិតរបាយការណ៍ជាលាយលក្ខណ៍អក្សររួមជាមួយនឹងរបាយការណ៍របស់រដ្ឋ ។

មុននឹងតួអង្គសង្គមស៊ីវិល ចាប់ផ្តើមព្រាងរបាយការណ៍របស់ខ្លួន គេត្រូវបានណែនាំឲ្យធ្វើឲ្យខ្លួនឯងយល់ជាមុននូវគោលការណ៍ណែនាំធ្វើសេចក្តីរាយការណ៍ជាក់លាក់របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយ ។ របាយការណ៍ជាលាយលក្ខណ៍អក្សរ គួរតែមានបំណងធ្វើឲ្យដូចរចនាសម្ព័ន្ធរបស់របាយការណ៍រដ្ឋ ។ គោលបំណងនៃរបាយការណ៍គួរតែដើម្បីវិភាគជាលក្ខណៈប្រព័ន្ធលើកម្រិតដែលច្បាប់ គោលនយោបាយ និងការអនុវត្តនៅក្នុងភាគីរដ្ឋ អនុលោមតាមគោលការណ៍ និងស្តង់ដារនៃសន្ធិសញ្ញា ។

របាយការណ៍ជាលាយលក្ខណ៍អក្សរ គួរតែ:

- ច្បាស់លាស់ និងជាក់លាក់ ត្រឹមត្រូវ និងមិនលម្អៀង ។
- រំលេចនូវអ្វីដែលអ្នកធ្វើសេចក្តីរាយការណ៍ ចាត់ទុកថាជាបញ្ហាក្នុងការអនុវត្ត និងគួរតែផ្តល់អនុសាសន៍ពិតជាក់ស្តែង ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសណាមួយ ។ និង
- ត្រូវបានដាក់ជូនពិនិត្យឲ្យបានឆាប់តាមដែលអាចធ្វើបាន មុនពេលពិនិត្យដែលបានកំណត់ពេលវេលានៃរបាយការណ៍របស់រដ្ឋ ដែលនេះអនុញ្ញាតឲ្យស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ពិចារណាទៅលើរបាយការណ៍ជាលាយលក្ខណ៍អក្សរ នៅពេលរៀបចំបញ្ជីបញ្ហា ដោយរៀបចំត្រៀមសម្រាប់វគ្គប្រជុំពេញអង្គ និងការធ្វើពង្រាងសេចក្តីសង្កេតសន្និដ្ឋាន ។

គោលការណ៍ណែនាំ:

- ព័ត៌មានដែលតួអង្គសង្គមស៊ីវិលផ្តល់ជូន ត្រូវតែពាក់ព័ន្ធតែនឹងប្រទេស និងពាក់ព័ន្ធនឹងអាណត្តិរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលវាត្រូវបានផ្តោតការយកចិត្តទុកដាក់ទៅលើ ។ ប្រសិនបើ អាចធ្វើបាន វាគួរតែរៀបចំយោងផ្ទាល់ទៅនឹងមាត្រារបស់សន្ធិសញ្ញា ដោយផ្តល់នូវសិទ្ធិជាក់លាក់ ដែលត្រូវបានរំលោភបំពានដោយមានទឡ្ហីករណ៍ ។
- ទឡ្ហីករណ៍នៃការរំលោភបំពានសិទ្ធិមនុស្ស ជានិច្ចកាល គួរតែត្រូវបានអមដោយភ័ស្តុតាង និងកម្រងឯកសារពាក់ព័ន្ធ ។
- ព័ត៌មានទាំងអស់ គួរតែត្រូវបានរៀបចំសេចក្តីយោងដោយត្រឹមត្រូវ ។ នៅពេលរៀបចំសេចក្តីយោងឯកសាររបស់អង្គការសហប្រជាជាតិ លេខកថាខ័ណ្ឌ គួរតែត្រូវបានរៀបចំយោង ដោយហេតុថា លេខទំព័រប្រែប្រួលពីភាសាមួយទៅភាសាមួយទៀត ។ នេះក៏គួរតែអាចយកជាការបានផងដែរ ចំពោះសេចក្តីដកស្រង់នៃរបាយការណ៍របស់រដ្ឋ ដែលត្រូវតែបានរៀបចំយោងជាទម្រង់ផ្លូវការនៃអង្គការសហប្រជាជាតិរបស់វា ។
- ទម្រង់អេឡិចត្រូនិច និងទម្រង់រឹងជាច្រើន គួរតែត្រូវបានផ្តល់ជូនទៅលេខាធិការដ្ឋាននៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធ ដោយហេតុថា លេខាធិការដ្ឋានមិនមានសមត្ថភាពផលិតបន្តឡើងវិញនូវឯកសារពីសង្គមស៊ីវិលទេ ។
- ឯកសារដែលមានភាសាដែលត្រូវបានចាត់ទុកថាជាការរំលោភបំពាន នឹងមិនត្រូវបានទទួលយកឡើយ ។

ឯកសារស្នើសុំពិនិត្យជាលាយលក្ខណ៍អក្សរ របស់សង្គមស៊ីវិលសម្រាប់វគ្គប្រជុំពេញអង្គរបស់អង្គ/គណៈសន្ធិសញ្ញា ជាក់លាក់ ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស **នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ឬ នៅក្នុងករណី គណៈកម្មាធិការសិទ្ធិកុមារ វិបសាយរបស់បណ្តាញព័ត៌មានសិទ្ធិកុមារ (ក្រុមអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកអនុសញ្ញាសិទ្ធិកុមារ)** ។

**សូមមើលប្រអប់នៅខាងចុងនៃជំពូកនេះ សម្រាប់ព័ត៌មានស្តីពីការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ ដែលមានលក្ខណៈជាក់លាក់ចំពោះស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ ។**

## សិក្ខាសាលាបណ្តុះបណ្តាល លើការសរសេររបាយការណ៍ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌

នៅក្នុងខែ មិថុនា ឆ្នាំ ២០០៧ ការិយាល័យបច្ចុប្បន្ននៅមូលដ្ឋានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) នៅ**ចរជៀ** បានរៀបចំសិក្ខាសាលាមួយនៅក្នុងរដ្ឋធានី ទីប៊ិលីស៊ិ សម្រាប់តំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ២០ រូប ស្តីពីការដាក់ជូនពិនិត្យនូវរបាយការណ៍ទៅគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ។ សិក្ខាសាលានេះត្រូវបានសម្របសម្រួលដោយសមាជិកពីររូបរបស់គណៈកម្មាធិការនេះ និងព្យាយាមៈ

- លើកកម្ពស់ការយល់ដឹងអំពីលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស យន្តការពិនិត្យតាមដានរបស់វា និងតួនាទីជាក់លាក់របស់អង្គការមិនមែនរដ្ឋាភិបាល។
- បង្កើនការស្វែងយល់អំពីគោលការណ៍សមភាព ភាពមិនរើសអើង និងការចូលរួមនៅក្នុងការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ។ និង
- បង្កើនចំណេះដឹងអំពីតួនាទីរបស់សង្គមស៊ីវិលក្នុងការពិនិត្យតាមដានវឌ្ឍនភាពលើការអនុវត្តកតិកាសញ្ញានេះ ។

ជាការអនុវត្តបន្តទៅនឹងវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពនេះ កិច្ចប្រជុំតុមូលមួយចំនួន ត្រូវបានរៀបចំឡើង ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានក្នុងអំឡុងឆ្នាំ ២០០៧ ។

# ៤. ការចូលរួម និងការរួមចំណែកក្នុងវគ្គប្រជុំពេញអង្គ របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

## ការចូលរួមវគ្គប្រជុំពេញអង្គ

របាយការណ៍របស់ភាគីរដ្ឋ ត្រូវបានពិចារណានៅក្នុងកិច្ចប្រជុំសាធារណៈ ដែលតួអង្គសង្គមស៊ីវិលអាចចូលរួមបានក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ជួយតួអង្គសង្គមស៊ីវិលឲ្យអាចៈ

- ពន្យល់ដោយសង្ខេបដល់គណៈកម្មាធិការទាំងមូល ឬ សមាជិកម្នាក់ៗរបស់គណៈកម្មាធិការ ។
- សង្កេតការណ៍កិច្ចពិភាក្សារវាងគណៈកម្មាធិការ និងរដ្ឋ ។ និង
- ដឹងពីប្រភពដើមអំពីបញ្ហាដែលត្រូវបានលើកឡើង និងអនុសាសន៍ដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការ ។

ច្បាប់ និងការអនុវត្ត ដែលធ្វើអភិបាលកិច្ចការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ក៏ដូចជា នៅក្នុងអំឡុងពេលមុនវគ្គប្រជុំពេញអង្គ ផ្លាស់ប្តូររវាងគណៈកម្មាធិការ ។

**ការអនុញ្ញាតឲ្យចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស គួរតែត្រូវបានស្នើសុំពីលេខាធិការដ្ឋានពាក់ព័ន្ធជាមុន ។**

## ការរួមចំណែកក្នុងវគ្គប្រជុំពេញអង្គ

តួអង្គសង្គមស៊ីវិល ក្នុងនោះរួមមាន មន្ត្រីជំនាញម្នាក់ៗ អ្នកសិក្សាជាន់ខ្ពស់ និងតំណាងរបស់ក្រុមអ្នកវិជ្ជាជីវៈ អាចមានតួនាទីសកម្មនៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ។ ទោះបីជា គេមិនចូលរួមក្នុងកិច្ចពិភាក្សារវាងភាគីរដ្ឋ និងគណៈកម្មាធិការក៏ដោយ ក៏គេអាចធ្វើបទបង្ហាញជូនសមាជិកគណៈកម្មាធិការលើបញ្ហាដែលត្រូវបានបញ្ចូលទៅក្នុងឯកសារស្នើសុំពិនិត្យជាលាយលក្ខណ៍អក្សររបស់គេដែរ ។

គណៈកម្មាធិការភាគច្រើន រៀបចំទុកដោយឡែកនូវពេលវេលាសម្រាប់ឯកសារស្នើសុំពិនិត្យ ដែលត្រូវបានបង្ហាញដោយផ្ទាល់មាត់ដោយតួអង្គសង្គមស៊ីវិល ។ ចូរមើលឧបសម្ព័ន្ធនៃជំពូកនេះ សម្រាប់ព័ត៌មានបន្ថែមស្តីពីឯកសារស្នើសុំពិនិត្យ ដែលត្រូវបានបង្ហាញដោយផ្ទាល់មាត់ នៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ និងក្រុមការងារមុនវគ្គប្រជុំពេញអង្គ ។

## វគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ

គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ និងគណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ បានលៃទុកនូវពេលវេលាសម្រាប់ការដាក់ជូនពិនិត្យដោយផ្ទាល់មាត់ក្នុងអំឡុងពេលវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍របស់គេ ។ នេះផ្តល់ដល់តួអង្គសង្គមស៊ីវិលនូវឱកាសធ្វើបទបង្ហាញជូនគណៈកម្មាធិការទាំងឡាយនូវបញ្ហា ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់គេ ។

សូមកត់សម្គាល់ថា ដោយមានការលើកលែងចំពោះ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ និងគណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទដែលកិច្ចប្រជុំរបស់គេ ជាកិច្ចប្រជុំបើកចំហនោះ ការពន្យល់ដោយសង្ខេបផ្ទាល់មាត់របស់តួអង្គសង្គមស៊ីវិលប្រព្រឹត្តទៅនៅក្នុងកិច្ចប្រជុំជាសម្ងាត់ ។

## ក្រុមការងារមុនវគ្គប្រជុំពេញអង្គ

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ និងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ បានលៃទុកពេលវេលាជាក់លាក់សម្រាប់តួអង្គសង្គមស៊ីវិល រួមចំណែកក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គ ។ ទោះបីជាគណៈកម្មាធិការផ្សេងទៀតមិនអាចផ្តល់នូវបណ្តាញផ្លូវការសម្រាប់ការរួមចំណែកនេះក៏ដោយ ក៏វានៅតែអាចធ្វើបាន ដោយរៀបចំកិច្ចប្រជុំមិនផ្លូវការជាមួយនឹងសមាជិកគណៈកម្មាធិការ ដោយទាក់ទងនឹងលេខាធិការដ្ឋានរបស់គណៈកម្មាធិការពាក់ព័ន្ធផងដែរ ។

អ្វីដែលជាការរួមចំណែករបស់សង្គមស៊ីវិលនៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គ អាចត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបញ្ហាដែលត្រូវបានផ្ញើជូនទៅរដ្ឋភាគី ។ ក្រុមការងារមុនវគ្គប្រជុំពេញអង្គ ក៏ផ្តល់ផងដែរនូវឱកាសសម្រាប់តួអង្គសង្គមស៊ីវិលដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរ ។ គណៈកម្មាធិការភាគច្រើន មិនអនុញ្ញាតឲ្យគណៈប្រតិភូរបស់រដ្ឋាភិបាល មានវត្តមាននៅក្នុងកិច្ចប្រជុំមុនវគ្គប្រជុំពេញអង្គទេ ។

**i**

**គោលការណ៍ណែនាំសម្រាប់ការដាក់ជូនពិនិត្យផ្ទាល់មាត់នៅក្នុងវគ្គ ប្រជុំពេញអង្គរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងក្រុមការងារមុន វគ្គប្រជុំពេញអង្គ**

- ឯកសារស្នើសុំពិនិត្យ ដែលត្រូវបានបង្ហាញជូនដោយផ្ទាល់មាត់ ត្រូវតែទាក់ទងនឹងសន្ធិសញ្ញាជាក់លាក់ ។
- ឯកសារស្នើសុំពិនិត្យ ដែលត្រូវបានបង្ហាញជូនដោយផ្ទាល់មាត់ ត្រូវតែគោរពកម្រិតពេលវេលា ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការ ។
- តាមធម្មតា មូលដ្ឋានសម្ភារៈសម្រាប់ការបកប្រែផ្ទាល់មាត់ ត្រូវបានរៀបចំឲ្យមាននៅក្នុងវគ្គប្រជុំពេញអង្គទាំងនេះ និងតំណាងរបស់សង្គមស៊ីវិល គួរតែធ្វើឲ្យប្រាកដថា ពួកគេមានរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់ការដាក់ជូនពិនិត្យដោយផ្ទាល់មាត់របស់ពួកគេ ដែលត្រូវបានផ្តល់ជូនទៅអ្នកបកប្រែផ្ទាល់មាត់ ។
- តាមធម្មតា គណៈប្រតិភូក្នុងក្រុមតូចៗដែលបានសម្របសម្រួលដ៏ល្អប្រសើរ មានប្រសិទ្ធភាពជាងគណៈប្រតិភូដែលផ្តោតលើតែកិច្ចការមួយក្នុងក្រុមធំៗ ។ និង
- ភាសាដែលត្រូវបានចាត់ទុកថា រំលោភបំពាន ឬ មានលក្ខណៈខឹងសម្បានឹងមិនត្រូវបានទទួលយកទេ និងនរណាម្នាក់ដែលប្រើប្រាស់ភាសាបែបនេះ អាចនឹងត្រូវបានបណ្តេញចេញពីវគ្គប្រជុំពេញអង្គ ។

**អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ត្រូវបានរំលឹកឲ្យ ទាក់ទងនឹងលេខាធិការដ្ឋានរបស់គណៈកម្មាធិការពាក់ព័ន្ធ ឲ្យបានលឿនបំផុតជាមុន ដើម្បីផ្តល់ព័ត៌មានដល់លេខាធិការដ្ឋានជាផ្លូវការអំពីការចូលរួមដែលបានគ្រោងទុករបស់គេ ។**

## កិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេប

តាមធម្មតា វគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ផ្តល់នូវឱកាសសម្រាប់តួអង្គសង្គមស៊ីវិលជួបប្រជុំមិនផ្លូវការជាមួយនឹងសមាជិកគណៈកម្មាធិការ ។ ជាទូទៅ **កិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេប** ដែលត្រូវបានរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលនោះ អាចត្រូវបានរៀបចំជាព្រឹត្តិការណ៍បន្ទាប់បន្សំក្រៅកិច្ចប្រជុំផ្លូវការដោយជាញឹកញាប់បំផុត នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ចាប់ពីម៉ោង ១ ដល់ម៉ោង ៣ រសៀល ។ សូមកត់សម្គាល់ថា មូលដ្ឋានសម្ភារៈបកប្រែផ្ទាល់មាត់ មិនត្រូវបានរៀបចំឲ្យមានសម្រាប់កិច្ចប្រជុំពន្យល់ប្រាប់ដោយផ្ទាល់មាត់ "ពេលថ្ងៃត្រង់" នេះទេ ។

ការផ្តោតការយកចិត្តទុកដាក់របស់កិច្ចប្រជុំមិនផ្លូវការ គួរតែធ្វើឡើងទៅលើបញ្ហា និងរដ្ឋដែលគណៈកម្មាធិការណាមួយកំពុងតែផ្តោតទៅលើ ។ តាមធម្មតា កិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេបមិនផ្លូវការ ប្រព្រឹត្តទៅនៅថ្ងៃមុន ឬ ចំថ្ងៃដែលមានការពិចារណាលើរបាយការណ៍រដ្ឋរបស់ប្រទេសពាក់ព័ន្ធ ។ កិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេបដែលបានរៀបចំ និងបានសម្របសម្រួលយ៉ាងល្អប្រសើរ មានទំនោរទៅរកការចូលរួមដ៏ច្រើនរបស់សមាជិកគណៈកម្មាធិការ និងមានប្រសិទ្ធភាពជាងកិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេបជាច្រើនលើបញ្ហាខុសៗគ្នាជាច្រើន ។ ហេតុដូច្នេះ តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្តឲ្យសម្របសម្រួលសកម្មភាពរបស់គេ ។

ក្នុងករណីខ្លះ លេខាធិការដ្ឋានរបស់គណៈកម្មាធិការ អាចសម្របសម្រួលកិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេប ដោយផ្តល់នូវបន្ទប់ និងគ្រឿងបរិក្ខារ និងដោយផ្តល់ដំណឹងដល់គណៈកម្មាធិការអំពីកិច្ចប្រជុំពន្យល់ប្រាប់ដោយសង្ខេបនេះ ។

## ៥. ការអនុវត្តបន្តនូវសេចក្តីសង្កេតសន្និដ្ឋានរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស

កាលណាវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ បានប្រព្រឹត្តហើយទៅភ្លាម និងសេចក្តីសង្កេតសន្និដ្ឋាន ត្រូវបានអនុម័តហើយ សង្គមស៊ីវិល អាចធានារ៉ាប់រងអនុវត្តសកម្មភាពអនុវត្តន៍បន្តនៅថ្នាក់ជាតិដើម្បីលើកកម្ពស់ការយល់ដឹងអំពីអនុសាសន៍ និងជំរុញលើកទឹកចិត្តដល់ភាគីរដ្ឋឲ្យអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន។

ហេតុដូច្នេះវាមានលក្ខណៈសំខាន់ថាតួអង្គសង្គមស៊ីវិលធ្វើឲ្យខ្លួនឯងយល់អំពីសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានអនុម័តដោយគណៈកម្មាធិការ ។

i

ចូរចូលមើលវិបសាយរបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីជាវជាប្រចាំទៅ**ការកែសម្រួលអ៊ីម៉ែលសម្រាប់អនុសាសន៍នៃស្ថាប័នសន្ធិសញ្ញា** ។

សង្គមស៊ីវិល អាចធ្វើការងារផ្នែកអនុវត្តបន្តនូវសេចក្តីសង្កេតសន្និដ្ឋានរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ដោយៈ

- **ការធ្វើការងារ**រួមជាមួយនឹងរដ្ឋាភិបាល ដើម្បីជួយដល់រដ្ឋាភិបាលនោះឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួន។ សង្គមស៊ីវិល ជារឿយៗ បំពេញមុខងារជាកាតាលីករ ដើម្បីលើកកម្ពស់កំណែទម្រង់ច្បាប់ជាតិ និង ដើម្បីបង្កើតឡើងនូវគោលនយោបាយជាតិ ។ តួអង្គសង្គមស៊ីវិលក៏អាចប្រើប្រាស់សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការជាមូលដ្ឋានផងដែរ សម្រាប់ការពិភាក្សារបស់គេជាមួយនឹងរដ្ឋាភិបាល និង កម្មវិធីសកម្មភាពផ្ទាល់របស់គេ ។
- **ការពិនិត្យតាមដាន**ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសជាក់លាក់ និងវិធានការដែលត្រូវបានអនុវត្តនៅក្នុងមូលដ្ឋាន ដើម្បីអនុវត្តសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ ។
- **ការលើកកម្ពស់ការយល់ដឹង**អំពីដំណើរការនីតិវិធីរបស់អង្គប្រជុំគណៈកម្មាធិការ អនុសាសន៍ដែលភាគីរដ្ឋ ត្រូវបានតម្រូវឲ្យមានដើម្បីអនុវត្ត និងថាតើសេចក្តីសង្កេតសន្និដ្ឋាន អាចត្រូវបានប្រើប្រាស់ដោយរបៀបណា ដើម្បីពង្រឹងការទទួលបានសិទ្ធិមនុស្សនៅទូទាំងប្រទេស ។ នេះអាចត្រូវបានធ្វើឡើង ដោយការរៀបចំកិច្ចពិភាក្សាប្រធានបទ កិច្ចប្រជុំតុមូល សិក្ខាសាលាធម្មតា និងសិក្សាសាលាពិភាក្សា ដោយការបកប្រែភាសា និងបោះពុម្ពផ្សាយសេចក្តីសង្កេតសន្និដ្ឋាន ឬ ដោយការសហការជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងប្រព័ន្ធផ្សព្វផ្សាយជាតិ ។
- **ការរួមចំណែកនៅក្នុងការងាររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស** ដោយការផ្តល់ដល់គណៈកម្មាធិការនូវព័ត៌មានស្តីពីវឌ្ឍនភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន និងអនុសាសន៍ និងការផ្តល់ដល់គណៈកម្មាធិការទាំងនោះនូវព័ត៌មានដែលបានផ្តោតការយកចិត្តទុកដាក់ និងបានកំណត់ជាគោលដៅ ។

## ៦. វិធីដាក់ជូនពិនិត្យបណ្តឹងបុគ្គលទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

បុគ្គលណាម្នាក់ក៏ដោយដែលមានទទ្បីករណ៍ថា សិទ្ធិរបស់គេដូចមានចែងនៅក្នុងសន្ធិសញ្ញា ត្រូវបានរំលោភបំពានដោយភាគីរដ្ឋដែលជាភាគីនៃសន្ធិសញ្ញានោះ អាចបញ្ជូនបណ្តឹងទៅគណៈកម្មាធិការពាក់ព័ន្ធ **ឲ្យតែរដ្ឋនោះ បានទទួលស្គាល់ចំពោះសមត្ថភាពរបស់គណៈកម្មាធិការក្នុងការទទួលបណ្តឹងនេះ** ។ បណ្តឹងក៏អាចត្រូវបានធ្វើឡើងដោយ**ភាគីទីបី** ក្នុងនោះរួមមានតួអង្គសង្គមស៊ីវិលផងដែរ ជំនួសមុខឲ្យបុគ្គល ទោះជាបុគ្គលនោះ បានផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរដល់គោលដៅនេះ ("លិខិតប្រគល់អំណាច" លិខិតផ្ទេរសិទ្ធិអំណាចក្នុងការអនុវត្ត) ឬ មិនអាចផ្តល់ការយល់ព្រមនេះក៏ដោយ ។

**បណ្តឹងបុគ្គល អាចត្រូវបានដាក់ជូនពិនិត្យបានតែនៅពេលដែលឧបាស្រ័យក្នុងស្រុក ត្រូវបានប្រើប្រាស់អស់ និងលក្ខណវិនិច្ឆ័យនៃការចូលរួមផ្សេងទៀតទាំងអស់ ត្រូវបានបំពេញ ។**

*i* សម្រាប់ព័ត៌មានបន្ថែមស្តីពី**បណ្តឹងបុគ្គល** សូមមើល**ឧបសម្ព័ន្ធនៃជំពូកនេះ** និងជំពូក **VIII (ការដាក់ជូនពិនិត្យបណ្តឹងលើការរំលោភបំពានសិទ្ធិមនុស្សដែលមានទទ្បីករណ៍)** នៃសៀវភៅនេះ។

## ៧. ការផ្តល់ព័ត៌មានសម្រាប់ការស៊ើបសួរជាសម្ងាត់

តួអង្គសង្គមស៊ីវិល ដោយផ្តល់ព័ត៌មានដល់គណៈកម្មាធិការ អាចប្រើប្រាស់ឥទ្ធិពលលើការសម្រេចចិត្តរបស់គណៈកម្មាធិការក្នុងការទទួលរ៉ាប់រងអនុវត្តការស៊ើបសួរជាសម្ងាត់ ។ ការស៊ើបសួរជាសម្ងាត់ ជាយន្តការសំខាន់ ដែលអនុញ្ញាតឲ្យតួអង្គសង្គមស៊ីវិលជម្រាបជូនដល់គណៈកម្មាធិការឲ្យបានដឹងអំពីការរំលោភបំពាន និងស្ថានភាពកង្វល់ ។

ការស៊ើបសួរជាសម្ងាត់ភាគច្រើន ត្រូវបានជំរុញដោយព័ត៌មានដែលត្រូវបានដាក់ជូនពិនិត្យដោយអង្គការមិនមែនរដ្ឋាភិបាល ។ ឧទាហរណ៍ៈ ការស៊ើបសួរជាសម្ងាត់ចំនួនប្រាំពីរ ដែលត្រូវបានទទួលរ៉ាប់រងអនុវត្តដោយគណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម (លើប្រទេសប្រេស៊ីល អេស៊ីប ម៉ិចស៊ីកូ ប៉េរូ ស៊ែប និងម៉ុងតេណេហ្គ្រូ ស្រីលង្កា និងតួគី) ដែលទាំងអស់នេះ ត្រូវបានផ្តួចផ្តើមដោយមានមូលដ្ឋាននៅលើព័ត៌មានដែលត្រូវបានទទួលពីអង្គការមិនមែនរដ្ឋាភិបាល ។ គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទបានបញ្ចប់ការស៊ើបសួរមួយ (លើប្រទេសម៉ិចស៊ីកូ) ។

តួអង្គសង្គមស៊ីវិល ក៏អាចរួមចំណែកជាព័ត៌មានបន្ថែមផងដែរ កាលណាការស៊ើបសួរជាសម្ងាត់ កំពុងតែដំណើរការ ។

## ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការផ្តួចផ្តើមការស៊ើបសួរជាសម្ងាត់

ការស៊ើបសួរលើកទីមួយដូចដែលបានចែងនៅក្នុងមាត្រា ៨ នៃពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះនារីភេទ ត្រូវបានផ្តួចផ្តើមឡើងដោយមានមូលដ្ឋាននៅលើព័ត៌មានដែលត្រូវបានផ្តល់ឲ្យទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ ដោយអង្គការមិនមែនរដ្ឋាភិបាលចំនួនបី ពោលគឺ **អង្គការបញ្ចប់អំពើហិង្សា និងការរើសអើងចំពោះស្ត្រី និង ក្មេងស្រីនៅជុំវិញពិភពលោក អេខ្វ លីធីណាវ មជ្ឈមណ្ឌលកាសាអាមីហ្កាប្រឆាំងនឹងការរំលោភសេពសន្ថវៈលើកដំបូង និងការរំលោភផ្លូវភេទនៅក្រុងអ៊ិក្សវ៉ារ៉េស៍** និង **គណៈកម្មាធិការទទួលបន្ទុកកិច្ចការពារ និងលើកកម្ពស់សិទ្ធិមនុស្សរបស់ម៉ិចស៊ីកូ** ទាក់ទងនឹងការសម្លាប់ និងការបាត់ខ្លួនរបស់ស្ត្រី ចំនួនជាង ២០០នាក់ នៅក្នុងក្រុង ស៊ីយូឌឹតអ៊ិក្សវ៉ារ៉េស៍ **ប្រទេស ម៉ិចស៊ីកូ** ។ អង្គការមិនមែនរដ្ឋាភិបាល បានដាក់ជូនពិនិត្យនូវព័ត៌មានពិស្តារដែលមានទន្និការណ៍នៃការចាប់ពង្រត់ ការរំលោភសេពសន្ថវៈ និងឃាតកម្មលើស្ត្រី ចាប់តាំងពីឆ្នាំ ១៩៩៣ មក។ គណៈកម្មាធិការបានរកឃើញថា ព័ត៌មាននេះ គួរឲ្យជឿទុកចិត្តបាន និងថាវាបានបញ្ចូលសន្ទស្សន៍ដែលបានបង្ហាញនូវភ័ស្តុតាងនៃការរំលោភ បំពានដ៏ធ្ងន់ធ្ងរ ឬ ជាប្រព័ន្ធលើ សិទ្ធិដែលត្រូវបានចែងនៅក្នុងអនុសញ្ញានេះ ។

នៅក្នុងអំឡុងពេល នៃការស៊ើបសួរ ដែលត្រូវបានទទួលរ៉ាប់រងអនុវត្តនៅក្នុងខែ តុលា ឆ្នាំ ២០០៣ អង្គការមិនមែនរដ្ឋាភិបាល បានដាក់ជូនពិនិត្យនូវព័ត៌មានបន្ថែម និងបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរទស្សនកិច្ច ទៅកាន់ប្រទេសម៉ិចស៊ីកូរបស់សមាជិកចំនួនពីររូបនៃគណៈកម្មាធិការនេះ ។ ការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋភាគី បានចេញជារបាយការណ៍គ្រប់ជ្រុងជ្រោយមួយដែលផ្តោតការយកចិត្តទុកដាក់ទៅលើទាំងការរំលោភបំពាន និងសាវតារផ្នែកវប្បធម៌-សង្គមប្រឆាំងនឹងព្រឹត្តិការណ៍ដែលបានកើតឡើង ដោយផ្តោតការយកចិត្តទុកដាក់ទៅលើបុព្វហេតុជាឫសគល់នៃអំពើហិង្សាចំពោះស្ត្រីភេទ និងការផ្តល់អនុសាសន៍យ៉ាងម៉ឺងម៉ាត់ ដើម្បីធានាថាសិទ្ធិដែលត្រូវបានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះនារីភេទ ត្រូវបានសម្រេចបាន ។

របាយការណ៍ និងចម្លើយតបពីរដ្ឋាភិបាលម៉ិចស៊ីកូ ត្រូវបានដាក់ផ្សាយនៅក្នុង**ផ្នែកសម្រាប់ការចម្រើនជឿនលឿនទៅមុខនៃវិបសាយរបស់ស្ត្រី (Division for Advancement of Women's website)** ។

i

គួរអង្គសង្គមស៊ីវិលដែលមានបំណងប្រាថ្នាចង់ដាក់ជូនពិនិត្យនូវព័ត៌មានសម្រាប់**ការស៊ើបសួរជា សម្ងាត់** គួរតែផ្ញើវាទៅៈ

**[ឈ្មោះរបស់គណៈកម្មាធិការ]**
មានការិយាល័យស្ថិតនៅក្នុងៈ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 ប្រទេសស៊ីស

## ៨. ការផ្តល់ព័ត៌មានសម្រាប់នីតិវិធីនៃការព្រមានជាមុន និងវិធានការបន្ទាន់

ព័ត៌មានដែលត្រូវបានដាក់ជូនដោយតួអង្គសង្គមស៊ីវិល អាចជួយធ្វើឲ្យមាននីតិវិធីនៃការព្រមានជាមុន និងវិធានការបន្ទាន់សម្រាប់គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍ ។ នៅក្នុងរយៈពេលកន្លងមក នីតិវិធីទាំងនេះ ត្រូវបានផ្តួចផ្តើមជាលទ្ធផលនៃព័ត៌មាន ដែលត្រូវបានទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល និងក្រុមជនជាតិដើមភាគតិច ។

> **i** សម្រាប់ព័ត៌មានបន្ថែមស្តីពី**បណ្តឹងជាលក្ខណៈបុគ្គល** សូមមើល**ឧបសម្ព័ន្ធនៃជំពូកនេះ** និងជំពូក **VIII** (**ការដាក់ជូនពិនិត្យនូវបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍**) នៃ*សៀវភៅ*នេះ ។

## ៩. ការចូលរួម និងការរួមចំណែកក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រធាន និងកិច្ចប្រជុំអន្តរគណៈកម្មាធិការ

កិច្ចប្រជុំទាំងនេះ បើកចំហឲ្យមានការចូលរួមរបស់តួអង្គសង្គមស៊ីវិលក្នុងឋានៈជា**អ្នកសង្កេតការណ៍**។

កិច្ចប្រជុំអន្តរគណៈកម្មាធិការ មានចំណុចរបៀបវារៈ ដែលអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលទាក់ទងគ្នាទៅវិញទៅមកជាមួយនឹងសមាជិកគណៈកម្មាធិការលើប្រធានបទទូទៅទាក់ទងនឹងមុខងារ នីតិវិធី និងវិធីសាស្ត្រធ្វើការងាររបស់ស្ថាប័នសន្ធិសញ្ញា ។

# ឃ. ធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (OHCHR)

## វិបសាយរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (OHCHR)

ព័ត៌មាន និងកម្រងឯកសារទាក់ទងនឹងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានរៀបចំឲ្យមានជាសាធារណៈនៅក្នុង**វិបសាយរបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល សិទ្ធិមនុស្ស (OHCHR)** ។ ស្ថាប័នសន្ធិសញ្ញានីមួយៗ មានវិបសាយមួយដែលបានបូជាវិភាជន៍ឲ្យដោយមានព័ត៌មានស្តីពីសន្ធិសញ្ញានោះឯង ការផ្តល់សច្ចាប័ននាពេលកន្លងទៅថ្មីៗ វគ្គប្រជុំពេញអង្គនាពេលកន្លងមក និងពេលខាងមុខរបស់គណៈកម្មាធិការ វិធីសាស្ត្រធ្វើការងារ និងផ្នែកជាច្រើនទៀត ។

ជាងនេះទៀត **មូលដ្ឋានទិន្នន័យរបស់ស្ថាប័ន សន្ធិសញ្ញា**ស្តីពីវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (OHCHR) ផ្តល់នូវលទ្ធភាពទទួលបានឯកសារជាច្រើន

ទាក់ទងនឹងស្ថាប័នសន្ធិសញ្ញា ក្នុងនោះរួមមាន របាយការណ៍របស់ភាគីរដ្ឋ សេចក្តីសង្កេតសន្និដ្ឋាន សេចក្តីសង្កេតទូទៅ និងសេចក្តីសម្រេចចិត្តលើទំនាក់ទំនងនីមួយៗ ។

## ឯកសារសង្ខេបព័ត៌មានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស ( OHCHR )

ឯកសារសង្ខេបព័ត៌មានរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួល សិទ្ធិមនុស្ស (**OHCHR**) ក៏ផ្តល់នូវព័ត៌មានស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ បញ្ជីថ្មី និងដែលបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ នៃឯកសារសង្ខេបព័ត៌មានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (**OHCHR**) ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកអត្ថបទបោះពុម្ពផ្សាយនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (**OHCHR**) ។

## ថាសឌីវីដេអូ ស្តីពី "ការនាំយកសិទ្ធិមនុស្សមកមាតុភូមិ" នៃស្ថាប័ន សន្ធិសញ្ញា របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួល សិទ្ធិមនុស្ស ( OHCHR )

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (**OHCHR**) បានផលិតឧបករណ៍បណ្តុះបណ្តាលលើការងាររបស់ស្ថាប័ន សន្ធិសញ្ញាជាទម្រង់ថាសវីដេអូអេឡិចត្រូនិច ដែលមានចំណងជើងថា "ស្ថាប័នសន្ធិសញ្ញាៈ ការនាំយកសិទ្ធិមនុស្សមកមាតុភូមិ" ។ វាត្រូវបានរៀបចំឲ្យមាននៅឯ**ការិយាល័យផ្នែកអត្ថបទបោះពុម្ពផ្សាយ និងព័ត៌មាននៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** នៅពេលមានការស្នើសុំ ។ ចូរទាក់ទងនឹង **publications@ohchr.org** ។

## ប្រព័ន្ធកុំព្យូទ័រ ( អិក្សស្រ្តាណិត )

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនបី មានវិបសាយដែលបានបូជាវិភាជន៍ នៅក្នុងប្រព័ន្ធកុំព្យូទ័រអិក្សត្រាណិតរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (**OHCHR**): គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ និងគណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍ ។ គេហទំព័រនៃប្រព័ន្ធកុំព្យូទ័រអិក្សត្រាណិតស្តីពីស្ថាប័នសន្ធិសញ្ញានីមួយៗ កត់ត្រាខ្លឹមសារពិស្តារនៃរបាយការណ៍របស់រដ្ឋ របាយការណ៍របស់សង្គមស៊ីវិល ព័ត៌មានទាក់ទងនឹងកិច្ចប្រជុំរបស់គណៈកម្មាធិការ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

*i*

ដើម្បីចូលមើលគេហទំព័រនៃប្រព័ន្ធកុំព្យូទ័រ (អិក្យត្រាណិត) ដែលត្រូវបានការពារដោយអក្សរសម្ងាត់នោះ ចូរបំពេញទម្រង់ជាអេឡិចត្រូនិចដែលត្រូវបានរៀបចំឲ្យមាន នៅក្នុងគេហទំព័រក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (**OHCHR**) ។ នៅពេលដែលអ្នកបានធ្វើកិច្ចការនេះចប់ អ្នកនឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងអក្សរសម្ងាត់ តាមរយៈអ៊ីម៉ែល ។

## សន្ទស្សន៍សិទ្ធិមនុស្សជាសកល

**សន្ទស្សន៍សិទ្ធិមនុស្សជាសកល (សន្ទស្សន៍)** គឺជាឧបករណ៍ផ្តល់ព័ត៌ជាអេឡិចត្រូនិច ដែលត្រូវបានរៀបចំជាបឋម ដើម្បីសម្របសម្រួលដល់លទ្ធភាពទទួលបានឯកសារសិទ្ធិមនុស្ស ដែលត្រូវបានចេញផ្សាយដោយ**ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស**របស់អង្គការសហប្រជាជាតិ និង**យន្តការពិសេស**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ វិបសាយថ្មីនេះ (ដែលអាចត្រូវបានប្រើប្រាស់ តាមរយៈវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្ស (OHCHR)) មានសេចក្តីសង្កេតសន្និដ្ឋានទាំងអស់ដែលត្រូវបានចេញផ្សាយដោយស្ថាប័នសន្ធិសញ្ញា ចាប់តាំងពីឆ្នាំ ២០០០ មក ក៏ដូចជា សេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃយន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សពាក់ព័ន្ធនឹងប្រទេសជាក់លាក់ ដែលត្រូវបានអនុម័តតាំងតែពីឆ្នាំ ២០០៦ មកម្លេះ ។ សន្ទស្សន៍នេះ នឹងផ្តល់ក្នុងពេលឆាប់ៗនេះនូវលទ្ធភាពទទួលបានអនុសាសន៍ដែលត្រូវបានផ្តល់ជូននៅក្នុងក្របខ័ណ្ឌនៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

# ឧបសម្ព័ន្ធ: ទម្រង់ជីវប្រវត្តិរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស

ទោះបីជាគណៈកម្មាធិការ មានសកម្មភាព នីតិវិធី និងការអនុវត្តរួមក៏ដោយ ក៏គណៈកម្មាធិការនីមួយៗ មានតម្រូវការផ្ទាល់របស់ខ្លួនផងដែរ ។ ព័ត៌មានខាងក្រោមនេះ ផ្តល់នូវសេចក្តីសង្ខេបរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ ។

## គណៈកម្មាធិការសិទ្ធិមនុស្ស

***ឧបករណ៍ត្រួតពិនិត្យ***

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR) និងពិធីសារបន្ថែមរបស់វា ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់ប្រាំបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នាបីដងក្នុងមួយឆ្នាំនៅក្នុងវគ្គប្រជុំពេញអង្គ ដែលមានរយៈពេលបីសប្តាហ៍ តាមធម្មតានៅក្នុងខែ មីនា នៅឯទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិក្នុងទីក្រុងញូវយ៉ក និង នៅក្នុងខែ កក្កដា និងខែ តុលា/វិច្ឆិកា នៅឯអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូងក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីបានក្លាយជាភាគីនៃអនុសញ្ញានេះ និងបន្ទាប់មក នៅពេលណាដែលគណៈកម្មាធិការ ស្នើសុំ (ចន្លោះពីបីទៅប្រាំឆ្នាំ) ។ សេចក្តីសង្កេតសន្និដ្ឋាននៃរបាយការណ៍មុន តាមធម្មតា បញ្ជាក់បន្ថែមអំពីពេលវេលា ដែលរបាយការណ៍បន្ទាប់ដល់ពេលកំណត់។

***ការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា វិទ្យាស្ថានសិក្សាអប់រំ ឬ ស្រាវជ្រាវ និងសមាគមអ្នកវិជ្ជាជីវៈ អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានគណៈកម្មាធិការ ។ នេះអាចត្រូវបានធ្វើឡើងនៅពេលណាមួយក៏បាន ក៏ប៉ុន្តែ ដោយគួរឲ្យចូលចិត្តជាងនោះគឺ រយៈពេលពីរសប្តាហ៍មុនវគ្គប្រជុំពេញអង្គ ដែលនៅក្នុងនោះ របាយការណ៍របស់ប្រទេសមួយគឺត្រូវ បានពិនិត្យ និងរយៈពេលប្រាំមួយសប្តាហ៍មុនកិច្ចប្រជុំរបស់ក្រុមការងារពិសេសទទួលបន្ទុករបាយការណ៍ប្រចាំប្រទេស ដែលកំណត់អំពីបញ្ជីបញ្ហាដែលត្រូវបានដោះស្រាយនៅក្នុងវគ្គប្រជុំពេញអង្គលើកក្រោយរបស់គណៈ កម្មាធិការ ។ ព័ត៌មានទាំងអស់ត្រូវតែបានដាក់ជូនពិនិត្យជាទម្រង់អេឡិចត្រូនិច និងទម្រង់រឹង (យ៉ាងតិច ២៥ ច្បាប់) ទៅលេខាធិការដ្ឋានរបស់គណៈកម្មាធិការទៅតាម អាសយដ្ឋានដូចខាងក្រោម ។

***ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ ក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ ដើម្បីធ្វើដូច្នេះ ដំបូងគេចាំបាច់ ត្រូវសរសេរទៅកាន់លេខាធិការដ្ឋានទៅតាម អាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។ នៅថ្ងៃដំបូងនៃវគ្គប្រជុំពេញអង្គ ដែលក្នុងនោះរបាយការណ៍របស់ភាគីរដ្ឋ នឹងត្រូវបានពិចារណា

គណៈកម្មាធិការ លែទុកដោយឡែកនូវពេលវេលាសម្រាប់តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល ដើម្បីពន្យល់ដោយសង្ខេបនូវរបាយការណ៍ដោយផ្ទាល់មាត់ នៅក្នុងកិច្ចប្រជុំសម្ងាត់ ។ កិច្ចប្រជុំពេលអាហារពេលព្រឹក និងអាហារថ្ងៃត្រង់បន្ថែម ត្រូវបានរៀបចំឡើងជាទៀងទាត់ ដើម្បីអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ផ្តល់ព័ត៌មានថ្មីបំផុតពាក់ព័ន្ធតែនឹងប្រទេស ។

ក្រុមការងារពិសេសទទួលបន្ទុករបាយការណ៍ប្រចាំប្រទេស ជួបប្រជុំជាសម្ងាត់នៅក្នុងអំឡុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ដើម្បីរៀបចំបញ្ជីបញ្ហាពាក់ព័ន្ធនឹងរបាយការណ៍របស់រដ្ឋ ដែលនឹងត្រូវបានត្រួតពិនិត្យនៅក្នុងវគ្គប្រជុំពេញអង្គលើក្រោយរបស់គណៈកម្មាធិការ ។ ដើម្បីសម្រេចគោលដៅនេះ តួអង្គសង្គមស៊ីវិល អាចគ្រោងទុកជាមុន ដើម្បីរៀបចំកិច្ចប្រជុំពន្យល់ដោយសង្ខេបមិនផ្លូវការជាមួយនឹង សមាជិកគណៈកម្មាធិការ ។

### *បណ្តឹងជាលក្ខណៈបុគ្គល*

**បណ្តឹងជាលក្ខណៈបុគ្គល** ដូចដែលមានចែងនៅក្នុងពិធីសារបន្ថែមទីមួយនៃកតិកាសញ្ញានេះ អាចត្រូវបានផ្ញើជូនទៅ:

**ក្រុមដោះស្រាយបដ្ឋនាលិខិត**
ការិយាល័យអង្គការសហប្រជាជាតិឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩០ ២២
អ៊ីម៉ែល: tb-petitions@ohchr.org

### *ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន*

គណៈកម្មាធិការសិទ្ធិមនុស្ស
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខ: +៤១ (0)២២ ៩១៧ ៩០ ២៩
ទូរស័ព្ទលេខ: +៤១ (0)២២ ៩១៧ ៩៣ ៣២ ឬ +៤១ (0)២២ ៩១៧ ៩៣ ៩៥

ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពី**គណៈកម្មាធិការសិទ្ធិមនុស្ស** ចូរមើល**ឯកសារសង្ខេបព័ត៌មាន លេខ ១៥ (កែសម្រួលលើកទី ១)** ។ ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីពិធីសារបន្ថែមទីមួយនៃកតិកាសញ្ញានេះ សូមចូលមើលផ្នែកស្ថាប័នសន្ធិសញ្ញា នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

**ទម្រង់ពាក្យបណ្តឹងគំរូ** ត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃជំពូក VIII **(ការដាក់ជូនពិនិត្យនូវបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្បីករណ៍)** នៃ*សៀវភៅ*នេះ ។

# គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌

***ឧបករណ៍ត្រួតពិនិត្យ***

កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ (ICESCR) ។ សូមកត់សម្គាល់ថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស អនុម័តពិធីសារបន្ថែមនៃកតិកាសញ្ញានេះ នៅក្នុងខែ មិថុនា ឆ្នាំ ២០០៨ ។ មហាសន្និបាតអង្គការសហប្រជាជាតិ ក៏ត្រូវបានគេរំពឹងថានឹងអនុម័តវានៅក្នុងឆ្នាំ ២០០៨ ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់ប្រាំបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការនេះ ជួបប្រជុំគ្នាពីរដងក្នុងមួយឆ្នាំ សម្រាប់វគ្គប្រជុំពេញអង្គ ដែលមានរយៈពេលបីសប្តាហ៍ គួបផ្សំជាមួយនឹងក្រុមការងារមុនវគ្គប្រជុំពេញអង្គដែលមានរយៈពេលមួយសប្តាហ៍ ដែលតាមធម្មតានៅក្នុងខែ ឧសភា និងខែ វិច្ឆិកា នៅឯអង្គការ សហប្រជាជាតិនៅក្នុងទីក្រុងហ្សឺណែវ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

ទុកណាជាកតិកាសញ្ញានេះ មិនចែងអំពីដំណាក់កាលនៃការធ្វើសេចក្តីរាយការណ៍ក៏ដោយ ក៏វាជាទម្លាប់សម្រាប់ភាគីរដ្ឋទាំងឡាយធ្វើសេចក្តីរាយការណ៍ជាដំបូងនៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីក្លាយជាភាគីនៃកតិកាសញ្ញា និងក្រោយមក រៀងរាល់ប្រាំឆ្នាំម្តង ឬ បើមិនដូច្នោះទេ តាមការស្នើសុំរបស់គណៈកម្មាធិការនេះ ។

***ការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា មូលនិធិស្រាវជ្រាវ សមាគមអ្នកវិជ្ជាជីវៈ និងក្រុមជនជាតិដើមភាគតិច អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍ ទៅលេខាធិការដ្ឋាន សម្រាប់ទាំងវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍ និងវគ្គមុនវគ្គប្រជុំពេញអង្គ ។ ព័ត៌មានអាចត្រូវបានដាក់ជូនពិនិត្យ នៅពេលណាមួយក៏បាន ក៏ប៉ុន្តែដោយគួរឲ្យចូលចិត្តជាងនោះ គឺ យ៉ាងហោចណាស់ក៏មួយសប្តាហ៍មុន ទាំងទម្រង់អេឡិចត្រូនិច និងទម្រង់រឹងទៅកាន់អាសយដ្ឋានដូចខាងក្រោម ។ ចំពោះវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍ យ៉ាងហោចណាស់ក៏ ២៥ ច្បាប់ដែរ ត្រូវបានដាក់ជូនពិនិត្យ និងសម្រាប់ក្រុមការងារមុនវគ្គប្រជុំពេញអង្គ យ៉ាងហោចណាស់ក៏ ១០ ច្បាប់ដែរ ។

សូមកត់សម្គាល់ថា លេខាធិការដ្ឋាន នឹងរៀបចំឲ្យមានព័ត៌មានជាលាយលក្ខណ៍អក្សរណាក៏ដោយ ដែលត្រូវបានដាក់ជូនពិនិត្យជាផ្លូវការ ដោយតួអង្គសង្គមស៊ីវិលទាក់ទងនឹងការពិចារណា លើរបាយការណ៍របស់ភាគីរដ្ឋជាក់លាក់ សម្រាប់តំណាងរបស់រដ្ឋនោះ ឲ្យបានឆាប់តាមដែលអាចធ្វើបាន លុះត្រាតែ ត្រូវបានគូសសម្គាល់ជាក់លាក់ថា "មានលក្ខណៈសម្ងាត់" ។

**អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ (ECOSOC) (ឬ ដែលស្ថិតនៅក្នុងភាពជាដៃគូជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលដែលមានឋានៈបែបនេះ) អាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ដើម្បីបោះពុម្ពផ្សាយជាភាសាផ្លូវការរបស់គណៈកម្មាធិការនៅក្នុងវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍របស់គណៈកម្មាធិការនេះ ។** សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវតែមានលក្ខណៈជាក់លាក់ចំពោះមាត្រានៃកតិកាសញ្ញា

ដោយផ្តោតទៅលើបញ្ហាបន្ទាន់បំផុត ផ្តើមចេញពីទស្សនវិស័យរបស់សង្គមស៊ីវិល និងត្រូវតែទៅដល់លេខាធិការដ្ឋាន មិនឲ្យហួសពីរយៈពេលបីខែ មុនវគ្គប្រជុំពេញអង្គ ដែលវាត្រូវបានរៀបចំសម្រាប់នោះ ។

*ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ*

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ ក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ ដើម្បីធ្វើដូច្នេះ គេនឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋានតាមអាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងមន្ត្រីជំនាញនីមួយៗ អាចអានសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ នៅក្នុងអំឡុងព្រឹកទីមួយនៃកិច្ចប្រជុំក្រុមការងារមុនវគ្គប្រជុំពេញអង្គ ដែលតាមធម្មតា ត្រូវបានរៀបចំឡើងនៅថ្ងៃ ច័ន្ទ ចាប់ពីម៉ោង ១០ និង ៣០ នាទីព្រឹក ដល់ម៉ោង ១ រសៀល ក៏ដូចជា នៅក្នុងអំឡុងពេលសវនាការរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលប្រព្រឹត្តទៅនៅថ្ងៃទីមួយ នៃវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍ចាប់ផ្តើមពីម៉ោង ៣ ដល់ម៉ោង ៤ រសៀល។ កម្រិតពេលវេលាសម្រាប់សេចក្តីថ្លែងការណ៍ គឺ ១៥ នាទី ។

នៅក្នុងវគ្គប្រជុំពេញអង្គនីមួយៗ គណៈកម្មាធិការលះបង់រយៈពេលមួយថ្ងៃ តាមធម្មតា ថ្ងៃ ច័ន្ទ នៃសប្តាហ៍ទីបី សម្រាប់ការពិភាក្សាប្រធានបទទូទៅ លើសិទ្ធិណាមួយ ឬ ទិដ្ឋភាពណាមួយនៃកតិកាសញ្ញា នេះ ។ អង្គការមិនមែនរដ្ឋាភិបាលជំនាញ និងអ្នកចូលរួមផ្សេងទៀតរបស់សង្គមស៊ីវិល ក្នុងនោះរួមមាន អ្នកសិក្សាជាន់ខ្ពស់ អ្នកស្រាវជ្រាវ និងសមាជិកក្រុម អ្នកវិជ្ជាជីវៈ អាចដាក់ជូនពិនិត្យនូវឯកសារគាំទ្រ ឬ ចូលរួមក្នុងកិច្ចពិភាក្សាទូទៅប្រចាំថ្ងៃបាន ។

***ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន***

**គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌**

នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២៩

ដើម្បីជ្រាបព័ត៌មានបន្ថែម ស្តីពី**គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែក វប្បធម៌** សូមមើលឯកសារសង្ខេបព័ត៌មានលេខ ១៦ (កែសម្រួលលើកទី ១) ។

ដើម្បីជ្រាបព័ត៌មានបន្ថែម ស្តីពីការចូលរួមរបស់សង្គមស៊ីវិលជាមួយនឹងគណៈកម្មាធិការ សូមចូលមើលផ្នែកស្ថាប័ន សន្ធិសញ្ញានៃវិបសាយ របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍

***ឧបករណ៍ត្រួតពិនិត្យ***

អនុសញ្ញាអន្តរជាតិ ស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ (ICERD) ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់ប្រាំបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នានៅឯអង្គការសហប្រជាជាតិនៅក្នុងទីក្រុងហ្សឺណែវ និងរៀបចំវគ្គប្រជុំពេញអង្គរយៈពេលបីសប្តាហ៍ចំនួនពីរលើកនៅក្នុងខែ កុម្ភៈនិងខែ សីហា រៀងរាល់ឆ្នាំ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូងក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីក្លាយជាភាគីនៃអនុសញ្ញានេះ និងបន្ទាប់មកតាមធម្មតារៀងរាល់ពីរឆ្នាំម្តង ។ ទោះជាយ៉ាងណាក៏ដោយកថាខ័ណ្ឌចុងក្រោយនៃសេចក្តីសង្កេតសន្និដ្ឋាន តាមធម្មតាបញ្ជាក់អំពីពេលវេលាដែលរបាយការណ៍បន្ទាប់ ដល់ពេលកំណត់ ។

***ការដាក់ជូនពិនិត្យព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ដូចជា សមាគមអ្នកវិជ្ជាជីវៈ គ្រឹះស្ថានសិក្សា អប់រំ ក្រុមជនជាតិដើមភាគតិច និងស្ថាប័នជំនាញ ដែលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងផ្នែកទទួលខុសត្រូវរបស់គណៈកម្មាធិការ អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ។ នេះអាចត្រូវ បានធ្វើឡើងនៅពេលណាមួយក៏បាន ក៏ប៉ុន្តែដោយចូលចិត្តជាងនោះ គឺក្នុងរយៈពេលពីរខែមុនវគ្គប្រជុំពេញអង្គ របស់គណៈកម្មាធិការ ។

ព័ត៌មានជាលាយលក្ខណ៍អក្សរជាទម្រង់អេឡិចត្រូនិច ក៏ដូចជា ទម្រង់រឹងចំនួន ៣៧ ច្បាប់ គួរតែត្រូវបានដាក់ជូនពិនិត្យទៅលេខាធិការដ្ឋានទៅតាមអាសយដ្ឋានដូចខាងក្រោម ។ តួអង្គសង្គមស៊ីវិលជាតិ ដែលមានធនធានតិចតួច ដែលមានការលំបាកក្នុងការប្រព្រឹត្តតាមតម្រូវការទាំងនេះ អាចស្វែងរកជំនួយ **ពីផ្នែកសេវាព័ត៌មានប្រឆាំងនឹងការប្រកាន់ពូជសាសន៍ (ARIS)** ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយនៅក្នុងទីក្រុងហ្សឺណែវ ដែលជួយបញ្ជូនព័ត៌មានទៅនិងមកពីគណៈកម្មាធិការ ។ ផ្នែកសេវាព័ត៌មានប្រឆាំងនឹងការប្រកាន់ពូជសាសន៍ (ARIS) ផ្តល់សេវានេះដល់អង្គការមិនមែនរដ្ឋាភិបាលតំបន់ និងជាតិក្រុមសិទ្ធិមនុស្សផ្សេងទៀត និងបុគ្គលទាំងឡាយ ។

គណៈកម្មាធិការនេះ ក៏ព្រមទទួលយកឯកសារស្នើសុំពិនិត្យជាលាយលក្ខណ៍អក្សរពីសង្គមស៊ីវិល ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញ ដោយគ្មានរបាយការណ៍លើការអនុវត្តអនុសញ្ញាដោយភាគីរដ្ឋ ដែលរបាយការណ៍គេមានកាលកំណត់ហួស កំណត់រយៈពេលយ៉ាងតិចណាស់ក៏ប្រាំឆ្នាំដែរ និងទាក់ទងទៅនឹង**នីតិវិធីព្រមានជាមុន និងវិធានការបន្ទាន់** ។ តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល អាចផ្ញើព័ត៌មានទៅគណៈកម្មាធិការ ដោយស្នើសុំឲ្យគណៈកម្មាធិការនេះ ដោះស្រាយស្ថានភាពដែលគេចាត់ទុកថាបន្ទាន់ ដូចដែលត្រូវបានចែងនៅក្នុងនៅនីតិវិធីទាំងនេះ ។

***ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ***

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការតែក្នុងឋានៈជាអ្នកសង្កេតការការណ៍ប៉ុណ្ណោះ ។ ដើម្បីធ្វើដូច្នេះ គេនឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋាន ទៅតាមអាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។ គណៈកម្មាធិការ មិនរៀបចំកិច្ចប្រជុំជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ឬ តួអង្គសង្គមស៊ីវិលផ្សេងទៀត នៅក្នុងម៉ោងប្រជុំផ្លូវការរបស់ខ្លួនឡើយ

ប៉ុន្តែតួអង្គសង្គមស៊ីវិល អាចរៀបចំកិច្ចប្រជុំពន្យល់ដោយសង្ខេបមិនផ្លូវការនៅថ្ងៃទីមួយ នៃការពិចារណាលើរបាយការណ៍នីមួយៗ នៅចន្លោះម៉ោង ១ និង ៤៥ នាទី និង ម៉ោង ២ និង ៤៥ នាទីរសៀល និងអញ្ជើញសមាជិករបស់គណៈកម្មាធិការឲ្យចូលរួម ។ តួអង្គសង្គមស៊ីវិលគួរតែស្នើសុំឲ្យលេខាធិការដ្ឋាន កក់ទុកនូវបន្ទប់សម្រាប់កិច្ចប្រជុំពន្យល់ដោយសង្ខេបទាំងនេះ ។ គេក៏អាចស្វែងរកផងដែរ នូវជំនួយពីផ្នែកសេវាព័ត៌មានប្រឆាំងនឹងការរើសអើងពូជសាសន៍ (ARIS) ដែលរៀបចំកិច្ចប្រជុំពន្យល់ដោយសង្ខេបទាំងនេះ ។

គណៈកម្មាធិការ ក៏រៀបចំផងដែរនូវកិច្ចពិភាក្សាប្រធានបទជាទៀងទាត់ ស្តីពីបញ្ហាដែលពាក់ព័ន្ធនឹងការរើសអើងជាតិសាសន៍ និងអនុសញ្ញា និង អញ្ជើញតួអង្គសង្គមស៊ីវិល ដូចជា អ្នកសិក្សាជាន់ខ្ពស់មន្រ្តីជំនាញម្នាក់ៗ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជំនាញ ដើម្បីចូលរួម និងសម្តែងនូវមតិយោបល់របស់គេលើកម្មវត្ថុណាមួយ ។

គណៈកម្មាធិការ ក៏រៀបចំផងដែរនូវកិច្ចពិភាក្សាប្រធានបទជាទៀងទាត់ ស្តីពីបញ្ហាដែលពាក់ព័ន្ធនឹងការរើសអើងជាតិសាសន៍ និងអនុសញ្ញា និង អញ្ជើញតួអង្គសង្គមស៊ីវិល ដូចជា អ្នកសិក្សាជាន់ខ្ពស់មន្រ្តីជំនាញម្នាក់ៗ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជំនាញ ដើម្បីចូលរួម និងសម្តែងនូវមតិយោបល់របស់គេលើកម្មវត្ថុណាមួយ ។

***បណ្តឹងជាលក្ខណៈបុគ្គល***

បណ្តឹងជាលក្ខណៈបុគ្គល ដូចដែលត្រូវបានចែងនៅក្នុងមាត្រា ១៤ នៃអនុសញ្ញានេះ អាចត្រូវបានផ្ញើជូនទៅៈ

**ក្រុមបដ្ឋនាលិខិត**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩0 ២២
(ជាពិសេសសម្រាប់បណ្តឹងបន្ទាន់)
អ៊ីម៉ែលៈ **tb-petitions@ohchr.org**

***ព័ត៌មានទំនាក់ទំនាក់របស់លេខាធិការដ្ឋាន***
**គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍**
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩0 ២៩

ព័ត៌មានបន្ថែម ស្តីពីផ្នែកសេវាព័ត៌មានប្រឆាំងនឹងការប្រកាន់ពូជសាសន៍ (ARIS) ត្រូវបានរៀបចំឲ្យមាននៅក្នុងៈ
វ៉ិបសាយៈ **http://www.antiracism-info.org**[23]
អ៊ីម៉ែលៈ **centre-docs@antiracism,info.org**

ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពី**គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍** ចូរមើល

[23] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មិនទទួលខុសត្រូវចំពោះខ្លឹមសារនៃវ៉ិបសាយខាងក្រៅ និងការផ្តល់ទំនាក់ទំនងទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតនៅក្នុងទំព័រនេះ មិនថ្លែងបង្កប់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ភ្ជាប់ខ្លួនឯងជាមួយនឹងខ្លឹមសារនេះទេ ។

ឯកសារសង្ខេបព័ត៌មានលេខ ១២ ។

ទម្រង់ពាក្យបណ្តឹងគំរូ ត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃ**ជំពូក VIII (ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍)** នៃ*សៀវភៅ*នេះ ។

## គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ

***ឧបករណ៍ត្រួតពិនិត្យ***

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ (CEDAW) និងពិធីសារបន្ថែមរបស់វា ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនម្ភៃបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នាពីពីរទៅបីដងក្នុងមួយឆ្នាំ ទាំងនៅក្នុងទីក្រុងហ្សឺណែវ និងញូវយ៉កសម្រាប់វគ្គប្រជុំពេញអង្គរយៈពេលពីរសប្តាហ៍ ដែលតាមធម្មតា ត្រូវបានបំពេញបន្ថែមដោយក្រុមការងារមុនវគ្គប្រជុំពេញអង្គ ដែលមានរយៈពេលមួយសប្តាហ៍ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូង នៅក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីក្លាយជាភាគីនៃអនុសញ្ញានេះ និងបន្ទាប់មក យ៉ាងហោចណាស់ក៏រៀងរាល់បួនឆ្នាំម្តង និងនៅពេលណា ដែលគណៈកម្មាធិការស្នើសុំដូច្នេះ ។

***ការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា ក្រុមស្ត្រី អង្គការដែលមានមូលដ្ឋាននៅលើសាសនា មន្ត្រីជំនាញឯករាជ្យ និងសមាជិកសភា អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬរបាយការណ៍ជាលាយលក្ខណ៍អក្សរ ទៅលេខាធិការដ្ឋាន ។ នេះអាចត្រូវបានធ្វើឡើងនៅពេលណាមួយក៏បាន ក៏ប៉ុន្តែដោយចូលចិត្តជាងនោះគឺក្នុងរយៈពេលពីរសប្តាហ៍មុនកិច្ចប្រជុំមុនវគ្គប្រជុំពេញអង្គ ឬ ពីរខែមុនវគ្គប្រជុំពេញអង្គ របស់គណៈកម្មាធិការនេះ ។ ឯកសារជាទម្រង់អេឡិចត្រូនិច និងជាទម្រង់រឹងយ៉ាងហោចណាស់ ៣៥ ច្បាប់ គួរតែត្រូវបានដាក់ជូនពិនិត្យទៅលេខាធិការដ្ឋាន ទៅតាមអាសយដ្ឋានដូចខាងក្រោម ។ អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដូចជា គ្រឹះស្ថានសិក្សាអប់រំជាដើម ក៏អាចសម្រេចចិត្តផងដែរក្នុងការផ្ញើឯកសារស្នើសុំពិនិត្យជាច្បាប់ចម្លងរបស់ខ្លួនទៅ**អង្គការឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអន្តរជាតិនៅតំបន់អាស៊ីប៉ាស៊ីភិច** (IWRAW-AP) ដែលជាអង្គការមិនមែនរដ្ឋាភិបាលជំនាញ ដែលជួយបញ្ជូនព័ត៌មានទៅ និងមកពីគណៈកម្មាធិការ ។[24]

***ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ***

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការក្នុងឋានៈជាអ្នកសង្កេតការណ៍។ ដើម្បីធ្វើដូច្នេះ គេនឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋាន ទៅតាមអាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។ តួអង្គសង្គមស៊ីវិលជាពិសេស អង្គការមិនមែនរដ្ឋាភិបាល អាចអានបទបង្ហាញដោយផ្ទាល់មាត់ ជូនក្រុមការងារមុនវគ្គប្រជុំពេញអង្គ (តាមធម្មតានៅព្រឹកទីមួយ) ។ ក្រុមការងារមុនវគ្គប្រជុំពេញអង្គ ជួបប្រជុំគ្នានៅចុងវគ្គប្រជុំពេញអង្គ មុនកិច្ចប្រជុំដែលក្នុងនោះ របាយការណ៍របស់រដ្ឋាភិបាលណាមួយនឹងត្រូវបានត្រួតពិនិត្យឡើងវិញ។ អង្គការមិនមែនរដ្ឋាភិបាល ក៏អាចអានផងដែរនូវ

---

[24] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មិនទទួលខុសត្រូវចំពោះខ្លឹមសារនៃវិបសាយខាងក្រៅ និងការផ្តល់ទំនាក់ទំនងទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតនៅក្នុងទំព័រនេះ មិនថ្លែងបង្កប់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ភ្ជាប់ខ្លួនឯងជាមួយនឹងខ្លឹមសារនេះទេ ។

បទបង្ហាញដោយផ្ទាល់មាត់ជូនគណៈកម្មាធិការនៅថ្ងៃទីមួយនៃសប្តាហ៍នីមួយៗនៃវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការនេះ ។ កិច្ចប្រជុំមិនផ្លូវការជាមួយនឹងសមាជិករបស់គណៈកម្មាធិការ ជូនកាល អាចត្រូវបានរៀបចំឡើង តាមរយៈការទាក់ទងនឹងលេខាធិការដ្ឋាន តាមអាសយដ្ឋានដូចខាងក្រោម ។

*បណ្តឹងជាលក្ខណៈបុគ្គល*

បណ្តឹងជាលក្ខណៈបុគ្គល ដូចដែលត្រូវបានចែងនៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញា អាចត្រូវបានផ្ញើជូនទៅៈ

**ក្រុមបដ្ឋនាលិខិត**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២២
(ជាពិសេសសម្រាប់បណ្តឹងបន្ទាន់)
អ៊ីម៉ែលៈ **tb-petitions@ohchr.org**

**គោលការណ៍ណែនាំស្តីពីការប្តឹង**ដូចដែលត្រូវបានចែងនៅក្នុងពិធីសារបន្ថែមនៃអនុសញ្ញានេះ ត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃ**ជំពូក VIII (ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្បីករណ៍)** នៃ*សៀវភៅ*នេះ ។ ទម្រង់ឯកសារបណ្តឹងគំរូ ត្រូវបានរៀបចំឲ្យមានតាមបណ្តាញអេឡិចត្រូនិចជាភាសាផ្លូវការទាំងអស់របស់អង្គការសហប្រជាជាតិនៅក្នុងវិបសាយនៃផ្នែកលើកកម្ពស់ស្ត្រី ។

*ការស៊ើបសួរជាលក្ខណៈសម្ងាត់*

តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល អាចដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរស្តីពីការរំលោភបំពានធ្ងន់ធ្ងរ ធ្ងន់ធ្ងរបំផុត ឬ ជាប្រព័ន្ធលើអនុសញ្ញានេះ ទៅលេខាធិការដ្ឋាន ។ ព័ត៌មាននេះ ត្រូវតែគួរឲ្យជឿទុកចិត្តបាន និងបង្ហាញថា ភាគីរដ្ឋ កំពុងតែរំលោភបំពានជាលក្ខណៈប្រព័ន្ធលើសិទ្ធិ ដែលត្រូវបានចែងនៅក្នុងអនុសញ្ញានេះ ។

***ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន***

**គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ**
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២៩
អ៊ីម៉ែលៈ **cedaw@ohchr.org**

ដើម្បី**ជ្រាបព័ត៌មានបន្ថែម** ស្តីពីគណៈកម្មាធិការ ចូរមើលឯកសារសង្ខេបព័ត៌មានលេខ ២២ និង ឯកសារសង្ខេបព័ត៌មានលេខ ៧ ។ សម្រាប់**ការណែនាំផ្នែកនីតិវិធី** ស្តីពីការផលិតរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់គណៈកម្មាធិការនេះ ចូរមើលវិបសាយរបស់ **អង្គការឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអន្តរជាតិនៅតំបន់អាស៊ីប៉ាស៊ីភិច (IWRAWAP)** ។

## គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម

***ឧបករណ៍ត្រួតពិនិត្យ***

អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT) ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់រូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នានៅក្នុងទីក្រុងហ្ស៊ឺណែវ និងតាមធម្មតារៀបចំវគ្គប្រជុំពេញអង្គចំនួនពីរក្នុងមួយឆ្នាំ ដែលមានសម័យប្រជុំពេញអង្គមួយ (ក្នុងនោះមានរយៈពេលបីសប្តាហ៍នៅក្នុងខែឧសភា និងពីរសប្តាហ៍នៅក្នុងខែ វិច្ឆិកា) និងក្រុមការងារមុន វគ្គប្រជុំពេញអង្គដែលមានរយៈពេលមួយសប្តាហ៍ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ដូចជា ក្រុមជនរងគ្រោះ អង្គការដែលមានមូលដ្ឋាននៅលើសាសនា តំណាងសហជីព និងសមាគមអ្នកវិជ្ជាជីវៈ អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរ ទៅលេខាធិការ ។ នេះ អាចត្រូវបានធ្វើឡើងនៅពេលណាមួយក៏បាន ក៏ប៉ុន្តែដោយចូលចិត្តជាងនោះគឺក្នុងរយៈពេលប្រាំមួយសប្តាហ៍ មុនវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ។ ទិន្នន័យបញ្ចូលសម្រាប់បញ្ជីបញ្ហា គួរតែត្រូវបានដាក់ជូនពិនិត្យ ក្នុងរយៈពេលបីខែមុនពេលបញ្ជីណាមួយ ដល់ពេលកំណត់ ត្រូវបានរៀបចំបង្កើយ ។ ព័ត៌មានទាំងអស់ ត្រូវតែបានដាក់ជូនពិនិត្យជាទម្រង់អេឡិចត្រូនិច និងយ៉ាងហោចណាក៏ឯកសារជាទម្រង់រឹងចំនួន១៥ច្បាប់ដែរគួរតែត្រូវបានផ្ញើជូនលេខាធិកាដ្ឋាន ទៅតាមអាសយដ្ឋានដូចខាងក្រោម ។

សូមកត់សម្គាល់ថា លេខាធិការដ្ឋាន នឹងរៀបចំឲ្យមានព័ត៌មានជាលាយលក្ខណ៍អក្សរណាមួយក៏ដោយ ដែលត្រូវបានផ្តល់ជូនជាផ្លូវការដោយតួអង្គសង្គមស៊ីវិល ទាក់ទងនឹងការពិចារណាលើរបាយការណ៍របស់ភាគីរដ្ឋជាក់លាក់ សម្រាប់តំណាងរបស់រដ្ឋនោះឲ្យបានឆាប់តាមដែលអាចធ្វើបាន លុះត្រាតែត្រូវបានគូសសម្គាល់ជាក់លាក់ថា "មានលក្ខណៈសម្ងាត់" ។

***ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ***

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការក្នុងឋានៈជាអ្នកសង្កេតការណ៍។ ដើម្បីធ្វើដូច្នេះ គេនឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋាន ទៅតាមអាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។ តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល អាចពន្យល់ដោយសង្ខេបជូន គណៈកម្មាធិការដោយផ្ទាល់មាត់ ក្នុងអំឡុងពេលវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការនេះ ។ វគ្គមានរបស់ជនរងគ្រោះម្នាក់ៗនៅក្នុងកិច្ចប្រជុំពន្យល់ដោយសង្ខេប តាមធម្មតា ត្រូវបានសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល ។ កិច្ចប្រជុំពន្យល់ដោយសង្ខេប ផ្តោតទៅលើប្រទេសមួយក្នុងមួយលើក និងតាមធម្មតា ប្រព្រឹត្តទៅចាប់ពីម៉ោង ៥ ទៅ ៦ ល្ងាច នៅថ្ងៃមុនការសន្ទនារបស់ភាគីរដ្ឋជាមួយនឹងគណៈកម្មាធិការ ។

***បណ្តឹងជាលក្ខណៈបុគ្គល***

បណ្តឹងជាលក្ខណៈបុគ្គលដូចដែលត្រូវបានចែងនៅក្នុងមាត្រា២២នៃអនុសញ្ញានេះ អាចត្រូវបានផ្ញើជូនទៅៈ

**ក្រុមបដ្ឋនាលិខិត**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២២
(ជាពិសេសសម្រាប់បណ្តឹងបន្ទាន់)
អ៊ីម៉ែលៈ **tb-petitions@ohchr.org**

**ទម្រង់ពាក្យបណ្តឹងគំរូ** ត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃ**ជំពូក VIII (ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលទទួលទឡ្ហីករណ៍)** នៃ*សៀវភៅ*នេះ ។

***ការស៊ើបសួរជាលក្ខណៈសម្ងាត់***

តួអង្គសង្គមស៊ីវិល អាចដាក់ជូនពិនិត្យនូវព័ត៌មានស្តីពីការរំលោភបំពានធ្ងន់ធ្ងរ ធ្ងន់ធ្ងរបំផុត ឬជាប្រព័ន្ធលើអនុសញ្ញានេះ ទៅលេខាធិការដ្ឋាន ។ ព័ត៌មានត្រូវតែគួរឲ្យជឿជាក់បាន និងមានការបង្ហាញសមហេតុសមផលថា ការធ្វើទារុណកម្ម ត្រូវបានអនុវត្តជាប្រព័ន្ធ នៅក្នុងទឹកដីរបស់ភាគីរដ្ឋនោះ ។

***ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន***

**គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម**
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២៩

**ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការ** ចូរមើលឯកសារសង្ខេបព័ត៌មានលេខ ១៧ ។

## អនុគណៈកម្មការបង្ការ ទប់ស្កាត់ការធ្វើទារុណកម្ម

***ឧបករណ៍ត្រួតពិនិត្យ***

ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (OP- CAT) ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់រូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបានម្តងគត់ ។ សមាជិកភាព នឹងកើនឡើង រហូតដល់ ២៥ រូប បន្ទាប់ពីការផ្តល់សច្ចាប័ន ឬ ការចូលជាភាគីលើកទីហាសិបនៃពិធីសារបន្ថែម (ចូរមើល មាត្រា ៥) ។

***វគ្គប្រជុំពេញអង្គ***

អនុគណៈកម្មការនេះ ជួបប្រជុំគ្នាបីដងក្នុង មួយឆ្នាំ សម្រាប់វគ្គប្រជុំពេញអង្គដែលមានរយៈពេលមួយសប្តាហ៍ នៅឯអង្គការសហប្រជាជាតិនៅក្នុងទីក្រុង ហ្សឺណែវ ។ អនុគណៈកម្មការនេះ ក៏រ៉ាប់រងធ្វើទស្សនកិច្ចសួរសុខទុក្ខជាទៀងទាត់ទៅកាន់ទីកន្លែងដែលមានមនុស្សត្រូវបានគេដកហូតសេរីភាពជាមូលដ្ឋានរបស់ពួកគេ ដើម្បីបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើ ខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

***តម្រូវការរបស់រដ្ឋ***

ភាគីរដ្ឋ ត្រូវតែបង្កើត ជ្រើសរើស ឬ រក្សានៅថ្នាក់ជាតិនូវស្ថាប័នសន្និសញ្ញាទស្សនកិច្ចសួរសុខទុក្ខមួយ ឬច្រើន (ដែលអាចរួមបញ្ចូលស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) មន្ត្រីស៊ើបអង្កេត និងទទួលពាក្យ បណ្តឹងរបស់ពលរដ្ឋ គណៈកម្មការសភា ឬ អង្គការមិនមែនរដ្ឋាភិបាល) សម្រាប់ការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ។ ភាគីរដ្ឋ ក៏ត្រូវតែអនុញ្ញាតឲ្យមានផងដែរ នូវទស្សនកិច្ចសួរសុខទុក្ខរបស់អនុគណៈកម្មការ និងស្ថាប័ន ទស្សនកិច្ចសួរសុខទុក្ខក្នុងស្រុកផ្ទាល់របស់ខ្លួនទៅកាន់ទីកន្លែងណាមួយស្ថិតនៅក្រោមដែនសមត្ថកិច្ច និងការត្រួតត្រារបស់ខ្លួនដែលបុគ្គលទាំងឡាយត្រូវបាន ឬ អាចត្រូវបានគេដកហូតសេរីភាពជាមូលដ្ឋានរបស់ពួកគេ ។ ទស្សនកិច្ចសួរសុខទុក្ខទាំងនេះ ត្រូវបានរ៉ាប់រងធ្វើក្នុងបំណងពង្រឹង ប្រសិនបើចាំបាច់ កិច្ចការពារបុគ្គលទាំងនេះចំពោះទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

**ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីអនុគណៈកម្ម ការបង្ការទប់ស្កាត់ការធ្វើទារុណកម្ម** ចូរចូលមើល វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ

***ឧបករណ៍ត្រួតពិនិត្យ***

អនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ (CRC) និងពិធីសារបន្ថែមទាំងឡាយរបស់វា ។

***សមាជិកភាព***

មន្ត្រីជំនាញឯករាជ្យចំនួនដប់ប្រាំបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នាបីដងក្នុងមួយឆ្នាំ សម្រាប់វគ្គប្រជុំពេញអង្គដែលមានរយៈពេលបីសប្តាហ៍ និងក្រុមការងារមុនវគ្គប្រជុំពេញអង្គដែលមានរយៈពេលមួយសប្តាហ៍ចំនួនបី នៅក្នុងខែ មករា ខែ ឧសភា និង ខែ កញ្ញា នៅឯអង្គការសហប្រជាជាតិ ក្នុងទីក្រុងហ្សឺណែវ ។

***តម្រូវការធ្វើសេចក្តីរាយការណ៍***

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូងក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ និងបន្ទាប់មក គឺរៀងរាល់ប្រាំឆ្នាំម្តង ។ ភាគីរដ្ឋនៃពិធីសារបន្ថែមទាំងឡាយនៃអនុសញ្ញានេះ ក៏ត្រូវតែដាក់ជូនពិនិត្យផងដែរនូវរបាយការណ៍ដូចដែលត្រូវបានចែងនៅក្នុងលិខិតុបករណ៍ទាំងនេះ ដោយជាលើកដំបូង ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃលិខិតុបករណ៍ទាំងនេះ និងបន្ទាប់មក ដោយរួមគ្នាជាមួយនឹងរបាយការណ៍ជាទៀងទាត់របស់ខ្លួនទៅគណៈកម្មាធិការនេះ (ឬ រៀងរាល់ប្រាំឆ្នាំម្តង ប្រសិនបើរដ្ឋនោះ ជាភាគីនៃពិធីសារបន្ថែមមួយ ឬ ទាំងពីរ ប៉ុន្តែមិនមែនអនុសញ្ញានេះទេ) ។

***ការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ដូចជា អង្គការកុមារ អង្គការដែលមានមូលដ្ឋាននៅលើសាសនា សមាគមអ្នកវិជ្ជាជីវៈ និងអង្គការសេវាសង្គមកិច្ច អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរទៅកាន់លេខាធិការការដ្ឋាន ។ នេះអាចត្រូវបានធ្វើឡើង នៅពេលណាមួយក៏បាន ក៏ប៉ុន្តែដោយចូលចិត្តជាងនោះគឺ យ៉ាងហោចណាស់ក៏ ក្នុងរយៈពេលពីរខែមុនក្រុមការងារ មុនវគ្គប្រជុំពេញអង្គពាក់ព័ន្ធដែរ ។ ឯកសារជាទម្រង់ រឹងយ៉ាងហោចណាស់ក៏ ២០ ច្បាប់ដែរ គួរតែត្រូវបានដាក់ជូនពិនិត្យទៅកាន់លេខាធិការដ្ឋានទៅតាមអាសយដ្ឋានដូចខាងក្រោម ជាបន្ថែមទៅលើឯកសារទម្រង់អេឡិចត្រូនិច ។ តួអង្គសង្គមស៊ីវិល អាចស្នើសុំឲ្យរក្សាការសម្ងាត់លើឯកសារស្នើសុំពិនិត្យរបស់ខ្លួន ។

អង្គការមិនមែនរដ្ឋាភិបាល ដែលដាក់ជូនពិនិត្យនូវព័ត៌មានទៅកាន់គណៈកម្មាធិការនេះ ក៏អាចមានបំណងប្រាថ្នាផងដែរក្នុងការទាក់ទងនឹង**ក្រុមអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិរបស់ កុមារ** ដែលជាសម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិដែលខិតខំពុះពារសម្របសម្រួលដល់ការអនុវត្តអនុសញ្ញានេះ ។ ក្រុមអង្គការមិនមែនរដ្ឋាភិបាល មានអង្គភាពទំនាក់ទំនងមួយដែលគាំទ្រឲ្យមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ជាពិសេស សម្ព័ន្ធភាពចម្រុះជាតិនៅក្នុងដំណើរការធ្វើសេចក្តីរាយការណ៍របស់គណៈកម្មាធិការនេះ ។ តួអង្គសង្គមស៊ីវិល ក្រៅពីអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានជំរុញលើកទឹកចិត្តឲ្យរួមចំណែកជាព័ត៌មាន ដោយសម្របសម្រួលជាមួយនឹងសម្ព័ន្ធភាពចម្រុះជាតិទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិរបស់កុមាររបស់ខ្លួន ប្រសិនបើសម្ព័ន្ធភាពចម្រុះនេះ មាននៅក្នុងប្រទេសរបស់ខ្លួនមែន ។

ក្រុមអង្គការមិនមែនរដ្ឋាភិបាល អាចត្រូវបាន ទាក់ទងតាមរយៈ:

**ក្រុមអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិរបស់ កុមារ លេខាធិការដ្ឋាន**
1, rue de Varembé
CH- 1202 Geneva - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៧៤0 ៤៧៣0
ទូរសារលេខៈ +៤១ (0)២២ ៧៤0 ១១៤៥
អ៊ីម៉ែលៈ **secretariat@childrightsnet.org**
វ៉ិបសាយៈ **http://www.childrightsnet.org**[25]

*ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ*

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងវគ្គប្រជុំពេញអង្គធ្វើសេចក្តីរាយការណ៍របស់គណៈកម្មាធិការតែក្នុងឋានៈជាអ្នកសង្កេតការណ៍ប៉ុណ្ណោះ ។ ដើម្បីធ្វើដូច្នេះ គេនឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋានទៅតាមអាសយដ្ឋានដូចខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។

តួអង្គសង្គមស៊ីវិល ក៏ត្រូវបានអញ្ជើញឲ្យចូលរួមផងដែរនៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គ សម្រាប់កិច្ចប្រជុំរយៈពេលបីម៉ោង ដែលក្នុងនោះដៃគូ អាចផ្តល់ព័ត៌មានបន្ថែមបាន ។ មន្ត្រីជំនាញ និងសមាជិកម្នាក់ៗរបស់អង្គការយុវជន គឺជាអ្នករួមចំណែកដ៏សំខាន់ នៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ ។ សេចក្តីស្នើសុំចូលរួម គួរតែត្រូវបានបញ្ជូនទៅលេខាធិការដ្ឋានឲ្យបានយ៉ាងហោចណាស់ក៏រយៈពេល ពីរខែមុនពេលចាប់ផ្តើមក្រុមការងារមុនវគ្គប្រជុំពេញអង្គដែលពាក់ព័ន្ធដែរ ។ ដោយផ្អែកលើព័ត៌មានជាលាយលក្ខណ៍អក្សរដែលត្រូវបានដាក់ជូនពិនិត្យ គណៈកម្មាធិការ នឹងផ្ញើជូននូវសេចក្តីអញ្ជើញជាលាយលក្ខណ៍អក្សរ ដើម្បីជ្រើសរើសតួអង្គសង្គមស៊ីវិលតាមធម្មតាគឺ អង្គការមិនមែនរដ្ឋាភិបាល (ដែលព័ត៌មានរបស់គេ មានភាពពាក់ព័ន្ធជាពិសេសទៅនឹងការពិចារណាលើរបាយការណ៍របស់ភាគីរដ្ឋ) ដើម្បីឲ្យចូលរួមនៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គ ។ សុន្ទរកថាចាប់ផ្តើមរបស់អ្នកចូលរួម ត្រូវបានកម្រិតជាអតិបរមាត្រឹមតែ ១៥ នាទី សម្រាប់តួអង្គសង្គមស៊ីវិលមកពីប្រទេសពាក់ព័ន្ធ និង ៥ នាទីសម្រាប់អ្នកផ្សេងទៀតដោយអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់កិច្ចសន្ទនាក្នុងន័យស្ថាបនា ។ ក្នុងឆ្នាំនីមួយៗ គណៈកម្មាធិការក៏រៀបចំផងដែរនូវ កិច្ចពិភាក្សាទូទៅប្រចាំថ្ងៃដែលនៅក្នុងនោះតួអង្គសង្គម ស៊ីវិល ក្នុងនោះរួមមាន កុមារ និងមន្ត្រីជំនាញផងដែរ ត្រូវបានទទួលស្វាគមន៍ឲ្យចូលរួម ។

*ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន*

**គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ**
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩0 ២៩

សូមចូលមើលវ៉ិបសាយរបស់**ក្រុមអង្គការមិនមែនរដ្ឋាភិបាល** ដើម្បីទទួលបាន**គោលការណ៍ណែនាំស្តីពីវិធីធ្វើសេចក្តីរាយការណ៍ជូនទៅគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ។**

ដើម្បីទទួលបាន**គោលការណ៍ណែនាំរបស់គណៈកម្មាធិការសម្រាប់ការចូលរួមរបស់អង្គការមិនមែន-រដ្ឋាភិបាល និងមន្ត្រីជំនាញម្នាក់ៗ**នៅក្នុងក្រុមការងារមុនវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការនេះ ចូរចូលមើលវ៉ិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

**ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ** ចូរមើល**ឯកសារសង្ខេបព័ត៌មាន លេខ ១0 (ការកែសម្រួលលើកទី ១) ។**

[25] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មិនទទួលខុសត្រូវចំពោះខ្លឹមសារនៃវ៉ិបសាយខាងក្រៅ និងការផ្តល់ទំនាក់ទំនងទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតនៅក្នុងទំព័រនេះ មិនថ្លែងបង្កប់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ភ្ជាប់ខ្លួនឯងជាមួយនឹងខ្លឹមសារនេះទេ ។

## គណៈកម្មាធិការទទួលបន្ទុកកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ

***ឧបករណ៍ត្រួតពិនិត្យ***

អនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារ ពួកគេ (ICRMW) ។

***សមាជិកភាព***

នាពេលបច្ចុប្បន្ននេះ មន្ត្រីជំនាញឯករាជ្យចំនួន ១០ រូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំង សម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបាន ។ ចំនួននេះ នឹង កើនដល់ ១៤ រូប នៅពេលមានការផ្ដល់សច្ចាប័នលើ អនុសញ្ញានេះ របស់ភាគីរដ្ឋទីសែបសិបមួយនៃអនុសញ្ញានេះ។ សម្រាប់ព័ត៌មានពិស្ដារបន្ថែម ចូរមើលមាត្រា ៧២ ។

***វគ្គប្រជុំពេញអង្គ***

គណៈកម្មាធិការ ជួបប្រជុំគ្នានៅក្នុងទីក្រុងហ្ស៊ឺណែវ និងតាមធម្មតា រៀបចំវគ្គប្រជុំពេញអង្គចំនួនពីរលើកក្នុង មួយឆ្នាំ តាមធម្មតា នៅក្នុងខែ មេសា និងវិច្ឆិកា ។

***តម្រូវការធ្វើសេចក្ដីរាយការណ៍***

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្ដីរាយការណ៍ជាលើកដំបូងក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីបានចូលជាភាគីនៃអនុ សញ្ញានេះ និងបន្ទាប់មក រៀងរាល់ប្រាំឆ្នាំម្ដង ។

***ការដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ***

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ដូចជាអង្គការសេវាសង្គមកិច្ច មន្ត្រីជំនាញម្នាក់ៗ និង សហជីព អាចដាក់ជូនពិនិត្យនូវព័ត៌មាន ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរ ទៅកាន់លេខាធិការដ្ឋាន នៅពេលណាមួយក៏បាន ។

ឯកសារព័ត៌មានទាំងអស់ គួរតែត្រូវបានដាក់ជូនពិនិត្យជាទម្រង់អេឡិចត្រូនិច និងឯកសារជាទម្រង់រឹងចំនួនយ៉ាងហោចណាស់ក៏ ១៥ ច្បាប់ដែរ គួរតែត្រូវបានផ្ញើជូនទៅលេខាធិការដ្ឋាន ទៅតាមអាសយដ្ឋានខាងក្រោម ។

តួអង្គសង្គមស៊ីវិល ដែលដាក់ជូនពិនិត្យនូវព័ត៌មានទៅកាន់គណៈកម្មាធិការនេះ ក៏អាចមានបំណងប្រាថ្នាផងដែរក្នុងការទាក់ទងនឹង**វេទិកាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិទទួលបន្ទុកអនុសញ្ញាស្ដីពីពលករទេសន្តរប្រវេសន៍** ដែលជាសម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលខិតខំពុះពាររួមគ្នា ដើម្បីសម្របសម្រួលដល់ការលើកកម្ពស់ ការអនុវត្ត និងការពិនិត្យតាមដានលើអនុសញ្ញានេះ ។

វេទិកាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនេះ អាចត្រូវបានទាក់ទងតាមរយៈ:

**វេទិកាអង្គការមិនមែនរដ្ឋាភិបាល**
នៅក្នុងអង្គការអន្តរជាតិខិសិមបើអេជីន
Rue de Varembé 1
P.O. Box 96
CH- 1211 Geneva 20 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩១៩ ១០ ៤២
ទូរសារលេខ: +៤១ (0)២២ ៩១៩ ១០ ៤៨
អ៊ីម៉ែល: **ipmwc@december18.net**
វិបសាយ: **http://www.december18.net**[26]

***ការចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការ***

តួអង្គសង្គមស៊ីវិល អាចចូលរួមក្នុងវគ្គប្រជុំពេញអង្គជាសាធារណៈរបស់គណៈកម្មាធិការនេះ ក្នុង

[26] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មិនទទួលខុសត្រូវចំពោះខ្លឹមសារនៃវិបសាយខាងក្រៅ និងការផ្ដល់ទំនាក់ទំនងទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតនៅក្នុងទំព័រនេះ មិនថ្លែងបង្កប់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ភ្ជាប់ខ្លួនឯងជាមួយនឹងខ្លឹមសារនេះទេ ។

ឋានៈជាអ្នកសង្កេតការណ៍ ។ ដើម្បីធ្វើដូច្នេះ គេ នឹងចាំបាច់ត្រូវសរសេរទៅកាន់លេខាធិការដ្ឋានទៅតាមអាសយដ្ឋានខាងក្រោម ដើម្បីស្នើសុំការអនុញ្ញាត ។

នៅក្នុងការរៀបចំលក្ខណៈត្រៀម ដើម្បីត្រួតពិនិត្យមើលរបាយការណ៍របស់ភាគីរដ្ឋ តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំសម្ងាត់ជាមួយនឹងគណៈកម្មាធិការ ដើម្បីធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់មាត់ស្តីពីស្ថានភាព របស់ពលករទេសន្តរប្រវេសន៍នៅក្នុងរដ្ឋណាមួយ និងដើម្បី ឆ្លើយនឹងសំណួររបស់សមាជិកគណៈកម្មាធិការនោះ ។ កិច្ចប្រជុំនេះ ប្រព្រឹត្តទៅនៅក្នុងអំឡុងពេលវគ្គប្រជុំពេញអង្គមុនវគ្គប្រជុំពេញអង្គដែលនៅក្នុងនោះ របាយការណ៍ របស់ភាគីរដ្ឋនឹងត្រូវបានត្រួតពិនិត្យ ដោយគណៈកម្មាធិការ ។

នៅក្នុងវគ្គប្រជុំពេញអង្គដែលនៅក្នុងនោះ របាយការណ៍របស់ភាគីរដ្ឋ ត្រូវបានត្រួតពិនិត្យ តួអង្គសង្គមស៊ីវិល ដែលបានដាក់ជូនពិនិត្យនូវព័ត៌មានជាលាយលក្ខណ៍អក្សរ ត្រូវបានផ្តល់នូវឱកាសឲ្យរាយការណ៍ព័ត៌មានដោយផ្ទាល់មាត់ជូនគណៈកម្មាធិការនេះនៅក្នុងកិច្ចប្រជុំជាសាធារណៈ មុនការត្រួតពិនិត្យរបស់គណៈកម្មាធិការលើរបាយការណ៍ របស់ភាគីរដ្ឋនោះ ។
អង្គការមិនមែនរដ្ឋាភិបាល អ្នកសិក្សាជាន់ខ្ពស់ និងតំណាងរបស់ក្រុមអ្នកវិជ្ជាជីវៈ ក្នុងចំណោម អ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចពិភាក្សាប្រធានបទទូទៅរយៈពេលជាច្រើនថ្ងៃ ដែលត្រូវបានរៀបចំឡើងទៅតាមដំណាក់កាល ដោយគណៈកម្មាធិការ ។

*បណ្តឹងជាលក្ខណៈបុគ្គល*

គណៈកម្មាធិការ នឹងអាចពិចារណាលើពាក្យបណ្តឹង ឬ ឯកសារបណ្តឹងនីមួយៗ កាលណា ភាគីរដ្ឋចំនួន ១០ បានយល់ព្រមទទួលយកនីតិវិធីនេះ ដោយអនុលោមទៅតាមមាត្រា ៧៧ នៃអនុសញ្ញានេះភ្លាម ។

***ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន***

**គណៈកម្មាធិការទទួលបន្ទុកកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ**

នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩0 ២៩
អ៊ីម៉ែលៈ **cmw@ohchr.org**

**ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការនេះ** ចូរមើលឯកសារសង្ខេបព័ត៌មាន **លេខ ២៤ (ការកែសម្រួលលើកទី ១) ។**

## គណៈកម្មាធិការការពារសិទ្ធិរបស់ជនពិការ

*ឧបករណ៍ត្រួតពិនិត្យ*

អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ និងពិធីសារបន្ថែមរបស់វា ។

*សមាជិកភាព*

គណៈកម្មាធិការនេះ នឹងមានជាលើកដំបូងនូវមន្ត្រីជំនាញឯករាជ្យចំនួន ១២ រូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្ត ទៀតបានតែម្តងគត់ និងគួរតែបញ្ចូលជនពិការដែលជាមន្ត្រីជំនាញ ។ បន្ទាប់ពីការផ្តល់សច្ចាប័ន ឬ ការចូលជា ភាគីចំនួន ៦០ លើកបន្ថែមទៀតនៃអនុសញ្ញានេះ សមាជិកភាពរបស់គណៈកម្មាធិការនេះ នឹងកើនឡើងដល់ ១៨ រូប ។ ភាគីរដ្ឋ ត្រូវបានអញ្ជើញឲ្យជំរុញយ៉ាងសកម្មឲ្យជនពិការ និងអង្គការតំណាងរបស់ពួកគេចូលរួមនៅពេល ជ្រើសតាំងបេក្ខជន សម្រាប់ការតែងតាំងជាគណៈកម្មាធិការ ។

*វគ្គប្រជុំពេញអង្គ*

នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ សមាជិកគណៈកម្មាធិការ មិនទាន់ត្រូវបានតែងតាំងទេ ។

*តម្រូវការធ្វើសេចក្តីសម្រេចចិត្ត*

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូងនៅក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការចូលជាភាគីនៃអនុសញ្ញានេះ និងបន្ទាប់មក យ៉ាងហោចណាស់ក៏រៀងរាល់ បួនឆ្នាំម្តងដែរ ឬ នៅពេលណាដែលគណៈកម្មាធិការនេះស្នើសុំដូច្នេះ ។

*បណ្តឹងជាលក្ខណៈបុគ្គល*

គណៈកម្មាធិការនេះ នឹងអាចពិចារណាលើឯកសារបណ្តឹងពីពីបុគ្គលទាំងឡាយ ឬ ក្រុមរបស់បុគ្គល ។ **ទម្រង់ពាក្យបណ្តឹងគំរូ** ត្រូវបានបញ្ចូលទៅក្នុង**ឧបសម្ព័ន្ធនៃ ជំពូក VIII (ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្ស)** នៃ*សៀវភៅ*នេះ ។

*ការស៊ើបសួរជាលក្ខណៈសម្ងាត់*

តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល អាចដាក់ជូនពិនិត្យនូវព័ត៌មានស្តីពីការរំលោភបំពានធ្ងន់ធ្ងរ ធ្ងន់ធ្ងរខ្លាំង ឬ ជាប្រព័ន្ធលើអនុសញ្ញានេះទៅកាន់លេខាធិការដ្ឋាន ។ ព័ត៌មាននេះ ត្រូវ តែគួរឲ្យជឿជាក់បាន និងបង្ហាញថា ភាគីរដ្ឋកំពុងតែរំលោភបំពានជាប្រព័ន្ធលើសិទ្ធិ ដែលត្រូវបានចែងនៅក្នុងអនុសញ្ញានេះ ។

*មាត្រា ៣៣*

អនុសញ្ញានេះ មានចែងនូវបទប្បញ្ញត្តិពិសេសមួយស្តីពីតួនាទីរបស់សង្គមស៊ីវិល ក្នុងការពិនិត្យតាមដានការអនុវត្តវា ។ មាត្រា ៣៣ ចែងថា សង្គមស៊ីវិលត្រូវតែបានជំរុញឲ្យចូលរួម និងចូលរួមដោយពេញលេញនៅក្នុងដំណើរការពិនិត្យតាមដាន ដែលត្រូវបានកំណត់ដោយភាគីរដ្ឋ ដោយហេតុដូច្នេះផ្តល់ដល់សង្គមស៊ីវិលនូវតួនាទីសំខាន់បំផុត ក្នុងការលើកកម្ពស់ការអនុវត្តអនុសញ្ញានេះ ។

*ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន*

**គណៈកម្មាធិការការពារសិទ្ធិរបស់ជនពិការ**
នៅក្នុងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ២៩
អ៊ីម៉ែលៈ crpd@ohchr.org

សម្រាប់ព័ត៌មានបន្ថែមស្តីពី**ការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល**

| | |
|---|---|
| **បន្ទុកសិទ្ធិមនុស្ស (OHCHR) ពាក់ព័ន្ធនឹងអនុសញ្ញា និង បញ្ញាពិការភាព** ជាទូទៅ ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។<br><br>ដើម្បីជ្រាបព័ត៌មានបន្ថែមស្ដីពី**អនុសញ្ញា និង ពិធីសារបន្ថែមរបស់វា** ចូរមើលអត្ថបទបោះពុម្ពផ្សាយ | របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្ដីពី ***ពីអបរិយាប័ន្ន ទៅសមភាពៈ ការសម្រេចបាននូវសិទ្ធិរបស់ជនពិការ*** (HR/PUB/07/6) ។ |

## គណៈកម្មាធិការប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ

*ឧបករណ៍ត្រួតពិនិត្យ*

អនុសញ្ញាអន្តរជាតិដើម្បីការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ ។

*សមាជិកភាព*

គណៈកម្មាធិការនេះ នឹងមានមន្ត្រីជំនាញឯករាជ្យចំនួន ១០ រូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំ ដែលអាចបន្តទៀតបានតែម្តងគត់ ។

*តម្រូវការធ្វើសេចក្តីរាយការណ៍*

ភាគីរដ្ឋ ត្រូវតែធ្វើសេចក្តីរាយការណ៍ជាលើកដំបូងនៅក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីចូលជាភាគីនៃអនុសញ្ញានេះ ។

*វិធានការបន្ទាន់*

គណៈកម្មាធិការនេះ នឹងអាចទទួលសំណើបន្ទាន់ពីបុគ្គលទាំងឡាយថា ជនបាត់ខ្លួន គួរតែត្រូវបានស្វែងរក និងរកឲ្យឃើញ ។ ជនដែលត្រូវបានពិភាក្សានេះ ត្រូវតែបានដាក់ឲ្យស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ភាគីរដ្ឋនៃអនុសញ្ញានេះ ។

*បណ្តឹងជាលក្ខណៈបុគ្គល*

គណៈកម្មាធិការនេះ នឹងអាចពិចារណាលើឯកសារបណ្តឹងនីមួយៗចំពោះភាគីរដ្ឋដែលយល់ព្រមទទួលយកនីតិវិធីនេះ ដោយអនុលោមទៅតាមមាត្រា ៣១ នៃអនុសញ្ញានេះ ។

*ការស៊ើបសួរ*

តួអង្គសង្គមស៊ីវិល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល នឹងអាចដាក់ជូនពិនិត្យនូវព័ត៌មាន ដែលបង្ហាញថាភាគីរដ្ឋ កំពុងតែរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើបទបញ្ញត្តិនានានៃអនុសញ្ញានេះ ដោយអនុលោមទៅតាមមាត្រា ៣៣។ ថែមពីលើនេះទៀត គណៈកម្មាធិការនេះ ត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បី ជម្រាបជូនជាបន្ទាន់ដល់មហាសន្និបាតអង្គការសហប្រជាជាតិនូវព័ត៌មានដែលបង្ហាញថាការអនុវត្តការបាត់ ខ្លួនដោយបង្ខំ មានការរីករាលដាល ឬមានលក្ខណៈ ជាប្រព័ន្ធនៅក្នុងភាគីរដ្ឋ ។

**ដើម្បីជ្រាបព័ត៌មានបន្ថែមស្តីពីការបាត់ខ្លួនដោយ បង្ខំ ឬ ដោយស្ម័គ្រចិត្ត ចូរមើលឯកសារសង្ខេបព័ត៌មាន លេខ ៦ (ការកែសម្រួលទី ២) ។**

# V. ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## ទិដ្ឋភាពរួមនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

*ដូចម្តេចដែលហៅថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស ?*

ក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាគណៈអន្តររដ្ឋាភិបាលដ៏សំខាន់បំផុតនៃអង្គការសហប្រជាជាតិ ដែលទទួលខុសត្រូវចំពោះសិទ្ធិមនុស្ស ។ ដោយត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចចិត្តមហាសន្និបាតអង្គការសហប្រជាជាតិ លេខ 60/251 ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ បានជំនួសឲ្យ និងទទួលបន្តនូវអាណត្តិ យន្តការមុខងារ និង ការទទួលខុសត្រូវភាគច្រើនដែល ត្រូវបានប្រគល់ឲ្យពីមុនដល់គណៈកម្មការសិទ្ធិមនុស្ស ។ ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គឺជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដូចដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនេះ បានបំពេញចំពោះគណៈកម្មការសិទ្ធិមនុស្សដែរ ។

*តើក្រុមប្រឹក្សាសិទ្ធិមនុស្សធ្វើការងារដោយវិធីណា ?*

ក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាគណៈអន្តររដ្ឋាភិបាលរបស់រដ្ឋជាសមាជិកចំនួន ៤៧ ដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ជួបប្រជុំគ្នាយ៉ាងហោចណាស់ក៏ ១០ សប្តាហ៍ដែរក្នុងមួយឆ្នាំ ដែលត្រូវបានរៀបចំបែងចែកឲ្យកើតមានឡើងជាបន្តបន្ទាប់មិនតិចជាងវគ្គប្រជុំពេញអង្គចំនួនបីលើក និងក៏អាចរៀបចំបានផងដែរនូវវគ្គប្រជុំពេញអង្គពិសេស ។ ខណៈពេលដែលគណៈកម្មការ ធ្លាប់ជា**គណៈផ្នែកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច** (ECOSOC) ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏ជាគណៈផ្នែកនៃ**មហាសន្និបាតអង្គការសហប្រជាជាតិ**ផងដែរ ។ តួនាទីរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រួមមាន ការដោះស្រាយបញ្ហាការរំលោភបំពានលើសិទ្ធិមនុស្ស ក្នុងនោះរួមមានការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងជាប្រព័ន្ធផងដែ និងការលើកកម្ពស់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងប្រព័ន្ធសហប្រជាជាតិ ។

នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៧ ពោលគឺ រយៈពេលមួយឆ្នាំក្រោយកិច្ចប្រជុំលើកទីមួយរបស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានយល់ព្រមលើឯកសារកញ្ចប់ ដែលបានរៀបចំនីតិវិធី យន្តការ និងរចនាសម្ព័ន្ធ សម្រាប់ការងារនាពេលអនាគតរបស់ខ្លួន ។ ឯកសារកញ្ចប់នេះ ដែលត្រូវបានអនុម័តជា**សេចក្តីសម្រេចចិត្តលេខ 5/1** របស់ខ្លួន បានរួមបញ្ចូលរបៀបវារៈ កម្មវិធី ការងារ និងវិធាននីតិវិធី និងបាន ធ្វើការផ្លាស់ប្តូរលើប្រព័ន្ធណែនាំ ផ្នែកជំនាញ និងនីតិវិធីប្តឹងដែលត្រូវបានទទួលពីគណៈកម្មការនេះ ។ សេចក្តីសម្រេចចិត្តលេខ 5/1 ក៏បានចែងផងដែរនូវស្ថានភាពបែបបទ សម្រាប់ដំណើរ

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

ការនៃយន្តការត្រួតពិនិត្យឡើងវិញ តាមដំណាក់កាលជាសកលរបស់ក្រុមប្រឹក្សានេះ និងបានបង្កើតឡើងនូវដំណើរការមួយសម្រាប់ត្រួតពិនិត្យឡើងវិញ ធ្វើសនិទានកម្ម និងកែលម្អអាណត្តិរបស់យន្តការពិសេសទាំងអស់ ។

***វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស និងអាណត្តិ និងយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ***

នៅក្នុងសេចក្តីសម្រេចចិត្តលេខ 60/251 មហាសន្និបាតអង្គការសហប្រជាជាតិ ទទួលការពិតអំពីតួនាទីសំខាន់ ដែលត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) និងតួអង្គសង្គមស៊ីវិលផ្សេងទៀត នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ។

ការចូលរួមរបស់អ្នកសង្កេតការណ៍ ក្នុងនោះរួមមានអង្គការមិនមែនរដ្ឋាភិបាលផងដែរ នៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា ត្រូវមានមូលដ្ឋាននៅលើការរៀបចំ និងការអនុវត្ត ដែលត្រូវបានសង្កេតមើលដោយអតីតគណៈកម្មការនេះ ។ ការអនុវត្ត និងការរៀបចំទាំងនេះ បន្តអភិវឌ្ឍ និងវិវត្តស្របជាមួយនឹងក្រុមប្រឹក្សា ដែលត្រូវបានតម្រូវឲ្យមាន ដើម្បីធានាឲ្យមាន "ការរួមចំណែកដែលមានប្រសិទ្ធភាពបំផុតរបស់អ្នកសង្កេត- ការណ៍" ។[27]

ទោះបីជា**ឋានៈពិគ្រោះយោបល់**ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ត្រូវបានតម្រូវឲ្យមានសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ទទួលបានការអនុញ្ញាតក្នុងឋានៈជាអ្នកសង្កេតការណ៍ នៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាល ដែលគ្មានឋានៈនេះ និងតួអង្គសង្គម ស៊ីវិលផ្សេងទៀត អាចរួមចំណែក នៅក្នុងការងារទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះតាមរបៀបមួយចំនួន ។ ជាងនេះទៀត កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ត្រូវបានផ្សាយផ្ទាល់នៅក្នុង**កម្មវិធីផ្សាយនៅលើអ៊ិនធើណិត** និងកម្រងឯកសារ និងព័ត៌មានជាច្រើនសន្ធឹកសន្ធាប់ ត្រូវបានរៀបចំឲ្យមាននៅក្នុង**វិបសាយ** និង**ប្រព័ន្ធកុំព្យូទ័រ (អ៊ិក្សត្រាណិត)** របស់ក្រុមប្រឹក្សានេះ ។

តាមធម្មតា ព័ត៌មានដែលពាក់ព័ន្ធតែនឹងវគ្គប្រជុំពេញអង្គ ត្រូវបានដាក់ផ្សាយនៅក្នុងវិបសាយនេះ ក្នុងរយៈពេលពីរសប្តាហ៍មុនវគ្គប្រជុំពេញអង្គជាទៀងទាត់នីមួយៗ ។

[27] ចូរមើលសេចក្តីសម្រេចចិត្តលេខ 60/251 របស់មហាសន្និបាត និងសេចក្តីសម្រេចចិត្តលេខ 5/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

## i ព័ត៌មានទំនាក់ទំនងសំខាន់ៗដែលទាក់ទងនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស

**សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស**
សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៩២ ៥៦
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ១១

**អង្គភាពសង្គមស៊ីវិល**
អង្គភាពសង្គមស៊ីវិលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៩០ 00
អ៊ីម៉ែលៈ **civilsocietyunit@ohchr.org**

**សម្រាប់សំណើសុំ ឬ ព័ត៌មានទាក់ទងនឹងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុម ប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)**
*ទីស្នាក់ការរបស់អង្គការសហប្រជាជាតិ*
ផ្នែកអង្គការមិនមែនរដ្ឋាភិបាល
នាយកដ្ឋានផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ
One UN Plaza, Room DC-1-1-1480
ទីក្រុងញូវយ៉ក NY 10017
ទូរស័ព្ទលេខៈ +១ ២១២ ៩៦៣ ៨៦៥២
ទូរសារលេខៈ +១ ២១២ ៩៦៣ ៩២៤៨
អ៊ីម៉ែលៈ **desangosection@un.org**

*ការិយាល័យអង្គការសហប្រជាជាតិ (UNDG)*
ការិយាល័យទំនាក់ទំនងអង្គការមិនមែនរដ្ឋាភិបាល
ការិយាល័យរបស់អគ្គនាយក
ការិយាល័យទី ១៥៣ វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ២១ ២៧
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ០៥ ៨៣
អ៊ីម៉ែលៈ **ungeneva.ngoliaison@unog.ch**

**ព័ត៌មានទំនាក់ទំនងសំខាន់ៗ សម្រាប់យន្តការនីមួយៗរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកពាក់ព័ន្ធនៅក្នុងជំពូកនេះទាំងមូល**

# ដូចម្តេចដែលហៅថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស ?

## អន្តរកាលពីគណៈកម្មការសិទ្ធិមនុស្ស ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ដែលត្រូវបានបង្កើតឡើងដោយ**សេចក្តីសម្រេចចិត្ត**មហាសន្និបាតអង្គការសហប្រជាជាតិ**លេខ 60/251** ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៦ គឺជាគណៈអន្តររដ្ឋាភិបាលដ៏សំខាន់បំផុតនៃអង្គការសហប្រជាជាតិដែលទទួលខុសត្រូវចំពោះសិទ្ធិមនុស្ស ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ជំនួស**គណៈកម្មការសិទ្ធិមនុស្ស** ដែលក្នុងរយៈពេលជាង ៦០ឆ្នាំ បានធ្វើជាចំណុចផ្តោតការយកចិត្តទុកដាក់នៃប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។ គណៈកម្មការនេះ បានជួបប្រជុំគ្នាជាលើកចុងក្រោយនៅក្នុងខែមីនា ឆ្នាំ២០០៦នៅឯវគ្គប្រជុំពេញអង្គលើកទីហុកសិបពីររបស់ខ្លួន ។ សមិទ្ធផលផ្នែកធម្មនិយាម និងការបង្កើតស្តង់ដា បង្កើតបានជាមូលដ្ឋានគ្រឹះនៃការងាររបស់ក្រុមប្រឹក្សានេះ ។

ខណៈពេលដែលគណៈកម្មការ ធ្លាប់ជាគណៈផ្នែកនៃ**ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច** (ECOSOC) ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏ជាគណៈផ្នែកនៃ**មហាសន្និបាតអង្គការសហប្រជាជាតិ**ផងដែរ ។ ការវាយតម្លៃនេះគូសបញ្ជាក់អំពីសិទ្ធិមនុស្សថាជាសសរស្តម្ភដ៏សំខាន់ជាសារវន្តមួយ ក្នុងចំណោមសសរស្តម្ភដ៏សំខាន់ទាំងបីរបស់អង្គការសហប្រជាជាតិ ព្រមជាមួយនឹងការអភិវឌ្ឍ និងសន្តិភាព និងសន្តិសុខ ។ ការបង្កើតក្រុមប្រឹក្សា ក៏បញ្ជាក់អំពីការប្តេជ្ញាចិត្ត របស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងការពង្រឹងក្បាលម៉ាស៊ីនដឹកនាំផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដោយមានគោលបំណងធានាឲ្យមានការសម្រេចបានប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិមនុស្សទាំងអស់ ពោលគឺ សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ក្នុងនោះរួមមាន សិទ្ធិទទួលបានការអភិវឌ្ឍផងដែរ ។

នៅក្នុងសេចក្តីសម្រេចចិត្តលេខ 60/251 របស់ខ្លួន មហាសន្និបាតអង្គការអង្គការសហប្រជាជាតិបានប្រគល់ឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្សនូវកិច្ចការត្រួតពិនិត្យឡើងវិញ និងក្នុងករណីចាំបាច់ កែលម្អ និងធ្វើសនិទានកម្មលើអាណត្តិ យន្តការ មុខងារ និងការទទួលខុសត្រូវ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានទទួលយកពីគណៈកម្មការនេះ ។ ក្រុមប្រឹក្សានេះ ត្រូវបានតម្រូវឲ្យបំពេញកិច្ចការនេះ ក្នុងរយៈពេលមួយឆ្នាំនៃការរៀបចំវគ្គប្រជុំពេញអង្គលើកទីមួយរបស់ខ្លួន ។ វិធីសាស្រ្តការងាររបស់ក្រុមប្រឹក្សា ក៏ត្រូវបានតម្រូវឲ្យមានផងដែរដើម្បីៈ

- ឲ្យមានតម្លាភាព យុត្តិធម៌ និងភាពមិនលម្អៀង ។
- ឲ្យមានការតម្រង់ទិសលទ្ធផល ។
- ជួយឲ្យមានការសន្ទនាពិត ។
- អនុញ្ញាតឲ្យមានការពិភាក្សាបន្តលើអនុសាសន៍របស់ក្រុមប្រឹក្សា និងការអនុវត្តអនុសាសន៍ទាំងនេះ និង
- អនុញ្ញាតឲ្យមានការទំនាក់ទំនងទៅវិញទៅមកដ៏សំខាន់ជាមួយនឹងយន្តការរបស់ក្រុមប្រឹក្សា ។

មហាសន្និបាតអង្គការសហប្រជាជាតិ នឹងត្រួតពិនិត្យឡើងវិញលើស្ថានភាពរបស់ក្រុមប្រឹក្សានៅក្នុងរយៈពេលប្រាំឆ្នាំ ។[28]

## ឯកសារកញ្ចប់កសាងស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សេចក្ដីសម្រេចចិត្តលេខ 5/1)

នៅថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០០៧ រយៈពេលមួយឆ្នាំ បន្ទាប់ពីកិច្ចប្រជុំលើកទីមួយរបស់ខ្លួន និង បន្ទាប់ពីរយៈពេលដ៏បង្ហំនៃ "ការកសាងស្ថាប័ន" ក្រុមប្រឹក្សាបានយល់ព្រមលើឯកសារកញ្ចប់ដែលចែងអំពីនីតិវិធី យន្តការ និងរចនាសម្ព័ន្ធរបស់ខ្លួន ។ ដោយត្រូវបានអនុម័តជា**សេចក្ដីសម្រេចចិត្តលេខ 5/1** ស្ដីពីការកសាងស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ[29] ឯកសារកញ្ចប់ បានរួមបញ្ចូលៈ

- របៀបវារៈថ្មី និងក្របខ័ណ្ឌសម្រាប់កម្មវិធីការងារ ។
- វិធីសាស្រ្តថ្មីនៃការងារ និងវិធាននីតិវិធីថ្មី ដោយមានមូលដ្ឋាននៅលើនីតិវិធី ដែលត្រូវបានបង្កើតឡើងសម្រាប់គណៈកម្មាធិការនានារបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។
- នីតិវិធីប្ដឹង (ដែលជំនួសនីតិវិធីលេខ ១៥០៣) ។
- គណៈកម្មាធិការទីប្រឹក្សាផ្ដល់យោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (ដែលជំនួសអនុគណៈកម្មការទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិមនុស្ស) ។
- គោលការណ៍ ដំណើរការនីតិវិធី និងស្ថានភាពបែបបទ សម្រាប់នាំផ្លូវដំណើរការនៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (UPR) ថ្មី និង
- លក្ខណវិនិច្ឆ័យសម្រាប់ការត្រួតពិនិត្យឡើងវិញ ការធ្វើសនិទានកម្ម និងការកែលម្អអាណត្តិរបស់យន្តការពិសេសដែលកំពុងតែបន្ត ។

## តើក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការ និងអាណត្តិរបស់ខ្លួនដំណើរការនៅដូចម្ដេច ?

### សមាជិកភាព

សមាជិកភាពរបស់ក្រុមប្រឹក្សា មានប្រទេសជាសមាជិកចំនួន ៤៧ ដែលត្រូវបានជ្រើសរើសដោយផ្ទាល់ និងជាលក្ខណៈបុគ្គល តាមរយៈការបោះឆ្នោតជាសម្ងាត់ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកមហាសន្និបាតអង្គការសហប្រជាជាតិ ។ លទ្ធផលឯកទត្តកម្មផ្នែកសិទ្ធិមនុស្ស និងការសន្យាផ្នែកសិទ្ធិមនុស្សស្ម័គ្រចិត្ត និងការប្ដេជ្ញាចិត្តរបស់រដ្ឋបេក្ខភាព គឺត្រូវបានពិចារណា នៅពេលបោះឆ្នោតជ្រើសតាំងរដ្ឋជាសមា

[28] ចូរមើលសេចក្ដីសម្រេចចិត្តលេខ 60/251 ដែលក្នុងនោះ មហាសន្និបាតអង្គការសហប្រជាជាតិ ក៏តម្រូវឲ្យក្រុមប្រឹក្សាត្រួតពិនិត្យឡើងវិញផងដែរលើការងារ និងមុខងាររបស់ក្រុមប្រឹក្សា នៅក្នុងរយៈពេលប្រាំឆ្នាំ បន្ទាប់ពីការបង្កើតក្រុមប្រឹក្សានេះ និងរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ។

[29] សេចក្ដីសម្រេចចិត្តលេខ 5/1 ត្រូវបានអនុម័តយល់ព្រមដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងសេចក្ដីសម្រេចចិត្តលេខ 62/219 របស់ខ្លួន ។

ជិក ។ រដ្ឋជាសមាជិករបស់ក្រុមប្រឹក្សា បម្រើសម្រាប់អាណត្តិបីឆ្នាំ និងមិនមានសិទ្ធិចូលរួមការបោះឆ្នោតជ្រើសតាំងឡើងវិញទេ បន្ទាប់ពីបានពីរអាណត្តិជាប់ៗគ្នា ។

ប្រសិនបើរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សា មានការរំលោភបំពានធ្ងន់ធ្ងរ និងជាប្រព័ន្ធលើសិទ្ធិមនុស្ស មហាសន្និបាតអង្គការសហប្រជាជាតិ ដោយសម្លេងពីរភាគបីដាច់ខាតនៃសមាជិកទាំងអស់ ដែលមានវត្តមាន និងបានបោះឆ្នោត អាចដកហូតជាបណ្តោះអាសន្ន នូវសិទ្ធិសមាជិកភាពរបស់រដ្ឋជាសមាជិកនៅក្នុងក្រុមប្រឹក្សា ។

> *i* សម្រាប់បញ្ជី**ឈ្មោះរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាបច្ចុប្បន្ន** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## កិច្ចប្រជុំ

ដោយហេតុថា អតីតគណៈកម្មការ បានជួបប្រជុំគ្នាតែម្តងក្នុងមួយឆ្នាំ សម្រាប់រយៈពេលសរុបប្រាំមួយសប្តាហ៍ ក្រុមប្រឹក្សា ជួបប្រជុំនៅឯវិមានជាតិនៅក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស សម្រាប់រយៈពេលយ៉ាងតិចបំផុតក៏វគ្គប្រជុំពេញអង្គសាមញ្ញចំនួនបីវគ្គក្នុងមួយឆ្នាំដែរក្នុងរយៈពេលសរុបមិនតិចជាង ១០ សប្តាហ៍ ។ តាមធម្មតា វគ្គប្រជុំពេញអង្គ (បួនសប្តាហ៍) សំខាន់បំផុតរបស់ក្រុមប្រឹក្សា ត្រូវបានរៀបចំឡើងនៅក្នុងខែមីនា។

ក្រុមប្រឹក្សា ក៏អាចរៀបចំវគ្គប្រជុំពេញអង្គពិសេសផងដែរ តាមការស្នើសុំរបស់រដ្ឋជាសមាជិក ដែលក្នុងនោះសំណើបែបនេះ ត្រូវបានគាំទ្រដោយរដ្ឋជាសមាជិករបស់ខ្លួនយ៉ាងតិចបំផុតក៏មួយភាគបីដែរ ។[30] នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ ក្រុមប្រឹក្សានេះ បានរៀបចំវគ្គប្រជុំពេញអង្គពិសេសចំនួនប្រាំពីរ ។[31]

ក្រុមប្រឹក្សា ក៏រៀបចំផងដែរនូវកិច្ចពិភាក្សាជាក្រុម និងព្រឹត្តិការណ៍ពិសេស ដើម្បីជំរុញឲ្យមានភាពជឿនលឿនលើការសន្ទនា និងការស្វែងយល់ទៅវិញទៅមកលើបញ្ហាជាក់លាក់ ។ នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ ក្រុមប្រឹក្សានេះ បានរៀបចំព្រឹត្តិការណ៍ចំនួនប្រាំមួយលើកក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ[32] ក្នុងនោះរួមមាន កិច្ចពិភាក្សាប្រចាំឆ្នាំស្តីពីសិទ្ធិរបស់ជនពិការ[33] និងការធ្វើសមាហរណ៍កម្មទស្សនវិស័យយេនឌ័រទៅក្នុងការងាររបស់ខ្លួន និងការងារនៃយន្តការរបស់ខ្លួន ។[34]

## អាណត្តិ និងយន្តការ

### ក. យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

**យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** (UPR) គឺជាយន្តការសិទ្ធិមនុស្សថ្មីមួយ ។ តាមរយៈវា ក្រុមប្រឹក្សា ត្រួតពិនិត្យឡើងវិញទៅតាមដំណាក់កាលលើការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្ត

[30] វា តម្រូវឲ្យមានការគាំទ្ររបស់រដ្ឋក្នុងការរៀបចំវគ្គប្រជុំពេញអង្គពិសេសនៅឯក្រុមប្រឹក្សាក្នុងចំនួនតិចជាងវាបានតម្រូវឲ្យមាននៅឯគណៈកម្មការ (មួយភាគបីនៃសមាជិក ៤៧ ធៀបនឹងភាគច្រើនដាច់ខាតនៃសមាជិក ៥៣) ។ គណៈកម្មការ បានរៀបចំវគ្គប្រជុំពេញអង្គពិសេសតែប្រាំប៉ុណ្ណោះ ។

[31] បីស្តីពីទឹកដីប៉ាលេស្ទីនដែលត្រូវបានកាន់កាប់ (ខែ កក្កដា និងខែ វិច្ឆិកា ឆ្នាំ ២០០៦ និងខែ មករា ឆ្នាំ ២០០៨) មួយទៀតស្តីពីប្រទេសលីបង់ (ខែ សីហា ឆ្នាំ ២០០៦) មួយទៀតស្តីពីតំបន់ដាហ្វួ (ខែ ធ្នូ ឆ្នាំ ២០០៦) មួយទៀតស្តីពីប្រទេសមីយ៉ាន់ម៉ា (ខែ តុលា ឆ្នាំ ២០០៧) និងវគ្គប្រជុំពេញអង្គផ្នែកប្រធានបទស្តីពីវិបត្តិស្បៀងពិភពលោក (ខែ ឧសភា ឆ្នាំ ២០០៨) ។

[32] ពីរស្តីពីការអនុម័ត និងការចូលជាធរមាននៃអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ (ខែ មីនា ឆ្នាំ ២០០៧ និងខែ មិថុនា ឆ្នាំ ២០០៨) មួយទៀតស្តីពី **សេចក្តីព្រាងគោលការណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ការប្រើប្រាស់សមស្រប និងលក្ខខណ្ឌនៃការថែទាំជម្រើសចំពោះកុមារ** (ខែ មិថុនា ឆ្នាំ ២០០៨) មួយទៀតស្តីពីការពិភាក្សាអន្តរវប្បធម៌លើសិទ្ធិមនុស្ស (ខែ មីនា ឆ្នាំ ២០០៨) មួយទៀតស្តីពីគោលដៅស្ម័គ្រចិត្តផ្នែកសិទ្ធិមនុស្ស (ខែ មីនា ឆ្នាំ ២០០៨) និងមួយទៀតស្តីពីមនុស្សបាត់ខ្លួន (ខែ កញ្ញា ឆ្នាំ ២០០៨) ។

[33] កិច្ចពិភាក្សាវែកញែកទីមួយ ត្រូវបានកំណត់ពេលវេលាថា នឹងប្រព្រឹត្តទៅនៅឯវគ្គប្រជុំពេញអង្គសាមញ្ញលើកទីដប់របស់ក្រុមប្រឹក្សា ដើម្បីផ្តោតទៅលើវិធានការច្បាប់សំខាន់ៗសម្រាប់ការផ្តល់សច្ចាប័ន និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ**អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវបានស្នើសុំ ដើម្បីរៀបចំការសិក្សាបែបប្រធានបទស្តីពីប្រធានបទនេះ ដោយពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល ក្នុងចំណោមអង្គការផ្សេងទៀត ។

[34] ចូរមើលសេចក្តីសម្រេចចិត្តលេខ 6/30 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ។ កិច្ចប្រជុំលើកទីមួយស្តីពីបញ្ហាអំពើហិង្សាចំពោះស្ត្រីភេទ ត្រូវបានរៀបចំឡើងនៅក្នុងវគ្គប្រជុំពេញអង្គលើកទីប្រាំបីរបស់ខ្លួន និងមានពីរក្រុមៈ មួយស្តីពីអំពើហិង្សាចំពោះស្ត្រីភេទ និងមួយទៀតស្តីពីអត្រាមរណភាពមាតា ។ នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៨ ក្រុមប្រឹក្សា បានរៀបចំកិច្ចពិភាក្សាជាក្រុមលើការធ្វើសមាហរណកម្មទស្សនវិស័យយេនឌ័រទៅក្នុងការងាររបស់ខ្លួន ។

ផ្នែកសិទ្ធិមនុស្សរបស់ក្រុមប្រឹក្សា ដោយសមាជិកនីមួយៗនៃសមាជិកទាំង ១៩២ របស់អង្គការសហប្រជាជាតិ ។ យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (UPR) គឺជាយន្តការសហប្រតិបត្តិការដោយមានមូលដ្ឋាននៅលើការពិភាក្សាគ្នាទៅវិញទៅមកជាមួយនឹងរដ្ឋ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។ វា ត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមតែមិនចម្លង លើការងាររបស់ស្ថាប័នសន្ធិសញ្ញា ។

ការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (UPR) ត្រូវបានចាត់ទុកថាជាដំណើរការដែលមានជាដំណាក់កាលនៅក្នុងរយៈពេលមួយខួបបួនឆ្នាំ:

- ការរៀបចំព័ត៌មានដែលការត្រួតពិនិត្យឡើងវិញ ត្រូវបានយកជាមូលដ្ឋាន (ក្នុងនោះរួមមាន ព័ត៌មានដែលត្រូវបានរៀបចំដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ (របាយការណ៍ជាតិ) កម្រងឯកសារព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** និងសេចក្តីសង្ខេបនៃឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ដែលក៏ត្រូវបានរៀបចំដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផងដែរ ។
- ការត្រួតពិនិត្យឡើងវិញនោះឯង ដែលប្រព្រឹត្តទៅនៅក្នុងក្រុមការងារទទួលបន្ទុកការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដែលមានរដ្ឋជាសមាជិកចំនួន ៤៧ របស់ក្រុមប្រឹក្សា ដែលជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គរយៈពេលពីរសប្តាហ៍ចំនួនបីវគ្គ រៀងរាល់ឆ្នាំ ។[35]
- ការពិចារណា និងការអនុម័តលើឯកសារលទ្ធផលនៃការត្រួតពិនិត្យឡើងវិញដោយក្រុមប្រឹក្សានៅក្នុងវគ្គប្រជុំពេញអង្គសាមញ្ញរបស់ខ្លួន និង
- ការពិនិត្យតាមដានបន្តលើការអនុវត្តលទ្ធផលនៃការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (UPR) ដោយរដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ ។

អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធ ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ អង្គការតំបន់ និងតំណាងសង្គមស៊ីវិល អាចចូលរួមនៅក្នុងដំណាក់កាលខ្លះនៃដំណាក់កាលទាំងនេះ ។

> *i* សម្រាប់ព័ត៌មានស្តីពី**យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** សូមមើល**ជំពូក VII (យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល)** នៃ*សៀវភៅ*នេះ ។

[35] ក្រុមការងារទទួលបន្ទុកការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ត្រួតពិនិត្យឡើងវិញលើរដ្ឋចំនួន ១៦ នៅក្នុងវគ្គប្រជុំពេញអង្គនីមួយៗ ពោលគឺ សរុបមាន ៤៨ រដ្ឋ នៅក្នុងមួយឆ្នាំៗ ។

## ខ. គណៈកម្មាធិការទីប្រឹក្សាផ្តល់យោបល់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

គណៈកម្មាធិការផ្តល់ប្រឹក្សា គឺជាគណៈផ្នែកនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ វាជំនួសឲ្យអនុគណៈកម្មការទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងមានងារជាអង្គការស្រាវជ្រាវសម្រាប់ក្រុមប្រឹក្សា ដោយផ្តោតភាគច្រើនទៅលើការសិក្សា និងការណែនាំដែលមានមូលដ្ឋាននៅលើការស្រាវជ្រាវ តាមរបៀប និងទម្រង់មួយដែលត្រូវបានស្នើសុំដោយក្រុមប្រឹក្សា ។

ទោះបីជាមិនអាចអនុម័តសេចក្តីសម្រេចចិត្ត ឬ សេចក្តីសម្រេច ឬ បង្កើតស្ថាប័ន ផ្នែកដោយគ្មានការអនុញ្ញាតរបស់ក្រុមប្រឹក្សាក៏ដោយ ក៏គណៈកម្មាធិការផ្តល់ប្រឹក្សា អាចផ្តល់ជាមតិយោបល់ដល់ក្រុមប្រឹក្សាបានដែរៈ

- ដើម្បីលើកកម្ពស់ភាពស័ក្តសិទ្ធិផ្នែកនីតិវិធីផ្ទាល់របស់ខ្លួន និង
- ដើម្បីបង្កើនសំណើសុំស្រាវជ្រាវនៅក្នុងវិសាលភាពនៃការងាររបស់ខ្លួន ។

គណៈកម្មាធិការផ្តល់ប្រឹក្សា មានមន្ត្រីជំនាញចំនួន ១៨ ដែលត្រូវបានជ្រើសរើសជាសមាមាត្រចេញពីក្រុមតំបន់ចំនួនប្រាំរបស់អង្គការសហប្រជាជាតិ (អាព្រិច អាស៊ី អឺរ៉ុបខាងកើត អាមេរិកឡាទីន និងការីប៊ីន និងអឺរ៉ុបខាងលិច និងតំបន់ផ្សេងទៀត) ។ សមាជិក បម្រើសម្រាប់អាណត្តិបីឆ្នាំ ក្នុងឋានៈផ្ទាល់របស់ខ្លួន និងមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតឡើងវិញបានតែម្តងគត់ ។[36] គណៈកម្មាធិការផ្តល់ប្រឹក្សា ជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គចំនួនពីរវគ្គក្នុងមួយឆ្នាំៗ សម្រាប់រយៈពេលសរុបរហូតដល់ ១០ ថ្ងៃធ្វើការ និងអាចរៀបចំវគ្គប្រជុំពេញអង្គពិសេសបន្ថែម ដោយមានការអនុម័តពីក្រុមប្រឹក្សា ។

> **i** សម្រាប់ព័ត៌មានបន្ថែមស្តីពី**គណៈកម្មាធិការផ្តល់ប្រឹក្សា** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## គ. នីតិវិធីប្តឹង

**នីតិវិធីប្តឹង** ផ្តោតទៅលើគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងដែលបានផ្តល់ភ័ស្តុតាងគួរឲ្យជឿទុកចិត្តបានលើសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូលដ្ឋាន ដែលកើតមានឡើងនៅក្នុងផ្នែកណាមួយនៃពិភពលោក និងក្នុងកាលៈទេសៈខ្លះ ។ នីតិវិធីនេះ មានមូលដ្ឋាននៅលើនីតិវិធីលេខ ១៥០៣ របស់អតីតគណៈកម្មការ ដែលត្រូវបានកែលម្អ ដើម្បីធានាថា នីតិវិធីនេះ មានលក្ខណៈអនាគតិ មិនលម្អៀង ស័ក្តសិទ្ធិតម្រង់ទិសជនរងគ្រោះ និងត្រូវបានអនុវត្តដោយទាន់ពេលវេលា ។

---

[36] ទោះជាយ៉ាងក៏ដោយ សេចក្តីសម្រេចចិត្តលេខ 5/1 បានចែងថា សម្រាប់អាណត្តិទីមួយ មួយភាគបីនៃសមាជិក នឹងបម្រើសម្រាប់រយៈពេលមួយឆ្នាំ និងមួយភាគបីទៀត នឹងបម្រើសម្រាប់រយៈពីរឆ្នាំ ដើម្បីរៀបចំផ្លាស់សមាជិកភាព ។ [37] ចូរមើលសេចក្តីសម្រេចចិត្តលេខ 1998/72 របស់គណៈកម្មការសិទ្ធិមនុស្ស និងសេចក្តីសម្រេចលេខ 1998/269 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ចនៃអង្គការសហប្រជាជាតិ ។

នីតិវិធីប្ដឹង មានមូលដ្ឋាននៅលើឯកសារបណ្ដឹងដែលត្រូវបានទទួលពីបុគ្គល ក្រុម ឬ អង្គការដែលបានអះអាងថាជាជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស ឬ ដែលបានដឹងផ្ទាល់ដែលគួរឲ្យជឿទុកចិត្តបានអំពីការរំលោភបំពាននេះ ។ ក្រុមការងារផ្សេងគ្នាពីរ ពោលគឺ ក្រុមការងារទទួលបន្ទុកឯកសារបណ្ដឹង និងក្រុមការងារទទួលបន្ទុកស្ថានភាព ទទួលខុសត្រូវដោយរៀងៗខ្លួន ចំពោះការត្រួតពិនិត្យឯកសារបណ្ដឹង និងការជម្រាបជូនអំពីគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងដែលបានផ្ដល់ភ័ស្ដុតាងគួរឲ្យជឿទុកចិត្តបានលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដល់ក្រុមប្រឹក្សានេះ ។

ក្រុមប្រឹក្សា ត្រួតពិនិត្យរបាយការណ៍របស់ក្រុមការងារទទួលបន្ទុកស្ថានភាព ដោយមានភាពសម្ងាត់ (លុះត្រាតែក្រុមប្រឹក្សា បានសម្រេចចិត្តតាមបែបផ្សេងទៀត) និងអាចៈ

- មិនបន្តការពិចារណារបស់ខ្លួនលើស្ថានភាពមួយ នៅពេលដែលការពិចារណា ឬ សកម្មភាពបន្ថែមមិនត្រូវបានធានា ។
- ដាក់ស្ថានភាពមួយឲ្យនៅក្រោមការត្រួតពិនិត្យឡើងវិញ និងស្នើសុំឲ្យរដ្ឋដែលពាក់ព័ន្ធ ផ្ដល់ព័ត៌មានបន្ថែម នៅក្នុងរយៈពេលសមស្រប ។
- ដាក់ស្ថានភាពមួយឲ្យនៅក្រោមការត្រួតពិនិត្យឡើងវិញ និងតែងតាំងមន្ត្រីជំនាញឯករាជ្យដែលមានលក្ខណៈសម្បត្តិពេញលេញឲ្យពិនិត្យតាមដានស្ថានភាពនោះ និងធ្វើសេចក្ដីរាយការណ៍ត្រឡប់ទៅក្រុមប្រឹក្សាវិញ ឬ
- ផ្ដល់អនុសាសន៍ថា ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) គួរតែផ្ដល់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ជំនួយសម្រាប់ការកសាងសមត្ថភាព ឬ សេវា ផ្ដល់ប្រឹក្សាដល់រដ្ឋដែលពាក់ព័ន្ធ ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្ដីពី**នីតិវិធីប្ដឹង** សូមមើល**ជំពូក** VIII (**ការដាក់ជូនពិនិត្យនូវពាក្យបណ្ដឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្ធីករណ៍**) នៃ*សៀវភៅ*នេះ ។

## ឃ. យន្តការពិសេស

"**យន្តការពិសេស**" គឺជាឈ្មោះទូទៅដែលត្រូវបានផ្តល់ដល់យន្តការដែលត្រូវបានបង្កើតឡើងដោយ អតីតគណៈកម្មការ និងត្រូវបានទទួលយកដោយក្រុមប្រឹក្សា ដើម្បីពិនិត្យតាមដាន ផ្តល់ការណែនាំ និងធ្វើសេចក្តីរាយការណ៍ជាសាធារណៈលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬ ទឹកដីជាក់លាក់ (**អាណត្តិប្រចាំប្រទេស**) ឬ លើបាតុភូតចម្បងនៃការរំលោភបំពានលើសិទ្ធិមនុស្សនៅទូទាំងពិភពលោក (**អាណត្តិប្រធានបទ**) ។

ចាប់តាំងតែពីខែមិថុនាឆ្នាំ២០០៧មកក្រុមប្រឹក្សានេះ បានចាប់ផ្តើមដំណើរការមួយ ដើម្បីត្រួតពិនិត្យឡើងវិញ ធ្វើសនិទានកម្ម និងកែលម្អអាណត្តិរបស់យន្តការពិសេសនីមួយៗ ដែលក្រុមប្រឹក្សានេះទទួល ។ ក្រុមប្រឹក្សានេះ មិនបានបន្ត តែបានធ្វើវិសោធនកម្មលើអាណត្តិខ្លះ បានបង្កើតអាណត្តិថ្មី បានរៀបចំបង្កើតដំណើរការជ្រើសរើស និងតែងតាំងថ្មីសម្រាប់អ្នកមានអាណត្តិ និងបានផលិត**ក្រមសីលធម៌សម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស** (សេចក្តីសម្រេចចិត្តលេខ 5/2) ។

អ្នកមានអាណត្តិ (អ្នករាយការណ៍ពិសេស តំណាងពិសេស តំណាង មន្ត្រីជំនាញ និងសមាជិកក្រុមការងារ) បម្រើក្នុងឋានៈផ្ទាល់របស់ខ្លួន ។ សកម្មភាពរបស់ពួកគេ អាចរួមបញ្ចូលៈ

- ការទទួលបាន ការចែករំលែក និងការវិភាគលើព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្ស ។
- ការឆ្លើយតបទៅនឹងបណ្តឹងជាលក្ខណៈបុគ្គល ។
- ការសិក្សាសន្និដ្ឋាន ។
- ការបញ្ជូនសេចក្តីអំពាវនាវបន្ទាន់ ឬ លិខិតទទ្បីករណ៍ ទៅរដ្ឋាភិបាល ។
- ការទទួលរ៉ាប់រងធ្វើទស្សនកិច្ចប្រចាំប្រទេស តាមការអញ្ជើញរបស់រដ្ឋាភិបាល និងការផលិតលទ្ធផលរកឃើញ និងអនុសាសន៍ ដោយមានមូលដ្ឋាននៅលើដំណើរទស្សនកិច្ចទាំងនេះ ។
- ការផ្តល់ការណែនាំលើសហប្រតិបត្តិការបច្ចេកទេសនៅថ្នាក់ជាតិ និង
- ការចូលរួមនៅក្នុងការលើកកម្ពស់ជាទូទៅ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់ដល់អ្នកមានអាណត្តិនៃយន្តការពិសេស នូវបុគ្គលិក ជំនួយផ្នែកភ័ស្តុភារ និងការស្រាវជ្រាវ ដើម្បីគាំទ្រដល់អាណត្តិរបស់ពួកគេ ។

*i*

សម្រាប់ព័ត៌មានបន្ថែមស្តីពី**យន្តការពិសេស** សូមមើល**ជំពូក VI (យន្តការពិសេស)** នៃ*សៀវភៅ*នេះ ។

## ខ. ក្រុមការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍដ៏ទូលំទូលាយ

ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍដ៏ទូលំទូលាយ ត្រូវបានបង្កើតឡើងដោយគណៈកម្មការសិទ្ធិមនុស្ស ។[37] នៅក្នុងខែមីនា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រួតពិនិត្យឡើងវិញលើអាណត្តិរបស់សម្រាប់រយៈពេលពីរឆ្នាំ (សេចក្តីសម្រេចចិត្តលេខ 4/4) ។

ក្រុមការងារ ជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គប្រចាំឆ្នាំដែលមានរយៈពេលប្រាំថ្ងៃធ្វើការ ។ អាណត្តិរបស់ក្រុមការងារ គឺដើម្បីៈ

- ពិនិត្យតាមដាន និងត្រួតពិនិត្យឡើងវិញលើវឌ្ឍនភាពដែលត្រូវបានសម្រេចបាន នៅក្នុងការលើកកម្ពស់ និងការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ ។
- ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ និងព័ត៌មានផ្សេងទៀត ដែលត្រូវបានដាក់ជូនពិនិត្យដោយរដ្ឋ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត និងអង្គការមិនមែនរដ្ឋាភិបាល និង
- ដាក់ជូនក្រុមប្រឹក្សាពិចារណានូវរបាយការណ៍វគ្គប្រជុំពេញអង្គលើការពិគ្រោះយោបល់ជាផ្លូវការរបស់ខ្លួន ដោយដាក់បញ្ចូលការណែនាំសម្រាប់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សលើការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ និងដោយផ្តល់ជាមតិយោបល់លើកម្មវិធីដែលអាចមានស្តីពីជំនួយបច្ចេកទេស តាមការស្នើសុំរបស់ប្រទេសដែលមានការចាប់អារម្មណ៍ ។

នៅក្នុងសេចក្តីសម្រេចចិត្តដដែល ក្រុមប្រឹក្សានេះ ក៏បានបន្តជាថ្មីសម្រាប់រយៈពេលពីរឆ្នាំនូវអាណត្តិរបស់**ក្រុមការងារពិសេសកម្រិតខ្ពស់ទទួលបន្ទុកអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ** ដែលត្រូវបានបង្កើតនៅក្នុងក្របខ័ណ្ឌរបស់ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍ ។

ទិសដៅរបស់ក្រុមការងារពិសេស គឺដើម្បីផ្តល់ជំនាញចាំបាច់ដល់ក្រុមការងារ ដើម្បីជួយក្រុមការងារនេះឲ្យអាចផ្តល់អនុសាសន៍សមស្របដល់តួអង្គផ្សេងៗបាន លើបញ្ហាដែលត្រូវបានកំណត់សម្រាប់ការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍ ។ ក្រុមការងារពិសេស មានមន្ត្រីជំនាញប្រាំរូប ដែលត្រូវបានជ្រើសតាំងដោយប្រធានក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍ ដោយពិគ្រោះយោបល់ជាមួយនឹងក្រុមប្រចាំតំបន់នីមួយៗរបស់អង្គការសហប្រជាជាតិ និងសមាជិកនីមួយៗរបស់ស្ថាប័នផ្សេងទៀត ក្នុងនោះរួមមាន តំណាងមកពីស្ថាប័នពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងអភិវឌ្ឍន៍អន្តរជាតិដែលត្រូវបានកំណត់ ។ ក្រុមការងារពិសេស បានជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គប្រចាំឆ្នាំដែលមានរយៈពេលប្រាំពីរថ្ងៃធ្វើការ និងដាក់ស្នើយោបល់ទៅក្រុមការងារនេះ ។

---

[37] ចូរមើលសេចក្តីសម្រេចចិត្តលេខ 1998/72 របស់គណៈកម្មការសិទ្ធិមនុស្ស និងសេចក្តីសម្រេចលេខ 1998/269 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ។

## ច. វេទិកាសង្គម

នៅក្នុងឆ្នាំ ២០០៧ ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបន្តជាថ្មីនូវអាណត្តិរបស់**វេទិកាសង្គម** ដោយរក្សាវាជា "សេរីភាពដែលរកអ្វីប្រៀបស្មើមិនបានសម្រាប់កិច្ចសន្ទនា រវាងក្បាលម៉ាស៊ីនដឹកនាំផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន អង្គការរបស់មហាជន និងដោបញ្ជាក់អំពីសារៈសំខាន់នៃការខិតខំប្រឹងប្រែងដែលបានសម្របសម្រួលនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីលើកកម្ពស់ទំនាក់ទំនងសង្គម ដោយមានមូលដ្ឋាននៅលើគោលការណ៍យុត្តិធម៌សង្គម សមធម៌ និងសាមគ្គីភាព ក៏ដូចជា ដើម្បីដោះស្រាយវិសាលភាពសង្គម និងបញ្ហាប្រឈមនៃដំណើរការសកលភាវូបនីយកម្ម ដែលកំពុងបន្ត" (សេចក្តីសម្រេចចិត្តលេខ 6/13) ។

កិច្ចផ្តួចផ្តើមរបស់អនុគណៈកម្មការ ដែលជាវេទិកាសង្គម[38] មានប្រភពដើមជាអ្នកបង្កើតជាវេទិកាមុនវគ្គប្រជុំពេញអង្គដែលមានរយៈពេលពីរថ្ងៃស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ដែលត្រូវបានរៀបចំឡើងមុនវគ្គប្រជុំពេញអង្គប្រចាំឆ្នាំរបស់អនុគណៈកម្មការ ។ ដោយហេតុថាវេទិកាសង្គម ពីមុនជាផ្នែកមួយរបស់អនុគណៈកម្មការនោះឥឡូវនេះវេទិកានេះក្លាយជាយន្តការឯករាជ្យនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

វេទិកាសង្គម ជួបប្រជុំគ្នា រៀងរាល់ឆ្នាំសម្រាប់រយៈពេលបីថ្ងៃធ្វើការ ដើម្បីផ្តោតទៅលើបញ្ហាប្រធានបទជាក់លាក់ដែលត្រូវបានកំណត់សម្រាប់វេទិកានេះដោយក្រុមប្រឹក្សា។វេទិកាសង្គមនេះ ជួបប្រជុំគ្នាជាលើកទីមួយជាយន្តការរបស់ក្រុមប្រឹក្សានៅក្នុងខែកញ្ញា ឆ្នាំ២០០៨ និងដូចដែលត្រូវបានស្នើសុំដោយក្រុមប្រឹក្សាអ្នកមានអាណត្តិយន្តការប្រធានបទខ្លះ បានចូលរួមនៅក្នុងវេទិកានេះ ។ វេទិកាសង្គម ត្រូវបានស្នើសុំឲ្យរៀបចំសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដែលត្រូវបានដាក់ស្នើសុំយោបល់ពីស្ថាប័ន ពាក់ព័ន្ធ តាមរយៈក្រុមប្រឹក្សា និងបានផ្តោតទៅលើៈ

- បញ្ហាទាក់ទងនឹងការលុបបំបាត់ភាពក្រីក្រនៅក្នុងបរិបទសិទ្ធិមនុស្ស ។
- ការបានទទួលវិធីអនុវត្តន៍ត្រឹមត្រូវក្នុងការប្រយុទ្ធនឹងភាពក្រីក្រ ដោយពិចារណាទៅលើបទបង្ហាញរបស់មហាជនជូនវេទិកាសង្គម និង
- វិសាលភាពសង្គមនៃដំណើរការសកលភាវូបនីយកម្ម ។

វេទិកាសង្គម ត្រូវបានធ្វើជាអធិបតីដោយប្រធាន-អ្នករាយការណ៍ដែលត្រូវបានតែងតាំងដោយប្រធានក្រុមប្រឹក្សាក្នុងឆ្នាំនីមួយៗ ពីក្នុងចំណោមបេក្ខជនដែលត្រូវបានជ្រើសតាំង ដែលត្រូវបានដាក់ស្នើយោបល់ដោយក្រុមប្រចាំតំបន់ ។

*i* សម្រាប់ព័ត៌មានបន្ថែមស្តីពី**វេទិកាសង្គម** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

[38] ចូរកុំច្រឡំជាមួយនឹងវេទិកាសង្គមពិភពលោក ។

## ឆ. វេទិកាស្តីពីបញ្ហារបស់ក្រុមជនភាគតិច

**វេទិការស្តីពីបញ្ហារបស់ក្រុមជនភាគតិច**[39] បានជំនួសក្រុមការងារទទួលបន្ទុកបញ្ហារបស់ក្រុមជនភាគតិចរបស់អនុគណៈកម្មការ ។ វេទិកាស្តីពីបញ្ហារបស់ក្រុមជនភាគតិចនេះ ផ្តល់នូវវេទិកាសម្រាប់លើកកម្ពស់ការសន្ទនា និងសហប្រតិបត្តិការលើបញ្ហាដែលទាក់ទងនឹងបុគ្គលដែលជារបស់ក្រុមជនភាគតិចជាតិ ឬ ជាតិពន្ធុ សាសនា និងភាសា ដោយៈ

- ការផ្តល់វិភាគទាន និងជំនាញប្រធានបទចំពោះការងាររបស់**មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហារបស់ក្រុមជនភាគតិច** និង
- ការកំណត់ និងការវិភាគលើវិធីអនុវត្តន៍ត្រឹមត្រូវ បញ្ហាប្រឈម កាលានុវត្តភាព និងកិច្ចផ្តួចផ្តើមសម្រាប់ការអនុវត្តបន្ថែមទៀតនូវ**សេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនដែលជារបស់ក្រុមជនភាគតិចជាតិ ឬ ជាតិពន្ធុ សាសនា និងភាសា** ។

វេទិកានេះជួបប្រជុំគ្នាសម្រាប់រយៈពេលពីរថ្ងៃនៅក្នុងទីក្រុងហ្សឺណែវ រៀងរាល់ឆ្នាំសម្រាប់កិច្ចពិភាក្សាប្រធានបទ និងត្រូវបានរំពឹងថានឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់ឧត្តមស្នងការ ដើម្បីកែលម្អកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមយន្តការ ស្ថាប័ន និងទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ និងមូលនិធិ និងកម្មវិធីស្តីពីសកម្មភាពដែលទាក់ទងនឹងការលើកកម្ពស់ និងកិច្ចការពារសិទ្ធិរបស់បុគ្គលដែលជារបស់ក្រុមជនភាគតិច ក្នុងនោះរួមមាននៅថ្នាក់តំបន់ ផងដែរ ។[40]

ដោយហេតុថា ប្រធាននៃវេទិការនេះ (ដែលត្រូវបានតែងតាំងដោយប្រធានក្រុមប្រឹក្សា រៀងរាល់ឆ្នាំដោយមានមូលដ្ឋាននៅលើការប្តូរវេនប្រចាំតំបន់) ទទួលខុសត្រូវចំពោះការរៀបចំខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សារបស់វេទិកានោះ **មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហារបស់ក្រុមជនភាគតិច** នាំផ្លូវការងាររបស់វេទិកា និងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់វេទិកានេះ ។ មន្ត្រីជំនាញឯករាជ្យ ក៏ត្រូវបានស្នើសុំឲ្យដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់គេនូវអនុសាសន៍ប្រធានបទរបស់វេទិកា និងអនុសាសន៍សម្រាប់កម្មវត្ថុប្រធានបទអនាគតសម្រាប់ដាក់ជូនក្រុមប្រឹក្សា ដើម្បីពិចារណា ។

ក្រុមប្រឹក្សា គឺត្រូវតែត្រួតពិនិត្យឡើងវិញលើការងាររបស់វេទិកា បន្ទាប់ពីរយៈពេលបួនឆ្នាំ គឺថានៅក្នុងឆ្នាំ ២០១២ ។

*i*

សម្រាប់ព័ត៌មានបន្ថែមស្តីពី**វេទិកាស្តីពីបញ្ហារបស់ក្រុមជនភាគតិច** និងស្តីពី**មន្ត្រីឯករាជ្យទទួលបន្ទុកបញ្ហារបស់ក្រុមជនភាគតិច**
ចូរចូលមើលវិបសាយរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ។

---

[39] ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចចិត្តលេខ 6/15 ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

[40] នៅក្នុងវគ្គប្រជុំពេញអង្គជាលក្ខណៈសម្ពោធន៍នៅថ្ងៃទី ១៥ និងទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៨ វេទិកានេះ ត្រូវបានរំពឹងថានឹងពិចារណាលើក្រុមជនភាគតិច និងលទ្ធភាពទទួលបានការអប់រំ ។

## ជ. យន្តការមន្ត្រីជំនាញការពារសិទ្ធិរបស់ជនជាតិដើមភាគតិច

**យន្តការមន្ត្រីជំនាញ**ការពារសិទ្ធិរបស់ជនជាតិដើមភាគតិច[41] គឺជាអ្នកស្នងបន្តពីក្រុមការងារទទួលបន្ទុកជនជាតិដើមភាគតិចរបស់អតីតអនុគណៈកម្មការ ។ ផ្នែកមួយនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលជាយន្តការមន្ត្រីជំនាញ ផ្តល់ដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សនូវជំនាញប្រធានបទលើផ្នែកសិទ្ធិរបស់ជនជាតិដើមភាគតិចទៅតាមរបៀប និងទម្រង់ដែលត្រូវបានស្នើសុំដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ យន្តការមន្ត្រីជំនាញ ធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំ ជូនទៅក្រុមប្រឹក្សា ផ្តោតភាគច្រើនទៅលើការសិក្សា និងការណែនាំដែលមានមូលដ្ឋាននៅលើការស្រាវជ្រាវ និងអាច នៅក្នុងវិសាលភាពនៃការងាររបស់ខ្លួន ផ្តល់មតិយោបល់លើសំណើសុំជូនទៅក្រុមប្រឹក្សា ដើម្បីពិចារណា និងអនុម័ត ។

យន្តការមន្ត្រីជំនាញ មានមន្ត្រីជំនាញឯករាជ្យចំនួនប្រាំរូប ដែលមួយរូបៗ បម្រើសម្រាប់រយៈពេលបីឆ្នាំ ដោយអាចមានការដែលត្រូវបានបោះឆ្នោតជ្រើសតាំងឡើងវិញសម្រាប់អាណត្តិបន្ថែម ។ យន្តការមន្ត្រីជំនាញនេះ អាចជួបប្រជុំគ្នារហូតដល់រយៈប្រាំថ្ងៃក្នុងមួយឆ្នាំ ដោយរួមបញ្ចូលកិច្ចប្រជុំជាសម្ងាត់ និងជាសាធារណៈ និងមានសេរីភាពក្នុងការសម្រេចចិត្តលើវិធីសាស្ត្រការងារផ្ទាល់របស់ខ្លួន ទោះបីជាមិនអាចអនុម័តសេចក្តីសម្រេចចិត្ត ឬ សេចក្តីសម្រេចក៏ដោយ ។

**អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច** និងសមាជិកនៃ**វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច** ក៏ចូលរួម និងរួមចំណែកនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់យន្តការមន្ត្រីជំនាញនេះផងដែរ ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្តីពី**យន្តការមន្ត្រីជំនាញ** និងស្តីពី**អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ឈ. សេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព

នៅក្នុងឆ្នាំ ២០០១ សន្និសីទពិភពលោកប្រឆាំងនឹងការប្រកាន់ពូជសាសន៍ ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងភាពមិនចេះអត់ឱនផ្នែកជំនឿសាសនាដែលពាក់ព័ន្ធ ត្រូវបានរៀបចំឡើងនៅក្នុងទីក្រុងឌឺប៊ែន ប្រទេសអាព្រិចខាងត្បូង ។ **សេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព** ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទនេះ កត់ត្រាការប្តេជ្ញាចិត្តរបស់រដ្ឋ ដើម្បីធ្វើការងាររួមគ្នា សំដៅលុបបំបាត់ការប្រកាន់ពូជសាសន៍ ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងភាពមិនចេះអត់ឱនផ្នែកជំនឿសាសនាដែលពាក់

[41] ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចចិត្តលេខ 6/36 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

ព័ន្ធ ។ វាជាផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងតម្រង់ទិសសកម្មភាព ដោយផ្តល់នូវយុទ្ធវិធីទូទៅដែលមានមុខងារពិសេស សម្រាប់សម្រេចបាននូវគោលការណ៍សមភាព និងភាពមិនរើសអើង។

នៅក្នុងឆ្នាំ ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានធ្វើការសម្រេចចិត្តរៀបចំសន្និសីទត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០០៩ លើការអនុវត្តសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព ។ មហាសន្និបាតអង្គការសហប្រជាជាតិ បានស្នើសុំក្រុមប្រឹក្សាសិទ្ធិមនុស្ស ឲ្យរៀបចំព្រឹត្តិការណ៍នេះ ដោយប្រើជាប្រយោជន៍នូវយន្តការតាមដានបន្តដែលមានស្រាប់ និងកំពុងដំណើរការ[42] ដើម្បីរៀបចំផែនការពិតជាក់ស្តែង និងដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាព និងរបាយការណ៍ប្រចាំឆ្នាំស្តីពីបញ្ហានេះ ដោយចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៧ ។[43] គណៈកម្មាធិការត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សា បានសម្រេចចិត្តថា សន្និសីទត្រួតពិនិត្យឡើងវិញ នឹងត្រូវបានរៀបចំឡើងនៅក្នុងទីក្រុងហ្សឺណែវនៅក្នុងខែ មេសា ឆ្នាំ ២០០៩ ។

## ១. ក្រុមការងារអន្តររដ្ឋាភិបាល ទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព

**ក្រុមការងារអន្តររដ្ឋាភិបាល ទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព** ត្រូវបានបង្កើតឡើងដោយគណៈកម្មការសិទ្ធិមនុស្ស (សេចក្តីសម្រេចចិត្តលេខ 2002/68) ។ នៅក្នុងខែ មិថុនា ឆ្នាំ ២០០៦ ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបន្តអាណត្តិរបស់ក្រុមការងារនេះ សម្រាប់រយៈពេលបីឆ្នាំបន្ថែមទៀត (សេចក្តីសម្រេចចិត្តលេខ 1/5) ។ ក្រុមការងារអន្តររដ្ឋាភិបាល ត្រូវបានផ្តល់អាណត្តិ ដើម្បីៈ

- ផ្តល់អនុសាសន៍ ក្នុងគោលបំណងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព និង
- រៀបចំស្តង់ដាអន្តរជាតិដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក ដើម្បីពង្រឹង និងធ្វើបច្ចុប្បន្នភាពលិខិតុបករណ៍អន្តរជាតិប្រឆាំងនឹងការប្រកាន់ពូជសាសន៍ ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងការមិនចេះអត់ឱនផ្សេងៗដែលពាក់ព័ន្ធ នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ។

> *i* ដើម្បីរកបានព័ត៌មានបន្ថែមអំពី**ក្រុមការងារអន្តររដ្ឋាភិបាល** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ២. ក្រុមមន្ត្រីជំនាញឯករាជ្យល្បីល្បាញ ទទួលបន្ទុកការអនុវត្តសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព

---

[42] ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព ក្រុមមន្ត្រីជំនាញឯករាជ្យល្បីល្បាញទទួលបន្ទុកការអនុវត្តសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព និងក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច ។

[43] ចូរមើលសេចក្តីសម្រេចចិត្តលេខ 61/149 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

សន្និសីទពិភពលោក បានស្នើសុំឲ្យឧត្តមស្នងការ ធ្វើសហប្រតិបត្តិការជាមួយនឹង**មន្ត្រីជំនាញឯករាជ្យដ៏ល្បីល្បាញ** ដើម្បីតាមដានបន្តការអនុវត្តបទប្បញ្ញត្តិនៃសេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព ។[44]

នៅក្នុងឆ្នាំ ២០០៣ មន្ត្រីជំនាញឯករាជ្យដ៏ល្បីល្បាញ (មួយរូបពីក្រុមប្រចាំតំបន់នីមួយៗ) ត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅពេលនោះ លោក កូហ្វីអាណាន់ ពីក្នុងចំណោមបេក្ខជនដែលត្រូវបានស្នើឡើងដោយប្រធានគណៈកម្មការសិទ្ធិមនុស្ស បន្ទាប់ពីការពិគ្រោះយោបល់ជាមួយនឹងក្រុមប្រចាំតំបន់ ។

អាណត្តិរបស់ពួកគេ គឺត្រូវតែៈ[45]

- តាមដានការអនុវត្តបទប្បញ្ញត្តិនៃសេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព ដោយធ្វើសហប្រតិបត្តិការជាមួយនឹងឧត្តមស្នងការ និង
- ជួយដល់ឧត្តមស្នងការក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំរបស់គេដែលត្រូវបានដាក់ជូនទៅក្រុមប្រឹក្សា និងទៅមហាសន្និបាតអង្គការសហប្រជាជាតិ លើព័ត៌មាន និងមតិយោបល់ដែលត្រូវបានផ្តល់ដោយរដ្ឋ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សដែលពាក់ព័ន្ធ យន្តការពិសេស និងយន្តការរបស់ក្រុមប្រឹក្សា អង្គការអន្តរជាតិ និងប្រចាំតំបន់ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ។

*i* ដើម្បីរកបានព័ត៌មានបន្ថែមអំពី**មន្ត្រីជំនាញឯករាជ្យដ៏ល្បីល្បាញ** និងសម្រាប់ព័ត៌មានបន្ថែមស្តីពី**ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច** ចូរចូលមើល វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ៣. ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច

**ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច** គឺជាយន្តការពិសេសរបស់ក្រុមប្រឹក្សា ។ ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច ត្រូវបានបង្កើតឡើងដោយគណៈកម្មការ តាមការស្នើសុំរបស់សន្និសីទពិភពលោក ។ ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច មានមន្ត្រីជំនាញឯករាជ្យចំនួនប្រាំរូបដែលត្រូវបានតែងតាំង ដោយឈរលើមូលដ្ឋានការធ្វើជាតំណាងភូមិសាស្ត្រប្រកបដោយសមធម៌ ។ ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិចនេះ រៀបចំកិច្ចប្រជុំពេញអង្គដែលមានរយៈពេលប្រាំថ្ងៃ រៀងរាល់ឆ្នាំ និងធ្វើទស្សនកិច្ចប្រចាំប្រទេស តាមការអញ្ជើញរបស់រដ្ឋាភិបាល ដើម្បីសម្របសម្រួលឲ្យមានការស្វែងយល់ស៊ីជម្រៅលើស្ថានភាពរបស់ប្រជាជនដែលមានត្រកូលអាព្រិចនៅក្នុងតំបន់ផ្សេងៗនៅលើពិភពលោក ។ ក្រុមការងារមន្ត្រីជំនាញ

---

[44] ចូរមើលកថាខ័ណ្ឌ ១៩១ (ខ) នៃកម្មវិធីសកម្មភាព និងសេចក្តីសម្រេចចិត្តលេខ 56/266 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

[45] ចូរមើលសេចក្តីសម្រេចចិត្តលេខ 2003/30 របស់គណៈកម្មការសិទ្ធិមនុស្ស ។ ចូរមើលផងដែរនូវសេចក្តីសម្រេចចិត្តលេខ 59/177 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

ទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិចនេះ ក៏ដាក់ជូនពិនិត្យផងដែរនូវរបាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

អាណត្តិរបស់ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកប្រជាជនដែលមានត្រកូលអាព្រិច គឺត្រូវតែៈ[46]

- សិក្សាលើបញ្ហានៃការរើសអើងជាតិសាសន៍ ដែលត្រូវបានប្រឈមមុខដោយប្រជាជនដែលមានត្រកូលអាព្រិច ដែលរស់នៅក្នុងប្រទេសផ្សេង និងដើម្បីសម្រេចគោលដៅនេះ ប្រមូលព័ត៌មានដែលពាក់ព័ន្ធទាំងអស់ពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងប្រភពដែលពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន តាមរយៈការរៀបចំកិច្ចប្រជុំជាសាធារណៈ ផងដែរ ។
- ស្នើឡើងនូវវិធានការ ដើម្បីធានាឲ្យមានលទ្ធភាពប្រើប្រាស់ពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធយុត្តិធម៌ របស់ប្រជាជនដែលមានត្រកូលអាព្រិច ។
- ដាក់ជូនពិនិត្យនូវអនុសាសន៍ស្តីពីការរៀបចំ ការអនុវត្ត និងការធានាឲ្យមានការអនុវត្តតាមវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់ចោលទម្រង់ជីវប្រវត្តិនៃការប្រកាន់ពូជសាសន៍របស់ប្រជា-ជនដែលមានត្រកូលអាព្រិច ។
- រៀបចំលម្អិតផែនការរយៈពេលខ្លី មធ្យម និងវែង សម្រាប់លុបបំបាត់ចោលការរើសអើងជាតិសាសន៍ចំពោះប្រជាជនដែលមានត្រកូលអាព្រិច ។
- ធ្វើសំណើសុំស្តីពីការលុបបំបាត់ចោលការរើសអើងជាតិសាសន៍ចំពោះប្រជាជនអាព្រិច និងប្រជាជនដែលមានត្រកូលអាព្រិចនៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក និង
- ដោះស្រាយបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសុខុមាលភាពរបស់ប្រជាជនអាព្រិច និងប្រជាជនដែលមានត្រកូលអាព្រិច ដែលត្រូវបានចែងនៅក្នុងសេចក្តីប្រកាសក្រុងឌឺប៊ែន និងកម្មវិធីសកម្មភាព ។

## ៤. គណៈកម្មាធិការដែលមានគោលដៅពិសេសទទួលបន្ទុករៀបចំលម្អិតស្តង់ដាដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក

ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបង្កើត**គណៈកម្មាធិការដែលមានគោលដៅពិសេសទទួលបន្ទុករៀបចំលម្អិតស្តង់ដាដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក** នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៦ ។ គណៈកម្មាធិការដែលមានគោលដៅពិសេសទទួលបន្ទុករៀបចំលម្អិតស្តង់ដាដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមកនេះ ត្រូវបានប្រគល់អាណត្តិឲ្យបង្កើត ជាស្ថានភាពពាក់ព័ន្ធនឹងអាទិភាព និងភាពចាំបាច់ នូវស្តង់ដាដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក ជាទម្រង់អនុសញ្ញា ឬ ពិធីសារបន្ថែមមួយ ឬ ច្រើន នៃ**អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងជាតិសាសន៍** ។ ស្តង់ដាដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមកទាំងនេះ គឺត្រូវតែៈ[47]

- បំពេញចន្លោះប្រហោងដែលមានស្រាប់នៅក្នុងអនុសញ្ញានេះ និង
- ផ្តល់ស្តង់ដាធម្មនិយាមថ្មី ដែលមានគោលបំណងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការប្រកាន់ពូជសាសន៍សហសម័យ ក្នុងនោះរួមមានការញុះញង់ឲ្យមានការស្អប់ជាតិសាសន៍ និងសាសនា ផងដែរ ។

---

[46] ចូរមើលសេចក្តីសម្រេចចិត្តលេខ 2002/68 និង 2003/30 របស់គណៈកម្មការសិទ្ធិមនុស្ស ។

[47] ចូរមើលសេចក្តីសម្រេចលេខ 3/103 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសេចក្តីសម្រេចចិត្តលេខ 6/21 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ។

គណៈកម្មាធិការពិសេស ជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គប្រចាំឆ្នាំដែលមានរយៈពេល ១០ ថ្ងៃធ្វើការ ដើម្បីរៀបចំលិខិតុបករណ៍ច្បាប់ចាំបាច់ ។ គណៈកម្មាធិការពិសេស បានរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ភោធ នៅក្នុងខែ កុម្ភៈ ឆ្នាំ២០០៨ និងត្រូវបានតម្រូវឲ្យធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ទៅក្រុមប្រឹក្សាលើវឌ្ឍនភាពរបស់គណៈកម្មាធិការពិសេសនេះ ។

## ៥. គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញ ក្រុងឌឺប៊ែន និងក្រុមការងារអន្តររដ្ឋាភិបាលអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ ដើម្បីតាមដានការងាររបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន

នៅក្នុងឆ្នាំ ២០០៧ ដោយឆ្លើយតបទៅនឹងអាណត្តិដែលត្រូវបានប្រគល់ឲ្យដោយមហាសន្និបាតអង្គការសហប្រជាជាតិ[48] នោះ ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបង្កើតឡើងនូវ**គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន** ។[49] គណៈកម្មាធិការរៀបចំត្រៀមបំរុង បានរៀបចំកិច្ចប្រជុំរៀបចំចាត់ចែងនៅក្នុងខែ សីហា ឆ្នាំ ២០០៧ បន្ទាប់មកគឺ វគ្គប្រជុំពេញអង្គដ៏សំខាន់ចំនួនពីរដែលមានរយៈពេល ១០ ថ្ងៃធ្វើការនៅក្នុងខែ មេសា និងខែ តុលា ឆ្នាំ ២០០៨ ដើម្បីសម្រេចលើស្ថានភាពបែបបទពាក់ព័ន្ធទាំងអស់សម្រាប់សន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន ដូចជាៈ

- ទិសដៅរបស់សន្និសីទ ។
- រចនាសម្ព័ន្ធនៃឯកសារលទ្ធផលសន្និសីទ ។
- កម្រិតដែលសន្និសីទ នឹងត្រូវបានរៀបចំឡើង ។
- កិច្ចប្រជុំត្រៀមរៀបចំថ្នាក់តំបន់ និងកិច្ចផ្តួចផ្តើមផ្សេងទៀត ក្នុងនោះរួមមាន នៅថ្នាក់ជាតិ ផងដែរ និង
- កាលបរិច្ឆេទ និងទីកន្លែងសន្និសីទ ។

**ក្រុមការងារអន្តររដ្ឋាភិបាលអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ ដើម្បីតាមដានការងាររបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន** ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅឯវគ្គប្រជុំពេញអង្គដ៏សំខាន់លើកទីមួយរបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងនៅក្នុងខែ មេសា ឆ្នាំ ២០០៨ ។ ក្រុមការងារអន្តររដ្ឋាភិបាលអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ ដើម្បីតាមដានការងាររបស់គណៈកម្មាធិការត្រៀមរៀបចំសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន ត្រូវបានផ្តល់អាណត្តិ ដើម្បីៈ[50]

- តាមដានការងាររបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង ក្នុងនោះរួមមាន តាមរយៈការត្រួតពិនិត្យឡើងវិញលើឯកសារដែលជាការចូលរួមចំណែក និងតាមរយៈការចាប់ផ្តើមការចរចាលើសេចក្តីព្រាងឯកសារលទ្ធផល និង

---

[48] ចូរមើលសេចក្តីសម្រេចចិត្តលេខ 61/149 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

[49] ចូរមើលសេចក្តីសម្រេចចិត្តលេខ3/2របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ចូរមើលផងដែរនូវសេចក្តីសម្រេចចិត្តលេខ 6/23 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

[50] ចូរមើលសេចក្តីសម្រេចលេខ PC.2/4 ។

- ត្រួតពិនិត្យឡើងវិញលើឯកសារដែលជាការរួមចំណែក និងរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលមាននៅពេលនោះ ទៅគណៈកម្មាធិការរៀបចំត្រៀមបម្រុង ។

> **i** ដើម្បីរកបានព័ត៌មានបន្ថែមទៀតស្តីពី**គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន និងក្រុមការងារអន្តររដ្ឋាភិបាលអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

# វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស និងអាណត្តិ និងយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## ការរៀបចំ និងការអនុវត្តសម្រាប់ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

*"...ការចូលរួម និងការពិគ្រោះយោបល់ជាមួយនឹងអ្នកសង្កេតការណ៍ ក្នុងនោះរួមមាន រដ្ឋដែលមិនមែនជាសមាជិករបស់ក្រុមប្រឹក្សា ទីភ្នាក់ងារជំនាញ អង្គការអន្តររដ្ឋាភិបាល និងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្សផ្សេងទៀត ក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាល ត្រូវតែមានមូលដ្ឋាននៅលើការរៀបចំ ក្នុងនោះរួមមានសេចក្តីសម្រេចចិត្តលេខ 1996/31 ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៩៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចផងដែរ និងការអនុវត្តដែលត្រូវបានពិនិត្យសង្កេតដោយគណៈកម្មការសិទ្ធិមនុស្ស ទន្ទឹមនឹងនេះធានាឲ្យមានការរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុតរបស់អង្គភាពទាំងនេះ" ។*[51]

នៅក្នុងសេចក្តីសម្រេចចិត្តលេខ 60/251 មហាសន្និបាតអង្គការសហប្រជាជាតិ ទទួលការពិតអំពីតួនាទីដ៏សំខាន់ដែលត្រូវបានបំពេញដោយអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀតជាលក្ខណៈជាតិ តំបន់ និងអន្តរជាតិ នៅក្នុងការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្ស ។ សេចក្តីសម្រេចចិត្តនេះ ក៏ចែងផងដែរថា ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស នឹងៈ

- មានមូលដ្ឋាននៅលើការរៀបចំ និងការអនុវត្ត ដែលត្រូវបានពិនិត្យសង្កេតដោយគណៈកម្មការ (ក្នុងនោះរួមមាន**សេចក្តីសម្រេចចិត្តលេខ 1996/31** របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ផងដែរ) និង
- ធានាឲ្យមានការរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុតរបស់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍ផ្សេងទៀត ។

ការរៀបចំ និងការអនុវត្តនៃការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានពិនិត្យសង្កេតដោយគណៈកម្មការសិទ្ធិមនុស្ស ត្រូវបានផ្ទេរដោយជោគជ័យទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ដោយស្របតាម

[51] ចូរមើលសេចក្តីសម្រេចចិត្តលេខ 60/251 របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចចិត្តលេខ 5/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សគ្រប់ឧបសម្ព័ន្ធ ។

កាតព្វកិច្ចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងការធានាឲ្យមាន "ការរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុត" របស់អ្នកសង្កេតការណ៍ ការអនុវត្ត និងការរៀបចំទាំងនេះ បន្តអភិវឌ្ឍ និងវិវត្ត ។

## អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ដែលចូលរួមក្នុងឋានៈជាអ្នកសង្កេតការ-ណ៍នៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

*តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល មានសារៈសំខាន់ជាសារវន្តចំពោះការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្សទាំងអស់នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ។ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងអត្ថិភាពរយៈពេលពីរឆ្នាំដំបូងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានជាកត្តាសំខាន់សម្រាប់បង្កើនទំនុកចិត្តរបស់អង្គការសហប្រជាជាតិ ។ អង្គការមិនមែនរដ្ឋាភិបាល បានរួមចំណែកដោយមានសារៈសំខាន់ដល់ការកសាងស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយមានធនធានបញ្ចូលដ៏មានតម្លៃ និងមានសារៈសំខាន់ជាសារវន្ត ក៏ដូចជានៅក្នុងកិច្ចពិភាក្សាវែកញែកដ៏សំខាន់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ទន្ទឹមនឹងនេះពិចារណាទៅលើចំណុចរបៀបវារៈទាំងអស់របស់ក្រុមប្រឹក្សានេះ ។*

*មួយវិញទៀត ការងារបំពេញបន្ថែមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យសិទ្ធិមនុស្ស ត្រូវបានដឹងថា កាន់តែផ្លាស់ប្តូរពីគោលនយោបាយ "និយាយថានរណាម្នាក់មានអាកប្បកិរិយាមិនល្អ" ជាប្រពៃណីទៅការចូលរួមជាលក្ខណៈសហប្រតិបត្តិការកាន់តែខ្លាំងឡើងជាមួយនឹងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ។ ការចូលរួមប្រកបដោយការទទួលខុសត្រូវបែបនេះ គួរតែត្រូវបានចាត់ទុកជាគោលបំណងកែលម្អស្ថានភាពសិទ្ធិមនុស្សនៅនឹងកន្លែង ។*

*ហេតុដូច្នេះ ការចូលរួម និងធនធានបញ្ចូលរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសារៈសំខាន់ជាសារវន្ត ជាពិសេស ដោយសារឥឡូវនេះ ក្រុមប្រឹក្សានេះ ជួបប្រជុំគ្នាកាន់តែញឹកញាប់ និងដោយពិចារណាថា យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល កំពុងតែប្រតិបត្តិការ ។ ដោយសង្ខេបទៅ បញ្ហាប្រឈមសំខាន់បំផុតដែលក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល ប្រឈមមុខ គឺត្រូវតែផ្លាស់ប្តូរពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការងាររបស់ក្រុមប្រឹក្សា ទៅភាពជាដៃគូពិតប្រាកដ រវាង រដ្ឋជាសមាជិក និងសង្គមស៊ីវិល ។*

***ឯកអគ្គរដ្ឋទូត លូអ៊ីសអាល់ហ្វងសូដឺអាល់បា របស់ប្រទេសម៉ិកស៊ិក***
***ដែលជាប្រធានដំបូងនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (ពីឆ្នាំ ២០០៦-២០០៧)***

អង្គការមិនមែនរដ្ឋាភិបាល មានការចូលរួមក្នុងកម្រិតមួយនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលត្រូវបានទទួលបានពីគណៈកម្មការ ដែលមានលក្ខណៈកម្រនៅក្នុងប្រព័ន្ធសហប្រជាជាតិ ។ បន្ទាប់មកទៀត ក្នុងឋានៈជាគណៈអន្តររដ្ឋាភិបាល ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានធ្វើឲ្យមានខ្លឹមសារខ្លាំងដោយចំណេះដឹង និង

ជំនាញ តួនាទីធ្វើជាសាក្សី និងភាពពាក់ព័ន្ធស្រទាប់មហាជន ដែលអង្គការមិនមែនរដ្ឋាភិបាល នាំយកមកជួយការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ។

ចាប់តាំងតែពីវគ្គប្រជុំពេញអង្គលើកទីមួយនៅក្នុងខែមិថុនា ឆ្នាំ២០០៦ មក អង្គការមិនមែនរដ្ឋាភិបាល មានការចូលរួមក្នុងកម្រិតមួយដែលមានខ្លឹមសារពេញលេញ និងបរិយាប័ន្ន នៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ នៅក្នុងវគ្គប្រជុំពេញអង្គសាមញ្ញលើកទីប្រាំពីរនៅក្នុងខែ មីនា ឆ្នាំ ២០០៨ អង្គការមិនមែនរដ្ឋាភិបាលចំនួន ១៨០ ត្រូវបានតំណាងដោយបុគ្គលចំនួនសរុប ១.១១៦ នាក់ ។ នៅក្នុងវគ្គប្រជុំពេញអង្គដូចគ្នានេះ អង្គការមិនមែនរដ្ឋាភិបាល បានដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរចំនួន ៩៨ បានអានសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ចំនួន ២២៤ ដង និងបានធ្វើជាម្ចាស់ផ្ទះឲ្យព្រឹត្តិការណ៍ស្រដៀងគ្នានេះចំនួន ៦៩ លើក ។ ប្រធាន និងលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស បានព្យាយាមប្រើប្រាស់ជាមូលដ្ឋានបន្តនូវការអនុវត្ត និងការរៀបចំ ដែលត្រូវបានសង្កេតការណ៍ដោយគណៈកម្មការ ក៏ដូចជា វិធីអនុវត្តន៍ត្រឹមត្រូវទន្ទឹមនឹងនេះពិចារណាថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ជួបប្រជុំគ្នាជាបន្តបន្ទាប់នៅក្នុងវេទិកាមួយចំនួន ពេញមួយឆ្នាំ ។

តែ**អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)** ប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ វា ជាបុព្វសិទ្ធិរបស់គេក្នុងការសម្រេចចិត្តថានរណា នឹងក្លាយជាតំណាងរបស់គេ ។

កាលណាត្រូវបានអនុញ្ញាតឲ្យធ្វើជាអ្នកសង្កេតការណ៍ភ្លាម អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ទទួលបានបុព្វសិទ្ធិ និងការរៀបចំមួយចំនួននៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ គេ អាចៈ

- ដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស មុនវគ្គប្រជុំពេញអង្គណាមួយ ។
- ធ្វើបទអន្តរាគមន៍ដោយផ្ទាល់មាត់ នៅក្នុងអំឡុងចំណុចសំខាន់ៗទាំងអស់នៃរបៀបវារៈរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។
- ចូលរួមនៅក្នុងកិច្ចពិភាក្សាវែកញែក កិច្ចសន្ទនាជាលក្ខណៈទំនាក់ទំនងទៅវិញទៅមក និងកិច្ចពិភាក្សាជាក្រុម និង
- រៀបចំ "ព្រឹត្តិការណ៍ស្រដៀងគ្នា" ស្តីពីបញ្ហាពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ក៏មានការទទួលខុសត្រូវផងដែរចំពោះការអនុលោមតាមជានិច្ចកាលទៅនឹងគោលការណ៍ដែលគ្រប់គ្រងការបង្កើតឡើង និងប្រភេទនៃទំនាក់ទំនងពិគ្រោះយោបល់នេះ ។ ដោយឡែក សេចក្តីសម្រេចចិត្តលេខ 1996/31 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ចែងថា អង្គការមិនមែនរដ្ឋាភិបាលមួយ

អាចត្រូវបានបញ្ឈប់ជាបណ្ដោះអាសន្ន ឬ ដកចេញមិនឲ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិ ឬ ឲ្យគេដកចេញនូវឋានៈពិគ្រោះយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលនោះ ក្នុងករណីដែល ក្នុងចំណោមកត្តាផ្សេងទៀត អង្គការមិនមែនរដ្ឋាភិបាលនោះ បំពានជាក់ស្ដែងលើឋានៈរបស់ខ្លួន ដោយចូលរួមនៅក្នុងគំរូសកម្មភាព ដែលផ្ទុយទៅនឹងគោលបំណង និងគោលការណ៍នៃ**ធម្មនុញ្ញអង្គការសហប្រជាជាតិ** ។

## ការអនុញ្ញាត

តំណាងទាំងឡាយរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) គួរតែស្វែងរកការអនុញ្ញាតសម្រាប់វគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលគេ មានបំណងប្រាថ្នាចង់ចូលរួម ។

លិខិតដែលស្នើសុំការអនុញ្ញាត គួរតែៈ

- ត្រូវបានដាក់ជូនពិនិត្យ ដោយមានក្បាលសំបុត្រផ្លូវការរបស់អង្គការ ។
- លើកឡើងដោយច្បាស់លាស់នូវឈ្មោះ និងរយៈពេលនៃវគ្គប្រជុំពេញអង្គដែលអង្គការ មានបំណងប្រាថ្នាចង់ចូលរួម ។
- ត្រូវបានចុះហត្ថលេខាដោយប្រធាន ឬ តំណាងពេញសិទ្ធិរបស់អង្គការនៅក្នុងទីក្រុងហ្ស៊ឺណែវ និង
- បង្ហាញអំពីឈ្មោះរបស់មនុស្សម្នាក់ (ឬ ច្រើននាក់) ដែលនឹងធ្វើជាតំណាងឲ្យអង្គការនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ចូរកត់សម្គាល់ថា ឈ្មោះរបស់មនុស្ស ត្រូវតែសរសេរដោយចំៗ ដូចឈ្មោះ សរសេរនៅក្នុងឯកសារអត្តសញ្ញាណ និងនាមត្រកូល គួរតែសរសេរជាអក្សរធំ ។

*i*

ដើម្បីទទួលបានការអនុញ្ញាត អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) គួរតែបញ្ជូនលិខិតតាមទូរសារ ដោយចូលចិត្តជាងនោះ គឺមុនពេលវគ្គប្រជុំពេញអង្គណាមួយ ដោយស្នើសុំការអនុញ្ញាតទៅកាន់ៈ
**ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ១១**

## សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ

នៅមុនពេលវគ្គប្រជុំពេញអង្គណាមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចដាក់ជូនពិនិត្យទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយឡែកពីគ្នា ឬ រួមជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត នូវសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ សេចក្ដីថ្លែងការណ៍ទាំងនេះក៏ត្រូវតែស្ដីពីអំពីកម្មវត្ថុផងដែរដែលក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលនោះមានសមត្ថភាពពិសេស។ កាលណាត្រូវបានទទួល និងដំណើរការដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្សភ្លាម សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់អង្គការមិនមែនរដ្ឋាភិបាលនោះ ក្លាយជាផ្នែកមួយនៃកម្រងឯកសារផ្លូវការនៃវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ។

ចូរកត់សម្គាល់ថាៈ

- អង្គការមិនមែនរដ្ឋាភិបាល ក្នុង**ឋានៈពិគ្រោះយោបល់ទូទៅជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)** អាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលមិនលើសពី ២.០០០ ពាក្យ និង
- អង្គការមិនមែនរដ្ឋាភិបាល ក្នុង**ឋានៈពិគ្រោះយោបល់ពិសេសជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)** ឬ នៅក្នុង**បញ្ជី** អាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលមិនលើសពី ១.៥០០ ពាក្យ ។

*i*

អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានជំរុញលើកទឹកចិត្តឲ្យមើល**ឯកសារផ្តល់ព័ត៌មានទូទៅ** ដែលត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (**OHCHR**) ។

**សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ** គួរតែត្រូវបានដាក់ជូនពិនិត្យទៅ**លេខាធិការដ្ឋាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** តាមរយៈ **hrcngo@ohchr.org** ។

## សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចធ្វើបទអន្តរាគមន៍ដោយផ្ទាល់មាត់នៅក្នុងអំឡុងចំណុចរបៀបវារៈសំខាន់ៗទាំងអស់ ទាំងនៅក្នុងកិច្ចពិភាក្សាវែកញែកទូទៅ និងកិច្ចសន្ទនាជាលក្ខណៈទំនាក់ទំនងទៅវិញទៅមកនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ស្ថានភាពបែបបទសម្រាប់បទអន្តរាគមន៍ដោយផ្ទាល់មាត់របស់អង្គការមិនមែនរដ្ឋាភិបាល ដែលបន្តវិវត្ត ដោយពិចារណាថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស ជួបប្រជុំគ្នាជាបន្តបន្ទាប់ពេញមួយឆ្នាំ អាចត្រូវបានរកឃើញនៅក្នុង**ប្រព័ន្ធកុំព្យូទ័រ (អ៊ិក្សត្រាណិត)** របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខាងក្រោមគេហទំព័រព័ត៌មានទំនាក់ទំនងអង្គការមិនមែនរដ្ឋាភិបាល ។

តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងប្រាថ្នាចង់ធ្វើបទអន្តរាគមន៍ដោយផ្ទាល់មាត់ គួរតែចុះឈ្មោះដោយផ្ទាល់នៅឯផ្នែក "បញ្ជីវាគ្មិន" នៅក្នុងបន្ទប់ប្រជុំ (ប្រជុំពេញអង្គ) ។ ទម្រង់ចុះឈ្មោះសម្រាប់សេចក្តីថ្លែងការណ៍ដោយឡែក និងរួម អាចត្រូវបានផ្ទេរចេញពី**វិបសាយ**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងគួរតែត្រូវបាននាំយកមកដោយផ្ទាល់ទៅផ្នែកនោះ នៅពេលចុះឈ្មោះ ។

**សូមកត់សម្គាល់ថា អង្គការមិនមែនរដ្ឋាភិបាល មិនត្រូវបានអនុញ្ញាតឲ្យចែកចាយឯកសារ កូនសៀវភៅផ្តល់ព័ត៌មាន ឬ សម្ភារៈឯកសារណាមួយផ្សេងទៀតនៅក្នុងបន្ទប់ប្រជុំពេញអង្គឡើយ ។** ទោះជាយ៉ាងណាក៏ដោយ ច្បាប់ចម្លងនៃសេចក្តីថ្លែងការជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់របស់អង្គការមិនមែនរដ្ឋាភិបាលដែលបានបង្ហាញជូន អាចត្រូវបានដាក់ទុកនៅលើតុដែលបានកំណត់នៅផ្នែកខាងក្រោយនៃបន្ទប់ប្រជុំពេញអង្គ ។ កម្រងឯកសារផ្សេងទៀតទាំងអស់របស់អង្គការមិនមែនរដ្ឋាភិបាល អាចត្រូវបានដាក់ទុកនៅលើតុសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលបានកំណត់នៅខាងក្រៅបន្ទប់ប្រជុំពេញអង្គ ។

## កិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សភ្លាម អាចរៀបចំព្រឹត្តិការណ៍ជាសាធារណៈដែលមានភាពពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ព្រឹត្តិការណ៍ទាំងនេះត្រូវបានគេដឹងថាជា"កិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ" និងប្រព្រឹត្តទៅនៅក្រៅវគ្គប្រជុំពេញអង្គ ដោយតាមធម្មតា នៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ។

តាមធម្មតា ដោយបញ្ចូលគ្នានូវការធ្វើបទបង្ហាញជាក្រុមជាមួយនឹងការពិភាក្សាជាចំហ កិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ ផ្តល់ដល់អង្គការមិនមែនរដ្ឋាភិបាលនូវពេលវេលាសម្រាប់ចែករំលែកបទពិសោធន៍របស់គេ និងចូលរួមនៅក្នុងការសន្ទនាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត រដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត (ក្នុងនោះរួមមាន អ្នកមានអាណត្តិនៃយន្តការពិសេស ផងដែរ) លើបញ្ហាសិទ្ធិមនុស្ស និងស្ថានភាពនៃភាពពាក់ព័ន្ធ និងសារៈសំខាន់សម្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

បន្ទប់ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់ការរៀបចំកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ និងការកក់បន្ទប់ ត្រូវបានដំណើរការដោយ "អ្នកមកមុន ទទួលបានមុន" ។ អង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងប្រាថ្នាចង់សហការឧបត្ថម្ភកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ គួរតែបំពេញ "ទម្រង់សហការឧបត្ថម្ភ" ។[52]

អង្គការមិនមែនរដ្ឋាភិបាលដែលរៀបចំកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ អាចអញ្ជើញ អ្នកដែលមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ចូលរួមនៅក្នុងកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ ។ បញ្ជីឈ្មោះពេញលេញនៃអ្នកដែលត្រូវបានអញ្ជើញ ត្រូវតែបានផ្តល់ជូនទៅលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងការិយាល័យសន្តិសុខប្រិហ្គនីក្នុងរយៈពេល ៤៨ ម៉ោងមុនកិច្ចប្រជុំនេះ ដើម្បីឲ្យអ្នកដែលត្រូវបានអញ្ជើញ ត្រូវបានផ្តល់ការអនុញ្ញាត ។ អ្នកដែលត្រូវបានអញ្ជើញនឹងត្រូវបានចេញលិខិតអនុញ្ញាតសម្រាប់តែកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយប៉ុណ្ណោះ ។

អង្គការមិនមែនរដ្ឋាភិបាលដែលរៀបចំកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ ទទួលខុសត្រូវចំពោះខ្លឹមសាររបស់កិច្ចប្រជុំនេះ និងការអនុវត្តរបស់អ្នកចូលរួមនៅឯកិច្ចប្រជុំ ។ សូមកត់សម្គាល់ផងដែរថាៈ

- លេខាធិការដ្ឋាន មិនផ្តល់សេវាបកប្រែផ្ទាល់មាត់សម្រាប់កិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយទេ ។ អង្គការមិនមែនរដ្ឋាភិបាល អាចនាំយកអ្នកបកប្រែផ្ទាល់មាត់ផ្ទាល់របស់គេមក ប្រសិនបើគេមានបំណងប្រាថ្នាចង់បាន និងគួរតែផ្តល់ព័ត៌មានជូនទៅលេខាធិការដ្ឋានឲ្យស្របទៅតាមនោះ ឲ្យបានមុនពេលប្រជុំ និង
- ការប្រើប្រាស់ម៉ាស៊ីនថតរូប/ម៉ាស៊ីនថតវីដេអូនៅក្នុងកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ មិនត្រូវបានជំរុញលើកទឹកចិត្តទេ វៀរលែងតែអ្នកសារព័ត៌មាន និងអ្នកថតរូបដែលត្រូវបានអនុញ្ញាតដោយត្រឹមត្រូវជាមួយនឹងការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ (UNOG) ។

[52] ត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

> **i**
>
> ការកក់បន្ទប់សម្រាប់ការរៀបចំកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ គួរតែត្រូវបានបញ្ជូនតាមទូរសារទៅ:
>
> **ទូរសារ: +៤១ (0) ២២ ៩១៧ ៩០ ១១**
>
> សម្រាប់ព័ត៌មានបន្ថែមស្ដីពី**លិខិតអនុញ្ញាត សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់ និងកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ** ចូរចូលមើលគេហទំព័រព័ត៌មានទំនាក់ទំនងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុង**ប្រព័ន្ធកុំព្យូទ័រ (អ៊ិក្សត្រាណិត)** របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

## ការចូលរួមនៅក្នុង និងការចូលរួមជាមួយនឹងអាណត្តិ និងយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### ក. យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

> **i**
>
> សម្រាប់ព័ត៌មានពិស្ដារស្ដីពីវិធីប្រើប្រាស់ និងចូលរួមជាមួយនឹង**យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** សូមមើល**ជំពូក VII (យន្តការត្រួតពិនិត្យឡើងវិញតាម ដំណាក់កាលជាសកល)** នៃ*សៀវភៅ*នេះ ។

### ខ. គណៈកម្មាធិការផ្ដល់ប្រឹក្សានៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

#### *ការចូលរួម និងការរួមចំណែកក្នុងការងាររបស់គណៈកម្មាធិការផ្ដល់ប្រឹក្សា*

អ្នកមុនរបស់គណៈកម្មាធិការផ្ដល់ប្រឹក្សា ដែលជាអតីតអនុគណៈកម្មការ បានទទួលប្រយោជន៍ជាច្រើនពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ។ នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ នៅពេលដែលគណៈកម្មាធិការផ្ដល់ប្រឹក្សា នៅកំពុងតែរៀបចំបង្កើតវិធាននីតិវិធី និងវិធីសាស្ត្រការងាររបស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានជំរុញគណៈកម្មាធិការផ្ដល់ប្រឹក្សានេះ នៅក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ដើម្បីបង្កើតឲ្យមានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ។ រដ្ឋទាំងឡាយ ក៏ត្រូវបានជំរុញលើកទឹកចិត្តផងដែរឲ្យពិគ្រោះយោបល់ជាមួយនឹងតួអង្គសង្គមស៊ីវិល មុនពេលការជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងទៅគណៈកម្មាធិការផ្ដល់ប្រឹក្សា ។

អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានផ្ដល់សិទ្ធិឲ្យចូលរួមនៅក្នុងការងាររបស់គណៈកម្មាធិការ ផ្ដល់ប្រឹក្សា ដោយមានមូលដ្ឋាននៅលើការរៀបចំ និងការអនុវត្ត ដែលត្រូវបានសង្កេតការណ៍ដោយគណៈកម្មការសិទ្ធិមនុស្ស និងក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងនោះរួមមាន សេចក្ដីសម្រេចចិត្តលេខ 1996/31 របស់ក្រុមប្រឹក្សា

សេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ទន្ទឹមនឹងនេះជានាឲ្យមានការរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុតរបស់អង្គការមិនមែនរដ្ឋាភិបាល ។

អង្គការមិនមែនរដ្ឋាភិបាលដែលចាប់អារម្មណ៍ចង់ចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការផ្តល់ប្រឹក្សា គួរតែទាក់ទងនឹងលេខាធិការដ្ឋាន ។

i

សម្រាប់ព័ត៌មានបន្ថែមស្តីពីវិធីរួមចំណែកនៅក្នុងការងាររបស់**គណៈកម្មាធិការផ្តល់ប្រឹក្សា** សូមទាក់ទង:
**HRCAdvisoryCommittee@ohchr.org**

## គ. នីតិវិធីប្តឹង

i

សម្រាប់ព័ត៌មានពិស្តារស្តីពីវិធីរួមចំណែកព័ត៌មានសម្រាប់**នីតិវិធីប្តឹង** សូមមើល**ជំពូក VIII (ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្បីករណ៍)** នៃ *សៀវភៅ*នេះ និងចូរទាក់ទង **CP@ohchr.org** ។

## ឃ. យន្តការពិសេស

i

សម្រាប់ព័ត៌មានពិស្តារស្តីពីវិធីប្រើប្រាស់ និងចូលរួមជាមួយនឹង**យន្តការពិសេស** ចូរមើល**ជំពូក VI (យន្តការពិសេស)** នៃ *សៀវភៅ*នេះ ។

## ង. ក្រុមការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍដ៏ទូលំទូលាយ
### *ការចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ*

ដោយសារក្រុមការងារ មានលក្ខណៈបើកចំហ អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចចូលរួមនៅក្នុងផ្នែកជាសាធារណៈនៃវគ្គប្រជុំពេញអង្គរបស់ក្រុមការងារនេះ ។

អង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមក្នុងកិច្ចប្រជុំរបស់**ក្រុមការងារពិសេសកម្រិតខ្ពស់ទទួលបន្ទុកអនុវត្តន៍សិទ្ធិទទួលបានការអភិវឌ្ឍ** មានឱកាសធ្វើសេចក្តីថ្លែងការណ៍បើក ។

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ដែលបានចាប់អារម្មណ៍ចង់ចូលរួមនៅក្នុង**ក្រុមការងារ** ឬ **ក្រុមការងារពិសេសកម្រិតខ្ពស់** គួរតែបំពេញ**ទម្រង់ចុះឈ្មោះ** (ដែលត្រូវបានរៀបចំឲ្យមានពីគេហទំព័រដែលបានបូជាវិភាជន៍នៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)) និងផ្ញើវារួមជាមួយនឹងសំណើសុំការអនុញ្ញាតដែលត្រូវបានចុះហត្ថលេខារបស់ខ្លួនទៅកាន់:

**មន្ត្រីទទួលបន្ទុកផ្តល់ការអនុញ្ញាត**

ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០១០

ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩៨២៩

## ***ការរួមចំណែកនៅក្នុងការងាររបស់ក្រុមការងារ***

កិច្ចការសំខាន់បំផុតមួយក្នុងចំណោមកិច្ចការសំខាន់បំផុតជាច្រើន ដែលត្រូវបានប្រគល់ជូនទៅក្រុមការងារ គឺត្រូវត្រួតពិនិត្យឡើងវិញលើរបាយការណ៍ និងព័ត៌មានណាមួយផ្សេងទៀតដែលត្រូវបានដាក់ជូនពិនិត្យដោយអង្គការមិនមែនរដ្ឋាភិបាល ស្តីពីទំនាក់ទំនង រវាងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល និងសិទ្ធិទទួលបានការអភិវឌ្ឍ ។ ក្រុមការងារ ទទួលស្វាគមន៍ការចូលរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ។ នេះគឺត្រូវបានសម្របសម្រួលមួយផ្នែកតាមរយៈការងាររបស់ក្រុមការងារពិសេសកម្រិតខ្ពស់ ដែលវគ្គប្រជុំពេញអង្គជាសាធារណៈរបស់ក្រុមការងារពិសេសកម្រិតខ្ពស់នេះ បើកចំហឲ្យមានការចូលរួមរបស់តួអង្គសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដ៏ច្រើនសន្ធឹកសន្ធាប់ ។

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ត្រូវបានជំរុញលើកទឹកចិត្តឲ្យដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ទាំងឡាយ និងចូលរួមជាមួយនឹងក្រុមការងារពិសេសលើសកម្មភាពរបស់ក្រុមការងារពិសេសនេះ ផែនការការងារ និងការអនុវត្តអនុសាសន៍របស់ក្រុមការងារ ។

## ច. វេទិកាសង្គម

## ***ការចូលរួមនៅក្នុងកិច្ចប្រជុំនៃវេទិកាសង្គម***

វេទិកាសង្គម បើកចំហឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធដែលបានចាប់អារម្មណ៍ ក្នុងនោះរួមមានៈ[53]

- អង្គការអន្តររដ្ឋាភិបាល ។
- ផ្នែកខុសៗគ្នានៃប្រព័ន្ធសហប្រជាជាតិ ជាពិសេស អ្នកមានអាណត្តិនៃយន្តការប្រធានបទ និងយន្តការនៃក្បាលម៉ាស៊ីនដឹកនាំផ្នែកសិទ្ធិមនុស្ស ។
- គណៈកម្មការសេដ្ឋកិច្ចតំបន់ ។

[53] ចូរមើលសេចក្តីសម្រេចចិត្តលេខ 6/13 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

- ទីភ្នាក់ងារ និងអង្គការជំនាញ ជាពិសេស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការពាណិជ្ជកម្មពិភពលោក ។
- តំណាងដែលត្រូវបានជ្រើសតាំងដោយស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និង
- អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ជាពិសេស តួអង្គដែលលេចឡើងថ្មីៗ ដូចជា ក្រុមតូច និងសមាគមជនបទ និងទីក្រុងពីក្រុមប្រទេសជឿនលឿន និងក្រុមប្រទេសក្រីក្រ ក្រុមប្រឆាំងនឹងភាពក្រីក្រ សមាគមអ្នកស្រែចំការ និងកសិករ និងសមាគមជាតិ និងអន្តរជាតិរបស់គេ អង្គការស្ម័គ្រចិត្ត សមាគមយុវជន អង្គការសហគមន៍ សហជីព និងសមាគមពលករ ក៏ដូចជា តំណាងវិស័យឯកជន ធនាគារតំបន់ និងគ្រឹះស្ថានហិរញ្ញវត្ថុ និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិផ្សេងទៀត ។

ការចូលរួមរបស់តួអង្គសង្គមស៊ីវិលនៅក្នុងវេទិកាសង្គម ត្រូវមានមូលដ្ឋាននៅលើការរៀបចំ ក្នុងនោះរួមមាន សេចក្តីសម្រេចចិត្តលេខ 1996/31 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងការអនុវត្តដែលត្រូវបានសង្កេតការណ៍ដោយគណៈកម្មការសិទ្ធិមនុស្ស ទន្ទឹមនឹងនេះធានាឲ្យមានការរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុតរបស់អង្គភាពដែលត្រូវបានរៀបរាប់ខាងលើ ។ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏បានស្នើសុំឲ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្វែងរកមធ្យោបាយប្រកបដោយប្រសិទ្ធភាពក្នុងការធានាឲ្យមានការពិគ្រោះយោបល់ និងការចូលរួមដែលអាចមានទូលំទូលាយបំផុតរបស់តំណាងមកពីគ្រប់តំបន់ ជាពិសេស តំណាងមកពីប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងវេទិកាសង្គម ក្នុងនោះរួមមាន ដោយបង្កើតឲ្យមានភាពជាដៃគូជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងអង្គការអន្តរជាតិ ផងដែរ ។[54]

i

តួអង្គសង្គមស៊ីវិល ដែលបានចាប់អារម្មណ៍ចង់ចូលរួមនៅក្នុង**វេទិកាសង្គម** គួរតែទាក់ទងនឹងលេខាធិការដ្ឋានរបស់វេទិកាសង្គម ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនឹង:
**socialforum@ohchr.org**

## ឆ. វេទិកាបញ្ហាក្រុមជនភាគតិច

### *ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់វេទិកាបញ្ហាក្រុមជនភាគតិច*

វេទិការបញ្ហាក្រុមជនភាគតិច គឺបើកចំហឲ្យមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលគោលដៅ និងគោលបំណងរបស់គេ គឺអនុលោមទៅតាមស្មារតី គោលបំណង និងគោលការ

[54] ចូរមើលសេចក្តីសម្រេចចិត្តលេខ 6/13 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ។

ណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ការចូលរួម ក៏ត្រូវបានបើកចំហដល់តួអង្គសង្គមស៊ីវិលផ្សេងទៀត ក្នុងនោះរួមមាន អ្នកសិក្សាជាន់ខ្ពស់ និងមន្ត្រីជំនាញខាងបញ្ហាក្រុមជនភាគតិចផងដែរ ។

i

តួអង្គសង្គមស៊ីវិលដែលបានចាប់អារម្មណ៍ចង់ចូលរួម ឬ រួមចំណែកក្នុងការងាររបស់**វេទិកាបញ្ហាក្រុមជនភាគតិច** គួរតែទាក់ទងនឹងលេខាធិការដ្ឋានរបស់វេទិកាបញ្ហាក្រុមជនភាគតិចនេះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនឹង: **minorityforum@ohchr.org** ។

### ***ការជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងជាប្រធានវេទិកា***

ដោយអនុលោមតាមសេចក្ដីសម្រេចចិត្តលេខ 5/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអ្នកសង្កេតការណ៍ផ្សេងទៀតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ព្រមជាមួយនឹងរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ក៏អាចស្នើឡើងផងដែរនូវបេក្ខភាពសម្រាប់ការតែងតាំងជាប្រធានវេទិកាបញ្ហាក្រុមជនភាគតិច ។

## ជ. យន្តការមន្ត្រីជំនាញទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិច

### ***ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់យន្តការមន្ត្រីជំនាញ***

កិច្ចប្រជុំប្រចាំឆ្នាំរបស់យន្តការមន្ត្រីជំនាញ គឺបើកចំហឲ្យមានការចូលរួមរបស់តួអង្គសង្គមស៊ីវិល ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការជនជាតិដើមភាគតិច ។

### ***មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច***

តួអង្គសង្គមស៊ីវិល ក៏គួរតែយល់ដឹងផងដែរនូវ**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច** ដែលត្រូវបានបង្កើតឡើង ដើម្បីជួយដល់តំណាងរបស់សហគមន៍ និងអង្គការជនជាតិដើមភាគតិចខាងផ្នែកហិរញ្ញវត្ថុ ដើម្បីចូលរួមនៅក្នុងយន្តការមន្ត្រីជំនាញ និងវេទិកាអចិន្ត្រៃយ៍ស្ដីពីបញ្ហាជនជាតិដើមភាគតិច ។

i

តួអង្គសង្គមស៊ីវិលដែលបានចាប់អារម្មណ៍ចង់ចូលរួម ឬ រួមចំណែកនៅក្នុងការងាររបស់យន្តការមន្ត្រីជំនាញ គួរតែទាក់ទងនឹងលេខាធិការដ្ឋានរបស់យន្តការមន្ត្រីជំនាញនេះ:

**expertmechanism@ohchr.org** ។

ដើម្បីរកបានព័ត៌មានបន្ថែមទៀតស្ដីពី**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច** ក្នុងនោះរួមមាន លក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសក្រុមអ្នកទទួលផល សូមមើល**ជំពូក IX (មូលនិធិ និងជំនួយ)** នៃ*សៀវភៅ*នេះ ។

### ការជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងនៅយន្តការមន្ត្រីជំនាញ

ស្របទៅតាមសេចក្តីសម្រេចចិត្តលេខ 5/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសិទ្ធិមនុស្សផ្សេងទៀត អាចជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងជាមន្ត្រីជំនាញឯករាជ្យ សម្រាប់យន្តការមន្ត្រីជំនាញ ។ បុគ្គល ក៏អាចជ្រើសតាំងខ្លួនឯងជាបេក្ខភាពបានដែរ ។

លក្ខណវិនិច្ឆ័យសម្រាប់ការតែងតាំងជាមន្ត្រីជំនាញឯករាជ្យ គឺជំនាញ បទពិសោធន៍នៅក្នុងវិស័យនៃអាណត្តិ ឯករាជ្យភាព អនាគតិ ភាពសុចរិតផ្ទាល់ខ្លួន និងភាពមិនលម្អៀង ។ ការពិចារណាដោយត្រឹមត្រូវ ក៏ត្រូវបានផ្តោតផងដែរទៅលើតុល្យភាពយេនឌ័រ ការធ្វើជាតំណាងភូមិសាស្ត្រប្រកបដោយសមធម៌ និងការធ្វើជាតំណាងសមស្របនៃប្រព័ន្ធច្បាប់ខុសៗគ្នា ។

*i* ដើម្បីរកបានព័ត៌មានបន្ថែមទៀតស្តីពីវិធី**ជ្រើសតាំងបេក្ខភាព** និងថាតើដំណើរការតែងតាំ ដំណើរការទៅដូចម្តេចនោះ **ចូរទាក់ទងនឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សៈ**

អ៊ីម៉ែលៈ **hrcexpertmechanism@ohchr.org**

ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០១១

## ឈ. សេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព

*i* សម្រាប់ព័ត៌មានស្តីពីវិធីចូលរួម និងការរួមចំណែកក្នុងការងាររបស់**យន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលទាក់ទងនឹងសន្និសីទពិភពលោកក្រុងឌឺបែន** សូមទាក់ទងនឹងៈ

**អង្គភាពប្រឆាំងនឹងការរើសអើង**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

8-14, avenue de la Paix

CH- 1211 Geneva 10 - ប្រទេសស្វីស

អ៊ីម៉ែលៈ **adusecretariat@ohchr.org**

ទូរស័ព្ទលេខៈ +៤១ (០)២២ ៩២៨ ៩៨ ០៨

ទូរសារលេខៈ +៤១ (០)២២ ៩២៨ ៩០ ៥០

## ១. ក្រុមការងារអន្តររដ្ឋាភិបាល ទទួលបន្ទុកអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព

ដោយហេតុថាក្រុមការងារនេះ មានលក្ខណៈបើកចំហនោះ អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោក អាចចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមការងារនេះ ។ អង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារនេះ មានឱកាសធ្វើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់ និងអាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ។

## ២. ក្រុមមន្ត្រីជំនាញឯករាជ្យដ៏ល្បីល្បាញ

អង្គការមិនមែនរដ្ឋាភិបាល ដែលបានចាប់អារម្មណ៍ចង់ដាក់ជូនពិនិត្យនូវរបាយការណ៍នានាទៅក្រុមមន្ត្រីជំនាញដ៏ល្បីល្បាញ គួរតែទាក់ទងនឹង**អង្គភាពប្រឆាំងនឹងការរើសអើងរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។**

## ៣. ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកមនុស្សដែលមានត្រកូលអាហ្វ្រិច

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោក អាចចូលរួមបាននៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ។ អង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារនេះ មានឱកាសដាក់ជូនពិនិត្យនូវសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ និងធ្វើបទបង្ហាញដោយផ្ទាល់មាត់ ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្តីពីការចូលរួមនៅក្នុងក្រុមការងារ ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ក៏ត្រូវបានស្នើសុំផងដែរឲ្យផ្តល់ដល់ក្រុមការងារនេះនូវព័ត៌មាន និងរបាយការណ៍ ដើម្បីជួយឲ្យក្រុមការងារនេះអាចអនុវត្តបាននូវអាណត្តិរបស់ខ្លួន ។ អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ក៏អាចសហការជាមួយនឹងក្រុមការងារផងដែរ នៅពេលដែលក្រុមការងារនេះ ទទួលធ្វើទស្សនកិច្ចដល់មូលដ្ឋាន ដោយផ្តល់ព័ត៌មាននៅកន្លែងសមស្រប និងរៀបចំឲ្យមនុស្សនិយាយបញ្ចេញយោបល់ជាមួយនឹងសមាជិករបស់ក្រុមការងារនេះ ។

## ៤. គណៈកម្មាធិការពិសេសទទួលបន្ទុករៀបចំលម្អិតស្តង់ដាបំពេញបន្ថែម

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសន្និសីទពិភពលោក

អាចចូលរួមនៅក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមការងារ និងមានឱកាសអានសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ ។

តួអង្គសង្គមស៊ីវិល អាចត្រូវបានស្នើសុំឲ្យរួមចំណែកជាព័ត៌មាន និងការសិក្សា ដល់គណៈកម្មាធិការពិសេស ។ តួអង្គសង្គមស៊ីវិលដែលបានចាប់អារម្មណ៍ចង់ធ្វើដូច្នេះ គួរតែទាក់ទងនឹង**អង្គភាពប្រឆាំងនឹងការរើសអើងរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** ។

## ៥. គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺបែន និងក្រុមការងារអន្តររដ្ឋាភិបាល អន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ ដើម្បីតាមដានការងាររបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺបែន

គណៈកម្មាធិការរៀបចំត្រៀមបម្រុង និងក្រុមការងារអន្តររដ្ឋាភិបាលដ៏ទូលំទូលាយ ត្រូវបានបង្កើតឡើង ដើម្បីរៀបចំត្រៀមសម្រាប់សន្និសីទត្រួតពិនិត្យឡើងវិញ ។ លក្ខណវិនិច្ឆ័យ និងការរៀបចំខាងក្រោមអនុវត្តចំពោះការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង ។ អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គទាំងនេះក៏អាចចូលរួមបានផងដែរនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារអន្តររដ្ឋាភិបាលដ៏ទូលំទូលាយ ។

- អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ត្រូវបានអញ្ជើញឲ្យចូលរួមដោយពេញលេញនៅក្នុងវគ្គប្រជុំពេញអង្គទាំងអស់របស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង ដោយអនុលោមទៅតាមសេចក្ដីសម្រេចចិត្តលេខ 1996/31 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ។
- អង្គការមិនមែនរដ្ឋាភិបាលដែលគ្មានឋានៈបែបនេះ ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសន្និសីទពិភពលោក និងយន្តការបន្តរបស់សន្និសីទនេះ ត្រូវបានអញ្ជើញឲ្យចូលរួមដោយពេញលេញនៅក្នុងវគ្គប្រជុំពេញអង្គ លុះត្រាតែរដ្ឋាភិបាល លើកឡើងអំពីបញ្ហាដែលពាក់ព័ន្ធនឹងលិខិតអនុញ្ញាតរបស់គេនោះ ។ ប្រសិនបើបញ្ហា ត្រូវបានលើកឡើងទាក់ទងនឹងលិខិតអនុញ្ញាតរបស់អង្គការមិនមែនរដ្ឋាភិបាលណាមួយ អង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវបានផ្ដល់នូវឱកាស ដើម្បីឆ្លើយតប ដោយមានការសម្រេចចិត្តចុងក្រោយដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការរៀបចំត្រៀមបម្រុង ដោយអនុលោមទៅតាមដំណើរការនីតិវិធីស្ដង់ដារដែលត្រូវបានកំណត់នៅក្នុងសេចក្ដីសម្រេចចិត្តលេខ 1996/31 ។
- អង្គការមិនមែនរដ្ឋាភិបាលដែលគ្មានឋានៈពិគ្រោះយោបល់ និងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសន្និសីទពិភពលោក និងយន្តការបន្តរបស់សន្និសីទនេះ អាចដាក់ជូនពិនិត្យនូវពាក្យសុំចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង ទៅលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ ។ លេខាធិការដ្ឋាន ត្រួតពិនិត្យឡើងវិញលើពាក្យសុំទាំងអស់ដែលត្រូវបានទទួល ដើម្បីធានាថា វា បំពេញតម្រូវការដែលត្រូវបានកំណត់នៅក្នុងសេចក្ដីសម្រេចចិត្តលេខ 1996/31 និង

- តំណាងរបស់ជនជាតិដើមភាគតិចដែលត្រូវបានអនុញ្ញាត ដោយអនុលោមទៅតាមសេចក្តីសម្រេចចិត្តលេខ 1995/32 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ដែលបង្ហាញពីការស្ម័គ្រចិត្តចង់ចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង នឹងត្រូវបានអនុញ្ញាត ។ តំណាងរបស់ជនជាតិដើមភាគតិចដទៃទៀតដែលបានចាប់អារម្មណ៍ ក៏អាចត្រូវបានអនុញ្ញាតផងដែរ ដោយអនុវត្តតាមនីតិវិធីស្តង់ដាដែលត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចចិត្តលេខ 1996/31 ។

អង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុង និងក្រុមការងារអន្តររដ្ឋាភិបាលដ៏ទូលំទូលាយ មានឱកាសអានសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដោយផ្ទាល់មាត់ និងអាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ។

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសន្និសីទពិភពលោក និងយន្តការបន្តរបស់សន្និសីទនេះ ក្នុងនោះរួមមាន គណៈកម្មាធិការរៀបចំត្រៀមបម្រុង ផងដែរ ក៏អាចចូលរួមបាននៅក្នុងសន្និសីទត្រួតពិនិត្យឡើងវិញផងដែរ ។[55]

អង្គការមិនមែនរដ្ឋាភិបាល ដែលគ្មានឋានៈបែបនេះ និងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសន្និសីទពិភពលោក និងយន្តការបន្តរបស់សន្និសីទនេះ ត្រូវបានស្នើសុំឲ្យដាក់ជូនពិនិត្យនូវពាក្យសុំចូលរួមនៅក្នុងសន្និសីទត្រួតពិនិត្យឡើងវិញ ។

[55] ចូរមើល "របាយការណ៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការចូលរួមសម្រាប់សន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែនៈ របាយការណ៍របស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងស្តីពីវគ្គប្រជុំពេញអង្គទីមួយរបស់គណៈកម្មាធិការនេះ" (វិធានទី ៦៦ នៃ A/62/375) ។

# ធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

## វិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិល គួរតែមើលគេហទំព័រអ៊ិនធើណិតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សជាទៀងទាត់ ដើម្បីរកព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីការចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ។ តាមធម្មតា ព័ត៌មានដែលពាក់ព័ន្ធតែនឹងវគ្គប្រជុំពេញអង្គ ត្រូវបានដាក់ផ្សាយនៅក្នុងវិបសាយក្នុងរយៈពេលពីរសប្តាហ៍ មុនវគ្គប្រជុំពេញអង្គសាមញ្ញនីមួយៗ ។

## ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត)

**ប្រព័ន្ធកុំព្យូទ័រ** (អិក្សត្រាណិត) ត្រូវបានភ្ជាប់ទៅនឹងវិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ វាមានៈ

- សេចក្តីព្រាងនៃសេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។
- វិភាគទានជាឯកសារមិនផ្លូវការលាយលក្ខណ៍អក្សររបស់រដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត និង
- សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលត្រូវបានអានដោយរដ្ឋ រដ្ឋជាអ្នកសង្កេតការណ៍ និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកចូលរួមផ្សេងទៀតនៅក្នុងវគ្គប្រជុំពេញអង្គសាមញ្ញ និងពិសេស និងកិច្ចប្រជុំរៀបចំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) ក៏មានទំព័រអ៊ិនធើណិតផ្តល់ព័ត៌មានទំនាក់ទំនាក់អង្គការមិនមែនរដ្ឋាភិបាល ដោយមានព័ត៌មានពាក់ព័ន្ធតែនឹងវគ្គប្រជុំពេញអង្គដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ។

> *i*
>
> ដើម្បីចូលមើលទំព័រអ៊ិនធើណិតដែលត្រូវបានការពារដោយពាក្យសម្ងាត់ ចូរបំពេញទម្រង់ជាបណ្តាញអេឡិចត្រូនិចដែលត្រូវបានរៀបចំឲ្យមានពីផ្នែករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃវិបសាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ នៅពេលដែលអ្នកបានធ្វើកិច្ចការនេះហើយ អ្នកនឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់តាមអ៊ីម៉ែល ។

## កម្មវិធីផ្សាយនៅលើអ៊ិនធើណិត

កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងកិច្ចប្រជុំខ្លះនៃយន្តការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ អាចត្រូវបានមើលផ្ទាល់នៅក្នុងកម្មវិធីផ្សាយនៅលើអ៊ិនធើណិតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ។ កន្លែងកម្មវិធីផ្សាយនៅលើអ៊ិនធើណិត ក៏មានវីដេអូស្តីពីកិច្ចប្រជុំមុនៗរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដែលបានរក្សាទុក ។ ដើម្បីមើលកម្មវិធីផ្សាយនៅលើអ៊ិនធើណិត អ្នក នឹងចាំបាច់ត្រូវផ្ទេរចេញពីផ្នែកទន់សមស្រប ។

i

សេវានៃកម្មវិធីផ្សាយនៅលើអ៊ិនធើណិត
ត្រូវបានរៀបចំឲ្យមានពីផ្នែករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
(OHCHR) ។


ក្រុមប្រឹក្សាសិទ្ធិមនុស្ស
យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល
ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញជាសកល
គណៈកម្មាធិការផ្តល់ប្រឹក្សានៃក្រុមប្រឹក្សាសិទ្ធិមនុស្ស
យន្តការបណ្តឹង
ក្រុមការងារទទួលបន្ទុកឯកសារបណ្តឹង
ក្រុមការងារទទួលបន្ទុកស្ថានភាព
យន្តការពិសេស
អាណត្តប្រចាំប្រទេស
អាណត្តិប្រធានបទ
ក្រុមការងារ
ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍន៍ទូលំទូលាយ
វេទិកាសង្គម
វេទិកាស្តីពីបញ្ហាក្រុមជនភាគតិច
យន្តការមន្ត្រីជំនាញទទួលបន្ទុកសិទ្ធិរបស់ជនជាតិដើមភាគតិច
យន្តការទាក់ទងនឹងសេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព

# ឧបសម្ព័ន្ធ: ការប្រើប្រាស់ និងការធ្វើការងារជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស និងអាណត្តិ

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាខ្លះ (CSA) អាចចូលរួមក្នុងកិច្ចប្រជុំរបស់យន្តការបាន ? | តើតួអង្គសង្គមស៊ីវិល (CSA) ទាំងនេះ អាចចូលរួមប្រាស្រ័យនៅក្នុងកិច្ចប្រជុំដែលគេបានចូលរួមដោយវិធីណា ? | តើតួអង្គសង្គមស៊ីវិល (CSA) ណាខ្លះ អាចរួមចំណែកនៅក្នុងការងាររបស់យន្តការ (ក្រៅពី តាមរយៈការចូលរួមក្នុងកិច្ចប្រជុំ) ? | តើការរួមចំណែកទាំងនេះ អាចមានទម្រង់ដូចម្តេច ? |
|---|---|---|---|---|
| **សម័យប្រជុំពេញអង្គសាមញ្ញ និងពិសេស របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស** | អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាត | • ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់<br>• ការរៀបចំកិច្ចប្រជុំស្រដៀងគ្នាក្នុងអំឡុងពេលតែមួយ | តែអង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ប៉ុណ្ណោះ អាចដាក់ជូនពិនិត្យនូវសេចក្តីថ្លែង-ការណ៍ជាលាយលក្ខណ៍អក្សរទៅវគ្គប្រជុំពេញអង្គសាមញ្ញ/ពិសេស | អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) គួរតែមើលគោលការណ៍ណែនាំសម្រាប់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍-អក្សរ |
| **យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** | អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាត | • ការរៀបចំវគ្គប្រជុំពេញអង្គផ្តល់ព័ត៌មាន<br>• សេចក្តីសង្កេតទូទៅសង្ខេប អាចត្រូវបានធ្វើឡើង មុនពេលអនុម័តឯកសារលទ្ធផលនៅក្នុងវគ្គប្រជុំពេញអង្គសាមញ្ញរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស | **តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ** | • ការធ្វើការងារជាមួយនឹងរដ្ឋាភិបាល ឆ្ពោះទៅរកការរៀបចំរបាយការណ៍ជាតិ<br>• ការរួមចំណែកនៅក្នុងឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធសម្រាប់ការដាក់បញ្ចូលជាសក្ខានុពលទៅក្នុងសេចក្តី-សង្ខេបរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)<br>• ធ្វើការងារអនុវត្តបន្តទៅនឹងលទ្ធផលនៃការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (សេចក្តីសន្និដ្ឋាន អនុ-សាសន៍ ការសន្យាផ្តល់ដោយស្ម័គ្រចិត្ត /ការប្តេជ្ញាចិត្ត |
| **គណៈកម្មាធិការផ្តល់ប្រឹក្សានៃក្រុមប្រឹក្សា សិទ្ធិមនុស្ស** | អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាត | • ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់ | **តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ** | • ការជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងទៅគណៈកម្មាធិការផ្តល់ប្រឹក្សានេះ |
| **យន្តការបណ្តឹង** | តួអង្គសង្គមស៊ីវិល (CSA) មិនអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយរបស់យន្តការ-បណ្តឹង ឬ ក្រុមការងាររបស់យន្តការនេះបានទេ ។ កិច្ចប្រជុំទាំងនេះ មានលក្ខណៈឯកជន ។ | មិនមាន | **តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ** | • ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងក្រោមយន្តការបណ្តឹងនេះ |

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាខ្លះ (CSA) អាច ចូលរួមក្នុងកិច្ចប្រជុំរបស់យន្តការបាន ? | តើតួអង្គសង្គមស៊ីវិល (CSA) ទាំងនេះ អាចចូលរួមប្រាស្រ័យនៅក្នុងកិច្ចប្រជុំដែលគេបានចូលរួមដោយវិធីណា ? | តើតួអង្គសង្គមស៊ីវិល (CSA) ណាខ្លះ អាចរួមចំណែកនៅក្នុងការងាររបស់យន្តការ (ក្រៅពី តាមរយៈការចូលរួមក្នុងកិច្ចប្រជុំ) ? | តើការរួមចំណែកទាំងនេះ អាចមានទម្រង់ដូចម្តេច ? |
|---|---|---|---|---|
| **យន្តការពិសេស** | អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គម ស៊ីវិល (CSA) ផ្សេងទៀត អាចរៀបចំត្រៀប្រជុំជាមួយនឹងអ្នកមានអាណត្តិនៅក្នុងអំឡុងកិច្ចប្រជុំផ្នែកដែលបានជ្រើសរើស នៃកិច្ចប្រជុំប្រចាំឆ្នាំរបស់យន្តការពិសេស | • កិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងទៅវិញទៅមកជាមួយនឹងអ្នកមានអាណត្តិនៅក្នុងអំឡុងកិច្ចប្រជុំផ្នែកដែលបានជ្រើសរើសនៃកិច្ចប្រជុំ ប្រចាំឆ្នាំរបស់យន្ត-ការពិសេស<br>• អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចចូលរួមនៅក្នុងកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងទៅវិញទៅមកជាមួយនឹងអ្នកមានអាណត្តិនៅក្នុងវគ្គប្រជុំពេញអង្គសាមញ្ញរបស់ក្រុមប្រឹក្សាសិទ្ធិ-មនុស្ស | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវសេចក្តីអំពាវនាវបន្ទាន់/ករណីជាលក្ខណៈបុគ្គល<br>• ការផ្តល់ការគាំទ្រសម្រាប់ដំណើរទស្សនកិច្ចប្រចាំប្រទេស<br>• ការខិតខំពុះពារស៊ូមតិ ផ្សព្វផ្សាយតាមដានបន្ត និងអនុវត្តការងាររបស់យន្តការពិសេស<br>• ការជួបប្រជុំជាមួយនឹងអ្នកមានអាណត្តិ<br>• ការជ្រើសតាំងបេក្ខជនសម្រាប់ជាអ្នកមានអាណត្តិ |
| **ក្រុមការងារទទួលបន្ទុកសិទ្ធិទទួលបានការអភិវឌ្ឍដ៏ទូលំទូលាយ** | អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវ បានអនុញ្ញាត អាចចូលរួមនៅក្នុងកិច្ចប្រជុំផ្នែកជាសាធារណៈនៃកិច្ចប្រជុំរបស់ក្រុម-ការងារ ។ | អង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់**ក្រុមការងារពិសេសកម្រិតខ្ពស់** មានឱកាសធ្វើសេចក្តីថ្លែង-ការណ៍បើក ។<br>ទោះជាយ៉ាងណាក៏ដោយ ឱកាសនេះមិនអនុវត្តចំពោះកិច្ចប្រជុំរបស់ក្រុមការងារទេ ។ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ទៅក្រុមការងារ<br>• ការចូលរួមជាមួយនឹងក្រុមការងារពិសេស<br>• ការខិតខំពុះពារអនុវត្តអនុសាសន៍របស់ក្រុមការងារនេះ |
| **វេទិកាសង្គម** | តួអង្គសង្គមស៊ីវិល (CSA) ដ៏ច្រើនសន្ធឹកសន្ធាប់ អាចចូលរួមក្នុងកិច្ចប្រជុំ | • ការផ្តល់ព័ត៌មានត្រឡប់ស្តីពីការងារសិទ្ធិមនុស្សរបស់យន្តការអន្តរជាតិនៅក្នុងកិច្ចប្រជុំ<br>• ការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវវិធីអនុវត្តន៍ត្រឹមត្រូវនៅក្នុងកិច្ចប្រជុំ<br>• បទបង្ហាញរបស់មហាជននៅក្នុងកិច្ចប្រជុំ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅវេទិកាសង្គមនេះ |

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាខ្លះ (CSA) អាច ចូលរួមក្នុងកិច្ចប្រជុំរបស់យន្តការបាន ? | តើតួអង្គសង្គមស៊ីវិល (CSA) ទាំងនេះ អាចចូលរួមប្រាស្រ័យនៅក្នុងកិច្ចប្រជុំដែល គេបានចូលរួមដោយវិធីណា ? | តើតួអង្គសង្គមស៊ីវិល (CSA) ណាខ្លះ អាចរួមចំណែកនៅក្នុងការងាររបស់យន្តការ (ក្រៅពី តាមរយៈការចូលរួមក្នុងកិច្ចប្រជុំ) ? | តើការរួមចំណែកទាំងនេះ អាចមានទម្រង់ដូចម្តេច ? |
|---|---|---|---|---|
| **វេទិកាស្តីពីបញ្ហារបស់ក្រុមជនភាគតិច** | តួអង្គសង្គមស៊ីវិល (CSA) ដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងនោះរួមមាន អង្គការមិនមែន-រដ្ឋាភិបាល អ្នកសិក្សាជាន់ខ្ពស់ និងមន្ត្រីជំនាញផ្នែកបញ្ហារបស់ក្រុមជនភាគតិច | • បទបង្ហាញ/សេចក្តីថ្លែងការណ៍ជាលាយ-លក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍-អក្សរ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅវេទិកានេះ<br>• អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងជាប្រធាននៃវេទិកានេះ |
| **យន្តការមន្ត្រីជំនាញការពារសិទ្ធិរបស់ជនជាតិដើមភាគតិច** | តួអង្គសង្គមស៊ីវិល (CSA) ដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល និងក្រុម និងអង្គការនៃជនជាតិដើមភាគតិចផងដែរ | • បទបង្ហាញ/សេចក្តីថ្លែងការណ៍ជាលាយ-លក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍-អក្សរ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅយន្តការមន្ត្រីជំនាញ<br>• ការជ្រើសតាំងបេក្ខភាពសម្រាប់ការតែងតាំងមន្ត្រីជំនាញឯករាជ្យ |
| **ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុក អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវ សេចក្តីប្រកាសក្រុងឌឺបែន និងកម្មវិធីសកម្មភាព** | អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)<br><br>អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោកក្រុងឌឺបែន | • បទបង្ហាញជាលាយលក្ខណ៍អក្សរបង្ហាញដោយផ្ទាល់មាត់<br>• សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍-អក្សរ | តែតួអង្គសង្គមស៊ីវិល (CSA) ដែលមានប្រភេទដូចបានជម្រាបជូននៅខាងឆ្វេង ប៉ុណ្ណោះ អាចរួមចំណែកជាព័ត៌មានដល់ក្រុមការងារអន្តររដ្ឋាភិបាល | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅក្រុមការងារនេះ |
| **ក្រុមមន្ត្រីជំនាញឯករាជ្យដ៏ល្បីល្បាញ** | ជាគោលការណ៍ កិច្ចប្រជុំ មានលក្ខណៈសម្ងាត់ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនេះ អាចអញ្ជើញតួអង្គសង្គមស៊ីវិល (CSA) ឲ្យចូលរួមផ្លាស់ប្តូរទៅវិញទៅមកនូវមតិយោបល់ជាមួយនឹងក្រុមនេះ ។ | • ការផ្លាស់ប្តូរទៅវិញនូវមតិយោបល់តាមការអញ្ជើញរបស់ក្រុមនេះ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅក្រុមនេះ |

| កិច្ចប្រជុំ/យន្តការ | តើតួអង្គសង្គមស៊ីវិលណាខ្លះ (CSA) អាច ចូលរួមក្នុងកិច្ចប្រជុំរបស់យន្តការបាន ? | តើតួអង្គសង្គមស៊ីវិល (CSA) ទាំងនេះ អាចចូលរួមប្រាស្រ័យនៅក្នុងកិច្ចប្រជុំដែល គេបានចូលរួមដោយវិធីណា ? | តើតួអង្គសង្គមស៊ីវិល (CSA) ណាខ្លះ អាចរួមចំណែកនៅក្នុងការងាររបស់យន្តការ (ក្រៅពី តាមរយៈការចូលរួមក្នុងកិច្ចប្រជុំ) ? | តើការរួមចំណែកទាំងនេះ អាចមានទម្រង់ដូចម្តេច ? |
|---|---|---|---|---|
| **ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកមនុស្សដែលមានត្រកូលអាព្រិច** | អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)<br><br>អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោកក្រុងឌឺប៊ែន | • បទបង្ហាញជាលាយលក្ខណ៍អក្សរ បង្ហាញដោយផ្ទាល់មាត់<br>• ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មានទៅក្រុមការងារ<br>• ការផ្តល់ព័ត៌មាននៅកន្លែងសមស្របនៅក្នុងអំឡុងពេលបេសកកម្មប្រចាំប្រទេសរបស់ក្រុមការងារនេះ<br>• ការជួបប្រជុំជាមួយសមាជិករបស់ក្រុមការងារនេះនៅក្នុងអំឡុងពេលទស្សនកិច្ចប្រចាំប្រទេស |
| **គណៈកម្មាធិការរៀបចំត្រៀមបម្រុង សន្និសីទត្រួតពិនិត្យឡើងវិញក្រុងឌឺប៊ែន**<br><br>**ក្រុមការងារអន្តររដ្ឋាភិបាលអន្តរវគ្គប្រជុំ ពេញអង្គដ៏ទូលំទូលាយ ដើម្បីតាមដាន ការងាររបស់គណៈកម្មាធិការរៀបចំត្រៀមបម្រុងសន្និសីទត្រួតពិនិត្យឡើងវិញ ក្រុងឌឺប៊ែន** | • អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOS-OC)<br>• អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោកក្រុងឌឺប៊ែន<br>• អង្គការមិនមែនរដ្ឋាភិបាល (ដែលគ្មានឋានៈពិគ្រោះយោបល់ និងដែលមិនបានចូលរួមក្នុងសន្និសីទពិភព-លោក) អាចដាក់ជូនពិនិត្យនូវពាក្យសុំដើម្បីចូលរួម<br>• តំណាងរបស់ជនជាតិដើមភាគតិច | • សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍-អក្សរបង្ហាញដោយផ្ទាល់មាត់<br>• ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តែតួអង្គសង្គមស៊ីវិល (CSA) ដែលមានប្រភេទដូចបានជម្រាបជូននៅខាងឆ្វេង ប៉ុណ្ណោះ អាចរួមចំណែកជាព័ត៌មានទៅគណៈកម្មាធិការរៀបចំត្រៀមបម្រុង និងក្រុមការងារអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ | • ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរទៅគណៈកម្មា-ធិការរៀបចំត្រៀមបម្រុង និងក្រុមការ-ងារអន្តរវគ្គប្រជុំពេញអង្គដ៏ទូលំទូលាយ |
| **គណៈកម្មាធិការពិសេសទទួលបន្ទុករៀបចំលម្អិតស្តង់ដាបំពេញបន្ថែម** | អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)<br><br>អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទពិភពលោកក្រុងឌឺប៊ែន | • បទបង្ហាញជាលាយលក្ខណ៍អក្សរ បង្ហាញដោយផ្ទាល់មាត់<br>• ការដាក់ជូនពិនិត្យនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ | តួអង្គសង្គមស៊ីវិល (CSA) ដែលពាក់ព័ន្ធ | • ការដាក់ជូនពិនិត្យនូវព័ត៌មាន និងលទ្ធផលនៃការសិក្សាទៅគណៈកម្មា-ធិការពិសេស |

# VI. យន្តការពិសេស

## ទិដ្ឋភាពរួមនៃយន្តការពិសេស

***ដូចម្ដេចដែលហៅថា យន្តការពិសេស ?***

"**យន្តការពិសេស**" គឺជាឈ្មោះទូទៅដែលត្រូវបានដាក់ឲ្យយន្តការដែលត្រូវបានបង្កើតឡើងដោយ**គណៈកម្មការសិទ្ធិមនុស្ស** និងត្រូវបានបន្តដោយ**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ដើម្បីត្រួតពិនិត្យ ពិនិត្យតាមដាន ណែនាំ និងធ្វើសេចក្ដីរាយការណ៍ជាសាធារណៈលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬ ទឹកដីជាក់លាក់ (**អាណត្តិប្រចាំប្រទេស**) ឬ បាតុភូតចម្បងនៃការរំលោភបំពានសិទ្ធិមនុស្សនៅទូទាំងពិភពលោក (**អាណត្តិប្រធានបទ**) ។ នៅត្រឹមខែកញ្ញា ឆ្នាំ ២០០៨ មានយន្តការពិសេសចំនួន៣៨(អាណត្តិប្រធានបទចំនួន ៣០ និងអាណត្តិប្រចាំប្រទេសចំនួន៨)ដែលធ្វើប្រតិបត្តិការ ។

មនុស្សដែលត្រូវបានតែងតាំងទៅយន្តការពិសេស គឺជាមន្ត្រីជំនាញឯករាជ្យ (អ្នកមានអាណត្តិ) និងអាចត្រូវបានគេដឹងថាជា អ្នករាយការណ៍ពិសេស តំណាង តំណាងពិសេស មន្ត្រីជំនាញឯករាជ្យ ឬ សមាជិករបស់ក្រុមការងារ ។

**ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ផ្ដល់ដល់យន្តការពិសេសនូវបុគ្គលិក ជំនួយផ្នែកភ័ស្ដុភារ និងស្រាវជ្រាវ ដើម្បីគាំទ្រដល់យន្តការពិសេស នៅក្នុងអាណត្តិរបស់យន្តការពិសេសនេះ ។

***តើយន្តការពិសេស ធ្វើការងារដោយវិធីណា ?***

យន្តការពិសេសៈ

- ទាក់ទងទៅវិញទៅមកប្រចាំថ្ងៃជាមួយនឹងជនរងគ្រោះជាក់ស្ដែង និងមានសក្ដានុពលដោយការរំលោភបំពានលើសិទ្ធិមនុស្ស និងតស៊ូមតិដើម្បីកិច្ចការពារសិទ្ធិរបស់ពួកគេ ។
- ដោះស្រាយបន្តនូវកង្វល់ផ្នែកសិទ្ធិមនុស្ស ជាករណីជាលក្ខណៈបុគ្គល ឬ បញ្ហាដែលមានលក្ខណៈទូទៅកាន់តែច្រើនឡើង តាមរយៈទំនាក់ទំនងផ្ទាល់ជាមួយនឹងរដ្ឋាភិបាល ។
- ទទួលអនុវត្តបេសកកម្មស្វែងរកការពិតនៅក្នុងប្រទេសនានា និងចេញផ្សាយរបាយការណ៍ជាមួយនឹងអនុសាសន៍ ។
- រៀបចំការសិក្សាប្រធានបទដែលបំពេញនាទីជាមគ្គុទេសក៍ស្ដីពីបទដ្ឋាន និងស្តង់ដា និង
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយស្ដីពីបញ្ហានានានៅក្នុងអាណត្តិរបស់គេ ។
- មិនដូចស្ថាប័ន សន្ធិសញ្ញានៃអង្គការសហប្រជាជាតិទេ យន្តការពិសេស អាចត្រូវបានដាស់តឿន សូម្បីតែក្នុងករណីដែលរដ្ឋមួយមិនបានផ្ដល់

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

| | | |
|---|---|---|
| សច្ចាប័នលើលិខិតុបករណ៍ ឬសន្ធិសញ្ញាពាក់ព័ន្ធ និងវាមិនចាំបាច់ប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យនៅក្នុងស្រុក ទើបប្រើប្រាស់យន្តការពិសេសនោះទេ ។<br><br>***វិធីប្រើប្រាស់និងធ្វើការងារជាមួយនឹងយន្តការពិសេស***<br><br>**តួអង្គសង្គមស៊ីវិល ជាបុគ្គល ឬ ជារូម អាចប្រើប្រាស់និងធ្វើការងារជាមួយនឹងយន្តការពិសេស** ។ គេ អាចធ្វើកិច្ចការនេះតាមរយៈ: | • ការដាក់ជូនពិនិត្យនូវករណីជាលក្ខណៈបុគ្គលទៅយន្តការពិសេស ។<br>• ការផ្តល់នូវព័ត៌មាន និងការវិភាគលើកង្វល់ផ្នែកសិទ្ធិមនុស្សជាក់លាក់ ។<br>• ការផ្តល់ការគាំទ្រដល់ដំណើរទស្សនកិច្ចរបស់យន្តការពិសេស ។<br>• ការធ្វើការងារនៅថ្នាក់មូលដ្ឋាន ឬ ថ្នាក់ជាតិ ដើម្បីតស៊ូមតិ ផ្សព្វផ្សាយ អនុវត្តបន្ត និងអនុវត្តការងាររបស់យន្តការពិសេស ។<br>• ការអញ្ជើញអ្នកមានអាណត្តិនៃយន្តការពិសេសឲ្យចូលរួមក្នុង | កិច្ចផ្តួចផ្តើមផ្ទាល់របស់ខ្លួន និង<br>• ការជួបនឹងអ្នកមានអាណត្តិម្នាក់ៗ ពេញមួយឆ្នាំ និងការចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់អ្នកមានអាណត្តិនៃយន្តការពិសេស ។<br><br>តួអង្គសង្គមស៊ីវិល ក៏អាចជ្រើសរើសបេក្ខជនសម្រាប់ជាអ្នកមានអាណត្តិយន្តការពិសេស ។ |

## i ការទាក់ទងនឹងអ្នកមានអាណត្តិនៃយន្តការពិសេស

អ៊ីម៉ែល: **SPDInfo@ohchr.org** (សម្រាប់ការសាកសួរ និងព័ត៌មានទូទៅ)

**urgent-action@ohchr.org** (សម្រាប់ករណី/ពាក្យបណ្តឹងជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ)

ទូរសារ: +៤១ (0)២២ ៩១៧ ៩០ ០៦

អាសយដ្ឋានប្រៃសណីយ៍: **ការិយាល័យឆ្លើយតបរហ័ស**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

វិមានជាតិ

8-14, avenue de la Paix

CH- 1211 Geneva 10 - ប្រទេសស្វីស

**តួអង្គសង្គមស៊ីវិល គួរតែបង្ហាញនៅក្នុងកន្លែងកម្មវត្ថុនៃអ៊ីម៉ែល ឬ ទូរសារ ឬ នៅលើក្រប ស្រោមសំបុត្រនូវយន្តការពិសេសណា ដែលគេមានបំណងប្រាថ្នាចង់ទាក់ ទង**

ដោយហេតុថាអាសយដ្ឋានទំនាក់ទំនង គឺដូចគ្នាសម្រាប់យន្តការពិសេសទាំងអស់នោះ ការបង្ហាញច្បាស់លាស់នៃកម្មវត្ថុ ឬគោលបំណងសំខាន់បំផុតនៃការសរសេរទាក់ទងគ្នា នឹងអនុញ្ញាតឲ្យមានការឆ្លើយតបកាន់តែទាន់ពេលវេលា។

វាមានលក្ខណៈសំខាន់ជាសារវន្តក្នុងការបង្ហាញផងដែរអំពីថាតើសំបុត្រទាក់ទងគ្នា ត្រូវបានចាត់ទុកជាគោលបំណងនូវការដាក់ជូនពិនិត្យនូវព័ត៌មានដ៏ទូលំទូលាយ ដែលជាពាក្យបណ្តឹងជាលក្ខណៈបុគ្គលដែរឬអត់ ឬ ថាតើវាជាប្រភេទនៃការស្នើសុំមួយទៀត (ឧទាហរណ៍: ការអញ្ជើញឲ្យចូលរួមក្នុងសន្និសីទ ការស្នើសុំជួបប្រជុំជាមួយនឹងអ្នកមានអាណត្តិ និង/ឬ អ្នកជំនួយការរបស់ពួកគេ) ដែរឬអត់ ។

# ដូចម្តេចដែលហៅថា យន្តការពិសេស ?

## បុព្វកថាសម្រាប់យន្តការពិសេស

**"យន្តការពិសេស"** គឺជាឈ្មោះទូទៅដែលត្រូវបានដាក់ឲ្យយន្តការនានាដែលត្រូវបានបង្កើតឡើងដោយ**គណៈកម្មការសិទ្ធិមនុស្ស** និងត្រូវបានបន្តដោយ**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** ដើម្បីដោះស្រាយស្ថានភាពរបស់ប្រទេសជាក់លាក់ណាមួយ ឬ បញ្ហាប្រធានបទនៅក្នុងគ្រប់ផ្នែកទាំងអស់នៃពិភពលោក ។ លក្ខណៈពិសេសដែលសំខាន់បំផុតនៃយន្តការពិសេស គឺសមត្ថភាពរបស់យន្តការពិសេសនេះក្នុងការឆ្លើយតបដោយរហ័សទៅនឹងទឡ្ហីករណ៍នៃការរំលោភបំពានលើសិទ្ធិមនុស្ស ដែលកើតមានឡើងនៅក្នុងកន្លែងណាមួយនៅក្នុងពិភពលោក នៅពេលណាមួយ ។

តាមធម្មតា អាណត្តិរបស់យន្តការពិសេស តម្រូវឲ្យអ្នកមានអាណត្តិ ពិនិត្យតាមដាន ណែនាំ និងធ្វើសេចក្តីរាយការណ៍ជាសាធារណៈស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬ ទឹកដីជាក់លាក់ (**អាណត្តិប្រចាំប្រទេស**) ឬ បាតុភូតចម្បងនៃការរំលោភបំពានលើសិទ្ធិមនុស្សនៅទូទាំងពិភពលោក (**អាណត្តិប្រធានបទ**) ។ អាណត្តិរបស់យន្តការពិសេសនីមួយៗ ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចចិត្តដែលបានបង្កើតយន្តការពិសេសនេះ ។អាណត្តិប្រធានបទ ត្រូវបានបន្តជាថ្មី រៀងរាល់បីឆ្នាំម្តង ចំណែកឯអាណត្តិប្រចាំប្រទេសត្រូវបានបន្តជាថ្មីក្នុងមួយឆ្នាំម្តង វៀរលែងតែ ត្រូវបានសម្រេចដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ។[56] នៅត្រឹមខែកញ្ញា ឆ្នាំ ២០០៨ មានយន្តការពិសេសចំនួន ៣៨ ដែលធ្វើប្រតិបត្តិការ ពោលគឺ អាណត្តិប្រធានបទចំនួន ៣០ និងអាណត្តិប្រចាំប្រទេសចំនួន ៨ (ចូរមើលឧបសម្ព័ន្ធនៃជំពូកនេះ) ។

អ្នកមានអាណត្តិនៃយន្តការពិសេស អាចជាបុគ្គល (អ្នករាយការណ៍ពិសេស តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ឬ មន្ត្រីជំនាញឯករាជ្យ) ឬ ក្រុមរបស់បុគ្គល (ក្រុមការងារ) ។[57] អ្នកមានអាណត្តិ បម្រើតាមសមត្ថភាពផ្ទាល់របស់គេសម្រាប់រយៈពេលអតិបរមាប្រាំមួយឆ្នាំ និងមិនទទួលប្រាក់បៀវត្សរ៍ ឬ សំណងហិរញ្ញវត្ថុណាមួយផ្សេងទៀតសម្រាប់ការងាររបស់គេទេ ។ ឋានៈឯករាជ្យរបស់អ្នកមានអាណត្តិ គឺមានសារៈសំខាន់ណាស់ចំពោះការអនុវត្តដែលមានលក្ខណៈអនាគតិនូវមុខងាររបស់គេ ។

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ផ្តល់ដល់អ្នកមានអាណត្តិនៃយន្តការពិសេសនូវបុគ្គលិក ជំនួយផ្នែកភស្តុភារ និងស្រាវជ្រាវ ដើម្បីគាំទ្រដល់គេនៅក្នុងអាណត្តិរបស់គេ ។

---

[56] ចូរមើលកថាខ័ណ្ឌទី ៦០ ក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចចិត្តលេខ 5/1 និង "អាណត្តិនៃការិយាល័យរបស់អ្នកមានអាណត្តិនៃយន្តការពិសេស" នៅក្នុងឯកសារ (A/HRC/PRST/8/2) ។

[57] ក្រុមការងារ ជាទូទៅ មានសមាជិកប្រាំរូប មួយរូបៗត្រូវបានជ្រើសរើសចេញពីក្រុមតំបន់នីមួយៗក្នុងចំណោមក្រុមតំបន់ទាំងប្រាំរបស់អង្គការសហប្រជាជាតិៈ អាព្រិច អាស៊ី អាមេរិកឡាទីន និងការីប៊ីន អឺរ៉ុបខាងកើត និង អឺរ៉ុបខាងលិច និងតំបន់ផ្សេងទៀត ។

អ្នកមានអាណត្តិនៃយន្តការពិសេសៈ

- ទទួល និងវិភាគព័ត៌មាន ស្ដីពីស្ថានភាពសិទ្ធិមនុស្ស ដែលត្រូវបានផ្ដល់ដោយប្រភពផ្សេងៗជាបន្តបន្ទាប់ ។
- បង្កើតបណ្ដាញ និងចែករំលែកព័ត៌មានជាមួយនឹងដៃគូ ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល នៅខាងក្នុង និងក្រៅអង្គការសហប្រជាជាតិ ។
- ស្វែងរក ជារឿយៗ គឺដោយបន្ទាន់ នូវការបំភ្លឺពីរដ្ឋាភិបាលលើការរំលោភបំពានដែលមានទទ្បីករណ៍ និងក្នុងករណីត្រូវបានតម្រូវឲ្យមាន ស្នើសុំរដ្ឋាភិបាលឲ្យអនុវត្តវិធានការការពារ ដើម្បីធានា ឬ ពង្រឹងការទទួលបានសិទ្ធិមនុស្ស ។
- លើកកម្ពស់ការយល់ដឹងអំពីស្ថានភាព និងបាតុភូតសិទ្ធិមនុស្សជាក់លាក់ និងការគំរាមកំហែង និងការរំលោភបំពានលើសិទ្ធិមនុស្ស ។
- នៅពេលដែលកាលៈទេសៈជាក់លាក់ត្រូវបានធានាដូច្នោះ ផ្សព្វផ្សាយអំពីកង្វល់ផ្នែកសិទ្ធិមនុស្សតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងសេចក្ដីថ្លែងការណ៍ជាសាធារណៈផ្សេងទៀត ។
- ទទួលធ្វើទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ដើម្បីវាយតម្លៃស្ថានភានសិទ្ធិមនុស្សដែលទាក់ទងនឹងអាណត្តិនីមួយៗរបស់គេនិងផ្ដល់អនុសាសន៍ដល់រដ្ឋាភិបាលក្នុងបំណងកែលម្អស្ថានភាពទាំងនោះ។
- ធ្វើសេចក្ដីរាយការណ៍ និងផ្ដល់អនុសាសន៍ដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងករណីពាក់ព័ន្ធនឹងអាណត្តិរបស់គេ ទៅមហាសន្និបាតអង្គការសហប្រជាជាតិ (និងក្នុងករណីខ្លះទៀត ទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ) លើសកម្មភាពជាទៀងទាត់ក្រោមអាណត្តិរបស់គេ ទស្សនកិច្ចបេសកកម្មនៅមូលដ្ឋាន និងនិន្នាការ និងបាតុភូតប្រធានបទជាក់លាក់ ។
- រួមចំណែកជាការសិក្សាប្រធានបទលើការបង្កើតបទដ្ឋាន និងស្តង់ដាផ្ដល់សិទ្ធិអំណាចសម្រាប់ផ្នែកកម្មវត្ថុនៃអាណត្តិ និងអាចផ្ដល់ជំនាញផ្នែកច្បាប់លើបញ្ហាជាក់លាក់ ។

## ការត្រួតពិនិត្យឡើងវិញ ការផ្ដល់សនិទានកម្ម និងការកែលម្អប្រព័ន្ធយន្តការពិសេស

មហាសន្និបាតអង្គការ តាមរយៈ**សេចក្ដីសម្រេចចិត្តលេខ 60/251** របស់ខ្លួន បានតម្រូវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រួតពិនិត្យឡើងវិញ និង ក្នុងករណីចាំបាច់ កែលម្អ និងធ្វើសនិទានកម្មប្រព័ន្ធយន្តការពិសេស ។ នៅក្នុង**សេចក្ដីសម្រេចចិត្តលេខ 5/1** ស្ដីពីការកសាងស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ក្រុមប្រឹក្សានេះ បានរៀបចំលម្អិតនូវនីតិវិធីជ្រើសរើស និងតែងតាំងថ្មីសម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស និងបានបង្កើតដំណើរការសម្រាប់ការត្រួតពិនិត្យឡើងវិញ ការធ្វើសនិទានកម្ម និងការកែលម្អអាណត្តិរបស់យន្តការពិសេស ។ ក្រុមប្រឹក្សានេះ ក៏បានអនុម័តផងដែរនូវ**សេចក្ដីសម្រេចចិត្តលេខ 5/2** ដែលចែងអំពីក្រមសីលធម៌សម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

អាណត្តិប្រចាំប្រទេសចំនួនពីរ (ប្រទេសបិឡារូស និងគុយបា) ត្រូវបានបញ្ឈប់ នៅពេលអនុម័តសេចក្តីសម្រេចចិត្តលេខ 5/1 ។ នៅចុងបញ្ចប់នៃវគ្គប្រជុំពេញអង្គសាមញ្ញលើកទីប្រាំបួនរបស់ខ្លួន ក្រុមប្រឹក្សានេះ បានបង្កើតអាណត្តិប្រធានបទថ្មីចំនួនពីរ (**អ្នករាយការណ៍ពិសេសស្តីពីទម្រង់សហកាលនៃទាសភាព ក្នុងនោះរួមមាន បុព្វហេតុ** និង**ផលវិបាករបស់វា** និងមន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហាកាតព្វកិច្ចសិទ្ធិមនុស្សដែលទាក់ទងនឹងលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់ និងអនាម័យ**) និងបានបញ្ឈប់អាណត្តិប្រចាំប្រទេសចំនួនពីរទៀត (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ និងលីបេរី) ។

*i* សម្រាប់ព័ត៌មានពិស្តារស្តីពី**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** សូមមើល**ជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស)** នៃ *សៀវភៅ*នេះ ។

# ការជ្រើសរើស និងការតែងតាំងអ្នកមានអាណត្តិ

## លក្ខណាវិនិច្ឆ័យទូទៅសម្រាប់ការតែងតាំង

ដោយស្របទៅតាមសេចក្តីសម្រេចចិត្តលេខ 5/1 លក្ខណាវិនិច្ឆ័យទូទៅដូចតទៅ អនុវត្តចំពោះការជ្រើសតាំង ការជ្រើសរើស និងការតែងតាំងអ្នកមានអាណត្តិៈ

- ជំនាញ
- បទពិសោធន៍នៅក្នុងវិស័យនៃអាណត្តិ
- ឯករាជ្យភាព
- អនាគតិ
- ភាពសុចរិតផ្ទាល់ខ្លួន និង
- ភាពមិនលម្អៀង ។

នៅក្នុងការតែងតាំងអ្នកមានអាណត្តិ ការពិចារណាដោយត្រឹមត្រូវ ក៏ត្រូវបានផ្តោតផងដែរទៅលើតុល្យភាពយេនឌ័រ ការធ្វើជាតំណាងភូមិសាស្ត្រប្រកបដោយសមធម៌ ក៏ដូចជា ការធ្វើជាតំណាងសមស្របនៃប្រព័ន្ធច្បាប់ខុសៗគ្នា ។

## នរណា មានសិទ្ធិទទួលបានការតែងតាំង ?

បុគ្គលប្រកបដោយសមត្ថភាពខ្ពស់ ដោយមានសមត្ថភាពដែលបានបង្កើតឡើង ជំនាញពាក់ព័ន្ធ បទពិសោធន៍វិជ្ជាជីវៈទូលំទូលាយនៅក្នុងវិស័យសិទ្ធិមនុស្ស និងភាពបត់បែន/ការចេះគ្រប់គ្រងពេលវេលា ត្រូវបានចាត់ទុកថាជាបេក្ខជនដែលមានសិទ្ធិទទួលបានការតែងតាំងជាអ្នកមានអាណត្តិ ។[58]

[58] ចូរមើលសេចក្តីសម្រេចលេខ 6/102 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សផងដែរ ។

បុគ្គលដែលកាន់តំណែងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងរដ្ឋាភិបាល ឬ អង្គការ ឬ អង្គភាពណាមួយផ្សេងទៀត (ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងអង្គការសិទ្ធិមនុស្សផ្សេងទៀត ផងដែរ) ដែលអាចបណ្តាលឲ្យមានទំនាស់ផលប្រយោជន៍ជាមួយនឹងការទទួលខុសត្រូវដែលមានជាប់ជាមួយនឹងអាណត្តិ ត្រូវបានដកចេញ ។

គោលការណ៍នៃភាពមិនបង្កើនមុខងារសិទ្ធិមនុស្ស ក៏ត្រូវបានគោរពផងដែរ នៅពេលតែងតាំងអ្នកមានអាណត្តិ ។ នេះ មានន័យថា បុគ្គលទាំងឡាយ មិនគួរកាន់កាប់អាណត្តិសិទ្ធិមនុស្សរបស់អង្គការសហប្រ-ជាជាតិច្រើនក្នុងពេលតែមួយនោះទេ ។

## នរណាអាចជ្រើសតាំងបេក្ខជន ?

អង្គភាព ឬអង្គការ និងមនុស្សដូចតទៅនេះ អាចជ្រើសតាំងបេក្ខជនសម្រាប់ជាអ្នកមានអាណត្តិនៃយន្តការពិសេសៈ

- រដ្ឋាភិបាល
- ក្រុមប្រចាំតំបន់ដែលធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ
- អង្គការអន្តរជាតិ ឬ ការិយាល័យរបស់គេ (ឧទាហរណ៍ៈ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR))
- អង្គការមិនមែនរដ្ឋាភិបាល
- ស្ថាប័នសិទ្ធិមនុស្សផ្សេងទៀត និង
- បុគ្គលទាំងឡាយ

## បញ្ជីឈ្មោះបេក្ខជនទូទៅ និងបញ្ជីអាណត្តិទំនេរ

ដោយផ្អែកលើបេក្ខភាពដែលត្រូវបានទទួល ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រៀបចំ រក្សា និងធ្វើបច្ចុប្បន្នភាពតាមដំណាក់កាលនូវបញ្ជីឈ្មោះបេក្ខជនទូទៅដែលទទួលបានសិទ្ធិតែងតាំង ។ នេះ រួមបញ្ចូលទិន្នន័យផ្ទាល់ខ្លួនរបស់បេក្ខជន វិស័យនៃជំនាញ និងបទ-ពិសោធន៍វិជ្ជាជីវៈ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ផ្សព្វផ្សាយផងដែរអំពីកន្លែងទំនេរទាំងអស់នាពេលខាងមុខនៃអាណត្តិ ។

> *i* **បញ្ជីឈ្មោះបេក្ខជនទូទៅ** ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកយន្តការពិសេសនៃប្រព័ន្ធកុំព្យូទ័រ (អ៊ិក្សត្រាណិត) របស់ក្រុមប្រឹក្សា ។

## ក្រុមពិគ្រោះយោបល់

ក្រុមពិគ្រោះយោបល់ ដោយមានសមាជិកមួយរូបមកពីក្រុមប្រចាំតំបន់នីមួយៗ ក្នុងចំណោមក្រុមប្រចាំតំបន់ទាំងប្រាំដែលបម្រើក្នុងសមត្ថភាពផ្ទាល់ខ្លួនរបស់គេ ត្រួតពិនិត្យបញ្ជីឈ្មោះរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងស្នើឡើងនូវបញ្ជីឈ្មោះបេក្ខជនផ្ទាល់របស់ខ្លួនសម្រាប់ប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស ធ្វើការពិចារណា ។ អនុសាសន៍របស់ក្រុម ត្រូវតែមានលក្ខណៈទូទៅ និងត្រូវបានបញ្ជាក់ភស្តុតាង ។

**នៅពេលកំណត់អំពីជំនាញចាំបាច់ បទពិសោធន៍ ជំនាញ និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀតសម្រាប់អាណត្តិទំនេរនីមួយៗ ក្រុមពិគ្រោះយោបល់ ពិចារណា តាមការសមស្រប លើមតិយោបល់របស់អ្នកពាក់ព័ន្ធក្នុងនោះរួមមាន អ្នកមានអាណត្តិថ្មី ឬ ចប់អាណត្តិ ផងដែរ ។** ក្រុមពិគ្រោះយោបល់ ត្រូវបានជួយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ការតែងតាំងអ្នកមានអាណត្តិ

ដោយមានមូលដ្ឋាននៅលើអនុសាសន៍របស់ក្រុមពិគ្រោះយោបល់ និងបន្ទាប់ពីការពិគ្រោះយោបល់ដ៏ទូលំទូលាយ ប្រធានក្រុមប្រឹក្សា ធ្វើបញ្ជីរបស់គាត់ផ្ទាល់ ដែលកំណត់អំពីបេក្ខជនសមស្របសម្រាប់អាណត្តិទំនេរនីមួយៗ ។ បញ្ជីនេះ ត្រូវបានដាក់ស្នើសុំយោបល់ទៅសមាជិកក្រុមប្រឹក្សា និងរដ្ឋជាអ្នកសង្កេតការណ៍ក្នុងរយៈពេលយ៉ាងតិចបំផុតពីរសប្តាហ៍មុនវគ្គប្រជុំពេញអង្គ និងប្រសិនបើចាំបាច់ ប្រធាន នឹងធ្វើការពិគ្រោះយោបល់បន្ថែម ដើម្បីធានាថា បេក្ខជនរបស់គាត់ដែលបានស្នើឡើងនោះ ត្រូវបានគេយល់ព្រម ។ ដំណើរការតែងតាំង ត្រូវបានបញ្ចប់ ដោយមានការអនុម័តរបស់ក្រុមប្រឹក្សាលើបញ្ជីរបស់ប្រធាន ។

*i* **ទាំងបញ្ជីឈ្មោះបេក្ខជនរបស់ក្រុមពិគ្រោះយោបល់ និងប្រធាន** ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកយន្តការពិសេសនៃប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់ក្រុមប្រឹក្សា ។

## កិច្ចប្រជុំប្រចាំឆ្នាំ និងគណៈកម្មាធិការសម្របសម្រួលនៃយន្តការពិសេស

ចាប់តាំងតែឆ្នាំ ១៩៩៤ មក កិច្ចប្រជុំប្រចាំឆ្នាំរបស់អ្នកមានអាណត្តិនៃយន្តការពិសេស ដែលប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ត្រូវបានរៀបចំឡើងជាកិច្ចប្រជុំបន្តពី**សន្និសីទពិភពលោកក្រុងវីយែនស្តីពីសិទ្ធិមនុស្ស។ សេចក្តីប្រកាសក្រុងវីយែន និងកម្មវិធីសកម្មភាព** ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកនេះ បានដៅបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាការពារ និងពង្រឹងប្រព័ន្ធយន្តការពិសេស និងបញ្ជាក់ថា យន្តការពិសេស

គួរតែត្រូវបានជួយឲ្យអាចធ្វើសុខដុមនីយកម្ម និងសនិទានកម្មការងាររបស់ខ្លួនបាន តាមរយៈកិច្ចប្រជុំតាមដំណាក់កាល ។

**កិច្ចប្រជុំប្រចាំ ក៏ជាឱកាសមួយផងដែរសម្រាប់អ្នកមានអាណត្តិ ដើម្បីជួបប្រជុំ និងផ្លាស់ប្តូរទៅវិញទៅមកនូវមតិយោបល់ជាមួយនឹងរដ្ឋជាសមាជិក ការិយាល័យរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត និងតំណាងមកពីលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ និងទីភ្នាក់ងារ និងកម្មវិធីនានា លើបញ្ហា ដូចជា ការអនុវត្តបន្តនៃទស្សនកិច្ចបេសកកម្មប្រចាំប្រទេស និងអនុសាសន៍របស់គេ ។**

> ***i*** សម្រាប់ព័ត៌មានបន្ថែមស្តីពី**កិច្ចប្រជុំប្រចាំឆ្នាំរបស់យន្តការពិសេស** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

**គណៈកម្មាធិការសម្របសម្រួលនៃយន្តការពិសេស** ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទីដប់ពីររបស់អ្នកមានអាណត្តិនៃយន្តការពិសេសនៅក្នុងឆ្នាំ ២០០៥ ។ គណៈកម្មាធិការសម្របសម្រួលសម្រួលដល់ការសម្របសម្រួលរវាងអ្នកមានអាណត្តិ និងបំពេញតួនាទីជាស្ពានតភ្ជាប់យន្តការពិសេស និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រព័ន្ធសិទ្ធិមនុស្សដែលកាន់តែទូលំទូលាយរបស់អង្គការសហប្រជាជាតិ និងតួអង្គសង្គមស៊ីវិល ។

គណៈកម្មាធិការសម្របសម្រួល មានអ្នកមានអាណត្តិចំនួនប្រាំមួយរូប ដែលត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិមួយឆ្នាំ និងត្រូវបានធ្វើជាប្រធានដោយអ្នកមានអាណត្តិមួយរូបក្នុងចំណោមអ្នកមានអាណត្តិទាំងនោះ ។[59] ការបោះឆ្នោតជ្រើសរើសសមាជិករបស់គណៈកម្មាធិការសម្របសម្រួលនេះប្រព្រឹត្តទៅនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ និងពិចារណាទៅលើតម្រូវការឲ្យមានតុល្យភាពតំបន់ និងយេនឌ័រ និងតម្រូវការឲ្យមានការធ្វើជាតំណាងដោយមានតុល្យភាពគ្នានៃអ្នកមានអាណត្តិនៃយន្តការពិសេសប្រធានបទ និងប្រចាំប្រទេសនៅក្នុងគណៈកម្មាធិការនេះ ។ គណៈកម្មាធិការសម្របសម្រួល ត្រូវបានគាំទ្រនៅក្នុងការងាររបស់ខ្លួនដោយផ្នែកយន្តការពិសេសនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

> ***i*** សម្រាប់ព័ត៌មានបន្ថែមស្តីពី**គណៈកម្មាធិការសម្របសម្រួលនៃយន្តការពិសេស** ចូរចូលមើលវិបសាយរបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ។

[59] ប្រធានមុន នៅតែស្ថិតនៅក្នុងគណៈកម្មាធិការសម្រាប់មួយឆ្នាំបន្ថែមទៀតដោយសារតែតំណែង ។

# តើយន្តការពិសេស ធ្វើការងារដោយរបៀបណា ?

អ្នកមានអាណត្តិនៃយន្តការពិសេស មានឧបករណ៍មួយចំនួនដែលត្រូវបានរៀបចំឲ្យមាន សម្រាប់គេបំពេញលក្ខខណ្ឌនៃអាណត្តិរបស់គេ ក្នុងនោះរួមមានៈ

- ការបញ្ជូនឯកសារបណ្ដឹង ។
- ការទទួលធ្វើទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ។
- ការចេញផ្សាយរបាយការណ៍ ។
- ការរៀបចំការសិក្សាប្រធានបទ និង
- ការចេញសេចក្ដីប្រកាសព័ត៌មាន ។

អ្នកមានអាណត្តិ ក៏ត្រូវបានណែនាំផងដែរនៅក្នុងការងាររបស់គេ តាមរយៈ**ឯកសារណែនាំរបស់យន្តការពិសេស** និង**ក្រមសីលធម៌សម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស** ។

## ក. ក្រមសីលធម៌ និងឯកសារណែនាំរបស់យន្តការពិសេស

### ក្រមសីលធម៌សម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស

**ក្រមសីលធម៌សម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស** ត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងឆ្នាំ២០០៧ ។គោលបំណងរបស់វា គឺដើម្បីធ្វើឲ្យប្រព័ន្ធយន្តការពិសេសកាន់តែមានប្រសិទ្ធភាព ដោយកំណត់នូវស្តង់ដានៃការប្រព្រឹត្តប្រកបដោយសីលធម៌ និងការអនុវត្តផ្នែកវិជ្ជាជីវៈដែលអ្នកមានអាណត្តិនៃយន្តការពិសេស ត្រូវតែប្រតិបត្តិតាម នៅពេលអនុវត្តអាណត្តិរបស់ខ្លួន ។

### ឯកសារណែនាំរបស់យន្តការពិសេស

**ឯកសារណែនាំរបស់យន្តការពិសេស** ដែលត្រូវបានផលិតដោយអ្នកមានអាណត្តិនោះ មានគោលបំណងផ្តល់ការណែនាំដល់អ្នកមានអាណត្តិ ដើម្បីអនុវត្តតួនាទីរបស់គេ ។ វា ក៏ព្យាយាមសម្របសម្រួលឲ្យមានការយល់ដឹងកាន់តែល្អប្រសើរនូវការងាររបស់គេ របស់អ្នកពាក់ព័ន្ធផ្សេងទៀតទាំងអស់ផងដែរ ។ឯកសារណែនាំនេះ ព្យាយាមឆ្លុះបញ្ចាំងនូវវិធីអនុវត្តន៍ត្រឹមត្រូវ និងជួយអ្នកមានអាណត្តិនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់គេក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ។

ឯកសារណែនាំ ត្រូវបានអនុម័តជាលើកដំបូងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទីប្រាំមួយរបស់អ្នកមានអាណត្តិនៃយន្តការពិសេសនៅក្នុងឆ្នាំ ១៩៩៩ ។ ចាប់តាំងតែពេលនោះមក វាត្រូវបានធ្វើវិសោធនកម្មដើម្បី

ឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធ ដែលមានការផ្លាស់ប្តូរនៃក្បាលម៉ាស៊ីនដឹកនាំផ្នែកសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ហេតុការណ៍វិវត្តន៍ថ្មីៗទាក់ទងនឹងអាណត្តិ និងវិធីសាស្រ្តធ្វើការងារដែលមានការវិវត្តរបស់អ្នកមានអាណត្តិ ។ ចំពោះវិសោធនកម្មថ្មីបំផុតនៃឯកសារណែនាំនេះ ទិន្នន័យបញ្ចូល ត្រូវបានសុំពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ។ ឯកសារណែនាំនេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញតាមដំណាក់កាល និងធ្វើប្រតិបត្តិការ ស្របទៅតាមបទប្បញ្ញត្តិនៃក្រមសីលធម៌ ។

> **i**
> សម្រាប់ព័ត៌មានបន្ថែមស្តីពី**ឯកសារណែនាំរបស់យន្តការពិសេស**
> ចូរចូលមើលទំព័ររបស់វានៅក្នុង ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់យន្តការពិសេស ។

## ខ. ឯកសារបណ្តឹង

សកម្មភាពសំខាន់បំផុតមួយក្នុងចំណោមសកម្មភាពសំខាន់បំផុតជាច្រើន របស់អ្នកមានអាណត្តិនៃយន្តការពិសេស គឺការអនុវត្តវិធានការលើករណីជាលក្ខណៈបុគ្គល ដោយមានមូលដ្ឋាននៅលើព័ត៌មានដែលគេទទួលបានពីប្រភពពាក់ព័ន្ធ និងគួរឲ្យជឿបាន (ភាគច្រើន គួរអង្គសង្គមស៊ីវិល) ។

ជាទូទៅ បទអន្តរាគមន៍ ជំរុញឲ្យមានការពាក់ព័ន្ធនឹងការផ្ញើលិខិតទៅរដ្ឋាភិបាល (លិខិតទឡ្ហីករណ៍) ដោយស្នើសុំព័ត៌មាន និងចម្លើយតបទៅនឹងទឡ្ហីករណ៍ និងក្នុងករណីចាំបាច់ ស្នើសុំរដ្ឋាភិបាលឲ្យអនុវត្តវិធានការទប់ស្កាត់ ឬ ស៊ើបអង្កេត (សេចក្តីអំពាវនាវបន្ទាន់) ។ បទអន្តរាគមន៍ទាំងនេះ ត្រូវបានគេដឹងថាជា "**ឯកសារបណ្តឹង**" ។

| |
|---|
| **ឯកសារបណ្តឹង**នៅក្នុងឆ្នាំ ២០០៧ |
| ឯកសារបណ្តឹងសរុបចំនួន **១.០០៣** ត្រូវបានផ្ញើចេញនៅក្នុងឆ្នាំ ២០០៧ ។ |
| **៤៩ ភាគរយ**នៃឯកសារបណ្តឹងទាំងនេះ គឺជាសេចក្តីថ្លែងការណ៍រួម ។ |
| ករណីជាលក្ខណៈបុគ្គលចំនួន **២.២៩៤** ត្រូវបានរួមបញ្ចូល ។ **១៣ ភាគរយ**នៃករណីជាលក្ខណៈបុគ្គលទាំងនេះ បានពាក់ព័ន្ធនឹងស្ត្រី ។ |
| រដ្ឋាភិបាល បានឆ្លើយតបទៅនឹងឯកសារបណ្តឹងចំនួន **៥២ ភាគរយ** ។ |
| ប្រទេសសរុបចំនួន **១២៨** បានទទួលបានឯកសារបណ្តឹង ។ |

**សេចក្តីអំពាវនាវបន្ទាន់** ត្រូវបានផ្ញើចេញ នៅពេលដែលការរំលោភបំពានដែលមានទឡ្ហីករណ៍ មានផលប៉ះពាល់នៃការប្រែប្រួលពេលវេលាចំពោះការជំរុញឲ្យមានការពាក់ព័ន្ធនឹងការបាត់បង់ជីវិត ស្ថានភាពគំរាមកំហែងអាយុជីវិត ឬ ការខូចខាតដែលបម្រុងនឹងកើតមានឡើង ឬ កំពុងតែបន្តនៃប្រភេទធ្ងន់ធ្ងរខ្លាំងចំពោះជនរងគ្រោះ ។ **លិខិតទឡ្ហីករណ៍** ត្រូវបានផ្ញើចេញនៅពេលដែលនីតិវិធីនៃការអំពាវនាវបន្ទាន់ មិនអាចប្រើប្រាស់បានដើម្បីផ្តល់ព័ត៌មាននិងស្នើសុំការបំភ្លឺអំពីការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍។

អ្នកមានអាណត្តិ អាចធ្វើចេញនូវសេចក្តីថ្លែងការណ៍រួម នៅពេលដែលករណី ស្ថិតនៅក្នុងវិសាលភាពដែលមានអាណត្តិច្រើនជាងមួយ ។ ការសម្រេចចិត្តថាតើត្រូវធ្វើអន្តរាគមន៍ជាមួយនឹងរដ្ឋាភិបាលឬអត់ ត្រូវបានទុកឲ្យស្ថិតនៅលើការសម្រេចចិត្តរបស់អ្នកមានអាណត្តិនៃយន្តការពិសេស ហើយនឹងពឹងផ្អែកទៅលើលក្ខណវិនិច្ឆ័យដែលត្រូវបានកំណត់ដោយអ្នកមានអាណត្តិ នៃយន្តការពិសេសទាំងនេះ ក៏ដូចជាលក្ខណវិនិច្ឆ័យ ដែលត្រូវបានចែងនៅក្នុងក្រមសីលធម៌ ។ អ្នកមានអាណត្តិ ក៏ត្រូវបានតម្រូវឲ្យពិចារណាដោយទូលំទូលាយ និងទាន់ពេលវេលាផងដែរ លើព័ត៌មានដែលត្រូវបានផ្តល់ដោយរដ្ឋដែលពាក់ព័ន្ធ ស្តីពីស្ថានភាពពាក់ព័ន្ធទៅនឹងអាណត្តិរបស់គេ ។

នៅក្នុងសកម្មភាពប្រមូលព័ត៌មានរបស់ខ្លួន អ្នកមានអាណត្តិ ត្រូវតែ:

- បានណែនាំ តាមរយៈគោលការណ៍នៃឆន្ទានុសិទ្ធិ តម្លាភាព អនាគតិ និងសមធម៌ ។
- រក្សាការសម្ងាត់ចំពោះប្រភពនៃសក្ខីកម្ម ប្រសិនបើការបកអាក្រាតប្រភពនៃសក្ខីកម្មទាំងនេះ អាចបង្កអន្តរាយដល់បុគ្គលដែលពាក់ព័ន្ធ ។
- ពឹងពាក់ទៅលើទិសដៅ និងអង្គហេតុដែលអាចទុកចិត្តបាន ដោយមានមូលដ្ឋាននៅលើស្តង់ដានៃភស្តុតាងដែលសមស្របទៅនឹងលក្ខណៈមិនមែនផ្លូវតុលាការនៃរបាយការណ៍ និងសេចក្តីសន្និដ្ឋានដែលគេ ត្រូវបានតម្រូវឲ្យសរសេរនោះ និង
- ផ្តល់ដល់តំណាងរបស់រដ្ឋដែលពាក់ព័ន្ធនូវឱកាសធ្វើសេចក្តីសង្កេតលើការវាយតម្លៃ និងឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលត្រូវបានផ្តល់ប្រឆាំងនឹងរដ្ឋនោះ ។ ចម្លើយតបសង្ខេបជាលាយលក្ខណ៍អក្សររបស់រដ្ឋ ក៏ត្រូវបានបញ្ចូលជាឧបសម្ព័ន្ធនៃរបាយការណ៍របស់អ្នកមានអាណត្តិមួយ (ច្រើន) ផងដែរ ។

## គ. ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស

**ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ឬ ដល់មូលដ្ឋាន** (ឬ បេសកកម្មស្វែងរកការពិត) គឺជាឧបករណ៍ដ៏សំខាន់ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់អ្នកមានអាណត្តិនៃយន្តការពិសេស ។ អ្នកមានអាណត្តិ ជាតួយ៉ាង ផ្ញើលិខិតទៅកាន់រដ្ឋាភិបាល ដោយស្នើសុំធ្វើទស្សនកិច្ចទៅកាន់ប្រទេសនោះ និងប្រសិនរដ្ឋាភិបាលយល់ព្រម លិខិតអញ្ជើញធ្វើទស្សនកិច្ចបេសកកម្ម ត្រូវបានប្រគល់ជូន ។ ប្រទេសខ្លះ បានចេញ "**លិខិតអញ្ជើញបើកចំហ**" ដែលមានន័យថា ជាគោលការណ៍ គេ ត្រូវបានរៀបចំត្រៀមទទួលទស្សនកិច្ចបេសកកម្មពីអ្នកមានអាណត្តិនៃយន្តការពិសេសណាមួយ ។ ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ត្រូវបានណែនាំតាមរយៈបទប្បញ្ញត្តិដែលត្រូវបានចែងនៅក្នុងក្រមសីលធម៌ និង**លក្ខខណ្ឌយោងការងារសម្រាប់បេសកកម្មស្វែងរកការពិតដោយយន្តការពិសេស** ។[60]

> *i*
>
> **នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ រដ្ឋចំនួនជាង ៦០ បានចេញលិខិតអញ្ជើញបើកចំហ ។**
> ដើម្បីមើលបញ្ជីថ្មីដែលមានឈ្មោះរដ្ឋដែលបានចេញ**លិខិតអញ្ជើញបើកចំហ**ទៅយន្តការពិសេស ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

---

[60] លក្ខខណ្ឌយោងការងារ (លេខ E/CN.4/1998/45) សម្រាប់ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទីបួន (ឆ្នាំ ១៩៩៧) របស់យន្តការពិសេស និងត្រូវបានរៀបចំ ដើម្បីណែនាំរដ្ឋាភិបាលនៅក្នុងការបំពេញទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ។

ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស អនុញ្ញាតឲ្យអ្នកមានអាណត្តិវាយតម្លៃស្ថានភាពទូទៅនៃសិទ្ធិមនុស្ស និង/ឬ ស្ថានភាពស្ថាប័ន ផ្លូវច្បាប់ ផ្លូវតុលាការ និងរដ្ឋបាលជាក់លាក់នៅក្នុងរដ្ឋណាមួយ ក្រោមអាណត្តិរៀងៗខ្លួនរបស់គេ ។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចទាំងនេះ គេជួបប្រជុំជាមួយនឹងអាជ្ញាធរជាតិ តំណាងរបស់សង្គមស៊ីវិល ជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស ក្រុមទីភ្នាក់ងារប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ អ្នកសិក្សាជាន់ខ្ពស់ សហគមន៍អ្នកការទូត និងប្រព័ន្ធផ្សព្វផ្សាយ ។

ដោយផ្អែកលើលទ្ធផលរកឃើញរបស់គេ គេផ្តល់អនុសាសន៍តាមរយៈរបាយការណ៍ជាសាធារណៈ ។ របាយការណ៍ទាំងនេះ ត្រូវបានដាក់ជូនពិនិត្យទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ អ្នកមានអាណត្តិខ្លះ ក៏បានរៀបចំសន្និសីទសារព័ត៌មាន និងចេញលទ្ធផលរកឃើញដំបូងនៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេសនេះ ។ ជោគជ័យនៃទស្សនកិច្ចបេសកកម្មប្រចាំប្រទេសនេះ ត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងច្រើន តាមរយៈ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងការចូលរួមរបស់តួអង្គសង្គមស៊ីវិលមុន ក្នុងអំឡុងពេល និងក្រោយដំណើរទស្សនកិច្ចបេសកកម្មនេះ ដើម្បីគាំទ្រដល់ការងាររបស់អ្នកមានអាណត្តិ ។

## ឃ. ការធ្វើសេចក្តីរាយការណ៍ និងការរួមចំណែកដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

អ្នកមានអាណត្តិនៃយន្តការពិសេស ត្រូវបានស្នើសុំដោយក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំដែលនៅក្នុងនោះ គេពិពណ៌នាអំពីសកម្មភាពដែលត្រូវបានទទួលអនុវត្ត នៅក្នុងអំឡុងឆ្នាំមុនៗ ។ នៅក្នុងកាលៈទេសៈខ្លះ ក្រុមប្រឹក្សា ក៏អាចស្នើសុំផងដែរដល់អ្នកមានអាណត្តិឲ្យធ្វើសេចក្តីរាយការណ៍អំពីផ្ទៃរឿង ឬ ប្រធានបទជាក់លាក់ដែលមានផលប្រយោជន៍ចំពោះខ្លួន ។ របាយការណ៍ មានលក្ខណៈទូទៅ និងធ្វើជាតំណាងឲ្យឧបករណ៍អាជ្ញាព្រឹត្តសម្រាប់ការអនុវត្តបន្ត ឬ ការតស៊ូមតិនៅក្នុងវិស័យនៃអាណត្តិនេះ ។

របាយការណ៍ប្រចាំឆ្នាំ មានព័ត៌មានស្តីពីវិធីសាស្ត្រធ្វើការងារ ការវិភាគទ្រឹស្តី និន្នាការទូទៅ និងហេតុការណ៍វិវត្តន៍ថ្មីៗ ទាក់ទងនឹងអាណត្តិ និងអាចមានអនុសាសន៍ទូទៅ ។ របាយការណ៍ ក៏មានផងដែរនូវខ្លឹមសារសង្ខេបនៃឯកសារបណ្តឹងដែលត្រូវបានបញ្ជូនទៅរដ្ឋាភិបាល និងចម្លើយតបដែលត្រូវបានទទួល ។ តាមធម្មតា របាយការណ៍ស្តីពីទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ត្រូវបានដាក់ស្នើយោបល់ជាអត្ថបទបន្ថែមភ្ជាប់ទៅនឹងរបាយការណ៍ប្រចាំឆ្នាំ ។ យន្តការខ្លះ ត្រូវបានស្នើសុំឲ្យធ្វើសេចក្តីរាយការណ៍ជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិ ដែលជួបប្រជុំនៅទីក្រុងញូវយ៉កចាប់ពីខែ កញ្ញា ដល់ខែ ធ្នូ រៀងរាល់ឆ្នាំ ។

អ្នកមានអាណត្តិនៃយន្តការពិសេស ក៏រួមចំណែកជាជំនាញផងដែរដល់ទិដ្ឋភាពផ្សេងទៀតនៃការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

> *i* ដើម្បីទទួលបាន**របាយការណ៍របស់យន្តការពិសេសជូនទៅក្រុមប្រឹក្សា** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## វគ្គប្រជុំពេញអង្គពិសេសស្ដីពីវិបត្តិស្បៀងពិភពលោក

នៅក្នុងខែ ឧសភា ឆ្នាំ ២០០៨ **អ្នករាយការណ៍ពិសេស ស្ដីពីសិទ្ធិមានស្បៀង អាហារគ្រប់គ្រាន់** គឺលោក អូលីវីយេដឺស្កាត់ធើ បានអំពាវនាវសុំឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្ស រៀបចំវគ្គប្រជុំពេញអង្គពិសេស ស្ដីពីវិបត្តិស្បៀងពិភពលោក ។ នៅក្នុងការឆ្លើយតប ក្រុមប្រឹក្សា បានរៀបចំវគ្គប្រជុំពេញអង្គពិសេស "ស្ដីពីឥទ្ធិពលអវិជ្ជមានលើការសម្រេចបានសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ដែលធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងនូវវិបត្តិស្បៀងពិភពលោក ដែលត្រូវបានបណ្ដាលមកពី ក្នុងចំណោមកត្តាផ្សេងទៀត ដោយតម្លៃស្បៀងដ៏ខ្ពស់ខ្លាំង" នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ។

អ្នករាយការណ៍ពិសេស លើសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ បានចូលរួម និងចូលរួមពាក់ដោយសកម្មនៅក្នុងវគ្គប្រជុំពេញអង្គពិសេស ដែលជាវគ្គប្រជុំពេញអង្គលើកទីមួយដែលត្រូវបានរៀបចំឡើង ដោយផ្ដោតលើបញ្ហាប្រធានបទ ។

## ខ. ការសិក្សាប្រធានបទ

អ្នកមានអាណត្តិនៃយន្តការពិសេស ក៏អាចរៀបចំផងដែរនូវការសិក្សាប្រធានបទ ដែលជាឧបករណ៍ដ៏មានប្រយោជន៍ ដើម្បីណែនាំដល់រដ្ឋាភិបាល ក៏ដូចជា សង្គមស៊ីវិល លើខ្លឹមសារធម្មនិយាម និងការអនុវត្តបទដ្ឋាន និងស្តង់ដាសិទ្ធិមនុស្ស ។ អ្នកមានអាណត្តិ ក៏ធ្វើជាម្ចាស់ផ្ទះ និងចូលរួមផងដែរនៅក្នុងកិច្ចប្រជុំមន្ត្រីជំនាញលើបញ្ហាប្រធានបទសិទ្ធិមនុស្ស ។

### សិក្ខាសាលាមន្ត្រីជំនាញ - ការពង្រឹងការការពារស្ត្រីភេទពីការធ្វើទារុណកម្ម

នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៧ សិក្ខាសាលាមន្ត្រីជំនាញ ស្តីពី "ការពង្រឹងកិច្ចការពារស្ត្រីភេទពីការធ្វើទារុណកម្ម" ត្រូវបានរៀបចំ ឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងនាម**អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ឬ ការដាក់ទណ្ឌកម្មផ្សេងទៀត** ក្នុងបំណងរួមចំណែកដល់ការអនុវត្ត ដែលមានលក្ខណៈជាប្រព័ន្ធកាន់តែច្រើនឡើងនៃក្របខ័ណ្ឌអន្តរជាតិស្តីពីការធ្វើទារុណកម្មចំពោះកង្វល់របស់ស្ត្រី និង ពង្រឹងកិច្ចការពារពួកគេ ។ មន្ត្រីជំនាញចំនួនម្ភៃប្រាំរូបមកពីតំបន់ខុសៗគ្នា និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាលដ៏ច្រើនសន្ធឹកសន្ធាប់ (ក្នុងនោះរួម មានយន្តការប្រឆាំងនឹងការធ្វើទារុណកម្ម ប្រចាំតំបន់ និងនៃអង្គការសហប្រជាជាតិផងដែរ) បានចូលរួមនៅក្នុងកិច្ចពិភាក្សា ។

## ច. សេចក្តីប្រកាសព័ត៌មាន

យន្តការពិសេស អាចជាលក្ខណៈបុគ្គល ឬជារួម ចេញសេចក្តីប្រកាសព័ត៌មាន ដោយរំលេចស្ថានភាពជាក់លាក់ ឬ បទដ្ឋានអន្តរជាតិ ដែលត្រូវបានគោរពដោយរដ្ឋនានា ។

i

ច្បាប់ចម្លងនៃ**សេចក្តីប្រកាសព័ត៌មាន**ទាំងអស់ **សេចក្តីថ្លែងការណ៍ និងសារផ្សេងទៀត ដែលត្រូវបានចេញដោយយន្តការពិសេស** ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែកយន្តការពិសេសនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

# វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹងយន្តការពិសេស

*"សង្គមស៊ីវិល និយាយជារួម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ តំបន់ និងជាតិ និយាយដោយឡែក ផ្តល់ការគាំទ្រដែលមិនអាចកាត់ថ្លៃបានដល់ប្រព័ន្ធយន្តការពិសេស ។ គេ ផ្តល់ព័ត៌មាន និងការវិភាគ ជួយផ្សព្វផ្សាយលទ្ធផលរកឃើញរបស់យន្តការពិសេស និងជួយដល់សកម្មភាពអនុវត្តបន្ត និងហេតុដូច្នេះ ក៏ជួយរៀបចំ និងអនុវត្តផងដែរនូវគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធសម្រាប់ការអប់រំសិទ្ធិមនុស្ស ដើម្បីកែលម្អស្ថានភាពនៃបញ្ហា ដែលស្ថិតនៅក្រោមយន្តការពិសេស ។ ការជួបប្រជុំជាមួយនឹងតំណាងរបស់គេ មានលក្ខណៈសមស្របនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការងាររបស់យន្តការពិសេស ក្នុងនោះរួមមាន នៅក្នុងសកម្មភាពរបស់គេនៅក្នុងទីក្រុងហ្សឺណែវ និងញូវយ៉កផងដែរ នៅក្នុងបេសកកម្មដល់មូលដ្ឋាន និងដោយ*

*កាន់តែមានលក្ខណៈទូទៅ ។ ហេតុដូច្នេះ វា សមស្របសម្រាប់អ្នកមានអាណត្តិ ធ្វើការពិចារណាដោយហ្មត់ចត់ និងទាន់ពេលវេលា លើលិខិតអញ្ជើញរបស់អង្គការមិនមែនរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សាអប់រំ ដើម្បីចូលរួមនៅក្នុងសកម្មភាពនានា ដូចជា សន្និសីទ កិច្ចពិភាក្សាវែកញែក សិក្ខាសាលា និងកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ ។ ជាទូទៅ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គួរតែត្រូវបានបន្តផ្តល់នូវព័ត៌មានស្តីពីសកម្មភាពពាក់ព័ន្ធរបស់អ្នកមានអាណត្តិ ដោយហេតុថា វាពាក់ព័ន្ធនឹងសង្គមស៊ីវិល" ។*

## ឯកសារណែនាំប្រតិបត្តិការរបស់យន្តការពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (**គ្រប់កថាខ័ណ្ឌទី ១៣៣**) ។

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ យន្តការពិសេស បានបង្កើតទំនាក់ទំនង និងបានធ្វើសហប្រតិបត្តិការជាមួយនឹងតួអង្គសង្គមស៊ីវិលផ្សេងៗ ។ យន្តការពិសេស បានជួយដល់គេក្នុងការផ្តល់កិច្ចការពារដល់ជនរងគ្រោះពិតជាក់ស្តែង ឬ ជាសក្តានុពល និងបានរួមចំណែកនៅក្នុងការផ្តល់សិទ្ធិអំណាចដល់ពួកគេ។ អាណត្តិខុសៗគ្នា បានបង្កើតទម្រង់ខុសៗគ្នានៃការចូលរួម និងការសហការ ។

បន្ទាប់មកទៀត ប្រសិទ្ធភាពនៃប្រព័ន្ធយន្តការពិសេសក្នុងកិច្ចការពារសិទ្ធិមនុស្ស និងការទប់ស្កាត់ការរំលោភបំពាន ក៏ពឹងពាក់ទៅលើការចូលរួមពាក់ព័ន្ធដ៏សកម្មរបស់តួអង្គសិទ្ធិមនុស្សផ្សេងទៀត ក្នុងនោះរួមមានសង្គមស៊ីវិល ផងដែរ ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ តំបន់ និងជាតិ និងតួអង្គសង្គមស៊ីវិលផ្សេងទៀត គឺជាអ្នកចូលរួមដែលមានលក្ខណៈសំខាន់ជាសារវន្តនៅក្នុងប្រព័ន្ធយន្តការពិសេស ។ ជាងនេះទៀត សង្គមស៊ីវិល បានស្ថិតនៅទីតាំងជួរមុខនៃការបង្កើតស្តង់ដាសិទ្ធិមនុស្ស និងការតស៊ូមតិដើម្បីបង្កើតអាណត្តិថ្មីជាយូរមកហើយ ។

ប្រភេទនៃតួអង្គសង្គមស៊ីវិល ដែលចូលរួមជាមួយនឹងយន្តការពិសេស រួមមានៈ

- អង្គការសិទ្ធិមនុស្ស (អង្គការមិនមែនរដ្ឋាភិបាល សមាគម ក្រុមជនរងគ្រោះ) ។
- អ្នកការពារសិទ្ធិមនុស្ស ។
- អង្គការដែលមានមូលដ្ឋាននៅលើបញ្ហាពាក់ព័ន្ធ ។
- សម្ព័ន្ធភាពចម្រុះ និងបណ្តាញ (សិទ្ធិរបស់ស្ត្រី សិទ្ធិរបស់កុមារ សិទ្ធិរបស់ក្រុមជនភាគតិច សិទ្ធិផ្នែកបរិស្ថាន) ។
- ជនពិការ និងអង្គការតំណាងរបស់ពួកគេ ។
- ក្រុមដែលមានមូលដ្ឋាននៅក្នុងសហគមន៍ (ជនជាតិដើមភាគតិច ក្រុមជនភាគតិច) ។
- ក្រុមដែលមានមូលដ្ឋាននៅលើសាសនា (វិហារសាសនាគ្រឹះ ក្រុមសាសនា) ។
- សហភាព (សហជីព ក៏ដូចជា សមាគមអ្នកអាជីព ដូចជា សមាគមអ្នកកាសែត គណៈមេធាវី សមាគមចៅក្រម សហជីពនិស្សិត) ។
- ចលនាសង្គម (ចលនាសន្តិភាព ចលនានិស្សិត ចលនាគាំទ្រប្រជាធិបតេយ្យ) ។

- អ្នកវិជ្ជាជីវៈ ដែលរួមចំណែកដោយផ្ទាល់ដល់ការទទួលបានសិទ្ធិមនុស្ស (មន្ត្រីផ្នែកមនុស្សធម៌ អ្នកច្បាប់ វេជ្ជបណ្ឌិត និងមន្ត្រីសុខាភិបាល) ។
- សាច់ញាតិរបស់ជនរងគ្រោះ និង
- ស្ថាប័នសាធារណៈ ដែលរួមបញ្ចូលសកម្មភាព ដែលត្រូវបានចាត់ជាគោលបំណងនូវការលើកកម្ពស់សិទ្ធិមនុស្ស (សាលារៀន សកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ) ។




**តួអង្គសង្គមស៊ីវិល ដោយឡែកពីគ្នា ឬ ជារួម អាចប្រើប្រាស់ និងធ្វើការងារជាមួយនឹងយន្តការពិសេស ។ មិនដូចស្ថាប័ន សន្ធិសញ្ញានៃអង្គការសហប្រជាជាតិទេ យន្តការពិសេស អាចត្រូវបានដាស់តឿនសូម្បីតែក្នុងករណីរដ្ឋ មិនបានផ្តល់សច្ចាប័នលើលិខិតុបករណ៍ ឬ សន្ធិសញ្ញាដែលពាក់ព័ន្ធក្តី និងវាមិនចាំបាច់ប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុកទើបប្រើប្រាស់យន្តការពិសេសនោះទេ ។ ហេតុដូច្នេះ យន្តការពិសេសអាចត្រូវបានប្រើប្រាស់សម្រាប់ប្រទេស ឬ បញ្ហាសិទ្ធិមនុស្សណាមួយ នៅក្នុងកត្តាកំណត់នៃអាណត្តិដែលមានស្រាប់ ។**

តួអង្គសង្គមស៊ីវិល អាចរួមចំណែកដល់ការងាររបស់យន្តការពិសេស ដោយៈ

- ការដាក់ជូនពិនិត្យនូវទឡ្ហីករណ៍ជាលក្ខណៈបុគ្គល នៃការរំលោភបំពានសិទ្ធិមនុស្សទៅអ្នកមានអាណត្តិនៃយន្តការពិសេសដែលពាក់ព័ន្ធមួយ (ឬ ច្រើន) ។
- ការផ្តល់ការគាំទ្រដល់ដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស និងព័ត៌មាន និងការវិភាគលើការរំលោភបំពានលើសិទ្ធិមនុស្ស ទៅអ្នកមានអាណត្តិនៃយន្តការពិសេសផ្សេងៗគ្នា ។
- ការអនុវត្តតួនាទីទប់ស្កាត់ ដោយផ្តល់ព័ត៌មានដល់យន្តការពិសេសលើការណែនាំឲ្យប្រើប្រាស់ច្បាប់ថ្មីដែលអាចនាំទៅដល់ការរំលោភបំពានលើសិទ្ធិមនុស្ស ។

- ការអនុវត្តបន្តនូវអនុសាសន៍របស់យន្តការពិសេសនៅថ្នាក់មូលដ្ឋាន និងជាតិ ។ កាន់តែទូលំទូលាយថែមទៀតនោះ សង្គមស៊ីវិលអាចគាំទ្រដល់ការផ្សព្វផ្សាយការងារ និងលទ្ធផលរកឃើញរបស់អ្នកមានអាណត្តិនៃយន្តការពិសេសនៅក្នុងក្រុមគាំទ្រផ្នែកនយោបាយរបស់ខ្លួន ។

ទំនាក់ទំនងដែលសំខាន់ជាសារវន្ត រវាងយន្តការពិសេស និងសង្គមស៊ីវិល ត្រូវបានបង្ហាញនៅក្នុងអាណត្តិរបស់**អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស** ។

# អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស

**តើនរណា ជាអ្នករាយការណ៍ពិសេស ស្តីពី ស្ថានភាពអ្នកការពារសិទ្ធិមនុស្ស?**

អាណត្តិរបស់**អ្នករាយការណ៍ពិសេសលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស** (ដោយពីមុនគឺជា តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស) ត្រូវបានបង្កើតឡើងជាយន្តការ ពិសេសនៅក្នុងឆ្នាំ ២០០០ ដោយ **សេចក្តីសម្រេចចិត្តលេខ 2000/61** របស់គណៈកម្មការសិទ្ធិមនុស្ស ។ ការបង្កើតឡើងនូវអាណត្តិនេះ ទទួលស្គាល់នូវតួនាទីដ៏សំខាន់ជាសារវន្ត និងជារឿយៗប្រកបដោយគ្រោះថ្នាក់របស់អ្នកការពារសិទ្ធិមនុស្សនៅជុំវិញពិភពលោក ។ "កិច្ចការពារ" អ្នកការពារសិទ្ធិមនុស្សគឺជាកង្វល់ចម្បងជាងគេរបស់អ្នករាយការពិសេស ។ វា ត្រូវបានគេយល់ថាបានបញ្ចូលទាំងកិច្ចការពារអ្នកការពារ និងកិច្ចការពារសិទ្ធិក្នុងកិច្ចការពារសិទ្ធិមនុស្ស ។ តួនាទីសំខាន់បំផុតរបស់អ្នករាយការណ៍ពិសេស គឺត្រូវតែៈ

- ស្វែងរក ទទួល ត្រួតពិនិត្យ និងឆ្លើយតបទៅនឹងព័ត៌មានស្តីពីស្ថានភាព និងសិទ្ធិរបស់មនុស្សណាម្នាក់ ដោយខិតខំដោយឡែកពីគ្នា ឬ ចូលរួមជាមួយនឹងអ្នកផ្សេងទៀត ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។
- បង្កើតកិច្ចសហប្រតិបត្តិការ និងរៀបចំកិច្ចសន្ទនាជាមួយនឹងរដ្ឋាភិបាល និងតួអង្គដែលបានចាប់អារម្មណ៍ផ្សេងទៀតលើការលើកកម្ពស់ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ**សេចក្តីប្រកាសស្តីពី សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការផ្នែកនៃសង្គម ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសក-ល** (ដែលត្រូវបានគេដឹងជាទូទៅថាជា "សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស") និង
- ផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីការពារឲ្យបានកាន់តែល្អប្រសើរនូវអ្នកការពារសិទ្ធិមនុស្ស និងតាមដានបន្តនូវអនុសាសន៍ទាំងនេះ ។

**ដូចម្តេចដែលហៅថា អ្នកការពារសិទ្ធិមនុស្ស ?**

អ្នកការពារសិទ្ធិមនុស្ស គឺជាមនុស្សណាម្នាក់ដែលជាបុគ្គល ឬ ដោយចូលរួមជាមួយនឹងអ្នកផ្សេងទៀត ជាប់រវល់នឹងការលើកកម្ពស់ ការពារ និងសម្រេចបាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ ។ អ្នកការពារសិទ្ធិមនុស្ស ត្រូវតែទទួលយកសកលភាពនៃសិទ្ធិមនុស្ស ដូចដែលបានកំណត់នៅក្នុង**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ។ មនុស្សមិនអាចបដិសេធសិទ្ធិមនុស្សខ្លះបានទេ ទោះបីជា ដូច្នោះក៏ដោយ ក៏ទាមទារសុំធ្វើជាអ្នកការពារសិទ្ធិមនុស្ស ដោយហេតុថាគេតស៊ូមតិ ដើម្បីអ្នកដទៃ ។

**តើតួអង្គសង្គមស៊ីវិល ជាអ្នកការពារសិទ្ធិមនុស្ស ដែរឬទេ ?**

បុគ្គលិក និងអ្នកស្ម័គ្រចិត្តជាតិ និងអន្តរជាតិ ដែលបម្រើការងារឲ្យសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន ឬ សមាគមដែលដោះស្រាយកង្វល់ផ្នែកសិទ្ធិមនុស្សនៅជុំវិញពិភពលោក អាចត្រូវបានពិពណ៌នាថាជាអ្នកការពារសិទ្ធិមនុស្ស ។

**តើសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស គឺជាអ្វី ?**

ដោយត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៩៨ នោះ សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិ

មនុស្ស កំណត់យក "កិច្ចការពារ" សិទ្ធិមនុស្សជាសិទ្ធិនោះឯង និងទទួលស្គាល់ បុគ្គលដែលទទួលធ្វើការងារសិទ្ធិមនុស្សជា "អ្នកការពារសិទ្ធិមនុស្ស" ។ សេចក្តីប្រកាសនេះ អនុញ្ញាតឲ្យមានការគាំទ្រ និងកិច្ចការពារអ្នកការពារសិទ្ធិមនុស្សនៅក្នុងបរិបទនៃការងាររបស់ពួកគេ ។ សេចក្តីប្រកាសនេះ មិនបង្កើតសិទ្ធិថ្មី ប៉ុន្តែជាជំនួស វែកញែកសិទ្ធិដែលមានស្រាប់ តាមរបៀបមួយដែលធ្វើឲ្យវាមានលក្ខណៈកាន់តែងាយស្រួលក្នុងការអនុវត្តសិទ្ធិដែលមានស្រាប់ទាំងនោះចំពោះតួនាទី និងស្ថានភាពជាក់ស្តែងរបស់អ្នកការពារសិទ្ធិមនុស្ស ។

តួនាទីសំខាន់របស់អ្នករាយការណ៍ពិសេស គឺត្រូវតែរាយការណ៍អំពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សនៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក និងមធ្យោបាយ ដែលអាចមានដើម្បីបង្កើនកិច្ចការពារដោយប្រតិបត្តិតាម ដោយពេញលេញទៅនឹងសេចក្តីប្រកាសនេះ ។

**វិធីទាក់ទងនឹងយន្តការពិសេស ឬដាក់ជូនពិនិត្យនូវទឡ្ហីករណ៍ស្តីពីការរំលោភបំពានលើរូបអ្នកការពារសិទ្ធិមនុស្ស**

តួអង្គសង្គមស៊ីវិល អាចទាក់ទងនឹងយន្តការពិសេសទៅតាមអាសយដ្ឋានដូចខាងក្រោម (ចូរកត់សម្គាល់ថា លិខិតទាក់ទងគួរតែរៀបចំយោងដោយច្បាស់លាស់ទៅនឹងអាណត្តិរបស់អ្នកការពារសិទ្ធិមនុស្ស)៖

**អ្នករាយការណ៍ពិសេសរបស់ស្ថានភាព អ្នកការពារសិទ្ធិមនុស្ស**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ-មនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10
អ៊ីម៉ែល:
ដើម្បីដាក់ជូនពិនិត្យនូវទឡ្ហីករណ៍ស្តីពីការរំលោភបំពានៈ
**urgent-action@ohchr.org**
ដើម្បីទាក់ទងនឹងអ្នកមានអាណត្តិសម្រាប់គោលបំណង ផ្សេងទៀត
**defenders@ohchr.org**

ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ០៦
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ១២ ៣៤

- នេះ គឺជាលេខទូរស័ព្ទរបស់ប្រព័ន្ធបញ្ជាទូរស័ព្ទកណ្តាលរបស់អង្គការសហប្រជាជាតិនៅក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស ។

អ្នកហៅទូរស័ព្ទ គួរតែស្នើសុំនិយាយជាមួយនឹងបុគ្គលិកនៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលធ្វើការដោះស្រាយជាមួយនឹងយន្តការពិសេស និងដោយជាក់លាក់នោះ ជាមួយនឹងបុគ្គលិកដែលគាំទ្រអាណត្តិរបស់អ្នករាយពិសេសលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស ។

## ស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស

នៅក្នុងឆ្នាំ ២០០២ តំណាងពិសេសនៅពេលនោះ របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកដែលប្រមូលផ្តុំមន្ត្រីជំនាញផ្នែកយេនឌ័រដ៏សំខាន់បំផុត និងស្ត្រីជាអ្នកការពារសិទ្ធិមនុស្សមកពីប្រទេសជាង ៧០ ។

នៅក្នុងអាណត្តិការងាររបស់អ្នកស្រី អ្នកស្រីតំណាងពិសេសបានលើកបញ្ហាក់ឡើងវិញ ដោយមានសង្កតិភាពថា ស្ត្រីជាអ្នកការពារប្រឈមនឹងហានិភ័យនៃអំពើហិង្សា និងការកំហិតលក្ខខណ្ឌស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស អ្នកស្រី ហ៊ីនដាជីឡានី បានដឹកនាំយុទ្ធនាការអន្តរជាតិ រយៈពេលបីឆ្នាំដែលឡើងដល់ជាទម្រង់ខ្លះ និងបានក្លាយជាងាយរងគ្រោះដោយសារបុរេនិច្ឆ័យ អបរិយាប័ន្ន និងការបដិសេធមិនទទួលយក ដោយកងកម្លាំងរដ្ឋ និងតួអង្គសង្គម ជាពិសេស នៅពេលដែលរវល់នឹងកិច្ចការពារសិទ្ធិរបស់ស្ត្រី ។[61] អ្នកស្រីតំណាងពិសេស ក៏អនុវត្តបន្តផងដែរនូវករណីចំនួន ៤៤៩ ស្តីពីការរំលោភបំពានលើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស ដោយពាក់ព័ន្ធនឹងអ្នកការកម្រិតខ្ពស់បំផុតនៅក្នុងសន្និសីទពិភពលោកស្តីពីស្ត្រីជាអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានរៀបចំឡើងនៅក្នុងប្រទេសស្រីលង្កា ពារចំនួន ២.៣១៤ នាក់នៅក្នុងអាណត្តិការងាររបស់អ្នកស្រី ។ ហុកសិបប្រាំនៃឯកសារបណ្តឹងទាំងនេះ ត្រូវបានផ្ញើជូន**អ្នករាយការណ៍ពិសេសលើអំពើហិង្សាចំពោះស្ត្រីភេទ បុព្វហេតុរបស់វា និងផលវិបាក ។**

[61] ចូរមើលកថាខ័ណ្ឌទី ៨០-៩៤ នៃឯកសារ E/CN/.4/2002/106 ។

## ក. ការដាក់ជូនពិនិត្យនូវករណីជាលក្ខណៈបុគ្គលទៅអ្នកមានអាណត្តិនៃយន្តការពិសេស

**នរណាម្នាក់ក៏ដោយ ក៏អាចដាក់ជូនពិនិត្យនូវព័ត៌មានដែលគួរឲ្យជឿបាន និងទុកចិត្តបានស្តីពីការរំលោភបំពានលើសិទ្ធិមនុស្ស ទៅអ្នកមានអាណត្តិនៃយន្តការពិសេស ដែលត្រូវបានប្រគល់អាណត្តិឲ្យទទួលព័ត៌មានស្តីពីការរំលោភបំពានលើសិទ្ធិមនុស្ស ។** ការដាក់ជូនពិនិត្យនូវបណ្តឹងជាលក្ខណៈបុគ្គលទៅយន្តការពិសេស គឺជារបៀបមួយក្នុងចំណោមរបៀបដែលមានប្រសិទ្ធភាពបំផុតមួយជាច្រើនក្នុងការស្វែងរកអន្តរាគមន៍ផ្ទាល់នៅក្នុងករណីជាលក្ខណៈបុគ្គល ។ ជារឿយៗ តួអង្គសង្គមស៊ីវិល អាចបំពេញមុខងារជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកកិច្ចការពារពីការបំពារបំពានលើសិទ្ធិមនុស្ស ។

តាមធម្មតា ឯកសារបណ្តឹងដែលត្រូវបានផ្ញើចេញ និងត្រូវបានទទួលមានលក្ខណៈសម្ងាត់ និងស្ថិតនៅដូច្នេះរហូតដល់របាយការណ៍របស់អ្នកមានអាណត្តិទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានចេញជាសាធារណៈ លុះត្រាតែអ្នកមានអាណត្តិ បានសម្រេចចិត្តចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ មុនពេលកំណត់នៅក្នុងដំណើរការនេះ ។ របាយការណ៍នេះ មានព័ត៌មានស្តីពីឯកសារបណ្តឹងដែលត្រូវបានផ្ញើចេញ និងចម្លើយតបដែលត្រូវបានទទួលពីរដ្ឋាភិបាល ស្តីពីករណីជាក់លាក់ ។ សូមកត់សម្គាល់ថា ជនរងគ្រោះដែលមានទទ្បីករណ៍ត្រូវបានសរសេរឈ្មោះនៅក្នុងរបាយការណ៍ លើកលែងតែកុមារ ឬ ជនរងគ្រោះដែលមានប្រភេទជាក់លាក់ផ្សេងទៀត ដូចជាជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទជាដើម ។

ដោយពិចារណាទៅលើប្រភេទទូទៅ នៃរបាយការណ៍របស់យន្តការពិសេស វាមានលក្ខណៈសំខាន់ថា អង្គការដែលបំពេញមុខងារ ក្នុងនាមជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស ធានាថាជនរងគ្រោះ ដឹងថាករណីរបស់គេ កំពុងត្រូវបានបញ្ជូនទៅយន្តការពិសេស ថាឈ្មោះរបស់គេ នឹងត្រូវបានបញ្ជូនទៅអាជ្ញាធរ និងថាឈ្មោះរបស់គេ (ឬ អក្សរអាទិសង្កេត) នឹងបង្ហាញនៅក្នុងរបាយការណ៍ទូទៅរបស់យន្តការពិសេស ។ ទោះជាយ៉ាងណាក៏ដោយ វាគួរតែត្រូវបានកត់សម្គាល់ថា ការអនុញ្ញាតរបស់ជនរងគ្រោះ មិនត្រូវបានតម្រូវឲ្យដាក់ជូនពិនិត្យជានិច្ចកាលនូវករណី (ឧទាហរណ៍ៈ ប្រសិនបើជនរងគ្រោះ មិនអាចចូលជួបបានពីព្រោះគេ ស្ថិតនៅក្នុងការឃុំឃាំង ឬ កាលៈទេសៈបែបនេះផ្សេងទៀត) ។ អាណត្តិមួយចំនួនតូច បានរៀបចំកម្រងសំណួរពិសេសដែលត្រូវបានប្រើប្រាស់ នៅពេលដាក់ជូនពិនិត្យនូវព័ត៌មានស្តីពីការរំលោភបំពានលើសិទ្ធិមនុស្ស ។

**យន្តការពិសេសនីមួយៗ កំណត់តម្រូវការខុសៗគ្នាសម្រាប់ការដាក់ជូនពិនិត្យនូវឯកសារបណ្តឹង ។** ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអប្បបរមាដូចតទៅនេះ ត្រូវតែបានបញ្ចូលសម្រាប់ឯកសារបណ្តឹងដែលត្រូវបានវាយតម្លៃៈ

- អត្តសញ្ញាណរបស់ជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) ដែលមានទទ្បីករណ៍ ។
- អត្តសញ្ញាណរបស់ចារីដែលមានទទ្បីករណ៍នៃការរំលោភបំពាន ។

- អត្តសញ្ញាណរបស់បុគ្គលម្នាក់ (ឬ ច្រើននាក់) ឬ អង្គការមួយ (ឬ ច្រើន) ដែលដាក់ជូនពិនិត្យនូវឯកសារបណ្ដឹង (ព័ត៌មាននេះ នឹងត្រូវបានរក្សាជាការសម្ងាត់) ។
- កាលបរិច្ឆេទ និងទីកន្លែងនៃឧប្បត្តិហេតុ និង
- សេចក្ដីពិពណ៌នាពិស្ដារស្ដីពីកាលៈទេសៈដែលក្នុងនោះ ការរំលោភបំពានដែលមានទទ្បីករណ៍បានកើតឡើង ។

i **កម្រងសំណួរ** ជាលក្ខណៈស្តង់ដាសម្រាប់អាណត្តិជាក់លាក់ ត្រូវបានរៀបចំឲ្យមានក្រោមអាណត្តិមួយចំនួនតូចសម្រាប់ធ្វើសេចក្ដីរាយការណ៍អំពីការរំលោភបំពានដែលមានទទ្បីករណ៍នៅក្នុងវិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

តួអង្គសង្គមស៊ីវិល ក៏អាចដាក់ជូនពិនិត្យផងដែរនូវ**ព័ត៌មានសម្រាប់ការអនុវត្តបន្ត**ទៅអ្នកមានអាណត្តិស្ដីពីថាតើបញ្ហា/ស្ថានភាពសិទ្ធិមនុស្សមួយ (ឬ ច្រើន) ដែលត្រូវបានដោះស្រាយនៅក្នុងឯកសារស្នើសុំពិនិត្យដើមរបស់គេ បានល្អប្រសើរឡើងដែរឬអត់ ។ ព័ត៌មានសម្រាប់ការអនុវត្តបន្ត មានប្រយោជន៍ច្រើនសម្រាប់អ្នកមានអាណត្តិ ។ ព័ត៌មានខ្លះ ប្រើប្រាស់សំណើសុំទស្សនកិច្ចបេសកកម្មប្រចាំប្រទេសដោយមានមូលដ្ឋាននៅលើនិន្នាការដែលត្រូវបានកំណត់ តាមរយៈនីតិវិធីនៃការដាក់ពិនិត្យនូវឯកសារបណ្ដឹង ។

**ព័ត៌មានដែលត្រូវបានផ្ដល់ទៅយន្តការពិសេស មិនគួរត្រូវបានជំរុញដោយផ្នែកនយោបាយ មានលក្ខណៈរំលោភបំពាន ឬ ដោយមានមូលដ្ឋានតែទៅលើរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយនោះទេ ។**

i ករណី/បណ្ដឹងជាលក្ខណៈបុគ្គល អាចត្រូវបានដាក់ជូនពិនិត្យតាមរយៈ
អ៊ីម៉ែល: **urgent-action@ohchr.org**
ទូរសារ: ៤១ (0)២២ ៩១៧ ៩០ ០៦ ឬ
អាសយដ្ឋានប្រៃសណីយ៍: ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) - ការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងហ្សឺណែវ (UNOG) 8-14 avenue de la Paix, CH-1211 Geneva 10 ប្រទេសស្វីស ។

**នៅពេលផ្ញើចេញឯកសារបណ្ដឹង សូមបញ្ជាក់អំពីថាតើយន្តការពិសេសណាមួយដែលព័ត៌មាននេះត្រូវបានផ្ញើទៅ នៅក្នុងកន្លែងកម្មវត្ថុនៃអ៊ីម៉ែល ឬ ទូរសារ ឬ នៅលើស្រោមសំបុត្រ ។**

សម្រាប់ព័ត៌មានបន្ថែមស្ដីពីវិធីដាក់ជូនពិនិត្យនូវព័ត៌មានស្ដីពីការរំលោភបំពានដែលមានទទ្បីករណ៍ទៅយន្តការពិសេស សូមមើលជំពូក **VIII** (**ការដាក់ជូនពិនិត្យនូវពាក្យបណ្ដឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្បីករណ៍**) នៃ*សៀវភៅ*នេះ និងទាក់ទងនឹង **SPDInfo@ohchr.org** ។

## ខ. ការផ្តល់ការគាំទ្រសម្រាប់ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស

ទស្សនកិច្ចបេសកកម្មប្រចាំប្រទេសរបស់អ្នកមានអាណត្តិនៃយន្តការពិសេស មានលក្ខណៈសំខាន់ជាសារវន្តចំពោះការប្រមូលព័ត៌មានពីប្រភពដើម ដោយហេតុថាវា អនុញ្ញាតឲ្យមានការសង្កេតផ្ទាល់លើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសជាក់លាក់ ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងជាតិ សមាជិករបស់សង្គមស៊ីវិល និងចលនាមហាជន មានវិភាគទានដ៏សំខាន់ ដើម្បីរួមចំណែកនៅក្នុងដំណាក់កាលខុសៗគ្នានៃបេសកកម្ម ។

### ១. ការស្នើសុំទស្សនកិច្ចបេសកកម្មប្រចាំប្រទេស

តួអង្គសង្គមស៊ីវិល អាចជំរុញលើកទឹកចិត្តឲ្យរដ្ឋាភិបាល អញ្ជើញអ្នកមានអាណត្តិមកធ្វើទស្សនកិច្ចប្រទេស ឬ ផ្តល់នូវការអញ្ជើញបើកចំហទៅយន្តការពិសេស ។ ការជម្រាបជូនទៅអ្នកមានអាណត្តិអំពីបញ្ហានៅក្នុងរដ្ឋមួយ ក៏អាចកំណត់អំពីថាតើអ្នកមានអាណត្តិ ស្នើសុំទស្សនកិច្ចបេសកកម្មពិសេសណាមួយដែរឬអត់ ដោយហេតុថាអ្នកមានអាណត្តិខ្លះ ប្រើប្រាស់ការស្នើសុំទស្សនកិច្ចបេសកកម្មប្រចាំប្រទេសរបស់គេ ដោយមានមូលដ្ឋាននៅលើបរិមាណព័ត៌មាន (បណ្តឹង/ករណីជាលក្ខណៈបុគ្គល) ដែលគេទទួលបាន ។ អ្នកមានអាណត្តិខ្លះ ក៏បានបានអនុវត្តផងដែរនូវ**ដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេសរួម** ។

### ២. នៅពេលដែលទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ត្រូវបានអនុម័តបញ្ជាក់

កាលណាទស្សនកិច្ចបេសកម្មប្រចាំប្រទេស ត្រូវបានអនុម័តបញ្ជាក់ភ្លាម (នៅពេលដែលរដ្ឋ បានអនុម័តលើសំណើសុំធ្វើទស្សនកិច្ចរបស់អ្នកមានអាណត្តិ និងកាលបរិច្ឆេទសម្រាប់ទស្សនកិច្ចនេះ ត្រូវបានយល់ព្រម) តួអង្គសង្គមស៊ីវិល អាចលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីដំណើរទស្សនកិច្ចនេះ ។

តួអង្គសង្គមស៊ីវិល ក៏អាចដាក់ជូនពិនិត្យផងដែរនូវព័ត៌មានពាក់ព័ន្ធ និងលើកឡើងនូវបញ្ហាកង្វល់ជាមួយនឹងអ្នកមានអាណត្តិ មុនពេលដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ប្រព្រឹត្តទៅ ។ នេះ ជួយដល់អ្នកមានអាណត្តិ ឲ្យលើកឡើងបាននូវបញ្ហាជាក់លាក់ជាមួយនឹងអាជ្ញាធរ មុនពេលកំណត់ និងប្រសិនបើចាំបាច់ ធ្វើការរៀបចំ ដើម្បីបញ្ចូលវាទៅក្នុងទៅក្នុងកម្មវិធីជាផ្លូវការនៃដំណើរទស្សនកិច្ចនេះ (ឧទាហរណ៍ៈ ដោយស្នើសុំការចូលទៅមណ្ឌលឃុំឃាំង ឬ ជំរុំជនភៀសខ្លួនជាក់លាក់ ឬ ដោយរៀបចំត្រៀមជួបប្រជុំជាមួយនឹងអាជ្ញាធរជាតិ ឬ មូលដ្ឋាន ឬ បុគ្គលជាលក្ខណៈឯកជន) ។

## ការសម្របសម្រួលថ្នាក់ជាតិនៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រេស៊ីល

អង្គការមិនមែនរដ្ឋាភិបាលមួយក្រុមរបស់ប្រេស៊ីល (**វេទិកាសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌ (ផ្លាតាហ្វម៉ា ដេអេចអ៊ីអេសស៊ី)**) បានបង្កើតប្រព័ន្ធពិនិត្យតាមដានសិទ្ធិមនុស្សមួយ ដែលត្រូវបានធ្វើគំរូ តាមយន្តការពិសេស ។ អ្នកដែលបម្រើជាមណ្ឌលសកម្មភាពនីមួយៗ ក្នុងចំណោម អ្នកដែលបម្រើជាមណ្ឌលសកម្មភាពចំនួនប្រាំមួយ ធ្វើការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពោលគឺ សិទ្ធិទទួលបានជម្រកស្នាក់នៅគ្រប់គ្រាន់ ការអប់រំ បរិស្ថាន អាហារគ្រប់គ្រាន់ ផ្នែកសុខភាព ឬ ខាងការងារ និង ផលិតរបាយការណ៍ជាតិស្ដីពីបញ្ហានោះ ដែលត្រូវបានបញ្ជូនទៅអ្នកមានអាណត្តិនៃយន្តការពិសេស ដែលពាក់ព័ន្ធមួយ (ឬ ច្រើន) ។ ការធ្វើវិភាជន៍បញ្ហាជាក់លាក់ទៅអ្នកដែលបម្រើជាមណ្ឌលសកម្មភាពនីមួយៗ បង្កើនជាអតិបរមានូវការប្រើប្រាស់ធនធាន និងជំនាញ និងបានកាត់បន្ថយនូវការចម្លង ដោយចេញលទ្ធផលជាការរួមចំណែកដែលកាន់តែមានប្រសិទ្ធភាពនៅក្នុងការងាររបស់យន្តការពិសេស ។

## ៣. នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស

នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស តួអង្គសង្គមស៊ីវិល អាចស្នើសុំជួបប្រជុំជាមួយនឹងអ្នកមានអាណត្តិ ដោយទាក់ទងនឹងអ្នកមានអាណត្តិនោះ ឬ បុគ្គលិកពាក់ព័ន្ធរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ ឬ នៅនឹងកន្លែង តាមរយៈទូរសារ ប្រៃសណីយ៍ ឬ អ៊ីម៉ែល ។

*i* សូមចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ មនុស្ស (OHCHR) សម្រាប់អាសយដ្ឋានទំនាក់ទំនងរបស់**មន្ត្រីនៅមូលដ្ឋាន និងមន្ត្រីប្រចាំការិយាល័យ**ដែលពាក់ព័ន្ធ ។

## ៤. បន្ទាប់ពីដំណើរទស្សនកិច្ចបេសកកម្ម

តួអង្គសង្គមស៊ីវិល អាចមានតួនាទីសំខាន់បំផុតនៅក្នុងការអនុវត្តនូវសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ដែលចេញលទ្ធផលពីដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស តាមរយៈ:

- ការផ្សព្វផ្សាយអនុសាសន៍ដល់អ្នកគាំទ្រផ្នែកនយោបាយនៅមូលដ្ឋានរបស់គេ ។
- ការផ្សព្វផ្សាយការងាររបស់យន្តការពិសេស និងការលើកកម្ពស់ការយល់ដឹងជាទូទៅ ។

- ការរៀបចំផែនការសកម្មភាព និងសកម្មភាព ដើម្បីបន្តការងារដែលត្រូវបានផ្តួចផ្តើម តាមរយៈទស្សនកិច្ចបេសកកម្មប្រចាំប្រទេស ។
- ការធ្វើការងារជាមួយនឹងរដ្ឋាភិបាល ឆ្ពោះទៅរកការអនុវត្តអនុសាសន៍របស់យន្តការពិសេស ។
- ការរួមចំណែកជាទិន្នន័យបញ្ចូលទៅក្នុងរបាយការណ៍អនុវត្តន៍បន្តជាក់លាក់ ដែលត្រូវបានចេញផ្សាយដោយអ្នកមានអាណត្តិខ្លះ និង
- ការពិនិត្យតាមដានវិធានការដែលរដ្ឋាភិបាល បានអនុវត្ត ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ និងការបន្តផ្តល់ដល់អ្នកមានអាណត្តិមួយ (ឬ ច្រើន) នោះនូវព័ត៌មានស្តីពីវឌ្ឍនភាពលើការអនុវត្តអនុសាសន៍ដោយរដ្ឋ ។

## ការបង្កើតបណ្តាញ ដើម្បីធ្វើការអនុវត្តអនុសាសន៍របស់យន្តការពិសេស

បន្ទាប់ពីដំណើរទស្សនកិច្ចរបស់**អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីទម្រង់សហកាលនៃការប្រកាន់ពូជសាសន៍ ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងភាពមិន អត់ឱនផ្នែកជំនឿ សាសនា** នៅពេលនោះ គឺលោក ឌូឌូ ដាយអ៊ីន ទៅកាន់ប្រទេសជប៉ុននៅក្នុងឆ្នាំ ២០០៥ **ចលនាអន្តរប្រឆាំងរាល់ទម្រង់នៃការប្រកាន់ប្រកាន់ពូជសាសន៍ (IMADR)** និងក្រុមជនភាគតិច និងសិទ្ធិមនុស្សចំនួន ៨៥ បាន បង្កើតបណ្តាញអង្គការមិនមែនមិនមែនរដ្ឋាភិបាលសម្រាប់លុបបំបាត់ការរើសអើងជាតិសាសន៍ ដោយមានមូលដ្ឋាននៅលើរបាយការណ៍បេសកកម្មរបស់គេ ។ បណ្តាញនេះ មានមុខងារជាមធ្យោបាយកណ្តាលសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការប្រកាន់ពូជសាសន៍ និងការ រើសអើងនៅក្នុងប្រទេសជប៉ុន និង ដើម្បីចូលរួមពាក់ព័ន្ធជាមួយនឹងយន្តការអន្តរជាតិ។ អ្នករាយការណ៍ពិសេស បានទទួលស្វាគមន៍ ការរៀបចំឲ្យមានបណ្តាញនេះ ក៏ដូចជាការសន្ទនាក្នុងន័យស្ថាបនា ដែលត្រូវបានធ្វើឡើងរវាងអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសហគមន៍ ដែលត្រូវបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយការប្រកាន់ពូជសាសន៍ និងការស្អប់ជនបរទេស ក្នុងនោះរួមមានជនជាតិភាគតិចអាយនុ (ដែលពីមុនត្រូវបានទទួលស្គាល់ដោយជប៉ុនថាជាជនជាតិដើមភាគតិចនៅក្នុងឆ្នាំ ២០០៨) ក្រុមជនភាគតិចជាតិ (ជនជាតិភាគតិចប៊ូរ៉ាគុ និងប្រជាជននៃកោះអូគីណា វ៉ា) អ្នកជាប់វង្សត្រកូលនៃមនុស្សមកពីអតីតអាណានិគមជប៉ុន (ជនជាតិកូរ៉េ និងចិន) និងជន អន្តោប្រវេសន៍មកពីប្រទេសនៃ តំបន់អាស៊ីអាព្រិច អាមេរិកខាង ត្បូង និងមជ្ឈិមបូព៌ា ។

## គ. ការផ្តល់ព័ត៌មានដល់អ្នកមានអាណត្តិនៃយន្តការពិសេស

អង្គការមិនមែនរដ្ឋាភិបាល អាចជម្រាបជូនទៅយន្តការពិសេសនូវព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្សជាក់លាក់នៅក្នុងប្រទេសពិសេសណាមួយ ឬ ច្បាប់ និងការអនុវត្តរបស់ប្រទេសនោះ ដោយមានការជំពាក់ទាក់ទងនឹងសិទ្ធិមនុស្ស ។ អ្នកមានអាណត្តិ អាចស្នើសុំទៅតាមដំណាក់កាលនូវព័ត៌មានជាក់លាក់ស្តីពីប្រធានបទដែលស្ថិតនៅក្នុងអាណត្តិរបស់គេ ឬ រៀបចំកិច្ចពិគ្រោះយោបល់ពិសេសជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ក្នុងនោះរួមមាន ស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាអប់រំផងដែរ ។

### សហប្រតិបត្តិការរបស់សង្គមស៊ីវិលជាមួយនឹងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិ អប់រំ ពាក់ព័ន្ធនឹង ការរៀបចំរបាយការណ៍ស្តីពីសិទ្ធិ អប់រំរបស់ជនពិការ

នៅក្នុងឆ្នាំ ២០០៧ **អ្នករាយការណ៍ពិសេសលើសិទ្ធិទទួលបានការអប់រំ** លោកវើណ័រមូណូហ្សវីឡាឡូបស បានលះបង់របាយការណ៍ប្រចាំឆ្នាំលើកទីបីរបស់ខ្លួន (A/HRC/4/29) សម្រាប់សិទ្ធិទទួលបានការអប់រំរបស់ជនពិការ ដោយពិចារណាថា ពួកគេ ជាក្រុមមួយក្នុងចំណោមក្រុមដែលត្រូវទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ដោយអបរិយាប័ន្នពីការអប់រំ ។

របាយការណ៍នេះបានផ្តល់នូវការវិភាគស៊ីជម្រៅលើក្របខ័ណ្ឌស្ថាប័ន និងច្បាប់នៃសិទ្ធិទទួលបានការអប់រំរបស់ជនពិការ ។ វា ក៏បានត្រួតពិនិត្យផងដែរលើការជាប់ទាក់ទងនៃ "ការអប់រំសម្រាប់ទាំងអស់គ្នា" ជាផ្នែកដែលមានជាប់ជាមួយ និងសំខាន់ជាសារវន្តនៃសិទ្ធិទទួលបានការអប់រំ និងបានដោះស្រាយបញ្ហាជាឧបសគ្គ និងបញ្ហាប្រឈមចម្បងបំផុតដែលគំរាមកំហែងដល់ការសម្រេចបានដោយពេញលេញនូវសិទ្ធិទទួលបានការអប់រំរបស់ជនពិការ ។

នៅក្នុងការរៀបចំរបាយការណ៍ អ្នករាយការណ៍ពិសេសបានពិគ្រោះយោបល់ជាមួយនឹងអង្គការជាតិ និងតំបន់ ក្នុងនោះរួមមានអង្គការរបស់ជនពិការផងដែរ និងបានទទួលព័ត៌មានពីប្រភពដើម (ក្នុងនោះរួមមាន ការសិក្សាស្ថិតិ និងទស្សនវិស័យ) ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងតំបន់ដ៏ល្បីល្បាញ ។ ព័ត៌មាននេះជួយដល់គេក្នុងការកំណត់អំពីបញ្ហាប្រឈម និងឧបសគ្គដែលរារាំងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំរបស់ជនពិការ និងក្នុងការរៀបចំអនុសាសន៍ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដោយធ្វើសហប្រតិបត្តិការជាមួយនឹងយន្តការពិសេស ក៏បានរៀបចំផងដែរនូវសិក្ខាសាលាមន្ត្រីជំនាញ ដែលមានរយៈពេលពីរថ្ងៃស្តីពីសិទ្ធិទទួលបានការអប់រំរបស់ជនពិការ ដែលនៅក្នុងនោះ ជនពិការ និងអ្នកធ្វើការងារផ្នែកបញ្ហាពិការភាព បានចូលរួមដោយសកម្ម ។ ការរួមចំណែករបស់តំណាងសង្គមស៊ីវិល នៅក្នុងសិក្ខាសាលានោះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ជនពិការ និងអង្គការតំណាងរបស់ពួកគេ សកលវិទ្យាល័យ ទីភ្នាក់ងាររដ្ឋាភិបាល និងក្រុមអង្គការសង្គមស៊ីវិលផ្សេងទៀត ។

## ការរួមចំណែករបស់គ្រឹះស្ថានសិក្សាអប់រំដល់អាណត្តិរបស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងកាត់ព្រំដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀត

គ្រឹះស្ថានសិក្សាអប់រំដ៏ច្រើនសន្ធឹកសន្ធាប់នៅជុំវិញពិភពលោក បានរួមចំណែកដល់ការងាររបស់**តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងកាត់ព្រំដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀត ។**

ការរួមចំណែក មានទម្រង់ជាការស្រាវជ្រាវលើប្រធានបទជាក់លាក់ ដែលត្រូវបានស្នើសុំ ឬយល់ព្រមដោយតំណាងពិសេស ការចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ និងកិច្ចប្រជុំមន្ត្រីជំនាញ ដែលត្រូវបានរៀបចំដោយតំណាងពិសេស និងសេចក្តីសង្ខេត និងឯកសារស្នើសុំពិនិត្យជូនទៅតំណាងពិសេសលើបញ្ហាបញ្ហាផ្សេងៗ ដែលត្រូវបានចែងនៅក្នុងអាណត្តិរបស់គេ ។ ការរួមចំណែកទាំងអស់ ដែលត្រូវបានទទួលដោយតំណាងពិសេសត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយ ដែលត្រូវបានដំណើរការដោយ**មជ្ឈមណ្ឌលធនធានពាណិជ្ជកម្ម និងសិទ្ធិមនុស្ស ។**[62]

## ឃ. ការធ្វើការងារនៅថ្នាក់មូលដ្ឋាន ជាតិ ឬ តំបន់ ដើម្បីតស៊ូមតិ ផ្សព្វផ្សាយតាមដានបន្ត និងអនុវត្តការងាររបស់យន្តការពិសេស

ការងារដែលកំពុងដំណើរការរបស់អ្នកមានអាណត្តិនៃយន្តការពិសេស ក្នុងនោះរួមមានរបាយការណ៍ និងអនុសាសន៍របស់គេផងដែរ ផ្តល់នូវឯកសារដ៏មានតម្លៃដែលតួអង្គសង្គមស៊ីវិល អាចធ្វើសមាហរណ៍កម្មចូលទៅក្នុងការងារតស៊ូមតិដែលកំពុងដំណើរការរបស់គេ ។ នេះ អាចរួមបញ្ចូលៈ

### ១. ការអនុវត្តអនុសាសន៍របស់យន្តការពិសេសនៅថ្នាក់ជាតិ

ការតស៊ូមតិបន្តជាមួយនឹងរដ្ឋាភិបាល ដើម្បីអនុវត្តអនុសាសន៍របស់យន្តការពិសេស ជាពិសេសបន្ទាប់ពីដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេស គឺជាតួនាទីដ៏សំខាន់មួយដែលសង្គមស៊ីវិល អាចបំពេញដើម្បីលើកកម្ពស់សិទ្ធិមនុស្ស ។ តួអង្គសង្គមស៊ីវិល អាចអនុវត្តវិធានការ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពរបស់រដ្ឋាភិបាល ក្នុងការអនុវត្តអនុសាសន៍ ឬ អាចព្យាយាមបំពេញអនុសាសន៍ដោយខ្លួនឯង ប្រសិនបើវា ត្រូវបានផ្តោតទៅលើសង្គមស៊ីវិល ។

---

[62] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មិនទទួលខុសត្រូវចំពោះខ្លឹមសារនៃវិបសាយខាងក្រៅ និងការផ្តល់ទំនាក់ទំនងទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតនៅក្នុងទំព័រនេះ មិនថ្លែងបង្កប់ថា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ភ្ជាប់ខ្លួនឯងជាមួយនឹងខ្លឹមសារនេះទេ ។

## ២. ការកំណត់ស្តង់ដាជាតិ ឬ នៅមូលដ្ឋាន

ស្តង់ដាអន្តរជាតិ ច្បាប់គំរូ ឬ វិធីអនុវត្តន៍ត្រឹមត្រូវ ដែលត្រូវបានចងក្រងជាឯកសារដោយអ្នកមានអាណត្តិនៃយន្តការពិសេស អាចត្រូវបានប្រើប្រាស់ដោយតួអង្គសង្គមស៊ីវិល ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាពិសេសណាមួយ ដើម្បីធ្វើយុទ្ធនាការដើម្បីគាំទ្រស្តង់ដាថ្នាក់ជាតិ ឬ មូលដ្ឋាន ឬ ដើម្បីបំពេញនាទីជាស្តង់ដាគំរូ សម្រាប់បកស្រាយច្បាប់ជាតិ ។

តួអង្គសង្គមស៊ីវិល ក៏អាចរៀបចំផងដែរនូវព្រឹត្តិការណ៍ និងកម្មវិធីបណ្តុះបណ្តាលលើការរៀបចំបង្កើតស្តង់ដា និងដើម្បីធ្វើការងារឆ្ពោះទៅរកការកសាងសមត្ថភាពរបស់តួអង្គសង្គមស៊ីវិលផ្សេងទៀត ដើម្បីប្រើ-ប្រាស់និងចូលរួមពាក់ព័ន្ធជាមួយនឹងយន្តការពិសេស។ជារឿយៗអ្នកមានអាណត្តិ រួមចំណែកដល់សកម្មភាពកសាងសមត្ថភាពបែបនេះ ។

## ៣. ឧបករណ៍សម្រាប់ការរៀបចំបង្កើតគោលការណ៍ណែនាំប្រតិបត្តិ

ការងាររបស់អ្នកមានអាណត្តិនៃយន្តការពិសេស អាចផ្តល់នូវឯកសារពិស្តារស្តីពីសិទ្ធិ និងកាតព្វកិច្ច ដែលតួអង្គសង្គមស៊ីវិល អាចប្រើប្រាស់បាន ដើម្បីរៀបចំគោលការណ៍ណែនាំប្រតិបត្តិផ្ទៃក្នុង ។ ឧទាហរណ៍ៈ

- ការងាររបស់**អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិអប់រំ** ផ្តល់នូវគោលការណ៍ណែនាំដ៏មាន តម្លៃសម្រាប់គ្រឹះស្ថានអប់រំ ។
- ការងាររបស់**អ្នករាយការណ៍ពិសេសប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** អាចត្រូវបានប្រើប្រាស់ដោយមណ្ឌលឃុំឃាំង និងពន្ធនាគារ នៅក្នុងការរៀបចំស្តង់ដាបណ្តុះបណ្តាល និងប្រតិបត្តិការផ្ទៃក្នុង និង
- ការងាររបស់**អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាចំពោះស្ត្រីភេទ បុព្វហេតុ និងផលវិបាករបស់វា** អាចផ្តល់នូវនិយមន័យដ៏មានតម្លៃស្តីពីអំពើហិង្សាចំពោះស្ត្រីភេទ បុព្វហេតុរបស់វា និងវិធីអនុវត្តន៍ត្រឹមត្រូវសម្រាប់លុបបំបាត់វា ។ គោលការណ៍ណែនាំ និយមន័យ និងនីតិវិធីទាំងនេះ អាចត្រូវបានប្រើប្រាស់នៅតាមបណ្តាសាលារៀន ពន្ធនាគារ មជ្ឈមណ្ឌលស្ត្រី ឬ អង្គការផ្សេងទៀត ដែលព្យាយាមបង្កើតលក្ខខណ្ឌប្រកបដោយសុវត្ថិភាពសម្រាប់ស្ត្រី ។

## ខ. ការជួបប្រជុំជាមួយនឹងអ្នកមានអាណត្តិនៃយន្តការពិសេស

អ្នកមានអាណត្តិនៃយន្តការពិសេស ត្រៀមជាស្រេចសម្រាប់កិច្ចប្រជុំជាមួយនឹងតួអង្គសង្គមស៊ីវិលជាផ្នែកមួយនៃកិច្ចពិគ្រោះយោបល់របស់គេ នៅក្នុងទីក្រុងហ្សឺណែវ ញូវយ៉ក (សម្រាប់អ្នកដែលចូលរួមក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ) និងនៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចបេសកកម្មប្រចាំប្រទេសរបស់គេ ។ កិច្ចប្រជុំទាំងនេះ មានលក្ខណៈសំខាន់ជាពិសេស ក្នុងការជួយកសាងភាពជាដៃគូជាបន្តបន្ទាប់ រវាងអ្នកមានអាណត្តិ និងសង្គមស៊ីវិល ។ បុគ្គលិកដែលជួយអ្នកមានអាណត្តិនៅក្នុងការិយាល័យឧត្តមស្នងការអង្គសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) អាចត្រូវបានទាក់ទងពេញមួយឆ្នាំ ដើម្បីរៀបចំកិច្ចប្រជុំទាំងនេះ ។

## ធនធានរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

### ទំព័របណ្ដាញ (គេហទំព័រ) — វិបសាយរបស់យន្តការពិសេស

តួអង្គសង្គមស៊ីវិល គួរតែមើលជាទៀងទាត់នូវផ្នែករបស់យន្តការពិសេសនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្ដីពីយន្តការពិសេស ។ វិបសាយនេះ ត្រូវបានរៀបចំឲ្យមានជាស្រេចជាភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ រួមជាមួយនឹងទម្រង់ជាភាសាអារ៉ាប់ និងចិន ដែលស្ថិតនៅក្នុងដំណើរការបង្កើតឡើង ។

### វិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិល គួរតែមើលជាទៀងទាត់នូវផ្នែករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្ដីពីការចូលរួមនៅក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា និងព័ត៌មានស្ដីពីការបង្ហាញរបាយការណ៍របស់យន្តការពិសេស ។

### ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត)

ព័ត៌មានស្ដីពីទិដ្ឋភាពផ្សេងៗនៃប្រព័ន្ធយន្តការពិសេស ក៏ត្រូវបានរៀបចំឲ្យមានផងដែរនៅក្នុង:

- ផ្នែករបស់យន្តការពិសេសនៃ**ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស** និង
- **ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់យន្តការពិសេស ។**

### ព្រឹត្តិប័ត្ររបស់យន្តការពិសេស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផលិតព្រឹត្តិប័ត្រប្រចាំត្រីមាសស្ដីពីសកម្មភាពរបស់យន្តការពិសេស ។ ព្រឹត្តិប័ត្រនេះ ត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយរបស់យន្តការពិសេស នៃការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) ។

> *i* ដើម្បីចូលមើល**ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស**ដែលត្រូវបានការពារដោយអក្សរសម្ងាត់ ចូរបំពេញទម្រង់តាមបណ្ដាញអេឡិចត្រូនិចដែលត្រូវបានរៀបចំឲ្យមាន ។ នៅពេលដែលអ្នក ធ្វើកិច្ចការនេះចប់ហើយ អ្នក នឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងអក្សរសម្ងាត់តាមរយៈអ៊ីម៉ែល ។
>
> ដើម្បីចូលមើល**ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត) របស់យន្តការពិសេស** ចូរបំពេញទម្រង់តាមបណ្ដាញអេឡិចត្រូនិច ។

## ព័ត៌មានត្រឹមត្រូវ និងពិស្តារប្រចាំឆ្នាំស្តីពីយន្តការពិសេស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផលិតធនធានប្រចាំឆ្នាំទាក់ទងនឹងព័ត៌មានត្រឹមត្រូវ និងពិស្តាររបស់យន្តការពិសេស ។ ធនធាននេះ រួមបញ្ចូលព័ត៌មាន និងស្ថិតិស្តីពីទំនាក់ទំនង ទស្សនកិច្ចបេសកកម្មប្រចាំប្រទេស របាយការណ៍ សេចក្តីប្រកាសព័ត៌មាន ការសម្របសម្រួល និងព្រឹត្តិការណ៍ប្រធានបទ ។ ធនធានព័ត៌មានត្រឹមត្រូវ និងពិស្តារ ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែករបស់យន្តការពិសេស នៃវ៉ិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## កម្រងអនុសាសន៍របស់យន្តការពិសេសប្រចាំឆ្នាំ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផលិតកម្រងអនុសាសន៍របស់យន្តការពិសេសប្រចាំឆ្នាំ ដែលត្រូវបានរៀបចំតាមប្រទេស ។ វាត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែករបស់យន្តការពិសេសនៃវ៉ិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## សន្ទស្សន៍សិទ្ធិមនុស្សជាសកល

**សន្ទស្សន៍សិទ្ធិមនុស្សជាសកល (សន្ទស្សន៍)** គឺជាឧបករណ៍ព័ត៌មានតាមបណ្តាញអេឡិចត្រូនិច ដែលត្រូវបានរៀបចំជាលើកដំបូង ដើម្បីសម្របសម្រួលឲ្យមានលទ្ធភាពទទួលបានឯកសារសិទ្ធិមនុស្ស ដែលត្រូវបានចេញផ្សាយដោយ**ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ** និង**យន្តការពិសេស**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ វ៉ិបសាយថ្មីនេះ (ដែលអាចត្រូវបានចូលមើលតាមរយៈវ៉ិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)) មានសេចក្តីសង្កេតសន្និដ្ឋានទាំងអស់ដែលត្រូវបានចេញផ្សាយដោយស្ថាប័នសន្ធិសញ្ញាចាប់ពីឆ្នាំ ២០០០ មក ក៏ដូចជា សេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃយន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងប្រទេសជាក់លាក់ ដែលត្រូវបានអនុម័ត ចាប់តាំងតែពីឆ្នាំ ២០០៦ មក ។ សន្ទស្សន៍នេះ នឹងផ្តល់ភ្លាមៗនូវលទ្ធភាពទទួលបានអនុសាសន៍ដែលត្រូវបានផ្តល់នៅក្នុងក្របខ័ណ្ឌ នៃយន្តការត្រួតពិនិត្យឡើងវិញ តាមដំណាក់កាលជាសកលរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

# ឧបសម្ព័ន្ធ

នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ មានយន្តការពិសេសចំនួន ៣៨ ដែលដំណើរការ (អាណត្តិប្រធានបទចំនួន ៣០ និងអាណត្តិប្រចាំប្រទេសចំនួន ៨) ។

*i* ចំពោះបញ្ជីថ្មីនៃយន្តការពិសេស សូមចូលមើលនៅក្នុងផ្នែករបស់យន្តការពិសេសនៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ក. តារាងអាណត្តិប្រធានបទ

| ឋានន្តរ/អាណត្តិ | អាណត្តិដែលត្រូវបានបង្កើតឡើង | | អាណត្តិដែលត្រូវបានបន្ត | |
|---|---|---|---|---|
| | នៅក្នុងឆ្នាំ | ដោយ | នៅក្នុងឆ្នាំ | ដោយ |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពីមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយ នៃសិទ្ធិមានកម្រិតជីវភាពរស់សមរម្យ** | ២០០០ | សេចក្តីសម្រេចចិត្តលេខ 2000/9 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្តលេខ 6/27 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **ក្រុមការងារមន្ត្រីជំនាញទទួលបន្ទុកមនុស្សដែលមានត្រកូលអាព្រិច** | ២០០២ | សេចក្តីសម្រេចចិត្តលេខ 2002/68 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 9/14 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **ក្រុមការងារប្រឆាំងនឹងការឃុំឃាំងដោយបំពាន** | ១៩៩១ | សេចក្តីសម្រេចចិត្តលេខ 1991/42 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្តលេខ 6/4 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ប្រឆាំង ការលក់ដូរកុមារ ពេស្យាចារកុមារ និងកាមសាស្ត្រកុមារ** | ១៩៩០ | សេចក្តីសម្រេចចិត្តលេខ 1990/68 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/13 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

| | | | | |
|---|---|---|---|---|
| **អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិ អប់រំ** | ១៩៩៨ | សេចក្តីសម្រេចចិត្ត លេខ 1998/33 របស់គណៈកម្មាសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 8/4 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **ក្រុមការងារប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ ឬ គ្មានការស្ម័គ្រចិត្ត** | ១៩៨០ | សេចក្តីសម្រេចចិត្ត លេខ 20 (XXXVI) របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្ត លេខ 7/12 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពីការសំលាប់ក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវ តាមច្បាប់ ឬ ដោយបំពាន** | ១៩៨២ | សេចក្តីសម្រេចចិត្ត លេខ 1982/35 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 8/3 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

| ឋានន្តរ/អាណត្តិ | អាណត្តិដែលត្រូវបានបង្កើតឡើង | | អាណត្តិដែលត្រូវបានបន្ត | |
|---|---|---|---|---|
| | នៅក្នុងឆ្នាំ | ដោយ | នៅក្នុងឆ្នាំ | ដោយ |
| មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស និងភាពក្រីក្រធ្ងន់ធរ | ១៩៩៨ | សេចក្តីសម្រេចចិត្តលេខ 1998/25 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 8/11 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេស របស់ អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ | ២០០០ | សេចក្តីសម្រេចចិត្តលេខ 2000/10 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្តលេខ 6/2 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី សេរីភាពក្នុងការ បញ្ចេញមតិយោបល់ | ១៩៩៣ | សេចក្តីសម្រេចចិត្តលេខ 1993/45 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/36 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសេរីភាពខាងជំនឿ សាសនា | ១៩៨៦ | សេចក្តីសម្រេចចិត្តលេខ 1986/20 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្តលេខ 6/37 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី សិទ្ធិបុគ្គលគ្រប់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តក្នុងកម្រិតស្តង់ដាមួយ ខ្ពស់បំផុត | ២០០២ | សេចក្តីសម្រេចចិត្តលេខ 2002/31 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្តលេខ 6/29 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី ស្ថានភាពអ្នកការពារសិទ្ធិមនុស្ស (អតីត តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ) | ២០០០ | សេចក្តីសម្រេចចិត្តលេខ 2000/61 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/8 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

| | | | | |
|---|---|---|---|---|
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី ឯករាជ្យភាពរបស់ចៅក្រម និង មេធាវី** | ១៩៩៤ | សេចក្តីសម្រេចចិត្ត លេខ 1994/41 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 8/6 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់ រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី ស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច** | ២០០១ | សេចក្តីសម្រេចចិត្ត លេខ 2001/57 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្ត លេខ 6/12 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់ រយៈពេល ៣ ឆ្នាំ) |
| **តំណាងរបស់លោកអគ្គលេខាធិការអង្គការ - សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សរបស់ ចំណាកស្រុកក្នុងប្រទេស** | ២០០៤ | សេចក្តីសម្រេចចិត្ត លេខ 2004/55 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្តីសម្រេចចិត្ត លេខ 6/32 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់ រយៈពេល ៣ ឆ្នាំ) |
| **ក្រុមការងារប្រឆាំងនឹងការប្រើប្រាស់ ទាហានស៊ីឈ្នួលជាមធ្យោបាយរំលោភ បំពានលើសិទ្ធិមនុស្ស និងរារាំងការ ប្រើប្រាស់សិទ្ធិរបស់ប្រជាជន ក្នុងការ សម្រេចចិត្តដោយខ្លួនឯង** | ២០០៥ | សេចក្តីសម្រេចចិត្ត លេខ 2005/2 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/21 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស |

| ប្រធានបទ/អាណត្តិ | អាណត្តិដែលត្រូវបាន បង្កើតឡើង | | អាណត្តិដែលត្រូវបាន បន្ត | |
|---|---|---|---|---|
| | នៅក្នុងឆ្នាំ | ដោយ | នៅក្នុងឆ្នាំ | ដោយ |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី សិទ្ធិមនុស្សរបស់ទេសន្តរប្រវេសន៍** | ១៩៩៩ | សេចក្តីសម្រេចចិត្ត លេខ 1999/44 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 8/10 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហារបស់ក្រុមជនភាគតិច** | ២០០៥ | សេចក្តីសម្រេចចិត្ត លេខ 2005/79 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/6 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី ទម្រង់សហកាលនៃការប្រកាន់ពូជសាសន៍ ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងភាពមិនអត់ឱនផ្នែកជំនឿសាសនា** | ១៩៩៣ | សេចក្តីសម្រេចចិត្ត លេខ 1993/20 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/34 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី ទម្រង់សហកាលនៃទាសភាព ក្នុងនោះរួមមាន បុព្វហេតុ និងផលវិបាករបស់វា** | ២០០៧ | សេចក្តីសម្រេចចិត្ត លេខ 6/14 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) | | |
| **មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកសិទ្ធិមនុស្ស និងសាមគ្គីភាពអន្តរជាតិ** | ២០០៥ | សេចក្តីសម្រេចចិត្ត លេខ 2005/55 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/5 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកឥទ្ធិពលនៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិ ដែលពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋទាំងឡាយ ទៅលើការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស ជាពិសេស សិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌** | ២០០០ | សេចក្តីសម្រេចចិត្ត លេខ 2000/82 របស់ គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/4 របស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

| | | | | |
|---|---|---|---|---|
| **មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកបញ្ហានៃកាតព្វកិច្ចសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់ និងអនាម័យ** | ២០០៨ | សេចក្ដីសម្រេចចិត្តលេខ 7/22 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) | | |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្ដីពីការ លើកកម្ពស់ និងការពារសិទ្ធិមនុស្ស ក្នុងខណៈដែលប្រយុទ្ធប្រឆាំងនឹងភេរវកម្ម** | ២០០៥ | សេចក្ដីសម្រេចចិត្តលេខ 2005/80 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៧ | សេចក្ដីសម្រេចចិត្តលេខ 6/28 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្ដីពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** | ១៩៨៥ | សេចក្ដីសម្រេចចិត្តលេខ 1985/33 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្ដីសម្រេចចិត្តលេខ 8/8 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

| ឋានន្តរ/អាណត្តិ | អាណត្តិដែលត្រូវបានបង្កើតឡើង | | អាណត្តិដែលត្រូវបានបន្ត | |
|---|---|---|---|---|
| | នៅក្នុងឆ្នាំ | ដោយ | នៅក្នុងឆ្នាំ | ដោយ |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពីផលប៉ះពាល់អវិជ្ជមាននៃការផ្លាស់ប្តូរទីកន្លែងដោយខុសច្បាប់ និងការចាក់ចោលនូវផលិតផល និងកាកសំណល់ ដែលមានជាតិពុល និងគ្រោះថ្នាក់ទៅលើការទទួលបានសិទ្ធិមនុស្ស** | ១៩៩៥ | សេចក្តីសម្រេចចិត្តលេខ1995/81របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 9/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្ស នៃការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ** | ២០០៤ | សេចក្តីសម្រេចចិត្តលេខ 2004/110 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 8/12 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **តំណាងពិសេសរបស់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀត** | ២០០៥ | សេចក្តីសម្រេចចិត្តលេខ2005/69របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 8/7 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីអំពើហិង្សាលើស្ត្រីភេទ បុព្វហេតុ និងផលវិបាករបស់វា** | ១៩៩៤ | សេចក្តីសម្រេចចិត្តលេខ1994/45របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/24 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៣ ឆ្នាំ) |

## ខ. តារាងអាណត្តិប្រចាំប្រទេស

| ឋានន្តរ/អាណត្តិ | អាណត្តិដែលត្រូវបានបង្កើតឡើង | | អាណត្តិដែលត្រូវបានបន្ត | |
|---|---|---|---|---|
| | នៅក្នុងឆ្នាំ | ដោយ | នៅក្នុងឆ្នាំ | ដោយ |
| មន្ត្រីជំនាញឯករាជ្យទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សប្រចាំនៅប៊ូរុនឌី | ២០០៤ | សេចក្តីសម្រេចចិត្តលេខ2004/82របស់គណៈកម្មការសិទ្ធិមនុស្ស (រយៈពេលនៃអាណត្តិមិនត្រូវបានបញ្ជាក់) | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 9/19 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (រយៈពេលនៃអាណត្តិមិនត្រូវបានបញ្ជាក់) |
| តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា | ១៩៩៣ | សេចក្តីសម្រេចចិត្តលេខ 1993/6 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 9/15 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ១ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិមនុស្សប្រចាំនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ | ២០០៤ | សេចក្តីសម្រេចចិត្តលេខ 2004/13 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/15 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ១ ឆ្នាំ) |
| មន្ត្រីជំនាញឯករាជ្យ ដែលត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សប្រចាំនៅហៃទី | ១៩៩៥ | សេចក្តីសម្រេចចិត្តលេខ 1995/70 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីថ្លែងការណ៍លេខ A/HCR/PRST/9/1 របស់ប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ២ ឆ្នាំ) |
| អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅមីយ៉ាន់ម៉ា | ១៩៩២ | សេចក្តីសម្រេចចិត្តលេខ 1992/58 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្តលេខ 7/32 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ១ ឆ្នាំ) |

| | | | | |
|---|---|---|---|---|
| **អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ស្ថានភាពសិទ្ធិមនុស្ស នៅលើទឹកដីប៉ាឡេស្ទីន ដែលត្រូវបានកាន់ កាប់ដោយអ៊ីស្រាអែល ចាប់តាំងពីឆ្នាំ១៩៦៧ មក** | ១៩៩៣ | សេចក្តីសម្រេចចិត្ត លេខ 1993/2 A របស់គណៈកម្មការសិទ្ធិមនុស្ស ("រហូតដល់ចប់ការកាន់កាប់របស់អ៊ីស្រាអែល") | | |
| **មន្ត្រីជំនាញឯករាជ្យដែលត្រូវបានតែងតាំង ឲ្យទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្ស នៅសូម៉ាលី** | ១៩៩៣ | សេចក្តីសម្រេចចិត្ត លេខ 1993/86 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 7/35 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ១ ឆ្នាំ) |
| **អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី សិទ្ធិមនុស្សនៅ ស៊ូដង់** | ២០០៥ | សេចក្តីសម្រេចចិត្ត លេខ 2005/82 របស់គណៈកម្មការសិទ្ធិមនុស្ស | ២០០៨ | សេចក្តីសម្រេចចិត្ត លេខ 9/17 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (សម្រាប់រយៈពេល ៩ ខែ) |

# VII. យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

## ទិដ្ឋភាពរួមនៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

***ដូចម្តេចដែលហៅថា យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ?***

ដោយត្រូវបានបង្កើតឡើងដោយ**សេចក្តីសម្រេចចិត្តលេខ 60/251** របស់មហាសន្និបាតអង្គការសហប្រជាជាតិនោះ យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាល ជាសកល (UPR) គឺជាយន្តការសិទ្ធិមនុស្សថ្មី មួយ ។ តាមរយៈ យន្តការត្រួតពិនិត្យតាមដំណាក់កាលជាសកល **ក្រុមប្រឹក្សាសិទ្ធិ មនុស្ស** ត្រួតពិនិត្យឡើងវិញ តាមដំណាក់កាល លើការបំពេញរបស់រដ្ឋជាសមាជិកនីមួយៗរបស់អង្គការសហប្រជាជាតិនៅក្នុងចំណោម រដ្ឋជាសមាជិកទាំង ១៩២ របស់ អង្គការសហប្រជាជាតិ នូវកាតព្វកិច្ច និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់ខ្លួន ។ យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាល ជាសកល គឺជាយន្តការសហប្រតិបត្តិការ និងត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមលើការងាររបស់ **ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស** មិនមែនចម្លងតាមនោះទេ ។

***តើយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលធ្វើការងារតាមរបៀបណា ?***

**សេចក្តីសម្រេចចិត្តលេខ 5/1** របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សមាន ចែងអំពីដំណាក់កាល និងដំណើរ ការ ។ យន្តការត្រួតពិនិត្យតាមដំណាក់កាលជាសកល ដំណើរការក្នុងអំឡុងពេលនៃខួបបួនឆ្នាំ និងមានដំណាក់កាលខ្លះ ដូចជា:

- ការរៀបចំព័ត៌មានដែលការត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្តដោយមានមូលដ្ឋាននៅលើវា ក្នុងនោះរួមមានៈ ព័ត៌មានដែលត្រូវបានរៀបចំឡើងដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ (របាយការណ៍ជាតិ) កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិស្តីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ដែលត្រូវបានរៀបចំឡើងដោយ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) និងសេចក្តីសង្ខេបព័ត៌មាន ដែលត្រូវបានដាក់ជូនពិនិត្យដោយអ្នកពាក់ព័ន្ធផ្សេងទៀត (ក្នុងនោះរួមមាន តួអង្គសង្គមស៊ីវិលផងដែរ) ដែលក៏ត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផងដែរ ។
- ការត្រួតពិនិត្យឡើងវិញនោះឯងប្រព្រឹត្តទៅនៅក្នុងទីក្រុងហ្សឺណែវនៅក្នុងក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើង

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការ [illegible]

| | | |
|---|---|---|
| វិញតាមដំណាក់កាលជាសកល ដែលមានសមាសភាពរដ្ឋជាសមាជិកទាំង ៤៧ របស់ក្រុមប្រឹក្សា និងមានទម្រង់ជាការសន្ទនាដែលលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមក រវាងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សា ។ ក្រុមការងារ | ជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គដែលមានរយៈ ពេលពីរសប្តាហ៍ចំនួនបីលើកក្នុងមួយឆ្នាំៗ និងត្រួតពិនិត្យឡើងវិញលើរដ្ឋចំនួន ១៦ ក្នុងមួយវគ្គប្រជុំពេញអង្គ ក្នុងនោះសរុបមានចំនួន ៤៨ រដ្ឋ ក្នុងមួយឆ្នាំ ។<br>• ក្រុមដែលមានអ្នករាយការណ៍បីរូប ("ត្រីភាគី") ដែលត្រូវ | បានជ្រើសរើសចេញពីក្នុងចំណោមរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សា សម្របសម្រួលដល់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ ។<br>• ការអនុម័តរបស់ក្រុមការងារលើឯកសារលទ្ធផលនៅចុងបញ្ចប់នៃដំណើរការត្រួតពិនិត្យឡើងវិញមួយលើកៗ ។ |

- ការពិចារណា និងការអនុម័តរបស់ក្រុមប្រឹក្សាលើឯកសារលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល តាមធម្មតាត្រូវបានធ្វើឡើងនៅក្នុងវគ្គប្រជុំពេញអង្គធម្មតាលើកក្រោយរបស់ក្រុមប្រឹក្សានេះ និង
- ការអនុវត្តបន្តរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន សង្គមស៊ីវិលផងដែរ ទៅនឹងការអនុវត្តធម្មតានូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដែលត្រូវបានលើកឡើងនៅក្នុងឯកសារលទ្ធផល ។

### *វិធីចូលរួមពាក់ព័ន្ធជាមួយនឹងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល*

សេចក្តីសម្រេចចិត្តលេខ 5/1 អនុញ្ញាតឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការ ។ ដោយហេតុនេះ ការចូលរួមរបស់អង្គការអន្តររដ្ឋាភិបាលប្រចាំតំបន់ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចជាតំណាងសង្គមស៊ីវិលក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល(NGO)អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ ត្រូវបានប្រមើលមើលនៅក្នុងដំណាក់កាលដែលពាក់ព័ន្ធ ។

**ឋានៈពិគ្រោះយោបល់**ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) នៃអង្គការសហប្រជាជាតិ ត្រូវបានតម្រូវឲ្យមាន ដើម្បីចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ទោះជាយ៉ាងណាក៏ដោយ តួអង្គសង្គមស៊ីវិល អាចរួមចំណែកដល់ការងាររបស់យន្តការត្រួតពិនិត្យឡើងតាមដំណាក់កាលជាសកលក្នុងចំណោមកត្តាផ្សេងទៀតដោយៈ

- ការចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ ដែលត្រូវបានរៀបចំឡើងដោយរដ្ឋាភិបាល ដើម្បីរៀបចំរបាយការណ៍ជាតិរបស់គេ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់គេ ។
- ការរៀបចំឯកសារស្នើសុំពិនិត្យស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ដើម្បីបញ្ចូលជាសក្ខានុពលទៅក្នុងសេចក្តីសង្ខេបនៃខ្លឹមសារឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធដែលត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ សេចក្តីសង្ខេបរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវបានពិចារណាដោយក្រុមការងារ នៅពេលត្រួតពិនិត្យឡើងវិញលើរដ្ឋទាំងឡាយ និង
- ការរួមចំណែកដល់ការអនុវត្តបន្តទៅនឹងការអនុវត្តធម្មតានូវលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ ។

វគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ត្រូវបានផ្សាយផ្ទាល់នៅក្នុង**កម្មវិធីផ្សាយលើអ៊ិនធើណិត**របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងកម្រងឯកសារ និងព័ត៌មានដ៏ច្រើនរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ត្រូវបានរៀបចំឲ្យមាននៅក្នុងផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៃ**វិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** និងនៅលើគេហទំព័ររបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៅក្នុង**ប្រព័ន្ធកុំព្យូទ័រ (អ៊ិក្សត្រាណិត)** របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

### អ្នកដែលអាចទាក់ទងបានសំខាន់ៗ ដែលទាក់ទងនឹងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

**សាខាក្រុមប្រឹក្សាសិទ្ធិមនុស្សនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៩២ ៦៩
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩0 ១១

**អង្គភាពសង្គមស៊ីវិលនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៩0 00
អ៊ីម៉ែលៈ **civilsocietyunit@ohchr.org**

# ដូចម្តេចដែលហៅថា យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ?

## ការបង្កើតឡើងនូវយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (UPR) ដែលត្រូវបានបង្កើតឡើងដោយ **សេចក្តីសម្រេចចិត្តលេខ 60/251** ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងដែលត្រូវបានអធិប្បាយលម្អិតនៅក្នុង**សេចក្តីសម្រេចចិត្តលេខ 5/1** ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៧ របស់**ក្រុមប្រឹក្សាសិទ្ធិមនុស្ស** គឺជាយន្តការសិទ្ធិមនុស្សថ្មី ។ តាមរយៈយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានប្រគល់កិច្ចការឲ្យត្រួតពិនិត្យឡើងវិញ តាមដំណាក់កាល លើការបំពេញរបស់រដ្ឋជាសមាជិកនីមួយៗរបស់អង្គការសហប្រជាជាតិ នៅក្នុងចំណោមរដ្ឋជា

សមាជិកទាំង ១៩២ របស់អង្គការសហប្រជាជាតិ នូវកាតព្វកិច្ច និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់គេ ។ យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល គឺជាយន្តការសហប្រតិបត្តិការ និងត្រូវបានប្រើប្រាស់ ដោយមានមូលដ្ឋាននៅលើការសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមក រវាង រដ្ឋនីមួយដែល ស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សា ។ យន្តការ ត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមលើការងាររបស់**អង្គ/ គណៈសន្ធិសញ្ញាសិទ្ធិមនុស្ស** មិនមែនចម្លងតាមទេ ។

ដោយដំណើរការនៅក្នុងអំឡុងពេលនៃខួបបួនឆ្នាំ យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជា-សកល មានដំណាក់កាលខ្លះ ក្នុងនោះរួមមាន ការរៀបចំឯកសារដែលការត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្ត ដោយមានមូលដ្ឋាននៅលើវា ដំណើរការត្រួតពិនិត្យឡើងវិញនោះឯង និងការអនុវត្តបន្តនូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ដែលជាលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញ ។ ការចូលរួមរបស់អង្គការអន្តររដ្ឋាភិបាល ប្រចាំតំបន់ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចជា តំណាងសង្គមស៊ីវិល ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ ត្រូវ បានប្រមើលមើលនៅក្នុងដំណាក់កាលដែលពាក់ព័ន្ធនៃដំណើរការត្រួតពិនិត្យឡើងវិញ ។

នៅចុងបញ្ចប់នៃខួបទីមួយនៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ក្រុមប្រឹក្សា សិទ្ធិមនុស្ស អាចត្រួតពិនិត្យឡើងវិញលើស្ថានភាពបែបបទ និងដំណាក់កាលនៃដំណើរការត្រួតពិនិត្យឡើង វិញ ដោយមានមូលដ្ឋាននៅលើវិធីអនុវត្តន៍ត្រឹមត្រូវ និងមេរៀនបទពិសោធន៍ ។

## គោលការណ៍ និងទិសដៅ ដែលណែនាំយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

គោលការណ៍មួយចំនួន ណែនាំយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល តាមរយៈ ដំណាក់កាលផ្សេងៗរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ ។ យន្តការត្រួតពិនិត្យ ឡើងវិញតាមដំណាក់កាលជាសកល ត្រូវតែៈ

- លើកកម្ពស់សកលភាព ភាពពឹងពាក់គ្នាទៅវិញទៅមក អវិភាគភាព និងភាពទាក់ទងគ្នាទៅវិញទៅ មកនៃសិទ្ធិមនុស្សទាំងអស់ ។
- ធ្វើជាយន្តការសហប្រតិបត្តិការ ដោយមានមូលដ្ឋាននៅលើព័ត៌មានមិនលម្អៀង និងដែលគួរជឿទុក ចិត្តបាន និងការសន្ទនាដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។
- ធានាឲ្យមានវិសាលភាពសកល និងប្រព្រឹត្តកម្មស្មើភាពគ្នារបស់រដ្ឋទាំងអស់ ។
- ជាដំណើរការអន្តររដ្ឋាភិបាល ដែលជំរុញដោយសមាជិកអង្គការសហប្រជាជាតិ និងមានលក្ខណៈ តម្រង់ទិសសកម្មភាព ។
- ជំរុញឲ្យមានការចូលរួមដោយពេញលេញនូវរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។
- បំពេញបន្ថែម និងមិនចម្លងតាមយន្តការសិទ្ធិមនុស្សផ្សេងទៀត ដោយហេតុដូច្នេះបន្ថែមគុណតម្លៃ ។

- ត្រូវបានប្រើប្រាស់ ដោយមិនលម្អៀង មានតម្លាភាព មិនរើស មានលក្ខណៈស្ថាបនា គ្មានការប្រឈមមុខដាក់គ្នា និងមិនពាក់ព័ន្ធនយោបាយ ។
- មិនមែនជាបន្ទុកធ្ងន់ធ្ងរហួសចំពោះរដ្ឋដែលពាក់ព័ន្ធ ឬ របៀបវារៈរបស់ក្រុមប្រឹក្សា ។
- មិនពន្យារពេលហួសពេក ។ វាគួរតែមានលក្ខណៈប្រាកដនិយម និងមិនស្រូបយកពេលវេលា ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ក្នុងលក្ខណៈវិសមាមាត្រ ។
- មិនធ្វើឲ្យចុះខ្សោយសមត្ថភាពរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងការឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នៃសិទ្ធិមនុស្ស ។
- ធ្វើសមាហរណកម្មដោយពេញលេញនូវទស្សនវិស័យយេនឌ័រ ។
- ពិចារណាទៅលើកម្រិតនៃការអភិវឌ្ឍ និងភាពជាក់លាក់របស់ប្រទេសនានា និង
- ធានាឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) ផងដែរ ដោយអនុលោមទៅតាមសេចក្តីសម្រេចចិត្តលេខ 60/251 របស់មហាសន្និបាតអង្គការសហប្រជាជាតិ និង**សេចក្តីសម្រេចចិត្តលេខ 1996/31** របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ក៏ដូចជា សេចក្តីសម្រេចដែលក្រុមប្រឹក្សាសិទ្ធិមនុស្ស អាចធ្វើឡើង ចំពោះរឿងនេះ ។

ទិសដៅរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល គឺៈ
- ការកែលម្អស្ថានភាពសិទ្ធិមនុស្សនៅនឹងកន្លែង ។
- ការបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់រដ្ឋ និងការវាយតម្លៃលើហេតុការណ៍វិវត្តន៍ថ្មីៗជាវិជ្ជមាន និងបញ្ហាប្រឈម ដែលយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ ប្រឈមមុខ ។
- ការបង្កើនសមត្ថភាពរបស់រដ្ឋ និងការផ្តល់ជំនួយបច្ចេកទេស ដោយពិគ្រោះយោបល់ជាមួយនឹង និងដោយមានការយល់ព្រមពីរដ្ឋដែលពាក់ព័ន្ធ ។
- ការចែករំលែកវិធីអនុវត្តន៍ត្រឹមត្រូវនៅក្នុងចំណោមរដ្ឋទាំងឡាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។
- ការគាំទ្រឲ្យមានកិច្ចសហប្រតិបត្តិការនៅក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និង
- ការជំរុញលើកទឹកចិត្តឲ្យមានសហប្រតិបត្តិការ និងការចូលរួមពាក់ព័ន្ធដោយពេញលេញជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័នសិទ្ធិមនុស្សផ្សេងទៀត និង**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ។

យន្តការហិរញ្ញវត្ថុពីរ គឺ **មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** និង**មូលនិធិស្ម័គ្រចិត្តសម្រាប់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស**[63] ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ (ជាពិសេស ប្រទេសក្រីក្រ និងទន់ខ្សោយបំផុត) នៅក្នុងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងគាំទ្រការអនុវត្តបន្តរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ នៅថ្នាក់ជាតិដោយរៀងខ្លួន ។

[63] ចូរមើលសេចក្តីសម្រេចចិត្តលេខ 6/17 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

# តើយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ធ្វើការងារដោយរបៀបណា ?

## ក. ដំណាក់កាល លំដាប់លំដោយ និងមូលដ្ឋាននៃដំណើរការត្រួតពិនិត្យ ឡើងវិញ

### ដំណាក់កាល

យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដំណើរការទៅនៅក្នុងអំឡុងពេលនៃខួបបួនឆ្នាំ ។ នៅក្នុងវគ្គប្រជុំពេញអង្គលើកទីប្រាំមួយរបស់ខ្លួន នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានអនុម័ត**ប្រតិទិន**សម្រាប់ការត្រួតពិនិត្យឡើងវិញ លើរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ នៅក្នុងអំឡុងពេលនៃខួបទីមួយ ។

*i*

ដើម្បីមើល**លំដាប់លំដោយនៃរដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងអំឡុងពេលនៃខួបទីមួយ** (២០០៨-២០១១) ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

### លំដាប់លំដោយនៃការត្រួតពិនិត្យឡើងវិញ

លំដាប់លំដោយដែលនៅក្នុងនោះ រដ្ឋនានា ត្រូវបានត្រួតពិនិត្យឡើងវិញនោះ ត្រូវបានណែនាំដោយគោលការណ៍សកលភាព និងប្រព្រឹត្តកម្មដោយស្មើភាពគ្នា ។ សេចក្ដីសម្រេចចិត្តលេខ 5/1 ក៏បានថែងផងដែរ អំពីបទប្បញ្ញត្តិដូចខាងក្រោម ដើម្បីកំណត់អំពីលំដាប់លំដោយនៃការត្រួតពិនិត្យឡើងវិញៈ

- រដ្ឋជាសមាជិកទាំងអស់របស់ក្រុមប្រឹក្សា ត្រូវតែបានត្រួតពិនិត្យឡើងវិញ នៅក្នុងរយៈពេលនៃសមាជិកភាពរបស់ខ្លួន ។
- រដ្ឋជាសមាជិកដំបូងរបស់ក្រុមប្រឹក្សា ជាពិសេស រដ្ឋជាសមាជិកដែលត្រូវបានជ្រើសរើសសម្រាប់រយៈពេលមួយឆ្នាំ ឬ ពីរឆ្នាំ គួរតែត្រូវបានត្រួតពិនិត្យឡើងវិញមុន ។
- រដ្ឋជាសមាជិកចម្រុះ និងរដ្ឋជាសមាជិកបេក្ខភាពរបស់ក្រុមប្រឹក្សា គួរតែត្រូវបានត្រួតពិនិត្យបន្ទាប់ និង
- របាយភូមិសាស្ត្រប្រកបដោយសមធម៌ គួរតែត្រូវបានគោរព នៅក្នុងការជ្រើសរើសប្រទេសសម្រាប់ការត្រួតពិនិត្យឡើងវិញ ។

## មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

រដ្ឋនីមួយៗ ត្រូវបានត្រួតពិនិត្យដោយមានមូលដ្ឋាននៅលើៈ

- **ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ** ។
- **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ។
- លិខិតុបករណ៍សិទ្ធិមនុស្សដែលរដ្ឋនេះ ជាភាគីនោះ ។
- ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តរបស់រដ្ឋនេះ ក្នុងនោះរួមមាន (ក្នុងករណីពាក់ព័ន្ធ) ការសន្យា និងការប្តេជ្ញាចិត្តដែលត្រូវបានទទួលអនុវត្ត នៅពេលដាក់ស្នើសុំយោបល់បេក្ខភាពរបស់រដ្ឋនេះសម្រាប់ការបោះឆ្នោតជាក្រុមប្រឹក្សា និង
- ច្បាប់មនុស្សធម៌អន្តរជាតិដែលអាចអនុវត្តបាន ។

## ខ. ដំណើរការត្រួតពិនិត្យឡើងវិញ

### ១. ការចងក្រងឯកសារ

ការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញ គឺជាដំណាក់កាលដំបូងនៃដំណើរការ ។ ការត្រួតពិនិត្យឡើងវិញលើរដ្ឋ ត្រូវបានអនុវត្ត ដោយមានមូលដ្ឋាននៅលើព័ត៌មានដែលត្រូវបានលើកឡើងនៅក្នុងឯកសារបីប្រភេទៈ

- ព័ត៌មាន ដែលត្រូវបានរៀបចំដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិតឡើងវិញ ។
- កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និង
- សេចក្តីសង្ខេបនៃឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ (ដែលត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)) ។

ឯកសារបីប្រភេទនេះ ផ្តល់នូវទស្សនវិស័យបំពេញបន្ថែមផ្សេងគ្នាស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋនីមួយៗដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។ វាគួរតែត្រូវបានរៀបចំឲ្យមាន ក្នុងរយៈពេលយ៉ាងហោចណាស់ក៏ប្រាំមួយសប្តាហ៍មុនពេលត្រួតពិនិត្យឡើងវិញដែរ និងត្រូវបានដាក់ផ្សាយនៅក្នុង**ផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល**នៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR):

(ក) **ព័ត៌មានដែលត្រូវបានរៀបចំដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ (របាយការណ៍ជាតិ):**

រដ្ឋ ដាក់ស្នើយោបល់នូវព័ត៌មានដែលខ្លួន បានរៀបចំសម្រាប់ការត្រួតពិនិត្យឡើងវិញលើរដ្ឋខ្លួនឯង ដែលមានទម្រង់ជារបាយការណ៍ជាតិ ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ។ បទបង្ហាញជាលាយលក្ខណ៍អក្សរ មិនត្រូវលើសពី ២០ ទំព័រឡើយ ។ **រដ្ឋទាំងឡាយ ត្រូវបានជំរុញលើកទឹកចិត្តឲ្យរៀបចំព័ត៌មាននេះ តាមរយៈ ដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយថ្នាក់ជាតិជាមួយនឹងអ្នកពាក់ព័ន្ធដែលពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមមាន សង្គមស៊ីវិលផងដែរ ។**

(ខ) **កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR):**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រៀបចំដោយមិនឲ្យលើសពី ១០ ទំព័រ នូវកម្រងព័ត៌មាន ដែលត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍របស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស យន្តការពិសេស និងឯកសារផ្លូវការដែលពាក់ព័ន្ធផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ។

(គ) **សេចក្តីសង្ខេបនៃឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ដែលត្រូវបានរៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR):**
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏រៀបចំផងដែរ ដោយមិនឲ្យលើសពី ១០ ទំព័រ នូវសេចក្តីសង្ខេបឯកសារស្នើសុំពិនិត្យ ដែលត្រូវបានផ្តល់ដោយអ្នកពាក់ព័ន្ធផ្សេងទៀត របស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (**ក្នុងនោះរួមមាន ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងអង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត**) ។ សេចក្តីសង្ខេបរបស់អ្នកពាក់ព័ន្ធត្រូវបានពិនិត្យពិចារណា នៅក្នុងអំឡុងពេលនៃការត្រួតពិនិត្យឡើងវិញ ។

## គោលការណ៍ណែនាំទូទៅសម្រាប់ការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញ

នៅក្នុង**សេចក្តីសម្រេចលេខ 6/102** ក្រុមប្រឹក្សាសិទ្ធិមនុស្សបង្ហាញអំពីគោលការណ៍ណែនាំទូទៅរបស់ខ្លួនសម្រាប់ការរៀបចំព័ត៌មាន នៅក្រោមយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។ **គោលការណ៍ណែនាំនេះ អនុវត្តចំពោះរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត ក៏ដូចជា ចំពោះការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់ការរៀបចំឯកសារ ក្រោមការទទួលខុសត្រូវរបស់គេ** និងចែងថា ព័ត៌មានដែលត្រូវបានដាក់ជូនពិនិត្យសម្រាប់ការត្រួតពិនិត្យឡើងវិញ គួរតែរួមបញ្ចូលៈ

- ការពិពណ៌នាអំពីវិធីសាស្ត្រ និងដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយ ដែលត្រូវបានអនុវត្តតាមដើម្បីរៀបចំព័ត៌មានដែលត្រូវបានផ្តល់ជូន ។
- សាវតារ និងក្របខ័ណ្ឌ (ជាពិសេស ដែលមានលក្ខណៈធម្មនិយាម និងស្ថាប័ន) សម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងរដ្ឋ ក្នុងនោះរួមមាន រដ្ឋធម្មនុញ្ញ ច្បាប់ វិធានការគោលនយោបាយ យុត្តិសាស្ត្រជាតិ ហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្ស (ដូចជាឧទាហរណ៍ៈ ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងវិសាលភាពនៃកាតព្វកិច្ចអន្តរជាតិ ដែលត្រូវបានកំណត់នៅក្នុង "មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ" (ចូរមើលខាងលើ) ។
- ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅនឹងកន្លែង ក្នុងនោះរួមមាន ការអនុវត្តកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានកំណត់នៅក្នុង "មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ" ច្បាប់ជាតិ និង

សេចក្ដីប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្ត សកម្មភាពរបស់ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ការលើកកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសិទ្ធិមនុស្ស និងកិច្ចសហប្រតិបត្តិការជាមួយនឹងយន្តការសិទ្ធិមនុស្ស និង

- ការកំណត់អំពីសមិទ្ធផល វិធីអនុវត្តន៍ត្រឹមត្រូវ បញ្ហាប្រឈម និងបញ្ហាកម្រិតលក្ខខណ្ឌ ។

រដ្ឋនីមួយៗ ក៏គួរតែកំណត់/ផ្ដល់ជូនផងដែរនូវព័ត៌មានស្ដីពីៈ

- អាទិភាពជាតិ កិច្ចផ្ដួចផ្ដើម និងសេចក្ដីប្ដេជ្ញាចិត្តសំខាន់បំផុតដែលគេ មានបំណងទទួលរ៉ាប់រងពុះពារជំនះបញ្ហាប្រឈម និងបញ្ហាកម្រិតលក្ខខណ្ឌ និងកែលម្អស្ថានភាពសិទ្ធិមនុស្សនៅនឹងកន្លែង ។
- ការរំពឹងទុករបស់គេចំពោះការកសាងសមត្ថភាពនិងសំណើសុំប្រសិនបើមាននូវជំនួយបច្ចេកទេស។
- ព័ត៌មានផ្សេងទៀត ដែលគេ ចាត់ទុកថា ពាក់ព័ន្ធ និង
- នៅក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យឡើងវិញចុងក្រោយ ការអនុវត្តបន្តរបស់គេទៅនឹងដំណើរការត្រួតពិនិត្យឡើងវិញលើកមុន ។

## ២. ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

ការត្រួតពិនិត្យឡើងវិញជាក់ស្ដែងលើរដ្ឋនានា ប្រព្រឹត្តទៅនៅក្នុងក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងតាមដំណាក់កាលជាសកល ។ ការត្រួតពិនិត្យឡើងវិញនេះ ត្រូវបានធ្វើជាអធិបតីដោយប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមានសមាសភាពចូលរួមជារដ្ឋជាសមាជិកចំនួន ៤៧ របស់ក្រុមប្រឹក្សា ។ ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងតាមដំណាក់កាលជាសកល ជួបប្រជុំគ្នានៅក្នុងវគ្គប្រជុំពេញអង្គដែលមានរយៈពេលពីរសប្ដាហ៍ចំនួនបីលើក ក្នុងមួយឆ្នាំៗដោយត្រួតពិនិត្យឡើងវិញលើរដ្ឋចំនួន ១៦ ក្នុងវគ្គប្រជុំពេញអង្គនីមួយៗ ពោលគឺ សរុបមានចំនួន ៤៨រដ្ឋ ក្នុងមួយឆ្នាំៗ ។ ក្រុមការងារ ជួបប្រជុំគ្នាជាលើកដំបូងនៅក្នុងខែមេសា ឆ្នាំ ២០០៨ ។

ការសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមករយៈពេលបីម៉ោង រវាងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សាប្រព្រឹត្តទៅបាន ។ នៅក្នុងអំឡុងពេលនៃកិច្ចសន្ទនានេះ រដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍ មានពេលវេលាពីរម៉ោងដើម្បីសួរសំណួរ និងផ្ដល់អនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។ បន្ទាប់មកទៀត រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ មានពេលវេលាមួយម៉ោង ដើម្បីធ្វើបទបង្ហាញដល់ក្រុមការងារនូវព័ត៌មានដែលខ្លួន បានរៀបចំសម្រាប់ការត្រួតពិនិត្យឡើងវិញលើខ្លួន ដើម្បីឆ្លើយតបទៅនឹងសំណួរ និងអនុសាសន៍ដែលត្រូវបានធ្វើបទបង្ហាញដោយរដ្ឋនានា មុន និងនៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមក និងដើម្បីធ្វើសេចក្ដីសង្កេតសន្និដ្ឋាននៅចុងបញ្ចប់នៃដំណើរការត្រួតពិនិត្យឡើងវិញ ។[64]

[64] ចូរមើល "ស្ថានភាពបែបបទ និងការអនុវត្តសម្រាប់ដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល" -ឯកសារលេខ A/HCR/PRST/8/1 ។

**អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) អាចចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ប៉ុន្តែមិនមានតួនាទីអ្វីនៅក្នុងកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមកទេ ។**

> *i* សម្រាប់ព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ស្ដីពី វគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ក្នុងនោះរួមមាន ឯកសារផ្ដល់ព័ត៌មានសម្រាប់អង្គការមិនមែនរដ្ឋាភិបាលផងដែរ ចូរចូលមើលផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៃវ៉ិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្ដីពី**ឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)** ចូរចូលមើលវ៉ិបសាយរបស់ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ ។

### ក្រុមត្រីភាគី

ក្រុមដែលមានអ្នករាយការណ៍បីរូប ("ក្រុមត្រីភាគី") សម្របសម្រួលដល់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ ។ ក្រុមត្រីភាគីខុសៗគ្នា ត្រូវបានបង្កើតឡើងសម្រាប់ការត្រួតពិនិត្យឡើងវិញលើរដ្ឋនីមួយៗ ដោយមានសមាជិកក្រុមត្រីភាគី (ដែលត្រូវបានជ្រើសរើសចេញពីក្រុមប្រចាំតំបន់ខុសៗគ្នារបស់អង្គការសហប្រជាជាតិ) ដែលត្រូវបានជ្រើសរើស តាមរយៈការចាប់ឆ្នោតពីក្នុងចំណោមរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។[65] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់ជំនួយដល់សមាជិកក្រុមត្រីភាគីនៅក្នុងការបំពេញតួនាទីរបស់ពួកគេ ។

រដ្ឋទាំងឡាយ មានឱកាសលើកឡើងនូវសំណួរ/បញ្ហាជាលាយលក្ខណ៍អក្សរស្តីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ មុនពេលដំណើរការត្រួតពិនិត្យឡើងវិញរបស់គេ ។[66] ក្រុមត្រីភាគី ទទួលខុសត្រូវចំពោះការទទួលសំណួរ/បញ្ហារបស់គេ និងប្រសិនបើក្រុមត្រីភាគីនេះ សម្រេចដូច្នេះ ប្រមូលចងក្រងវាជាក្រុម ។[67] បន្ទាប់មក ក្រុមត្រីភាគី ផ្ញើសំណួរ/បញ្ហាទៅលេខាធិការដ្ឋានរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដែលបន្ទាប់មកទៀត ផ្ញើវាទៅរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ដោយមិនឲ្យហួសពី ១០ ថ្ងៃធ្វើការ មុនពេលដំណើរការត្រួតពិនិត្យឡើងវិញលើរដ្ឋនោះ ។ សំណួរ/បញ្ហា ក៏ត្រូវបានចែកផ្សាយផងដែរក្នុងចំណោមរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សា ។

## ៣. ឯកសារលទ្ធផលរបស់ក្រុមការងារ ស្តីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ

បន្ទាប់ពីកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមកស្តីពីរដ្ឋនីមួយៗ ក្រុមត្រីភាគីដែលត្រូវបានជ្រើសរើស សម្របសម្រួលដល់ការរៀបចំឯកសារលទ្ធផល (របាយការណ៍) ស្តីពីការត្រួតពិនិត្យឡើងវិញ រួមជាមួយនឹងជំនួយរបស់លេខាធិការដ្ឋាននៃយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងការចូលរួមពាក់ព័ន្ធដែលមានលក្ខណៈពេញលេញរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ ។ ក្រុមការងារបែងចែកពេលវេលាជាអតិបរមា ៣០ នាទី សម្រាប់ការពិចារណា និងការអនុម័តលើឯកសារលទ្ធផលនីមួយៗ ដោយមិនឲ្យលើសពី ៤៨ ម៉ោង បន្ទាប់ពីការត្រួតពិនិត្យឡើងវិញ ។ របាយការណ៍ប្រចាំប្រទេសរបស់ក្រុមការងារ ត្រូវបានអនុម័ត *ដោយសុំការឯកភាព* ដោយទុករយៈពេលពីរសប្តាហ៍សម្រាប់រដ្ឋនានាធ្វើការផ្លាស់ប្តូរយោបល់លើសេចក្តីថ្លែងការណ៍ផ្ទាល់របស់គេ ។

---

[65] រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ អាចស្នើថា សមាជិកមួយរូបក្នុងចំណោមសមាជិកទាំងបីរូប គួរតែមកពីក្រុមប្រចាំតំបន់ផ្ទាល់របស់គេ និងក៏អាចស្នើសុំផងដែរនូវការជំនួសមួយបានតែម្តងគត់ ។ សមាជិកក្រុមត្រីភាគី ក៏អាចស្នើសុំផងដែរឲ្យត្រូវបានរួចពីការចូលរួមនៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញជាក់លាក់ ។

[66] សំណួរ/បញ្ហាទាំងនេះ ត្រូវបានផ្ញើទៅក្រុមត្រីភាគី និងគួរតែត្រូវបានប្រើប្រាស់ ដោយមានមូលដ្ឋានភាគច្រើននៅលើឯកសាររបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។

[67] នៅក្នុងការធ្វើដូច្នេះ ក្រុមត្រីភាគី មិនត្រូវប្តូរអត្ថន័យរបស់សំណួរ/បញ្ហា តាមរបៀបណាមួយទេ និងត្រូវតែបញ្ឈប់ការវាយតម្លៃសំណួរ/បញ្ហា ឬស្ថានភាពសិទ្ធិមនុស្ស នៅក្នុងរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។

ឯកសារលទ្ធផល រួមបញ្ចូលសេចក្តីសង្ខេបកំណត់ហេតុនៃកិច្ចត្រួតពិនិត្យឡើងវិញ សេចក្តីសន្និដ្ឋាន និង/ឬ អនុសាសន៍ និងសេចក្តីប្តេជ្ញាចិត្ត និងសេចក្តីសន្យាដោយស្ម័គ្រចិត្តណាមួយ ដែលត្រូវបានធ្វើឡើងដោយរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។

រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញនីមួយៗ ត្រូវបានផ្តល់នូវឱកាស ដើម្បីបង្ហាញថាតើគេ គាំទ្រដល់សេចក្តីសន្និដ្ឋាន/អនុសាសន៍ ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារលទ្ធផលដែរឬអត់ ។ គេអាចធ្វើកិច្ចការនេះ:

- នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមការងារ ។
- នៅចន្លោះពេលនៃវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ និងវគ្គប្រជុំពេញអង្គបន្ទាប់របស់ក្រុមប្រឹក្សា ឬ
- នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីអនុម័តឯកសារលទ្ធផលរបស់ក្រុមការងារ ។

អនុសាសន៍ដែលត្រូវបានគាំទ្រដោយរដ្ឋនោះ ត្រូវបានកំណត់ដោយឋានៈនោះឯង នៅក្នុងឯកសារលទ្ធផល ។ អនុសាសន៍ដែលមិនត្រូវបានគាំទ្រដោយរដ្ឋនោះ ត្រូវបានកត់សម្គាល់ទុក នៅក្នុងឯកសារលទ្ធផល រួមជាមួយនឹងសេចក្តីសង្កេតដែលរដ្ឋនោះ អាចមានលើអនុសាសន៍ទាំងនោះ ។

## ៤. ការអនុម័តឯកសារលទ្ធផល ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស

កាលណា ត្រូវបានអនុម័តដោយក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលភ្លាម របាយការណ៍ស្តីពីប្រទេសដែលត្រូវបានត្រួតពិនិត្យឡើងវិញនីមួយៗ ត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ តាមធម្មតា ក្រុមប្រឹក្សាពិចារណា និងអនុម័តឯកសារលទ្ធផលទាំងនេះនៅក្នុងវគ្គប្រជុំពេញធម្មតាបន្ទាប់របស់ខ្លួន ដោយដោយលៃទុកពេលវេលារហូតដល់មួយម៉ោងសម្រាប់ឯកសារលទ្ធផលនីមួយៗ ។

ដោយអនុលោមតាមសេចក្តីសម្រេចលេខ 5/1 មុនពេលដែលឯកសារលទ្ធផលនីមួយ ត្រូវបានអនុម័ត:

- រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ ត្រូវបានផ្តល់នូវឱកាស ដើម្បីបង្ហាញអំពីមតិយោបល់របស់ខ្លួនលើសេចក្តីសន្និដ្ឋាន/អនុសាសន៍ សេចក្តីសន្យា និងសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត និងដើម្បីបង្ហាញអំពីចម្លើយទៅនឹងសំណួរ ឬ បញ្ហាដែលមិនត្រូវបានដោះស្រាយពេញលេញនៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាដែលមានលក្ខណៈទំនាក់ទំនងគ្នាទៅវិញទៅមករបស់ក្រុមការងារ ។
- រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ និងរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍របស់ក្រុមប្រឹក្សា ត្រូវបានផ្តល់នូវឱកាសដើម្បីសម្តែងនូវមតិយោបល់របស់គេលើលទ្ធផល និង

- អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត (ក្នុងនោះរួមមាន ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC)) ត្រូវបានផ្តល់នូវឱកាស ដើម្បីធ្វើសេចក្តីសង្កេតទូទៅ ។

នៅពេលអនុម័តឯកសារលទ្ធផល ក្រុមប្រឹក្សា ក៏សម្រេចផងដែរថាតើ និងនៅពេលដែលការតាមដានបន្តជាក់លាក់ទៅនឹងការត្រួតពិនិត្យឡើងវិញ មានលក្ខណៈចាំបាច់ដែរឬអត់ ។

## ៥. ការតាមដានបន្តទៅនឹងការត្រួតពិនិត្យឡើងវិញ

សេចក្តីសន្និដ្ឋាន/អនុសាសន៍ ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារលទ្ធផលដែលទទួលបានការគាំទ្ររបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញ មានតួនាទីជាមូលដ្ឋានសម្រាប់ការតាមដានបន្តរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។

ជាបឋម វាជាការទទួលខុសត្រូវរបស់រដ្ឋដែលត្រូវបានត្រួតពិនិត្យឡើងវិញចំពោះការអនុវត្តលទ្ធផលរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល (ក្នុងនោះរួមមាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងសេចក្តីសន្យា និងសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តផងដែរ) ។ ទោះជាយ៉ាងណាក៏ដោយ **សេចក្តីសម្រេចចិត្តលេខ 5/1 ចែងថា អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន តួអង្គសង្គមស៊ីវិលផងដែរ ក៏មានតួនាទីផងដែរដែលត្រូវបំពេញក្នុងការអនុវត្តវា ។** សហគមន៍អន្តរជាតិ ជួយដល់រដ្ឋទាំងឡាយឲ្យអនុវត្តលទ្ធផលនៃការត្រួតពិនិត្យឡើងវិញស្តីពីការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ដោយពិគ្រោះយោបល់ជាមួយនឹងរដ្ឋទាំងនោះ និងដោយមានការយល់ព្រមរបស់គេ ។

ខួបនៃការត្រួតពិនិត្យឡើងវិញលើកក្រោយ នឹងផ្តោតក្នុងចំណោមកត្តាផ្សេងទៀត ទៅលើការអនុវត្តអនុសាសន៍របស់រដ្ឋនីមួយៗ និងដើម្បីសម្រេចគោលដៅនេះ ក្រុមប្រឹក្សាអាចដោះស្រាយតាមការចាំបាច់ករណីគ្មានកិច្ចសហការដែលមានលក្ខណៈរឹងត្អឹងជាមួយនឹងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ក្នុងករណីដែលយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនេះ បានប្រើប្រាស់អស់នូវកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីជំរុញលើកទឹកចិត្តដល់រដ្ឋឲ្យធ្វើសហប្រតិបត្តិការជាមួយនឹងខ្លួន ។

# ដំណើរការរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល



# វិធីចូលរួមពាក់ព័ន្ធជាមួយនឹងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

សង្គមស៊ីវិលមានតួនាទីសំខាន់ ត្រូវបំពេញនៅក្នុងដំណាក់កាល ដែលពាក់ព័ន្ធនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ពោលគឺនៅក្នុងការរៀបចំឯកសារស្នើសុំពិនិត្យ សម្រាប់ការត្រួតពិនិត្យឡើងវិញ ការចូលរួមក្នុងដំណើរការត្រួតពិនិត្យឡើងវិញ និងដោយរួមចំណែកដល់ការអនុវត្តបន្តទៅនឹងការអនុវត្តធម្មតានូវអនុសាសន៍ និងសេចក្ដីសន្និដ្ឋាន របស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។

## ក. ការធ្វើការងារជាមួយនឹងរដ្ឋទាំងឡាយ ដើម្បីរៀបចំរបាយការណ៍ជាតិ

សេចក្ដីសម្រេចចិត្តលេខ 5/1 ជំរុញលើកទឹកចិត្តដល់រដ្ឋទាំងឡាយឲ្យរៀបចំព័ត៌មានដែលគេដាក់ជូនពិនិត្យសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់គេ តាមរយៈដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយថ្នាក់ជាតិជាមួយនឹងអ្នកពាក់ព័ន្ធដែលពាក់ព័ន្ធទាំងអស់ ។ នេះអាចរួមបញ្ចូលស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ក៏ដូចគ្នា តំណាងសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល អ្នកការពារសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សាអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ ។

បទពិសោធន៍របស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល រហូតមកដល់ពេលនេះ បង្ហាញអំពីភាពនានានៃគំរូ "វិធីអនុវត្តន៍ត្រឹមត្រូវ" សម្រាប់កិច្ចសហប្រតិបត្តិការរបស់សង្គមស៊ីវិល និងរដ្ឋាភិបាលនៅក្នុងការរៀបចំរបាយការណ៍ជាតិ ។

## ការរួមចំណែកដល់ការរៀបចំព័ត៌មានរបស់រដ្ឋ (របាយការណ៍ជាតិ)

នៅក្នុងដំណើរការត្រៀមពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យឡើងវិញលើ**ប្រទេសស្វីស**នៅក្នុងវគ្គប្រជុំពេញអង្គលើកទីពីររបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៅក្នុងខែឧសភា ឆ្នាំ ២០០៨ សម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងប្រទេសស្វីសចំនួន ៣២ បានជួបប្រជុំគ្នាដើម្បីសម្របសម្រួលដល់ការរៀបចំរបស់សម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលនេះ ឲ្យចូលរួមនៅក្នុងកិច្ចពិភាក្សារយៈពេលមួយថ្ងៃជាមួយនឹងរដ្ឋាភិបាល ។ នៅក្នុងកិច្ចប្រជុំនោះ សម្ព័ន្ធភាពចម្រុះ បានផ្ដល់សេចក្ដីសង្កេតដ៏សំខាន់លើសេចក្ដីព្រាងរបាយការណ៍របស់ឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ។ ដោយត្រូវបានសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាលចំនួនបី (**អង្គការលើកលែងទោសផ្នែកស្វីស អង្គការ យូមែនរ៉ាយស៍ និងមជ្ឈមណ្ឌលអប់រំ និងគាំទ្រផ្នែកសិទ្ធិមនុស្សសម្រាប់យុវជន(CODAP)**) "សម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាល" បានរៀបចំ និងបញ្ជូនសេចក្ដីព្រាងដំបូងនៃឯកសារស្នើរដ្ឋាភិបាល និងបានបង្ហាញនូវអនុសាសន៍មួយស៊េរី ។ សេចក្ដីសង្កេតមួយចំនួនរបស់សម្ព័ន្ធភាពចម្រុះត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ជាតិក្នុងទម្រង់ចុងក្រោយដែលត្រូវបានដាក់ជូនពិនិត្យទៅយន្តការត្រួតពិនិត្យឡើងវិញតាមសុំពិនិត្យរបស់ខ្លួនទៅរដ្ឋាភិបាលស្វីស ។

រដ្ឋាភិបាលសហព័ន្ធស្វីសបានដាក់ជូនពិនិត្យនូវសេចក្ដីព្រាងរបាយការណ៍ជាតិរបស់ខ្លួនដែលត្រូវដាក់ជូនទៅយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ជូនទៅសម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាល និងបានអញ្ជើញសមាជិកដំណាក់កាលជាសកល ដោយរដ្ឋាភិបាល ក៏បានបូជាវិភាជន៍ផងដែរនូវរបាយការណ៍មួយផ្នែករបស់ខ្លួនទៅលើការកំណត់ និងការដោះស្រាយកង្វល់ចម្បងបំផុតខ្លះ ដែលត្រូវបានលើកឡើងដោយសម្ព័ន្ធភាពចម្រុះនោះ ។

## ខ. ឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ

ស្របតាមសេចក្ដីសម្រេចចិត្តលេខ 5/1 អ្នកពាក់ព័ន្ធក៏ត្រូវបានអញ្ជើញផងដែរឲ្យដាក់ជូនពិនិត្យនូវឯកសារស្នើសុំពិនិត្យស្ដីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ សម្រាប់ការដាក់បញ្ចូលជាសក្ខានុពលទៅក្នុងសេចក្ដីសង្ខេបនៃឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ដែលត្រូវបានរៀបចំដោយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។ សេចក្ដីសង្ខេបនៃឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ដែលត្រូវបានរៀបចំដោយការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គឺជាឯកសារមួយក្នុងចំណោមឯកសារចំនួនបីដែលដំណើរការត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្តដោយមានមូលដ្ឋាននៅលើឯកសារទាំងនោះនោះ ។

ឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ គួរតែរួមបញ្ចូលព័ត៌មានដែលគួរឲ្យជឿ និងជឿទុកចិត្តបានស្ដីពីរដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ។

ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រៀបចំសេចក្ដីយោងលើឯកសារស្នើសុំពិនិត្យទាំងអស់របស់អ្នកពាក់ព័ន្ធដែលត្រូវបានបញ្ចូលទៅក្នុងឯកសារសង្ខេប ។ ជាង

នេះទៀត ឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធ ត្រូវបានរៀបចំឲ្យមាន ជាទម្រង់ច្បាប់ដើមដូចដែលត្រូវបាន ទទួល តាមរយៈ**ផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** នៃរិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ការរៀបចំ និងការដាក់ជូនពិនិត្យនូវឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

**ក្រុមការងារសិទ្ធិមនុស្ស (HRWG) - ឥណ្ឌូនេស៊ី** ដែលជាសម្ព័ន្ធភាពចម្រុះនៃអង្គការសិទ្ធិមនុស្សរបស់ឥណ្ឌូនេស៊ី បានរួមចំណែកដល់ឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធសម្រាប់ការត្រួតចំនួន ដែលធ្វើការងារខាងបញ្ហាប្រធានបទ ឲ្យជួបប្រជុំគ្នាដើម្បីពិភាក្សាជាមួយនឹងយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងដើម្បីបង្កើតទម្រង់ និងរចនាសម្ព័ន្ធសម្រាប់ឯកសារស្នើសុំពិនិត្យ។បន្ទាប់ពីកិច្ចប្រជុំអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ត្រូវបានបែងចែកការទទួលខុសត្រូវចំពោះការរៀបចំព័ត៌មានដែលពាក់ព័ន្ធទៅនឹងវិស័យជំនាញចំនួនមួយ

ពិនិត្យឡើងវិញលើ**ប្រទេសឥណ្ឌូនេស៊ី**នៅក្នុងវគ្គប្រជុំពេញអង្គលើកទីមួយរបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៅ ក្នុងខែមេសា ឆ្នាំ ២០០៨ ។

(ឬច្រើន)របស់ខ្លួនចំណែកឯក្រុមការងារសិទ្ធិមនុស្ស-ឥណ្ឌូនេស៊ីអនុវត្តការទទួលខុសត្រូវផ្នែកពិនិត្យផ្ទៀងផ្ទាត់ចំពោះឯកសារស្នើសុំពិនិត្យ ដោយបញ្ជូនវាទៅលេខាធិការដ្ឋានរបស់យន្តការត្រួត ពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

នៅក្នុងការរៀបចំឯកសារស្នើសុំពិនិត្យរបស់ខ្លួន ក្រុមការងារសិទ្ធិមនុស្ស-ឥណ្ឌូនេស៊ី បានទទួលអនុវត្តដំណើរការ "ពីក្រោមឡើងលើ" ដោយអញ្ជើញអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ

ក្រុមការងារសិទ្ធិមនុស្សឥណ្ឌូនេស៊ីក៏បានសហការជាមួយនឹងគណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិមនុស្សផងដែរ ដែលជាស្ថាប័នជាតិឥណ្ឌូនេស៊ីទទួលបន្ទុកសិទ្ធិមនុស្ស និងបានចូលរួមពាក់ព័ន្ធនៅក្នុងកិច្ចសន្ទនាជាមួយនឹងក្រសួងការបរទេសរបស់ឥណ្ឌូនេស៊ីនៅក្នុងការរៀបចំឯកសារស្នើសុំពិនិត្យរបស់អ្នកពាក់ព័ន្ធរបស់គេ ។

### ទម្រង់នៃឯកសារស្នើសុំពិនិត្យ

*អ្នកពាក់ព័ន្ធ ត្រូវបានស្នើសុំឲ្យផ្តល់ដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នូវឯកសារស្នើសុំពិនិត្យដែលៈ*

- អនុវត្តតាមរចនាសម្ព័ន្ធនៃគោលការណ៍ណែនាំទូទៅ សម្រាប់ការរៀបចំព័ត៌មានក្រោមយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដែលត្រូវបានចែងនៅក្នុង**សេចក្តីសម្រេចលេខ 6/102** របស់ក្រុមប្រឹក្សា (ចូរមើលផ្នែកពីមុន) ។
- មិនត្រូវមានលើសពី ៥ ទំព័រ ឬ នៅក្នុងករណីសម្ព័ន្ធភាពចម្រុះនៃអ្នកពាក់ព័ន្ធមានទំហំធំ ត្រូវមាន ១០ ទំព័រ ។

- មានរយៈពេលជាអតិបរមា បួនឆ្នាំ ។
- ត្រូវបានសរសេរជាភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ ដោយពេញចិត្តជាងនោះគឺ ភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ។
- ផ្តល់នូវព័ត៌មានជាកថាខ័ណ្ឌខ្លីៗលើទិសដៅ និងការងាររបស់អង្គភាព ដែលដាក់ជូនពិនិត្យនូវឯកសារស្នើសុំពិនិត្យ ។
- មានទម្រង់ជាការងារសម្រង់អត្ថបទរួម ដោយមានកថាខ័ណ្ឌ និងទំព័រដែលត្រូវបានដាក់លេខរៀង ។
- រួមបញ្ចូលកថាខ័ណ្ឌនាំមុខ ដែលសង្ខេបអំពីចំណុចសំខាន់បំផុត ។
- បង្ហាញអំពីពាក្យពេចន៍សំខាន់បំផុតដែលទាក់ទងនឹងឯកសារស្នើសុំពិនិត្យ (ឧទាហរណ៍ដូចជា អំពើហិង្សាក្នុងគ្រួសារ) ។
- បញ្ឈប់ការផលិតឡើងវិញនូវសេចក្តីសង្កេតសន្និដ្ឋាន និងអនុសាសន៍របស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ឬ យន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ថ្វីបើវាអាចសំដៅទៅលើកម្រិតនៃការអនុវត្តក្តី[68] និង
- បញ្ឈប់ការដកស្រង់ពាក្យ ឬ ការបញ្ចូលជាឧបសម្ព័ន្ធនូវរបាយការណ៍ពីអង្គការផ្សេងទៀត ។

សូមកត់សម្គាល់ថាៈ

- ឯកសារស្នើសុំពិនិត្យដែលលើសពីកម្រិត ៥ ឬ ១០ ទំព័រ នឹងមិនត្រូវបានពិចារណាឡើយ ។
- ឯកសារស្នើសុំពិនិត្យដែលត្រូវបានទទួលជាភាសា ក្រៅពីភាសាមួយផ្លូវការមួយ ក្នុងចំណោមភាសាផ្លូវការចំនួនប្រាំមួយរបស់អង្គការសហប្រជាជាតិ នឹងមិនត្រូវបានពិចារណាឡើយ ។
- ឯកសារស្នើសុំពិនិត្យ ដែលត្រូវបានដាក់ជូនពិនិត្យ ក្រោយកាលបរិច្ឆេទកំណត់ឈប់ទទួលឯកសារស្នើសុំពិនិត្យ នឹងមិនត្រូវបានពិចារណាឡើយ និង
- ឯកសារស្នើសុំពិនិត្យ ដែលបញ្ចូលពាក្យរំលោភបំពានជាក់ស្តែង (ឧទាហរណ៍ដូចជា ការញុះញង់ឲ្យមានអំពើហិង្សា ភាសាដែលមានជាប់ជាមួយនូវការប្រកាន់ពូជសាសន៍) នឹងមិនត្រូវបានពិចារណាឡើយ ។

[68] អនុសាសន៍ និងសេចក្តីសង្កេតរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការពិសេស ត្រូវបានដាក់បញ្ចូលទៅក្នុងកម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

*i*

តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាទៀងទាត់នូវផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល នៃវិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់កាលបរិច្ឆេទផុតកំណត់ទទួលឯកសារស្នើសុំពិនិត្យ ដែលមានលក្ខណៈជាក់លាក់ចំពោះវគ្គប្រជុំពេញអង្គនីមួយៗរបស់ក្រុមការងារ ។ **តាមធម្មតា ព័ត៌មានរបស់អ្នកពាក់ព័ន្ធគួរតែត្រូវបានដាក់ជូនពិនិត្យទៅការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងរយៈពេលប្រាំពីរខែ មុនពេលវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ។**

តួអង្គសង្គមស៊ីវិលដែលមានបំណងប្រាថ្នាចង់ដាក់ជូនពិនិត្យនូវព័ត៌មានសម្រាប់ការពិចារណា និងការដាក់បញ្ចូលដែលអាចធ្វើបានដោយការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ទៅក្នុងកម្រងព័ត៌មានរបស់អ្នកពាក់ព័ន្ធ គួរតែផ្ញើវិភាគទានរួមចំណែករបស់ខ្លួនទៅៈ **UPRsubmissions@ohchr.org** ។

ទោះបីជាតួអង្គសង្គមស៊ីវិល មិនត្រូវបានជំរុញលើកទឹកចិត្តឲ្យផ្ញើតាមទូរសារ ឬ ប៉ុស្តិ៍ប្រៃសណីយ៍នូវច្បាប់ចម្លងឯកសារស្នើសុំពិនិត្យរបស់គេ ទៅលេខាធិការដ្ឋាននៃការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ដោយ ក៏គេអាច ប្រសិនបើមានការលំបាកផ្នែកបច្ចេកទេសជាមួយនឹងសារតាមអេឡិចត្រូនិចនោះ ចូរផ្ញើឯកសារស្នើសុំពិនិត្យរបស់ខ្លួនទៅលេខ +៤១ (0)២២ ៩១៧ ៩០ ១១ ។

តួអង្គសង្គមស៊ីវិល ក៏ត្រូវបានជំរុញលើកទឹកចិត្តផងដែរ ឲ្យមើល**គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការដាក់ជូនពិនិត្យនូវព័ត៌មានរបស់អ្នកពាក់ព័ន្ធ** ។

## គ. ការចូលរួមវគ្គប្រជុំពេញអង្គរបស់ក្រុមការងារទទួលបន្ទុកពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាតភ្លាម អាចចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ប៉ុន្តែមិនអាចអានសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលបានទេ ។

*i*

សម្រាប់ព័ត៌មាន ស្តីពី **វិធីសុំការអនុញ្ញាតចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់លក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

### វគ្គផ្សព្វផ្សាយព័ត៌មាន

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាគេ ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់ក្រុមការងារភ្លាម អាចរៀបចំត្រៀម ដើម្បីរៀបចំវគ្គផ្សព្វផ្សាយព័ត៌មាននៅក្នុងអំឡុងពេលនៃវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ។ អង្គការមិនមែនរដ្ឋាភិបាលដែលចាប់អារម្មណ៍ក្នុងការរៀបចំវគ្គប្រជុំពេញអង្គបែបនេះ គួរតែទាក់ទងនឹង**លេខាធិការដ្ឋានរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។**

## ឃ. ការចូលរួមវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) កាលណាត្រូវបានអនុញ្ញាតភ្លាម អាចចូលរួមក្នុងវគ្គប្រជុំពេញអង្គធម្មតារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលនៅក្នុងនោះ ឯកសារលទ្ធផលរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ត្រូវបានពិចារណា និងអនុម័ត ។

**អង្គការមិនមែនរដ្ឋាភិបាល ក្នុងឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (ECOSOC) ត្រូវបានផ្តល់នូវឱកាសឲ្យធ្វើសេចក្តីសង្កេតទូទៅយ៉ាងសង្ខេប មុននឹងការអនុម័តលើឯកសារលទ្ធផលដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ។**

*i* សម្រាប់ព័ត៌មានស្តីពីវិធី**សុំការអនុញ្ញាតចូលរួមវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស** សូមមើល**ជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស)** នៃ*សៀវភៅ*នេះ ។

## ឃ. ការអនុវត្តបន្តនូវលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ

សេចក្តីសម្រេចចិត្តលេខ 5/1 ចែងថា ជាបឋម វាជាការទទួលខុសត្រូវរបស់រដ្ឋទាំងឡាយក្នុងការអនុវត្តលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញរបស់គេ (ក្នុងនោះរួមមាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងសេចក្តីសន្យា និងសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត) ។ **សេចក្តីសម្រេចចិត្តលេខ 5/1 ក៏ចែងផងដែរថា អ្នកពាក់ព័ន្ធដែលពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន តួអង្គសង្គមស៊ីវិលផងដែរ មានតួនាទីត្រូវបំពេញនៅក្នុងការអនុវត្តនេះ ។**

តួអង្គសង្គមស៊ីវិល ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាអប់រំ ប្រព័ន្ធផ្សព្វផ្សាយសហជីព និងក្រុមអ្នកវិជ្ជាជីវៈ អាចអនុវត្តបន្តនូវលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល តាមរបៀបមួយចំនួន ដូចជា:

- ការធ្វើការងារជាមួយនឹងអង្គភាពជាតិ (ក្នុងនោះរួមមាន រដ្ឋាភិបាល សភា តុលាការ និងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស) ដើម្បីជួយដល់រដ្ឋឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួន ។ សង្គមស៊ីវិល ជារឿយៗបំពេញមុខងារជាកាតាលីករ ដើម្បីលើកកម្ពស់កំណែទម្រង់ច្បាប់ជាតិ និងរៀបចំគោលនយោបាយជាតិ ។ សង្គមស៊ីវិល ក៏អាចប្រើប្រាស់លទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលជាមូលដ្ឋានសម្រាប់ការសន្ទនាជាមួយនឹងអង្គភាពរដ្ឋ និងសម្រាប់កំណត់កម្មវិធីសកម្មភាពផ្ទាល់របស់ខ្លួន ។
- ការពិនិត្យតាមដានស្ថានភាពសិទ្ធិមនុស្ស និងជំហានដែលត្រូវបានប្រកាន់យកនៅក្នុងមូលដ្ឋាន ដើម្បីអនុវត្តលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។
- លើកកម្ពស់ការយល់ដឹងអំពីយន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល លទ្ធផលដែលរដ្ឋទាំងឡាយ ត្រូវបានតម្រូវឲ្យអនុវត្ត និងថាតើលទ្ធផលអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើឲ្យប្រសើរឡើងនូវការទទួលបានសិទ្ធិមនុស្សនៅក្នុងប្រទេសដោយរបៀបណា ។ នេះអាចត្រូវបានធ្វើឡើងតាមរយៈការរៀបចំកិច្ចពិភាក្សាប្រធានបទទូទៅ កិច្ចប្រជុំតុមូល សិក្ខាសាលាធម្មតា និងសិក្ខាសាលាពិភាក្សា ការបកប្រែភាសា និងការបោះពុម្ពផ្សាយលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងការធ្វើការងារជាមួយនឹងស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) និងប្រព័ន្ធផ្សព្វផ្សាយជាតិ និងដោយលើកកម្ពស់ការយល់ដឹងអំពីលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលនៅក្នុងចំណោមសាធារណជនទូទៅ និងសង្គមស៊ីវិល ។
- ដោយចូលរួមពាក់ព័ន្ធជាមួយនឹងអង្គភាពជាតិ ឆ្ពោះទៅរកការរៀបចំព័ត៌មានសម្រាប់ការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាបន្ទាប់ និង
- សហការជាមួយនឹងតួអង្គសង្គមស៊ីវិលផ្សេងទៀត នៅក្នុងការរៀបចំ និងការដាក់ជូនពិនិត្យទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នូវព័ត៌មានសម្រាប់ការអនុវត្តបន្តលើការអនុវត្តលទ្ធផល នៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល។

## ការអនុវត្តបន្តនូវលទ្ធផល នៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

***ការអនុវត្តបន្តនូវរបាយការណ៍ដែលត្រូវបានអនុម័តដោយក្រុមការងារទទួលបន្ទុកត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល***

បន្ទាប់ពីដំណើរការត្រួតពិនិត្យឡើងវិញ និងការអនុម័តរបាយការណ៍ស្តីពីប្រទេសប្រេស៊ីល របស់ក្រុមការងារនៅក្នុងខែ មេសា ឆ្នាំ ២០០៨ រួចមក **អង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សកូណិកតាសរបស់ប្រេស៊ីល** ដែលជាអង្គការសិទ្ធិមនុស្សរបស់ប្រេស៊ីល បានទទួលអនុវត្តសកម្មភាពដូចតទៅៈ

- អង្គការនេះ បានបកប្រែអនុសាសន៍ និងសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្រដែលត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍របស់ក្រុមការងារទៅជាភាសាប៉ុទុយហ្គាល់ ។
- អង្គការនេះ បានវិភាគខ្លឹមសារនៃរបាយការណ៍របស់ក្រុមការងារ សេចក្តីសន្និដ្ឋានដែលខ្លឹមសាររបស់វា ត្រូវបានជម្រាបជូនទៅរដ្ឋាភិបាលប្រេស៊ីល និងត្រូវបានកំណត់ដោយអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សកូណិកតាសរបស់ប្រេស៊ីល នៅក្នុងបទអន្តរាគមន៍ដោយផ្ទាល់មាត់ ដែលត្រូវបានធ្វើឡើងនៅក្នុងវគ្គប្រជុំពេញអង្គទីប្រាំបីរបស់ក្រុមប្រឹក្សា និង
- ដោយសហការជាមួយនឹងសម្ព័ន្ធភាពចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រេស៊ីល (**គណៈកម្មាធិការ ប្រេស៊ីល ទទួលបន្ទុកសិទ្ធិមនុស្ស និងគោលនយោបាយបរទេស**) អង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សកូណិកតាសរបស់ប្រេស៊ីល បានរៀបចំកិច្ចពិភាក្សាជាសាធារណៈស្តីពីដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកលជាមួយនឹងគណៈកម្មការសិទ្ធិមនុស្សរបស់សភាប្រេស៊ីល ។ ផ្នែកទាំងឡាយនៃកម្មវិធីផ្សាយលើ អ៊ិនធើណិត ស្តីពីដំណើរការត្រួតពិនិត្យឡើងវិញលើប្រទេស ប្រេស៊ីល ត្រូវបានជ្រើសរើសនៅក្នុងកិច្ចប្រជុំ ។

***ការអនុវត្តបន្តនូវរបាយការណ៍នៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស***

ចាប់តាំងពីមានការអនុម័តលើរបាយការណ៍ចុងក្រោយ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សមកលើប្រទេស ប្រេស៊ីល អង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្ស កូណិកតាស :

- បានអនុវត្តបន្តនូវអនុសាសន៍ និងសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្ររបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដោយបង្កើតឡើងវិញនូវភាពជាដៃគូជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារខាងបញ្ហាជាក់លាក់ ដើម្បីវាយតម្លៃវឌ្ឍនភាពរបស់ប្រទេសប្រេស៊ីលនៅក្នុងការអនុវត្តលទ្ធផលនៃដំណើរការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ។
- បានធ្វើការងារជាមួយនឹងរដ្ឋាភិបាលនៅក្នុងដំណើរការ ដែលកំពុងតែបន្តដើម្បីកំណត់អំពីវិធានការ និងគោលនយោបាយពិតជាក់ស្តែងឆ្ពោះទៅរកការអនុវត្តអនុសាសន៍របស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល និងការសម្រេចបានសេចក្តីប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត ។

អង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សកូណិកតាសរបស់ប្រេស៊ីល ក៏បានចែករំលែកផងដែរនូវបទពិសោធន៍របស់ខ្លួនជាមួយនឹងអង្គការដៃគូនៅក្នុងប្រទេសអាសង់ទីន ប៉េរូ ភីលីពីន និងអាព្រិចខាងត្បូង ដើម្បីរួមចំណែកដល់ការត្រួតពិនិត្យឡើងវិញលើប្រទេសទាំងនេះ ។

# ធនធានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

## វិបសាយរបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល

តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាទៀងទាត់នូវផ្នែករបស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល នៃវិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីវគ្គប្រជុំពេញអង្គរបស់ក្រុមការងារ ។

## វិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

តួអង្គសង្គមស៊ីវិល ត្រូវបានជំរុញលើកទឹកចិត្តឲ្យមើលជាទៀងទាត់ នូវផ្នែករបស់ក្រុមប្រឹក្សានៃវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សម្រាប់ព័ត៌មានបច្ចុប្បន្នភាព និងព័ត៌មានស្តីពីវគ្គប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា ។ តាមធម្មតា ព័ត៌មានដែលពាក់ព័ន្ធនឹងវគ្គប្រជុំពេញអង្គ ត្រូវបានដាក់ផ្សាយនៅក្នុងវិបសាយក្នុងរយៈពេលពីរសប្តាហ៍មុនវគ្គប្រជុំពេញអង្គធម្មតានីមួយៗ ។

## ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត)

**ប្រព័ន្ធកុំព្យូទ័រ (អិក្សត្រាណិត)** ត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងគេហទំព័រវិបសាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ វារួមបញ្ចូលគេហទំព័រ ដែលត្រូវបានបូជាវិភាគ៍របស់យន្តការត្រួតពិនិត្យឡើងវិញតាមដំណាក់កាលជាសកល ដោយមានព័ត៌មានដែលមានលក្ខណៈជាក់លាក់ ចំពោះវគ្គប្រជុំពេញអង្គនីមួយៗរបស់ក្រុមការងារ ក្នុងនោះរួមមានៈ

- រដ្ឋ (ដែលត្រូវបាន) ដែលត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងវគ្គប្រជុំពេញអង្គ ។
- ឯកសារដែលដំណើរការត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្តដោយមានមូលដ្ឋាននៅលើឯកសារនោះនោះ ។
- បញ្ហាដែលត្រូវបានដាក់ជូនពិនិត្យទៅរដ្ឋទាំងឡាយ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញដោយរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សា មុនពេលដំណើរការត្រួតពិនិត្យឡើងវិញ ។
- សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដែលត្រូវបានអានដោយផ្ទាល់មាត់ ដែលត្រូវបានធ្វើឡើងដោយរដ្ឋជាសមាជិក និងរដ្ឋសង្កេតការណ៍នៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញ និង
- ឯកសារលទ្ធផល ដែលត្រូវបានអនុម័តដោយក្រុមការងារ ។

i

ដើម្បីចូលមើលគេហទំព័រប្រព័ន្ធកុំព្យូទ័រ (អិក្សាត្រាណិត) ដែលត្រូវបានការពារដោយអក្សរសម្ងាត់នោះ ចូរបំពេញទម្រង់តាមបណ្តាញអេឡិចត្រូនិចដែលត្រូវបានរៀបចំឲ្យមាន ។ នៅពេលដែលអ្នកធ្វើកិច្ចការនេះចប់ អ្នកនឹងទទួលបានឈ្មោះអ្នកប្រើប្រាស់ និងអក្សរសម្ងាត់ តាមរយៈអ៊ីម៉ែល។

## កម្មវិធីផ្សាយនៅលើអ៊ិនធើណិត

វគ្គប្រជុំពេញអង្គរបស់ក្រុមការងារ អាចត្រូវបានមើលផ្ទាល់នៅក្នុងកម្មវិធីផ្សាយលើអ៊ិនធើណិតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ទីកន្លែងកម្មវិធីផ្សាយលើអ៊ិនធើណិត ក៏រួមបញ្ចូលវីដេអូដែលបានរក្សាទុកស្តីពីវគ្គប្រជុំពេញអង្គមុនៗរបស់ក្រុមប្រឹក្សា ។ ដើម្បីមើលកម្មវិធីផ្សាយលើអ៊ិនធើណិត អ្នកនឹងចាំបាច់ត្រូវផ្ទេរចេញយកមកប្រើប្រាស់នូវផ្នែកទន់សមស្រប ។

i

សេវាកម្មវិធីផ្សាយលើអ៊ិនធើណិត ត្រូវបានរៀបចំឲ្យមានពីផ្នែករបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃវិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

# VIII. ការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍

## ទិដ្ឋភាពរួមនៃយន្តការបណ្តឹង

***ដូចម្តេចដែលហៅថា យន្តការបណ្តឹង ?***

យន្តការបណ្តឹងផ្នែកសិទ្ធិមនុស្ស គឺជាយន្តការសម្រាប់ជម្រាបជូនទៅអង្គការសហប្រជាជាតិ អំពីករណីនៃការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍ ។ មានយន្តការបែបនេះចំនួន បីប្រភេទ:

- បណ្តឹងជាលក្ខណៈបុគ្គល ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស (បដ្ឋនាលិខិត) ។
- បណ្តឹងជាលក្ខណៈបុគ្គលក្រោម **យន្តការពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** និង
- **យន្តការបណ្តឹង**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

***តើយន្តការបណ្តឹង ធ្វើការងារដោយរបៀបណា ?***

យន្តការនីមួយៗ មានតម្រូវការ អត្ថប្រយោជន៍ និងការកម្រិតលក្ខខណ្ឌផ្ទាល់របស់វា ។ ទាំងនេះ ចាំបាច់ត្រូវបានពិចារណាដោយប្រុងប្រយ័ត្ន មុននឹងសម្រេចថាតើត្រូវប្រើយន្តការណាមួយ (ឬណាខ្លះ):

- បណ្តឹងជាលក្ខណៈបុគ្គលលើការរំលោភបំពានសិទ្ធិមនុស្ស អាចត្រូវបានដាក់ជូនពិនិត្យ ដូចដែលមានចែងនៅក្នុង**សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ**សំខាន់បំផុតចំនួនប្រាំ ។
- បណ្តឹងជាលក្ខណៈបុគ្គល ដំណើរការនៅក្រោមអាណត្តិប្រធានបទ និងភូមិសាស្ត្ររបស់យន្តការពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស និងយន្តការបណ្តឹងរបស់ក្រុមប្រឹក្សាផ្តោតទៅលើគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងដែលមានទឡ្ហីករណ៍ដែលគួរឲ្យជឿទុកចិត្តបានលើសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូលដ្ឋានទាំងអស់ដែលកើតមានឡើងនៅក្នុងផ្នែកណាមួយនៃពិភពលោក និងកាលៈទេសៈណាមួយ ។

***វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹងយន្តការបណ្តឹង***

តួអង្គសង្គមស៊ីវិលណាមួយក៏ដោយ ដោយបានពិចារណាត្រឹមត្រូវលើតម្រូវការជាក់លាក់នៃយន្តការនីមួយៗ អាចប្រើប្រាស់យន្តការទាំងនេះ ដោយមិនគិតដល់ឋានៈជាមួយនឹងអង្គការសហប្រជាជាតិទេ។ បណ្តឹងក្រោមយន្តការនីមួយៗនៃយន្តការទាំងនេះអាចត្រូវបានដាក់ជូនពិនិត្យដោយបុគ្គលដែលទទួលរងការរំលោភបំពានលើសិទ្ធិមនុស្ស ដែលមានទឡ្ហីករណ៍ ឬក្នុងនាមបុគ្គលនោះ ដោយភាគីទីបី ឧទាហរណ៍: អង្គការមិនមែនរដ្ឋាភិបាល (NGO) ។ ជារឿយៗ តួអង្គសង្គមស៊ីវិល អាចបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកសំណងពីការបំពានសិទ្ធិមនុស្ស តាមរយៈការរៀបចំការដាក់ជូនពិនិត្យ ឬការប្តឹងក្នុងនាមពួកគេ ។

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

| | | |
|---|---|---|
| ទោះជាយ៉ាងណាក៏ដោយ នរណាម្នាក់ក៏ដោយដែលដាក់ជូនពិនិត្យនូវបណ្តឹងក្នុងនាមរបស់បុគ្គលគួរតែធានាថា ពួកគេទទួលបាន | ការយល់ព្រមពីបុគ្គលនោះ និងថាបុគ្គលនោះគឺដឹងអំពីការជាប់ទាក់ទិននៃការប្តឹង ។ តម្រូវការសម្រាប់យន្តការនីមួយៗ គួរតែត្រូវបាន | អនុវត្តតាមដោយប្រុងប្រយ័ត្ន ដើម្បីធានាថា ពាក្យបណ្តឹងអាចត្រូវបានទទួលយក ។ |

**i**

## អ្នកដែលអាចទាក់ទងបានសំខាន់ៗសម្រាប់យន្តការបណ្តឹងផ្នែកសិទ្ធិមនុស្ស

**បណ្តឹងដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស**

(ជូនចំពោះ **គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងជាតិសាសន៍ ឬ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិរបស់ជនពិការ**)

ក្រុមបដ្ឋនាលិខិត
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០ ២២
អ៊ីម៉ែលៈ **tb-petitions@ohchr.org**

**បណ្តឹងក្រោមយន្តការពិសេស**

ផ្នែកយន្តការពិសេស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០ ០៦
អ៊ីម៉ែលៈ **urgent-action@ohchr.org**

**យន្តការបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស (យន្តការបណ្តឹង)
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០ ១១
អ៊ីម៉ែលៈ **CP@ohchr.org**

## ដូចម្តេចដែលហៅថា យន្តការបណ្តឹង ?

ប្រព័ន្ធអង្គការសហប្រជាជាតិ ផ្តោតភាគច្រើនទៅលើកាតព្វកិច្ចរបស់រដ្ឋ និងដំណើរការនៅកម្រិតរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធសិទ្ធិមនុស្សរបស់ខ្លួន ក៏រួមបញ្ចូលផងដែរនូវយន្តការខុសៗគ្នា ដែលបើកទូលាយដល់បុគ្គល និងក្រុមមនុស្សដែលស្វែងរកវិធានការរបស់អង្គការសហប្រជាជាតិលើស្ថានភាពសិទ្ធិមនុស្សដែលជាកង្វល់ចំពោះគេ ។ ទាំងនេះ ត្រូវបានហៅថា យន្តការបណ្តឹងផ្នែកសិទ្ធិមនុស្ស ។

តាមរយៈយន្តការទាំងនេះ បុគ្គលទាំងឡាយ អាចជម្រាបជូនអង្គការសហប្រជាជាតិអំពីកង្វល់ផ្នែកសិទ្ធិមនុស្ស ។ មនុស្សរាប់ពាន់នាក់នៅជុំវិញពិភពលោក ធ្វើដូច្នេះ រៀងរាល់ឆ្នាំ ។

បណ្តឹងផ្នែកសិទ្ធិមនុស្ស អាចត្រូវបានដាក់ជូនពិនិត្យ ក្រោមយន្តការទាំងបីនេះ:

- **សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ** (បដ្ឋនាលិខិត) ។
- **យន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស** និង
- **យន្តការបណ្តឹង**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

ក្រោមកាលៈទេសៈខ្លះ យន្តការខុសៗគ្នាទាំងនេះ អាចបំពេញគ្នាទៅវិញទៅមក និងយន្តការលើសពីមួយ អាចត្រូវបានប្រើប្រាស់ ។

## តើយន្តការបណ្តឹង ធ្វើការងារដោយរបៀបណា ?

វាមានលក្ខណៈសំខាន់ ត្រូវពិចារណាដោយប្រុងប្រយ័ត្នថាតើយន្តការបណ្តឹងណា សមបំផុតចំពោះករណីពិសេសណាមួយ ។ យន្តការបណ្តឹងនីមួយៗ មានចំណុចខ្លាំង តម្រូវការជាក់លាក់ និងការកម្រិតលក្ខខណ្ឌ ។ យន្តការបណ្តឹងទាំងនេះ ចាំបាច់ត្រូវបានពិចារណាជាប្រយោជន៍ដល់ជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) និងបុគ្គលម្នាក់ (ឬ ច្រើននាក់) ឬ អង្គការមួយ (ឬ ច្រើន) ដែលដាក់ឲ្យពិភាក្សានូវពាក្យបណ្តឹងនោះ ។

### ក. បណ្តឹងជាលក្ខណៈបុគ្គល ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនប្រាំពីរ អនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គលជូនទៅអង្គ/គណៈសន្ធិសញ្ញាសិទ្ធិមនុស្ស:

- **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ក្រោម**ពិធីសារបន្ថែមទីមួយរបស់វា** ។
- **អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** ដូចដែលមានចែងនៅក្នុងមាត្រា ២២ របស់វា ។

- **អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ** ក្រោម**ពិធីសារបន្ថែម**របស់វា (សន្ធិសញ្ញានេះ ក៏អនុញ្ញាតផងដែរឲ្យមានបណ្តឹងពីក្រុមបុគ្គល) ។
- **អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍** ដូចដែលមានចែងនៅក្នុងមាត្រា ១៤ របស់វា (សន្ធិសញ្ញានេះ ក៏អនុញ្ញាតផងដែរឲ្យមានបណ្តឹងពីក្រុមបុគ្គល) ។
- **អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកទាំងអស់របស់គ្រួសារពួកគេ** ដូចដែលមានចែងនៅក្នុងមាត្រា ៧៧ របស់វា ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិនេះ នឹងចូលជាធរមាន តែនៅពេលបន្ទាប់ពីភាគីរដ្ឋចំនួន ១០ បានធ្វើសេចក្តីប្រកាសដើម្បីគោលបំណងនោះ ។[69]
- **អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** ក្រោមពិធីសារបន្ថែមរបស់វា (សន្ធិសញ្ញានេះ ក៏អនុញ្ញាតផងដែរឲ្យមានបណ្តឹងពីក្រុមបុគ្គល) និង
- **អនុសញ្ញាអន្តរជាតិដើម្បីកិច្ចការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ** ដូចដែលមានចែងនៅក្នុងមាត្រា ៣១ របស់វា ។ នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ អនុសញ្ញានេះ មិនទាន់ចូលជាធរមាននៅឡើយទេ ។

នៅពេលចូលជាធរមាន **ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌**[70] ក៏នឹងអនុញ្ញាតឲ្យមានបណ្តឹងជាលក្ខណៈបុគ្គលផងដែរ ។

## ចំណុចខ្លាំង

- អត្ថប្រយោជន៍ដ៏សំខាន់នៃការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងទៅស្ថាប័នសន្ធិសញ្ញា គឺថា កាលណាភាគីរដ្ឋបានធ្វើសេចក្តីប្រកាសដែលពាក់ព័ន្ធភ្លាម ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញា **ភាគីរដ្ឋនោះគួរតែអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន** ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ ក្នុងនោះរួមមានកាតព្វកិច្ចក្នុងការផ្តល់ឧបាស្រ័យប្រកបដោយប្រសិទ្ធភាព ចំពោះការប្រព្រឹត្តល្មើសលើសន្ធិសញ្ញាផងដែរ ។ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សដែលពាក់ព័ន្ធ តាមរយៈបណ្តឹងជាលក្ខណៈបុគ្គល កំណត់ដោយអាជ្ញាព្រឹត្តថាតើមានការរំលោភបំពានដែរឬអត់ និងរដ្ឋដែលពាក់ព័ន្ធ មានកាតព្វកិច្ចអនុវត្តលទ្ធផលរកឃើញមួយ (ច្រើន) របស់ស្ថាប័នសន្ធិសញ្ញា ។
- ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អាចចេញវិធានការបណ្តោះអាសន្ននៅក្នុងករណីបន្ទាន់ ដើម្បីរក្សាស្ថានភាពរហូតដល់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សទាំងនេះ ធ្វើសេចក្តីសម្រេចជាស្ថាពរលើបញ្ហានេះ ។ វិធានការបណ្តោះអាសន្ននឹងនៅជាធរមានរហូតដល់សេចក្តីសម្រេច ត្រូវបានធ្វើឡើង ។

---
[69] នៅត្រឹមខែ កញ្ញា ឆ្នាំ ២០០៨ រដ្ឋតែមួយប៉ុណ្ណោះ បានធ្វើសេចក្តីប្រកាសបែបនេះ ។

[70] ពិធីសារបន្ថែម ត្រូវបានអនុម័តដោយក្រុមប្រឹក្សា នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ និងត្រូវបានរំពឹងទុកថានឹងត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅពេលបន្ទាប់មក នៅក្នុងឆ្នាំ ២០០៨ ។

- សេចក្ដីសម្រេចរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អាចមានប្រសិទ្ធភាពហួសពីកាលៈទេសៈ នៃករណីជាលក្ខណៈបុគ្គល និងផ្ដល់នូវគោលការណ៍ណែនាំសកម្មជាមុន ដើម្បីទប់ស្កាត់ការរំលោភបំពានស្រដៀងគ្នានេះដែលនឹងកើតមានឡើងនៅពេលអនាគត ។
- ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ក៏អាចពិចារណាផងដែរ លើពាក្យបណ្ដឹងដែលកំពុងត្រូវបាន ឬត្រូវបានដោះស្រាយដោយយន្តការពិសេស ។

## តម្រូវការជាក់លាក់ និងការកម្រិតលក្ខខណ្ឌ

- ករណីរបស់ដើមចោទ ត្រូវតែស្ថិតនៅក្នុងវិសាលភាពនៃការអនុវត្តសន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាជាច្រើនដែលអនុញ្ញាតឲ្យមានបណ្ដឹងជាលក្ខណៈបុគ្គល ។
- រដ្ឋដែលត្រូវបានពិភាក្សា ត្រូវតែជាភាគីនៃសន្ធិសញ្ញានេះ និងត្រូវតែផ្ដល់សច្ចាប័នលើពិធីសារបន្ថែមដែលពាក់ព័ន្ធ ឬ បានទទួលយកសមត្ថកិច្ចរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់ ដើម្បីទទួលពាក្យបណ្ដឹងនានា ។
- នៅពេលដាក់ជូនពិនិត្យនូវទឡ្ហីករណ៍ទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស លក្ខខណ្ឌមួយចំនួន ត្រូវតែបានបំពេញ ក្នុងនោះរួមមាន ការយល់ព្រម ឬ ការអនុញ្ញាតរបស់ជនរងគ្រោះផងដែរ ។ ប្រសិនបើលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ មិនត្រូវបានបំពេញ ឬ បាត់ពាក្យបណ្ដឹង អាចមិនត្រូវបានពិចារណា ។
- ដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ ស្ដីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងជាតិសាសន៍ ការប្ដឹងត្រូវតែបានធ្វើឡើងនៅក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីសេចក្ដីសម្រេចចុងក្រោយរបស់អាជ្ញាធរជាតិលើករណីណាមួយ ។
- ដើមចោទ ត្រូវតែប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុកទាំងអស់ដែលត្រូវបានរៀបចំឲ្យមាន និងដែលប្រកបដោយប្រសិទ្ធភាព មុនពេលធ្វើពាក្យបណ្ដឹងជូនទៅស្ថាប័នសន្ធិសញ្ញា ហើយឧបាស្រ័យមួយ ត្រូវបានចាត់ទុកថា មានប្រសិទ្ធភាព ប្រសិនបើឧបាស្រ័យនោះ ផ្ដល់នូវទិដ្ឋភាពសមស្របនៃសំណងសម្រាប់ដើមចោទ ។
- វាត្រូវការរយៈពេលជាមធ្យមពីពីរទៅបីឆ្នាំ សម្រាប់ការធ្វើសេចក្ដីសម្រេចចុងក្រោយលើពាក្យបណ្ដឹងមួយ ។
- ជាទូទៅ ពាក្យបណ្ដឹងដែលផ្ដោតទៅលើស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស មិនទាក់ទងទៅនឹងគំរូដ៏ទូលំទូលាយនៃការរំលោភបំពានលើសិទ្ធិមនុស្សទេ ។
- ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អាចមិនពិចារណាលើករណីដែលកំពុងត្រូវបានពិចារណាហើយដោយយន្តការបណ្ដឹងតាមផ្លូវតុលាការមួយផ្សេងទៀតជាអន្តរជាតិ ឬ តំបន់ ។[71]

> **i** សម្រាប់ព័ត៌មានពិស្ដារស្ដីពី**ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស** សូមមើល**ជំពូក IV (ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស)** នៃ*សៀវភៅ*នេះ ។

[71] នេះ អាចជាស្ថាប័ន សន្ធិសញ្ញាមួយផ្សេងទៀត តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ឬ តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ប៉ុន្តែមិនរួមបញ្ចូលយន្តការពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សទេ ។

## ខ. បណ្តឹងក្រោមយន្តការពិសេស

យន្តការពិសេសមួយចំនួន អនុញ្ញាតឲ្យមានទទ្បីករណ៍ដែលត្រូវបានធ្វើឡើង ពាក់ព័ន្ធនឹងករណីជាលក្ខណៈបុគ្គល ឬ គំរូដែលកាន់តែមានលក្ខណៈទូទៅនៃការបំពារបំពានសិទ្ធិមនុស្ស ។ បុគ្គលទាំងអស់ ឬ អ្នកដទៃទៀត ដែលបំពេញមុខងារក្នុងនាមបុគ្គល អាចដាក់ជូនពិនិត្យនូវករណីជាលក្ខណៈបុគ្គលទៅអ្នកមានអាណត្តិនៃយន្តការពិសេស ប្រសិនបើអាណត្តិនោះអនុញ្ញាតឲ្យមានករណីនេះ ។ ជារឿយៗ តួអង្គសង្គមស៊ីវិល អាចគាំទ្រដល់បុគ្គលទាំងឡាយដែលស្វែងរកកិច្ចការពារពីការបំពារបំពានសិទ្ធិមនុស្ស ។

### ចំណុចខ្លាំង

- បណ្តឹងជាលក្ខណៈបុគ្គលក្រោមយន្តការពិសេស គឺជានីតិវិធីដែលអាចត្រូវបានប្រើប្រាស់សម្រាប់ករណីជាលក្ខណៈបុគ្គល ក៏ដូចជា គំរូដែលកាន់តែមានលក្ខណៈទូទៅនៃការរំលោភបំពាន ។
- វាអាចជាឧបករណ៍ដែលមានប្រយោជន៍នៅក្នុងករណីបន្ទាន់ ដោយហេតុថា វាអនុញ្ញាតឲ្យមានវិធានការបន្ទាន់ ឬ ទប់ស្កាត់ (ដែលត្រូវបានគេស្គាល់ថាជា **ការអំពាវនាវបន្ទាន់**) ។
- ករណីនានា អាចត្រូវបាននាំយកមកជំនុំជម្រះទោស **ដោយមិនគិតដល់រដ្ឋដែលនៅក្នុងនោះ** ករណីទាំងនេះ បានកើតមានឡើងឡើយ និងថាតើរដ្ឋនោះ បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយ ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនដែរឬអត់ ។
- វា មិនចាំបាច់ប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុកទាំងអស់ មុននឹងប្រើប្រាស់នីតិវិធីនោះទេ ។
- ពាក្យបណ្តឹង មិនត្រូវបានតម្រូវឲ្យត្រូវបានធ្វើឡើងដោយជនរងគ្រោះនោះទេ ទុកណាជាប្រភពនោះត្រូវតែគួរឲ្យជឿទុកចិត្តបានក៏ដោយ និង
- ការប្តឹង អាចត្រូវបានធ្វើឡើងនៅពេលជាមួយគ្នា នៅចំពោះមុខស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការពិសេស (ប្រសិនបើមានអាណត្តិដែលពាក់ព័ន្ធ) ។

### ការកម្រិតលក្ខខណ្ឌ

- ត្រូវតែមានយន្តការពិសេសជាស្រេចដែលនឹងដំណើរការ ដោយរួមបញ្ចូលបញ្ហាសិទ្ធិមនុស្សជាក់លាក់នោះ ឬ ប្រទេសជាក់លាក់នោះ (មិនមែនអ្នកមានអាណត្តិនៃយន្តការពិសេសទាំងអស់ សុទ្ធតែអាចអនុវត្តវិធានការផ្អែកតាមករណីជាលក្ខណៈបុគ្គលនោះទេ) ។
- យន្តការពិសេស មិនមែនជាយន្តការដែលភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់នោះទេៈ វាជាឆន្ទានុសិទ្ធិរបស់រដ្ឋនីមួយៗក្នុងការអនុវត្តតាមអនុសាសន៍របស់អ្នកមានអាណត្តិនៃយន្តការពិសេស និង
- នីតិវិធី ប្រែប្រួលទៅតាមអាណត្តិនោះ ។

i

សម្រាប់ព័ត៌មានពិស្តារស្តីពី**យន្តការពិសេស** សូមមើល**ជំពូក VI (យន្តការពិសេស)** នៃ*សៀវភៅ*នេះ ។

## គ. យន្តការបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

បុគ្គល ឬ ក្រុមណាមួយ ដែលអះអាងថាជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស អាចដាក់ជូនពិនិត្យនូវពាក្យបណ្ដឹងដូចដែលមានចែងនៅក្នុងនីតិវិធីនេះ ហើយមនុស្ស ឬ ក្រុមណាមួយផ្សេងទៀតដែលបានជ្រាបព័ត៌មានដោយផ្ទាល់ និងដែលគួរឲ្យជឿទុកចិត្តបានស្ដីពីការរំលោភបំពានបែបនេះ ក៏អាចដាក់ជូនពិនិត្យនូវពាក្យបណ្ដឹងដូចដែលមានចែងនៅក្នុងនីតិវិធីនេះបានដែរ ។ យន្តការបណ្ដឹងរបស់ក្រុមប្រឹក្សា គឺជាយន្តការបណ្ដឹងជាសកលតែមួយគត់ ដែលរួមបញ្ចូលសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូលដ្ឋានទាំងអស់នៅក្នុងរដ្ឋទាំងអស់ ។

### ចំណុចខ្លាំង

- យន្តការនេះ អាចដោះស្រាយ**បញ្ហាការរំលោភបំពានលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់** ។ រដ្ឋមិនចាំបាច់ក្លាយជាភាគីនៃសន្ធិសញ្ញាសម្រាប់ការប្ដឹងលើរដ្ឋនោះ ដែលត្រូវបានដាក់ជូនពិនិត្យក្រោមយន្តការនេះនោះទេ ។
- ការប្ដឹង អាចត្រូវបានធ្វើឡើង **ចំពោះរដ្ឋណាមួយ** ។
- ពាក្យបណ្ដឹង អាចត្រូវបានដាក់ជូនពិនិត្យដោយជនរងគ្រោះ ឬ នរណាម្នាក់ដែលបំពេញមុខងារក្នុងនាមជនរងគ្រោះ និងមិនតម្រូវឲ្យមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់ជនរងគ្រោះជាចាំបាច់នោះទេ ។
- ដើមចោទ (អ្នកដើមបណ្ដឹង) ត្រូវបានផ្ដល់ព័ត៌មានអំពីសេចក្ដីសម្រេចដែលត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលសំខាន់បំផុតផ្សេងៗនៃដំណើរការ និង
- ជាទូទៅ លក្ខណវិនិច្ឆ័យទទួលយក មានភាពតឹងរ៉ឹងតិចជាចំពោះយន្តការបណ្ដឹងផ្សេងទៀត ។

### ការកម្រិតលក្ខខណ្ឌដែលអាចមាន

- ដំណើរការនេះ អាចអូសបន្លាយពេលយូរ ដោយហេតុថា ការប្ដឹងឆ្លងកាត់ដំណាក់កាលមួយចំនួនតូចនៃការពិចារណា និងហេតុដូច្នេះ អាចមិនសមស្របសម្រាប់ករណីបន្ទាន់ ។
- ដើមចោទ ត្រូវតែប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុកទាំងអស់ដែលត្រូវបានរៀបចំឲ្យមាន និងដែលប្រកបដោយប្រសិទ្ធភាព មុនពេលផ្ញើព័ត៌មានចេញក្រោមយន្តការនេះ ។
- មិនមានបទប្បញ្ញត្តិសម្រាប់វិធានការបណ្ដោះអាសន្នជាលក្ខណៈបន្ទាន់ចំពោះកិច្ចការពារទេ ។
- ជាទូទៅ ពាក្យបណ្ដឹង ត្រូវតែរៀបចំយោងទៅនឹងគំរូសង្គតិភាពនៃការរំលោភបំពានលើសិទ្ធិមនុស្សម្យ៉ាងដោយមានឥទ្ធិពលលើមនុស្សមួយចំនួនធំ ជាជាងករណីជាលក្ខណៈបុគ្គល ។
- ដោយសារតែភាពសម្ងាត់របស់វា យន្តការនេះមិនអាចសុំឲ្យសង្កេតជាសាធារណៈ ទៅលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋណាមួយទេ និង

- ករណីដែលហាក់ដូចជាបញ្ចេញឲ្យដឹងនូវគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលត្រូវបានដោះស្រាយរួចហើយដោយយន្តការពិសេស ស្ថាប័នសន្ធិសញ្ញា ឬ អង្គការសហប្រជាជាតិផ្សេងទៀត ឬ យន្តការបណ្តឹងផ្នែកសិទ្ធិមនុស្សថ្នាក់តំបន់ស្រដៀងគ្នានេះ មិនអាចទទួលយកបានក្រោមយន្តការនេះទេ ។

> i សម្រាប់ព័ត៌មានបន្ថែមស្តីពី**យន្តការបណ្តឹង** សូមមើល**ជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស)** នៃ *សៀវភៅ*នេះ ។

# វិធីប្រើប្រាស់ និងធ្វើការងារជាមួយនឹងយន្តការបណ្តឹង

តួអង្គសង្គមស៊ីវិលណាមួយក៏ដោយ ដោយពិចារណាត្រឹមត្រូវចំពោះតម្រូវការជាក់លាក់របស់យន្តការនីមួយៗ អាចប្រើប្រាស់យន្តការបណ្តឹងបាន ។ ពាក្យបណ្តឹងក្រោមយន្តការនីមួយៗ អាចត្រូវបានដាក់ជូនពិនិត្យដោយបុគ្គលដែលទទួលរងការរំលោភបំពានលើសិទ្ធិមនុស្សដែលមានទទ្បីករណ៍ ឬ ដោយភាគីទីបីក្នុងនាមបុគ្គលនោះ ឧទាហរណ៍ៈ អង្គការមិនមែនរដ្ឋាភិបាល ។

ជារឿយៗ តួអង្គសង្គមស៊ីវិល បំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកសំណងពីការបំពារបំពានសិទ្ធិមនុស្ស តាមរយៈការរៀបចំ ការដាក់ជូនពិនិត្យ ឬ ការប្តឹងក្នុងនាមបុគ្គលទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកណាក៏ដោយដែលដាក់ជូនពិនិត្យនូវពាក្យបណ្តឹងក្នុងនាមបុគ្គល គួរតែធានាថាគេ ទទួលបានការយល់ព្រមរបស់បុគ្គលនោះ និងថា បុគ្គលនោះ ដឹងអំពីការជំពាក់ទាក់ទិននៃដំណើរការប្តឹងនោះ ។ ឧទាហរណ៍ៈ នៅពេលដែលព័ត៌មាន ត្រូវបានដាក់ជូនពិនិត្យទៅយន្តការពិសេស អ្នកមានអាណត្តិបញ្ជូនពាក្យបណ្តឹងទៅរដ្ឋនោះលើករណីនេះ ដែលនៅទីបំផុត នឹងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍សាធារណៈ ។ នៅពេលដែលពាក្យបណ្តឹង ត្រូវបានដាក់ជូនពិនិត្យទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អត្តសញ្ញាណរបស់បុគ្គលនោះ នឹងត្រូវបានបញ្ចេញឲ្យរដ្ឋាភិបាលដឹង ។ ហេតុដូច្នេះ វាមានលក្ខណៈសំខាន់ជាសារវន្តសម្រាប់ជនរងគ្រោះដែលមានទទ្បីករណ៍ ត្រូវដឹងច្បាស់អំពីរបៀបដែលយន្តការបណ្តឹងនីមួយៗដំណើរការ ។

តម្រូវការសម្រាប់យន្តការនីមួយៗ ក៏គួរតែត្រូវបានអនុវត្តតាមដោយប្រុងប្រយ័ត្ន ដើម្បីធានាថា ពាក្យបណ្តឹងអាចទទួលយកបាន ។

## ក. បណ្តឹងជាលក្ខណៈបុគ្គលដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

ការប្តឹង អាចត្រូវបានធ្វើឡើងដោយបុគ្គល ឬ ភាគីទីបីដែលត្រូវបានអនុញ្ញាតដោយត្រឹមត្រូវ ឧទាហរណ៍ៈ អ្នកច្បាប់ អង្គការមិនមែនរដ្ឋាភិបាល (NGO) ឬ ក្រុមអ្នកវិជ្ជាជីវៈ ក្នុងនាមបុគ្គលដែលបាន

អះអាងថា ជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស ។ ផ្នែកនេះត្រួតពិនិត្យលើតម្រូវការ និងកត្តាសំខាន់បំផុតនៃបណ្ដឹងជាលក្ខណៈបុគ្គល ។

**តម្រូវការ**

## ១. ការផ្ដល់សច្ចាប័នរបស់ភាគីរដ្ឋ

ការប្ដឹងលើការរំលោភបំពានលើសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស អាចត្រូវបានធ្វើឡើងចំពោះរដ្ឋមួយ ប្រសិនបើៈ

- រដ្ឋនោះ គឺជាភាគីនៃសន្ធិសញ្ញាដែលត្រូវបានពិភាក្សា ដោយបានផ្ដល់សច្ចាប័ន ឬ បើមិនដូច្នោះទេ ទទួលយកវា និង
- ភាគីរដ្ឋ បានទទួលស្គាល់សមត្ថកិច្ចរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ដែលត្រូវបានកំណត់នៅក្នុងសន្ធិសញ្ញានោះ ក្នុងការពិចារណាលើពាក្យបណ្ដឹងបែបនេះ ។ ដោយពឹងពាក់លើសន្ធិសញ្ញានោះនេះ តម្រូវឲ្យរដ្ឋឬមួយក្លាយជាភាគីនៃពិធីសារបន្ថែមដែលពាក់ព័ន្ធ ឬក៏ធ្វើសេចក្ដីប្រកាសចាំបាច់ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ ។

វាគួរតែត្រូវបានកត់សម្គាល់ថា ភាគីរដ្ឋមួយចំនួន បានធ្វើសេចក្ដីថ្លែងការណ៍វិសោធនកម្មឯកតោភាគី ឬ សេចក្ដីប្រកាសប្រកបដោយខ្លឹមសារ ដែលអាចកម្រិតលក្ខខណ្ឌលើវិសាលភាពនៃកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សដែលគេមាន ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញានានា ។ ទាំងនេះ គួរតែត្រូវបានត្រួតពិនិត្យឡើងវិញនៅពេលកំណត់ថាតើការប្ដឹង អាចត្រូវបានធ្វើឡើង ដូចដែលមានចែងនៅក្នុងផ្នែកជាក់លាក់មួយនៃសន្ធិសញ្ញា ដែរឬអត់ ។[72]

## ២. ការរំលោភបំពានជាលក្ខណៈបុគ្គល

បណ្ដឹងជាលក្ខណៈបុគ្គលនៅក្រោមស្ថាប័នសន្ធិសញ្ញា អាចត្រូវបានប្រើប្រាស់សម្រាប់តែ**ករណីនៃការរំលោភបំពានលើសិទ្ធិមនុស្សពាក់ព័ន្ធនឹងបុគ្គលម្នាក់ ឬ ច្រើននាក់** និងតាមធម្មតា មិនសមនឹងគំរូទូទៅនៃការរំលោភបំពានលើសិទ្ធិមនុស្ស ក្នុងករណីដែលបុគ្គល មិនត្រូវបានកំណត់នោះទេ ។

## ៣. ឧបាស្រ័យក្នុងស្រុក

បណ្ដឹងជាលក្ខណៈបុគ្គលដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ អាចត្រូវបានដាក់ជូនពិនិត្យ តែនៅពេលដែល**ឧបាស្រ័យក្នុងស្រុកប្រកបដោយប្រសិទ្ធភាព ត្រូវបានប្រើប្រាស់អស់ប៉ុណ្ណោះ** គឺថា ករណី/ការប្ដឹងបានឆ្លងកាត់គ្រប់ដំណាក់កាលផ្សេងៗនៃប្រព័ន្ធតុលាការក្នុងស្រុក ឬ តាមរយៈដំណាក់

[72] ដើម្បីរកបានព័ត៌មានបន្ថែមទៀតស្ដីពីទាំងស្ថានភាពផ្ដល់សច្ចាប័ន និងសេចក្ដីប្រកាស/សេចក្ដីថ្លែងការណ៍វិសោធនកម្មឯកតោភាគីចំពោះសន្ធិសញ្ញានីមួយៗ និងពិធីសារបន្ថែមដែលពាក់ព័ន្ធ ចូរចុចត្រង់នេះ ។

កាលនៃដំណើរការនីតិវិធីរដ្ឋបាលខ្លះ ដែលអាចផ្ដល់នូវឧបាស្រ័យដែលត្រូវបានរៀបចំឲ្យមាន និងដែលប្រកបដោយប្រសិទ្ធភាព នៅក្នុងរយៈពេលសមស្រប ។ វិធាននេះ មិនអនុវត្តបានទេ ប្រសិនបើឧបាស្រ័យក្នុងស្រុក **មិនមានប្រសិទ្ធភាព ឬ ត្រូវបានធ្វើឲ្យអូសបន្លាយពេលយូរជ្រុលហួសហេតុ** ។ ជាទូទៅ អ្វីដែលជា "ការធ្វើឲ្យអូសបន្លាយពេលយូរជ្រុលហួសហេតុ" មិនអាចត្រូវបានកំណត់ និងត្រូវតែបានវាយតម្លៃមួយករណីម្ដងៗ ។

## ៤. ការប្ដឹងក្នុងនាមជនរងគ្រោះ

បុគ្គល ឬ អង្គការអាចធ្វើការប្ដឹងក្នុងនាមបុគ្គលម្នាក់ផ្សេងទៀត ឲ្យតែជនរងគ្រោះជាលក្ខណៈបុគ្គលបានផ្ដល់**ការយល់ព្រមជាលាយលក្ខណ៍អក្សរ** ក្នុងទម្រង់ "លិខិតប្រគល់អំណាច" ឬ "លិខិតផ្ទេរសិទ្ធិអំណាចក្នុងការអនុវត្ត" ។[73]

## ៥. ដំណើរការនីតិវិធីបណ្ដឹងផ្សេងទៀត

ប្រសិនបើករណីមួយ **កំពុងត្រូវបានពិចារណាហើយដោយយន្តការបណ្ដឹងតាមផ្លូវតុលាការរបស់អង្គ/គណៈមួយផ្សេងទៀតនៃអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ ឬ តំបន់** ជាទូទៅ វាមិនអាចត្រូវបានពិចារណាដោយស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិទៀតឡើយ ។ ប្រសិនបើករណីនោះ ត្រូវបានពិចារណាលើកមុន និងត្រូវបានបដិសេធដោយ**តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ឬ តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប**នោះ បន្ទាប់មក ពាក្យបណ្ដឹងដូចគ្នានេះ ជួនកាលអាចមានសិទ្ធិទទួលបានការពិចារណាដោយអង្គ/គណៈសន្ធិសញ្ញាទៀត ។ ករណីនានា ដែលត្រូវបានដាក់ជូនពិនិត្យនៅក្រោមអាណត្តិនៃយន្តការពិសេស ក៏អាចត្រូវបានដាក់ជូនពិនិត្យទៅស្ថាប័ន សន្ធិសញ្ញាទៀតផងដែរ ។

## ៦. ទម្រង់នៃពាក្យបណ្ដឹង

ទោះបីជាដើមចោទ ត្រូវបានជំរុញលើកទឹកចិត្តឲ្យប្រើប្រាស់ទម្រង់គំរូនៃពាក្យបណ្ដឹង (ចូរមើលឧបសម្ព័ន្ធ I និង II នៃជំពូកនេះ) ក៏ដោយ ក៏ជាគោលការណ៍ ទម្រង់ណាមួយនៃលិខិតឆ្លើយឆ្លង ដែលរួមបញ្ចូលព័ត៌មានដែលពាក់ព័ន្ធ មានលក្ខណៈគ្រប់គ្រាន់ហើយ ។ នេះ គួរតែត្រូវបានដាក់ជូនពិនិត្យជាភាសាការងារមួយក្នុងចំណោមភាសាការងារជាច្រើនរបស់ស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្សដែលពាក់ព័ន្ធ ។[74]

---

[73] ការយល់ព្រមបែបនេះ មិនមានលក្ខណៈចាំបាច់ទេ ប្រសិនបើមានមូលដ្ឋានរឹងមាំ ដើម្បីជឿថា វា មិនអាចទទួលបាន ក្រោមកាលៈទេសៈនោះទេ ។

[74] តាមធម្មតា ភាសាទាំងនេះ គឺ ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ប៉ុន្តែដើមចោទ ត្រូវបានណែនាំឲ្យមើលវិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីបញ្ជាក់អំពីភាសាការងាររបស់ស្ថាប័ន នីមួយៗ ។

**i**

**តើព័ត៌មានអ្វីខ្លះ ដែលបណ្តឹងជាលក្ខណៈបុគ្គលក្រោមស្ថាប័នសន្ធិសញ្ញា គួរតែរួមបញ្ចូល ?**

- **ព័ត៌មានផ្ទាល់ខ្លួនជាមូលដ្ឋាន**ស្តីពីបុគ្គលដែលសិទ្ធិមនុស្សរបស់គេ ត្រូវបានរំលោភបំពានដោយមានទឡ្ហីករណ៍ (ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត) ។
- ឈ្មោះរបស់**ភាគីរដ្ឋ** ដែលពាក្យបណ្តឹងនេះ តម្រង់ទៅរកភាគីរដ្ឋនោះ ។
- ប្រសិនបើការប្តឹង ត្រូវបានធ្វើឡើង ក្នុងនាមបុគ្គលម្នាក់ផ្សេងទៀត **តឹកតាង**ដែលបញ្ជាក់អំពី**ការយល់ព្រម** ឬ ការអនុញ្ញាតរបស់បុគ្គលនោះ ("លិខិតប្រគល់អំណាច" ជាទម្រង់រឹង) ឬ ជាជម្រើស ការធ្វើយុត្តិកម្មអំពីមូលហេតុដែលការយល់ព្រម ឬ ការអនុញ្ញាតបែបនេះ មិនត្រូវបានរៀបចំឲ្យមាន ឬ មិនអាចត្រូវបានផ្តល់ជូន ។
- **ការអធិប្បាយ**ល្អិតល្អន់**អំពីអង្គហេតុ**ដែលពាក្យបណ្តឹងនេះ ត្រូវបានដាក់ជូនពិនិត្យដោយមានមូលដ្ឋាននៅលើអង្គហេតុនោះ ដែលត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ទៅតាមលំដាប់ប្រវត្តិការណ៍តាមកាល ។
- សេចក្តីពិស្តារនៃ**ដំណាក់កាលដែលត្រូវបានអនុវត្ត ដើម្បីប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យផ្នែកតុលាការទាំងអស់ដែលត្រូវបានរៀបចំឲ្យមាននៅក្នុងតុលាការនៅក្នុងស្រុក ក៏ដូចជា ឧបាស្រ័យរដ្ឋបាលប្រកបដោយប្រសិទ្ធភាពខ្លះទៀត** ដែលអាចត្រូវបានរៀបចំឲ្យមាននៅក្នុងរដ្ឋដែលពាក់ព័ន្ធ ។
- សេចក្តីពិស្តារនៃ**ការដាក់ជូនពិនិត្យផ្សេងទៀតនៃករណី ឬ អង្គហេតុដែលពាក់ព័ន្ធ** ទៅមធ្យោបាយមួយទៀតនៃការស៊ើបអង្កេត ឬ ការដោះស្រាយជាលក្ខណៈអន្តរជាតិ ប្រសិនបើមាន ។
- ការអធិប្បាយអំពី**សេចក្តីសំអាងចំពោះមូលហេតុដែលអង្គហេតុនៅក្នុងករណីនេះ ដូចគ្នានឹងការរំលោភបំពាន**លើសិទ្ធិមនុស្សដែលត្រូវបានចែងនៅក្នុងសន្ធិសញ្ញាដែលបទប្បញ្ញត្តិរបស់វា ត្រូវបានប្រើប្រាស់នោះ ។ វាមានប្រយោជន៍ចំពោះ**មាត្រាដែលពាក់ព័ន្ធនៃសន្ធិសញ្ញា**ដែលត្រូវបានកំណត់ ។
- **ឯកសារទាំងអស់ដែលពាក់ព័ន្ធ**នឹងសេចក្តីអះអាង និងសេចក្តីសំអាង (សេចក្តីសម្រេចរបស់តុលាការ ។ល។) ។
- ច្បាប់ចម្លងនៃ**ច្បាប់ជាតិដែលពាក់ព័ន្ធ** ក្នុងករណីដែលត្រូវបានរៀបចំឲ្យមាន ។

ជាទូទៅ ពាក្យបណ្តឹងដែលមានភាពភាសាដែលមានលក្ខណៈបំពារបំពាន មិនត្រូវបានពិចារណាឡើយ ។

## ៧. កម្រិតពេលវេលា

អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ គឺជាសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយគត់ដែលបានកំណត់អំពីកាលកំណត់ទទួលពាក្យបណ្តឹងជាផ្លូវការសម្រាប់ការប្តឹង ។ ទោះបីដូច្នេះក៏ដោយ ជាគោលការណ៍ ពាក្យបណ្តឹង គួរតែត្រូវបានដាក់ជូនពិនិត្យ**ឲ្យឆាប់តាមដែលអាចធ្វើបាន** បន្ទាប់ពីការរំលោភបំពានដែលមានទឡ្ហីករណ៍ បានកើតមានឡើង និងឧបាស្រ័យក្នុងស្រុក ត្រូវបានប្រើប្រាស់អស់ ។ ការដាក់ជូនពិនិត្យដែលត្រូវបានពន្យារពេល អាចធ្វើឲ្យវាមានការលំបាកចំពោះភាគីរដ្ឋក្នុងការឆ្លើយតបដោយសមស្រប និងចំពោះស្ថាប័ន សន្ធិសញ្ញាក្នុងការវាយតម្លៃលើសាវតារដែលប្រកបទៅតាមការពិត ដោយហ្មត់ចត់ ។ ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពានដែលបានកើតមានឡើងមុនការចូលជាធរមានបញ្ញត្តិនូវយន្តការបណ្តឹងសម្រាប់ភាគីរដ្ឋដែលពាក់ព័ន្ធ នឹងមិនត្រូវបានត្រួតពិនិត្យឡើយ (លើកលែងតែប្រសិនបើគេ

បានអនុវត្តជាបន្តបន្ទាប់ក្នុងការរំលោភបំពានលើសន្ធិសញ្ញា) ។ ពាក្យបណ្តឹងដែលត្រូវបានដាក់ជូនពិនិត្យដូច ដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ត្រូវតែ បានដាក់ជូនពិនិត្យ **នៅក្នុងរយៈពេលប្រាំមួយខែ** បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយរបស់អាជ្ញាធរជាតិនៅក្នុង ករណីនេះ ។

## ៨. វិធានការបន្ទាន់

គណៈកម្មាធិការនីមួយៗ អាចអនុវត្តវិធានការបន្ទាន់ តាមវិធីវិធានការបណ្តោះអាសន្ន ប្រសិនបើ គ្រោះថ្នាក់ដែលមិនអាចជួសជុលបាន នឹងបើមិនដូច្នោះទេ ត្រូវបានទទួលរង មុនពេលដែលករណីណាមួយ ត្រូវបានត្រួតពិនិត្យនៅក្នុងវគ្គធម្មតា ។ ជាតួយ៉ាង គំនិតផ្តួចផ្តើមបែបនេះ ត្រូវបានទទួលអនុវត្តដើម្បីទប់ស្កាត់ សកម្មភាពដែលមិនអាចត្រូវបានមិនធ្វើនៅពេលក្រោយ ឧទាហរណ៍ៈ ការអនុវត្តទោសប្រហារជីវិត ឬ ការ បណ្តេញចេញដោយបង្ខំនូវបុគ្គលដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម ។ **បុគ្គល ឬ អង្គការ ដែលស្នើសុំស្ថាប័ន សន្ធិសញ្ញាសិទ្ធិមនុស្ស ពិចារណាលើការទទួលអនុវត្តវិធានការបណ្តោះអាសន្ន ត្រូវបានជំរុញលើកទឹកចិត្តឲ្យលើកឡើងដោយច្បាស់លាស់នូវករណីនេះនៅក្នុងពាក្យបណ្តឹងរបស់គេ ។**

## ៩. បញ្ហាផលប៉ះពាល់នៃការប្រែប្រួល

ប្រសិនបើមានបញ្ហាផលប៉ះពាល់នៃការប្រែប្រួលនៃប្រភេទឯកជន ឬ ផ្ទាល់ខ្លួន ដែលលេចឡើងនៅ ក្នុងពាក្យបណ្តឹង វាអាចស្នើសុំបានទៅគណៈកម្មាធិការ ដើម្បីបង្ហាញនូវឈ្មោះរបស់ជនរងគ្រោះនៅក្នុង សេចក្តីសម្រេចចុងក្រោយរបស់គណៈកម្មាធិការនោះ ដើម្បីឲ្យអត្តសញ្ញាណរបស់គេ មិនត្រូវបានបញ្ចេញជា សាធារណៈ ។

### កត្តានានានៃនីតិវិធី

ប្រសិនបើពាក្យបណ្តឹង មានកត្តាសំខាន់ជាសារវន្ត ដូចដែលបានលើកឡើងខាងលើ ករណីនេះត្រូវ បានចុះជាផ្លូវការទៅក្នុងបញ្ជីសម្រាប់ការពិចារណា (នោះគឺ **ត្រូវបានចុះបញ្ជី**) ដោយស្ថាប័ន សន្ធិសញ្ញា សិទ្ធិមនុស្សដែលពាក់ព័ន្ធ ។

បន្ទាប់មក ករណីនេះនឹងត្រូវបានបញ្ជូនទៅភាគីរដ្ឋដែលពាក់ព័ន្ធ ដើម្បីផ្តល់ដល់ភាគីរដ្ឋនោះនូវ ឱកាសដើម្បីផ្តល់សេចក្តីសង្កេត ។ កាលណាភាគីរដ្ឋ ឆ្លើយតបភ្លាម ដើមចោទត្រូវបានផ្តល់នូវឱកាស ដើម្បី ផ្តល់សេចក្តីសង្កេតលើការឆ្លើយតបរបស់រដ្ឋនោះ ។ នៅត្រង់ចំណុចនោះ ករណីនេះមានលក្ខណៈពេញ លេញជាស្រេចសម្រាប់ការធ្វើសេចក្តីសម្រេចរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ ប្រសិនបើរដ្ឋនោះមិន បានឆ្លើយតបទេ ថ្វីបើមានលិខិតរំលឹកមួយ ឬ ច្រើនក៏ដោយ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស នឹងធ្វើសេចក្តី សម្រេចលើករណីនោះ ដោយឲ្យទម្ងន់ត្រឹមត្រូវទៅលើសេចក្តីអះអាងដែលត្រូវបានរៀបចំដោយដើមចោទ ។

ដំណាក់កាលសំខាន់ពីរនៃដំណើរការត្រួតពិនិត្យឡើងវិញ របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ត្រូវបានស្គាល់ថាជាដំណាក់កាល "អង្គច្បាប់" និងដំណាក់កាល "អង្គសេចក្តី" ។ នៅក្នុងដំណាក់កាលអង្គច្បាប់ ស្ថាប័នសន្ធិសញ្ញា ពិចារណាថាតើពាក្យបណ្តឹង បំពេញលក្ខខណ្ឌនៃនីតិវិធីដែរឬអត់ ។ ប្រសិនបើអង្គ/គណៈសន្ធិសញ្ញា កំណត់ករណីនោះថាអាចទទួលយកបាន ស្ថាប័នសន្ធិសញ្ញា ពិចារណាលើអង្គសេចក្តីនៃពាក្យបណ្តឹង ។ ទុកណាជា តាមធម្មតា ដំណាក់កាលទាំងនេះ ត្រូវបានពិចារណារួមគ្នាក៏ដោយ ក៏វាអាចត្រូវបានបំបែកពីគ្នាតាមការស្នើសុំរបស់ភាគីរដ្ឋ ។ ប្រសិនបើករណី មិនអាចសម្រេចបាននៅក្នុងដំណាក់កាលអង្គច្បាប់ អង្គសេចក្តីនៃករណី អាចមិនត្រូវបានពិចារណាផងដែរ ។

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ពិចារណាលើករណីនីមួយៗនៅក្នុងកិច្ចប្រជុំសម្ងាត់ ។ កាលណាស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស បានធ្វើសេចក្តីសម្រេចលើករណីមួយភ្លាម សេចក្តីសម្រេចនោះត្រូវបានបញ្ជូនទៅដើមចោទ និងរដ្ឋនោះនៅក្នុងពេលជាមួយគ្នា ។ ប្រសិនបើ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស សម្រេចថា ដើមចោទពិតជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្សរបស់ភាគីរដ្ឋ ដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាដែលពាក់ព័ន្ធមែន ជាទូទៅ ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនោះ កំណត់អំពីឧបាស្រ័យដែលគួរតែត្រូវបានផ្តល់ និងអញ្ជើញភាគីរដ្ឋនោះឲ្យផ្តល់ព័ត៌មានសម្រាប់ការអនុវត្តបន្តនៅក្នុងរយៈពេលជាក់លាក់ (តាមធម្មតាប្រាំមួយខែ) លើដំណាក់កាលដែលភាគីរដ្ឋនោះ ប្រកាន់យកដើម្បីអនុវត្តលទ្ធផលរកឃើញរបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។

អត្ថបទនៃសេចក្តីសម្រេចចុងក្រោយណាមួយលើអង្គសេចក្តីនៃករណី ឬ សេចក្តីសម្រេចមិនទទួលយក ត្រូវបានដាក់ផ្សាយលើវិបសាយរបស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាផ្នែកមួយនៃយុត្តិសាស្ត្ររបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។

**i**

**ទីកន្លែងដែលត្រូវផ្ញើចេញបណ្តឹងជាលក្ខណៈ បុគ្គលដូចដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ**

ពាក្យបណ្តឹង គួរតែត្រូវបានផ្ញើចេញទៅៈ
ក្រុមបដ្ឋនាលិខិត
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០ ២២ (ជាពិសេស សម្រាប់បញ្ហាបន្ទាន់ គួរតែដាក់បញ្ចូលឯកសារ ដែលពាក់ព័ន្ធទាំងអស់ជាទម្រង់រឹង)
អ៊ីម៉ែលៈ **tb-petitions@ohchr.org**

**ជានិច្ចកាល ចូរបញ្ជាក់ថាតើស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយ ដែលអ្នកសរសេរទៅកាន់ ។**

យន្តការនេះ អនុញ្ញាតឲ្យមានការប្ដឹងត្រូវបានធ្វើឡើង ពាក់ព័ន្ធនឹង ឬមួយករណីជាលក្ខណៈបុគ្គល ឬក៏ គំរូដែលកាន់តែមានលក្ខណៈទូទៅនៃការបំពារបំពានសិទ្ធិមនុស្ស។បុគ្គល ឬក្រុមណាមួយ ឬអង្គការដែលបំពេញតួនាទីក្នុងនាមបុគ្គល អាចដាក់ជូនពិនិត្យនូវករណីនានាទៅអ្នកមានអាណត្តិនៃយន្តការពិសេស ។

ជារឿយៗ តួអង្គសង្គមស៊ីវិល អាចបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់បុគ្គលដែលស្វែងរកការការពារពីការបំពារបំពានសិទ្ធិមនុស្ស ។ បុគ្គល ឬ អង្គការដែលមានបំណងចង់ដាក់ជូនពិនិត្យនូវករណីក្រោមអាណត្តិនៃយន្តការពិសេសណាមួយក្នុងចំណោមអាណត្តិនៃយន្តការពិសេសជាច្រើន គួរតែពិនិត្យមើលជាដំបូងថាតើមានអាណត្តិប្រចាំប្រទេស ឬ ប្រធានបទដែលពាក់ព័ន្ធនឹងករណីរបស់គេដែរឬអត់ ។ ថែមពីលើនេះទៀត គេគួរតែអានដោយប្រុងប្រយ័ត្ននូវលក្ខណៈវិនិច្ឆ័យនៃអាណត្តិ ដែលត្រូវតែបានបំពេញ មុនពេលដែលពាក្យបណ្ដឹង អាចត្រូវបានទទួលយក ។ ជាពិសេស **ក្រុមការងារទទួលបន្ទុកការឃុំឃាំងដោយបំពាន** និង**ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬ ដោយគ្មានការស្ម័គ្រចិត្ត** មានលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលខុសពីលក្ខណៈវិនិច្ឆ័យនៃអាណត្តិផ្សេងទៀត ។

នៅពេលទទួលបានបណ្ដឹងជាលក្ខណៈបុគ្គល សេចក្ដីសំរេចដើម្បីធ្វើអន្តរាគមន៍ គឺជាឆន្ទានុសិទ្ធិរបស់អ្នកកាន់អាណត្តិយន្តការពិសេស ។ វាអាស្រ័យលើលក្ខណៈវិនិច្ឆ័យ ដែលអ្នកកាន់អាណត្តិបានរកឃើញ ហើយគួរតែស្របនឹងក្រមសីលធម៌សម្រាប់អ្នកកាន់អាណត្តិនៃយន្តការពិសេសនោះ ។ ជាទូទៅ លក្ខណៈវិនិច្ឆ័យ ត្រូវទាក់ទងនឹង :

- ភាពដែលគួរឲ្យជឿទុកចិត្តបានលើប្រភព ដែលមិនគួរត្រូវបានប្រើប្រាស់ ជាលក្ខណៈអបរិយាប័ន្ន ដោយមានមូលដ្ឋាននៅលើរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ។
- ទំនុកចិត្តលើព័ត៌មានដែលត្រូវបានទទួល ដែលមិនគួរត្រូវបានជំរុញដោយផ្នែកនយោបាយ ។
- សេចក្ដីពិស្ដារដែលត្រូវបានផ្ដល់ជូន និង
- វិសាលភាពនៃអាណត្តិនោះឯង ។

ដើម្បីសម្របសម្រួលដល់ការត្រួតពិនិត្យលើការរំលោភបំពានដែលបានរាយការណ៍ **កម្រងសំណួរ** ដែលទាក់ទងនឹងអាណត្តិមួយចំនួនតូច ត្រូវបានរៀបចំឲ្យមានតាមបណ្ដាញអេឡិចត្រូនិចសម្រាប់បុគ្គលដែលមានបំណងចង់ធ្វើសេចក្ដីរាយការណ៍លើការរំលោភបំពានដែលមានទឡ្ហីករណ៍ (ចូរមើលខាងក្រោម) ។ ទោះជាយ៉ាងណាក៏ដោយ វា គួរតែត្រូវបានកត់សម្គាល់ថា ពាក្យបណ្ដឹងពីបុគ្គលទាំងឡាយ ឬ អ្នកដើមបណ្ដឹងដទៃទៀត ត្រូវបានពិចារណា សូម្បីតែនៅពេលដែលវា ត្រូវបានដាក់ជូនពិនិត្យជាទម្រង់កម្រងសំណួរក្ដី ។ អ្នកដើមបណ្ដឹង ត្រូវបានជំរុញលើកទឹកចិត្តឲ្យធ្វើចេញនូវសេចក្ដីបច្ចុប្បន្នភាពជាទៀងទាត់នៃព័ត៌មានដែលពួកគេបានដាក់ជូនពិនិត្យ ។

## i តើព័ត៌មានអ្វីខ្លះ ដែលបណ្ដឹងជាលក្ខណៈបុគ្គលក្រោមយន្តការពិសេសរួមបញ្ចូល ?

- ការកំណត់អំពី**ជនរងគ្រោះ**ដែលមានទទ្បីករណ៍មួយ (ឬ ច្រើន) ។
- ការកំណត់អំពី**ចារី**ដែលមានទទ្បីករណ៍នៃការរំលោភបំពាន ។
- ការកំណត់អំពី**បុគ្គល ឬ អង្គការដែលដាក់ជូនពិនិត្យនូវពាក្យបណ្ដឹង** (ព័ត៌មាននេះ នឹងត្រូវបានរក្សាការសម្ងាត់) ។
- **កាលបរិច្ឆេទ និងទីកន្លែង**ដែលកើតមានឧប្បត្តិហេតុ និង
- **សេចក្ដីពិពណ៌នាពិស្ដារអំពីកាលៈទេសៈ**នៃការរំលោភបំពានដែលមានទទ្បីករណ៍ ។

**កំណត់សម្គាល់:**

- ជាទូទៅ ពាក្យបណ្ដឹងដែលមានភាសាដែលរំលោភបំពាន **មិន**ត្រូវបានពិចារណាឡើយ ។
- ពាក្យបណ្ដឹង គួរតែមានលក្ខណៈ**ច្បាស់លាស់ និងខ្លីល្មម** ។
- ជានិច្ចកាល **ចូរបញ្ជាក់ថាតើយន្តការពិសេសណាមួយ**ដែលពាក្យបណ្ដឹងនោះ ត្រូវបានផ្ញើទៅ ។
- ជានិច្ចកាល **ចូរមើលតម្រូវការ ដែលត្រូវបានកំណត់តាមអាណត្តិនីមួយៗ** សម្រាប់ការដាក់ជូនពិនិត្យនូវបណ្ដឹងជាលក្ខណៈបុគ្គល និង
- ពាក្យបណ្ដឹង អាចត្រូវបានសរសេរជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ។

## i ទីកន្លែងដែលត្រូវផ្ញើចេញបណ្ដឹងជាលក្ខណៈបុគ្គល ក្រោមយន្តការពិសេស

ផ្នែកយន្តការពិសេស
ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (០)២២ ៩១៧ ៩០ ០៦
អ៊ីម៉ែល: **urgent-action@ohchr.org**

សូមបញ្ជាក់អំពីយន្តការពិសេសណាមួយ ដែលពាក្យបណ្ដឹងត្រូវបានផ្ញើទៅ នៅក្នុងកន្លែងកម្មវត្ថុនៃអ៊ីម៉ែល ឬ ទូរសារ ឬ នៅលើស្រោមសំបុត្រ ។ ចូរកត់សម្គាល់ថា អាណត្តិនៃយន្តការពិសេស បានកំណត់អំពីតម្រូវការជាក់លាក់ ដែលពាក្យបណ្ដឹងត្រូវតែបំពេញ ។ សេចក្ដីពិស្ដារនៃតម្រូវការទាំងនេះ អាចត្រូវបានរកឃើញនៅក្នុងវិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្រោមអាណត្តិនីមួយៗ ។

ដោយមានមូលដ្ឋាននៅលើព័ត៌មានដែលគួរឲ្យជឿបាន និងទុកចិត្តបាន ដែលត្រូវបានទទួលពីជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្សដែលមានទឡ្ហីករណ៍នោះ អ្នកមានអាណត្តិនៃយន្តការពិសេស អាចបញ្ជូន**ពាក្យបណ្ដឹងទៅរដ្ឋាភិបាល** ។ ទាំងនេះ ត្រូវបានបញ្ជូនតាមរយៈការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងអាចមានទម្រង់ជា**សេចក្ដីអំពាវនាវបន្ទាន់** ប្រសិនបើការរំលោភបំពានធ្ងន់ធ្ងរ ហាក់ដូចជាកំពុងតែបន្ត ឬ បម្រុងនឹងកើតមានឡើង ឬ **លិខិតទឡ្ហីករណ៍** ប្រសិនបើការរំលោភបំពាន បានកើតមានឡើងរួចស្រេចទៅហើយដោយមានទឡ្ហីករណ៍ ។ តាមរយៈពាក្យបណ្ដឹង អ្នកមានអាណត្តិ សុំឲ្យរដ្ឋាភិបាលដែលពាក់ព័ន្ធផ្ដល់ការបំភ្លឺលើករណីជាក់លាក់ និង/ឬ វិធានការឧបាស្រ័យពេញលេញ ។ អ្នកមានអាណត្តិ ក៏អាចស្នើសុំឲ្យរដ្ឋាភិបាលផ្សព្វផ្សាយអំពីលទ្ធផលនៃការស៊ើបអង្កេត និងសកម្មភាពរបស់អ្នកមានអាណត្តិនេះ ។

ដោយពឹងពាក់លើការឆ្លើយតបដែលត្រូវបានទទួល គេអាចសម្រេចធ្វើការស៊ើបសួរតទៅទៀត ឬ ផ្ដល់អនុសាសន៍ជាក់លាក់ ។ ក្នុងករណីខ្លះ គេក៏អាចសម្រេចចេញសេចក្ដីថ្លែងការណ៍សាធារណៈលើករណីនេះ ។

ដូចដែលមានចែងនៅក្នុងវិធានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការពិសេសទាំងអស់ ត្រូវបានតម្រូវឲ្យ**ធ្វើសេចក្ដីរាយការណ៍**ស្ដីពីសកម្មភាពរបស់គេ នៅក្នុងវគ្គប្រជុំពេញអង្គប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ។ តាមធម្មតា ពាក្យបណ្ដឹងដែលត្រូវបានផ្ញើចេញ និងទទួល មានលក្ខណៈសម្ងាត់ និងនៅតែមានលក្ខណៈសម្ងាត់ដូច្នេះ រហូតដល់របាយការណ៍ប្រចាំឆ្នាំរបស់យន្តការពិសេសដែលពាក់ព័ន្ធ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ លុះត្រាតែអ្នកមានអាណត្តិ សម្រេចចិត្តចេញសេចក្ដីប្រកាសព័ត៌មាន ។[75]

សូមកត់សម្គាល់ថា ជនរងគ្រោះដែលមានទឡ្ហីករណ៍ ត្រូវបានដាក់ឈ្មោះនៅក្នុងរបាយការណ៍របស់អ្នកមានអាណត្តិនៃយន្តការពិសេស លើកលែងតែនៅក្នុងករណីរបស់កុមារ ឬ កាលៈទេសៈជាក់លាក់ ។ ដោយពិចារណាទៅលើប្រភេទជាសាធារណៈនៃរបាយការណ៍របស់យន្តការពិសេស វា មានលក្ខណៈសំខាន់ថា បុគ្គល ឬ អង្គការដែលបំពេញតួនាទីក្នុងនាមជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស ធានាថា ជនរងគ្រោះ ដឹងថា ករណីរបស់ខ្លួន កំពុងតែត្រូវបានបញ្ជូនទៅយន្តការពិសេស ថាឈ្មោះរបស់ខ្លួន អាចត្រូវបានផ្សព្វផ្សាយទៅអាជ្ញាធរដែលពាក់ព័ន្ធ និងថាឈ្មោះរបស់ខ្លួន (ឬ អក្សរអាទិសង្កេត) អាចបង្ហាញឲ្យឃើញនៅក្នុងរបាយការណ៍សាធារណៈរបស់យន្តការពិសេស ។

---

[75] ដោយរួមទាំងរបាយការណ៍ប្រចាំឆ្នាំ អ្នកមានអាណត្តិខ្លះ ដាក់ចេញនូវឯកសារផ្សេងទៀត ដែលជួយពន្យល់អំពីការងាររបស់គេ និងវិសាលភាពនៃអាណត្តិរបស់គេ ។ ជាពិសេស ក្រុមការងារទទួលបន្ទុកឃុំឃាំងដោយបំពាន ដាក់ចេញនូវ "សេចក្ដីពិគ្រោះយោបល់ផ្លូវការ" ស្ដីពីបញ្ហា និង "មតិ" ទូទៅលើបណ្ដឹងជាលក្ខណៈបុគ្គល និងក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬ គ្មានការស្ម័គ្រចិត្ត ដាក់ចេញនូវ "សេចក្ដីសង្កេតទូទៅ" លើសេចក្ដី-ប្រកាសស្ដីពីកិច្ចការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ ។

***i***

**កម្រងសំណួរស្តង់ដា** ត្រូវបានរៀបចំឲ្យមាន សម្រាប់ធ្វើសេចក្តីរាយការណ៍អំពីការរំលោភបំពានដែលមានទទឡីករណ៍ ក្រោមអាណត្តិដូចតទៅ:

- ក្រុមការងារទទួលបន្ទុកការឃុំឃាំងដោយបំពាន ។
- ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬ គ្មានការស្ម័គ្រចិត្ត ។
- ក្រុមការងារប្រឆាំងនឹងការប្រើប្រាស់ទាហានស៊ីឈ្នួលជាមធ្យោបាយរារាំងការប្រើប្រាស់សិទ្ធិរបស់ប្រជាជនក្នុងការសម្រេចចិត្តដោយខ្លួនឯង ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីការប្រហារជីវិតក្រៅតុលាការដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពាន ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ ។
- អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី សិទ្ធិមនុស្សរបស់ទេសន្តរប្រវេសន៍ ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ការលក់ដូរកុមារ ពេស្យាចារកុមារ និងកាមសាស្ត្រកុមារ ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ។
- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពី អំពើហិង្សាចំពោះស្ត្រីភេទ បុព្វហេតុ និងផលវិបាករបស់វា និង
- អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិស្តីពី ស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ។

ទោះជាយ៉ាងណាក៏ដោយ ពាក្យបណ្តឹងពីបុគ្គល និងប្រភពផ្សេងទៀត នឹងត្រូវបានពិចារណា សូម្បីតែនៅពេលដែលវាមិនត្រូវបានដាក់ជូនពិនិត្យជាទម្រង់នៃកម្រងសំណួរក្តី ។

## គ. យន្តការបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រោមយន្តការបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ពាក្យបណ្តឹងអាចត្រូវបានដាក់ជូនពិនិត្យដោយ បុគ្គល ឬ ក្រុម ដែលអះអាងថាជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិមនុស្ស ឬ មានចំណេះដឹងផ្ទាល់ ដែលគួរឲ្យជឿទុកចិត្តបានអំពីការរំលោភបំពាននេះ ។ កត្តាសំខាន់នៃយន្តការនេះ ត្រូវបានចែងដូចខាងក្រោម ។

### i តើព័ត៌មានអ្វីខ្លះ ដែលពាក្យបណ្តឹងក្រោមយន្តការបណ្តឹង របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រួមបញ្ចូល ?

- ការកំណត់អំពី**បុគ្គលម្នាក់ (ឬ ច្រើននាក់) ឬ អង្គការមួយ (ឬ ច្រើន) ដែលដាក់ជូនពិនិត្យនូវពាក្យបណ្តឹង** (ព័ត៌មាននេះនឹងត្រូវបានរក្សាការសម្ងាត់ ប្រសិនបើត្រូវបានស្នើសុំ) ។ ពាក្យបណ្តឹងអនាមិកមិនត្រូវបានទទួលយកឡើយ ។
- ការពិពណ៌នាអំពីអង្គហេតុដែលពាក់ព័ន្ធឲ្យបានពិស្តារតាមដែលអាចធ្វើបាន ដោយផ្តល់នូវឈ្មោះរបស់**ជនរងគ្រោះ**ដែលមានទទ្បីករណ៍ **កាលបរិច្ឆេទ ទីតាំង និងភស្តុតាងផ្សេងទៀត** ។
- គោលបំណងនៃពាក្យបណ្តឹង និង**សិទ្ធិដែលត្រូវបានរំលោភបំពានដោយមានទទ្បីករណ៍** ។
- **ការពន្យល់**អំពីថាតើករណីនេះ អាចបញ្ចេញឲ្យដឹងនូវ**គំរូនៃការរំលោភបំពានលើសិទ្ធិមនុស្សធ្ងន់ធ្ងរ និងដែលត្រូវបានផ្តល់នូវភស្តុតាងដោយគួរឲ្យជឿទុកចិត្តបាន**ដោយរបៀបណា ជាជាងការរំលោភបំពានជា លក្ខណៈបុគ្គល និង
- សេចក្តីពិស្តារអំពីថាតើ**ឧបាស្រ័យក្នុងស្រុកត្រូវបានប្រើប្រាស់**អស់ដោយរបៀបណា ឬ ការពន្យល់អំពីថាតើឧបាស្រ័យបែបនេះ នឹងមិនមានប្រសិទ្ធភាព ឬ ត្រូវបានអូសបន្លាយពេលយូរដោយមិនសមហេតុផលដោយរបៀបណា ។

**កំណត់សម្គាល់:**

- ពាក្យបណ្តឹងទាំងអស់ត្រូវតែមានលក្ខណៈជាលាយលក្ខណ៍អក្សរ ។ សូមកត់សម្គាល់ថា វាមិនមានលក្ខណៈពេញលេញដែលត្រូវពឹងពាក់លើរបាយការណ៍របស់ប្រព័ន្ធឃោសនាមហាជននោះទេ ។ ប្រសិនបើ អ្នកមានបំណងដាក់ជូនពិនិត្យនូវរបាយការណ៍សិទ្ធិមនុស្សជាភស្តុតាង ចូរជូនភ្ជាប់លិខិតអមដោយកំណត់អំពីខ្លួនអ្នកផ្ទាល់ ពន្យល់អំពីករណីដែលអ្នកចង់ប្តឹង និងដែលអ្នកមានបំណងចង់ឲ្យបណ្តឹងត្រូវបានដោះស្រាយ ក្រោមយន្តការបណ្តឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។
- វាមានលក្ខណៈអាចធ្វើបានដែលត្រូវកម្រិតលក្ខខណ្ឌលើពាក្យបណ្តឹងត្រឹមតែ ១០-១៥ ទំព័រ ។ ព័ត៌មានបន្ថែមអាចត្រូវបានដាក់ជូនពិនិត្យ នៅក្នុងដំណាក់កាលក្រោយ ។
- ពាក្យបណ្តឹង អាចត្រូវបានសរសេរជាភាសាអង់គ្លេស បារាំង រុស្ស៊ី ឬ អេស្ប៉ាញ ។ ឯកសារជាភាសាផ្សេងទៀតគួរតែត្រូវបានបកប្រែ ឬ សង្ខេបទៅជាភាសាមួយក្នុងចំណោមភាសាទាំងនេះ និង
- ពាក្យបណ្តឹងដែលមានភាសាដែលត្រូវបានចាត់ទុកថា រំលោភបំពាន ឬ ដែលធ្វើឲ្យមានការមើលងាយ នឹងមិនត្រូវបានពិចារណាឡើយ ។

ស្ថានភាពបែបបទ និងនីតិវិធីដែលមានលក្ខណៈពិស្តារនៃយន្តការបណ្តឹងនេះ ត្រូវបានបង្ហាញនៅក្នុង**សេចក្តីសម្រេចចិត្តលេខ 5/1** របស់ក្រុមប្រឹក្សា ។ ព័ត៌មានដែលត្រូវបានផ្តល់ជូននៅក្នុងផ្នែកនេះ មានមូលដ្ឋាននៅលើបទប្បញ្ញត្តិនៃសេចក្តីសម្រេចចិត្តនោះ ។ វាត្រូវបានរំពឹងទុកថា បទប្បញ្ញត្តិ និងវិធីសាស្ត្រការងារដំបូងទាំងនេះ ជាពិសេស ទាក់ទងទៅនឹងការចែករំលែកព័ត៌មានត្រឡប់ជាមួយនឹងដើមចោទ តាមរយៈដំណាក់កាលផ្សេងៗនៃដំណើរការ នឹងត្រូវបានរៀបចំបន្ថែមទៀត ។

ដំណាក់កាលនៃនីតិវិធីប្តឹង គឺៈ

## ដំណាក់កាលទី ១: ការពិនិត្យជ្រើសរើសដំបូង

លេខាធិការដ្ឋាននៃការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) រួមជាមួយនឹងប្រធាន**ក្រុមការងារទទួលបន្ទុកឯកសារបណ្តឹង** ពិនិត្យជ្រើសរើសពាក្យបណ្តឹងទាំងអស់ (ពាក្យបណ្តឹង) នៅពេលដែលវាមកដល់ ដោយមានមូលដ្ឋាននៅលើលក្ខណវិនិច្ឆ័យអង្គច្បាប់ និងច្រានចោលពាក្យបណ្តឹងដែលត្រូវបានរកឃើញថា មិនមានភស្តុតាងជាក់ស្តែង ឬ អនាមិក ។ ប្រសិនបើពាក្យបណ្តឹងត្រូវបានទទួលយកសម្រាប់ដំណាក់កាលបន្ទាប់នៃនីតិវិធី ដើមបណ្តឹងទទួលបានលិខិតបញ្ជាក់ថាបានទទួលជាលាយលក្ខណ៍អក្សរ ហើយពាក្យបណ្តឹងត្រូវផ្ញើចេញទៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីសុំការឆ្លើយតប ។

## ដំណាក់កាលទី ២: ក្រុមការងារទទួលបន្ទុកឯកសារបណ្តឹង

**ក្រុមការងារទទួលបន្ទុកឯកសារបណ្តឹង** មានសមាសភាពសមាជិកដែលត្រូវបានតែងតាំងចំនួនប្រាំរូបមកពី**គណៈកម្មាធិការផ្តល់ប្រឹក្សានៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** និងត្រូវបានប្រគល់អាណត្តិឲ្យជួបប្រជុំគ្នាយ៉ាងហោចណាស់ក៏ពីរដងក្នុងមួយឆ្នាំដែរសម្រាប់រយៈពេលប្រាំថ្ងៃក្នុងវគ្គប្រជុំពេញអង្គនីមួយៗ ។ ក្រុមការងារត្រួតពិនិត្យលើពាក្យបណ្តឹងដែលបានឆ្លងផុតដំណាក់កាលពិនិត្យជ្រើសរើសដំបូង និងចម្លើយតបខ្លះដែលត្រូវបានទទួលពីរដ្ឋាភិបាល ក្នុងបំណងជម្រាបជូនទៅក្រុមការងារទទួលបន្ទុកស្ថានភាពអំពីស្ថានភាពពិសេសណាមួយ ដែលហាក់ដូចជាបង្ហាញអំពីគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងដែលត្រូវបានផ្តល់ភស្តុតាងដោយគួរឲ្យជឿទុកចិត្តបានលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

## ដំណាក់កាលទី ៣: ក្រុមការងារទទួលបន្ទុកស្ថានភាព

**ក្រុមការងារទទួលបន្ទុកស្ថានភាព** មានសមាសភាពសមាជិកចំនួនប្រាំរូបមកពីក្រុមប្រឹក្សាសិទ្ធិមនុស្សដែលបម្រើនៅក្នុងឋានៈផ្ទាល់ខ្លួនរបស់ពួកគេ និងត្រូវបានប្រគល់អាណត្តិឲ្យជួបប្រជុំគ្នាយ៉ាងហោចណាស់ក៏ពីរដងក្នុងមួយឆ្នាំដែរ សម្រាប់រយៈពេលប្រាំថ្ងៃក្នុងវគ្គប្រជុំពេញអង្គនីមួយៗ ដើម្បីពិចារណាទៅលើស្ថានភាពដែលត្រូវបានបញ្ជូនឲ្យទៅក្រុមការងារទទួលបន្ទុកស្ថានភាពនេះ ដោយក្រុមការងារទទួលបន្ទុកឯកសារបណ្តឹង ។ ក្រុមការងារទទួលបន្ទុកស្ថានភាពនេះ វាយតម្លៃលើករណីដែលត្រូវបានបញ្ជូនឲ្យទៅខ្លួន និងផលិតរបាយការណ៍សម្រាប់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រួមជាមួយនឹងអនុសាសន៍ជាក់លាក់ស្តីពីវិធានការដែលត្រូវបានអនុវត្តទាក់ទងនឹងស្ថានភាពណាមួយដែលបង្ហាញពីគំរូសង្គតិភាពនៃការរំលោភបំពានដ៏ធ្ងន់ធ្ងរ ។ ជាជម្រើស

ក្រុមការងារទទួលបន្ទុកស្ថានភាពនេះ អាចសម្រេចដាក់ស្ថានភាពឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ឬ រំលត់បណ្ដឹងអាជ្ញា ។

> **i** សម្រាប់ព័ត៌មានបន្ថែមស្ដីពី**គណៈកម្មាធិការផ្ដល់ប្រឹក្សានៃក្រុមប្រឹក្សាសិទ្ធិមនុស្ស** សូមមើល**ជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស)** នៃ*សៀវភៅ*នេះ ។

## ដំណាក់កាលទី ៤: ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស ពិចារណានៅក្នុងវគ្គប្រជុំពេញអង្គ លើស្ថានភាពដែលត្រូវបានជម្រាបជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ដោយក្រុមការងារទទួលបន្ទុកស្ថានភាព ដោយញឹកញាប់តាមការចាំបាច់ ប៉ុន្តែយ៉ាងហោចណាស់ក៏ម្ដងក្នុងមួយឆ្នាំដែរ ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ត្រួតពិនិត្យលើរបាយការណ៍របស់ក្រុមការងារទទួលបន្ទុកស្ថានភាព ដែលត្រូវបានបញ្ជូនទៅឲ្យខ្លួន ដោយសម្ងាត់ លុះត្រាតែក្រុមប្រឹក្សាសិទ្ធិមនុស្សសម្រេចតាមបែបផ្សេង ។ ដោយមានមូលដ្ឋាននៅលើការពិចារណារបស់ខ្លួនលើស្ថានភាពមួយ ក្រុមប្រឹក្សានេះ អាចអនុវត្តវិធានការ តាមធម្មតា ជាទម្រង់នៃសេចក្ដីសម្រេចចិត្ត ឬ សេចក្ដីសម្រេច ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សអាចសម្រេចលើវិធានការដូចតទៅៈ

- ដើម្បីបញ្ឈប់ការពិចារណាលើស្ថានភាព នៅពេលដែលការពិចារណា ឬ វិធានការបន្ថែម មិនត្រូវបានធានា ។
- ដើម្បីដាក់ស្ថានភាពឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងស្នើសុំឲ្យរដ្ឋដែលពាក់ព័ន្ធ ផ្ដល់ព័ត៌មានបន្ថែមនៅក្នុងរយៈពេលសមស្រប ។
- ដើម្បីដាក់ស្ថានភាពឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ និងតែងតាំងមន្ត្រីជំនាញឯករាជ្យដែលមានសមត្ថភាពខ្ពស់ ដើម្បីពិនិត្យតាមដានស្ថានភាព និងធ្វើសេចក្ដីរាយការណ៍ត្រឡប់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនេះវិញ ។
- ដើម្បីបញ្ឈប់ការត្រួតពិនិត្យឡើងវិញលើបញ្ហា ដូចដែលមានចែងនៅក្នុងនីតិវិធីបណ្ដឹងជាលក្ខណៈសម្ងាត់ ដើម្បីចាប់ផ្ដើមពិចារណាជាសាធារណៈលើករណីដូចគ្នានេះ ។
- ដើម្បីផ្ដល់អនុសាសន៍ថា ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គួរតែផ្ដល់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ជំនួយកសាងសមត្ថភាព ឬ សេវាផ្ដល់ប្រឹក្សាដល់រដ្ឋដែលពាក់ព័ន្ធ ។

ឯកសារទាំងអស់ដែលត្រូវបានផ្ដល់ដោយបុគ្គល និងរដ្ឋាភិបាលទាំងឡាយ លើស្ថានភាពដែលកំពុងត្រូវបានពិចារណា ក៏ដូចជា សេចក្ដីសម្រេចដែលត្រូវបានអនុវត្តនៅដំណាក់កាលផ្សេងៗនៃនីតិវិធី នៅតែមាន**លក្ខណៈសម្ងាត់** ។ នេះក៏អនុវត្តផងដែរចំពោះស្ថានភាពដែលត្រូវបានបញ្ឈប់ ។

## i ទីកន្លែងដែលត្រូវផ្ញើចេញនូវពាក្យបណ្ដឹង នៅក្រោមយន្តការបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

**សាខាក្រុមប្រឹក្សាសិទ្ធិមនុស្ស (យន្តការបណ្ដឹង)**
ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ១១
អ៊ីម៉ែលៈ **CP@ohchr.org**

# ឧបសម្ព័ន្ធ I - ទម្រង់ពាក្យបណ្តឹងគំរូ សម្រាប់ការប្តឹងដូចដែលមានចែងនៅក្នុង:

- ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬ
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ។

**សូមបង្ហាញអំពីនីតិវិធីណាមួយក្នុងចំណោមនីតិវិធីខាងលើដែលអ្នកកំពុងតែប្រើប្រាស់**

កាលបរិច្ឆេទ: __________________________

**I. ព័ត៌មានស្តីពីដើមចោទ:**

- គោត្តនាម
- នាមខ្លួនមួយ (ឬ ច្រើន)
- សញ្ជាតិ
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងពាក្យបណ្តឹងនេះ ។
- ចូរបង្ហាញថាតើអ្នកកំពុងតែដាក់ជូនពិនិត្យនូវពាក្យបណ្តឹង:
  - ក្នុងនាមខ្លួនឯងផ្ទាល់
  - ក្នុងនាមបុគ្គលម្នាក់ទៀត

*[ប្រសិនបើពាក្យបណ្តឹង កំពុងត្រូវបានដាក់ជូនពិនិត្យ ក្នុងនាមបុគ្គលម្នាក់ទៀត:]*

- សូមផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួនដូចតទៅរបស់បុគ្គលផ្សេងទៀតនោះ:
- គោត្តនាម
- នាមខ្លួនមួយ (ឬ ច្រើន)
- សញ្ជាតិ
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- អាសយដ្ឋាន ឬ លំនៅដ្ឋានបច្ចុប្បន្ន ។

ប្រសិនបើអ្នក កំពុងតែបំពេញតួនាទីដោយបានដឹង និងមានការយល់ព្រមពីបុគ្គលនោះ សូមបង្ហាញអំពីការអនុញ្ញាតរបស់បុគ្គលនោះសម្រាប់ឲ្យអ្នកធ្វើការប្តឹងនេះ ។

ឬ

ប្រសិនបើ អ្នកមិនត្រូវបានអនុញ្ញាតទេ សូមពន្យល់អំពីប្រភេទនៃទំនាក់ទំនងរបស់អ្នកជាមួយនឹងបុគ្គលនោះ និងព័ត៌មានលម្អិតស្តីពីមូលហេតុដែលអ្នកចាត់ទុកថាវាសមស្របត្រូវធ្វើការប្តឹងក្នុងនាមបុគ្គលនោះ ។

## II. រដ្ឋដែលពាក់ព័ន្ធ/មាត្រាដែលត្រូវបានរំលោភបំពាន

- ឈ្មោះរបស់រដ្ឋដែលឬមួយជាភាគីនៃពិធីសារបន្ថែម (ក្នុងករណីដែលពាក្យបណ្តឹងជូនទៅគណៈកម្មាធិការសិទ្ធិមនុស្ស) ឬក៏បានធ្វើសេចក្តីប្រកាសដែលពាក់ព័ន្ធ (ក្នុងករណីដែលពាក្យបណ្តឹងជូនទៅគណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ឬ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងជាតិសាសន៍) ។
- មាត្រាទាំងឡាយនៃកតិកាសញ្ញា ឬ អនុសញ្ញា មានទទ្បីករណ៍ត្រូវបានរំលោភបំពាន ។

## III. ការប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុក/ការអនុវត្តចំពោះយន្តការអន្តរជាតិផ្សេងទៀត

- វិធានការដែលត្រូវបានអនុវត្តឬក្នុងនាមជនរងគ្រោះដែលមានទទ្បីករណ៍ម្នាក់ (ឬ ច្រើននាក់) ដើម្បីរកឲ្យបាននូវសំណងនៅក្នុងរដ្ឋដែលពាក់ព័ន្ធ ចំពោះការរំលោភបំពានដែលមានទទ្បីករណ៍ ពោលគឺ រៀបរាប់ឲ្យបានល្អិតល្អន់នីតិវិធីណាខ្លះ ត្រូវបានព្យាយាមអនុវត្តក្នុងនោះរួមមាន ឧបាស្រ័ចំពោះតុលាការ និងអាជ្ញាធរសាធារណៈផ្សេងទៀតផងដែរ សេចក្តីអះអាងណាខ្លះដែលអ្នកបានធ្វើឡើងនៅពេលណាខ្លះ និងដោយមានលទ្ធផលអ្វីខ្លះ ។
- ប្រសិនបើ អ្នកមិនបានប្រើប្រាស់អស់នូវឧបាស្រ័យទាំងនេះ ដោយសារការអនុវត្តលើឧបាស្រ័យទាំងនេះ នឹងត្រូវបានអូសបន្លាយពេលយូរជ្រុលហួសហេតុ វានឹងមិនមានប្រសិទ្ធភាពទេ វាមិនត្រូវបានរៀបចំឲ្យមានសម្រាប់អ្នកទេ ឬ ចំពោះមូលហេតុណាមួយផ្សេងទៀត សូមពន្យល់អំពីមូលហេតុរបស់អ្នកឲ្យបានពិស្តារ ។
- តើអ្នកបានដាក់ជូនពិនិត្យនូវបញ្ហាដូចគ្នា សម្រាប់ការត្រួតពិនិត្យក្រោមយន្តការមួយទៀតនៃការស៊ើបអង្កេត ឬ ដំណោះស្រាយជាលក្ខណៈអន្តរជាតិ (ឧទាហរណ៍ដូចជាៈ គណៈកម្មការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ឬ គណៈកម្មការអាព្រិចទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ) ដែរឬទេ ?
- ប្រសិនបើដូច្នេះមែន ចូររៀបរាប់ឲ្យបានល្អិតល្អន់នីតិវិធីណាមួយ (ឬ ណាខ្លះ) ត្រូវបាន ឬ កំពុងត្រូវបានព្យាយាមអនុវត្ត សេចក្តីអះអាងណាខ្លះដែលអ្នកបានធ្វើឡើង នៅពេលណាខ្លះ និងដោយមានលទ្ធផលអ្វីខ្លះ ។

## IV. អង្គហេតុនៃពាក្យបណ្តឹង

- ចូររៀបរាប់ឲ្យបានល្អិតល្អន់តាមលំដាប់ប្រវត្តិការណ៍តាមកាលនូវអង្គហេតុ និងស្ថានភាពនៃការរំលោភបំពានដែលមានទទ្បីករណ៍ ។ បញ្ចូលបញ្ហាទាំងអស់ដែលអាចពាក់ព័ន្ធនឹងការវាយតម្លៃ និងការពិចារណាលើករណីពិសេសរបស់អ្នក ។ សូមពន្យល់ថាតើអ្នកពិចារណាថាអង្គហេតុ និងស្ថានភាពដែលត្រូវបានពិពណ៌នា រំលោភបំពានលើសិទ្ធិរបស់អ្នកដោយរបៀបណា ។
- ហត្ថលេខារបស់អ្នកដើមចោទ ។

**V. បញ្ជីឯកសារអម (ច្បាប់ចម្លង មិនមែនច្បាប់ដើមទេ ដែលត្រូវបានភ្ជាប់ជាមួយនឹងពាក្យបណ្តឹងរបស់អ្នក)ៈ**

- លិខិតផ្ទេរសិទ្ធិអំណាចក្នុងការអនុវត្តជាលាយលក្ខណ៍អក្សរ (ប្រសិនបើអ្នកធ្វើការប្តឹងក្នុងនាមបុគ្គលម្នាក់ទៀត និងបើមិនដូច្នោះទេ កំពុងធ្វើយុត្តិកម្មអវត្តមាននៃការអនុញ្ញាតជាក់លាក់) ។
- សេចក្តីសម្រេចរបស់តុលាការក្នុងស្រុក និងអាជ្ញាធរលើសេចក្តីអះអាងរបស់អ្នក (ច្បាប់ចម្លងនៃច្បាប់ជាតិដែលពាក់ព័ន្ធ ក៏មានប្រយោជន៍ផងដែរ) ។
- ពាក្យបណ្តឹង និងសេចក្តីសម្រេចដោយយន្តការណាមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬដំណោះស្រាយជាលក្ខណៈអន្តរជាតិ ។
- កម្រងឯកសារណាមួយ ឬ ភស្តុតាងបញ្ជាក់ផ្សេងទៀតដែលអ្នកមាន ដែលបញ្ជាក់ភស្តុតាងដល់សេចក្តីពិពណ៌នារបស់អ្នកនៅក្នុងផ្នែក IV (ខាងលើ) នៃអង្គហេតុនៃសេចក្តីអះអាងរបស់អ្នក និង/ឬ សេចក្តីសំអាងរបស់អ្នកថា អង្គហេតុដែលត្រូវបានពិពណ៌នា ដូចគ្នានឹងការរំលោភបំពានលើសិទ្ធិរបស់អ្នក ។

ប្រសិនបើអ្នកមិនភ្ជាប់មកជាមួយនូវព័ត៌មាននេះទេ និងវាចាំបាច់ត្រូវបានស្វែងរកដោយជាក់លាក់ពីអ្នក ឬ ប្រសិនបើឯកសារអមមិនត្រូវបានផ្តល់ជាភាសាការងាររបស់លេខាធិការដ្ឋានទេនោះ ការពិចារណាលើពាក្យបណ្តឹងរបស់អ្នកអាចត្រូវបានពន្យារពេល ។

# ឧបសម្ព័ន្ធ II - គោលការណ៍ណែនាំស្តីពីពាក្យបណ្តឹងសម្រាប់ការប្តឹង ដូចដែលមានចែងនៅក្នុង:

- **ពិធីសារបន្ថែមនៃអនុសញ្ញា ស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី**

**១. ព័ត៌មានពាក់ព័ន្ធនឹងអ្នកដើមបណ្តឹងម្នាក់ (ឬ ច្រើននាក់)**

- គោត្តនាម
- នាមខ្លួន
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ/ភាពជាពលរដ្ឋ
- លិខិតឆ្លងដែន/លេខអត្តសញ្ញាណប័ណ្ណ (ប្រសិនបើមាន)
- ភេទ
- ស្ថានភាពអាពាហ៍ពិពាហ៍/កូន
- មុខងារ
- សាវតារជាពន្ធុ អង្គការសាខាខាងសាសនា ក្រុមសង្គមកិច្ច (ប្រសិនបើពាក់ព័ន្ធ) ។
- អាសយដ្ឋានបច្ចុប្បន្ន
- អាសយដ្ឋានប្រៃសណីយ៍សម្រាប់លិខិតទាក់ទងដែលមានលក្ខណៈសម្ងាត់ (ប្រសិនបើមានក្រៅពីអាសយដ្ឋានបច្ចុប្បន្ន) ។
- ទូរសារ/ទូរស័ព្ទ/អ៊ីម៉ែល
- ចូរបង្ហាញថាតើអ្នកកំពុងដាក់ជូនពិនិត្យនូវពាក្យបណ្តឹងក្នុងនាមជា:
  - ជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) ដែលមានទទ្បីករណ៍ដែរឬអត់ ។ ប្រសិនបើមានក្រុមជនរងគ្រោះ ចូរផ្តល់ព័ត៌មានជាមូលដ្ឋានអំពីបុគ្គលម្នាក់ៗ ។
  - ក្នុងនាមជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) ។ ចូរផ្តល់ភស្តុតាងដែលបង្ហាញអំពីការយល់ព្រមរបស់ជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) ឬ មូលហេតុដែលផ្តល់យុត្តិកម្មលើការដាក់ជូនពិនិត្យនូវពាក្យបណ្តឹងដោយគ្មានការយល់ព្រម ។

**២. ព័ត៌មានពាក់ព័ន្ធនឹងជនរងគ្រោះម្នាក់ (ឬ ច្រើននាក់) ដែលមានទទ្បីករណ៍ (ប្រសិនបើមានក្រៅពីដើមបណ្តឹង)**

- គោត្តនាម
- នាមខ្លួន
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ/ភាពជាពលរដ្ឋ

- លិខិតឆ្លងដែន/លេខអត្តសញ្ញាណប័ណ្ណ (ប្រសិនបើមាន)
- ភេទ
- ស្ថានភាពអាពាហ៍ពិពាហ៍/កូន
- មុខងារ
- សាវតារជាតិពន្ធុ អង្គការសាខាខាងសាសនា ក្រុមសង្គមកិច្ច (ប្រសិនបើពាក់ព័ន្ធ) ។
- អាសយដ្ឋានបច្ចុប្បន្ន
- អាសយដ្ឋានប្រៃសណីយ៍សម្រាប់លិខិតទាក់ទងដែលមានលក្ខណៈសម្ងាត់ (ប្រសិនបើមានក្រៅពីអាសយដ្ឋានបច្ចុប្បន្ន) ។
- ទូរសារ/ទូរស័ព្ទ/អ៊ីម៉ែល ។

## ៣. ព័ត៌មានស្តីពីភាគីរដ្ឋដែលពាក់ព័ន្ធ

- ឈ្មោះរបស់ភាគីរដ្ឋ (ប្រទេស) ។

## ៤. ប្រភេទនៃការរំលោភបំពានមួយ (ឬ ច្រើន) ដែលមានទទ្បីករណ៍

- ការពិពណ៌នាអំពីការរំលោភបំពានមួយ (ឬ ច្រើន) ដែលមានទទ្បីករណ៍ និងចារីម្នាក់ (ឬ ច្រើននាក់) ដែលមានទទ្បីករណ៍ ។
- កាលបរិច្ឆេទមួយ (ឬ ច្រើន)
- ទីកន្លែងមួយ (ឬ ច្រើន)
- បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ ដែលត្រូវបានរំលោភបំពានដោយមានទទ្បីករណ៍ ។ ប្រសិនបើពាក្យបណ្ដឹង សំដៅទៅលើបទប្បញ្ញត្តិច្រើនជាងមួយ ចូរពិពណ៌នាអំពីបញ្ហានីមួយៗដោយឡែកៗពីគ្នា ។

## ៥. វិធានការដែលត្រូវបានអនុវត្ត ដើម្បីប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុក

ចូរពិពណ៌នាអំពីវិធានការដែលត្រូវបានអនុវត្ត ដើម្បីប្រើប្រាស់ឲ្យអស់នូវឧបាស្រ័យក្នុងស្រុក ។ ឧទាហរណ៍ៈ ការប៉ុនប៉ងរកឲ្យបាននូវឧបាស្រ័យស្របច្បាប់ រដ្ឋបាល ផ្លូវច្បាប់ គោលនយោបាយ ឬ កម្មវិធី ក្នុងនោះរួមមានៈ

- ប្រភេទមួយ (ឬ ច្រើន) នៃឧបាស្រ័យ ដែលត្រូវបានស្វែងរក ។
- កាលបរិច្ឆេទមួយ (ឬ ច្រើន)
- ទីកន្លែងមួយ (ឬ ច្រើន)
- នរណាបាន ផ្តួចផ្តើមវិធានការ ។
- អាជ្ញាធរ ឬ ស្ថាប័ន ណាមួយ ត្រូវបានផ្តោតការយកចិត្តទុកដាក់ ។
- ឈ្មោះរបស់តុលាការ ដែលធ្វើសវនាការករណីនេះ (ប្រសិនបើមាន) ។
- ប្រសិនបើឧបាស្រ័យក្នុងស្រុក មិនត្រូវបានប្រើប្រាស់អស់ ចូរពន្យល់អំពីមូលហេតុ ។

**កំណត់សម្គាល់:** ចូរភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃកម្រងឯកសារទាំងអស់ដែលពាក់ព័ន្ធ ។

## ៦. យន្តការអន្តរជាតិផ្សេងទៀត

តើបញ្ហាដូចគ្នានេះ ត្រូវបានត្រួតពិនិត្យរួចហើយ ឬ តើវាកំពុងត្រូវបានត្រួតពិនិត្យក្រោមយន្តការមួយទៀត នៃការស៊ើបអង្កេត ឬ ដំណោះស្រាយជាលក្ខណៈអន្តរជាតិដែរឬទេ ? ប្រសិនបើដូច្នេះមែន ចូរពន្យល់:

- ប្រភេទនៃយន្តការមួយ (ឬ ច្រើន)
- កាលបរិច្ឆេទមួយ (ឬ ច្រើន)
- ទីកន្លែងមួយ (ឬ ច្រើន)
- លទ្ធផល (ប្រសិនបើមាន)

**កំណត់សម្គាល់:** ចូរភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃកម្រងឯកសារទាំងអស់ដែលពាក់ព័ន្ធ ។

## ៧. កាលបរិច្ឆេទ និងហត្ថលេខា

កាលបរិច្ឆេទ/ទីកន្លែង: ______________________

ហត្ថលេខារបស់អ្នកដើមបណ្ដឹងម្នាក់ (ឬ ច្រើននាក់) និង/ឬ ជនរងគ្រោះម្នាក់ (ឬ ច្រើននាក់):______

## ៨. បញ្ជីឈ្មោះឯកសារដែលត្រូវបានជូនភ្ជាប់មកជាមួយ (ចូរកុំផ្ញើចេញនូវឯកសារច្បាប់ដើម តែច្បាប់ចម្លងប៉ុណ្ណោះ)

# IX. មូលនិធិ និងជំនួយ

មានមូលនិធិ និងជំនួយមួយចំនួន ដែលក្នុងនោះ មូលនិធិ និងជំនួយខ្លះ ត្រូវបានគ្រប់គ្រងដោយផ្ទាល់ ដោយ**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស** (OHCHR) ដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់តួអង្គសង្គមស៊ីវិល ក្នុងនោះរួមមាន អង្គការមិនមែនរដ្ឋាភិបាល (NGO) អង្គការក្នុងស្រទាប់មហាជន សមាគមអ្នកវិជ្ជាជីវៈ និងបុគ្គលទាំងឡាយ ។ ទាំងនេះ អាចផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់សកម្មភាពរបស់សង្គមស៊ីវិលនៅក្នុងវិស័យសិទ្ធិមនុស្សខ្លះ ។

**អង្គការមូលនិធិ** រៀបចំឲ្យមានជំនួយហិរញ្ញវត្ថុ ដើម្បីគាំទ្រសកម្មភាពនៅក្នុងអាណត្តិរបស់គេ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងការិយាល័យផ្សេងទៀតរបស់អង្គការសហប្រជាជាតិ គ្រប់គ្រងមូលនិធិ និងជំនួយមួយចំនួន ដើម្បីគាំទ្រដល់តួអង្គសង្គមស៊ីវិលនៅកាលៈទេសៈខ្លះ ។ អង្គការមូលនិធិ ទទួលវិភាគទានស្ម័គ្រចិត្តពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គភាពឯកជន ឬ សាធារណៈផ្សេងទៀត និងបុគ្គលទាំងឡាយ សម្រាប់ចែកចាយ ដោយអនុលោមតាមអាណត្តិរបស់គេ ។

ជាទូទៅ អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការក្នុងស្រទាប់មហាជន ក្រុមសហគមន៍ និងសមាគមអ្នកវិជ្ជាជីវៈ មានសិទ្ធិដាក់ពាក្យសុំមូលនិធិ និងជំនួយ ។ នៅក្នុងករណីខ្លះ បុគ្គលក៏អាចដាក់ពាក្យសុំមូលនិធិជំនួយបានដែរ ។ តួអង្គសង្គមស៊ីវិលដែលចង់ដាក់ពាក្យសុំ គួរតែត្រួតពិនិត្យមើលឡើងវិញដោយប្រុងប្រយ័ត្នលើគោលការណ៍ណែនាំ និងធានាថា គោលការណ៍ណែនាំទាំងនេះ បំពេញលក្ខខណ្ឌផ្នែករដ្ឋបាល និងផ្សេងទៀត ។

**ឋានៈពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ (ECOSOC) មិនមែនជាលក្ខខណ្ឌសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ចូលរួម ឬ ប្រើប្រាស់មូលនិធិ ឬ ជំនួយណាមួយក្នុងចំណោមមូលនិធិ ឬ ជំនួយទាំងនេះនោះទេ ។**

## ក. តើមូលនិធិ និងជំនួយមានអ្វីខ្លះ ?

មូលនិធិ និងជំនួយ ដែលត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានៈ

---

សៀវភៅនេះ ត្រូវបានរៀបចំឲ្យមានជាទម្រង់អេឡិចត្រូនិកនៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR): **http://www.ohchr.org/civilsocietyhandbook/** ។

នៅទីនោះ អ្នក នឹងរកឃើញជំពូកនានារបស់សៀវភៅនេះ ដែលត្រូវបានរៀបចំឲ្យមានសម្រាប់ផ្ទេរចេញយកមកប្រើប្រាស់ ក៏ដូចជា ការភ្ជាប់ទំព័រអ៊ិនធើណិតមួយទៅទំព័រអ៊ិនធើណិតមួយផ្សេងទៀតដែលមានឯកសារយោងទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងអត្ថបទបោះពុម្ពផ្សាយ ។

- **មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម** ដែលផ្តល់ជំនួយដល់តួអង្គសង្គមស៊ីវិលដែលផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច សេវាជំនួយផ្នែកច្បាប់ ជំនួយមនុស្សធម៌ ឬ ទម្រង់ផ្សេងទៀតនៃជំនួយ ដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម និងសមាជិកនៃគ្រួសាររបស់ពួកគេ ។ តួអង្គសង្គមស៊ីវិលដែលមានសិទ្ធិ រួមមាន ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនីតិសម្បទាជំនាញ សមាគមជនរងគ្រោះ មូលនិធិ និងមន្ទីរពេទ្យ និងពុំសូវញឹកញាប់នោះគឺ បុគ្គលជាអ្នកការពារសិទ្ធិមនុស្ស ឧទាហរណ៍ៈ អ្នកច្បាប់ ដែលបំពេញតួនាទីក្នុងនាមជនរងគ្រោះ ។
- **មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច** ដែលផ្តល់ជំនួយសម្រាប់ការធ្វើដំណើរ ដើម្បីសម្របសម្រួលឲ្យមានការចូលរួមរបស់តំណាងសហគមន៍ និងអង្គការរបស់ជនជាតិដើមភាគតិច នៅក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិ ដែលទាក់ទងទៅនឹងបញ្ហារបស់ជនជាតិដើមភាគតិច ។
- **មូលនិធិទំនុកចិត្តស្ម័គ្រចិត្ត នៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព** ដែលផ្តល់ជំនួយគម្រោងខ្នាតតូច ជាពិសេស ដល់អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ និងក្រុមយុវជន សហជីព ឬ សមាគមអ្នកវិជ្ជាជីវៈ ដែលជួយដល់ជនរងគ្រោះដោយទម្រង់សហកាលនៃទាសភាព និង
- **គម្រោង "ជួយសហគមន៍រួម" (ACT)** ដែលផ្តល់ជំនួយខ្នាតតូច ដើម្បីគាំទ្រដល់កិច្ចផ្តួចផ្តើមបណ្តុះបណ្តាល និងអប់រំសិទ្ធិមនុស្សនៅមូលដ្ឋាន ។

មូលនិធិពីរផ្សេងទៀតដែលគាំទ្រដល់សកម្មភាពរបស់សង្គមស៊ីវិលលើបញ្ហាសំខាន់ៗ ក៏ត្រូវបានផ្តោតការយកចិត្តទុកដាក់ផងដែរនៅក្នុងជំពូកនេះៈ

- **មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ** ដែលផ្តល់មូលនិធិជំនួយសម្រាប់គម្រោងដែលបង្កើត និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ លើកកម្ពស់សិទ្ធិមនុស្ស និងធានាឲ្យមានការចូលរួមរបស់ក្រុមទាំងអស់នៅក្នុងដំណើរការប្រជាធិបតេយ្យ និង
- **មូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការនៃអង្គការសហប្រជាជាតិ** ដែលផ្តល់ជំនួយខ្នាតតូច ដើម្បីគាំទ្រដល់សកម្មភាព ដែលចាត់ទុកជាគោលបំណងនូវការកសាងសមត្ថភាព របស់អង្គការសង្គមស៊ីវិល ដើម្បីចូលរួមនៅក្នុងការអនុវត្ត**អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ** ។

ទោះបីជាត្រូវបានគ្រប់គ្រងដោយការិយាល័យផ្សេងទៀត របស់អង្គការសហប្រជាជាតិក៏ដោយ ក៏ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានតួនាទីជ្រើសតាំងនៅក្នុងមូលនិធិទាំងពីរនេះដែរ ។

## i ព័ត៌មានទំនាក់ទំនង

*មូលនិធិដែលត្រូវបានគ្រប់គ្រងដោយការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)*

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម**

មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩១៧ ៩៣ ១៥
ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ១៧
អ៊ីម៉ែលៈ **unvfvt@ohchr.org**

**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច**

មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩១ ៦៤ ឬ +៤១ (0)២២ ៩២៨ ៩១ ៤២
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០ ៦៦
អ៊ីម៉ែលៈ **IndigenousFunds@ohchr.org**

**មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព**

មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩៣ ៨១ ឬ +៤១ (0)២២ ៩២៨ ៩១ ៦៤
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០ ៦៦
អ៊ីម៉ែលៈ **SlaveryFund@ohchr.org**

**គម្រោង ‘ជួយសហគមន៍រួម’ (ACT)**
គម្រោងជួយសហគមន៍រួម
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩០ ៦១
អ៊ីម៉ែលៈ **ACTProject@ohchr.org**

*មូលនិធិដែលត្រូវបានគ្រប់គ្រងដោយការិយាល័យផ្សេងទៀត របស់អង្គការសហប្រជាជាតិ ដែលក្នុងនោះការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានតួនាទីជ្រើសតាំង*

**មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ**
មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ (UNDEF)
អង្គការសហប្រជាជាតិ
One UN Plaza, Room DC1-1330
ញូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរស័ព្ទៈ +១ ៩១៧ ៣៦៧ ៤២ ១០ ឬ +១ ៩១៧ ៣៦៧ ៨០ ៦២
ទូរសារលេខៈ +១ ២១២ ៩៦៣ ១៤ ៨៦
អ៊ីម៉ែលៈ **democracyfund@ohchr.org**

**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការនៃអង្គការសហប្រជាជាតិ**
លេខាធិការដ្ឋានទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ
ផ្នែកសេដ្ឋកិច្ច និងកិច្ចការសង្គម
អង្គការសហប្រជាជាតិ
Two UN Plaza, Room DC1-1330
ញូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរសារលេខៈ +១ ២១២ ៩៦៣ ០១ ១១
អ៊ីម៉ែលៈ **enable@ohchr.org**

## ខ. តើមូលនិធិ និងជំនួយ ដំណើរការទៅដោយរបៀបណា ?

### ១. មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះ ដោយការធ្វើទារុណកម្ម

អាណត្តិរបស់**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម** ត្រូវតែផ្តល់**ជំនួយ**ដល់គម្រោងជំនួយមនុស្សធម៌ (ផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ ច្បាប់ សង្គមកិច្ច និងហិរញ្ញវត្ថុ) ជនរងគ្រោះដោយការធ្វើទារុណកម្ម និងសមាជិកគ្រួសាររបស់ពួកគេ តាមរយៈបណ្តាញជំនួយដែលត្រូវបានបង្កើតឡើង ដែលតាមធម្មតា ជាតួអង្គសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនីតិសម្បទាជំនាញ សមាគមជនរងគ្រោះ មូលនិធិ និងមន្ទីរពេទ្យ និងដោយពុំសូវញឹកញាប់នោះ គឺ បុគ្គលជាអ្នកការពារសិទ្ធិមនុស្ស ។ ពាក្យសុំជំនួយពីអង្គភាពរដ្ឋាភិបាល សភា ឬ រដ្ឋបាល គណបក្សនយោបាយ ឬ ចលនាសេរីភាពជាតិ មិនអាចទទួលយកបានទេ ។

មូលនិធិស្ម័គ្រចិត្តសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម គឺជាមូលនិធិធំបំផុតដែលត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលរួមវិភាគទានដល់គម្រោងដែលត្រូវបានអនុវត្តដោយតួអង្គសង្គមស៊ីវិលនៅក្នុងប្រទេសចំនួនជាង ៦០ ។ មូលនិធិនេះ ត្រូវបានគ្រប់គ្រងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ផ្អែកលើការណែនាំរបស់ក្រុមប្រឹក្សាអ្នកទទួលគ្រប់គ្រង ។ក្រុមប្រឹក្សានេះ ជួបប្រជុំគ្នាពីរដងក្នុងមួយឆ្នាំនៅក្នុងខែ កុម្ភៈ លើបញ្ហាគោលនយោបាយ និងនៅខែតុលា ដើម្បីប្រគល់ជំនួយ ។ ក្រុមប្រឹក្សានេះ ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ស្តីពីការប្រើប្រាស់ជំនួយមុនៗ និងអនុម័តអនុសាសន៍ស្តីពីជំនួយថ្មី និងក៏ជួបប្រជុំជាមួយនឹងម្ចាស់ជំនួយធម្មតារបស់អង្គការមូលនិធិផងដែរ ក៏ដូចជា ម្ចាស់ជំនួយជាលក្ខណៈស្ថាប័នផ្សេងទៀត និងពិភាក្សាលើបញ្ហាគោលនយោបាយដែលទាក់ទងនឹងជំនួយសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម ។

លេខាធិការដ្ឋាន និងក្រុមប្រឹក្សារបស់អង្គការមូលនិធិ មានមូលដ្ឋាននៅឯការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅក្នុងទីក្រុងហ្សឺណែវ ។ លេខាធិការដ្ឋាននេះ កំណត់អំពីភាពដែលអាចទទួលយកបាននៃពាក្យសុំជំនួយសម្រាប់ជំនួយសម្រាប់គម្រោង ចំណែកឯវា គឺជាតួនាទីរបស់ក្រុមប្រឹក្សាក្នុងការវិនិច្ឆ័យលើពាក្យសុំជំនួយដោយផ្អែកលើលក្ខណសម្បត្តិរបស់គេ ។ ក្រុមប្រឹក្សានេះ ពិចារណាលើកត្តាមួយចំនួនៈ

- ចំនួនជនរងគ្រោះដោយការធ្វើទារុណកម្ម និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានផ្តល់ជំនួយដោយគម្រោង ។
- ប្រភេទនៃការធ្វើទារុណកម្មដែលត្រូវបានស៊ូទ្រាំ និងឥទ្ធិពលបន្តមកទៀត ដែលត្រូវបានទទួលរង ។
- ប្រភេទជំនួយដែលត្រូវការចាំបាច់ ។
- បទពិសោធន៍ផ្នែកវិជ្ជាជីវៈរបស់បុគ្គលិកគម្រោង ក្នុងការជួយជនរងគ្រោះដោយការធ្វើទារុណកម្ម ។

- ករណីសិក្សារបស់ជនរងគ្រោះដែលត្រូវបានផ្តល់ជំនួយ និង
- តម្រូវការឲ្យជួយគម្រោងខ្នាតតូច សម្រាប់ជំនួយមនុស្សធម៌សម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម ដែលគម្រោងខ្នាតតូចភាគច្រើនទាំងនោះ មានមូលនិធិជំនួយតិចតួចណាស់នៅក្នុងតំបន់អាទិភាព: អាព្រិច អាស៊ី អាស៊ីកណ្តាល និងអឺរ៉ុបខាងកើត ។

ជំនួយពីអង្គការមូលនិធិ រួមបញ្ចូលរយៈពេល ១២ ខែ ។ ពាក្យសុំជំនួយថ្មីសម្រាប់ការបន្តគម្រោងអាចត្រូវបានដាក់ជូនពិនិត្យ និងជំនួយថ្មី ត្រូវបានផ្តល់អនុសាសន៍ ឲ្យតែក្រុមប្រឹក្សាទទួលបាន**របាយការណ៍ដំណើរការហិរញ្ញវត្ថុ និងសវនកម្មស្តីពីការប្រើប្រាស់ជំនួយមុនៗ**ដែលគួរឲ្យពេញចិត្ត ។

ខួបជំនួយ គឺឆ្នាំនីមួយៗដូចតទៅ:
- កាលបរិច្ឆេទកំណត់ទទួលពាក្យសុំជំនួយ និងរបាយការណ៍ស្តីពីការប្រើប្រាស់ជំនួយមុនៗ: **ថ្ងៃទី ១ ខែ មេសា** ។
- ការវិភាគដោយលេខាធិការដ្ឋានលើពាក្យសុំជំនួយ ក៏ដូចជា ទស្សនកិច្ចពិនិត្យជ្រើសរើសជាមុនទៅកាន់អ្នកដាក់ពាក្យសុំជំនួយដែលអាចទទួលយកបាន: **ពីខែ មេសា ដល់ខែ កញ្ញា** ។
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអ្នកទទួលគ្រប់គ្រង: **ខែ តុលា** ។
- ព័ត៌មានសម្រាប់អ្នកដាក់ពាក្យសុំជំនួយស្តីពីអនុសាសន៍របស់ក្រុមប្រឹក្សា: **ខែ វិច្ឆិកា** ។
- ការទូទាត់ថវិកាជំនួយ: **ខែ មករា នៃឆ្នាំ បន្ទាប់ពីការដាក់ពាក្យសុំ** ។

## វិធីប្រើប្រាស់មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម[76]

### តើនរណាមានសិទ្ធិទទួលបានជំនួយ?

- មានតែអង្គភាពមិនមែនរដ្ឋាភិបាលប៉ុណ្ណោះ អាចដាក់ពាក្យសុំបាន ។ នេះរួមមាន អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលស្តារនីតិសម្បទាជំនាញ សមាគមជនរងគ្រោះ មូលនិធិ និងមន្ទីរពេទ្យ និងដោយពុំសូវញឹកញាប់នោះគឺ បុគ្គលជាអ្នកការពារសិទ្ធិមនុស្ស ឧទាហរណ៍: អ្នកច្បាប់ដែលបំពេញតួនាទីក្នុងនាមជនរងគ្រោះ ។
- ពាក្យសុំជំនួយពីរដ្ឋាភិបាល ចលនាសេរីភាពជាតិ ឬ គណបក្សនយោបាយ មិនអាចទទួលយកបានទេ ។
- ក្រុមអ្នកទទួលផលផ្ទាល់របស់គម្រោង ត្រូវតែជាជនរងគ្រោះដោយការធ្វើទារុណកម្ម ដូចដែលត្រូវបានស្វែងយល់នៅក្នុងមាត្រា ១ នៃសេចក្តីប្រកាស ស្តីពីកិច្ចការពារមនុស្សទាំងអស់ពីការដែលត្រូវ

[76] រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពឯកជន ឬ សាធារណៈផ្សេងទៀត អាចរួមវិភាគទានដល់អង្គការមូលនិធិបាន ។ សម្រាប់ព័ត៌មានស្តីពីរបៀបរួមវិភាគទាន សូមទាក់ទងនឹងលេខាធិការដ្ឋានរបស់អង្គការមូលនិធិនោះ ។

បានដាក់ឲ្យស្ថិតនៅក្រោមការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប ឬ ការដាក់ទណ្ឌកម្មផ្សេងទៀត ឬ សមាជិកគ្រួសារផ្ទាល់របស់ពួកគេ ។

- បុគ្គលិកដែលចូលរួមពាក់ព័ន្ធនៅក្នុងគម្រោង គួរតែមានបទពិសោធន៍លើជំនួយផ្ទាល់ចំពោះជនរងគ្រោះដោយការធ្វើទារុណកម្ម និងគម្រោង គួរតែមានហើយជាស្រេចដែលនឹងដំណើរការនៅពេលដាក់ជូនពិនិត្យសំណើសុំជំនួយ ។
- ពាក្យសុំជំនួយត្រូវតែបានរៀបចំឡើង ដោយប្រើប្រាស់ទម្រង់ពាក្យសុំជាទម្រង់អេឡិចត្រូនិច របស់អង្គការមូលនិធិ ដែលត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។
- ពាក្យសុំជំនួយត្រូវតែបានដាក់ជូនពិនិត្យទៅលេខាធិការដ្ឋានរបស់អង្គការមូលនិធិ នៅមុនថ្ងៃទី ១ ខែមេសា រៀងរាល់ឆ្នាំ ។

អ្នកដាក់ពាក្យសុំជំនួយលើកទីមួយទៅអង្គការមូលនិធិ គួរតែៈ

- ផ្តល់ព័ត៌មានជាមូលដ្ឋានស្តីពីអង្គការរបស់គេ ។
- បង្ហាញថា បុគ្គលិករបស់ខ្លួន មានបទពិសោធន៍ពាក់ព័ន្ធនៅក្នុងការផ្តល់ជំនួយផ្ទាល់ដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម (អាជីវប្រវត្តិ គួរតែត្រូវបានជូនភ្ជាប់មកជាមួយ) ។
- ពន្យល់អំពីគោលបំណង និងការធ្វើយុត្តិកម្មចំពោះគម្រោង និង
- ផ្តល់លក្ខន្តិកៈរបស់អង្គការ ។

## តើគម្រោងប្រភេទណាខ្លះ ត្រូវបានទទួលយក ?

- ពាក្យសុំជំនួយ គួរតែមានគោលបំណងផ្តល់នូវជំនួយផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច ច្បាប់ មនុស្សធម៌ ឬ ទម្រង់ផ្សេងទៀតនៃជំនួយ ដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម និងសមាជិកគ្រួសាររបស់ពួកគេ ។
- ពាក្យសុំជំនួយសម្រាប់គម្រោងដែលពាក់ព័ន្ធនឹងការធ្វើសមាហរ័ណកម្មសង្គម ឬ សេដ្ឋកិច្ចរបស់ជនរងគ្រោះដោយការធ្វើទារុណកម្មទៅក្នុងសង្គម ក្នុងនោះរួមមាន ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនរងគ្រោះនោះឯងផងដែរ ត្រូវបានទទួលយក ។
- ដោយអាស្រ័យទៅលើមូលនិធិដែលមាន ជំនួយមួយចំនួនតូច ក៏អាចត្រូវបានផ្តល់ជូនផងដែរសម្រាប់ការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈ ឬ ការរៀបចំសន្និសីទ និងសិក្ខាសាលា ដោយផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើការព្យាបាលជនរងគ្រោះដោយការធ្វើទារុណកម្ម ។
- ពាក្យសុំជំនួយសម្រាប់គម្រោងដែលមានគោលបំណងធ្វើយុទ្ធនាការប្រឆាំងនឹងការធ្វើទារុណកម្ម ការទប់ស្កាត់ការធ្វើទារុណកម្ម ឬ ការផ្តល់ជំនួយហិរញ្ញវត្ថុដល់គម្រោងផ្សេងទៀត នឹងមិនត្រូវបានទទួលយកឡើយ ។
- ពាក្យសុំជំនួយសម្រាប់គម្រោងដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត ការសិក្សា ការស្រាវជ្រាវ ការបោះពុម្ពផ្សាយព្រឹត្តិបត្រសារព័ត៌មាន ឬ សកម្មភាពស្រដៀងគ្នានេះ នឹងមិនត្រូវបានទទួលយកឡើយ ។

- ជាទូទៅ ពាក្យសុំជំនួយសម្រាប់គម្រោងដែលមានគោលបំណងធ្វើហិរញ្ញប្បទាន ដល់ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលថ្មី ឬ អង្គការសង្គមស៊ីវិលផ្សេងទៀត នឹងមិនត្រូវបានទទួលយកឡើយ ។
- អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិលផ្សេងទៀតដែលដាក់ជូនពិនិត្យនូវពាក្យសុំជំនួយសម្រាប់គម្រោង ដើម្បីផ្តល់សេវាជំនួយផ្នែកច្បាប់ផ្ទាល់ដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម គួរតែដាក់ជូនពិនិត្យនូវព័ត៌មានស្តីពីថាតើតុលាការ អាចផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ដើម្បីការពារជនរងគ្រោះ ដោយអនុលោមទៅតាមច្បាប់ជាតិ ដែរឬអត់ ។ បញ្ជីឈ្មោះជនរងគ្រោះដែលត្រូវបានផ្តល់ជំនួយក្រោមជំនួយផ្នែកច្បាប់ គួរតែត្រូវបានផ្តល់ រួមជាមួយនឹងទម្រង់ពាក្យសុំជំនួយ ។
- អង្គការមូលនិធិ មិនផ្តល់សំណងផ្នែកហិរញ្ញវត្ថុដល់ជនរងគ្រោះទេ ។

## ជំនួយសង្គ្រោះបន្ទាន់

តួអង្គសង្គមស៊ីវិល អាចដាក់ជូនពិនិត្យដោយឡែកនូវសំណើសុំជំនួយសង្គ្រោះបន្ទាន់ នៅចន្លោះវគ្គប្រជុំពេញអង្គពីរ របស់ក្រុមប្រឹក្សាសម្រាប់គម្រោងដែលត្រូវបានផ្តល់ឧបត្ថម្ភធនបដិភាគបច្ចុប្បន្ន ដោយអង្គការមូលនិធិ ដែលជួបប្រទះនឹងការលំបាកផ្នែកហិរញ្ញវត្ថុ ។ តួអង្គសង្គមស៊ីវិល គួរតែធ្វើចេញនូវសំណើសុំរបស់ខ្លួនសម្រាប់មូលនិធិជំនួយសង្គ្រោះបន្ទាន់ជាទម្រង់ពាក្យសុំជំនួយរបស់លេខាធិការដ្ឋាន ក៏ដូចជាលិខិតពិស្តារដែលពន្យល់អំពីមូលហេតុដែលគេត្រូវការជំនួយផ្នែកហិរញ្ញវត្ថុសង្គ្រោះបន្ទាន់នេះ ។ ពាក្យសុំជំនួយនឹងត្រូវបានចាត់ទុកថាអាចទទួលយកបាន តែក្នុងករណីដែលស្ថានភាពដែលមិនអាចព្យាករណ៍បាន បានចេញជាលទ្ធផល ក្នុងការកើនឡើងភ្លាមៗនូវចំនួនជនរងគ្រោះដែលត្រូវបានផ្តល់ជំនួយ (ឧទាហរណ៍ដូចជាលទ្ធផលនៃការមកដល់ដោយគំហុកនៃជនរងគ្រោះដោយការធ្វើទារុណកម្ម ដោយសារតែវិបត្តិមនុស្សធម៌) ។

### *i* របៀបដាក់ជូនពិនិត្យនូវពាក្យសុំជំនួយទៅអង្គការមូលនិធិ

ជាទូទៅ ពាក្យសុំជំនួយគួរតែត្រូវបានរៀបចំឡើង តាមរយៈប្រព័ន្ធគ្រប់គ្រងជំនួយជាទម្រង់អេឡិចត្រូនិច ។ ដោយឡែក ពាក្យសុំជំនួយអាចត្រូវបានធ្វើចេញជាទម្រង់ក្រដាស ដែលត្រូវបានផ្ញើតាមអាកាសយាន ឬ អ៊ីម៉ែល ។ ទម្រង់ពាក្យសុំជំនួយ ត្រូវបានរៀបចំឲ្យមាន នៅពេលមានការស្នើសុំពីលេខាធិការដ្ឋាន ។

### ទីកន្លែងដែលត្រូវដាក់ជូនពិនិត្យពាក្យសុំជំនួយ

**មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះ ដោយការធ្វើទារុណកម្ម**
**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩១៧ ៩៣ ១៥

ទូរសារលេខៈ +៤១ (0)២២ ៩១៧ ៩០ ១៧
អ៊ីម៉ែលៈ unvfvt@ohchr.org

**នៅពេលដាក់ជូនពិនិត្យពាក្យសុំជំនួយ សូមកត់សម្គាល់ៈ**

- លេខាធិការដ្ឋានរបស់អង្គការមូលនិធិ នឹងមិនទទួលយកពាក្យសុំជំនួយដែលមិនប្រើប្រាស់ទម្រង់ពាក្យសុំជំនួយរបស់អង្គការមូលនិធិ មិនផ្តល់ព័ត៌មានទាំងអស់ដែលត្រូវបានស្នើសុំ មិនត្រូវបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយអ្នកដឹកនាំគម្រោង ឬ ដោយរបៀបណាមួយ មិនអនុលោមទៅតាមគោលការណ៍ណែនាំរបស់អង្គការមូលនិធិ ។
- ពាក្យសុំជំនួយ អាចត្រូវបានសរសេរជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ។

**សម្រាប់ព័ត៌មានបន្ថែម ស្តីពីមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះ ដោយការធ្វើទារុណកម្ម** ចូរចូលមើលវ៉ិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ២. មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច

**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច** ព្យាយាមសម្របសម្រួលឲ្យមានការចូលរួមរបស់តំណាងនៃសហគមន៍ និងអង្គការជនជាតិដើមភាគតិច នៅក្នុងអង្គពីររបស់អង្គការសហប្រជាជាតិដែលធ្វើការងារខាងសិទ្ធិជនជាតិដើមភាគតិចៈ

- **យន្តការមន្ត្រីជំនាញទទួលបន្ទុកសិទ្ធិរបស់ជនជាតិដើមភាគតិច** និង
- **វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច** ។

យន្តការមន្ត្រីជំនាញទទួលបន្ទុកសិទ្ធិរបស់ជនជាតិដើមភាគតិច គឺជាយន្តការថ្មីរបស់**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**[77] ដែលជំនួស**ក្រុមការងារទទួលបន្ទុកជនជាតិដើមភាគតិច**នៃអតីតអនុគណៈកម្មការទទួលបន្ទុកការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្ស ។

> *i* សម្រាប់ព័ត៌មានបន្ថែមស្តីពីយន្តការមន្ត្រីជំនាញ សូមមើល**ជំពូក V (ក្រុមប្រឹក្សាសិទ្ធិមនុស្ស)** នៃ*សៀវភៅ*នេះ ។

វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច ដែលជាអង្គផ្តល់ប្រឹក្សារបស់**ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច**នៃអង្គការសហប្រជាជាតិ គឺជាអង្គកម្រិតខ្ពស់ ដែលមានមូលដ្ឋាននៅក្នុងទីក្រុងញូវយ៉ក ដែលរួមចំណែកដល់កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារលើបញ្ហាជនជាតិដើមភាគតិច ។ មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច ដែលត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តល់**ជំនួយសម្រាប់ការធ្វើដំណើរ**ដល់តំណាងរបស់ជនជាតិដើមភាគតិច និងអង្គការដែលធ្វើការងារជាមួយនឹងពួកគេ ដើម្បីចូលរួមនៅក្នុងអង្គទាំងនេះ ។ តាមរបៀបនេះ តួអង្គសង្គមស៊ីវិលនៃជនជាតិដើមភាគតិច អាចរួមចំណែកជំនាញរបស់ខ្លួន និងយកមកប្រទេសខ្លួនវិញនូវមេរៀនបទពិសោធន៍ ។

មូលនិធិនេះ ត្រូវបានគ្រប់គ្រងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយអនុលោមទៅតាមច្បាប់ និងវិធានហិរញ្ញវត្ថុរបស់អង្គការសហប្រជាជាតិ ដោយទទួលបានការណែនាំពីក្រុមប្រឹក្សាអ្នកទទួលគ្រប់គ្រង ដែលសមាជិកទាំងអស់របស់ក្រុមប្រឹក្សាអ្នកទទួលគ្រប់គ្រងនេះ មានបទពិសោធន៍ខាងបញ្ហាជនជាតិដើមភាគតិច ។

[77] ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចចិត្តលេខ 6/36 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ។

## វិធីប្រើប្រាស់មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច[78]

ការរួមចំណែក និងការចូលរួមដ៏សកម្មរបស់តួអង្គសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន ជាតិ និងអន្តរជាតិ បានជួយយ៉ាងច្រើន ក្នុងការធ្វើឲ្យចម្រើនជឿនលឿនទៅមុខ លើបញ្ហាជនជាតិដើមភាគតិចនៅលើពិភពលោក ។ ស្ថាប័នរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជនជាតិដើមភាគតិច ជាឧបករណ៍សកម្មភាពដ៏សំខាន់សម្រាប់តួអង្គសង្គមស៊ីវិលដែលធ្វើការងារជាមួយនឹងជនជាតិដើមភាគតិច និងដើម្បីក្រុមសង្គមស៊ីវិលនៃជនជាតិដើមភាគតិចខ្លួនឯង ។ ជំនួយសម្រាប់ការធ្វើដំណើររបស់មូលនិធិនេះ មានគោលបំណងបង្កើនចំនួន និងនានាភាពនៃជនជាតិដើមភាគតិចនៅក្នុងអង្គទាំងនេះ ។

## នរណា មានសិទ្ធិទទួលជំនួយ ?

តំណាងជនជាតិដើមភាគតិចនៃអង្គការ និងសហគមន៍របស់ជនជាតិដើមភាគតិចៈ

- ដែលបើមិនដូច្នោះទេ នឹងមិនអាចចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់យន្តការមន្ត្រីជំនាញ ឬ វេទិកាអចិន្ត្រៃយ៍ទេ និង
- ដែលអាចរួមចំណែកដល់ចំណេះដឹងដ៏ជ្រាលជ្រៅ ដែលត្រូវបានអនុវត្តដោយយន្តការមន្ត្រីជំនាញ ឬ វេទិកាអចិន្ត្រៃយ៍ ទាក់ទងនឹងបញ្ហាដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងក៏នឹងធានាដល់តំណាងតាមភូមិសាស្ត្រដ៏ទូលំទូលាយផងដែរ ។

## លក្ខខណ្ឌនៃការដាក់ពាក្យសុំជំនួយ

- ជំនួយសម្រាប់ការធ្វើដំណើរត្រូវបានផ្តល់ជូនទៅតាមបុគ្គល ពោលគឺ អង្គការ ឬ ក្រុមអ្នកទទួលផលមិនអាចស្នើសុំថាជាក្រុមអ្នកទទួលផលគួរតែត្រូវបានជំនួសដោយម្នាក់ទៀតទេ ។
- ពាក្យសុំជំនួយរបស់បុគ្គលត្រូវតែបានអមដោយលិខិតបញ្ជាក់លក្ខណសម្បត្តិ ដែលត្រូវបានចុះហត្ថលេខាដោយអ្នកប្រតិបត្តិរបស់អង្គការជនជាតិដើមភាគតិចរបស់ពួកគេ ។ ក្រុមប្រឹក្សា នឹងមិនត្រួតពិនិត្យលើលិខិតដែលត្រូវបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំជំនួយខ្លួនឯងនោះទេ ។
- ក្នុងអង្គការមួយ អ្នកដាក់ពាក្យសុំជំនួយជាអតិបរមា អាចមានពីរនាក់ ។
- អ្នកដាក់ពាក្យសុំជំនួយ ត្រូវបានស្នើសុំឲ្យដាក់ជូនពិនិត្យនូវពាក្យសុំជំនួយ និងលិខិតបញ្ជាក់លក្ខណសម្បត្តិជាភាសាការងាររបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សា (ភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ) ។
- អ្នកដាក់ពាក្យសុំជំនួយ ត្រូវបានស្នើសុំឲ្យបង្ហាញអំពីការទទួលខុសត្រូវរបស់ពួកគេនៅក្នុងអង្គការ ឬ សហគមន៍របស់ពួកគេ ។

[78] រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពឯកជន ឬ សាធារណៈផ្សេងទៀត អាចរួមវិភាគទានដល់អង្គការមូលនិធិបាន ។ សម្រាប់ព័ត៌មានស្តីពីរបៀបរួមវិភាគទាន សូមទាក់ទងនឹងលេខាធិការដ្ឋានរបស់អង្គការមូលនិធិនោះ ។

- អនុសាសន៍របស់ក្រុមប្រឹក្សាដែលជាប្រយោជន៍ដល់អ្នកដាក់ពាក្យសុំជំនួយ ដើម្បីចូលរួមក្នុងវគ្គប្រជុំពេញអង្គរបស់វេទិកាអចិន្ត្រៃយ៍ មិនត្រូវមិនដាក់បញ្ចូលអនុសាសន៍មួយទៀត ដើម្បីចូលរួមក្នុងយន្តការមន្ត្រីជំនាញឡើយ និងច្រាសមកវិញ ។

## i ទីកន្លែងដែលត្រូវដាក់ពាក្យសុំជំនួយ

ទម្រង់ពាក្យសុំជំនួយ ត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងត្រូវបានដាក់ជូនពិនិត្យនៅត្រឹម**ថ្ងៃទី ១ ខែ តុលា រៀងរាល់ឆ្នាំ** ទៅកាន់:

**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនជាតិដើមភាគតិច**
**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខៈ +៤១ (0)២២ ៩២៨ ៩១ ៦៤ ឬ +៤១ (0)២២ ៩២៨ ៩១ ៤២
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩0 ៦៦
**អ៊ីម៉ែលៈ IndigenousFunds@ohchr.org**

**ដើម្បីរកបានព័ត៌មានបន្ថែមស្តីពីការងាររបស់ជនជាតិដើមភាគតិចរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)** ចូរចូលមើលវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ៣. មូលនិធិទំនុកចិត្តស្ម័គ្រចិត្ត នៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព

**មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព** ផ្តល់ **ជំនួយគម្រោង**ខ្នាតតូច ជាពិសេស ដល់អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ និងយុវជន សហជីព ឬ សមាគមអ្នកវិជ្ជាជីវៈ ដែលជួយដល់ជនរងគ្រោះដោយទម្រង់សហកាលនៃទាសភាព (ឧទាហរណ៍ដូចជា: ពលកម្មកុមារ ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ) ។ គោលបំណងនៃជំនួយសម្រាប់គម្រោង គឺដើម្បីពង្រីក តាមរយៈបណ្តាញជំនួយដែលបានបង្កើតឡើង នូវជំនួយមនុស្សធម៌ ផ្នែកច្បាប់ និងហិរញ្ញវត្ថុ ដល់បុគ្គលដែលសិទ្ធិមនុស្សរបស់ពួកគេ ត្រូវបានរំលោភបំពានដោយធ្ងន់ធ្ងរជាលទ្ធផលនៃទម្រង់សហកាលនៃទាសភាព ។ មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព ផ្តល់នូវឱកាសដល់តួអង្គសង្គមស៊ីវិល ជារឿយៗ ដែលធ្វើការងារនៅកម្រិតមហាជន ដើម្បីជួយដល់ជនរងគ្រោះមួយចំនួនធំដោយផ្ទាល់ ដោយប្រើប្រាស់មូលនិធិតិចតួចល្មម ។

### វិធីប្រើប្រាស់មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព

សព្វថ្ងៃនេះ តួអង្គសង្គមស៊ីវិលជាច្រើន កំពុងតែប្រយុទ្ធ និងការពារជនរងគ្រោះដោយទម្រង់សហកាលនៃទាសភាព នៅតាមផ្នែកផ្សេងៗនៃពិភពលោក ។ ជារឿយៗ ការអនុវត្តដូចទាសភាព មានលក្ខណៈលបលាក់ផ្ទុយនឹងច្បាប់ និងតួអង្គសង្គមស៊ីវិល អាចមានតួនាទីសំខាន់ណាស់នៅក្នុងការបង្ហាញអំពីការរំលោភបំពានលើសិទ្ធិមនុស្សដែលត្រូវបានលាក់បំបាំង ដែលត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងទម្រង់សហកាលនៃទាសភាព ។ សព្វថ្ងៃនេះ ពាក្យ "ទាសភាព" រួមបញ្ចូល ការរំលោភបំពានលើសិទ្ធិមនុស្សជាច្រើនប្រភេទ ។ ដោយរួមទាំងទាសភាពជាប្រពៃណី និងពាណិជ្ជកម្មទាសភាព ការបំពារបំពានទាំងនេះ រួមបញ្ចូល ការលក់ដូរកុមារ ពេស្យាចារកុមារ រូបអាសអាភាសកុមារ ការកេងប្រវ័ញ្ចពលកម្មកុមារ ការធ្វើកាយវិកលកម្មផ្លូវភេទលើក្មេងស្រី ការប្រើប្រាស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ សេរភាពបំណុល ការជួញដូរមនុស្ស និងការលក់សរីរាង្គមនុស្ស ការធ្វើអាជីវកម្មពេស្យាចារ និងការអនុវត្តខ្លះនៅក្រោមការប្រកាន់ពូជសាសន៍ និងរបបអាណានិគម ។

**ជំនួយសម្រាប់គម្រោង** ជាពិសេស សម្រាប់អង្គការសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ និងយុវជន សហជីព ឬ សមាគមអ្នកវិជ្ជាជីវៈ មានគោលបំណងបង្កើនការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងការលុបបំបាត់ទាសភាព នៅជុំវិញពិភពលោក ។

## នរណា មានសិទ្ធិទទួលជំនួយ ?

- អង្គការដែលផ្តល់ជំនួយផ្ទាល់ ដល់បុគ្គលដែលសិទ្ធិមនុស្សរបស់ពួកគេ ត្រូវបានរំលោភបំពានជាលទ្ធផលនៃទម្រង់សហកាលនៃទាសភាព ។ ជំនួយផ្ទាល់នេះ មានជំនួយភាគច្រើនដែលត្រូវបានប្រគល់ជូន ។ មូលនិធិ ត្រូវបានប្រគល់ឲ្យទៅអ្នកទទួល តាមរយៈអង្គការសង្គមស៊ីវិល ឬ បណ្តាញមហាជនដែលត្រូវបានអនុម័ត និងបង្កើតឡើង ដែលផ្តល់ជំនួយមនុស្សធម៌ សេវាជំនួយផ្នែកច្បាប់ និងជំនួយហិរញ្ញវត្ថុ ដល់ជនរងគ្រោះ ។
- អង្គការដែលផ្តល់ជំនួយផ្ទាល់ដល់ជនរងគ្រោះ តាមរយៈ វិធានការទប់ស្កាត់ និងការបណ្តុះបណ្តាល ។ គម្រោងភាគច្រើន ដែលត្រូវបានជ្រើសរើស ជាប់ទាក់ទងនឹងកម្មវិធីស្តារនីតិសម្បទា និងអប់រំ ដើម្បីជួយដល់ជនរងគ្រោះឲ្យទៅជាអាចបំពេញសេចក្តីត្រូវការខ្លួនឯងបាន និងមានភាពងាយរងគ្រោះកាន់តែតិចទៅនឹងការកេងប្រវ័ញ្ច ។

## លក្ខខណ្ឌនៃការដាក់ពាក្យសុំជំនួយ

- ទម្រង់ពាក្យសុំជំនួយជាច្បាប់ដើម ដែលជាបណ្តាញអេឡិចត្រូនិចដែលត្រូវបានរៀបចំឲ្យមាន ត្រូវតែបានដាក់ជូនពិនិត្យ តាមរយៈការផ្ញើតាមអាកាសយាន និងគួរតែត្រូវបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទ ។ ពាក្យសុំជំនួយ អាចត្រូវបានដាក់ជូនពិនិត្យជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ។
- អង្គការមួយ អាចស្នើសុំបានជាអតិបរមា ១៥.០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងជំនួយមួយ ពីអង្គការមូលនិធិ ។
- គម្រោង នឹងត្រូវបានជ្រើសរើសពីគ្រប់តំបន់ភូមិសាស្ត្រទាំងអស់ ដើម្បីផ្តល់នូវទិដ្ឋភាពដែលអាចមានធំទូលាយបំផុតនៃទម្រង់សហកាលនៃទាសភាពនៅក្នុងពិភពលោក ។
- គម្រោង គួរតែពិចារណាទៅលើតុល្យភាពយេនឌ័រ ។
- ជំនួយសម្រាប់គម្រោង គួរតែត្រូវបានធ្វើវិភាជន៍សម្រាប់ជំនួយផ្ទាល់ដល់ជនរងគ្រោះ និងអង្គការសង្គមស៊ីវិលនៅក្នុងមូលដ្ឋាន ។ ជំនួយ អាចត្រូវបានបញ្ជូន តាមរយៈ អង្គការមិនមែនរដ្ឋាភិបាលឲ្យតែអង្គការមិនមែនរដ្ឋាភិបាលនោះ មិនរក្សាផ្នែកណាមួយនៃជំនួយសម្រាប់សកម្មភាពរបស់ខ្លួន ។
- ក្រុមប្រឹក្សានេះ នឹងមិនពិចារណាលើពាក្យសុំជំនួយដែលលេខាធិការដ្ឋាន មិនបានទទួល តាមការស្នើសុំរបស់ខ្លួននូវព័ត៌មានដែលគួរឲ្យពេញចិត្តបន្ថែមសម្រាប់ពាក្យសុំជំនួយនោះ បន្ទាប់ពីលិខិតរំឭកលើកទីពីរនោះទេ ។

## គម្រោងដែលទទួលប្រយោជន៍ពីមូលនិធិធំនុកចិត្តស្ម័គ្រចិត្តប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព

**គម្រោងម៉ាហ៊ីឡាសេវ៉ាសាមីធី ប្រទេសឥណ្ឌា:** នៅក្នុងឆ្នាំ ២០០៥ ជំនួយដែលមានតម្លៃជាទឹកប្រាក់ចំនួន ២.០០០ ដុល្លារសហរដ្ឋអាមេរិក បានជួយដល់ជនរងគ្រោះដោយពលកម្មកុមារចំនួន ៨៨ នាក់ ដើម្បីបញ្ចូលទៅក្នុងសាលាដំបូង និងបឋមសិក្សា និងបានផ្តត់ផ្គង់សម្ភារៈសិក្សា ។ គម្រោង បានធានាឲ្យមានការវាយតម្លៃបន្តរៀងរាល់បួនខែម្តង ដើម្បីតាមដានវឌ្ឍភាពរបស់កុមារ ។

**គម្រោងចាដាគ្រីស ប្រទេសនីសេរីយ៉ា:** នៅក្នុងឆ្នាំ ២០០៦ ជនរងគ្រោះដោយការជួញដូរមនុស្សចំនួន ៣០ នាក់ បានទទួលជំនួយគាំទ្រដែលមានតម្លៃជាទឹកប្រាក់ចំនួន ៦.៤០០ ដុល្លារសហរដ្ឋអាមេរិកសម្រាប់ការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលឡើងវិញ ដើម្បីជួយពួកគេឲ្យអាចប្រកបរបរចិញ្ចឹមជីវិតបាន ។

## *i* ទីកន្លែងដែលត្រូវដាក់ពាក្យសុំជំនួយ

ទម្រង់ពាក្យសុំជំនួយ គួរតែត្រូវបានដាក់ជូនពិនិត្យនៅត្រឹម**ថ្ងៃទី ១៥ ខែ កញ្ញា រៀងរាល់ឆ្នាំ** ទៅកាន់:


**មូលនិធិធំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព**
**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរស័ព្ទលេខ: +៤១ (0)២២ ៩២៨ ៩៣ ៨១ ឬ +៤១ (0)២២ ៩២៨ ៩១ ៦៤
ទូរសារលេខ: +៤១ (0)២២ ៩២៨ ៩0 ៦៦
**អ៊ីម៉ែល:** **SlaveryFunds@ohchr.org**


**អ្នកដាក់ពាក្យសុំជំនួយ គួរតែដាក់ជូនពិនិត្យនូវទម្រង់ពាក្យសុំជំនួយដែលត្រូវបានបំពេញដោយពេញលេញ ដែលត្រូវបានរៀបចំឲ្យមាននៅក្នុងវិបសាយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។**

*i* សម្រាប់ព័ត៌មានបន្ថែម ក៏សូមមើលផងដែរនូវប័ណ្ណផ្សព្វផ្សាយអំពី**មូលនិធិទំនុកចិត្តស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិប្រឆាំងនឹងទម្រង់សហកាលនៃទាសភាព** ។

## ៤. គម្រោង "ជួយសហគមន៍រួម" (ACT)

នៅក្នុងឆ្នាំ ១៩៩៨ ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស (OHCHR) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានបង្កើតឡើងនូវគម្រោង **"ជួយសហគមន៍រួម"** (**ACT**) ដែលផ្តល់ជំនួយខ្នាតតូចដល់តួអង្គសង្គមស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាល សមាគមនៅមូលដ្ឋាន គ្រឹះស្ថានអប់រំ និងក្រុមអ្នកវិជ្ជាជីវៈ ដែលអនុវត្ត**សកម្មភាពអប់រំ និងបណ្តុះបណ្តាលសិទ្ធិមនុស្សនៅក្នុងសហគមន៍នៅមូលដ្ឋាន** ។ នៅក្នុងអំឡុងពេលមួយឆ្នាំពេញ គម្រោង "ជួយសហគមន៍រួម" (**ACT**) នេះបានផ្តោតការយកចិត្តទុកដាក់ទៅលើ សកម្មភាពគាំទ្រនៅក្នុងបរិបទនៃទសវត្សរ៍ដើម្បីការអប់រំសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ (ពីឆ្នាំ ១៩៩៥-២០០៤) និងកម្មវិធីពិភពលោកដើម្បីការអប់រំសិទ្ធិមនុស្ស (ពីឆ្នាំ ២០០៥-បច្ចុប្បន្ន) ។ ចាប់តាំងតែពីឆ្នាំ ១៩៩៨ មក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានគាំទ្រដល់គម្រោងចំនួនជាង ៨០០ នៅក្នុងប្រទេសចំនួន ៧៣ ។

ការគ្រប់គ្រងរដ្ឋបាលរួមលើគម្រោងជួយសហគមន៍រួមនេះ ត្រូវបានសម្របសម្រួលដោយទីស្នាក់ការធំ របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។ នៅក្នុងប្រទេសចូលរួមនីមួយៗ "ក្រុមការងារពិសេសគម្រោងជួយសហគមន៍រួម" ដែលមានសមាសភាពបុគ្គលិករបស់ការិយាល័យប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងអ្នកមានវត្តមាននៅមូលដ្ឋាននៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) (នៅពេលដែលអាចអនុវត្តបាន) ក៏ដូចជា អង្គភាពផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ផ្សព្វផ្សាយទម្រង់ពាក្យសុំជំនួយ ជ្រើសរើសសកម្មភាពដែលត្រូវបានផ្តល់ជំនួយ និងទទួលខុសត្រូវចំពោះការពិនិត្យតាមដានលើការអនុវត្តសកម្មភាពតាមរយៈទំនាក់ទំនងផ្ទាល់ជាមួយនឹងអ្នកទទួលជំនួយ ។

គម្រោងជួយសហគមន៍រួម អនុវត្តយុទ្ធវិធីពីក្រោមឡើងលើ ដោយជំរុញលើកទឹកចិត្តឲ្យមានវិធានការនៅកម្រិតសហគមន៍ ក្នុងបំណងធ្វើឲ្យប្រសើរឡើងនូវការគោរពសិទ្ធិមនុស្សដោយជាក់ស្តែង ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌជាក់លាក់របស់មនុស្ស ។ ជាគោលការណ៍ គម្រោងជួយសហគមន៍រួម ចាត់ទុកជាគោលបំណងនូវការពង្រឹងសមត្ថភាពនៅមូលដ្ឋានសម្រាប់ការអប់រំសិទ្ធិមនុស្ស ការបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ។ ឧទាហរណ៍ៈ គម្រោងជួយសហគមន៍រួម បានផ្តល់មូលនិធិដល់ៈ

- សិក្ខាសាលាពិភាក្សា និងវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមផ្សេងៗ ក្នុងនោះរួមមាន គ្រូបង្រៀន ស្ត្រី បុគ្គលិកសង្គមកិច្ច មន្ត្រីសាធារណៈ និងជនជាតិដើមភាគតិច ។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស រួមជាមួយនឹងព្រឹត្តិការណ៍វប្បធម៌ ដូចជា ការសម្តែងនាដកថា ការតាំងពិព័ណ៌សិល្បៈ និងការប្រគុំដន្ត្រីសម័យ ។
- ការផលិត/ការបកប្រែភាសានូវឯកសារសិទ្ធិមនុស្ស និងការផ្សព្វផ្សាយឯកសារទាំងនេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។
- ការបង្កើតមជ្ឈមណ្ឌលព័ត៌មានសម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ។

- កម្មវិធីអប់រំសម្រាប់ក្រុមងាយរងគ្រោះជាក់លាក់ ដូចជា អ្នកជាប់ពន្ធនាគារ អ្នករកស៊ីផ្លូវភេទ បុគ្គលផ្ទុកមេរោគអេដស៍ កុមារកំព្រា ជនភៀសសឹកនៅក្នុងប្រទេស និង
- សកម្មភាពអប់រំសិទ្ធិមនុស្សសម្រាប់កុមារ និងយុវជន ដូចជា ការប្រកួតប្រជែងនៅតាមសាលារៀន និងការបង្កើតក្លឹបយុវជនសិទ្ធិមនុស្ស ។

## វិធីប្រើប្រាស់គម្រោងជួយសហគមន៍រួម

គម្រោងជួយសហគមន៍រួម ផ្តល់ជំនួយហិរញ្ញវត្ថុដល់តួអង្គសង្គមស៊ីវិលនៅក្នុងស្រទាប់មហាជន ជាពិសេសអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន គ្រឹះស្ថានអប់រំ ក្រុមអ្នកវិជ្ជាជីវៈ ប្រព័ន្ធផ្សព្វផ្សាយនៅមូលដ្ឋាន និងអង្គការរបស់ស្ត្រី ដែលអនុវត្តសកម្មភាពអប់រំសិទ្ធិមនុស្ស ។

## លក្ខខណ្ឌនៃការដាក់ពាក្យសុំជំនួយ

- អ្នកដាក់ពាក្យសុំជំនួយ ត្រូវតែជាអង្គការសង្គមស៊ីវិល ឬ សមាគមដែលមានសមត្ថភាពស្ថាប័នក្នុងការអនុវត្តគម្រោង ដែលគេនឹងស្នើឡើង ។
- គម្រោងដែលបានស្នើឡើង គួរតែមានលក្ខណៈច្នៃបង្កើតថ្មី អាចអនុវត្តឡើងវិញបាន និងត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឥទ្ធិពលប្រកបដោយចីរភាពជាអតិបរមានៅមូលដ្ឋាន ។
- គម្រោងនានា គួរតែមានរយៈពេលមិនលើសពីប្រាំមួយខែ និងមានថវិកាអតិបរមា ៥.០០០ ដុល្លារសហរដ្ឋអាមេរិក ។
- ពាក្យសុំជំនួយ ត្រូវបានចែកចាយ និងប្រមូលដោយអ្នកដែលបម្រើជាមណ្ឌលសកម្មភាពថ្នាក់ជាតិរបស់អង្គការសហប្រជាជាតិសម្រាប់គម្រោងជួយសហគមន៍រួម នៅក្នុងប្រទេសដែលចូលរួម នៅក្នុងរយៈពេលកំណត់ទទួលពាក្យសុំ ដែលត្រូវបានកំណត់នៅថ្នាក់ជាតិ ។ អនុប្បទានិក រៀបចំកិច្ចព្រមព្រៀងជំនួយជាមួយនឹងការិយាល័យប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ឬ ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។
- ពាក្យសុំជំនួយ និងរបាយការណ៍គម្រោង អាចត្រូវបានដាក់ជូនពិនិត្យជាភាសាអង់គ្លេស បារាំង ឬ អេស្ប៉ាញ ។

## ឧទាហរណ៍ស្ដីពីមូលនិធិជំនួយនៃគម្រោងជួយសហគមន៍រួម

**នៅក្នុងប្រទេសម៉ាដាហ្គាស្ការ** គម្រោងជួយសហគមន៍រួម បានគាំទ្រដល់កិច្ចផ្ដួចផ្ដើម ដែលបានផ្ដោតការយកចិត្តទុកដាក់ទៅលើសិទ្ធិរបស់កុមារពិការ ដែលបានដាក់បញ្ចូលល្ខោនស្បែកធំ និងការរៀបចំ និងចែកចាយសៀវភៅក្បួនដែលទាក់ទង ។ គម្រោង បានទៅដល់កូនសិស្សចំនួនជាង ៦.០០០ នាក់នៅក្នុងសាលារៀនចំនួន ១៤ កន្លែង ។ នាយកសាលាបានផ្ដល់អនុសាសន៍ថា ព្រឹត្តិការណ៍នេះ គួរ តែត្រូវបានរៀបចំឡើងវិញនៅដើមឆ្នាំសិក្សានីមួយៗ ។

**វេទិកាប្រព័ន្ធផ្សព្វផ្សាយស្ត្រីភាគខាងត្បូង** នៅក្នុងទីក្រុង វ៉ាហ្វាហ៍ នៃតំបន់ ហ្គាហ្សាស្ទ្រីប ភាគខាងត្បូង ទឹកដី ប៉ាឡេស្ទីន ដែលបានគ្រប់គ្រង ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥ សម្រាប់ស្ត្រីវ័យក្មេង ជាពិសេស អ្នកដែលធ្វើការងារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ។ ស្ថាបនិកបានជឿជាក់ថា វាមានលក្ខណៈសំខាន់ត្រូវផ្ដល់វេទិកាដល់ស្ត្រីជាបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយដែលយល់ថា វាមានការលំបាកជាងសមភាគីភេទប្រុសរបស់ពួកគេ ក្នុងការជួបប្រជុំបង្កើតបណ្ដាញ និងចែករំលែក មតិយោបល់អំពីការងាររបស់ពួកគេ និងដោយទទួលស្គាល់ថា សិទ្ធិរបស់ស្ត្រី មិនត្រូវបានដោះស្រាយដោយពេញលេញដោយប្រព័ន្ធផ្សព្វផ្សាយ ។ គម្រោងជួយសហគមន៍រួម បានជួយគាំទ្រដល់ការបណ្ដុះបណ្ដាលសិទ្ធិមនុស្ស ដោយផ្ដោតការយកចិត្តទុកដាក់ទៅ លើសិទ្ធិរបស់ស្ត្រី សម្រាប់ស្ត្រីជាអ្នកសារព័ត៌មានចំនួន ១៥ រូប មកពីតំបន់ហ្គាហ្សាស្ទ្រីប ភាគខាងត្បូង ការផលិតទស្សនាវដ្ដីឯកទេសលេខទីមួយសម្រាប់ស្ត្រីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលបានផ្ដោតការយកចិត្តទុកដាក់ទៅលើសិទ្ធិមនុស្ស និងសិក្ខាសាលាពិភាក្សាចំនួនប្រាំសម្រាប់ស្ត្រី មកពីតំបន់ខុសៗគ្នានៅក្នុងតំបន់ហ្គាហ្សាស្ទ្រីប ភាគខាងត្បូង ។

## i របៀបទាក់ទងនឹងគម្រោងជួយសហគមន៍រួម


**គម្រោងជួយសហគមន៍រួម**
**ការិយាល័យ ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
វិមានជាតិ
8-14, avenue de la Paix
CH- 1211 Geneva 10 - ប្រទេសស្វីស
ទូរសារលេខៈ +៤១ (0)២២ ៩២៨ ៩0 ៦១
**អ៊ីម៉ែលៈ** **ACTProject@ohchr.org**


សម្រាប់ព័ត៌មានបន្ថែមស្ដីពីគម្រោងជួយសហគមន៍រួម ចូរចូល*មើលប័ណ្ណផ្សព្វផ្សាយអំពីគម្រោងជួយសហគមន៍រួម ដែលជួយសហគមន៍រួមគ្នា* សម្រាប់ដំណាក់កាល I និង II នៃគម្រោងនេះ នៅក្នុងវ៉ិបសាយរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ។

## ៥. មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ

**មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ** (UNDEF) ត្រូវបានបង្កើតឡើងនៅក្នុងខែ កក្កដា ឆ្នាំ ២០០៥ ជាលទ្ធផលនៃកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០០៥ ។[79] គោលបំណងបឋមរបស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ គឺដើម្បីគាំទ្រដល់ប្រជាធិបតេយ្យូបនីយកម្មនៅទូទាំងពិភពលោក ដោយផ្តល់ជំនួយដល់អង្គការរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អង្គការតំបន់ និងអង្គការអន្តរជាតិ ក្នុងនោះរួមមាន ផ្នែកការិយាល័យ មូលនិធិ កម្មវិធី និងទីភ្នាក់ងារដែលពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិផងដែរ ។ មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ ធ្វើហិរញ្ញប្បទានដល់គម្រោងដែលបង្កើត និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ លើកកម្ពស់សិទ្ធិមនុស្ស និងធានាឲ្យមានការចូលរួមរបស់ក្រុមទាំងអស់នៅក្នុងដំណើរការប្រជាធិបតេយ្យ ។ សកម្មភាពដែលមានលក្ខណៈគ្រប់គ្រាន់ រួមមានៈ

- កិច្ចសន្ទនាប្រជាធិបតេយ្យ និងការគាំទ្រឲ្យមានដំណើរការរដ្ឋធម្មនុញ្ញ ។
- ការផ្តល់សិទ្ធិអំណាចដល់សង្គមស៊ីវិល ។
- ការអប់រំពលរដ្ឋ ការចុះឈ្មោះអ្នកបោះឆ្នោត និងការពង្រឹងគណបក្សនយោបាយ ។
- លទ្ធភាពទទួលបានព័ត៌មានរបស់ពលរដ្ឋ ។
- សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និង
- គណនេយ្យ តម្លាភាព និងភាពសុចរិត ។

មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ ត្រូវបានគ្រប់គ្រងដោយ**ការិយាល័យទទួលបន្ទុកភាពជាដៃគូនៃអង្គការសហប្រជាជាតិ** នៅឯទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិ នៅក្នុងទីក្រុងញូវយ៉ក ។ ក្រុមប្រឹក្សាផ្តល់ប្រឹក្សាដែលមានសមាជិកចំនួន ១៩ រូប ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការណែនាំផ្នែកគោលនយោបាយ និងដើម្បីផ្តល់អនុសាសន៍លើសំណើសុំមូលនិធិជំនួយសម្រាប់ការអនុម័តដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ក្រុមប្រឹក្សាផ្តល់ប្រឹក្សា មានរដ្ឋជាសមាជិក តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងតំណាងផ្ទាល់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅក្នុងជុំទីមួយនៃការជ្រើសរើសគម្រោង និងការធ្វើវិភាជន៍មូលនិធិនៅក្នុងឆ្នាំ ២០០៦ អគ្គលេខាធិការអង្គការសហប្រជាជាតិនៅពេលនោះ គឺលោក កូហ្វីអាណាន់ បានអនុម័តលើគម្រោងចំនួន ១២៥ ដែលមានតម្លៃជាទឹកប្រាក់ចំនួន ៣៦ លានដុល្លារ សហរដ្ឋអាមេរិក ដោយរួមបញ្ចូលតំបន់ទាំងអស់ ។

### វិធីប្រើប្រាស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ

មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ អាចទទួលពាក្យសុំជំនួយសម្រាប់មូលនិធិជំនួយសម្រាប់គម្រោងរបស់តួអង្គប្រជាធិបតេយ្យ និងអភិបាលកិច្ចមួយចំនួនធំ ក្នុងនោះរួមមាន ស្ថាប័នជាតិទទួលបន្ទុកសិទ្ធិមនុស្ស (NHRI) ផងដែរ ប៉ុន្តែដោយមានការផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើអង្គការសង្គម

[79] ចូរមើលសេចក្តីសម្រេចលេខ 60/1 របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០០៥ ។

ស៊ីវិល ដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងគោលនយោបាយ និងសមាគមអ្នកវិជ្ជាជីវៈ ។

លក្ខខណ្ឌខ្លះដែលគម្រោងក្រោមមូលនិធិរបស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ ត្រូវតែបំពេញ គឺ:

- ជាទូទៅ គម្រោងនានា ត្រូវតែបានអនុវត្ត នៅក្នុងអំឡុងពេលពីរឆ្នាំ ។
- ជាគោលការណ៍ គម្រោងនានាមិនត្រូវលើសពី ៥០០.០០០ ដុល្លារសហរដ្ឋអាមេរិក សម្រាប់គម្រោងកំណត់ណាមួយ និងតាមធម្មតា មានតម្លៃជាអប្បបរមា ៥០.០០០ ដុល្លារសហរដ្ឋអាមេរិក ។
- ពាក្យសុំជំនួយពីប្រទេសទាំងអស់ ក៏ដូចជាកិច្ចផ្តួចផ្តើមប្រចាំតំបន់ និងសកលលោក ត្រូវបានពិចារណា និង
- អាទិភាព នឹងត្រូវបានផ្តល់ជូនទៅអ្នកដាក់ពាក្យសុំជំនួយមកពីប្រទេស និងតំបន់ ដែលនៅទីនោះការលំបាកផ្នែកប្រជាធិបតេយ្យ មានលក្ខណៈកាន់តែសំខាន់ និងមាននៅគ្រប់ទីកន្លែង ដូចជា ប្រទេសដែលងើបផុតពីជម្លោះ ប្រទេសប្រជាធិបតេយ្យថ្មី និងដែលត្រូវបានពង្រឹងឡើងវិញ ប្រទេសទន់ខ្សោយ និងក្រីក្របំផុត និងប្រទេសដែលមានចំណូលជាតិទាប និងមធ្យម ។

មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ មានគោលបំណងគាំទ្រដល់គម្រោងនានា ដែលលើកកម្ពស់ប្រជាធិបតេយ្យ និងដែលទិន្នផលរបស់គម្រោងទាំងនោះនឹងពង្រឹង ឧទាហរណ៍ៈ ទំនាក់ទំនងរវាងសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាល ការដាក់បញ្ចូល និងការចូលរួមរបស់ផ្នែកទន់ខ្សោយខ្វះឥទ្ធិពលនៃសង្គម និងក្រុមងាយរងគ្រោះ ឬ ជំរុញឲ្យចម្រើនឡើងនូវសហប្រតិបត្តិការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

## *i* របៀបដាក់ពាក្យសុំទៅមូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ

អង្គការដែលមានបំណងចង់ដាក់ពាក្យសុំមូលនិធិជំនួយ របស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ គួរតែចូលមើលវិបសាយរបស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិនេះ ដែលនៅទីនោះ គេនឹងត្រូវបានជំរុញឲ្យបំពេញសំណើសុំតាមបណ្តាញអេឡិចត្រូនិច ដែលអាចត្រូវបានបំពេញជាភាសាអង់គ្លេស ឬ បារាំង ។ អង្គការមូលនិធិ នឹងមិនទទួលយកសំណើសុំ ដែលត្រូវបានដាក់ជូនពិនិត្យតាមអ៊ីម៉ែល ប៉ុស្តិ៍ប្រៃសណីយ៍ធម្មតា ទូរសារ ហុចផ្ទាល់ដៃ ឬ យានដឹកនាំសំបុត្រ ឬ បណ្តាញណាមួយផ្សេងទៀតទេ ។

## របៀបទាក់ទងនឹងមូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ

មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ (UNDEF)
**អង្គការសហប្រជាជាតិ**
1 UN Plaza, Room DC1-1330

ញូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរស័ព្ទ: +១ ៩១៧ ៣៦៧ ៤២ ១០ ឬ +១ ៩១៧ ៣៦៧ ៨០ ៦២
ទូរសារលេខ: +១ ២១២ ៩៦៣ ១៤ ៨៦
អ៊ីម៉ែល: **democracyfund@ohchr.org**

**សម្រាប់ព័ត៌មានបន្ថែម** **សូមចូលមើល**វិបសាយរបស់មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជា-ជាតិ ។

## ៦. មូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការនៃអង្គការសហប្រជាជាតិ

**មូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការនៃអង្គការសហប្រជាជាតិ** ត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមសេចក្ដីសម្រេចចិត្តលេខ 32/133 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការរៀបចំត្រៀមសម្រាប់ឆ្នាំអន្តរជាតិនៃជនពិការឆ្នាំ ១៩៨១ ។ តាំងតែពីពេលនោះមក មហាសន្និបាតអង្គការសហប្រជាជាតិ បានសម្រេចចិត្តថា អង្គការមូលនិធិ គួរតែបន្ត និងឥឡូវនេះ អង្គការមូលនិធិនេះ ផ្ដល់ជំនួយខ្នាតតូច ដើម្បីគាំទ្រដល់សកម្មភាពដែលចាត់ជាគោលបំណងនូវការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ដើម្បីចូលរួមនៅក្នុងការអនុវត្ត**អនុសញ្ញាស្ដីពីសិទ្ធិរបស់ជនពិការ** ។

អង្គការមូលនិធិ ផ្ដល់ជំនួយខ្នាតតូច ដើម្បីគាំទ្រដល់សកម្មភាពដែលមានមុខងារជាកាតាលីករ និងមានលក្ខណៈច្នៃបង្កើតថ្មី ដើម្បី:

- លើកកម្ពស់ការយល់ដឹងឲ្យកាន់តែច្រើនឡើងអំពីអនុសញ្ញា និងបញ្ហាពិការភាព និងគាំទ្រឲ្យមានការអនុវត្តអនុសញ្ញានេះ ។
- អនុញ្ញាតឲ្យមានការផ្លាស់ប្ដូរគ្នាទៅវិញនូវចំណេះដឹង និងបទពិសោធន៍ ក៏ដូចជា ការផ្សព្វផ្សាយអំពីគោលនយោបាយ និងការអនុវត្តបរិយាប័ន្ន និងដែលអាចប្រើប្រាស់បាន ។
- ជំរុញឲ្យមានការបញ្ជ្រាបភាពពិការទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ និង
- កសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការប្រកបរបរចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ជនពិការ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងដើម្បីអនុវត្តអនុសញ្ញានេះ (អ្នកពាក់ព័ន្ធអាចដាក់បញ្ចូលអង្គការរបស់ជនពិការ អង្គការសង្គមស៊ីវិលផ្សេងទៀត រដ្ឋាភិបាល អង្គការវិស័យឯកជន និងម្ចាស់ជំនួយអភិវឌ្ឍន៍អន្តរជាតិ) ។

មូលនិធិនេះ ត្រូវបានគ្រប់គ្រងដោយ**ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច** នៅឯទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិ នៅក្នុងទីក្រុង ញូវយ៉ក ។

## វិធីប្រើប្រាស់មូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការ នៃអង្គការសហប្រជាជាតិ

ចាប់តាំងតែពីពេលបង្កើតមូលនិធិស្ម័គ្រចិត្ត សម្រាប់ជនពិការនៃអង្គការសហប្រជាជាតិនេះនៅក្នុងឆ្នាំ ១៩៨១ មក អង្គការមូលនិធិ បានគាំទ្រដល់សកម្មភាពដែលមានគោលបំណងកសាងសមត្ថភាពជាតិ និងស្ថាប័ន ដើម្បីធ្វើឲ្យប្រសើរឡើងនូវការប្រកបរបរចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ជនពិការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ អង្គការមូលនិធិនេះ ក៏បានគាំទ្រដល់ការលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ ដូចជា សកម្មភាពបណ្តុះបណ្តាល ការគាំទ្រទំនាក់ទំនង និងព័ត៌មានសាធារណៈ ។ មូលនិធិជំនួយ ត្រូវបានរៀបចំឲ្យមានសម្រាប់ទាំងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ប៉ុន្តែមិនពង្រីកទៅដល់បុគ្គលទេ ។

សំណើសុំគម្រោង ត្រូវបានទទួលយកនៅក្នុងអំឡុងពេលមួយឆ្នាំពេញ ។ អង្គការសង្គមស៊ីវិលដែលមានបំណងចង់ដាក់ជូនពិនិត្យនូវសំណើសុំដំបូង ចាំបាច់ត្រូវរកឲ្យបានលិខិតឯកភាព/អវិរុទ្ធហេតុពីមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ មុននឹងដាក់ជូនពិនិត្យនូវសំណើសុំជំនួយទៅអង្គការមូលនិធិ ។ អង្គការសង្គមស៊ីវិលអាចមានបំណងចង់ពិគ្រោះយោបល់ជាមួយនឹងការិយាល័យនៅមូលដ្ឋានរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លើនីតិវិធីរកឲ្យបានលិខិតនេះ ។

### i រៀបដាក់ពាក្យសុំទៅមូលនិធិស្ម័គ្រចិត្តសម្រាប់ជនពិការនៃអង្គការសហប្រជាជាតិ

គំរូសំណើសុំគម្រោង ត្រូវបានរៀបចំឲ្យមានសម្រាប់ការប្រើប្រាស់ នៅពេលដាក់ជូនពិនិត្យនូវពាក្យសុំជំនួយសម្រាប់ជំនួយ ។ សំណើសុំគម្រោង នឹងត្រូវបានទទួលយកជាទម្រង់ផ្សេងទៀត ឲ្យតែព័ត៌មានចាំបាច់ទាំងអស់ ត្រូវបានដាក់បញ្ចូល ។សំណើសុំអាចត្រូវបានដាក់ជូនពិនិត្យជាភាសាអង់គ្លេស បារាំងឬ អេស្ប៉ាញ ។ គំរូសំណើសុំគម្រោង ត្រូវបានរៀបចំឲ្យមាននៅក្នុង**វិបសាយជំនួយនៃអង្គការសហប្រជាជាតិ** ។

សំណើសុំ គួរតែត្រូវបានផ្ញើចេញតាមអ៊ីម៉ែល ទូរសារ ឬ ប៉ុស្តិ៍ប្រៃសណីយ៍ (ឯកសារស្នើសុំពិនិត្យតាមអ៊ីម៉ែល ត្រូវបានពេញចិត្តជាង) ទៅកាន់:

**លេខាធិការដ្ឋានទទួលបន្ទុកអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ**
**ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច**
**អង្គការសហប្រជាជាតិ**
Two UN Plaza, Room DC2-1372
ញូវយ៉ក NY 10017
សហរដ្ឋអាមេរិក
ទូរសារលេខ: +១ ២១២ ៩៦៣ ០១ ១១
អ៊ីម៉ែល: **enable@ohchr.org**

សម្រាប់ព័ត៌មានបន្ថែមស្តីពីអង្គការមូលនិធិ អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ និងការងាររបស់អង្គការសហប្រជាជាតិទទួលបន្ទុកពិការភាព សូមចូលមើលវិបសាយជំនួយនៃអង្គការសហប្រជាជាតិ ។